Food and Agriculture Organization
of the United Nations

# ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម

## គម្រោងភាពជាដៃគូរវាងរដ្ឋ ឯកជន និងសហគមន៍ដើម្បីលើកកម្ពស់កសិកម្ម ភាតរបរិស្ថាន និងជីវភាពដែលធន់នឹងអាកាសធាតុរបស់សហគមន៍នៅភាគខាងជើងនៃបឹងទន្លេសាប (គម្រោង PEARL)



អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO)
ខែកញ្ញា ឆ្នាំ២០២២

## បញ្ជីមាតិកា

**បញ្ជីមាតិកា** ...... 2
**បញ្ជីតារាង** ...... 5
**បញ្ជីរូបភាព** ...... 6
**បញ្ជីអក្សរកាត់** ...... 7
**សេចក្តីសង្ខេបប្រតិបត្តិ** ...... 9
**១. សេចក្តីផ្តើម** ...... 19
**២. ការពិពណ៌នាអំពីគម្រោង** ...... 20
២.១ គោលបំណង និងលទ្ធផលរបស់គម្រោង ...... 21
២.២ ទីតាំងគម្រោង ...... 43
២.៣ ក្រុមអ្នកទទួលផលពីគម្រោង ...... 46
២.៤ ការរៀបចំការអនុវត្តគម្រោង ...... 48
**៣. លក្ខខណ្ឌមូលដ្ឋាននៃបរិស្ថាន និងសេដ្ឋកិច្ចសង្គម** ...... 53
៣.១ លក្ខខណ្ឌបរិស្ថាន ...... 53
៣.១.១ អាកាសធាតុ ...... 53
៣.១.២ ការប្រើប្រាស់ដី ...... 55
៣.១.៣ ជីវៈចម្រុះ បរិស្ថាន និងព្រៃឈើ ...... 55
៣.១.៤ ធនធានទឹក ...... 56
៣.២ លក្ខខណ្ឌសេដ្ឋកិច្ច-សង្គម ...... 57
៣.៣ ការផ្លាស់ប្តូររំពឹងទុកជាសក្តានុពលនាពេលអនាគតទទួលបានជាលទ្ធផលពីសកម្មភាពដែលបានគ្រោងទុក ...... 59
៣.៣.១ ផលប៉ះពាល់នៃការផ្លាស់ប្តូរក្នុងការរំពឹងទុករបស់គម្រោង PEARL ...... 60
៣.៣.២ ទ្រឹស្តីនៃការផ្លាស់ប្តូរ- របៀបដែលគម្រោងគាំទ្រការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ...... 61
**៤. ក្របខ័ណ្ឌច្បាប់ និងស្ថាប័ន** ...... 63

**៥. គោលនយោបាយការពារសុវត្ថិភាពជាធរមាន** ....... 67
៥.១ បទដ្ឋានបរិស្ថាន និងសង្គមរបស់អង្គការ FAO ....... 69
៥.២ ការចាត់ចំណាត់ថ្នាក់ហានិភ័យរបស់គម្រោង ....... 71
៥.៣ ការការពារសុវត្ថិភាពនៃមូលនិធិអាកាសធាតុបៃតង ....... 73
៥.៤ ការការពារបរិស្ថាន និងសង្គមជាធរមានរបស់អង្គការ FAO ....... 74
**៦. ការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម** ....... 81
៦.១ ជំហានទី ១៖ ការកំណត់និយមន័យនៃអនុសកម្មភាព ....... 82
៦.២ ជំហានទី ២៖ ការត្រួតពិនិត្យហានិភ័យបរិស្ថាន និងសង្គមនៃអនុសកម្មភាព ....... 82
៦.៣ ជំហានទី ៣៖ ផែនការគ្រប់គ្រងបរិស្ថាននិងសង្គម ការត្រួតពិនិត្យនិងការរាយការណ៍ ....... 84
៦.៤ វិធានការកាត់បន្ថយហានិភ័យបរិស្ថាន និងសង្គមដែលមានសក្ដានុពល ....... 85
**៧. ការប្រឹក្សាយោបល់ និងការចូលរួមរបស់ភាគីពាក់ព័ន្ធ** ....... 97
៧.១ ការកំណត់អត្តសញ្ញាណភាគីពាក់ព័ន្ធ ....... 97
៧.២ ទិដ្ឋភាពទូទៅនៃការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ និងការបញ្ចូលភាគីពាក់ព័ន្ធក្នុងការរៀបចំគម្រោង ....... 97
៧.៤ ការផ្សព្វផ្សាយព័ត៌មាន ....... 103
៧.៥ យន្តការដោះស្រាយបណ្ដឹងតវ៉ា ....... 104
៧.៥.១ យន្តការបណ្ដឹងតវ៉ារបស់អង្គការ FAO ....... 104
៧.៥.២ យន្តការបណ្ដឹងតវ៉ានៅកម្រិតគម្រោង ....... 105
**៨. ជនជាតិដើមភាគតិច និងក្របខ័ណ្ឌរៀបចំផែនការបរិយាប័ន្នសង្គម** ....... 113
៨.១ ជនជាតិដើមភាគតិច និងក្របខ័ណ្ឌរៀបចំផែនការបរិយាប័ន្នសង្គម ....... 113
៨.១.១ ព័ត៌មានជាមូលដ្ឋាន ....... 113
៨.១.២ លទ្ធផលរកឃើញសំខាន់ៗ និងការវិភាគផលប៉ះពាល់ ហានិភ័យ និងឱកាស ....... 118
៨.២ ការវាយតម្លៃ និងសកម្មភាពយេនឌ័រ ....... 124
**៩. ក្របខ័ណ្ឌការគ្រប់គ្រងជីវៈចម្រុះ** ....... 132
៩.១ សេចក្ដីផ្ដើម ....... 132
៩.២ គោលបំណង និងវិធីសាស្ត្រអភិរក្សជីវៈចម្រុះ ....... 133

៩.៣ ស្ថានភាពជីវៈចម្រុះ ...... 135
៩.៤ សហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើគោលដៅ ...... 137
៩.៤.១ ទិដ្ឋភាពរួម ...... 137
៩.៤.២ សហគន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើសមស្របសម្រាប់គំនិតផ្តួចផ្តើម/កម្មវិធីក្នុងការស្តារការស្តារដីព្រៃឈើឡើងវិញ ...... 138
**ឧបសម្ព័ន្ធ** ...... 154
ឧបសម្ព័ន្ធទី ១៖ ផែនការការងារ និងថវិកាក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម(ESMF) ...... 155
ឧបសម្ព័ន្ធទី ២៖ បញ្ជីសកម្មភាពមិនគាំទ្រដោយគម្រោង ...... 173
ឧបសម្ព័ន្ធទី ៣៖ បញ្ជីផ្ទៀងផ្ទាត់លើវាយតម្លៃផ្នែកបរិស្ថាន និងសង្គមរបស់អង្គការ FAO ...... 174
ឧបសម្ព័ន្ធទី ៤៖ យន្តការពិនិត្យឡើងវិញលើបណ្តឹងតវ៉ារបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិប្រចាំនៅកម្ពុជា ...... 213

# បញ្ជីតារាង

តារាងទី 1. វិធានការដាក់លាក់សម្រាប់មុខដំណាំដើម្បីកសាងភាពធន់នឹងអាកាសធាតុ និងផ្តល់តម្លៃខ្ពស់ ......... 34

តារាងទី 2. ទិដ្ឋភាពទូទៅនៃដំណាំសំខាន់ៗនៅក្នុងតំបន់ភាគខាងជើងនៃបឹងទន្លេសាប ................................ 44

តារាងទី 3. ទិដ្ឋភាពទូទៅនៃបទដ្ឋានបរិស្ថាន និងសង្គមរបស់អង្គការ FAO ................................................ 69

តារាងទី 4. ការបន្ស៊ីបទដ្ឋានអនុវត្តរបស់ IFC និងបទដ្ឋានបរិស្ថាន និងសង្គមរបស់អង្គការ FAO ..................... 73

តារាងទី 5. ការការពារសុវត្ថិភាពរបស់អង្គការ FAO សម្រាប់គម្រោង PEARL ............................................ 74

តារាងទី 6. ផលប៉ះពាល់អវិជ្ជមានជាសក្តានុពល និងវិធានការកាត់បន្ថយដែលបានស្នើឡើងសម្រាប់លទ្ធផលទី ១៖ សមត្ថភាពរបស់កសិករត្រូវបានពង្រឹងដើម្បីគ្រប់គ្រងផលប៉ះពាល់អាកាសធាតុ និងហានិភ័យពាក់ព័ន្ធ ............. 86

តារាងទី 7. ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន និងវិធានការដែលបានស្នើឡើងសម្រាប់លទ្ធផលទី២៖ សមត្ថភាពបន្សាំរបស់កសិករខ្នាតតូច និងតួអង្គខ្សែច្រវ៉ាក់តម្លៃ ផ្សេងៗទៀតនៅមូលដ្ឋាន ជាពិសេសកសិករ និងតួអង្គខ្សែច្រវ៉ាក់តម្លៃជាស្ត្រី ត្រូវបានលើកកម្ពស់ តាមរយៈកសិកម្មនិរន្តរភាព ធន់នឹងអាកាសធាតុ និងមានគុណតម្លៃខ្ពស់ ........................................................................................................................ 86

តារាងទី 8. ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន និងវិធានការកាត់បន្ថយដែលបានស្នើឡើងសម្រាប់លទ្ធផលទី៣ ........................................................................................................................ 93

តារាងទី 9. យន្តការបណ្តឹងតវ៉ា ដំណោះស្រាយបណ្តឹង និងការតវ៉ារបស់កម្ពុជា .........................................108

តារាងទី 10. ទិដ្ឋភាពរួមនៃនីតិវិធីពិនិត្យបណ្តឹងតវ៉ា..................................................................................... 111

តារាងទី 11. ចំនួនជនជាតិដើមភាគតិចក្នុងខេត្តចំនួនបួន .........................................................................118

តារាងទី 12. សកម្មភាពផ្តោតការយកចិត្តទុកដាក់លើយេនឌ័រ .....................................................................129

តារាងទី 13. ទិដ្ឋភាពរួមនៃផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានលើជីវៈចម្រុះបណ្តាលមកពីសកម្មភាពគម្រោង ........................................................................................................................134

តារាងទី 14. សេចក្តីសង្ខេបពីសហគមន៍តំបន់ការពារធម្មជាតិ និងសហគន៍ព្រៃឈើដែលត្រូវបានជ្រើសរើសសម្រាប់គម្រោង PEARL......................................................................................................141

# បញ្ជីរូបភាព


រូបភាពទី 1. ទីតាំងតំបន់ភាគខាងជើងនៃបឹងទន្លេសាបក្នុងប្រទេសកម្ពុជា ................................................ 21

រូបភាពទី 2. ដំណាក់កាលនៃយន្តការកសាងភាពធន់ក្នុងវិស័យកសិកម្មដែលដឹកនាំដោយកសិករ (FARM) .... 32

រូបភាពទី 3. ការរៀបចំការអនុវត្តគម្រោង ........................................................................................ 50

រូបភាពទី 4. បរិមាណទឹកភ្លៀងជាមធ្យមសរុប (មម) ក្នុងរដូវវស្សាខែឧសភា ដល់ខែតុលា (ឆ្វេង) និងចាប់ពីខែមករា ដល់ខែមេសា (ស្តាំ) ជាមធ្យមក្នុងរយៈពេល ១៩៨៩-២០១៦ (ពីសំណុំទិន្នន័យវិភាគឡើងវិញ W5E5 (FAO)) ................................................................................................................................. 53

រូបភាពទី 5. សីតុណ្ហភាពជាមធ្យមអតិបរមា (ឆ្វេង) និងសីតុណ្ហភាពអប្បបរមា (ស្តាំ) ក្នុងរដូវវស្សា ខែឧសភា ដល់ខែតុលា ក្នុងរយៈពេល ១៩៨៧-២០១៦ ពីសំណុំទិន្នន័យ W5E5 (ការវិភាគរបស់អង្គការ FAO) ................. 54

រូបភាពទី 6. ទ្រឹស្តីនៃការផ្លាស់ប្តូររបស់គម្រោង PEARL ........................................................................ 62

រូបភាពទី 7. ទិដ្ឋភាពទូទៅនៃវិធីសាស្ត្រគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម (E&S) របស់អង្គការ FAO........81

រូបភាពទី 9. ផែនទីសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើត្រូវបានជ្រើសរើសជាតំបន់គោលដៅគម្រោង PEARL.................................................................................................................... 152

# បញ្ជីអក្សរកាត់

| | |
|---|---|
| CBD | អនុសញ្ញាស្តីពីជីវៈចម្រុះ |
| CBO | អង្គការសហគមន៍ |
| CEDAW | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ |
| CF | សហគមន៍ព្រៃឈើ |
| CPA | សហគមន៍តំបន់ការពារធម្មជាតិ |
| DRR | ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ |
| ESA | ការវិភាគបរិស្ថាន និងសង្គម |
| ESCP | ផែនការស្តីពីការប្តេជ្ញាចិត្តផ្នែក  បរិស្ថាន និងសង្គម |
| ESM | ការគ្រប់គ្រងបរិស្ថាន និងសង្គម |
| ESMP | ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម |
| ESMF | ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម |
| ESS | បទដ្ឋានបរិស្ថាន និងសង្គម |
| EWS | ប្រព័ន្ធប្រកាសឱ្យដឹងមុន |
| FAO | អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ |
| FARM | យន្តការកសាងភាពធន់ក្នុងវិស័យកសិកម្មដែលដឹកនាំដោយកសិករ |
| FPIC | ការយល់ព្រមជាមុន ដោយសេរីដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់ |
| GBV | អំពើហិង្សាទាក់ទងនឹងយេនឌ័រ |
| GAP | ផែនការសកម្មភាពយេនឌ័រ |
| GCF | មូលនិធិអាកាសធាតុបៃតង |
| GDP | ផលិតផលក្នុងស្រុកសរុប |
| GESI | សមភាពយេនឌ័រ និងបរិយាប័ន្នសង្គម |
| HDI | សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស |
| IFC | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| ILO | អង្គការពលកម្មអន្តរជាតិ |
| IP | ជនជាតិដើមភាគតិច |
| LAMS | ប្រព័ន្ធត្រួតពិនិត្យកសិបរិស្ថានកម្រិតទេសភាព |
| LDC | ប្រទេសមានការអភិវឌ្ឍតិចតួច |
| LRP | ធនធានមនុស្សក្នុងស្រុក |
| M&E | ត្រួតពិនិត្យ និងវាយតម្លៃ |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MoE | ក្រសួងបរិស្ថាន |
| MIS | ប្រព័ន្ធព័ត៌មានគ្រប់គ្រង |
| NCCD | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NDA | អាជ្ញាធរទទួលបន្ទុកថ្នាក់ជាតិ |

| | |
|---|---|
| NDC | ការរួមចំណែកថ្នាក់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ |
| NGO | អង្គការក្រៅរដ្ឋាភិបាល |
| NPD | នាយកគម្រោងថ្នាក់ជាតិ |
| NTFP | អនុផលព្រៃឈើ |
| OHS | សុខភាព និងសុវត្ថិភាពការងារ |
| PCU | អង្គភាពសម្របសម្រួលគម្រោង |
| PMC | គណៈកម្មាធិការគ្រប់គ្រងគម្រោង |
| PMSU | អង្គភាពគាំទ្រការគ្រប់គ្រងគម្រោង |
| PS | បទដ្ឋានអនុវត្ត |
| PSC | គណៈកម្មាធិការដឹកនាំគម្រោង |
| NRM | ការគ្រប់គ្រងធនធានធម្មជាតិ |
| SDG | គោលដៅអភិវឌ្ឍដោយចីរភាព |
| SEAH | ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ |
| SME | សហគ្រាសខ្នាតតូច និងមធ្យម |
| SNRM | ការគ្រប់គ្រងធនធានធម្មជាតិដោយចីរភាព |
| SOP | នីតិវិធីប្រតិបត្តិស្តង់ដារ |
| TCM | កិច្ចប្រជុំគណៈកម្មាធិការបច្ចេកទេស |
| UNCCD | អនុសញ្ញាសហប្រជាជាតិប្រយុទ្ធប្រឆាំងនឹងរហោស្ថានកម្ម |
| UNFCC | អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |

## សេចក្តីសង្ខេបប្រតិបត្តិ

### ទិដ្ឋភាពរួម

រាជរដ្ឋាភិបាលកម្ពុជា ដោយសហការជាមួយអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (អង្គការ FAO) បានរៀបចំបង្កើតគម្រោងមានឈ្មោះថា *"គម្រោងភាពជាដៃគូរវាងរដ្ឋ ឯកជន និងសហគមន៍ដើម្បីលើកកម្ពស់កសិកម្មភាតបរិស្ថាន និងជីវភាពដែលធន់នឹងអាកាសធាតុរបស់សហគមន៍នៅភាគខាងជើងនៃបឹងទន្លេសាប (គម្រោង PEARL)"* ដើម្បីស្នើការគាំទ្រថវិកាពីមូលនិធិអាកាសធាតុបៃតង (GCF)។ គោលបំណងរួមនៃគម្រោងនេះគឺដើម្បី *"លើកកម្ពស់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុរបស់កសិករខ្នាតតូច និងសហគមន៍មូលដ្ឋាននៅតំបន់ភាគខាងជើងនៃបឹងទន្លេសាប (NTSB) តាមរយៈការបង្កើនលទ្ធភាពទទួលបានទីផ្សារផលិតផលដែលមានតម្លៃល្អដែលតម្រូវការកំពុងកើនឡើង ហើយប្រើប្រាស់យន្តការទីផ្សារនេះដើម្បីលើកទឹកចិត្តដល់ការផ្លាស់ប្តូរទៅរកការអនុវត្តបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ជាពិសេសតាមរយៈភាពជាដៃគូដ៏មានប្រសិទ្ធភាពរវាងរដ្ឋ ឯកជន និងសហគមន៍"*។ ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) ត្រូវបានចងក្រងយ៉ាងល្អិតល្អន់ ដើម្បីណែនាំដល់ការកំណត់អត្តសញ្ញាណ និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមានជាសក្តានុពលលើបរិស្ថាន និងសង្គមពីគម្រោងដែលបានស្នើសុំ។ ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម ត្រូវបានរៀបចំបង្កើតឡើង ស្របតាមគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងបរិស្ថាន និងសង្គមរបស់អង្គការ FAO ក៏ដូចជាការពិចារណាបន្ថែមពីភាពស៊ីសង្វាក់គ្នារវាងបទដ្ឋានបរិស្ថាន និងសង្គម (ESS) របស់អង្គការ FAO និងបទដ្ឋានការពារបរិស្ថាន និងសង្គមបណ្តោះអាសន្នរបស់ GCF (ដូចជាបទដ្ឋានប្រតិបត្តិរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC))។

### ឥទ្ធិពលវិជ្ជមាន អ្នកទទួលផលប្រយោជន៍ និងការស៊ីសង្វាក់គ្នាទៅនឹងគោលនយោបាយរបស់ប្រទេសកម្ពុជា

គម្រោង PEARL នឹងផ្តល់លទ្ធផលដែលមានទំនាក់ទំនងគ្នាចំនួនបី ដើម្បីជំនះឧបសគ្គលើផលិតកម្ម និង សកម្មភាពកែច្នៃ និងបច្ចេកវិទ្យានិរន្តរភាពដោយផ្អែកលើព័ត៌មានទីផ្សារគ្រប់គ្រាន់ និងការបន្សាំនឹងអាកាសធាតុ៖

១. សមត្ថភាពរបស់កសិករត្រូវបានលើកកម្ពស់ដើម្បីគ្រប់គ្រងផលប៉ះពាល់អាកាសធាតុ និងហានិភ័យពាក់ព័ន្ធ។

២. សមត្ថភាពបន្សាំរបស់កសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃផ្សេងៗទៀតនៅមូលដ្ឋាន ជាពិសេសកសិករ និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃជាស្ត្រី ត្រូវបានលើកកម្ពស់ តាមរយៈកសិកម្មនិរន្តរភាពធន់នឹងអាកាសធាតុ និងមានគុណតម្លៃខ្ពស់ និង

៣. លក្ខខណ្ឌអំណោយផលសម្រាប់កសិកម្មធន់នឹងអាកាសធាតុត្រូវបានធានា តាមរយៈក្របខណ្ឌគោលនយោបាយ ច្បាប់ និងស្ថាប័នដែលមានភាពស៊ីសង្វាក់គ្នា និងរឹងមាំ។

គម្រោងនេះនឹងផ្តល់ផលប្រយោជន៍ផ្ទាល់ដល់កសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃផ្សេងៗទៀតនៅមូលដ្ឋានយ៉ាងតិច ១៣៥.០០០ នាក់ និងកសិករប្រមាណជា ៤៥០.០០០ នាក់ ដើម្បីពង្រឹងលទ្ធភាពចូលទីផ្សារ ហើយជាលទ្ធផល លើកកម្ពស់ភាពស៊ាំរបស់ខ្លួនទៅនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ ក្រៅពីនេះ គម្រោងនឹងផ្តល់ផលប្រយោជន៍ដោយប្រយោលដល់ប្រជាជនជាង ១ លាននាក់ ដែលកំពុងរស់នៅក្នុងតំបន់ទទួលបានអន្តរាគមន៍ពីគម្រោង PEARL។ គម្រោងនេះត្រូវបានរៀបចំឡើង ស្របទៅនឹងផែនការអភិវឌ្ឍថ្នាក់ជាតិ គោលនយោបាយស្តីពីការប្រែប្រួលអាកាសធាតុ និងយុទ្ធសាស្ត្រអន្តរវិស័យសំខាន់ៗ ព្រមទាំងការប្តេជ្ញាចិត្តរបស់កម្ពុជាលើឆាកអន្តរជាតិ

ក្នុងនោះរួមទាំងការរួមចំណែកលើការប្តេជ្ញាចិត្តរបស់ខ្លួនសម្រាប់អន្តជាតិ (NDC) ចំពោះអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)។

## វិធានការកាត់បន្ថយហានិភ័យបរិស្ថាន និងសង្គម

ដោយផ្អែកលើលទ្ធផលនៃការសិក្សាវាយតម្លៃសម្រាប់រៀបចំ ក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម(ESMF) នេះ គម្រោងដែលបានស្នើសុំនេះបានកំណត់កម្រិតនៃហានិភ័យប្រភេទ ខ ដោយកម្រិតនេះបង្ហាញថា គម្រោងនេះមានសកម្មភាពដែលមានផលប៉ះពាល់ និង ហានិភ័យអវិជ្ជមានតិចតួចជាសក្តានុពលលើបរិស្ថាន និង/ឬសង្គម មានជាលក្ខណៈដោយឡែកៗ ឬជាលក្ខណៈរួមបញ្ចូលគ្នា មានចំនួនតូច ជាទូទៅនៅតាមទីតាំងជាក់លាក់ ភាគច្រើនអាចកែប្រែឡើងវិញបាន និងងាយស្រួលដោះស្រាយ តាមរយៈវិធានការកាត់បន្ថយផ្សេងៗ។ សេចក្តីសង្ខេបខាងក្រោមនេះឆ្លុះបញ្ចាំងពីហានិភ័យគួរឱ្យកត់សម្គាល់មួយចំនួនដែលអាចមានផលប៉ះពាល់អវិជ្ជមានលើសក្តានុពលបរិស្ថាន និងសង្គមផ្សេងៗ ដែលនឹងត្រូវមានផែនការកាត់បន្ថយជាក់លាក់។

- ហានិភ័យកម្រិតខ្ពស់ដែលជាប់ពាក់ព័ន្ធនឹងសកម្មភាពការងាររបស់គម្រោងនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ (តិចជាង ១០.000 ហិកតា) និងសហគមន៍ព្រៃឈើ (CFA) មានទីតាំងនៅក្នុងឧទ្យានជាតិ និងដែនជម្រកសត្វព្រៃ។
- ហានិភ័យកម្រិតមធ្យមដែលមានជាប់ពាក់ព័ន្ធនឹងការដឹកជញ្ជូន និងការផ្តល់គ្រាប់ពូជ និងសម្ភារដាំដុះសម្រាប់ទាំងការដាំដុះលក្ខណៈកសិកម្ម និងការដាំដុះព្រៃឈើ ព្រមទាំងការបង្កើតព្រៃដាំ ដោយផ្អែកលើការគាំទ្រដល់ការផ្គត់ផ្គង់សន្និធិ/ស្តុកសម្រាប់ការដាំដែលមានការកែលម្អដល់កសិកម្ម រួមទាំងការងារស្តារព្រៃឡើងវិញក្នុងសហគមន៍តំបន់ការពារធម្មជាតិ (តិចជាង ១០.000 ហិកតា) និងសហគមន៍ព្រៃឈើ។
- ហានិភ័យផ្សេងៗទៀតត្រូវបានកំណត់ថាជាហានិភ័យទាប ដោយសារ គម្រោងនេះនឹងខិតខំប្រឹងប្រែងកែលម្អសកម្មភាពនានាទាក់ទងទៅនឹងវិស័យកសិកម្ម និងការគ្រប់គ្រងដីនៅទូទាំងតំបន់ទេសភាពជាគោលដៅ តាមរយៈការអនុវត្តសកម្មភាពដែលមានការកែលម្អ និងការផ្តល់ការគាំទ្រ និងបរិយាកាសអំណោយផលដែលបានកែលម្អឱ្យកាន់តែប្រសើរឡើង ហើយជាលទ្ធផល ការខិតខំប្រឹងប្រែងទាំងនេះនឹងជួយកាត់បន្ថយហានិភ័យបរិស្ថាន និងសង្គមឱ្យនៅក្រោមកម្រិតអនុវត្តសកម្មភាពតាមធម្មតា នៅកន្លែងណាដែលមានការកំណត់ឃើញពីកត្តាហានិភ័យ។

ព័ត៌មានបន្ថែមអំពីចំណុចហានិភ័យដែលបានកំណត់ និងវាយតម្លៃ ព្រមទាំងការឆ្លើយតប និងវិធានការកាត់បន្ថយហានិភ័យត្រូវបានរៀបរាប់នៅក្នុងតារាងខាងក្រោម ដោយផ្អែកលើ ESS របស់អង្គការ FAO ហើយក្នុងពេលជាមួយគ្នានេះ ផ្សារភ្ជាប់ទៅនឹងបទដ្ឋានអនុវត្តរបស់ IFC ដែលបានអនុម័តឱ្យប្រើប្រាស់ជាបណ្តោះអាសន្នដោយ GCF។

| វិធានការការពារបរិស្ថាន និងសង្គម អង្គការ FAO | ការការពារដែលត្រូវអនុវត្ត? | ដំណោះស្រាយ និងសកម្មភាពកាត់បន្ថយ |
|---|---|---|
| ESMG-ការពិចារណាទូទៅ | មាន | |
| FAO ESS១៖ ការគ្រប់គ្រងធនធានធម្មជាតិ<br><br>IFC PS ១. ការវាយតម្លៃ និងការគ្រប់គ្រងផលប៉ះពាល់ និងហានិភ័យបរិស្ថាន និងសង្គម | គ្មាន | គម្រោងនេះលើកកម្ពស់ការគ្រប់គ្រងដីដោយចីរភាព ដើម្បីទប់ស្កាត់ ឬកាត់បន្ថយការរេចរឹលដីតាមរយៈការគ្រប់គ្រងការហូរច្រោះដី ការគ្រប់គ្រងសារធាតុចិញ្ចឹមចម្រុះ ការគ្រប់គ្រង និងការស្តារឡើងវិញនូវធនធានដី ទឹក និងជីវៈចម្រុះ ព្រមទាំងការថែរក្សាសេវាកម្មប្រព័ន្ធអេកូឡូស៊ី ដោយធ្វើការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយអ្នកប្រើប្រាស់ដីនៅមូលដ្ឋាន។<br><br>គម្រោងនេះក៏នឹងជួយគាំទ្រដល់ការគ្រប់គ្រងព័ត៌មាន និងលទ្ធភាពក្នុងការទទួលបានហិរញ្ញវត្ថុ ដើម្បីគាំទ្របច្ចេកវិទ្យាប្រសើរជាងមុនក្នុងការលើកកម្ពស់ប្រសិទ្ធភាព និងកាត់បន្ថយផលប៉ះពាល់នៃការបញ្ចេញបញ្ចូលទឹក (រួមមានប្រព័ន្ធធារាសាស្ត្រដើរដោយថាមពលព្រះអាទិត្យ និងប្រព័ន្ធធារាសាស្ត្រវៃឆ្លាត (ឌ. ប្រព័ន្ធស្រោចស្រពដំណក់ទឹក ស្រះក៏ដូចជាប្រព័ន្ធចិញ្ចឹមត្រីក្នុងស្រែ)និងប្រព័ន្ធគ្រប់គ្រងទឹកនៅក្នុងតំបន់ផលិតកម្ម (ដោយប្រព័ន្ធទាំងអស់ ប្រើប្រាស់ទំនប់ទឹកតិចជាង ៥ ម៉ែត្រ និងមិនកំណត់ទិសដៅស្រោចស្រពលើសពី ២០ ហិកតា)។ អនុសកម្មភាពទាំងអស់ដែលបានលើកឡើងនឹងរួមបញ្ចូលទៅក្នុងសកម្មភាពប្រព័ន្ធធារាសាស្ត្រជាក់លាក់ផង នឹងត្រូវឆ្លងកាត់ការត្រួតពិនិត្យហានិភ័យមុននឹងអនុវត្តផងដែរ។<br><br>គម្រោងនេះនឹងលើកកម្ពស់ការបញ្ជាក់ឱ្យកាន់តែច្បាស់អំពីសិទ្ធិអាស្រ័យផល និងសិទ្ធិកាន់កាប់របស់កសិករ និងគ្រួសារ ដើម្បីកាត់បន្ថយហានិភ័យនៃការវិនិយោគក្នុងការជ្រើសរើសអនុវត្តបច្ចេកវិទ្យា និងការអនុវត្តធន់នឹងអាកាសធាតុ និងប្រកបដោយនិរន្តរភាព។ គម្រោងនេះនឹងមិនបណ្តាលឱ្យមានការផ្លាស់ប្តូរអវិជ្ជមានលើសិទ្ធិកាន់កាប់ស្របច្បាប់ដែលមានស្រាប់នោះទេដោយផ្តោតលើសមានគមកសិកម្មក្នុងស្រុក សហគមន៍តំបន់ការពារធម្មជាតិ និងក្រុមគ្រប់គ្រងព្រៃឈើដែលត្រូវបានកំណត់ជាសិទ្ធិអ្នកប្រើប្រាស់រួចហើយ ប៉ុន្តែអាចស្នើសុំការគាំទ្រឡើងវិញក្នុងការពង្រឹងក្នុងការចងក្រងឯកសារសម្រាប់សិទ្ធិទាំងនេះ។ សកម្មភាពណាមួយដើម្បីកែប្រែ ឬផ្លាស់ប្តូរសិទ្ធិនឹងត្រូវត្រួតពិនិត្យវាយតម្លៃពេញលេញ និងផែនការគ្រប់គ្រង។ |

| | | |
|---|---|---|
| | | គម្រោងនេះក៏នឹងធ្វើការសំដៅពង្រឹងសមត្ថភាពបន្សាំ និងភាពធន់នៃសហគមន៍គោលដៅ តាមរយៈព័ត៌មានដែលមានភាពល្អប្រសើរស្តីពីផលប៉ះពាល់អាកាសធាតុ និងព្រឹត្តិការណ៍អាកាសធាតុនានា ព្រមទាំងជំនាញ និងសកម្មភាពកសិកម្មដែលមានភាពប្រសើរឡើង ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាស។ តាមរយៈការគាំទ្រសកម្មភាពប្រើប្រាស់ដីដែលមានកែលម្អ ការដាំដុះ និងការដាំស្តារព្រៃឡើងវិញ គម្រោងនេះក៏នឹងផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើការលើកកម្ពស់ការស្តុកទុកកាបូន និងការកាត់បន្ថយការបំភាយឧស្ម័នផងដែរ។<br><br>បញ្ជីនៅក្នុងឧបសម្ព័ន្ធទី៦ ជានាបន្ថែមទៀតថា គម្រោងនេះនឹងមិនផ្តល់ហិរញ្ញវត្ថុដល់សកម្មភាពដែលបានចាត់ទុកថាមាន "ហានិភ័យខ្ពស់" ទេ។ |
| FAO ESS២៖ ជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងជម្រកធម្មជាតិ<br>IFC PS ៦. ការអភិរក្សជីវៈចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិរស់ដោយចីរភាព | មាន | គម្រោងនេះនឹងសហការមួយសហគមន៍តំបន់ការពារធម្មជាតិចំនួន ១៤ សហគមន៍ ដោយសហគមន៍ចំនួន ៣ ក្នុងចំណោមសហគមន៍ទាំង ១៤ ស្ថិតនៅក្នុងឧទ្យានជាតិ សហគមន៍ចំនួន៥ នៅក្នុងដែនជម្រកសត្វព្រៃ និងសហគមន៍ចំនួន២ទៀត ស្ថិតនៅប្រករបៀងអភិរក្សជីវៈចម្រុះភាគខាងជើង។ ខណៈពេលសកម្មភាពនានានៅក្នុងតំបន់ការពារធម្មជាតិត្រូវបានចាត់ទុកថាមានហានិភ័យខ្ពស់នោះ កត្តាកាត់បន្ថយមួយចំនួនដែលមានស្រាប់អាចជួយកាត់បន្ថយហានិភ័យនៃការអនុវត្តនៅក្នុងតំបន់ទាំងនេះ។ សកម្មភាពទាំងនោះមានដូចជា៖<br>• ប្រព័ន្ធផលិតកម្មកសិកម្មនៅក្នុងតំបន់ការពារធម្មជាតិនៅកម្ពុជាបានស្ថិតក្នុងតំបន់ការពារធម្មជាតិ មុនពេលបង្កើតតំបន់ការពារធម្មជាតិ និងគម្រោង ហើយត្រូវបានអនុញ្ញាតឱ្យបន្តរស់នៅ តែមិនត្រូវបានអនុញ្ញាតឱ្យពង្រីកដី ស្របតាមច្បាប់កម្ពុជា។<br>• សកម្មភាពដែលបានស្នើឡើងផ្តោតការយកចិត្តទុកដាក់លើការលើកកម្ពស់និរន្តរភាពនៃប្រព័ន្ធផលិតកម្មកសិកម្ម ហើយជាលទ្ធផលគាំទ្រដល់ការកសាងសមត្ថភាព និងការគាំទ្រដល់ការកាត់បន្ថយផលប៉ះពាល់ទៅលើកសិកម្មនៅក្នុងតំបន់ទាំងនេះ និងការស្តារឡើងវិញនូវតំបន់រេចរឹល (ដោយប្រើប្រាស់ប្រភេទរុក្ខជាតិមានស្រាប់នៅតំបន់នោះ និងប្រភេទក្នុងស្រុក) នៃតំបន់អភិរក្សដែលពីមុនបានរងផលប៉ះពាល់ដោយសារកសិកម្មពនេរចរ និង/ឬការកាប់ឈើ។<br>• ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP) ដែលគ្រប់ជ្រុងជ្រោយនឹងត្រូវបានរៀបចំសម្រាប់តំបន់គោលដៅ នៅពេលដែលទីតាំងជាក់លាក់ និងសកម្មភាពគាំទ្រត្រូវបានព្រមព្រៀងគ្នាក្នុងដំណាក់កាលអនុវត្ត ដោយវាត្រូវបានប្រើដើម្បីធ្វើបច្ចុប្បន្ន |

| | | |
|---|---|---|
| | | ភាព និងពង្រឹងការឆ្លើយតបទៅនឹងការគ្រប់គ្រងដែលបានស្នើឡើង |
| FAO ESS ៣៖ ធនធានពន្ធុរុក្ខជាតិសម្រាប់អាហារ និងកសិកម្ម និង IFC PS ៦. ការអភិរក្សជីវៈចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិរស់ដោយចីរភាព | មាន | គម្រោងនេះនឹងមិនណែនាំដំណាំ និងពូជផ្សេងៗ ដែលពីមុនមិនបានដាំដុះក្នុងតំបន់គម្រោង ឬតំបន់ស្រដៀងគ្នាក្នុងប្រទេសកម្ពុជាឡើយ។ គម្រោងនេះនឹងគាំទ្រដល់ការស្តារឡើងវិញនូវសហគមន៍តំបន់ការពារ និងសហគមន៍ព្រៃឈើ ដោយផ្តោតលើការដាំដុះពូជដើម ក៏ដូចជា រុក្ខកម្មប្រកបដោយនិរន្តរភាពខ្នាតតូច (ឧ. ឈើហូបផ្លែ និងប្រព័ន្ធសួនច្បារតាមផ្ទះ) ដើម្បីបំពេញតម្រូវការគ្រួសារដែលកំពុងកើនឡើងសម្រាប់ប្រើប្រាស់ជា អុស និងផលិតផលធ្វើពីឈើ។ គម្រោងនេះនឹងអនុម័ត និងអនុវត្តតាមយ៉ាងជិតដល់នូវក្របខ័ណ្ឌជាតិ REDD+ និងច្បាប់ជាតិពាក់ព័ន្ធផ្សេងទៀត រួមទាំងគោលការណ៍ណែនាំ របស់សហគមន៍តំបន់ការពារ និងសហគមន៍ព្រៃឈើ ដើម្បីកាត់បន្ថយហានិភ័យសង្គម និងបរិស្ថានតាមរយៈសកម្មភាព ស្តារព្រៃឈើ។ |
| FAO ESS ៤៖ សត្វ-បសុសត្វ និង ទឹក - ធនធានពន្ធុសម្រាប់អាហារ និងកសិកម្ម<br>និង<br>IFC PS ៦. ការអភិរក្សជីវៈចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិរស់ដោយចីរភាព | គ្មាន | គម្រោងនេះនឹងមិនណែនាំប្រភេទពូជដែលមិនមែនជាប្រភេទដើម ឬមិនមែនប្រភេទក្នុងស្រុកដែលអាចសម្របខ្លួនទៅតាមតំបន់ ប្រភេទពូជហៃព្រុន ឬប្រភេទផ្សេងទៀតនោះទេ។ ការគាំទ្ររបស់គម្រោងក្នុងការធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ស្រះត្រីដែលភ្ជាប់ទៅនឹងប្រព័ន្ធធារាសាស្ត្រស្រូវក៏នឹងជួយលើកកម្ពស់ប្រព័ន្ធគ្រប់គ្រងទឹក និងកាត់បន្ថយផលប៉ះពាល់បរិស្ថាន ខណៈពេលដែលរួមចំណែកដល់សន្តិសុខស្បៀងក្នុងតំបន់។ |
| ESS ៥៖ ការគ្រប់គ្រងប្រភេទសត្វចង្រៃ និងថ្នាំសម្លាប់សត្វចង្រៃ និង PS ៣. ប្រសិទ្ធភាពធនធាន និងការការពារការបំពុល | គ្មាន | គម្រោងនេះនឹងលើកកម្ពស់ ការសម្គាល់អត្តសញ្ញាណភូមិសាស្ត្រ ទំនិញ (GI), ការអនុវត្តកសិកម្មល្អរបស់កម្ពុជា (CamGAP), ការវិភាគកម្រិតគ្រោះថ្នាក់ និងចំណុចត្រួតពិនិត្យសំខាន់ៗ (HACCP) និងការបង្កើត និងដំណើរការដែលអនុលោមតាមវិញ្ញាបនប័ត្រសរីរាង្គ និងវិធានការចម្រុះគ្រប់គ្រងដំណាំ (IPM)។ ដូចនេះ គម្រោងនេះនឹងបង្កើតគោលការណ៍ណែនាំ និងការគាំទ្រដល់កសិករដើម្បីកាត់បន្ថយ និងបញ្ឈាក់ពីការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត ដោយផ្អែកលើការអនុវត្តជោគជ័យពីអន្តរជាតិ និងក្នុងស្រុក។ គម្រោងនេះនឹងមិនមានលទ្ធផលក្នុងការធ្វើលទ្ធកម្ម ឬការផ្គត់ផ្គង់ដោយផ្ទាល់នូវថ្នាំសម្លាប់សត្វល្អិត ឬថ្នាំកសិកម្មឡើយ។ |

| | | |
|---|---|---|
| FAO ESS ៦៖ ការតាំងទីលំនៅថ្មី និងការផ្លាស់ទីលំនៅដោយស្ម័គ្រចិត្ត និង IFC PS ៥. ការទិញដី និងការតាំងទីលំនៅថ្មីដោយអចេតនា | គ្មាន | គម្រោងនេះនឹងមិនអនុញ្ញាតឱ្យមានការតាំងទីលំនៅថ្មី ឬការផ្លាស់ទីលំនៅដោយគ្មានការស្ម័គ្រចិត្តឡើយ។<br>ទោះបីជាមិនមានផលប៉ះពាល់អវិជ្ជមានត្រូវបានមើលឃើញជាមុននៅតាមសកម្មភាពដែលបានស្នើឡើងក៏ដោយ ក៏ ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម(ESMP)នឹងត្រូវបានរៀបចំឡើង នៅពេលតំបន់អន្តរាគមន៍ជាក់លាក់ពីគម្រោងត្រូវបានកំណត់រួចរាល់។ ប្រការនេះនឹងធានាថា គ្មានក្រុមមនុស្សណាមួយនឹងត្រូវបានផ្លាស់ទីលំនៅចេញពីដីរបស់ពួកគេ ឬធ្វើឱ្យមានផលប៉ះពាល់ដល់សិទ្ធិកាន់កាប់ដីរបស់ពួកគេដែរ។ ហានិភ័យទាំងនេះមិនត្រូវបានគិតទុកជាមុននោះទេ ដោយសារថា ការរៀបចំគម្រោងផ្តោតលើការធ្វើការជាមួយសមាគម និងសហជីពកសិកម្មដែលបានបង្កើតឡើង ដែលមានតំបន់ផលិតកម្ម និងបានកំណត់ច្បាស់លាស់ ព្រមទាំងជាមួយសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើ ដែលមានតំបន់កំណត់ព្រំប្រទល់ និងសិទ្ធិប្រើប្រាស់ដែលមានការទទួលស្គាល់តាមផ្លូវស្របច្បាប់។ |
| FAO ESS ៧៖ ការងារសមរម្យ និង IFC PS ២. លក្ខខណ្ឌការងារ និងកម្លាំងពលកម្ម និង IFC PS ៤. សុខភាពសុវត្ថិភាព និងសន្តិសុខ សហគមន៍ | គ្មាន | គម្រោងនេះនឹងពុំមានការផ្តល់ការងារដោយផ្ទាល់ដល់បុគ្គលិកនោះទេ ប៉ុន្តែវាទំនងជានឹងផ្តល់ឱកាសការងារដោយប្រយោល មិនមែនដោយផ្ទាល់ទេ។<br>គម្រោងនេះនឹងអនុវត្តការងារនៅក្នុងខ្សែច្រវ៉ាក់តម្លៃ និងតំបន់ទេសភាព ដែលរួមមានអ្នកផលិតដើម្បីគាំទ្រការចិញ្ចឹមជីវិត និងអ្នកធ្វើការក្នុងវិស័យកសិកម្មក្រៅផ្លូវការងាយរងគ្រោះផ្សេងទៀត ក៏ដូចជានៅក្នុងស្ថានភាពដែលយុវជនធ្វើការភាគច្រើនដោយគ្មានប្រាក់កម្រៃ ដើម្បីរួមចំណែកដល់គ្រួសារ។ សកម្មភាពរបស់គម្រោងគឺផ្តោតលើការកែលម្អលក្ខណៈការងារនៅក្នុងខ្សែច្រវ៉ាក់តម្លៃទាំងនេះ ក្នុងនោះរួមទាំងសកម្មភាពដើម្បីជួយកាត់បន្ថយឧប្បត្តិហេតុនៃ ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH) និង អំពើហិង្សាទាក់ទងនឹងយេនឌ័រ(GBV) និងការគាំទ្រដល់ការទទួលយកដែលមានការលើកកម្ពស់នៃវិធីសាស្រ្ត និងបទដ្ឋាននិរន្តរភាព និងមានគុណតម្លៃខ្ពស់ និងប្រកបដោយនិរន្តរភាព ដែលក្នុងករណីខ្លះមានការធ្វើឱ្យការងារកាន់តែប្រសើរឡើង។ តម្រូវការ និងជំនាញ ខណៈពេលអនុវត្តខ្សែច្រវ៉ាក់តម្លៃប្រសើរឡើង ក៏នឹងជួយកាត់បន្ថយការធ្វើចំណាកស្រុករបស់យុវជន តាមរយៈជម្រើសការងារដែលប្រសើរជាងមុន។ ក្រុមគោលដៅទាំងអស់គឺជាក្រុមដែលបានបង្កើតឡើងរួចហើយផងដែរដូចជា សហគមកសិកម្ម (ACs) សមាគមកសិករ (FAs) ក្រុមផលិត (PGs) និងសហជីពដែលបានដំណើរការជាក្រុម ហើយជាលទ្ធផលគម្រោងនឹងកម្ពស់កម្រិតសមធម៌នៅទូទាំងប្រព័ន្ធផលិតកម្មរបស់ពួកគេ។ ក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម(ESMF) ធ្វើការវាយតម្លៃលើបញ្ហាទាំងនេះ ក៏ដូចជាវិធានការកាត់បន្ថយហានិភ័យ |

| | | |
|---|---|---|
| | | សំខាន់ៗ ដើម្បីដោះស្រាយនូវអ្វីដែលជាហានិភ័យដែលកំពុងមានវត្តមាន។<br>ទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែហានិភ័យនៃសកម្មភាពនៅក្នុងខ្សែច្រវ៉ាក់តម្លៃ ផែនការគ្រប់គ្រងបរិស្ថាននិងសង្គម(ESMP)លម្អិតនឹងត្រូវបានរៀបចំនៅពេលដែលក្រុមអ្នកទទួលផលជាក់លាក់ ទីតាំង និងប្រព័ន្ធបញ្ជាក់គោលដៅត្រូវបាន ឯកភាព។ ផែនការគ្រប់គ្រងបរិស្ថាននិងសង្គម(ESMP)នេះក៏នឹងពិនិត្យមើលការចូលរួមពីតំបន់ការពារធម្មជាតិ ដូចដែលបានកត់សម្គាល់នៅក្រោម FAO ESS ២ ខាងលើដែរ។<br>សកម្មភាពសុខភាព និងសុវត្ថិភាពការងារ (OHS) នឹងត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំងសម្រាប់ការអនុវត្តសកម្មភាពគម្រោង។ ខណៈពេលដែលសកម្មភាពគម្រោងភាគច្រើនមានហានិភ័យទាប សកម្មភាពព្រៃឈើ និងកសិកម្មផ្សេងៗមានកម្រិតណា មួយនៃហា និភ័យ ឬមានហានិភ័យស្រាប់។ អន្តរាគមន៍របស់គម្រោងនឹងមិនបង្កើនហានិភ័យទាំងនេះ ដោយសារមានការបណ្តុះបណ្តាល និងការគាំទ្រប្រសើរជាងមុននៅលើការអនុវត្តកសិកម្មល្អរបស់កម្ពុជា (Cam-GAP) ក៏ដូចជាវឌ្ឍនភាពឆ្ពោះទៅរកវិញ្ញាបនបត្រស្តង់ដារពិភពលោក ដែលត្រូវបានមើលឃើញថាអាចជួយកាត់បន្ថយហានិភ័យទាំងនេះ – ដូចនេះ ចំណុចនេះត្រូវបានមើលឃើញថាមានហានិភ័យទាប។ |
| FAO ESS ៨៖ សមភាពយេនឌ័រ និង IFC PS ១. ការវាយតម្លៃ និងការគ្រប់គ្រងបរិស្ថាន និងផលប៉ះពាល់ និងហានិភ័យសង្គម | គ្មាន | គម្រោងនេះនឹងគាំទ្រដល់ការពង្រឹងសមត្ថភាពនិងសមភាពយេនឌ័រ ហើយត្រូវបានរៀបចំឡើងដើម្បីគិតគូរពីតម្រូវការ និងអាទិភាពជាក់លាក់របស់ស្ត្រី និងកុមារី និងធ្វើការពិចារណាសំខាន់ៗ ពាក់ព័ន្ធនឹង ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH) និង អំពើហិង្សាទាក់ទងនឹងយេនឌ័រ(GBV)ថាតើសកម្មភាពអ្វីខ្លះដែលអាចអនុវត្តបានដើម្បីដោះស្រាយបញ្ហាទាំងនេះ។ ការវាយតម្លៃយេនឌ័រ និងផែនការសកម្មភាពយេនឌ័រត្រូវបានបង្កើតឡើងសម្រាប់គម្រោងដែលមានសកម្មភាពជាក់លាក់ត្រូវអនុវត្ត និងថវិកាតាមការបែងចែក។ |
| ESS ៩៖ ជនជាតិដើមបេតិកភណ្ឌវប្បធម៌ និង IFC PS ៧. ជនជាតិដើម (IP) IFC PS ៨. បេតិកភណ្ឌវប្បធម៌ | មាន | មានមនុស្សជាង ៤០.000 នាក់នៅទូទាំង ១០ ក្រុមជនជាតិដើមភាគតិចដែលបានកំណត់ថាកំពុងរស់នៅក្នុងខេត្តគោលដៅ ដោយផ្អែកលើព័ត៌មានស្ទង់មតិឆ្នាំ២០១៩។ ខណៈពេលដែលទីតាំងគម្រោងជាក់លាក់មិនទាន់ត្រូវបានកំណត់អត្តសញ្ញាណនៅឡើយ ហើយដូច្នេះផលប៉ះពាល់របស់គម្រោងលើក្រុមជនជាតិដើមទាំងនេះមិនទាន់អាចត្រូវបានវាយតម្លៃបានពេញលេញនៅឡើយ។ ផែនការជនជាតិដើមភាគតិច (IPP) ត្រូវបានបង្កើតឡើងសម្រាប់គម្រោង ដោយផ្តល់នូវក្របខ័ណ្ឌណែនាំសកម្មភាព រួមនឹងការអភិវឌ្ឍបន្ថែមទៀតនៃ ផែនការជនជាតិដើមភាគតិច (IPP)ជាក់លាក់សម្រាប់តំបន់គោលដៅដែលត្រូវបានពិនិ |

| | | |
|---|---|---|
| | | ត្យឡើងវិញក្នុងអំឡុងពេលចាប់ផ្តើមគម្រោង ប្រសិនបើពួកគេត្រូវបានដាក់បញ្ចូលទៅក្រុម IP។<br>ផែនការនេះក៏យកចិត្តទុកដាក់ និងធានាថា កិច្ចខិតខំប្រឹងប្រែងនឹងត្រូវបានធ្វើឡើងក្នុងការគោរព ដាក់បញ្ចូល និងលើកកម្ពស់បញ្ហារបស់ជនជាតិដើម ក្នុងអំឡុងពេលអនុវត្តគម្រោង រួមទាំងសិទ្ធិរបស់ពួកគេក្នុងការផ្តល់ការឯកភាពដោយសេរី ជាមុន និងផ្អែកលើព័ត៌មានគ្រប់គ្រាន់ (FPIC) អំឡុងពេលកំណត់អត្តសញ្ញាណចុងក្រោយនៃកន្លែងអន្តរាគមន៍។ |

តាមរយៈក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMPs) ដែលផ្អែកលើហានិភ័យជាក់លាក់នៅក្នុងកម្រិតសកម្មភាព ការត្រួតពិនិត្យ និងរាយការណ៍អំពី ក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម(ESMF) និងផែនការរងជាក់លាក់នឹងត្រូវបានសម្របសម្រួល តាមរយៈអង្គភាពគ្រប់គ្រងគម្រោង (PMU) និងអ្នកជំនាញជាតិ កិច្ចការពារ បរិស្ថាន និងសង្គមរបស់គម្រោង។

## ជម្រើសផ្សេងៗ

គម្រោងនេះបង្កើតឡើង ដោយផ្អែកលើទម្លាប់អនុវត្តល្អបំផុត និងមេរៀនជាបទពិសោធ តាមរយៈគំនិតផ្តួចផ្តើមកន្លងមក និងកំពុងអនុវត្ត ដើម្បីពង្រឹងភាពធន់នឹងអាកាសធាតុ និងនិរន្តរភាពនៃសហគមន៍កសិករខ្នាតតូចនៅក្នុងប្រទេសកម្ពុជា។ វិធីសាស្រ្តគម្រោងនេះគឺផ្អែកលើការពិចារណាលើលក្ខខណ្ឌព័ត៌មានមូលដ្ឋាន ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ដែលមានសក្តានុពលក្នុងតំបន់គោលដៅ និងវិធីសាស្រ្តជំនួសដែលអាចមាន។

## អភិក្រមនៃក្របខ័ណ្ឌគ្រប់គ្រងការពារបរិស្ថាន និងសង្គម (ESMF)

ស្របតាមតម្រូវការនៃគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងបរិស្ថាន និងសង្គមរបស់អង្គការ FAO បទដ្ឋានការអនុវត្តរបស់ IFC គម្រោងនេះនឹងប្រើប្រាស់អភិក្រមនៃ ESMF ពីព្រោះថា អ្នកទទួលផលប្រយោជន៍ជាក់ស្តែងនឹងអាចដឹង នៅក្នុងពេលអនុវត្តតែប៉ុណ្ណោះ ហើយតំបន់ជាក់លាក់ និងទំនាក់ទំនងដែល ESMF នេះនឹងអនុវត្ត មិនត្រូវបានកំណត់ទេ។ ទោះជាយ៉ាងណាក៏ដោយ របាយការណ៍នេះមានមានលទ្ធផលនៃការវិភាគផលប៉ះពាល់បរិស្ថាន និងសង្គមនៃគម្រោងលើតំបន់គោលដៅទូលំទូលាយនៅក្នុងតំបន់ទំនាបបឹងទន្លេសាបភាគខាងជើង។ ឧបករណ៍សម្រាប់ពិនិត្យទីតាំង និងសហគមន៍ជាក់លាក់ នៅពេលពួកគេត្រូវបានកំណត់ ត្រូវបានប្រើប្រាស់ជាផ្នែកមួយនៃ ESMF ដើម្បីជួយសម្រួលដល់ការវិភាគហានិភ័យ និងកំណត់វិធានការគ្រប់គ្រងជាក់លាក់ស្របតាម ESMF។

## ការចូលរួមរបស់ភាគីពាក់ព័ន្ធ

គម្រោងនេះត្រូវបានរៀបចំឡើង តាមរយៈការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធយ៉ាងទូលំទូលាយនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងមូលដ្ឋាន រួមទាំងការពិគ្រោះយោបល់ជាមួយអង្គការសហគមន៍មូលដ្ឋាន សហព័ន្ធជនជាតិដើមភាគតិច និងក្រុមស្រ្តី ក្នុងចំណោមភាគីពាក់ព័ន្ធផ្សេងទៀត។ អាជ្ញាធរទទួលបន្ទុកថ្នាក់ជាតិ (NDA) បានចេញលិខិតមិនជំទាស់ចំពោះគម្រោងនេះ ហើយបានចូលរួមយ៉ាងសកម្ម ក្នុងការរៀបចំសំណើរគម្រោងនេះរួមមានសេចក្តីព្រាងគោលគំនិត និងឯកសារគម្រោងពេញលេញ និងឯកសារគាំទ្រផ្សេងៗ។

## យន្តការដោះស្រាយបណ្តឹងតវ៉ា (GRM)

យន្តការដោះស្រាយបណ្ដឹងតវ៉ា ដែលត្រូវបានស្នើឡើងក្រោមគម្រោងនឹងអនុវត្តតាមវិធីសាស្ត្រ យន្តការដោះស្រាយបណ្ដឹងរបស់អង្គការ FAO និងដំណើរការនៅក្នុងយន្តការពិនិត្យបណ្ដឹងតវ៉ារបស់អង្គការ FAO នៅកម្ពុជា ដែលបច្ចុប្បន្នកំពុងត្រូវបានរៀបចំបញ្ចប់ ហើយនឹងដាក់ឱ្យអនុវត្ត នៅពាក់កណ្ដាលឆ្នាំ២០២២ (កំណែសេចក្ដីព្រាងត្រូវបានផ្ដល់ជូននៅក្នុងឧបសម្ព័ន្ធទី ៤)។ ដោយផ្អែកលើគោលការណ៍នៃការផ្ទេរមុខងារ គម្រោងនឹងស្វែងរកការដោះស្រាយលើការប្ដឹងផ្ដល់ជាបឋមនៅកម្រិត អង្គភាពគ្រប់គ្រងគម្រោង (PMU)ជាមួយនឹងមន្ត្រីទទួលបន្ទុកផ្នែកការពារបរិស្ថាននិងសង្គមរបស់គម្រោងដែលជាមន្ត្រីបង្គោលក្នុងការទទួល ចងក្រង ពិនិត្យ កត់ត្រា និងធ្វើការជាមួយសមាជិក និងដៃគូ អង្គភាពគ្រប់គ្រងគម្រោង (PMU)ផ្សេងទៀតដើម្បីកំណត់ការឆ្លើយតបពាក់ព័ន្ធ។ វិធីសាស្ត្រនេះនឹងបង្កើត និងភ្ជាប់ជាមួយនឹងវិធីសាស្ត្រនៃការិយាល័យប្រចាំប្រទេសរបស់អង្គការ FAO ហើយធ្វើតាមពិធីការផ្សេងដែលមានលក្ខណៈចម្រុះ។

## ធនធានមនុស្ស

អ្នកជំនាញជាតិផ្នែកការពារបរិស្ថាន និងសង្គម និងអ្នកជំនាញយេនឌ័រជាតិនឹងធ្វើការរួមគ្នាលើការបញ្ជ្រាបការការពារទៅក្នុងគ្រប់វិស័យនៃការងារគម្រោង ស្របតាម ក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម(ESMF) និង ក្របខណ្ឌផែនការគ្រប់គ្រងបរិស្ថាននិងសង្គម (ESMPs) ជាក់លាក់ដែលមានបញ្ចូលការវាយតម្លៃជាមូលដ្ឋាន ការពិចារណាលើការការពារបរិស្ថាន និងសង្គមទៅក្នុងវគ្គបណ្ដុះបណ្ដាល និងការលើកកម្ពស់ការយល់ដឹងដល់ទាំងបុគ្គលិក និងភាគីពាក់ព័ន្ធឱ្យកាន់តែទូលំទូលាយតាមរយៈដំណើរការអនុវត្ត ក៏ដូចជាការពិនិត្យឡើងវិញ និងធានាផលិតផលគម្រោង និងវិធីសាស្ត្ររួមបញ្ចូលយ៉ាងពេញលេញក្នុងការពិចារណាអំពីយេនឌ័រ។ អ្នកឯកទេសការពារសុវត្ថិភាពអន្តរជាតិ និងក្រុមទីប្រឹក្សាយេនឌ័រជាតិនឹងផ្ដល់ការគាំទ្របន្ថែមដល់ការបង្កើតការវាយតម្លៃមូលដ្ឋានដែលផ្ដោតលើផ្នែកសំខាន់ៗ ការរៀបចំ ផែនការគ្រប់គ្រងបរិស្ថាននិងសង្គម (ESMPs)ជាក់លាក់ និងការអភិវឌ្ឍការសិក្សាមូលដ្ឋាន និងការណែនាំជាក់លាក់សម្រាប់ការអនុវត្តការការពារសុវត្ថិភាព។ ការអនុវត្តកម្មវិធីការពារសុវត្ថិភាពនឹងទទួលបានការសម្របសម្រួលយ៉ាងជិតស្និទ្ធរវាង អង្គភាពគ្រប់គ្រងគម្រោង (PMU) និងដៃគូអនុវត្តថ្នាក់ជាតិ រួមទាំងក្រសួងបរិស្ថានផងដែរ។

## ថវិកា

ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម មានថវិកាចំនួន ៥៦៩.000 ដុល្លារអាមេរិកជាមួយនឹងថវិកាបន្ថែមចំនួន ១៤.៩៩៩.៦៨៦ ដុល្លារអាមេរិកដែលបានដាក់បញ្ចូលនៅក្នុងផែនការសកម្មភាពយេនឌ័រ ហើយវាផ្នែកមួយនៃថវិកាគម្រោងទាំងមូល។

## រចនាសម្ព័ន្ធរបាយការណ៍ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF)

ឯកសារនេះត្រូវបានរៀបចំជាផ្នែកសំខាន់ៗចំនួនប្រាំបួនដោយចាប់ផ្ដើមពីសេចក្ដីផ្ដើម (ផ្នែកទី ១) និងការពិពណ៌នាគម្រោង (ផ្នែកទី ២) និងការពិពណ៌នាអំពីលក្ខខណ្ឌមូលដ្ឋាននៃបរិស្ថាន និងសេដ្ឋកិច្ចសង្គម (ផ្នែកទី ៣)។ ក្របខ័ណ្ឌច្បាប់ និងស្ថាប័ននៅថ្នាក់អន្តរជាតិ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានត្រូវបានបង្ហាញនៅក្នុងផ្នែកទី ៤ ដែលពិពណ៌នាអំពីក្របខ័ណ្ឌច្បាប់ដើម្បីធានាថាការការពារបរិស្ថាន និងសង្គមមានលក្ខណៈសមស្រប និងរួចរាល់សម្រាប់ការអនុវត្ត។ បន្ទាប់ពីចំណុចនេះគឺការពិពណ៌នាអំពីគោលនយោបាយធានាសុវត្ថិភាពដែលអាចអនុវត្តបានពីអង្គការ FAO និង GCF (ផ្នែកទី ៥) រួមទាំងដំណើរការចាត់ថ្នាក់ហានិភ័យគម្រោង និងលទ្ធផល។ ក្រៅពីនេះ ក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីតាមដាន វាយតម្លៃ និងកាត់បន្ថយហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គមដែលអាចកើតមានមានថែងនៅ (ផ្នែកទី ៦)។ ទិដ្ឋភាពទូទៅនៃផែនការពិគ្រោះយោបល់ និងការចូលរួមរបស់

ភាគីពាក់ព័ន្ធ និងលទ្ធផលត្រូវបានដាក់បញ្ចូលទៅក្នុងផ្នែកទី ៧។ ជនជាតិដើមភាគតិច និងក្របខ័ណ្ឌផែនការការបញ្ចូលសង្គមមានបង្ហាញនៅក្នុងផ្នែកទី ៨ ដោយធានាថា សិទ្ធិជនជាតិដើមភាគតិច និងក្រុមដែលមិនត្រូវបានរាប់បញ្ចូល/សេដ្ឋកិច្ចសង្គមត្រូវបានគោរព និងថា គម្រោងនេះនឹងមិនមានផលប៉ះពាល់អវិជ្ជមានដល់សហគមន៍ទាំងនេះឡើយ។ ផ្នែកទី ៩ ពិពណ៌នាអំពីក្របខ័ណ្ឌគ្រប់គ្រងជីវៈចម្រុះ ដែលបង្ហាញពីវិធីសាស្ត្រអនុវត្តដោយគម្រោងដើម្បីជៀសវាង និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើជីវៈចម្រុះ និងដើម្បីលើកកម្ពស់បន្ថែមទៀតនូវវិធានការដែលលើកកម្ពស់ការអភិរក្សជីវៈចម្រុះនៅក្នុងតំបន់គម្រោង។ លើសពីផ្នែកស្នូលទាំងនេះនៃ ក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម( ESMF) ឧបសម្ព័ន្ធ ផ្សេងៗត្រូវបានផ្តល់ជូនដោយមានការរៀបរាប់លម្អិត។

## ១. សេចក្តីផ្តើម

១. រដ្ឋាភិបាលកម្ពុជា ក្រោមកិច្ចសហការជាមួយអង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិកំពុងរៀបចំគម្រោង **"គម្រោងភាពជាដៃគូរវាងរដ្ឋ ឯកជន និងសហគមន៍ដើម្បីលើកកម្ពស់កសិកម្មភាគរបរិស្ថាន និងជីវភាពដែលធន់នឹងអាកាសធាតុរបស់សហគមន៍នៅភាគខាងជើងនៃបឹងទន្លេសាប (គម្រោង PEARL)"** ដើម្បីដាក់ស្នើសុំថវិកាពីមូលនិធិអាកាសធាតុបៃតង (GCF)។ ធនធានជំនួយរបស់ GCF រួមជាមួយនឹងសហហិរញ្ញប្បទានរបស់រដ្ឋាភិបាល នឹងវិនិយោគលើផែនការប្រើប្រាស់ដីដែលធន់នឹងអាកាសធាតុ ក៏ដូចជាការអនុវត្តការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព (SNRM) និងវិធានការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (DRR) នៅភាគខាងជើងបឹងទន្លេសាបដែលងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ។

២. នៅកម្រិតកម្មភាព គម្រោងនេះនឹងគាំទ្រដល់សមាគមក្រុមអ្នកផលិតក្នុងសហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ និងសហជីពកសិកម្មក្នុងការអភិវឌ្ឍ និងអនុវត្តផែនការអាជីវកម្មជាក់លាក់លើដំណាំដែលធន់នឹងអាកាសធាតុ។ គម្រោងនេះនឹងមានញ្ចូលការបណ្តុះបណ្តាលកសិករទទួលផល និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀត ដើម្បីបង្កើតចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងអាជីវកម្ម និងជំនាញសហគ្រិន និងអ្នកផ្តល់សេវាបន្ថែមដើម្បីគាំទ្រដល់ការអនុវត្តផែនទីបង្ហាញផ្លូវ និងផែនការអាជីវកម្ម។ គម្រោងនេះក៏នឹងបង្កើតភាពជាដៃគូផ្ទាល់ជាមួយសហគ្រាសធុនតូច និងមធ្យម និងពាណិជ្ជករ/អ្នកនាំចេញ ដើម្បីពន្លឿនដំណើរការផ្លាស់ប្តូរ។ ដូចគ្នានេះផងដែរ គោលការណ៍ណែនាំ និងឧបករណ៍បន្ថែមនឹងត្រូវបានបង្កើតឡើង ដើម្បីធានាថា វិញ្ញាបនបត្របញ្ជាក់ដែលបានជ្រើសរើស ពិចារណាពីហានិភ័យ និងផលប៉ះពាល់អាកាសធាតុឱ្យបានគ្រប់គ្រាន់។ ជាលទ្ធផល កសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀតចំនួន ១៣៥.០០០ នាក់ នឹងមានលទ្ធភាពទទួលបានផ្នែកហិរញ្ញវត្ថុកាន់តែប្រសើរឡើង និងការ ការគាំទ្រដើម្បីទទួលយកការអនុវត្តដែលធន់នឹងអាកាសធាតុ និងបច្ចេកវិទ្យា ហើយកសិករ ៤៥០.០០០នាក់ នឹងមានលទ្ធភាពទទួលបានប្រសើរឡើងសេវាប្រឹក្សាផ្នែកកសិឧតុនិយមតាមតម្រូវការ។ កសិករ និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃផ្សេងទៀតប្រមាណជាង ១ លាននាក់ នឹងទទួលបានអត្ថប្រយោជន៍ដោយប្រយោលពីគម្រោង។ គម្រោងនេះនឹងផ្តល់ផលប្រយោជន៍ដោយផ្ទាល់ និងដោយប្រយោលដល់ប្រជាជនជាង ១.៥៨៥ លាននាក់ (ជាង ៩% នៃចំនួនប្រជាជនកម្ពុជា) តាមរយៈការអភិវឌ្ឍយុទ្ធសាស្ត្រសម្រាប់ការប្រើប្រាស់ដីដែលធន់នឹងអាកាសធាតុនៅតំបន់ភាគខាងជើងនៃបឹងទន្លេសាប។

៣. ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) ធានាថា ការគ្រប់គ្រងបរិស្ថាន និងសង្គមត្រូវបានបញ្ចូលទៅក្នុងវដ្តនៃការអភិវឌ្ឍគម្រោង។ ទីតាំងពិតប្រាកដ និងអន្តរាគមន៍នឹងត្រូវបានកំណត់បញ្ចប់ក្នុងអំឡុងពេលអនុវត្តគម្រោង ហើយដូច្នេះ ESMF ត្រូវបានជ្រើសរើសជាឧបករណ៍សមស្របបំផុត។

៤. ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ESMF) សម្រាប់គម្រោង PEARL ត្រូវបានធ្វើឡើងដោយអនុលោមតាមគោលនយោបាយគាំពារបរិស្ថាន និងសង្គមរបស់អង្គការ FAO និងការការពារបរិស្ថាន និងសង្គមរបស់ GCF។ ឯកសារនេះត្រូវបានរៀបចំឡើងដើម្បីធានាគាំទ្រសកម្មភាពសំខាន់ៗដូចខាងក្រោម (សកម្មភាពសរុបចំនួន ១៦)[1]៖

ក. ការកំណត់អត្តសញ្ញាណ ការគ្រប់គ្រង និងការវាយតម្លៃនៃហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម ដែលទាក់ទងនឹងគម្រោង PEARL។

ខ. ការអនុម័តឋានានុក្រមកាត់បន្ថយដោយផ្អែកលើ៖

---

[1] FAO 2015

i. ការជៀសវាងផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងសង្គមជាអាទិភាព

ii. ក្នុងករណីដែលមិនអាចជៀសវាងបាន កាត់បន្ថយ ឬកាត់បន្ថយហានិភ័យដល់កម្រិតដែលអាចទទួលយកបាន និង

iii. នៅកន្លែងដែលមានផលប៉ះពាល់ដែលនៅសេសសល់ ទូទាត់សំណង/ប៉ះប៉ូវនៅពេលណាដែលអាចធ្វើទៅបានតាមលក្ខណៈបច្ចេកទេស និងហិរញ្ញវត្ថុ។

គ. ការលើកកម្ពស់ប្រព័ន្ធកសិកម្ម និងស្បៀងប្រកបដោយនិរន្តរភាព។

៥. អនុសកម្មភាពដែលមានហានិភ័យបរិស្ថាន និងសង្គមសំខាន់ៗត្រូវបានរកឃើញនឹងបង្កើតផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP) ដែលរួមបញ្ចូលព័ត៌មានស្តីពីវិធានការកាត់បន្ថយ សូចនាករ ទំនួលខុសត្រូវ និងរយៈពេការបញ្ចប់វិធានការបែបនេះត្រូវបានរំពឹងទុក (មើលជំពូក ៦.១ សម្រាប់ព័ត៌មានលម្អិតបន្ថែម)។

## ២. ការពិពណ៌នាអំពីគម្រោង

៦. គម្រោងនេះផ្តោតសំខាន់នៅតំបន់ភាគខាងជើងនៃបឹងទន្លេសាបរបស់ប្រទេសកម្ពុជា។ តំបន់ភាគខាងជើងនៃបឹងទន្លេសាបគឺស្ថិតនៅផ្នែកខាងក្រោមនៃទន្លេមេគង្គ ដូចដែលបានបង្ហាញនៅក្នុងរូបភាពទី១។ តំបន់ដែលត្រូវបានកំណត់ជាតំបន់ភាគខាងជើងបឹងទន្លេសាប រួមមានខេត្តឧត្តរមានជ័យ កំពង់ធំ ព្រះវិហារ និងសៀមរាប។ តំបន់នេះមានប្រជាជនរស់នៅប្រហែល ១៥%នៃចំនួនប្រជាជនក្នុងប្រទេសសរុប។ តំបន់នេះមានផ្ទៃដីសរុបប្រមាណ ២,៥ លានហិកតា ព័ទ្ធជុំវិញទៅដោយព្រៃស្រោង ព្រៃរបោះ តំបន់ខ្ពង់រាបភាគខាងជើង ដីបង្កបង្កើនផលដ៏ធំល្វឹងល្វើយនៅផ្នែកកណ្តាល (ភាគច្រើនជាដីស្រែ) និងព្រៃលិចទឹក និងតំបន់វាលស្មៅ តាមបណ្តោយបឹងទន្លេសាបភាគខាងត្បូង។ កម្រិតទឹកភ្លៀងប្រចាំឆ្នាំជាមធ្យមនៅតាមទីតាំងផ្សេងៗមានចន្លោះពី ១០០០ ទៅ ១៥០០ មីលីម៉ែត្រ។ តំបន់នេះចែកចេញជាសណ្ឋានដីសំខាន់ចំនួន១០ តំបន់ទីជម្រាលសំខាន់ៗចំនួន៥ ក្នុងនោះរួមមាន៖ ស្ទឹងសែន និងស្ទឹងស្ទោងដែលជាប្រភពទឹកយ៉ាងសំខាន់សម្រាប់ធ្វើស្រែចម្ការ និងការចិញ្ចឹមជីវិតក្នុងតំបន់ (Oeurng et al., 2019)។ ផលិតកម្មស្រូវក្រអូបជាង ២០% នៃប្រទេស រួមនឹងផលិតផលផ្សេងទៀតដូចជា ដំឡូងមី (៣៥%) និងអំពៅ (២៧%) បានមកពីតំបន់ភាគខាងជើងនេះ (NIS, 2019)។




*រូបភាពទី 1. ទីតាំងតំបន់ភាគខាងជើងនៃបឹងទន្លេសាបក្នុងប្រទេសកម្ពុជា*

**ប្រភព[2]៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០១៩**

## ២.១ គោលបំណង និងលទ្ធផលរបស់គម្រោង

៧. ការអនុវត្តការប្រើប្រាស់ដីដែលគ្មាននិរន្តរភាពធ្វើឱ្យការប្រឈមមុខនឹងមុខសញ្ញាគ្រោះថ្នាក់ និងហានិភ័យអាកាសធាតុ កាន់តែធ្ងន់ធ្ងរ ដែលការកាប់បំផ្លាញព្រៃឈើ ការអនុវត្តកសិកម្ម និងការប្រើប្រាស់ព្រៃឈើដែលគ្មាននិរន្តរភាពនាំឱ្យមានផលប៉ះពាល់ ផ្សេងៗដូចជា ការពន្លឿនការហូរច្រោះដី និងដីល្បាប់ ទឹកស្ទឹងទន្លេពាក់ដោយសារការកើនឡើងដីល្បាប់ ការរេចរឹលដី ការកើនឡើងតំបន់បាក់ដី និងទឹកជំនន់។ តំបន់ដែលងាយរងគ្រោះ ការរេចរឹលនៃប្រព័ន្ធអេកូឡូស៊ី និងការបាត់បង់ទីជម្រក កាត់បន្ថយការបញ្ចូលទឹកឡើងវិញ និងកាត់បន្ថយលទ្ធភាពទទួលបានផលិតផលព្រៃឈើ (អុស ចំណីសត្វ អនុផលព្រៃឈើ) ក្នុងចំណោមផលិតផលផ្សេងៗទៀត)។ ប្រសិនបើវិធានការសន្សំមិនត្រូវបានអនុវត្ត ហើយយើងនៅបន្តអនុវត្តសកម្មភាពធម្មតាដដែលៗ តំបន់ តំបន់ភាគខាងជើងនៃបឹងទន្លេសាបនៃប្រទេសកម្ពុជានឹងកាន់តែប្រឈមនឹងកំដៅខ្លាំង បញ្ហាខ្វះទឹក ភ្លើងឆេះព្រៃ និងទឹកជំនន់ដែលមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រជាជនក្នុងតំបន់ ប្រព័ន្ធអេកូឡូស៊ី និងសេដ្ឋកិច្ចរបស់ប្រទេស។

៨. **គោលបំណងគម្រោង៖** ដើម្បីបង្កើនសមត្ថភាពសន្សំរបស់កសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវាក់តម្លៃក្នុងស្រុកផ្សេងទៀតនៅតំបន់ភាគខាងជើងនៃបឹងទន្លេសាបដើម្បីទប់ទល់នឹងផលប៉ះពាល់ដែលបានសង្កេតឃើញ និងរំពឹងទុកនៃការប្រែប្រួលអាកាសធាតុ។ គោលបំណងនេះនឹងសម្រេចបានដោយការកែលម្អលទ្ធភាពទទួលបានហិរញ្ញវត្ថុ បច្ចេកវិទ្យា និងចំណេះដឹង ដើម្បីទទួលយកការអនុវត្តដែលធន់នឹងអាកាសធាតុ និងមានតម្លៃខ្ពស់ ដើម្បីចូលទៅកាន់ទីផ្សារពិសេសសម្រាប់ស្វាយចន្ទី ស្វាយ ស្រូវសរីរាង្គ និងបន្លែ។ ការទទួលបានចំណេះដឹងកម្រិតខ្ពស់ និងការទទួល

2 ការប្រើឈ្មោះទាំងឡាយ និងព័ត៌មានផ្សេងៗដែលមានបង្ហាញក្នុងឯកសារនេះមិនមែនជាការសម្តែងមតិណាមួយរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) ពាក់ព័ន្ធនឹងស្ថានភាពផ្លូវច្បាប់ ឬស្ថានភាពអភិវឌ្ឍន៍របស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ណាមួយ ឬ អាជ្ញាធរនៃប្រទេស ដែនដី ទីក្រុង ឬតំបន់ ឬពាក់ព័ន្ធនឹងការកំណត់ព្រំដែន របស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ទាំងនេះឡើយ។

បានទីផ្សាររបស់ពួកគេ នឹងផ្តល់មធ្យោបាយចាំបាច់ដើម្បីដោះស្រាយហានិភ័យអាកាសធាតុ និងភាពងាយរងគ្រោះនៃសេដ្ឋកិច្ចសង្គមរបស់ពួកគេ ហើយផ្លាស់ប្តូរជាអចិន្ត្រៃយ៍ឆ្ពោះទៅរកការប្រកបមុខរបរចិញ្ចឹមជីវិត និងការអនុវត្តកសិកម្មចម្រុះដែលធន់នឹងអាកាសធាតុ។

៩. ជាពិសេស គម្រោង PEARL នឹងផ្តោតលើ៖

- ធានាថា កសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀត មានការយល់ច្បាស់អំពីហានិភ័យទាក់ទងនឹងអាកាសធាតុ និងយុទ្ធសាស្ត្រកាត់បន្ថយ។ គម្រោង PEARL នឹងណែនាំបច្ចេកវិទ្យាទំនើបដើម្បីផ្តល់នូវការព្យាករណ៍កសិឧត្តុនិយមជាក់លាក់សម្រាប់មុខដំណាំកសិកម្ម ការប្រកាសឱ្យដឹងមុន និងការគ្រប់គ្រងការដាំដុះ និងផ្តល់សេវាប្រឹក្សាទីផ្សារដែលពាក់ព័ន្ធ ដើម្បីបង្កើនសមត្ថភាពកសិករក្នុងការកំណត់ និងឆ្លើយតបទៅនឹងហានិភ័យដែលទាក់ទងនឹងអាកាសធាតុ និងលក្ខខណ្ឌអាកាសធាតុ។ គម្រោងនេះក៏នឹងអភិវឌ្ឍការរៀបចំស្ថាប័នចាំបាច់ រួមទាំងវិស័យឯកជនផងដែរ ដើម្បីផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាពនូវសេវាកម្មប្រឹក្សាដល់អ្នកប្រើប្រាស់។ ការបង្កើនការព្យាករណ៍កសិឧតុនិយម និងសមត្ថភាពផ្តល់ប្រឹក្សាក៏នឹងបញ្ចូលដោយផ្ទាល់ទៅក្នុងលទ្ធផលទី ២ សម្រាប់ការទទួលយកនូវបច្ចេកទេស និងបច្ចេកវិទ្យាដែលធន់នឹងអាកាសធាតុដោយកសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀត និងការលើកកម្ពស់សេវាកម្មហិរញ្ញវត្ថុកាត់បន្ថយហានិភ័យ។
- ភាពជាដៃគូរវាងរដ្ឋ ឯកជន និងសហគមន៍ប្រកបដោយប្រសិទ្ធភាព (PSPPs) ដើម្បីលើកកម្ពស់ការទទួលយកនូវការអនុវត្ត និងបច្ចេកវិទ្យាដែលធន់នឹងអាកាសធាតុ តម្លៃខ្ពស់ ប្រកបដោយបរិយាប័ន និងនិរន្តរភាពដោយកសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀត។ ភាពជាដៃគូរវាងរដ្ឋ ឯកជន និងសហគមន៍មិនត្រឹមតែផ្តោតលើការបង្កើនប្រសិទ្ធភាពដោយការនាំយកវិស័យសាធារណៈ និងឯកជនរួមគ្នាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើការបង្កើតតម្លៃសង្គម និងទស្សនវិស័យរួមគ្នា ដោយយកចិត្តទុកដាក់លើតម្រូវការ និងផលប្រយោជន៍សាធារណៈផ្សេងៗ។ កិច្ចខិតខំប្រឹងប្រែងនេះនឹងរួមបញ្ចូលការអភិវឌ្ឍជំនាញសហគ្រិនធន់នឹងអាកាសធាតុ អាជីវកម្ម និងចំណេះដឹងហិរញ្ញវត្ថុដល់កសិករខ្នាតតូច តួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងៗ និងការផ្តល់ឧបករណ៍ដើម្បីធ្វើឱ្យមានហិរញ្ញវត្ថុសម្រាប់អ្នកទទួលផលទាំងនេះ ដែលមានមធ្យោបាយមានកម្រិតក្នុងការសន្សំទៅនឹងអាកាសធាតុការអនុវត្តទីផ្សារប្រកួតប្រជែង និងបច្ចេកវិទ្យា។
- ការធានាបាននូវលក្ខខណ្ឌអំណោយផលដើម្បីសម្រេចឱ្យបានជោគជ័យលទ្ធផលទី ១ និងទី ២ ខាងលើ។ កិច្ចខិតខំប្រឹងប្រែងនេះសំដៅធានាឱ្យមានលក្ខខណ្ឌចាំបាច់នានានៃបទប្បញ្ញត្តិ និងស្ថាប័ន ដើម្បីជាក់ឱ្យដំណើរ ការកម្មវិធីវិញ្ញាបនប័ត្របញ្ជាក់គុណភាពផលិតផល ដែលជាមធ្យោបាយចម្បងសម្រាប់ការទទួលយកការអនុវត្តកសិកម្មធន់នឹងអាកាសធាតុរបស់កសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀត។ ជាមួយគ្នា នេះដែរ វាក៏លើកកម្ពស់ភាពជាដៃគូរវាងរដ្ឋ ឯកជន និងសហគមន៍ប្រកបដោយប្រសិទ្ធភាព តាមរយៈយន្តការសម្របសម្រួលភាគីពាក់ព័ន្ធថ្នាក់ជាតិ និងខេត្តដែលមានស្រាប់ (លទ្ធផល ៣.១ សូមមើលរូបភាពទី ១)។ យន្តការទាំងនោះរួមមានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (NCSD) គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD) និងវេទិកាសាធារណៈនៅ ថ្នាក់ខេត្ត។ គម្រោងនេះនឹងចាប់ដៃគូជាមួយធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម(ARDB) និងស្ថាប័នហិរញ្ញវត្ថុឯកជន ដើម្បីបង្កើតប្រព័ន្ធពិន្ទុប្រាក់កម្ចី ដោយពិចារណាលើកត្តាភាពធន់នឹងអាកាសធាតុ កត្តាបរិយាប័ន និងកត្តានិរន្តរភាពជាលក្ខណៈវិនិច្ឆ័យសំខាន់ក្នុងការពិនិត្យមើលការស្នើសុំប្រាក់កម្ចី។ ប្រព័ន្ធនេះនឹងជំរុញមិនត្រឹមតែការផ្លាស់ប្តូរជារួមឆ្ពោះទៅរកកសិកម្មដែលធន់នឹងអាកាសធាតុនៅក្នុងវិស័យ

នេះប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាការផ្លាស់ប្តូរដ៏ត្រឹមត្រូវមួយដោយការបង្កើនលទ្ធភាពរបស់កសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀតក្នុងការទទួលបានហិរញ្ញវត្ថុបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

លទ្ធផលរំពឹងទុកនៃគម្រោងត្រូវបានបង្ហាញក្នុងរូបភាពទី ២

| ភាពធន់នឹងអាកាសធាតុ | កសិកម្មមានតម្លៃខ្ពស់ | បរិយាកាសអំណោយផល |
|---|---|---|
| **លទ្ធផលទី ១៖** | **លទ្ធផលទី ២៖** | **លទ្ធផលទី ៣៖** |
| សមត្ថភាពរបស់កសិករត្រូវបានពង្រឹងដើម្បីគ្រប់គ្រងផលប៉ះពាល់ពីអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយនានា | **សមត្ថភាពបន្សាំ**របស់កសិករខ្នាតតូច និងតួអង្គខ្សែច្រវ៉ាក់តម្លៃនៅមូលដ្ឋានត្រូវបានលើកកម្ពស់តាមរយៈកសិកម្មធន់នឹងអាកាសធាតុ មានតម្លៃខ្ពស់ ពិពិធកម្ម ប្រកបដោយចីរភាព។ | **លក្ខខណ្ឌអំណោយផល** សម្រាប់កសិកម្មធន់នឹងអាកាសធាតុត្រូវបានធានា តាមរយៈ ក្របខ័ណ្ឌគោលនយោបាយ ច្បាប់ និង ក្របខណ្ឌស្ថាប័នដែលរឹងមាំ។ |

១០. គម្រោងនេះនឹងគាំទ្រដោយផ្ទាល់ដល់កសិករខ្នាតតូចចំនួន ១៣៥.000 នាក់ និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀត ជាមួយនឹងការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានហិរញ្ញវត្ថុ និងការគាំទ្រសម្រាប់ការទទួលយកការអនុវត្ត និងបច្ចេកវិទ្យាដែលធន់នឹងអាកាសធាតុ។ កសិករ ៤៥0.000នាក់ នឹងមានលទ្ធភាពទទួលបានកាន់តែប្រសើរឡើងនូវសេវាប្រឹក្សាផ្នែកកសិឧតុនិយមតាមតម្រូវការ។ កសិករជាង ១ លាននាក់ និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃផ្សេងទៀត នឹងទទួលផលប្រយោជន៍ដោយប្រយោលពីគម្រោងនេះ។ គម្រោងនេះនឹងផ្តល់ផលប្រយោជន៍ដោយផ្ទាល់ និងដោយប្រយោលដល់ប្រជាជនជាង ១.៥៨៥ លាននាក់ (ជាង៩% នៃចំនួនប្រជាជនកម្ពុជា) តាមរយៈការអភិវឌ្ឍយុទ្ធសាស្ត្រសម្រាប់ការប្រើប្រាស់ដីដែលធន់នឹងអាកាសធាតុនៅតំបន់ភាគខាងជើងនៃបឹងទន្លេសាប។ គម្រោងក៏នឹងផ្តល់អត្ថប្រយោជន៍ដល់ ស្ត្រី ជនក្រីក្រ និងក្រុមដែលខ្វះខាតក្នុងសង្គម។

១១. គម្រោងអាចមានសក្តានុពលចូលរួមចំណែកក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ប៉ុន្តែ គម្រោងនេះមិនបានដាក់បញ្ចូលសកម្មភាពដើម្បីតាមដាន និងរាយការណ៍ពីលទ្ធផលនៃការកាត់បន្ថយដ៏មានសក្តានុពលនេះទេ ដោយសារមូលហេតុខាងក្រោម៖

ក. ក្នុងអំឡុងពេលនៃការរៀបចំគម្រោង ប្រទេសកម្ពុជាមិនមាននិយមន័យការសិករិករិលព្រៃឈើ ឬទិន្នន័យដើមកាលកន្លងមកពាក់ព័ន្ធនឹងការសាយភាយឧស្ម័នផ្ទះកញ្ចក់ចេញពីការសិករិករិលព្រៃឈើនោះទេ។ ដូច្នេះហើយ គម្រោងនេះមិនមានទិន្នន័យកម្រិតយោងជាក់លាក់នៅតំបន់គោលដៅដែលជាកម្មវត្ថុ សម្រាប់ការស្តារឡើងវិញ ដើម្បីវាស់វែង និងរាយការណ៍ពីការរួមចំណែកកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់នៅក្នុងឧបសម្ព័ន្ធបច្ចេកទេសនៃរបាយការណ៍ពីរឆ្នាំរបស់ប្រទេស (BUR) ដែលដាក់ជូន UNFCCC នោះទេ។

ខ. ការបង្កើនការស្តុកកាបូននៃសកម្មភាពស្តារព្រៃឡើងវិញរបស់គម្រោងទំនងជាមិនអាចវាស់វែងបានក្នុងរយពេលអនុវត្តគម្រោងនោះទេ ដោយសារការស្តារព្រៃដទាមទាររយពេលវែងដើម្បីទទួលបានលទ្ធផល។

១២. ដោយផ្អែកលើកត្តាខាងលើ គម្រោងនឹងផ្តោតលើការវិនិយោគរបស់ខ្លួនទាំងស្រុងលើការបង្កើតផលប៉ះពាល់លើការបន្សាំព្រោះវាត្រូវបានចាត់ទុកថាមានប្រសិទ្ធភាពជាងក្នុងកាលៈទេសៈនេះ។ ទោះជាយ៉ាងណាក៏ដោយ គម្រោងនេះនឹងសម្របសម្រួលជាមួយដំណើរការកម្មវិធី REDD+ របស់កម្ពុជា ដោយជាចម្បងតាមរយៈប្រព័ន្ធតាម

ដានព្រៃឈើជាតិ (NFMS) ដែលគ្រប់គ្រងដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធានាថា សហអត្ថប្រយោជន៍របស់ខ្លួនក្នុងការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ត្រូវបានរាប់បញ្ចូលយ៉ាងត្រឹមត្រូវសម្រាប់ជាផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់កម្ពុជា នៅក្រោមការប្តេជ្ញាចិត្តរបស់ប្រទេសជាតិក្នុងការរួមចំណែកការកាត់បន្ថយការប្រែប្រួលអាកាសធាតុ (NDC) (MoE, 2020b)។

១៣. គម្រោងដែលបានស្នើឡើងរួមមាន លទ្ធផល រយៈពេលវែងដែលបំពេញបន្ថែមឱ្យគ្នាចំនួនបី លទ្ធផលរយៈពេលខ្លីចំនួនប្រាំពីរ និងសកម្មភាពគាំទ្រចំនួនដប់ប្រាំមួយ។ ចំនុចខាងក្រោមនេះផ្តល់នូវទិដ្ឋភាពសង្ខេបនៃលទ្ធផល និងសកម្មភាពទាំងនេះ ប៉ុន្តែព័ត៌មានលម្អិតបន្ថែមមាននៅក្នុងសំណើគម្រោងពេញលេញ និងការសិក្សាសមិទ្ធិលទ្ធភាព។

១៤. គម្រោងនឹងគាំទ្រសកម្មភាពដែលផ្តោតលើការបង្កើនសមត្ថភាពបន្សាំដើម្បីទប់ទល់នឹងផលប៉ះពាល់ដែលបានសង្កេតឃើញ និងរំពឹងទុកនៃការប្រែប្រួលអាកាសធាតុ ដោយការដោះស្រាយភាពងាយរងគ្រោះនៃអាកាសធាតុ និងសេដ្ឋកិច្ចសង្គមនៅតំបន់ភាគខាងជើងជើងនៃបឹងទន្លេសាប ដោយផ្អែកលើបច្ចេកទេស ទីផ្សារ និងគោលនយោបាយ និងអន្តរាគមន៍កម្រិតស្ថាប័ន។ ដើម្បីគាំទ្រ ការអនុវត្ត និងពង្រីកគម្រោង សកម្មភាពក្នុងលទ្ធផលទី១ នឹងផ្តោតលើការលើកកម្ពស់សមត្ថភាពកសិករក្នុងការគ្រប់គ្រងផលប៉ះពាល់អាកាសធាតុ និងហានិភ័យដែលពាក់ព័ន្ធ។ លទ្ធផលទី ២ នឹងផ្តោតលើការកែលម្អសមត្ថភាពសន្សាំរបស់កសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀត ជាពិសេសកសិករស្រ្តីដែលងាយរងគ្រោះ និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃ តាមរយៈការបង្កើនភាពធន់នឹងអាកាសធាតុ តម្លៃខ្ពស់ កសិកម្មចម្រុះ និងនិរន្តរភាព។ លទ្ធផលទី ៣ នឹងធ្វើឱ្យប្រសើរ ឡើងនូវលក្ខខណ្ឌអំណោយផលសម្រាប់កសិកម្មដែលធន់នឹងអាកាសធាតុ តាមរយៈគោលនយោបាយដែលស៊ីសង្វាក់គ្នា និងរឹងមាំ ក្នុងក្របខ័ណ្ឌច្បាប់ និងស្ថាប័ន។

១៥. វិធានការអន្តរាគមន៍របស់គម្រោងដែលមានលក្ខណបំពេញបន្ថែមគ្នាទាំងនេះ នឹងជួយដោះស្រាយកត្តាជាឧបសគ្គចំពោះការសន្សំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ហើយវានឹងគាំទ្រដល់ការផ្លាស់ប្តូរគំរូមួយជាមួយនឹងបរិយាកាសអំណោយផលដ៏រឹងមាំ និងការពង្រីកអន្តរាគមន៍ដែលនឹងបង្កើនភាពភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ទាំងសហគមន៍ និងប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ។

១៦. គោលបំណងនៃគម្រោងនឹងត្រូវបានសម្រេចតាមរយៈលទ្ធផលដូចខាងក្រោម៖

- លទ្ធផលទី ១៖ ភាពធន់នឹងអាកាសធាតុ។
- លទ្ធផលទី ២៖ កសិកម្មមានតម្លៃខ្ពស់។
- លទ្ធផលទី ៣៖ បរិយាកាសអំណោយផល។

១៧. នៅក្រោមលទ្ធផលទី ១ គម្រោងនេះនឹងធានាថាកសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀតមានការយល់ដឹងច្បាស់លាស់អំពីហានិភ័យដែលទាក់ទងនឹងអាកាសធាតុ និងយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យ។ គម្រោង PEARL នឹងណែនាំបច្ចេកវិទ្យាទំនើបដើម្បីផ្តល់នូវការព្យាករណ៍អាកាសធាតុដែលជាក់លាក់សម្រាប់ដំណាំកសិកម្ម ការប្រកាសឱ្យដឹងមុន និងសេវាប្រឹក្សាទីផ្សារដែលពាក់ព័ន្ធនឹងការគ្រប់គ្រងការដាំដុះ ដើម្បីបង្កើនសមត្ថភាពអ្នកនៅមូលដ្ឋានក្នុងការ កំណត់ និងឆ្លើយតបទៅនឹងហានិភ័យដែលទាក់ទងនឹងអាកាសធាតុ និងលក្ខខណ្ឌអាកាសធាតុ។ គម្រោងនេះក៏នឹងអភិវឌ្ឍការរៀបចំស្ថាប័នចាំបាច់ រួមទាំងវិស័យឯកជនផងដែរ ដើម្បីផ្សព្វផ្សាយ ប្រកបដោយប្រសិទ្ធភាពនូវសេវាកម្មប្រឹក្សាដល់អ្នកប្រើប្រាស់ព័តមានកសិឧត្តុនិយម។ សមត្ថភាពកើនឡើងក្នុងការធ្វើការព្យាករណ៍អាកាសធាតុសម្រាប់វិស័យកសិកម្ម និងការផ្តល់ប្រឹក្សា នឹងជួយដោយផ្ទាល់ទៅក្នុងលទ្ធ

ផលទី ២ ដើម្បីជំរុញសម្រាប់ការទទួលយកនូវបច្ចេកទេស និងបច្ចេកវិទ្យាដែលធន់នឹងអាកាសធាតុដោយកសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀត និងការលើកកម្ពស់សេវាកម្មហិរញ្ញបទានដើម្បីកាត់បន្ថយហានិភ័យ។

១៨. លទ្ធផលនេះនឹងគាំទ្របន្ថែមលើគំនិតផ្តួចផ្តើម និងគម្រោងអន្តរជាតិផ្សេងៗនៅក្នុងតំបន់នេះ ដោយផ្តោតលើគម្លាតសមត្ថភាពដែលនៅសល់។ ផ្អែកលើតម្រូវការព័ត៌មានអាកាសធាតុជាក់លាក់ទាក់ទងនឹងកសិកម្ម គម្លាតសមត្ថភាពសំខាន់ៗត្រូវបានរកឃើញ ពាក់ព័ន្ធនឹងការផ្តល់សេវាប្រឹក្សាសម្រាប់ដំណាំជាក់លាក់ និងផ្តល់ដល់អ្នកប្រើប្រាស់ចុងក្រោយ (សូមមើលលទ្ធផល ១.១)។ សមត្ថភាពស្ថាប័ន និងបច្ចេកទេសពាក់ព័ន្ធនឹងកិច្ចការនេះ នៅមានកម្រិតនៅឡើយ ឧទាហរណ៍ ការបកប្រែទិន្នន័យអាកាសធាតុ និងធាតុអាកាសសម្រាប់យកទៅប្រើប្រាស់ ធ្វើជាសេវាកម្មប្រឹក្សាជាក់លាក់សម្រាប់ការអនុវត្តក្នុងវិស័យកសិកម្ម ជាពិសេសការដាក់ពត៌មានទាំងនេះក្នុងទម្រង់ និងបរិបទដែលមានលក្ខណងាយស្រួលអាចយល់បានដោយកសិករ និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀត។ ការរៀបចំស្ថាប័ននិងកិច្ចសម្របសម្រួលរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម គឺជាការចាំបាច់ដើម្បីផ្តល់សេវាប្រឹក្សាផ្នែកកសិឧតុនិយមដែលសមស្រប និងឆ្លើយតបទៅតម្រូវការដល់អ្នកប្រើប្រាស់ចុងក្រោយ។ ចំនុចមួយទៀត គឺការពង្រឹងសេវាកម្មបន្ថែម និងភាពជាដៃគូជាមួយតួអង្គឯកជន និងអង្គការក្រៅរដ្ឋា
ភិបាល តាមរយៈស្ថានីយ៍វិទ្យុ និងទូរទស្សន៍ក្នុងស្រុក ប្រព័ន្ធផ្សព្វផ្សាយសង្គម និងកម្មវិធីទូរសព្ទចល័តដូចជា Tonle Sap App និង EcoKaskor ដើម្បីផ្សព្វផ្សាយព័ត៌មានប្រកបដោយគុណភាព ស៊ីសង្វាក់គ្នា ដើម្បីជួយដល់កសិករក្នុងការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងការគ្រប់គ្រងដំណាំ និងការអនុវត្តក្រោយការប្រមូលផល។ នៅក្រោមលទ្ធផលនេះ សកម្មភាពនឹងសម្របសម្រួលជាមួយគម្រោង GEF7/LDCF (គម្រោង ការលើកកម្ពស់ជីវភាពដែលធន់នឹងអាកាសធាតុរបស់ប្រជាសហគមន៍ដាំស្រូវនៅតំបន់បឹងទន្លេសាប) របស់អង្គការ FAO ដើម្បីធានាបាននូវនិរន្តរភាព និងវិសាលភាពនៃការវិនិយោគរបស់គម្រោងនៅកម្រិតទេសភាព។ ការធ្វើឱ្យស្រសើរឡើងសេវាកម្មប្រឹក្សាកសិឧតុនិយមឆ្លើយតប ទៅនឹងតម្រូវការ និងអាចទទួលនិងប្រើប្រាស់បានដោយកសិករ និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃផ្សេងទៀត នៅក្នុងលទ្ធផលនេះ នឹងជួយដោះស្រាយឧបសគ្គសំខាន់ៗចំពោះវិស័យកសិកម្ម តាមរយៈការអភិវឌ្ឍសមត្ថភាពស្ថាប័នទទួលខុសត្រូវ និងអ្នកប្រើប្រាស់ចុងក្រោយ ដោយផ្តោតលើស្ត្រី និងជនជាតិភាគតិចផ្សេងទៀត និងការបង្កើនការយល់ដឹងអំពីហានិភ័យអាកាសធាតុ និងជម្រើសដើម្បីដោះស្រាយហានិភ័យទាំងនេះ (សូមមើល ការពិពណ៌នាអំពីកត្តារាំងខាងក្រោម)។

១៩. ដើម្បីគាំទ្រដល់ការធ្វើឱ្យប្រសើរឡើងកសិកម្មមានតម្លៃខ្ពស់ លទ្ធផលទី ២ នឹងផ្តោតលើភាពជាដៃគូរវាងរដ្ឋ ឯកជន និងសហគមន៍ដើម្បីលើកកម្ពស់ការទទួលយកនូវការអនុវត្ត និងបច្ចេកវិទ្យាដែលធន់នឹងអាកាសធាតុ ផ្តល់តម្លៃខ្ពស់ មានលក្ខណបរិយាប័ន និងនិរន្តរភាពដោយកសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀត។ ភាពជាដៃគូរវាងរដ្ឋ ឯកជន និងសហគមន៍មិនត្រឹមតែផ្តោតលើការបង្កើនប្រសិទ្ធភាពដោយការនាំយកវិស័យសាធារណៈ និងឯកជនរួមគ្នាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើការបង្កើតតម្លៃ និងទស្សនៈវិស័យសង្គមរួមគ្នា ដោយយកចិត្តទុកដាក់លើតម្រូវការ និងផលប្រយោជន៍សាធារណៈផ្សេងៗ។ កិច្ចខិតខំប្រឹងប្រែងនេះនឹងរួមបញ្ចូលការអភិវឌ្ឍជំនាញសហគ្រិន ភាពធន់នឹងអាកាសធាតុរបស់តួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុក និងក្នុងការអភិវឌ្ឍអាជីវកម្ម និងចំណេះដឹងផ្នែកហិរញ្ញវត្ថុ ព្រមទាំងការផ្តល់យន្តការដើម្បីធ្វើឱ្យមានហិរញ្ញវត្ថុសម្រាប់អ្នកទទួលផលទាំងនេះ ដែលមានមធ្យោបាយមានកម្រិតក្នុងការទទួលយកការអនុវត្ត និងបច្ចេកវិទ្យាធន់នឹងអាកាសធាតុ និងមានការប្រកួតប្រជែងទីផ្សារ។

២០. យន្តការហិរញ្ញវត្ថុចម្បងរបស់គម្រោងគឺ យន្តការកសាងភាពធន់ក្នុងវិស័យកសិកម្មដែលដឹកនាំដោយកសិករ (FARM) (សូមមើល លទ្ធផល ២.២)។ នៅក្រោមយន្តការ FARM គម្រោងនេះនឹងគាំទ្រដល់ សហគមន៍កសិកម្ម សមាគមកសិករ ក្រុមអ្នកផលិត និងសហជីពកសិកម្មក្នុងការអភិវឌ្ឍផែនការអាជីវកម្មសម្រាប់កសិកម្មដែលធន់នឹងអាកាសធាតុ និងផ្តល់តម្លៃខ្ពស់ក្នុងភាពជាដៃគូជាមួយសេវាផ្សព្វផ្សាយសាធារណៈ និងវិស័យឯកជន និងដៃគូអង្គការក្រៅរដ្ឋាភិបាល។ FARM ក៏នឹងគាំទ្រ ដល់ក្រុមអ្នកទទួលផលជាមួយនឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងបង្កើនសមត្ថភាពរបស់ពួកគេក្នុងការគ្រប់គ្រងប្រកបដោយបរិយាប័ន ឆ្លើយតបទៅនឹងតម្រូវការយេនឌ័រ និងមានលក្ខណៈសមធម៌។ ដូច្នេះ FARM នឹងជួយក្រុមអ្នកទទួលផលក្នុងការអនុវត្តផែនការអាជីវកម្មរបស់ពួកគេតាមលក្ខណៈបច្ចេកទេស ហិរញ្ញវត្ថុ និងប្រតិបត្តិការ (សូមមើលផ្នែក B.៣នៃគម្រោង សម្រាប់ព័ត៌មានលម្អិតបន្ថែម)។ ជាផ្នែកនៃដំណើរការអភិវឌ្ឍផែនការអាជីវកម្ម គម្រោងនេះនឹងបង្កើតភាពជាដៃគូជាមួយដៃគូឯកជន (ឧទាហរណ៍ អ្នកដឹកនាំខ្សែច្រវ៉ាក់តម្លៃ) ដើម្បីគាំទ្រការផ្លាស់ប្តូររបស់ក្រុមអ្នកទទួលផលទៅកាន់វិស័យកសិកម្មដែលធន់នឹងអាកាសធាតុ និងផ្តល់តម្លៃខ្ពស់។ ភាពជាអ្នកដឹកនាំអាជីវកម្ម និងការវិនិយោគរបស់ពួកគេត្រូវបានរំពឹងថានឹងបង្កើនមត្ថភាពសេដ្ឋកិច្ច និងជាផ្លូវមួយដែលនាំឱ្យមានការកើនឡើងការវិនិយោគឯកជន និងសាធារណៈ។ ដំណើរការនេះក៏នឹងផ្តល់អត្ថប្រយោជន៍ដល់ដៃគូឯកជនក្នុងការបង្កើនសមត្ថភាពផ្គត់ផ្គង់ និងគុណភាពរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់ពួកគេគឺផ្អែកលើលក្ខខណ្ឌអំណោយផលជាច្រើន (ឧទាហរណ៍ សមត្ថភាពរបស់កសិករម្នាក់ៗ និងសេវាកម្មបន្ថែម អភិបាលកិច្ចរួមគ្នារបស់កសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃផ្សេងទៀត ក្របខ័ណ្ឌច្បាប់ និយតកម្ម និងស្ថាប័នដែលអំណោយផល)។

២១. ការធានាបានលក្ខខណ្ឌទាំងនេះ គឺវាលើសពីសមត្ថភាពជំនាញរបស់តួអង្គឯកជនតែឯង។ ដូច្នេះហើយ គម្រោង PEARL នឹងបង្កើតលក្ខខណ្ឌទាំងនេះ ដែលតម្រូវឱ្យមានការវិនិយោគមូលធនសង្គម និងស្ថាប័នទូលំទូលាយ ហើយជារឿយៗមានតម្លៃថ្លៃ ដែលជាកត្តាសំខាន់សម្រាប់ភាពជោគជ័យនៃភាពជាដៃគូរវាងរដ្ឋ ឯកជន និងសហគមន៍ ប៉ុន្តែជាធម្មតាតាមទស្សនៈវិស័យឯកជន កិច្ចការនេះមិនត្រូវបានចាត់ទុកថាមិនអាចទទួលបានហិរញ្ញប្បទានសម្រាប់ ការវិនិ យោគ។ តាមរយៈភាពជាដៃគូទាំងនេះ គម្រោង PEARL នឹងលើកកម្ពស់ ការបញ្ជាក់អំពីសុវត្ថិភាពចំណីអាហារ និរន្តរភាព និងសុខុមាលភាពកម្មមួយចំនួនដែលកំពុងដំណើរការនាពេលបច្ចុប្បន្ន (ឧ. ការអនុវត្តកសិកម្មល្អរបស់កម្ពុជា (CamGAP) វិញ្ញាបនប័ត្រសរីរាង្គ, ការសម្គាល់អត្តសញ្ញាណភូមិសាស្ត្រទំនិញ (GI) ការវិភាគកម្រិតគ្រោះថ្នាក់ និងចំណុចត្រួតពិនិត្យសំខាន់ៗ (HACCP)) នៅក្នុងប្រព័ន្ធស្បៀងអាហាររបស់កម្ពុជា ឬមានសក្តានុពល (ឧ. W+)។ ដើម្បីផ្តល់នូវការលើកទឹកចិត្តដោយផ្អែកលើទីផ្សារសម្រាប់ការផ្លាស់ប្តូរទៅភាពធន់នឹងអាកាសធាតុ កសិកម្មដែលមានតម្លៃខ្ពស់ ប្រកបដោយបរិយាប័ន និងនិរន្តរភាព (សូមមើលលទ្ធផល ២.១)។ ដោយសារការចេញវិញ្ញាបនបត្រទាំងនេះផ្តោតជាសំខាន់លើទិដ្ឋភាពអេកូឡូស៊ី សង្គម និងសុវត្ថិភាពចំណីអាហារ គម្រោង PEARL ក៏នឹងគាំទ្រ លើការពិចារណាការដាក់បញ្ចូលហានិភ័យអាកាសធាតុក្នុងដំណើរការចេញវិញ្ញាបនបត្រនេះ ដើម្បីប្រើប្រាស់ទីផ្សារ ជាកត្តា ជំរុញការអនុវត្តកសិកម្មដែលធន់នឹងអាកាសធាតុ។ ការប្រើប្រាស់ដំណើរការចេញវិញ្ញាបនប័ត្រទាំងនេះគឺឆ្លើយតបទៅ នឹងពេលវេលា និងបរិបទ និងមានលក្ខណជាយុទ្ធសាស្ត្រ ដោយសារការកើនចំណាប់អារម្មណ៍សាធារណៈចំពោះអាហារដែលផលិតដោយសុវត្ថិភាព និងនិរន្តរភាពរបស់កម្ពុជា។

២២. គម្រោងនេះនឹងបង្កើតនិន្នាការទីផ្សារនេះ ដើម្បីបង្កើតភាពជាដៃគូយុទ្ធសាស្ត្ររវាងស្ថាប័នរដ្ឋាភិបាល វិស័យឯកជន និងក្រុមអ្នកផលិត។ ដោយឈរលើគោការណ៍ការលើកទឹកចិត្តផ្អែកលើទីផ្សារទាំងនេះ គម្រោង PEARL នឹងលើកកម្ពស់ការទទួលយកនូវបច្ចេកទេស និងបច្ចេកវិទ្យាដែលនឹងផ្តល់តម្លៃខ្ពស់សម្រាប់ផលិតផលកសិកម្ម និង

ប្រកបដោយនិរន្តរភាព រួមទាំងជួយដល់ការកសាងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចក្នុងចំណោមកសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀតដើម្បីគាំទ្រដល់ការផ្លាស់ប្តូររបស់ពួកគេ (លទ្ធផល ២.៣)។

២៣. យន្តការ FARM នឹងបំពេញបន្ថែមដោយផ្ទាល់ដល់សកម្មភាពនេះតាមរយៈការរៀបចំផែនការអាជីវកម្មជាយុទ្ធសាស្ត្រ និង ការផ្តល់ហិរញ្ញប្បទានដើម្បីទទួលយកបច្ចេកវិទ្យា និងបច្ចេកទេសដែលបានកំណត់នៅក្នុងផែនការអាជីវកម្ម។ ជាមួយគ្នានេះដែរ គម្រោង ក៏នឹងលើកកម្ពស់វិធីសាស្ត្រគ្រប់គ្រងទីជម្រាលដែលមានលក្ខណៈចម្រុះ (IWM) ដើម្បីកែលម្អលក្ខខណ្ឌកសិកម្មនៅកម្រិតតំបន់ជាក់លាក់ និងទេសភាព (លទ្ធផល ២.៤)។ សកម្មភាពរបស់ IWM នឹងគាំទ្រដល់សហគមន៍តំបន់ការពារ និងសហគមន៍ព្រៃឈើ នៅក្នុងតំបន់ផ្ទៃរងទឹកភ្លៀងសំខាន់ៗដែលទាក់ទងទៅនឹងផលិតកម្មស្វាយចន្ទី ស្វាយ ស្រូវសរីរាង្គ និងបន្លែ ដើម្បីពង្រឹងកិច្ចខិតខំប្រឹងប្រែងក្នុងការស្តារផ្ទៃរងទឹកភ្លៀង និងការការពារ និងលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគេ។ សកម្មភាពនេះនឹងលើកកម្ពស់ជម្រើសជីវភាពជំនួស (ឧ. ការចិញ្ចឹមឃ្មុំ កសិរុក្ខកម្ម ទេសចរណ៍កសិផល ផលិតកម្មស្រូវសរីរាង្គ និងការបន្ថែមតម្លៃលើអនុផលព្រៃឈើ (NTFPs))។ សកម្មភាពនៅក្រោមលទ្ធផលនេះនឹងដោះស្រាយឧបសគ្គជាមូលដ្ឋានចំនួនបីចំពោះការបន្សាំកសិកម្មទៅនឹងការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ភាគខាងជើងនៃបឹងទន្លេសាប– ចំណេះដឹងមានកម្រិតចំពោះការអនុវត្តសកម្មភាពបន្សុំនឹងការប្រែប្រួលអាកាសធាតុ និងការខ្វះខាតលទ្ធភាពទទួលបានហិរញ្ញវត្ថុ និងបច្ចេកវិទ្យា ដូចដែលបានកំណត់នៅក្នុងផែនការសកម្មភាពអាទិភាពការប្រែប្រួលអាកាសធាតុសម្រាប់ វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ ២០១៦-២០២០ (CCPAP-AFF) (MAFF, 2016) (សូមមើលការពិពណ៌នារកត្តារាំងខាងក្រោម)។ ដោយផ្អែកលើការធ្វើឱ្យប្រសើរឡើងនូវសេវាកម្មប្រឹក្សាផ្នែកកសិឧតុនិយម និងការបង្កើនការយល់ដឹងអំពីហានិភ័យអាកាសធាតុនៅក្នុងលទ្ធផលទី១ លទ្ធផលនេះនឹងអនុញ្ញាតដោយផ្ទាល់ឱ្យមានការផ្លាស់ប្តូររបស់អ្នកទទួលផលទៅ អនុវត្តកសិកម្មដែលធន់នឹងអាកាសធាតុ ផ្តល់តម្លៃខ្ពស់ និងប្រកបដោយនិរន្តរភាព ដោយធ្វើឱ្យមានចំណេះដឹងចាំបាច់ ជំនួយហិរញ្ញវត្ថុ និងបច្ចេកវិទ្យាអាចប្រើប្រាស់បាន។

២៤. លទ្ធផលទី ៣ ផ្តោតលើការធានាបាននូវលក្ខខណ្ឌអំណោយផលដើម្បីធានានាការសម្រេចបានដោយជោគជ័យ លទ្ធផលទី១ និងលទ្ធផលទី ២ ខាងលើ។ កិច្ចខិតខំប្រឹងប្រែងក្នុងលទ្ធផលទី៣នេះ នឹងធានាឱ្យមានលក្ខខណ្ឌចាំបាច់ការរៀបចំស្ថាប័នដើម្បីអនុវត្តកម្មវិធីវិញ្ញាបនប័ត្របញ្ជាក់គុណភាពផលិតផល ដែលជាមធ្យោបាយចម្បងសម្រាប់ការទទួលយកការអនុវត្តកសិកម្មធន់នឹងអាកាសធាតុរបស់កសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀត។ ជាមួយគ្នា នេះដែរ វាក៏លើកកម្ពស់ភាពជាដៃគូរវាងរដ្ឋ ឯកជន និងសហគមន៍ប្រកបដោយប្រសិទ្ធភាព តាមរយៈយន្តការសម្របសម្រួលភាគីពាក់ព័ន្ធថ្នាក់ជាតិ និងខេត្តដែលមានស្រាប់ (លទ្ធផល ៣.១ សូមមើលរូបភាពទី ១)។ យន្តការទាំងនោះរួមមានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (NCSD) គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD) និងវេទិកាសាធារណៈនៅ ថ្នាក់ខេត្ត។ គម្រោងនេះនឹងចាប់ដៃគូជាមួយធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម(ARDB) និងស្ថាប័នហិរញ្ញវត្ថុឯកជន ដើម្បីបង្កើតប្រព័ន្ធពិន្ទុប្រាក់កម្ចី ដោយពិចារណាលើកត្តាភាពធន់នឹងអាកាសធាតុ កត្តាបរិយាប័ន និងកត្តានិរន្តរភាពជាលក្ខណៈវិនិច្ឆ័យសំខាន់ក្នុងការពិនិត្យមើលការស្នើសុំប្រាក់កម្ចី។ ប្រព័ន្ធនេះនឹងជំរុញមិនត្រឹមតែការផ្លាស់ប្តូរជារួមឆ្ពោះទៅរកកសិកម្មដែលធន់នឹងអាកាសធាតុនៅក្នុងវិស័យនេះប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាការផ្លាស់ប្តូរដ៏ត្រឹមត្រូវមួយដោយការបង្កើនលទ្ធភាពរបស់កសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀតក្នុងការទទួលបានហិរញ្ញវត្ថុបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ គម្រោងនេះក៏នឹងបង្កើតប្រព័ន្ធត្រួតពិនិត្យបរិស្ថានវិទ្យាកម្រិតទេសភាព (LAMS) ដើម្បីជំរុញឱ្យកើនឡើងការវិនិយោគសាធារណៈ និងឯកជនក្នុងវិស័យកសិកម្មដែលធន់នឹងអាកាសធាតុ ផ្តល់តម្លៃខ្ពស់ និងមាននិរន្តរភាព (លទ្ធផល ៣.២)។ ប្រព័ន្ធនេះជាប្រព័ន្ធគាំទ្រការសម្រេចចិត្តនិ

យោគដែលផ្អែកលើព័ត៌មានអាកាសធាតុសម្រាប់អ្នកវិនិយោគសាធារណៈ និងឯកជន ដើម្បីជំរុញការវិនិយោគទៅក្នុងការផ្លាស់ប្តូរឆ្ពោះទៅរកភាពធន់នឹងអាកាសធាតុ។ ប្រព័ន្ធ LAMS ក៏នឹងត្រូវបានភ្ជាប់ជាមួយនឹងប្រព័ន្ធទិន្នន័យអាកាសធាតុផ្សេងទៀតដូចជា ប្រព័ន្ធសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ជាតិ (NGHGI) និងប្រព័ន្ធត្រួតពិនិត្យព្រៃឈើជាតិ ដើម្បីគាំទ្រការរាយការណ៍របស់កម្ពុជា ទៅកាន់ UN-FCCC តាមរយៈក្របខ័ណ្ឌពង្រឹងតម្លាភាព (ETF) ក្រោមកិច្ចព្រមព្រៀងប៉ារីសស្តីពីអាកាសធាតុ។ លទ្ធផលរយៈពេលខ្លីទាំងនេះនៅក្រោមលទ្ធផលរយៈពេលវែងនេះនឹងដោះស្រាយឧបសគ្គជាប្រព័ន្ធ និងតាមស្ថាប័ន ដែលរារាំងកិច្ចខិតខំប្រឹងប្រែង រួមគ្នារវាងអាជ្ញាធរសាធារណៈ និងឯកជន និងកម្រិតរដ្ឋាភិបាល ដើម្បីតម្រង់ទិសការវិនិយោគហិរញ្ញវត្ថុ បច្ចេកវិទ្យា និង ធនធានមនុស្សរបស់ពួកគេ ក្នុងការកសាងភាពធន់ក្នុងវិស័យកសិកម្ម ប្រកបដោយបរិយាប័ន និងនិរន្តរភាព ដែលវានឹងនាំ មកវិញនូវការការផ្លាស់ប្តូរដ៏ត្រឹមត្រូវមួយ។

២៥. លទ្ធផលទាំងបីដែលបានពិពណ៌នាខាងលើត្រូវបានកំណត់ដោយផ្អែកលើដំណើរការពិគ្រោះយោបល់ជាមួយភាគី ពាក់ព័ន្ធយ៉ាងទូលំទូលាយ និងការសិក្សាអំពីសមិទ្ធិលទ្ធភាពផ្សេងៗ រួមទាំងការពិនិត្យឡើងវិញលើការវិនិយោគមូលដ្ឋាន និងសកម្មភាពផ្តល់មូលនិធិស្របគ្នា ដើម្បីធានាបាននូវការបំពេញបន្ថែមនៃលទ្ធផលទាំងនេះ និងជាតុចេញ និងសកម្មភាពពាក់ព័ន្ធនានា។

## លទ្ធផលទី ១៖ សមត្ថភាពរបស់កសិករត្រូវបានពង្រឹង ដើម្បីគ្រប់គ្រងផលប៉ះពាល់អាកាសធាតុ និងហានិភ័យដែលពាក់ព័ន្ធ

២៦. លទ្ធផលនេះនឹងផ្តល់ឱ្យកសិករ និងសហគមន៍មូលដ្ឋាននូវលទ្ធភាពទទួលបានសេវាកម្មប្រឹក្សាផ្នែកកសិឧតុនិយមតាមតម្រូវការ និងជាក់លាក់សម្រាប់មុខដំណាំ។ សមាសធាតុនេះក៏នឹងបង្កើនការយល់ដឹងអំពីហានិភ័យអាកាសធាតុក្នុងចំណោមកសិករ និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀត ដើម្បីបង្កើនសមត្ថភាពរបស់ពួកគេក្នុងការកំណត់ និងគ្រប់គ្រងហានិភ័យ និងភាពងាយរងគ្រោះទាក់ទងនឹងអាកាសធាតុទាក់ទងនឹងផលិតកម្មកសិកម្ម ការកែច្នៃ និងជីវភាពរស់នៅរបស់ពួកគេ។ ការបង្កើត និងផ្សព្វផ្សាយព័ត៌មានកសិឧតុនិយម នឹងជំរុញកិច្ចសហការផលិតសេវាកម្មនៅទូទាំងស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងសាទ និងក្រសួងធនធានទឹក និងឧត្តុនិយម ហើយបញ្ចូលសំណុំទិន្នន័យផ្សេងៗ រួមទាំងការព្យាករណ៍អាកាសធាតុ ការព្យាករណ៍តាមសមុទ្រ ប្រតិទិនដំណាំ ផលិតកម្មដំណាំ និងព័ត៌មានប្រមូលផល និងសត្វល្អិត និងព័ត៌មានអំពីជំងឺ។ ទន្ទឹមនឹងនោះ សមាសភាគនេះ ក៏នឹងពង្រឹងសមត្ថភាពសេវាផ្សព្វផ្សាយកសិកម្មជាប្រព័ន្ធទាំងក្នុងវិស័យសាធារណៈ និងឯកជន និងអភិវឌ្ឍភាពជាដៃគូសាធារណៈ និងឯកជនប្រកបដោយប្រសិទ្ធភាព ដើម្បីធានាបាននូវការផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាពនៃព័ត៌មានប្រឹក្សាកសិឧតុនិយមតាមរយៈសមត្ថភាពផ្សព្វផ្សាយ និងពង្រីកការផ្សព្វផ្សាយព័ត៌មានឱ្យដល់អ្នកប្រើ ប្រាស់។

២៧. សេវាកម្មអាកាសធាតុ គឺពាក់ព័ន្ធនឹងការផលិត ការបកប្រែ ការផ្ទេរ និងការប្រើប្រាស់ចំណេះដឹង និងព័ត៌មានអំពីអាកាសធាតុសម្រាប់ការសម្រេចចិត្តទាក់ទងនឹងអាកាសធាតុ រួមទាំងនៅកម្រិតកសិដ្ឋានផងដែរ។ លក្ខណៈសម្បត្តិសំខាន់ៗសម្រាប់សេវាកម្មអាកាសធាតុប្រកបដោយប្រសិទ្ធភាព ដើម្បីបំពេញតម្រូវការរបស់អ្នកប្រើប្រាស់រួមមាន ភាពទាន់ពេលវេលា ភាពងាយស្រួល ភាពជឿជាក់ លទ្ធភាពប្រើប្រាស់ និងសមធម៌។ ឧបសគ្គចម្បងមួយចំនួនចំពោះការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព និងសមធម៌នៃសេវាកម្មអាកាសធាតុគឺ កង្វះសមត្ថភាពសម្រាប់ទំនាក់ទំនង កង្វះខាតសម្ថភាពក្នុងការរៀបចំសេវកម្មដែលឆ្លើយតបតាមតម្រូវការរបស់អ្នកប្រើប្រាស់ ការបកប្រែមិនគ្រប់គ្រាន់នៃសេវាកម្មពាក់ព័ន្ធឱ្យដែលអាចយកមកប្រើប្រាស់ធ្វើសកម្មភាពបាន និងការចូលរួមមានកម្រិតនៃតួអង្គផ្សេងទៀតដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម និងខ្សែច្រវ៉ាក់តម្លៃ (ឯកជននិងសាធារណៈ)។

២៨. ការវាយតម្លៃតម្រូវការសមត្ថភាពដោយផ្អែកលើទស្សនវិស័យសកលរបស់អង្គការ FAO ស្តីពីសេវាកម្មអាកាសធាតុក្នុងវិស័យកសិកម្ម (FAO, 2021) និងគ្របដណ្តប់លើតំបន់សមត្ថភាពចំនួនបួន – (១) ការព្យាករណ៍អាកាសធាតុ និងជលសាស្ត្រ (២) ទិន្នន័យកសិកម្ម (៣) ការព្យាករណ៍អំពីសត្វល្អិតនិងជំងឺ និង (៤) ទំនាក់ទំនង និងការផ្សព្វផ្សាយព័ត៌មានកសិកម្ម - ត្រូវបានធ្វើឡើងក្នុងដំណាក់កាលរៀបចំគម្រោង (សូមមើលឧបសម្ព័ន្ធទី ២)។ ការសិក្សានេះ បង្ហាញពីបញ្ហាប្រឈម និងផ្តល់អនុសាសន៍សកម្មភាពសំខាន់ៗចំនួនប្រាំពីរ ក្រោមក្របខ័ណ្ឌសេវាកម្មអាកាសធាតុ អនុសាសន៍ទាំងនេះត្រូវបានដាក់បញ្ចូលក្នុងដំណោះស្រាយដែលមានក្នុងលទ្ធផលរបស់គម្រោង។

២៩ លទ្ធផល ១.១៖ ភាពមានព័ត៌មាន និងលទ្ធភាពទទួលបានសេវាប្រឹក្សាខាងកសិឧតុនិយម ឆ្លើយតបតម្រូវការតាមខ្សែច្រវ៉ាក់តម្លៃគោលដៅ ត្រូវបានកែលម្អក្នុងចំណោមកសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុក ជាពិសេសកសិករ និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃជាស្ត្រី។

៣០. ដោយផ្អែកលើអនុសាសន៍ខាងលើ លទ្ធផលនេះនឹងផ្តល់នូវប្រព័ន្ធប្រសើរឡើងនៃសេវាប្រឹក្សាផ្នែកកសិឧតុនិយមដែលត្រូវបានកែសម្រួលទៅតាមដំណាំគោលដៅរបស់គម្រោង ដោយគ្របដណ្តបលើអនុសាសន៍សកម្មភាពសំខាន់ៗចំនួនប្រាំពីរខាងលើ។ ទន្ទឹមនឹងនេះ អនុសាសន៍ទាំងនេះដែលដែលពាក់ព័ន្ធនឹងជម្រើសកាត់បន្ថយហានិភ័យជាក់លាក់ណាមួយក្នុងការគ្រប់គ្រងដំណាំនិងការទទួលបានធនធាននឹងត្រូវបានអនុវត្តក្រោមសមាសភាគទី២នៃគម្រោង។ សកម្មភាពនៅក្នុងលទ្ធផលនឹងមាន៖

៣១. សកម្មភាព ១.១.១៖ បង្កើនវិសាលភាពការប្រមូលទិន្នន័យកសិឧតុនិយម និងសមត្ថភាពវិភាគបកស្រាយទិន្នន័យ ដើម្បីផលិតការព្យាករណ៍កសិឧតុនិយម និងសេវាកម្មប្រឹក្សាកសិឧតុនិយមដែលឆ្លើយតបតាមតម្រូវការប្រើប្រាស់ក្នុងខ្សែច្រវ៉ាក់តម្លៃគោលដៅ។

៣២. សកម្មភាព ១.១.២៖ បង្កើតនិតិវិធីប្រតិបត្តិការស្តង់ដារ (SOP) សម្រាប់ការផលិត និងការផ្សព្វផ្សាយសេវាកម្មប្រឹក្សាកសិឧតុនិយម និងតម្រូវការចែករំលែកទិន្នន័យ និងរចនាសម្ព័ន្ធ ដោយផ្តោតលើដំណាំស្វាយចន្ទី ស្វាយ ស្រូវ និងបន្លែ តាមរយៈមធ្យោបាយផ្សេងៗ។

៣៣. សកម្មភាព ១.១.៣៖ បង្កើនការយល់ដឹងអំពីសេវាប្រឹក្សាកសិឧតុនិយម និងអត្ថប្រយោជន៍នៃការអនុវត្តក្នុងការគ្រប់គ្រងដំណាំ និងសកម្មភាពបង្កើនតម្លៃបន្ថែម ដើម្បីគាំទ្រដល់ការសម្រេចចិត្ត និងកាត់បន្ថយភាពងាយរងគ្រោះរបស់កសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀតចំពោះការប្រែប្រួលអាកាសធាតុជាពិសេសកសិករ និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃជាស្ត្រី។

**លទ្ធផលទី ២៖ គាំទ្រកសិករខ្នាតតូច និងសហគ្រាសធុនតូច និងមធ្យម ដើម្បីទទួលយកការអនុវត្តកសិកម្មដែលធន់នឹងអាកាសធាតុ ផ្តល់តម្លៃខ្ពស់ មានភាពចម្រុះ និងនិរន្តរភាព តាមរយៈយន្តការទីផ្សារ។**

៣៤. សមាសភាគនេះ នឹងសម្រេចបាន តាមរយៈលទ្ធផលរយៈពេលខ្លីចំនួនបួនផ្សេងគ្នា ប៉ុន្តែអាស្រ័យគ្នាទៅវិញទៅមក៖

២.១. ការបង្កើនលទ្ធភាពទទួលបានទីផ្សារដែលផ្តល់តម្លៃខ្ពស់តាមរយៈកម្មវិធីបញ្ជាក់គុណភាពផលិតផលកសិកម្ម

២.២. ការបង្កើនលទ្ធភាពទទួលបានហិរញ្ញវត្ថុ និងបច្ចេកវិទ្យាដែលធន់នឹងអាកាសធាតុ និងបច្ចេកវិទ្យាដែលនឹងផ្តល់តម្លៃខ្ពស់សម្រាប់ផលិតផល។

២.៣. ការបង្ហាញ និងការលើកកម្ពស់ការអនុវត្ត និងបច្ចេកវិទ្យាកសិកម្មដែលធន់នឹងអាកាសធាតុ ផ្តល់តម្លៃខ្ពស់ និងមាននិរន្តរភាព និង

២.៤. ធ្វើឱ្យប្រសើរឡើងប្រព័ន្ធអេកូឡូស៊ីនៅកម្រិតទេសភាព។

**លទ្ធផល ២.១៖ ឱកាសទទួលបានទីផ្សារពិសេសសម្រាប់កសិករ និងអ្នកកែច្នៃស្វាយចន្ទី ស្វាយ ស្រូវសរីរាង្គ និងបន្លែបានកើនឡើងតាមរយៈកម្មវិធីវិញ្ញាបនប័ត្របញ្ជាក់គុណភាពផលិតផលដែលធន់នឹងអាកាសធាតុ និងមានតម្លៃខ្ពស់**

៣៥. ការសិក្សាដើមគ្រា និងសមិទ្ធិលទ្ធភាពដោយ IRAM (2018) និង ICEM (2020) លើកម្មវិធីវិញ្ញាបនបត្រកសិកម្ម និងខ្សែច្រវ៉ាក់តម្លៃដែលធន់នឹងអាកាសធាតុបានកំណត់ និងពិនិត្យមើលឱកាស និងបញ្ហាសេដ្ឋកិច្ច សង្គម និងអេកូឡូស៊ីដែលទាក់ទងនឹងដំណាំមានសក្តានុពលផ្តល់តម្លៃខ្ពស់ និងខ្សែច្រវ៉ាក់តម្លៃរបស់វា។ ដោយផ្អែកលើព័ត៌មាននិងការវិភាគពីការសិក្សាទាំងនេះ (ឧបសម្ព័ន្ធទី ២ នៃសំណើគម្រោង) និងពីការពិគ្រោះយោបល់ពីភាគីពាក់ព័ន្ធជាបន្តបន្ទាប់ (ឧបសម្ព័ន្ធទី ៧ នៃសំណើគម្រោង) គម្រោង PEARL ផ្តោតលើដំណាំចំនួនបួនមុខ៖ ១) ស្រូវនៅខេត្តព្រះវិហារ ២) ស្វាយនៅខេត្តឧត្តរមានជ័យ ៣) ស្វាយចន្ទីនៅខេត្តកំពង់ធំ និងព្រះវិហារ និង ៤) បន្លែស្លឹកនៅខេត្តសៀមរាប ជាមធ្យោបាយសម្រាប់លើកកម្ពស់កសិកម្មដែលធន់នឹងអាកាសធាតុ និងមាននិរន្តរភាព តាមរយៈកម្មវិធីវិញ្ញាបនប័ត្របញ្ជាក់គុណភាពផលិតផលតំបន់ភាគខាងជើងនៃបឹងទន្លេសាប។

៣៦. កម្មវិធីវិញ្ញាបនប័ត្រកសិកម្មដែលត្រូវបានពិនិត្យក្នុងការសិក្សាទាំងនេះរួមមាន ការសម្គាល់អត្តសញ្ញាណភូមិសាស្ត្រទំនិញ (GIs) វិញ្ញាបនប័ត្រសរីរាង្គ ការអនុវត្តកសិកម្មល្អនៅកម្ពុជា (CamGAP) ការវិភាគកម្រិតគ្រោះថ្នាក់ និងចំណុចត្រួតពិនិត្យសំខាន់ៗ (HACCP) និង ISO 22000។ ឱកាសសំខាន់ៗ ដែលមានស្រាប់សម្រាប់ស្រូវសរីរាង្គក្នុងខេត្តព្រះវិហារ និងស្វាយចន្ទីសរីរាង្គ ឬអនុវត្តតាមស្តង់ដាការអនុវត្តកសិកម្មល្អ ក្នុងខេត្តកំពង់ធំ និងផ្នែកខ្លះនៃព្រះវិហារ ស្វាយក្នុងខេត្តឧត្តរមានជ័យ និងបន្លែស្លឹកនៅខេត្តសៀមរាប។

៣៧. ទោះបីជាយ៉ាងណាក៏ដោយ ដោយសារការវិវឌ្ឍយ៉ាងឆាប់រហ័សនៃនិន្នាការទីផ្សារ ការជ្រើសរើសកម្មវិធីវិញ្ញាបនបត្រណាមួយដែលស្របគ្នា សម្រាប់ប្រើប្រាស់ក្នុងលទ្ធផលនេះ នឹងត្រូវធ្វើឡើងនៅនៅពេលគម្រោងចាប់ផ្តើមអនុវត្ត ដោយផ្អែកលើដំណើរការអភិវឌ្ឍយុទ្ធសាស្ត្រជាក់លាក់មួយ រួមទាំងការវិភាគភាពសមស្របទីផ្សារផងដែរ។ កម្មវិធីវិញ្ញាបនបត្រ បញ្ជាក់គុណភាពផលិតផលកសិកម្មផ្សេងៗទៀត អាចត្រូវបានពិចារណានៅដំណាក់កាលនេះផងដែរ។

៣៨. ដោយឈរលើឱកាស កម្មវិធីវិញ្ញាបនប័ត្របញ្ជាក់គុណភាពផលិតផលកសិកម្មជាក់លាក់ នៅក្នុងខេត្តនីមួយៗ គម្រោងPEARL នឹងចាប់ផ្តើមដំបូង ដោយបង្កើតគណៈកម្មការខ្សែច្រវ៉ាក់តម្លៃ ដើម្បីបង្កើតផែនទីបង្ហាញផ្លូវនៅថ្នាក់ខេត្ត ដើម្បីផ្តល់ផ្គងដំណាំគោលដៅជាមួយនឹងកម្មវិធីវិញ្ញាបនបត្រដែលសមស្របបំផុតសម្រាប់ការលើកកម្ពស់កសិកម្មដែលមានតម្លៃខ្ពស់ និងធន់នឹងអាកាសធាតុ។ ដោយផ្អែកលើផែនទីបង្ហាញផ្លូវ គម្រោង នឹងគាំទ្រដល់ សហគមន៍កសិកម្ម សមាគមកសិករ និងក្រុមផលិត សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ និងសហជីពកសិកម្មក្នុងការរៀបចំ និងអនុវត្តផែនការអាជីវកម្មដែលធន់នឹងអាកាសធាតុសម្រាប់ដំណាំជាក់លាក់។ នេះនឹងត្រូវបានរួមបញ្ចូលជាមួយនឹងការបណ្តុះបណ្តាលកសិករទទួលផល និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀត ដើម្បីបង្កើតចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងអាជីវកម្ម និងជំនាញសហគ្រិន និងអ្នកផ្តល់សេវាបន្ថែម ដើម្បីគាំទ្រដល់ការអនុវត្តផែនទីបង្ហាញផ្លូវ និងផែនការអាជីវកម្ម។ គម្រោងនេះក៏នឹងបង្កើតភាពជាដៃគូផ្ទាល់ជាមួយម្ចាស់ជើងឯក SMEs និងពាណិជ្ជករ/អ្នកនាំចេញ ដើម្បីពន្លឿនដំណើរការផ្លាស់ប្តូរ។ ដូចគ្នានេះផងដែរ គោលការណ៍ណែនាំ និងឧបករណ៍បន្ថែមនឹងត្រូវបានបង្កើតឡើង ដើម្បីធានាថា វិញ្ញាបនប័ត្រដែលបានជ្រើសរើស រួមបញ្ចូលហានិភ័យ និងផលប៉ះពាល់នៃអាកាសធាតុឱ្យបានគ្រប់គ្រាន់។

**៣៩. សកម្មភាពនឹងរួមបញ្ចូល៖ សកម្មភាពនៅក្រោមលទ្ធផល ២.១. (សូមមើលផ្នែក ង.៦. សម្រាប់ព័ត៌មានលម្អិតកម្រិតអនុសកម្មភាព)**

៤០. ដោយឈរលើឱកាស កម្មវិធីវិញ្ញាបនប័ត្របញ្ជាក់គុណភាពផលិតផលកសិកម្មជាក់លាក់ នៅក្នុងខេត្តនីមួយៗ គម្រោងPEARL នឹងចាប់ផ្តើមដំបូង ដោយបង្កើតគណៈកម្មការខ្សែច្រវ៉ាក់តម្លៃ ដើម្បីបង្កើតផែនទីបង្ហាញផ្លូវនៅថ្នាក់ខេត្ត ដើម្បីផ្តល់ដំណាំគោលដៅជាមួយនឹងកម្មវិធីវិញ្ញាបនបត្រដែលសមស្របបំផុតសម្រាប់ការលើកកម្ពស់កសិកម្មដែលមានតម្លៃខ្ពស់ និងធន់នឹងអាកាសធាតុ។ ដោយផ្អែកលើផែនទីបង្ហាញផ្លូវ គម្រោង នឹងគាំទ្រដល់ សហគមន៍កសិកម្ម សមាគមកសិករ និងក្រុមផលិត សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ និងសហជីពកសិកម្មក្នុងការរៀបចំ និងអនុវត្តផែនការអាជីវកម្មដែលធន់នឹងអាកាសធាតុសម្រាប់ដំណាំជាក់លាក់។ នេះនឹងត្រូវបានរួមបញ្ចូលជាមួយនឹងការបណ្តុះបណ្តាលកសិករទទួលផល និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀត ដើម្បីបង្កើតចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងអាជីវកម្ម និងជំនាញសហគ្រិន និងអ្នកផ្តល់សេវាបន្ថែម ដើម្បីគាំទ្រដល់ការអនុវត្តផែនទីបង្ហាញផ្លូវ និងផែនការអាជីវកម្ម។ គម្រោងនេះក៏នឹងបង្កើតភាពជាដៃគូផ្ទាល់ជាមួយម្ចាស់ជើងឯក SMEs និងពាណិជ្ជករ/អ្នកនាំចេញ ដើម្បីពន្លឿនដំណើរការផ្លាស់ប្តូរ។ ដូចគ្នានេះផងដែរ គោលការណ៍ណែនាំ និងឧបករណ៍បន្ថែមនឹងត្រូវបានបង្កើតឡើង ដើម្បីធានាថា វិញ្ញាបនប័ត្រដែលបានជ្រើសរើស រួមបញ្ចូលហានិភ័យ និងផលប៉ះពាល់នៃអាកាសធាតុឱ្យបានគ្រប់គ្រាន់។

៤១. សកម្មភាព ២.១.១៖ បង្កើត និងដាក់ឱ្យដំណើរការផែនទីបង្ហាញផ្លូវស្តីពីតួអង្គក្នុងខ្សែច្រវ៉ាក់អន្តរតម្លៃនៅថ្នាក់ខេត្ត និងផែនការសកម្មភាព/អាជីវកម្មសម្រាប់ការអភិវឌ្ឍខ្សែច្រវ៉ាក់តម្លៃដែលផ្តល់តម្លៃខ្ពស់ និងធន់នឹងអាកាសធាតុបរិយាប័ន្ន ព្រមទាំងឆ្លើយតបនឹងយេនឌ័រ និងកំណត់កម្មវិធីវិញ្ញាបនបត្រជាក់លាក់ជាយាន្ត។

៤២. សកម្មភាព ២.១.២៖ បង្កើតការណែនាំបន្ថែម ឧបករណ៍ និងសម្ភារៈបណ្តុះបណ្តាលដោយស្ម័គ្រចិត្ត ដើម្បីពិចារណាពីហានិភ័យអាកាសធាតុ និងយុទ្ធសាស្ត្រជាក់លាក់សម្រាប់កម្មវិធីវិញ្ញាបនបត្រដែលបានកំណត់នៅក្រោមសកម្មភាព ២.១.១។ (ឧ. CamGap, GI និងសរីរាង្គសម្រាប់ផលិតកម្ម និង ISO 2200 និង HACCP សម្រាប់ការកែច្នៃ) សម្រាប់ខ្សែច្រវ៉ាក់តម្លៃគោលដៅ (ការភ្ជាប់ទៅសកម្មភាព ៣.១.១. ពាក់ព័ន្ធនឹងក្របខណ្ឌគោល នយោបាយ បទដ្ឋានគតិយុត្តិ និងការរៀបចំស្ថាប័នទាក់ទងនឹងកម្មវិធីវិញ្ញាបនប័ត្រទាំងនេះ។

**លទ្ធផល ២.២៖ លទ្ធភាពទទួលបានហិរញ្ញវត្ថុ និងបច្ចេកវិទ្យាកសិកម្មធន់នឹងអាកាសធាតុ និងការអភិវឌ្ឍខ្សែច្រវ៉ាក់តម្លៃ ត្រូវបានធ្វើឱ្យប្រសើរឡើងក្នុងចំណោមកសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀតជាពិសេសកសិករ និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃជាស្ត្រី។**

៤៣. នៅក្រោមយន្តការ FARM ក្រុមអ្នកទទួលផលនីមួយៗនឹងបង្កើតគណនីមូលនិធិ FARM ជាមួយស្ថាប័នហិរញ្ញវត្ថុក្នុងស្រុក។ គម្រោង នឹងស្វែងរកស្ថាប័នហិរញ្ញវត្ថុជាដៃគូសម្រាប់ការរៀបបង្កើតគណនីមូលនិធិ FARM ជាមួយក្រុមអ្នកទទួលផលនីមួយៗ។ ការទូទាត់សងដែលធ្វើឡើងដោយក្រុមអ្នកទទួលផលនីមួយៗនឹងត្រូវធ្វើឡើងនៅក្នុងមូលនិធិ FARM របស់ខ្លួន។ ក្រុមប្រឹក្សាភិបាលមូលនិធី FARM នឹងត្រួតពិនិត្យការបញ្ចេញមូលនិធិ។ ដូចបង្ហាញក្នុងរូបភាពទី ២ ការចំណាយនឹងត្រូវបានប្រើដើម្បីជំរុញការអនុវត្តផែនការអាជីវកម្មដែលធន់នឹងអាកាសធាតុ និងដំណាំជាក់លាក់របស់ពួកគេ។ ការសម្រេចចិត្តដកប្រាក់នឹងត្រូវបានធ្វើឡើងដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ/ការត្រួតពិនិត្យគុណភាពដែលបង្កើតឡើងដោយគម្រោង PEARL រួមទាំងភាពធន់នឹងអាកាសធាតុ កសិកម្មដែលមានតម្លៃខ្ពស់ ការឆ្លើយតបយេនឌ័រ និងសមធម៌ ដើម្បីធានាថាមូលនិធិនឹងគាំទ្រដោយផ្ទាល់ដល់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងកិច្ចខិតខំប្រឹងប្រែងផ្សេងដែលពាក់ព័ន្ធ។ ក្រុមអ្នកទទួលផលក៏អាចប្រើប្រាស់មូលនិធិ FARM ជាវត្ថុបញ្ចាំ

ដើម្បីទទួលបាននូវផលិតផលកម្ចីស្តង់ដារ មីក្រូហិរញ្ញវត្ថុ និងកម្ចីកសិកម្ម។ គម្រោង ក៏នឹងធានាថា ការអនុវត្តកសិកម្ម និងផែនការអាជីវកម្មបំពេញ បន្ថែមផែនការអភិវឌ្ឍ និងផែនការវិនិយោគឃុំ (CDPs និង CIPs) ដើម្បីជួយដល់ការកសាងភាពធន់នឹងអាកាសធាតុ នៅកម្រិតមូលដ្ឋាន និងជំរុញបន្ថែមការចំណាយសាធារណៈ និងការវិនិយោគឯកជន។




*រូបភាពទី 2. ដំណាក់កាលនៃយន្តការកសាងភាពធន់ក្នុងវិស័យកសិកម្មដែលដឹកនាំដោយកសិករ (FARM)*

៤៤. លើសពីនេះ គម្រោង PEARL នឹងធ្វើការជាមួយអ្នកផ្តល់សេវាធានារ៉ាប់រងឈានមុខគេរបស់ប្រទេស (ឧ. ក្រុមហ៊ុនធានារ៉ាប់រង Forte) និងកម្មវិធីជាតិធានារ៉ាប់រងកសិកម្ម ដែលដឹកនាំដោយ ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងសាទ ដើម្បីស្វែងរកជម្រើសធានារ៉ាប់រងហានិភ័យបន្ថែម ជាពិសេសសម្រាប់ដំណាំស្វាយចន្ទី ស្វាយ និងបន្លែ។ បច្ចុប្បន្ននេះ ពួកគេមិនមានឱកាសច្រើនក្នុងការការពារខ្លួនពីហានិភ័យនៃការបាត់បង់។ គម្រោង ក៏នឹងបង្កើនការយល់ដឹងរបស់អ្នកទទួលផលអំពីផលិតផលជំនួយហិរញ្ញវត្ថុដែលមាន ដើម្បីកែលម្អលទ្ធភាពទទួលបានហិរញ្ញវត្ថុរបស់ពួកគេ។

៤៥. សកម្មភាព ២.២.១៖ បង្កើតយន្តការហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត គឺយន្តការ FARM សម្រាប់ សហគមន៍កសិកម្ម សមាគមកសិករ និងក្រុមផលិត សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ និងសហជីពកសិកម្ម ដើម្បីជួយដល់សមាជិករបស់ពួកគេទៅអនុវត្តសិកម្មធន់នឹងអាកាសធាតុ និងមានតម្លៃខ្ពស់ ប្រកបដោយបរិយាប័ន និង ឆ្លើយតបនឹងយេនឌ័រ។

៤៦. សកម្មភាព ២.២.២៖ សិក្សាវាយតម្លៃលទ្ធភាពនៃការបង្កើតជម្រើសហិរញ្ញវត្ថុកាត់បន្ថយហានិភ័យ សម្រាប់អ្នកផលិតស្វាយចន្ទី ស្វាយ និងបន្លែ ជាពិសេសកសិករជាស្ត្រី។

៤៧. សកម្មភាព ២.២.៣៖ លើកកម្ពស់ជាលក្ខណប្រព័ន្ធ ចំពោះយល់ដឹងអំពីផលិតផល និងសេវាកម្មជំនួយហិរញ្ញវត្ថុដែលមានស្រាប់ ក្នុងចំណោមកសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុក ជាពិសេសកសិករ និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃជាស្ត្រី។

**លទ្ធផល ២.៣៖ ការយល់ដឹង និងចំណេះដឹងអំពីកសិកម្មធន់នឹងអាកាសធាតុ ផ្តល់តម្លៃខ្ពស់ និងមាននិរន្តរភាព បានកើនឡើងក្នុងចំណោមកសិករ និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀត ជាពិសេសកសិករ និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃជាស្ត្រី**

៤៨. តារាងទី ១ បង្ហាញពីវិធានការសន្សាំជាក់លាក់សម្រាប់មុខដំណាំ ដែលត្រូវបានពិពណ៌នាបន្ថែមនៅក្នុងឧបសម្ព័ន្ធទី ២ និងការសិក្សាអំពីសនិទានភាពអាកាសធាតុ (ដកស្រង់ពីការវិភាគរបស់អង្គការ FAO)។ នៅក្រោមលទ្ធផលនេះ គម្រោង PEARL នឹងលើកកម្ពស់វិធានការទាំងនេះដោយភ្ជាប់ជាមួយនឹងសេវាកម្មប្រឹក្សាកសិឧតុនិយមដែលបានធ្វើឱ្យប្រសើរឡើង និងការយល់ដឹងអំពីហានិភ័យក្នុងចំណោមអ្នកទទួលផលក្រោមលទ្ធផល ១.១។ វិធានការទាំងនេះជាច្រើនដែលបានបង្ហាញនៅក្រោមលទ្ធផលនេះនឹងត្រូវបានដំណើរការពេញលេញជាផ្នែកនៃផែនការអាជីវកម្មក្រោមលទ្ធផល ២.១ និងផ្តល់ហិរញ្ញប្បទានក្នុងយន្តការ FARM ក្រោមលទ្ធផល ២.២។

**តារាងទី 1. វិធានការដាក់លាក់សម្រាប់មុខដំណាំដើម្បីកសាងភាពធន់នឹងអាកាសធាតុ និងផ្តល់តម្លៃខ្ពស់**

| ដំណាក់កាល | វិធានការសមស្របតាមអាកាសធាតុដែលបានណែនាំ/ភាពធន់ (បញ្ជីមិនគ្រប់ជ្រុងជ្រោយ) | | | |
|---|---|---|---|---|
| | ស្រូវសរីរាង្គ | ស្វាយចន្ទី | ស្វាយ | បន្លែស្លឹក |
| ការរៀបចំដី/ការគ្រប់គ្រង | • ផ្តល់សេវាកម្មអាកាសធាតុត្រឹមត្រូវ និងទាន់ពេលវេលា មុនពេលមានភ្លៀងធ្លាក់។<br>• លើកកម្ពស់ការអនុវត្តមនរំខានដល់ដីដូចជាការភ្ជួររាស់អប្បបរមា ការណែនាំឱ្យដាំដំណាំគម្របដីចាប់អាសូតជាដើម។<br>• លើកកម្ពស់ការពង្រាបដីដោយឡាស៊ែរ នៅកន្លែងសមស្របដើម្បីកាត់បន្ថយតម្រូវការទឹក។ | • គាំទ្រផែនការគ្រប់គ្រងសហគន៍ព្រៃឈើ/សហគមន៍តំបន់ការពារធម្មជាតិ ដើម្បីស្តារគម្របព្រៃឈើបឋម និងព្រៃបម្រុងឡើងវិញ ជាមួយនឹងការគាំទ្រ កសិរុក្ខកម្ម និងសកម្មភាពចិញ្ចឹមជីវិតផ្សេងទៀត (ឧ. អនុផលព្រៃឈើ ការចិញ្ចឹមឃ្មុំ កសិទេសចរណ៍)។<br>• ទប់ស្កាត់មិនឱ្យមានការពង្រីកកសិកម្មចូលទៅក្នុងតំបន់ព្រៃឈើ។<br>• លើកកម្ពស់ការធ្វើដំណាំចម្រុះ (ឧ. ជាមួយសណ្តែកដី)។ | • គាំទ្រផែនការគ្រប់គ្រង សហគន៍ព្រៃឈើ/សហគមន៍តំបន់ការពារធម្មជាតិ ដើម្បីស្តារគម្របព្រៃឈើបឋម និងព្រៃបម្រុងឡើងវិញជាមួយនឹងការគាំទ្រ កសិរុក្ខកម្ម និងសកម្មភាពចិញ្ចឹមជីវិតផ្សេងទៀត (ឧ. អនុផលព្រៃឈើ ការចិញ្ចឹមឃ្មុំ កសិទេសចរណ៍)។<br>• ទប់ស្កាត់មិនឱ្យមានការពង្រីកកសិកម្មចូលទៅក្នុងតំបន់ព្រៃឈើ។<br>• លើកកម្ពស់ការពង្រីកពឹងផ្អែកលើព័ត៌មានអំពីអាកាសធាតុ ដើម្បីកាត់បន្ថយគ្រោះទឹកជំនន់ហ៊េស និងការបាក់ដី។ | • លើកកម្ពស់ការអនុវត្តសាកវប្បកម្មល្អ (ឧ. ការប្រើប្រាស់ចំបើងគម្របដីដើម្បីកាត់បន្ថយការហួត ) និងដើម្បីកាត់បន្ថយការបាត់បង់សំណើមដី និងការខូចខាតបង្ករដោយជនទឹក។ |

| | | | | |
|---|---|---|---|---|
| **គ្រាប់ពូជ/ពូជ និងការបណ្ដុះគ្រាប់ពូជ** | • លើកកម្ពស់ការផ្គត់ផ្គង់គ្រាប់ពូជដែលមានគុណភាព និងការធ្វើតេស្តគ្រាប់ ពូជ។<br>• ផ្តល់ព័ត៌មានកសិឧតុនិយមជាក់លាក់ជាក់លាក់ (ឧ.ប្រតិទិនដាំដុះដែលផ្អែកលើព័ត៌មានអាកាសធាតុ)។<br>• លើកកម្ពស់ការប្រើប្រាស់ពូជ ដែលធន់នឹងស្រ្គេស មានអាយុកាលខ្លី (មានក្លិនក្រអូប)។<br>• ជំរុញករប្រើប្រាស់គ្រឿងយន្ត -សម្រាប់ការសាបព្រួស និងការស្ទូង និងប្រ់ប្រាស់ជាតុផ្សំ មួយចំនួននៃប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ។ | • ផ្សព្វផ្សាយពូជក្នុងស្រុកដែលធន់នឹងគ្រោះរាំងស្ងួត សត្វល្អិត និងជំងឺ។ | • គាំទ្រការគ្រប់គ្រងទឹក និងរចនាសម្ព័ន្ធមីក្រូជារាសាស្ត្រសម្រាប់បណ្តុះកូន។ | • គាំទ្រដល់ការផលិត ការផ្សព្វផ្សាយ និងការយល់ដឹងអំពីគ្រាប់ពូជ/ពូជដែលធន់នឹងអាកាសធាតុ។ |

| | | | | |
|---|---|---|---|---|
| **ផលិតកម្ម/ការចេញផ្កា** | <u>**រដូវវស្សា**</u><br>• វិនិយោគលើការប្រើប្រាស់បច្ចេកវិទ្យាសន្សំសំចៃទឹកកាន់តែទូលំទូលាយ និងកំណត់ពេលវេលាសមស្របសម្រាប់ស្រោចស្រព<br>• គាំទ្រការដាំដុះពូជស្រាលនៅតំបន់ភាគខាងកើត និងខាងជើង ឧ.ខេត្តព្រះវិហារ<br><br><u>**រដូវប្រាំង(ជម្រើស)**</u><br>• វិនិយោគលើតម្រូវការប្រព័ន្ធធារាសាស្ត្ររបស់អ្នកផលិតស្រូវរដូវប្រាំង រួមទាំងការផ្តល់ប្រឹក្សាដល់កសិករក្នុងការដាំដុះស្រូវរដូវប្រាំង។<br>• ផ្តល់ការប្រឹក្សាយោបល់ចំពោះការប្រើប្រាស់និងគ្រប់គ្រងទឹកតាមតម្រូវការ ដោយផ្សាភ្ជាប់ជាមួយសេវាកសិឧតុនិយម។ | <u>**ការចេញផ្កា**</u><br>• ផ្តល់សេវាកម្មអាកាសធាតុដែល ឆ្លើយតបនឹងតម្រូវការដោយផ្អែកលើប្រតិទិនដាំដុះ និងដំណាក់ កាលសំខាន់ៗរបស់ដំណាំដើម្បីការពារការខូចខាត។<br>• ផ្តល់ការបណ្តុះបណ្តាលកម្រិតកសិករ /សាលារៀនស្រែកសិករ ស្តីពីការគ្រប់គ្រងសត្វល្អិតនិងជំងឺលើដំណាំ ស្វាយចន្ទីឧ វិធានការ IPM ដោយបញ្ចូលចំណេះដឹងបែបប្រពៃណី។<br>• ផ្តល់ការបណ្តុះបណ្តាលកម្រិតកសិករ /សាលារៀនស្រែកសិករ ស្តីពីការគ្រប់គ្រងសត្វល្អិតនិងជំងឺលើដំណាំ ស្វាយចន្ទីឧ វិធានការ IPM ដោយបញ្ចូលចំណេះដឹងបែបប្រពៃណី។ | **ការចេញផ្កា**<br>• ផ្តល់ការបណ្តុះបណ្តាលកម្រិតកសិករ /សាលារៀនស្រែកសិករ ស្តីពីការគ្រប់គ្រងសត្វល្អិត និងជំងឺលើដំណាំ ស្វាយចន្ទីឧ វិធានការIPMដោយបញ្ចូលចំណេះដឹងបែបប្រពៃណី។<br>• ផ្តល់សេវាកម្មអាកាសធាតុដែលឆ្លើយតបនឹងតម្រូវការដោយផ្អែកលើប្រតិទិនដាំដុះ និងដំណាក់ កាលសំខាន់ៗរបស់ដំណាំដើម្បីការពារការខូចខាត។<br>**ការចេញផ្លែឈើ**<br>• ផ្តល់សេវាកម្មអាកាសធាតុដែលឆ្លើយតបនឹងតម្រូវការដោយផ្អែកលើប្រតិទិនដាំដុះ និងដំណាក់ កាលសំខាន់ៗរបស់ដំណាំដើម្បីការពារការខូចខាត | • ផ្សព្វផ្សាយផលិតកម្មពេញមួយឆ្នាំដោយផ្អែកលើលទ្ធផលទទួលបានពីម៉ូដែល (AquaCrop) ដើម្បីបង្កើនទិន្នផល និងដោះស្រាយបញ្ហាផលិតកម្មតាមរដូវកាល។<br>• ប្រើប្រាស់ Salt Models សម្រាប់ការប៉ាន់ប្រមាណឥទ្ធិពលនៃជាតិប្រៃលើការលូតលាស់របស់រុក្ខជាតិ។<br>• ផ្សព្វផ្សាយពូជដែលមានវដ្តខ្លីដើម្បីកាត់បន្ថយស្ត្រេសនឹងកំដៅនៅដំណាក់កាលសំខាន់ៗ និងកាត់បន្ថយតម្រូវការទឹកដំណាំ។<br>• លើកកម្ពស់ប្រព័ន្ធកសិរុក្ខកម្ម ដើម្បីកាត់បន្ថយហែួតដោយសារពន្លឺព្រះអាទិត្យ និងកាត់បន្ថយតុណ្ហភាពខ្យល់ និងនៅលើផ្ទៃដី។<br>• ផ្សព្វផ្សាយការដាំដុះ ក្នុងផ្ទះសំណាញ់ ដើម្បីកាត់បន្ថយភាពស្ត្រេសនឹងកំដៅ។ |

| | | | | |
|---|---|---|---|---|
| ធាតុចូល | • ពង្រឹងសមត្ថភាពផ្នែកផ្សព្វផ្សាយកសិកម្មសម្រាប់ការផ្តល់ការណែនាំ និងការបណ្តុះបណ្តាលពាក់ព័ន្ធដល់កសិករ។<br>• ផ្តល់ការណែនាំអំពីដីដោយផ្អែកលើប្រភេទដី។<br>• បង្កើនសមត្ថភាពផលិត ការទទួលបាន និងការប្រើប្រាស់ដីដែលសមស្រប រួមទាំងដីសរីរាង្គ។<br>• បង្កើនសមត្ថភាពអភិបាលកិច្ច រួមទាំងការត្រួតពិនិត្យគុណភាពនៃសហគមន៍កសិកម្ម និងសហជីព ដើម្បីធានាបាននូវលក្ខខណ្ឌអំណោយផលសម្រាប់ការទទួលយកការអនុវត្តកសិកម្មធន់នឹងអាកាសធាតុ និងមាននិរន្តរភាព។ | • ពង្រឹងសមត្ថភាពផ្នែកផ្សព្វផ្សាយកសិកម្មសម្រាប់ ការផ្តល់ការណែនាំ និងការបណ្តុះបណ្តាលពាក់ព័ន្ធដល់កសិករ (ឧ. ការប្រើ ប្រាស់ជាតុចូលគីមីកសិកម្មសមស្រប)<br>• បង្កើតយន្តការសម្របសម្រួល វិស័យសាធារណៈ និងឯកជន ដើម្បីលើកកម្ពស់ការត្រួតពិនិត្យការដាក់ស្លាកផលិតផលកសិកម្មដោយប្រើប្រាសជាតុចូលគីមី យកម្មវិធីសមស្រប និងផលិតផលដែលប្រើប្រាស់ជាតុចូលគីមីកសិកម្មកម្រិតតិចតួច។ | • ពង្រឹងសមត្ថភាពផ្នែកផ្សព្វផ្សាយកសិកម្មសម្រាប់ការផ្តល់ការណែនាំនិងការបណ្តុះបណ្តាលពាក់ព័ន្ធដល់កសិករ (ឧ. ការប្រើ ប្រាស់ជាតុចូលគីមីកសិកម្មសមស្រប)។<br>• បង្កើតយន្តការសម្របសម្រួលវិស័យសាធារណៈ-លីគ-ឯកជន ដើម្បីលើកកម្ពស់ការដាក់ស្លាក ផលិតផលកសិ-គីមីដែលត្រូវបានត្រួតពិនិត្យដោយកម្មវិធីសមស្របនិងកម្រិតតិចតួចនៃកម្មវិធីកសិកម្មគីមី។ | • ពង្រឹងសមត្ថភាពផ្នែកផ្សព្វផ្សាយកសិកម្មសម្រាប់ការផ្តល់ការណែនាំនិងការបណ្តុះបណ្តាលពាក់ព័ន្ធដល់ កសិករ (ឧ. ការប្រើ ប្រាស់ជាតុចូលគីមីកសិកម្មសមស្រប)<br>• បង្កើនល្បឿនផលិតកម្មជីសរីរាង្គនិងលទ្ធភាពប្រើប្រាស់ រួមទាំងឡជីវឧស្ម័ន<br>• បង្កើតយន្តការសម្របសម្រួលវិស័យសាធារណៈ-លីគ-ឯកជន ដើម្បីលើកកម្ពស់ការដាក់ស្លាកផលិតផលកសិ-គីមីដែលត្រូវបានត្រួតពិនិត្យដោយកម្មវិធីសមស្រប និងកម្រិតតិចតួចនៃកម្មវិធីកសិកម្មគីមី។ |

| | | | | |
|---|---|---|---|---|
| ការគ្រប់ គ្រងកត្តាចង្រៃ | • វិនិយោគលើការធ្វើម៉ូដែល និង ការស្រាវជ្រាវ និងអភិវឌ្ឍន៍ពាក់ព័ន្ធនឹងកត្តាចង្រៃ និងជំងឺលើដំណាំស្រូវ ដើម្បីបង្កើនការយល់ដឹងអំពីហានិភ័យនៅតាមតំបន់នានា។<br>• ផ្សព្វផ្សាយការអនុវត្ត IPM ដែលភ្ជាប់ទៅនឹងការផ្តល់សេវាកសិឧតុនិយមតាមតម្រូវការ។<br>• កែលម្អការព្យាករណ៍ និងការប្រកាសឱ្យដឹងមុនអំពីសត្វល្អិត និងជំងឺ និងផ្តល់ប្រឹក្សាយោបល់។ | • ធ្វើការស្រាវជ្រាវ និងប្រមូលទិន្នន័យអំពីសត្វល្អិត និងជំងឺសំខាន់ៗលើស្វាយចន្ទី ដើម្បីរៀបចំបង្កើតវិធានការ IPM ដែលសមស្រប ក្នុងការគ្រប់គ្រងកត្តាចង្រៃនិងជំងឺទាំងនេះ។<br>• ពង្រឹងសេវាកម្មផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការអនុវត្ត IPM ការអនុវត្តដែលពឹងផ្អែកលើព័ត៌មានអាកាសធាតុ និងការគ្រប់គ្រងហានិភ័យដោយប្រើប្រាស់ សេវាកសិឧតុនិយម។<br>• ផ្សព្វផ្សាយពូជ "ប្រពៃណី" ក្នុងស្រុក ដែលធន់នឹងសត្វល្អិតនិងជំងឺ។<br>• កែលម្អការព្យាករណ៍ និងការប្រកាសឱ្យដឹងមុនអំពីសត្វល្អិត និងជំងឺ និងផ្តល់ប្រឹក្សាយោបល់។<br>• ជំនួសការប្រើប្រាស់ថ្នាំសំលាប់ស្មៅដោយដាំស្មៅស្ទីឡូជាចំណីគោក្របី។ | • ធ្វើការស្រាវជ្រាវ និង ប្រមូលទិន្នន័យអំពីសត្វល្អិត និងជំងឺសំខាន់ៗលើស្វាយចន្ទី ដើម្បី រៀបចំបង្កើតវិធានការ IPM ដែលសមស្របក្នុងការគ្រប់គ្រងកត្តាចង្រៃនិងជំងឺទាំងនេះ។<br>• ពង្រឹងសេវាកម្មផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការអនុវត្ត IPM ការអនុវត្តដែលពឹងផ្អែកលើព័ត៌មានអាកាសធាតុ និងការគ្រប់គ្រងហានិភ័យដោយប្រើប្រាស់សេវាកសិ ឧតុនិយម។<br>• កែលម្អការព្យាករណ៍និងការប្រកាសឱ្យដឹងមុនអំពីសត្វល្អិត និងជំងឺ និងផ្តល់ប្រឹក្សាយោបល់។<br>• ជំនួសការប្រើប្រាស់ថ្នាំសំលាប់ស្មៅដោយ ដាំស្មៅស្ទីឡូជាចំណីគោក្របី។ | • ពង្រឹងសេវាកម្មផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការអនុវត្ត IPM ការអនុវត្តដែលពឹងផ្អែកលើព័ត៌មានអាកាសធាតុ និងការគ្រប់គ្រងហានិភ័យដោយប្រើប្រាស់សេវាកសិឧតុនិយម។<br>• កែលម្អការព្យាករណ៍និងការប្រកាសឱ្យដឹងមុនអំពីសត្វល្អិត និងជំងឺ និងផ្តល់ប្រឹក្សាយោបល់• ជំនួសការប្រើប្រាស់ថ្នាំសំលាប់ស្មៅដោយ ដាំស្មៅស្ទីឡូជាចំណីគោក្របី។<br>• ពង្រឹងសេវាកម្មផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការអនុវត្ត IPM ការអនុវត្តដែលពឹងផ្អែកលើព័ត៌មានអាកាសធាតុ និងការគ្រប់គ្រងហានិភ័យដោយប្រើប្រាស់សេវាកសិឧតុនិយម។<br>• ជំនួសការប្រើប្រាស់ថ្នាំសំលាប់ស្មៅដោយ ដាំស្មៅស្ទីឡូជាចំណីគោក្របី។ |

| | | | | |
|---|---|---|---|---|
| ប្រព័ន្ធធារាសាស្ត្រ/ការស្រោចស្រពដំណាំ | • បង្កើតយន្តការគ្រប់គ្រងទីជម្រាលដែលមានលក្ខណចម្រុះ (IWM) ដើម្បីកែលម្អលទ្ធភាពប្រើប្រាស់ទឹក និងការគ្រប់គ្រងការបំពុល។<br>• កែលម្អការអនុវត្តការអភិរក្ស/ការគ្រប់គ្រងទឹក រួមទាំងការប្រើប្រាស់ឧបករណ៍ចាប់សញ្ញាសំណើមដី និងជម្រើសប្រព័ន្ធធារាសាស្ត្ររដូវប្រាំង។<br>• លើកកម្ពស់ការផ្គត់ផ្គង់ទឹកតាមការកំណត់ ដើម្បីកាត់បន្ថយការបាត់បង់ទឹកពីការរំហួតដោយផ្ទាល់។ | • បង្កើតយន្តការគ្រប់គ្រងទីជម្រាលដែលមានលក្ខណចម្រុះ (IWM) ដើម្បីកែលម្អលទ្ធភាពប្រើប្រាស់ទឹក និងការគ្រប់គ្រងការបំពុល។<br>• អភិវឌ្ឍបណ្តាញប្រឡាយ និងស្រះធម្មជាតិ។<br>• ត្រួតពិនិត្យលំហូរទឹក និងគុណភាព និងតម្រូវការទឹកសម្រាប់ដំណាំ ដើម្បីផ្តល់ដំបូន្មានកសិឧតុនិយមឆ្លើយតបតាមតម្រូវការ។<br>• លើកកម្ពស់ប្រព័ន្ធស្រោចស្រពឆ្លាតវៃនឹងអាកាសធាតុ និងកំណត់កាលវិភាគស្រោចស្រព ដើម្បីប្រើប្រាស់ធនធានទឹកឱ្យមានប្រសិទ្ធភាព ។ | • ផ្សព្វផ្សាយប្រព័ន្ធស្រោចស្រពឆ្លាតវៃ (ឧ. ប្រព័ន្ធស្រោចស្រព ដោយដំណក់ទឹក និងស្រះ) និងកាលវិភាគស្រោចស្រព ដើម្បីដើម្បីប្រើប្រាស់ធនធានទឹកឱ្យមានប្រសិទ្ធភាព។<br>• តាមដានតម្រូវការទឹកសម្រាប់ដំណាំ ដើម្បីផ្តល់ដំបូន្មានកសិឧតុនិយមឆ្លើយតបតាមតម្រូវការ។ | • បង្កើតម៉ូដែលដំណាំ-ទឹក ដោយផ្អែកលើម៉ូដែល Aqua-Crop ដើម្បីផ្តល់ដំបូន្មានកសិឧតុនិយម ឆ្លើយតបតាមតម្រូវការ។<br>• លើកកម្ពស់ប្រព័ន្ធស្រោចស្រពដោយដំណក់ទឹក ដែលមានតម្លៃទាប និងការស្តុកទឹកទុក (ឧ. ស្រះ ប្រព័ន្ធចែកចាយទឹកពីធុងទឹកដោយប្រើទំនាញ)។ |
| ការប្រមូលផល | • លើកកម្ពស់ការសម្ងួតភ្លាមៗបន្ទាប់ពីប្រមូលផល។<br>• វិនិយោគលើការកសាងកន្លែងសម្ងួតដោយប្រើប្រាស់បច្ចេកវិទ្យាសន្សំសំចៃថាមពល។<br>• បង្កើនចំណេះដឹងអំពីវិធានការត្រួតពិនិត្យសីតុណ្ហភាព និងសំណើម។ | • ផ្តល់សេវាកម្មអាកាសធាតុសមស្រប និងពង្រឹងប្រព័ន្ធប្រកាសឱ្យដឹងមុន ដើម្បីជួយដល់ការសម្រេចចិត្តរបស់កសិករក្នុងការប្រមូលផល ជាមួយនឹងពេលវេលា និងវិធីសាស្ត្រសមស្រប។<br>• ជំរុញការសម្ងួត បន្ទាប់ពីប្រមូលផលភ្លាមៗ។ | • ផ្តល់សេវាកម្មអាកាសធាតុសមស្រប និងពង្រឹងប្រព័ន្ធប្រកាសឱ្យដឹងមុន ដើម្បីជួយដល់ការសម្រេចចិត្តរបស់កសិករក្នុងការប្រមូលផលជាមួយនឹងពេលវេលា និងវិធីសាស្ត្រសមស្រប។<br>• វិនិយោគលើសមត្ថភាពប្រព័ន្ធត្រជាក់ | • លើកកម្ពស់ការប្រមូលផលនៅពេលព្រឹក ដើម្បីជៀសវាងបញ្ហាកំដៅ និងពន្លឺកាំរស្មីយូវី។<br>• លើកកម្ពស់ការប្រើប្រាស់ធុងឬស្សី និងគម្របក្រណាត់សើម ដើម្បីកាត់បន្ថយការបាត់បង់ទឹក។ |

| | | | | |
|---|---|---|---|---|
| អាយុកាលស្តុកក្រោយការប្រមូលផល ការកិន និងការកែច្នៃ | • វិនិយោគលើគ្រឿងបរិក្ខារស្តុកផលិផលដែលមានប្រសិទ្ធភាពថាមពលដល់សហគមន៍កសិកម្ម សហជីព (ប្រភពថាមពលដែលកកើតឡើងវិញបាន)។<br>• បង្កើនការយល់ដឹងអំពីការបង្កើនអំណាចចរចាតម្លៃតាមរយៈការស្តុកទុកផលិតផល។<br>• បង្កើនចំណេះដឹង និងការប្រើប្រាស់ប្រព័ន្ធឧបករណ៍ចាប់សញ្ញាសីតុណ្ហភាព និងសំណើម (ឧ. ITCs)។<br>• រក្សាទុកផលិតផល កែច្នៃក្នុងថង់បិទជិត គ្មានខ្យល់ចេញចូល គ្មានមេរោគ។<br>• កន្លែងរក្សាទុក និងកែច្នៃស្រូវដែលធន់នឹងអាកាសធាតុ។ | ជំរុញការរក្សាទុកគ្រាប់ស្វាយចន្ទីក្នុងបាវក្រចៅដើម្បីកាត់បន្ថយផ្សិត។<br>• បង្កើនការយល់ដឹងអំពីបច្ចេកវិទ្យាកែច្នៃ ដោយកំដៅសមស្របនិងបច្ចេកទេសរក្សាទុក។<br>• បង្កើនការប្រើប្រាស់កង្ហារ ឧបករណ៍ កាត់បន្ថយសំណើម និងឧបករណ៍ខ្យល់ ដើម្បីកាត់បន្ថយការបាត់បង់នៅពេល ស្តុកទុក។<br>• បង្កើនចំណេះដឹង និងការប្រើប្រាស់ប្រព័ន្ធឧបករណ៍ចាប់សញ្ញាសីតុណ្ហភាព និងសំណើម (ឧ. ITCs)។<br>• លើកកម្ពស់ការប្រើប្រាស់កាកសំណល់ផលិតផល។ | • វិនិយោគលើការ កសាងសមត្ថភាពប្រព្រឹត្តិកម្មក្រោយប្រមូលផល ដូចជាប្រព្រឹត្តិកម្មទឹកក្តៅដើម្បីកាត់បន្ថយការបាត់បង់ និងអនុលោមតាមបទដ្ឋានអន្តរជាតិ។<br>• លើកកម្ពស់ការត្រួតពិនិត្យគុណភាព និង វិធានការផ្តល់វិញ្ញាបន បត្រការកែច្នៃ ។<br>• បង្កើនចំណេះដឹងនិងការប្រើប្រាស់ប្រព័ន្ធឧបករណ៍ចាប់សញ្ញាសីតុណ្ហភាព និងសំណើម (ឧ. ITCs)។<br>• វិនិយោគលើការវេចខ្ចប់ដែលអាចការពារមិនឱ្យខូចខាតពេលដឹកជញ្ជូន។ | • វិនិយោគលើប្រព័ន្ធត្រជាក់ដែលមានប្រសិទ្ធភាពថាមពល និងបច្ចេកវិទ្យាក្រោយការប្រមូលផលដល់សហគមន៍កសិកម្ម សហជីព (ឧ. ប្រព័ន្ធត្រជាក់ដែល ដើរដោយថាមពលពន្លឺព្រះអាទិត្យ)។<br>• លើកកម្ពស់ការអនុវត្តការដឹកជញ្ជូនល្អបំផុត (ឧ. សម្ភភាពប្រព័ន្ធត្រជាក់)។ |
| ទីផ្សារ | • រៀបចំឱ្យមានព័ត៌មានទីផ្សារដែលជាផ្នែកមួយនៃសេវាកម្មសម្រាប់កសិករ<br>• គាំទ្រការអនុវត្តកសិកម្មល្អរបស់កម្ពុជា ការសម្គាល់អត្តសញ្ញាណភូមិសាស្ត្រទំនិញ (GI) វិញ្ញាបនប័ត្រ សរីរាង្គ រួមទាំង Ibis Rice និងវិញ្ញាបនប័ត្របន្ថែមតម្លៃសមស្របផ្សេងទៀត។<br>• បង្កើតទំនាក់ទំនងជិតស្និទ្ធរវាងការផ្តល់វិញ្ញាបនប័ត្របញ្ជាក់គុណភាពផលិតផល និងភាពធន់នឹងអាកាសធាតុដើម្បីបង្កើនតម្លៃបន្ថែម។<br>• បង្កើត ភាពជាដៃគូរវាងរដ្ឋ ឯកជន និងសហគមន៍ដើម្បីបង្កើនកិច្ចសហការ និងការសម្របសម្រួលខ្សែ ច្រវ៉ាក់តម្លៃ។<br>• លើកកម្ពស់ការយល់ដឹងអំពីផលិតផលដែលធន់នឹងអាកាសធាតុ និងមានតម្លៃខ្ពស់ និងអត្ថប្រយោជន៍របស់វាក្នុងចំណោមអ្នកទិញ អ្នកនាំចេញ និងអ្នកប្រើប្រាស់។<br>• ជំរុញកសិកម្មតាមកិច្ចសន្យា និងកិច្ចព្រមព្រៀងទិញដោយផ្ទាល់ដើម្បីបង្កើនតម្រូវការនិងការផ្គត់ផ្គង់។<br>• វិនិយោគលើការដាក់ស្លាកសញ្ញាសម្គាល់ទំនិញ និងបង្កើតប្រព័ន្ធតាមដានប្រភពដើមទំនិញ។ | | | |

៤៩. សកម្មភាព ២.៣.១៖ បង្កើតប្រព័ន្ធប្រមូលនិងចែកចាយព័ត៌មាននិងឯកសារ បង្រួបបង្រួមប្រព័ន្ធចំណេះដឹងដែលមានស្រាប់ សម្រាប់ការគ្រប់គ្រងចំណេះដឹងប្រកបដោយសុខដុមរមនា និងការផ្សព្វផ្សាយជាលក្ខណៈ

ប្រព័ន្ធនៃមេរៀន និងការអនុវត្តល្អៗបំផុតពាក់ព័ន្ធនឹងកសិកម្មធន់នឹងអាកាសធាតុ ផ្តល់តម្លៃខ្ពស់ ប្រកបដោយបរិយាប័ន និងឆ្លើយតបនឹងយេនឌ័រសម្រាប់គាំទ្រការអនុវត្តផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាពក្រោមសកម្មភាព ២.១.១ និងសម្រាប់ការលើកកម្ពស់ការយល់ដឹងអំពីការអនុវត្ត និងបច្ចេកវិទ្យាក្រោមសកម្មភាព ២.៣.២ និង អត្ថប្រយោជន៍សេដ្ឋកិច្ច និងសង្គមដែលពាក់ព័ន្ធ។

៥០. សកម្មភាព ២.៣.២៖ ផ្តល់សេវាផ្សព្វផ្សាយដែលមានភាពចុះសម្រុងគ្នា តាមខ្សែបណ្តោយ និងខ្សែទទឹង ដោយភ្ជាប់កម្រិតថ្នាក់ខេត្ត ស្រុក ឃុំ និងភូមិ ជាមួយនឹងអ្នកផ្តល់សេវាសាធារណៈ និងឯកជន ដើម្បីលើកកម្ពស់ការទទួលយកនូវការអនុវត្តកសិកម្មធន់នឹងអាកាសធាតុ ផ្តល់តម្លៃខ្ពស់ ប្រកបដោយបរិយាប័ន និងឆ្លើយតបនឹងយេនឌ័រ សម្រាប់គាំទ្រការអនុវត្តផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាពក្រោមសកម្មភាពដែលត្រូវបានបង្កើតឡើងក្រោមសកម្មភាព ២.១.១ និងផ្តល់ហិរញ្ញប្បទានក្រោមសកម្មភាព ២.២.១។

## លទ្ធផល ២.៤៖ តំបន់ទីជម្រាលផ្នែកខាងលើត្រូវបានស្តារ និងការពារ ដើម្បីបង្កើនមុខងារសេវាកម្មអេកូឡូស៊ីសម្រាប់សកម្មភាពកសិកម្មនៅផ្នែកខាងក្រោមនៅតំបន់គោលដៅ។

៥១. គម្រោង PEARL ផ្តោតលើសកម្មភាពរបស់ខ្លួនក្រោមលទ្ធផលនេះ ដើម្បីគាំទ្រសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើ ក្នុងការស្តារ និងការពារព្រៃឈើ ៧.៦០០ ហិកតា និងតំបន់ស្ទឹងដែលងាយរងគ្រោះផ្សេងទៀត នៅតំបន់ទីជម្រាលផ្នែកខាងលើ តាមរយៈការអនុវត្តការគ្រប់គ្រងទីជម្រាលដែលមានលក្ខណៈចម្រុះ (IWM) និងអន្តរាគមន៍គាំទ្រកសិរុក្ខកម្ម។ គោលការណ៍ណែនាំសំខាន់ៗ របស់ការសិក្សាខាងលើ និងការប៉ាន់ប្រមាណតំបន់ត្រូវបានយកមកប្រើប្រាស់ដើម្បីវិភាគ និងកំណត់សហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើជាសក្តានុពលដើម្បីចូលរួមក្នុងការងារស្តារឡើងវិញក្រោមគម្រោង PEARL នេះ។

៥២. ក្នុងអំឡុងពេលរៀបចំគម្រោង ការសិក្សាមួយត្រូវបានធ្វើឡើងដើម្បីកំណត់យកសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើគោលដៅសម្រាប់អន្តរាគមន៍ស្តារឡើងវិញក្នុងក្របខណ្ឌគម្រោង PEARL។ របាយការណ៍សិក្សា (Seak, 2022) កំណត់ និងណែនាំ សហគមន៍តំបន់ការពារធម្មជាតិចំនួន ១៤ និងសហគមន៍ព្រៃឈើចំនួន ៦។ សហគមន៍ទាំងនេះមួយក្រុមធំ ស្ថិតនៅក្នុងតំបន់ផ្ទៃរងទឹកភ្លៀងស្ទឹងសែន ដែលសកម្មភាពស្តារ និងការពារផ្ទៃរងទឹកភ្លៀងនេះ ផ្តល់ផលប្រយោជន៍យ៉ាងសំខាន់ដល់ការធ្វើស្រែនៅផ្នែកខាងក្រោមក្នុងខេត្តព្រះវិហារ និងខេត្តកំពង់ធំ។

៥៣. សហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើផ្សេងទៀតមានទីតាំងនៅជិតឧទ្យានជាតិគូលែនក្នុងខេត្តសៀមរាប និងដែនជម្រកសត្វព្រៃសង្ឃរុក្ខវ័ន្ត ក្នុងខេត្តឧត្តរមានជ័យ។ របាយការណ៍នៃការសិក្សាខាងលើបាន ផ្តល់អនុសាសន៍ដល់គម្រោង PEARL ដើម្បីគាំទ្រសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើទាំងនេះក្នុងការរៀបចំ និងអនុវត្តសកម្មភាពស្តារ និងការពារ ដើម្បីកែលម្អជម្រើសជីវភាពរបស់ពួកគេសំដៅសម្រេចបាននូវគោលដៅស្តារឡើងវិញ។

៥៤. សកម្មភាព ២.៤.១៖ ស្តារ និងការពារព្រៃឈើសំខាន់ៗនៅតំបន់ផ្ទៃរងទឹកភ្លៀងផ្នែកខាងលើ ដែលដំណាំគោលដៅគម្រោង ត្រូវបានផលិត (សកម្មភាពនេះនឹងបំពេញបន្ថែមដោយផ្ទាល់លើ និងពង្រីកកិច្ចខិតខំប្រឹងប្រែងអភិរក្ស និងការពារ របស់ក្រសួងបរិស្ថាន អង្គការ WCS និងស្ថាប័នផ្សេងៗទៀត)។

លទ្ធផលទី ៣៖ លក្ខខណ្ឌអំណោយផលសម្រាប់កសិកម្មធន់នឹងអាកាសធាតុត្រូវបានធានា តាមរយៈក្របខណ្ឌគោលនយោបាយ ច្បាប់ និងស្ថាប័នដែលមានភាពស៊ីសង្វាក់គ្នា និងរឹងមាំ

៥៥. សមាសភាគនេះនឹងគាំទ្រដល់ការសម្រេចបានជោគជ័យ សមាសភាគទី ១ និងសមាសភាគទី ២នៃគម្រោង ដោយធានានូវលក្ខខណ្ឌអំណោយផល តាមរយៈក្របខ័ណ្ឌបទប្បញ្ញត្តិ និងស្ថាប័នដែលអំណោយផល។ តាមរយៈធាតុផ្សំនេះ សមាហរណកម្មបញ្ឈរ និងផ្តេកប្រកបដោយប្រសិទ្ធភាពនៃកិច្ចខិតខំប្រឹងប្រែង និងការអនុវត្តល្អៗនៅតាមវិស័យនានា ក្រុមភាគីពាក់ព័ន្ធ និងកម្រិតនៃរដ្ឋាភិបាលនឹងត្រូវបានធានាដើម្បីគាំទ្រគម្រោងក្នុងការបំពេញគោលបំណងរបស់ខ្លួន។

**លទ្ធផល ៣.១៖ ការរៀបចំបទប្បញ្ញត្តិ និងស្ថាប័ន និងសមត្ថភាពពាក់ព័ន្ធ ក្នុងការអភិវឌ្ឍខ្សែច្រវាក់តម្លៃផ្អែកលើវិញ្ញាបនបត្រត្រូវបានពង្រឹង ដើម្បីផ្តល់លក្ខខណ្ឌអំណោយផលសម្រាប់ការទទួលយកការអនុវត្តកសិកម្មធន់នឹងអាកាសធាតុ ផ្តល់តម្លៃខ្ពស់ និងមាននិរន្តរភាព និងធានាបាននូវសន្តិសុខស្បៀង។**

៥៦. ការគាំទ្រពីស្ថាប័ន និងកិច្ចខិតខំប្រឹងប្រែងសម្របសម្រួល និងយន្តការសម្រាប់គាំទ្រការផ្លាស់ប្តូរផ្អែកលើទីផ្សាររបស់កសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវាក់តម្លៃក្នុងស្រុកផ្សេងទៀតឆ្ពោះទៅរកកសិកម្មធន់នឹងអាកាសធាតុ និងមានតម្លៃខ្ពស់នាពេលបច្ចុប្បន្នមានកម្រិត។ ការដាក់ឱ្យដំណើរការលក្ខខណ្ឌនិយតកម្ម និងស្ថាប័នត្រូវតែធានាដើម្បីលើកម្ពស់ ការអនុវត្តបទដ្ឋានវិញ្ញាបនប័ត្រភាពធន់នឹងអាកាសធាតុដែលបានកំណត់ដោយគម្រោង ដើម្បីសម្រេចបាននូវគោលដៅរបស់គម្រោង។ វិធីសាស្ត្រជាប្រព័ន្ធក្នុងការលើកកម្ពស់លទ្ធភាពទទួលបានហិរញ្ញវត្ថុប្រកបដោយបរិយាប័ន និងឆ្លើយតបនឹងយេនឌ័រសម្រាប់កសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវាក់តម្លៃក្នុងស្រុកផ្សេងទៀតដោយគ្មានវត្ថុបញ្ចាំ ឬអ្នកធានា គឺចាំបាច់ដើម្បីបំពេញបន្ថែមយន្តការ FARM នៅក្រោមលទ្ធផល ២.២ ដើម្បីពន្លឿនការផ្លាស់ប្តូររបស់ពួកគេ។ គម្រោង PEARL ក៏នឹងធ្វើឱ្យប្រសើរឡើងនូវភាពជាដៃគូសាធារណៈ និងឯកជនដែលបច្ចុប្បន្នមានកម្រិត និងយន្តការសម្របសម្រួលអន្តរវិស័យ ដើម្បីគាំទ្រដល់ការផ្លាស់ប្តូរទៅកសិកម្មធន់នឹងអាកាសធាតុ។

៥៧. នៅក្រោមលទ្ធផលនេះ គម្រោង PEARL នឹងជួយដោយផ្ទាល់ដល់ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម (ARDB)ដើម្បីទទួលបាននូវការទទួលស្គាល់ដោយ GCF ព្រោះធនាគារ ARDB នឹងដើរតួនាទីសម្របសម្រួលសំខាន់សម្រាប់សកម្មភាព ៣.១.២ ដើម្បីរៀបចំ និងដំណើរការប្រព័ន្ធពិន្ទុសម្រាប់វិស័យហិរញ្ញវត្ថុកសិកម្ម។ នៅពេលត្រូវបានទទួលស្គាល់ដោយ GCF នោះ ធនាគារ ARDB ត្រូវបានគេរំពឹងថានឹងបង្កើប្រព័ន្ធពិន្ទុ ដើម្បីបង្កើតគម្រោង GCF បំពេញបន្ថែមសម្រាប់ពង្រីកហិរញ្ញប្បទានកសិកម្មតម្លៃទាប ដើម្បីគាំទ្រដល់ការផ្លាស់ប្តូរបានលឿនរបស់កម្ពុជាទៅកាន់កសិកម្មដែលធន់នឹងអាកាសធាតុ។

៥៨. ការដឹកនាំរួមគ្នារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងបរិស្ថានមានការគាំទ្រផ្នែកបច្ចេកទេសពីអង្គការ FAO ប្រចាំកម្ពុជា។ ទាក់ទងនឹងហិរញ្ញវត្ថុកសិកម្ម ធនាគារ ARDB នឹងដើរតួនាទីសម្របសម្រួល។

៥៩. សកម្មភាព ៣.១.១៖ ធ្វើឱ្យប្រសើរឡើង/បង្កើតការងារក្របខ័ណ្ឌនិយតកម្ម និងស្ថាប័នអំណោយផលសម្រាប់កម្មវិធីវិញ្ញាបនប័ត្របញ្ជាក់គុណភាពផលិតផលដែលចូលរួមចំណែកការពារអាកាសធាតុនៅក្រោមសកម្មភាព ២.១.២ ដើម្បីធ្វើប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព។

៦០. សកម្មភាព ៣.១.២៖ បង្ហាញពីវិធីសាស្ត្រតាមវិស័យដែលចុះសម្រុងគ្នាចំពោះហិរញ្ញវត្ថុដែលធន់នឹងអាកាសធាតុ ប្រកបដោយបរិយាប័ន និងឆ្លើយតបនឹងយេនឌ័រ ដើម្បីបំពេញបន្ថែមសកម្មភាព ២.២.១ សម្រាប់ការដាក់ចេញនូវយន្តការហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត និងកម្មវិធីកម្ចីការប្រាក់ទាប។

៦១. សកម្មភាព ៣.១.៣៖ ធានាបាននូវល័ក្ខខ័ណ្ឌសម្រាប់ ភាពជាដៃគូរវាងរដ្ឋ ឯកជន និងសហគមន៍ប្រកបដោយប្រសិទ្ធភាព និងការសម្របសម្រួលឆ្លងវិស័យនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**លទ្ធផល ៣.២៖ ប្រព័ន្ធតាមដានកសិអេកូឡូស៊ីកម្រិតទេសភាពដែលឆ្លើយតបនឹងយេនឌ័រ (LAMS) ត្រូវបានបង្កើតឡើងដើម្បីបង្កើនការវិនិយោគសាធារណៈ និងឯកជនក្នុងវិស័យកសិកម្មធន់នឹងអាកាសធាតុ ផ្តល់តម្លៃខ្ពស់ និងមាននិរន្តរភាព។**

៦២. បច្ចុប្បន្ននេះ ពុំទាន់មាន វិធីសាស្ត្រ និងដំណើរការជាប្រព័ន្ធ ដើម្បីជំរុញការវិនិយោគជាយុទ្ធសាស្ត្ររបស់វិស័យសាធារណៈ និងឯកជន នៅក្នុងវិស័យកសិកម្មធន់នឹងអាកាសធាតុ និងមានតម្លៃខ្ពស់ ក្នុងលក្ខណៈយុទ្ធសាស្ត្រ និងរចនាសម្ព័ន្ធ នៅឡើយ។ កត្តានេះរារាំងដល់ការយល់ដឹងច្បាស់លាស់ និងការត្រួតពិនិត្យគម្លាតសមត្ថភាព និងតម្រូវការការវិនិយោគហិរញ្ញវត្ថុអាកាសធាតុ ដូច្នេះវាបានកម្រិតលទ្ធភាពរបស់ប្រទេសក្នុងការគ្រប់គ្រងការចំណាយសាធារណៈ និងការវិនិយោគពីវិស័យឯកជនក្នុងការបង្កើតគម្រោងដែលអាចទទួលបានហិរញ្ញបទានដើម្បីសម្រេចបាន កំណើនលទ្ធផល។ គម្រោង PEARL នឹងបង្កើតឧបករណ៍គាំទ្រការសម្រេចចិត្តរួមបញ្ចូលគ្នាសម្រាប់ការត្រួតពិនិត្យជាប្រព័ន្ធនូវហានិភ័យអាកាសធាតុ និងការផ្លាស់ប្តូរសមស្រប ដោយភ្ជាប់ទៅលទ្ធផល ១.១ និងកំណត់គម្លាត និងឱកាសវិនិយោគ ព្រមទាំងតាមដានវឌ្ឍនភាពដើម្បីបង្កើនការវិនិយោគសាធារណៈ និងឯកជន។ ឧបករណ៍នេះក៏នឹងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសឆ្ពោះទៅរកការអភិវឌ្ឍ និងប្រតិបត្តិការក្របខ័ណ្ឌតម្លាភាពដែលប្រសើរឡើង (ETF) ក្រោមកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីអាកាសធាតុ។

៦៣. សកម្មភាព ៣.២.១៖ បង្កើតប្រព័ន្ធតាមដានកសិអេកូឡូស៊ីកម្រិតទេសភាពដែលឆ្លើយតបនឹងយេនឌ័រ (LAMS) ជាមួយនឹងទំរង់គេហទំព័រដែលមានអន្តរអំពើ។

៦៤. សកម្មភាព ៣.២.2៖ លើកកម្ពស់ការប្រើប្រាស់ LAMS ក្នុងការសម្រេចចិត្តវិនិយោគសាធារណៈ និងឯកជន ការត្រួតពិនិត្យ និងការរាយការណ៍។

## ២.២ ទីតាំងគម្រោង

៦៥. តំបន់ភាគខាងជើងនៃបឹងទន្លេសាបត្រូវបានកំណត់ជាតំបន់ភាគខាងជើងនៃបឹងទន្លេសាប រួមមានខេត្តឧត្តរមានជ័យ កំពង់ធំ ព្រះវិហារ និងខេត្តសៀមរាប។ តំបន់នេះមានប្រជាជនប្រហែល ១៥% នៃប្រជាជនរបស់ប្រទេស។ តំបន់នេះគ្របដណ្តប់លើផ្ទៃដីសរុបចំនួន ២,៥ លានហិកតា ជាមួយនឹងព្រៃស្រោង និងព្រៃរបោះ គ្របដណ្តប់លើតំបន់ភ្នំនៅភាគខាងជើង វាលស្រែដ៏ធំល្វឹងល្វើយនៅកណ្តាល (ជាចម្បងសម្រាប់ផលិតស្រូវ) និងព្រៃលិចទឹក និង វាលស្មៅតាមបណ្តោយបឹងទន្លេសាបនៅភាគខាងត្បូង។ (សូមមើលឧបសម្ព័ន្ធ ១៦ - ផែនទី)។ ទឹកភ្លៀងប្រចាំឆ្នាំ ជាមធ្យមនៅក្នុងតំបន់ប្រែប្រួលពី ១000 ទៅ ១៥00 មីលីម៉ែត្រ។ មានប្រភេទដីសំខាន់ៗចំនួន ១0 និងតំបន់ទីជម្រាលសំខាន់ៗចំនួន ៥ រួមមាន ស្ទឹងសែន និងស្ទឹងស្ទោង ដែលជាប្រភពទឹកដ៏សំខាន់សម្រាប់ផលិតស្រូវ និងការចិញ្ចឹមជីវិតក្នុងតំបន់ (Oeurng et al., 2019)។ ជាង ២0% នៃផលិតកម្មអង្ករក្រអូបរបស់ប្រទេស ក្នុងចំណោមផលិតផលផ្សេងទៀតដូចជាដំឡូងមី (៣៥%) និងអំពៅ (២៧%) បានមកពីតំបន់នេះ (NIS, 2019)។

*តារាងទី 2. ទិដ្ឋភាពទូទៅនៃដំណាំសំខាន់ៗនៅក្នុងតំបន់ភាគខាងជើងនៃបឹងទន្លេសាប*

| ដំណាំជំនួស/តំបន់ដាំដុះ | ឱកាស | ឧបសគ្គ/បញ្ហាប្រឈម |
|---|---|---|
| ស្វាយចន្ទី/កំពង់ធំ និងព្រះវិហារ<br>ស្វាយ/ឧត្តរមានជ័យ | • កសិករដាំស្វាយចន្ទីភាគច្រើនដាំពូជM២៣ ដែលផ្តល់ទិន្នផល និងតម្លៃទីផ្សារខ្ពស់ជាងពូជបុរាណ។<br>• កសិករដាំស្វាយភាគច្រើនដាំពូជកែវរមៀត ដែលត្រូវបានគេចាត់ទុកថាមានគុណភាព។<br>• ទីផ្សារតម្លៃល្អមានសម្រាប់ផលិតផលដែលមានគុណភាពល្អ<br>• និន្នាការទីផ្សារដែលកំពុងរីកចម្រើន ផ្តល់ឱកាសដើម្បីចូលទៅកាន់ទីផ្សារតម្លៃបុព្វលាភ ដោយប្រកាន់យកគុណភាព និងបទដ្ឋានផលិតកម្មអន្តរជាតិ។<br>• ជាដំណាំដែលមានអាយុច្រើនឆ្នាំ វាមានសក្តានុពលក្នុងការអនុវត្តកសិរុក្ខកម្ម ម្រាប់ការធ្វើពិពិធកម្មជីវភាពរស់នៅតាមជនបទ ការបង្កើនការផ្គត់ផ្គង់អុស ការអភិរក្សព្រៃឈើ ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងការការពារផ្ទៃរងទឹកភ្លៀង។ | • ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតកម្រិតមធ្យម ជាមួយនឹងវិធានការត្រួតពិនិត្យមិនគ្រប់គ្រាន់។<br>• កសិករខ្នាតតូចភាគច្រើន សហគមន៍កសិកម្ម និងសមាគមកសិករ និងក្រុមអ្នកផលិត លក់ទៅឱ្យអ្នកទិញទាំងស្រុងជាមួយនឹងឱកាសទទួលបានតម្លៃបន្ថែមមានកំណត់។ប្រាក់ចំណេញទាបផ្តល់ការលើកទឹកចិត្តតិចតួចសម្រាប់ការទទួលយកការអនុវត្តធន់នឹងអាកាសធាតុ និងនិរន្តរភាព រួមទាំងការអនុវត្ត IPM។<br>• កសិករខ្នាតតូច សហគមន៍កសិកម្ម និងសមាគមកសិករ និងក្រុមអ្នកផលិត និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀត ខ្វះធនធានចាំបាច់ដើម្បីទទួលបានទីផ្សារតម្លៃខ្ពស់។ |
| ស្រូវសរីរាង្គ/ព្រះវិហារ | • កង្វះកម្លាំងពលកម្ម ការកើនឡើងនៃការប្រែប្រួលអាកាសធាតុ និងនិន្នាការទីផ្សារបានលើកទឹកចិត្តកសិករឱ្យទទួលយកការផលិតស្រូវក្រអូបរយៈពេលខ្លី (ជាផ្នែកមួយយ៉ាងសំខាន់នៃអង្ករសរីរាង្គ) ដោយផ្លាស់ប្តូរពីការដាំស្រូវចំណីមិនមានក្លិនក្រអូបរយៈពេលវែង។ ការកើនឡើងតម្លៃតាមរយៈផលិតកម្មសរីរាង្គអាចប៉ះប៉ូវដល់ការធ្លាក់ចុះទិន្នផលដែល | • កង្វះនៃការធ្វើកសិកម្មតាមកិច្ចសន្យាអំណោយផល និងឱកាសទទួលបានទីផ្សារផ្ទាល់។<br>• លទ្ធភាពទទួលបានហិរញ្ញវត្ថុ និងការផ្គត់ផ្គង់ប្រកប ដោយគុណភាព និងសេវាកម្មបន្ថែមមានកំណត់។<br>• កង្វះការគ្រប់គ្រងទីជម្រាលជាលក្ខណៈចម្រុះដើម្បីធានាគុណភាពទឹក និងលទ្ធភាពទទួលបាននៅកម្រិតទេសភាព។ |

| | | |
|---|---|---|
| | រំពឹងទុកសម្រាប់កសិករនៅតំបន់ខ្ពង់រាបដាច់ស្រយាលទាំងនេះ។<br>• ស្រូវសេរីវាង្គក្នុងខេត្តព្រះវិហារត្រូវបានទទួលវិញ្ញាបនបត្របញ្ជាក់នៅទីផ្សារសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ហើយមានឱកាសទទួលបានតម្លៃបន្ថែមទៀតតាមរយៈ GI។<br>• លក្ខណៈសណ្ឋានដីរក្សាវាលស្រែឱ្យនៅតូច និងបែកខ្ញែកគ្នាជាមួយនឹងទ្រនាប់ធម្មជាតិ ដើម្បីរក្សាបាននូវប្រព័ន្ធអេកូឡូស៊ីដ៏សម្បូរបែប។ | • ការធ្វើសមាហរណកម្មមានកម្រិតនៃសេវាកម្មប្រឹក្សាផ្នែកកសិកម្ម និងទីផ្សារ ដើម្បីបង្កើនប្រសិទ្ធភាពផលិតកម្ម។ |
| បន្លែស្លឹក/សៀមរាប និងព្រះវិហារ | • បណ្តាញកសិករដាំបន្លែជើងឯកជាច្រើន³ដែលមានការពង្រីកទីផ្សារក្នុងស្រុក (អ្នកលក់រាយ សណ្ឋាគារ និងភោជនីយដ្ឋាន) នៅខេត្តសៀមរាប និងរាជធានីភ្នំពេញ។<br>• កំណើនតម្រូវការបន្លែដែលផលិតដោយសុវត្ថិភាព និងនិរន្តរភាពផ្តល់តម្លៃកាន់តែខ្ពស់។<br>• ការច្នៃប្រឌិតផ្នែកសាកវប្បកម្មជួយឱ្យការផលិតមានភាពធន់នឹងអាកាសធាតុសម្រាប់ការបង្កើតប្រាក់ចំណូល និងការប្រើប្រាស់ក្នុងគ្រួសារ។ | • កង្វះធនធាន (ចំណេះដឹង ហិរញ្ញវត្ថុ និងបច្ចេកវិជ្ជា) ដើម្បីផលិតមុខបន្លែឱ្យបានច្រើនមុខ និងមានគុណភាព និងដោះស្រាយបញ្ហាផលិតតាមរដូវកាល។ |

[3] Champion farmers have extensive experience in farming and mastered the knowledge and skills, and diffused them to other farmers.

## ២.៣ ក្រុមអ្នកទទួលផលពីគម្រោង

៦៦. ក្រុមអ្នកទទួលផលពីគម្រោង PEARL រួមមានកសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃពាក់ព័ន្ធក្នុងស្រុកផ្សេងៗទៀត រួមទាំងកសិករក្រីក្រ ស្ត្រី និងសហគមន៍ជាតិភាគតិចនៅក្នុងតំបន់គោលដៅនៃតំបន់ភាគខាងជើងនៃបឹងទន្លេសាប (NTSB) និងតួអង្គវិស័យឯកជនដែលពាក់ព័ន្ធនឹងខ្សែច្រវ៉ាក់តម្លៃគោលដៅ។ អ្នកទទួលផលត្រូវបានបែងចែកជាពីរក្រុមគឺដោយ ផ្ទាល់ និងដោយប្រយោល។

៦៧. ក្រុមអ្នកទទួលផលផ្ទាល់គឺភាគច្រើនជាសមាជិកនៃ សហគមន៍កសិកម្ម (ACs) សមាគមកសិករ (FAs) ក្រុមអ្នកផលិត (PGs) សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ និងសហគមន៍ដ៏ទៃទៀតដែលគម្រោងបានជ្រើសរើសជាគោលដៅដោយផ្ទាល់នៅក្នុងស្រុកទាំង ២៤ (សូមមើលផែនទីក្នុងឧបសម្ព័ន្ធ ១៦) ដើម្បីបង្កើនលទ្ធភាពទទួលបានសេវាព័ត៌មានប្រឹក្សាកសិឧតុនិយម សម្រាប់ដំណាំជាក់លាក់ ព័ត៌មានទីផ្សារ ចំណេះដឹង ហិរញ្ញវត្ថុ បច្ចេកវិទ្យាដែលធន់នឹងអាកាសធាតុ និងបច្ចេកទេសទំនើប សេវាប្រព័ន្ធអេកូឡូស៊ីដែលបានកែលម្អនិងស្តារឡើងវិញនៅក្នុងតំបន់ផ្នែកខាងលើនៃអាងទន្លេសាប ព្រមទាំងការកែលម្អប្រព័ន្ធក្សេត្របរិស្ថាននៅតំបន់ផ្នែកខាងក្រោមនៃអាងទន្លេសាប ។ ក្រុមអ្នកទទួលផលផ្ទាល់ផ្សេងទៀតរួមបញ្ចូលទាំងកសិករកសិករទូទៅ និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃពាក់ព័ន្ធដ៏ទៃទៀតនៅក្នុងតំបន់គោលដៅ និងតំបន់ជុំវិញដែលពួកគាត់ទាំងនោះនឹងទទួលបានអត្ថប្រយោជន៍ពីសេវាព័ត៌មានប្រឹក្សាកសិឧតុនិយម សេវាបណ្តុះបណ្តាល ផ្សព្វផ្សាយ និងសេវាកម្មផ្សេងទៀត។

- គាំទ្រកសិករខ្នាតតូចចំនួន ១៣៥.០០០ នាក់ និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃពាក់ព័ន្ធក្នុងស្រុកផ្សេងទៀត ដើម្បីទទួលបានសេវាទីផ្សារ និងលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ ព្រមទាំងការគាំទ្រលើការអនុវត្តបច្ចេកទេសទំនើបធន់នឹងអាកាសធាតុ និងផ្តល់តម្លៃខ្ពស់។
- គាំទ្រ កសិករ ៤៥០.០០០នាក់ ដើម្បីទទួលបានសេវាព័ត៌មានប្រឹក្សាកសិឧតុនិយម ដែលចាំបាច់ដើម្បីកាត់បន្ថយការខាតបង់ផលិតផលកសិកម្មដោយសារការប្រែប្រួលអាកាសធាតុ។
- គាំទ្រកសិករដែលរស់នៅតំបន់ផ្នែកខាងក្រោមនៃបឹងទន្លេសាបចំនួន៥០.០០០នាក់ ដើម្បីទទួលបានសេវាកម្មប្រព័ន្ធអេកូឡូស៊ី និងសេវាព័ត៌មានប្រឹក្សាកសិឧតុនិយមសមស្រប និងគាំទ្រដល់សហគមន៍តំបន់ការពារធម្មជាតិ/សហគមន៍ព្រៃឈើ ចំនួន២០ ផ្សេងទៀត ឱ្យមានជម្រើសរបរចិញ្ចឹមជីវិតមានលក្ខណៈប្រសើរឡើងតាមរយៈការស្តារឡើងវិញ និងការការពារតំបន់ផ្ទៃរងទឹកភ្លៀង។

៦៨. អ្នកទទួលផលដោយប្រយោលរួមមានប្រជាជនកសិករទូទៅដែលរស់នៅក្នុងតំបន់ភាគខាងជើងនៃបឹងទន្លេសាបទាំងមូល ដែលមានមានលទ្ធភាពទទួលបានសេវាព័ត៌មានប្រឹក្សាកសិឧតុនិយម និងលើកកម្ពស់ការបន្សាំខ្លួននិងការយល់ដឹងអំពីការអនុវត្ត និងការប្រើប្រាស់បច្ចេកវិទ្យាល្អៗ តាមរយៈមធ្យោបាយផ្សេងៗ រួមទាំងការសិក្សាពីមិត្តភ័ក្តិ សេវាផ្សព្វផ្សាយ វេទការប្រព័ន្ធផ្សព្វផ្សាយសង្គម និងកម្មវិធីទូរស័ព្ទ។ វិស័យឯកជននានា ដូចជាអ្នកផ្គត់ផ្គង់សម្ភារៈកសិកម្ម អ្នកប្រមូលទិញផលិផលកសិកម្ម ពាណិជ្ជករនាំចេញផលិផលកសិកម្ម អ្នកលក់រាយ ម្ចាស់សណ្ឋាគារនិងភោជនីយដ្ឋានដែលដើរតួរនាទីយ៉ាងសំខាន់ក្នុងការផ្តល់ និងប្រើប្រាស់សេវាផ្សព្វផ្សាយកសិកម្ម ការអភិវឌ្ឍឱកាសទីផ្សារ និងការលើកកម្ពស់ការអនុវត្តបច្ចេកវិទ្យាដែលធន់នឹងអាកាសធាតុ និងបច្ចេកទេសទំនើប នឹងទទួលបានអត្ថប្រយោជន៍តាមរយៈបង្កើនការផ្គត់ផ្គង់ និងសមត្ថភាពគាំទ្រដល់ផលិតផលដែលធន់នឹងការប្រែប្រួល អាកាសធាតុ និង ឱកាសនៃការធ្វើវិនិយោគផ្សេងៗ។

៦៩. កសិករជាង ១ លាននាក់ និងតួអង្គក្នុងខ្សែច្រវាក់តម្លៃផ្សេងទៀតនៅក្នុងតំបន់ភាគខាងជើងនៃបឹងទន្លេសាប។

| **កំណត់ចំណាំអំពីភាពងាយរងគ្រោះ និងការបដិសេធ** |
| --- |
| ៧០. ក្រុមជនដែលងាយរងគ្រោះត្រូវបានកំណត់ថាជា *"...ក្រុមជនដែលងាយទទួលរងផលប៉ះពាល់ខ្លាំងពីស្ថានការណ៍ ឬគ្រោះធម្មជាតិនានាដែលកើតឡើងដោយយថាហេតុដែលមិនមានលក្ខណៈជាក់លាក់ជាវេទនាសម្ព័ន្ធ។ តែភាពងាយទទួលរងគ្រោះរបស់ពួកគេគឺជាលទ្ធផលនៃស្ថានភាពជាក់លាក់មួយ (ក្នុងករណីខ្លះជាបណ្តោះអាសន្នប៉ុណ្ណោះ) ដែលបានកាត់បន្ថយសមត្ថភាពរបស់ពួកគេក្នុងការទប់ទល់នឹងគ្រោះធម្មជាតិជាជាងអត្តសញ្ញាណសង្គមដែលបានបង្កប់យ៉ាងស៊ីជម្រៅរបស់ពួកគេ"។*<br><br>៧១. សហគមន៍មូលដ្ឋាន ប្រព័ន្ធអេកូឡូស៊ី និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីរំពឹងថានឹងទទួលរងផលប៉ះពាល់ដោយសារការការកើនឡើងនៃការប្រែប្រួលអាកាសធាតុ ដែលបណ្តាលឱ្យមានការកើនឡើងនៃសីតុណ្ហភាព និងការប្រែប្រួលរបបទឹកភ្លៀងនៅក្នុងប្រទេសទាំងមូល។ តំបន់ភាគខាងជើងនៃបឹងទន្លេសាបត្រូវបានគេរំពឹងថានឹងរងផលប៉ះពាល់ដោយការបាត់បង់និងខូចខាតដំណាំ រួមទាំងការបាត់បង់ជីវចម្រុះផងដែរ។<br>៧២. ក្រុមជនដែលមិនត្រូវបានទទួលការយកចិត្តទុកដាក់ត្រូវបានកំណត់ថាជា "... ក្រុមជនដែលបានទទួលការរើសអើងអន្តរជំនាន់ ហើយមិនត្រូវបានទទួលការយកចិត្តទុកដាក់ជាប្រព័ន្ធដោយសារ [ស្ថានភាព] សេដ្ឋកិច្ច វណ្ណៈ ជាតិសាសន៍ យេនឌ័រ ពិការភាព ទំនោរផ្លូវភេទ និងហេតុផលភូមិសាស្ត្រផ្សេងៗ"។ ក្រុមជនទាំងនោះរួមបញ្ចូលទាំងក្រុមស្ត្រី ជនក្រីក្រ ជនពិការ ជនភេទទីបី និងប្រជាជនរស់នៅតំបន់ដាច់ស្រយាល។ ស្ត្រីមានប្រមាណ ៤០% - ៦០% ក្នុងចំណោមអ្នកទទួលពីផលគម្រោង។<br>៧៣. ការប្រែប្រួលអាកាសធាតុនឹងមានផលប៉ះពាល់អវិជ្ជមានមិនសមាមាត្រលើសហគមន៍ដែលមិនទទួលការយកចិត្តទុកដាក់ទាំងនេះ ហេតុដូច្នេះវាមានសារៈសំខាន់ដែលសកម្មភាពគម្រោងផ្តល់សិទ្ធិអំណាច និងធានាឱ្យមានការចូលរួមពីក្រុមងាយរងគ្រោះជាពិសេសទាំងនេះ។ ខណៈពេលដែលក្រុមទទួលផលគម្រោងទាំងអស់អាចត្រូវបានចាត់ទុកថាងាយរងគ្រោះ គម្រោងនេះត្រូវបានរៀបចំឡើងដើម្បីរួមបញ្ចូលសកម្មភាពដែលជួយដល់ក្រុមទទួលផលចម្រុះ រួមទាំងក្រុមដែលបានទទួលការយកចិត្តទុកដាក់ដើម្បីធានាថាភាពងាយរងគ្រោះផ្សេងៗគ្នា បរិបទ អាទិភាព និងតម្រូវការត្រូវបានយកមកពិចារណាដើម្បីបង្កើនភាពធន់ និងសមត្ថភាពសម្របខ្លួនរបស់ពួកគេ។ |

៧៤. ក្រុមជនទទួលផលពីគម្រោងសំខាន់នឹងជាកសិករក្នុងស្រុក និងអង្គការតាមសហគមន៍កសិករនានា។ នៅក្នុងលក្ខខណ្ឌនៃក្រុមជនទទួលផលផ្ទាល់ គម្រោងនេះនឹងកំណត់គោលដៅយកកសិករខ្នាតតូចចំនួន ១៣៥.០០០ នាក់ និងតួអង្គក្នុងខ្សែច្រវាក់តម្លៃក្នុងស្រុកផ្សេងទៀត ជាមួយនឹងការទទួលបានហិរញ្ញវត្ថុកាន់តែប្រសើរឡើង និងបង្កើនល្បឿនការគាំទ្រសម្រាប់ការទទួលយកការអនុវត្ត និងបច្ចេកវិទ្យានានាដែលធន់ទ្រាំទៅនឹងការបម្រែបម្រួលអាកាសធាតុ។ និងកសិករទទួលផលភ្ជាល់ចំនួន ៤៥០.០០០ នាក់ និងកសិករទទួលផលដោយប្រយោលចំនួនជាង ១ លាននាក់ ព្រមទាំងតួអង្គក្នុងខ្សែច្រវាក់តម្លៃផ្សេងទៀត។ យ៉ាងហោចណាស់ ប្រមាណ ៤០% - ៦០% នៃក្រុមជនទទួលផលពីគម្រោងជាស្ត្រី ហើយគម្រោងនេះនឹងលើកកម្ពស់ការចូលរួមនៃជនជាតិដើមភាគតិច និងក្រុមដែលខ្វះខាតផ្សេងទៀត។ ប្រជាជនទាំងមូលនៃតំបន់គម្រោង PEARL នឹងទទួលបានអត្ថប្រយោជន៍ដោយប្រយោលពីគម្រោងនេះតាមរយៈការរៀបចំយុទ្ធសាស្ត្រទប់ទល់នឹងអាកាសធាតុសម្រាប់តំបន់ PEARL។ លើសពីនេះ សមត្ថភាពក្នុងស្រុកនឹងត្រូវបានលើកកម្ពស់បន្ថែមលើការរៀបចំផែនការ និងការគ្រប់គ្រងការប្រើប្រាស់ដីដែលធន់ទ្រាំនឹងការបម្រែប

ម្រួលអាកាសធាតុ ដែលនឹងជះឥទ្ធិពលរយៈពេលវែងដើម្បីបន្តកសាងភាពធន់របស់សហគមន៍នៅក្នុងតំបន់តំបន់ភាគខាងជើងនៃបឹងទន្លេសាបនៃប្រទេសកម្ពុជា។

## ២.៤ ការរៀបចំការអនុវត្តគម្រោង[4]

៧៥. ក្របខ័ណ្ឌស្ថាប័នសម្រាប់ការអនុវត្តគម្រោងនេះនឹងមានចូលរួមជាមួយភាគីពាក់ព័ន្ធជាច្រើនដើម្បីធានានូវការចូលរួមរបស់ពួកគេជាប្រចាំចាប់ពីការរៀបចំគម្រោងរហូតដល់ការអនុវត្ត ការត្រួតពិនិត្យ និងដំណាក់កាលវាយតម្លៃ (M&E) និងក្របខ័ណ្ឌស្ថាប័នសម្រាប់ការអនុវត្តនេះត្រូវបានបង្ហាញក្នុងរូបភាពទី ៣ ខាងក្រោម។

៧៦. ការរៀបចំការគ្រប់គ្រង និងការអនុវត្តដែលបានស្នើឡើងក្នុងគម្រោង PEARL គឺជាលទ្ធផលផ្ទាល់នៃការពិភាក្សាដែលកំពុងបន្តរវាងអង្គការ FAO និងស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិ រួមទាំង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងសាទនិង និងក្រសួងបរិស្ថានក្នុងចំណោមស្ថាប័នផ្សេងទៀត ហើយជាតុចូលបន្ថែមត្រូវបានផ្តល់ដោយភាគីពាក់ព័ន្ធការខេត្ត និងមូលដ្ឋានគោលដៅតាមរយៈការពិគ្រោះយោបល់របស់លើគម្រោង។

៧៧. អង្គការ FAO នឹងដើរតួជាអង្គភាពទទួលស្គាល់ដោយ GCF (AE) ដើម្បីដឹកនាំការរៀបចំគម្រោង និងការ វាយតម្លៃ និងត្រួតពិនិត្យការអនុវត្ត ធានាបាននូវបទដ្ឋានប្រតិបត្តិការ តាមបទដ្ឋានបច្ចេកទេសសមស្រប ដោយមានការត្រួតពិនិត្យ និងវាយតម្លៃការប្រកបដោយការទទួលខុសត្រូវខ្ពស់។ ផ្អែកលើភាពជាអ្នកដឹកនាំជារួម ជំនាញជាក់លាក់តាមប្រទេស និងកំណត់ត្រាយូរអង្វែងនៃការគាំទ្ររាជរដ្ឋាភិបាលកម្ពុជាក្នុងវិស័យ កសិកម្ម រុក្ខាប្រមាញ់ នេសាទ និងការដោះស្រាយការប្រែប្រួលអាកាសធាតុរបស់អង្គការ FAO ជាស្ថាប័នជំនាញដែលមានតួនាទី ក្នុងការរៀបចំ និងអនុវត្តគម្រោងដែលបានស្នើឡើង ដូចដែលបានបញ្ជាក់ច្បាស់ក្នុងលិខិតគាំទ្ររបស់អង្គភាពជាតិទទួលបន្ទុក (NDA) (ឧបសម្ព័ន្ធទី ១ នៃសំណើគម្រោង)។

៧៨. ក្នុងអំឡុងពេលនៃការអនុវត្តគម្រោង NDA នឹងធានាឱ្យមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព រវាងគម្រោងPEARL និងគម្រោង CAVS ដែលផ្តល់មូលនិធិដោយ GCF ផ្សេងទៀតដែលដឹកនាំដោយ ADB ដោយសារគម្រោងទាំងពីរមានធាតុផ្សំសំខាន់នៃការឆ្លើយតបប្រកបដោយសុខដុមរមនារបស់កម្ពុជាចំពោះការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម ដែលបញ្ជាក់យ៉ាងក្នុង NDC និង CCCSP របស់ខ្លួន។ នៅក្រោមក្របខ័ណ្ឌសកម្មភាពរួម ក្រសួងបរិស្ថានជាស្ថាប័នស្នូលសម្រាប់មូលនិធិបរិស្ថានសកល (GEF) រួមជាមួយអង្គការ FAO ធានានូវការបំពេញបន្ថែមលើគម្រោងPEARL តាមរយៈនៃការអនុវត្តគម្រោង GEF7/LDCF ដែលដឹកនាំដោយFAO ជុំវិញបឹងទន្លេសាប។

### អង្គភាពប្រតិបត្តិគម្រោង

៧៩. អង្គភាពប្រតិបត្តិគម្រោង (EEs) គឺអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងសាទ (GDA/MAFF) រួមជាមួយអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាននៃដែលជាផ្នែកនៃ NDA (GDLC/MOE) របស់កម្ពុជាសម្រាប់សម្របសម្រួលជាមួយ GCFនិងអង្គការ FAO ប្រចាំកម្ពុជា។ គម្រោងនេះក៏នឹងសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងពាណិជ្ជកម្ម (MoC) ក្រសួងធនធានទឹក និងឧតុនិយម (MoWRAM) ធនាគារអភិវឌ្ឍន៍កសិកម្ម និងជនបទ (ARDB) និង អង្គការក្រៅរដ្ឋាភិបាលជាដៃគូ (រួមមានអង្គការ GRET, IRAM និង WCS)។ អង្គភាពជាដៃគូទាំងនេះត្រូវបានកំណត់ជាដៃគូអនុវត្តគម្រោងនៅក្នុងសំណើនេះ ដូចដែលបានពិពណ៌នាក្នុងផ្នែកខាងក្រោម។

[4] Additional information on the institutional arrangements can be found in the Feasibility Study

៨០. សហអង្គភាពប្រតិបត្តិគម្រោង Co-EEs (GDA/MAFF, និង GDLC/MOE) បានឆ្លងកាត់ការវាយតម្លៃដោយឯករាជ្យ (ឧទាហរណ៍ ការវាយតម្លៃ HACT) ដើម្បីកំណត់សមត្ថភាពប្រតិបត្តិការ ការគ្រប់គ្រងហិរញ្ញវត្ថុ និងសមត្ថភាពផ្នែករដ្ឋបាលរបស់ពួកគេក្នុងការគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវខ្ពស់។ ការវាយតម្លៃ HACT ទាំងនេះបានបង្ហាញថាដៃគូ EE ដែលបានស្នើឡើងនៅក្នុងគម្រោង PEARL ទាំងអស់មានប្រព័ន្ធរឹងមាំគ្រប់គ្រាន់អាចជាដៃគូដែលអាចទុកចិត្តបានសម្រាប់ការអនុវត្តសកម្មភាពដែលបានស្នើឡើងនេះ។

៨១. ក្នុងនាមជាសហអង្គភាពប្រតិបត្តិគម្រោង (Co-EEs) របស់រដ្ឋាភិបាលដែលមានចំណែកធំបំផុតនៃហិរញ្ញប្បទានឥតសំណង និង សកម្មភាពច្រើនបំផុតក្នុងការអនុវត្តនៅក្នុងគម្រោង PEARL នោះ ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងសាទ (MAFF) ក៏ជាស្ថាប័នដឹកនាំ អង្គភាពគ្រប់គ្រងគម្រោង (PMU) ហើយនឹងធានា ការគាំទ្រ និងការសម្របសម្រួលសហការយ៉ាងជិតស្និទ្ធជាមួយអង្គភាពសំខាន់ៗដែលពាក់ព័ន្ធ ថ្នាក់កណ្តាល ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន។ ដោយសារតែគម្រោង PEARL មានគោលបំណងធ្វើការនៅតាមតំបន់ជនបទ ទំនាក់ទំនងកម្រិតមូលដ្ឋាន ការគាំទ្រ និងការសម្របសម្រួលទាំងនេះគឺជាការងារគន្លឹះក្នុងការអនុវត្តគម្រោងប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាព។ ក្រសួងពាក់ព័ន្ធដែលជាដៃគូក្នុងគម្រោង PEARL មានការិយាល័យខេត្តរៀងខ្លួន ជាក់ស្តែងដូចជាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត (PDAFF)។ អង្គភាពថ្នាក់ខេត្តទាំងនេះ មានទាំងចំណេះដឹងក្នុងមូលដ្ឋានគ្រប់គ្រាន់ និងសមត្ថភាពផ្សព្វផ្សាយដើម្បីអនុវត្តរាល់សកម្មភាពទាំងអស់ដែលពាក់ព័ន្ធនៃគម្រោង PEARL ប្រកបដោយប្រសិទ្ធភាព។ សកម្មភាពគម្រោងជាក់លាក់នីមួយៗត្រូវបាន "គ្រប់គ្រងដឹកនាំ" ដោយដៃគូនៃគម្រោងមួយ។ ព័តមានលម្អិតនៅកម្រិតអនុសកម្មភាព និងតួនាទី និងទំនួលខុសត្រូវជាក់លាក់ត្រូវបានបង្ហាញនៅក្នុងផ្នែក E.៦ និងឧបសម្ព័ន្ធទី ៤។

## ដៃគូអនុវត្តគម្រោង

៨២. គម្រោងនេះក៏នឹងគិតគូលើដៃគូអនុវត្តផ្សេងៗទៀត (IPs) (ឧ. ក្រសួងពាណិជ្ជកម្ម (MoC) ក្រសួងធនធានទឹក និងឧតុនិយម (MoWRAM) ធនាគារអភិវឌ្ឍន៍កសិកម្ម និងជនបទ (ARDB), អង្គការមិនមែនរដ្ឋាភិបាល និដៃគូបាក់ព័ន្ធផ្សេងៗទៀត)។ ដៃគូទាំងនេះ មានជំនាញឯកទេស ចំនេះដឹង និងអាណត្តិ ហើយអាចផ្តល់នូវការយល់ដឹង និងសេវាកម្មចាំបាច់ដើម្បីសម្រេចបានលទ្ធផលរបស់គម្រោងដែលរំពឹងទុក។ ក្នុងករណីខ្លះ បុគ្គលិកដែលផ្តល់ហិរញ្ញប្បវត្ថុរបស់គម្រោង នឹងធ្វើការពិគ្រោះយោបល់ និងសម្របសម្រួលជាមួយដៃគូអនុវត្តផ្សេងៗទៀត (IPs) ដើម្បីរៀបចំ និងជូនដំណឹងអំពីសកម្មភាពជាក់លាក់ដែលត្រូវប្រគល់ជូនដែលស្ថិតនៅក្រោមគម្រោង។ ក្នុងករណីផ្សេងទៀត ដៃគូអនុវត្តផ្សេងៗទៀត (IPs) នឹងត្រូវបានចូលរួមនៅក្នុងគម្រោងតាមរយៈលិខិតកិច្ចព្រមព្រៀង (LoAs) ឬកិច្ចសន្យាផ្សេងៗ ដើម្បី ផ្តល់សេវាកម្មជាក់លាក់ដល់គម្រោង ដើម្បីគាំទ្រដល់អ្នកទទួលផលជាក់លាក់របស់គម្រោង ។ តួនាទី និងទំនួលខុសត្រូវរបស់ពួកគេត្រូវបានរៀបរាប់លម្អិតនៅក្នុងផែនការថវិកា (ឧបសម្ព័ន្ធទី ៤ នៃសំណើរគម្រោងនេះ)។




*រូបភាពទី 3. ការរៀបចំការអនុវត្តគម្រោង*

## គណៈកម្មាធិការគ្រប់គ្រងគម្រោង

៨៣. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) ដែលជាស្ថាប័នជាតិខ្ពស់ជាងគេ និងជាអង្គភាពទទួលផលជាតិដ៏សំខាន់ ក្នុងក្របខ័ណ្ឌគម្រោងនេះ នឹងរៀបចំបង្កើត និងធ្វើជាសហប្រធានគណៈកម្មាធិការដឹកនាំគម្រោង (PSC) ជាមួយអង្គការ FAO។ គណៈកម្មាធិការនេះនឹងមានសមាជិកដែលជាតំណាងមកពីក្រសួងពាក់ព័ន្ធ ដៃគូអនុវត្តផ្សេងៗទៀត។ គណៈកម្មាធិការដឹកនាំគម្រោង (PSC) ក៏នឹងអញ្ជើញតំណាងមកពីអង្គការ សង្គមស៊ីវិលពាក់ព័ន្ធ វិស័យឯកជន និងអ្នកសិក្សាតាមការចាំបាច់ ដើម្បីពិភាក្សាអំពីបញ្ហាប្រធានបទ ក៏ដូចជា ឱកាសនៃភាពជាដៃគូក្នុងក្របខ័ណ្ឌគម្រោង។ ទំនួលខុសត្រូវចម្បងរបស់ គណៈកម្មាធិការដឹកនាំគម្រោង (PSC) នឹងផ្តល់ការណែនាំជាយុទ្ធសាស្ត្រ និងគាំទ្រការសម្របសម្រួលក្នុងចំណោមស្ថាប័នរដ្ឋាភិបាល ហើយនឹងផ្តល់ការត្រួតពិនិត្យទូទៅសម្រាប់ការអនុវត្ត គម្រោង។ គណៈកម្មាធិការដឹកនាំគម្រោង (PSC) នឹងទទួលខុសត្រូវបន្ថែមទៀតសម្រាប់ការពិនិត្យឡើងវិញ និងអនុម័តផែនការការងារប្រចាំឆ្នាំ ថវិកា និងរបាយការណ៍វឌ្ឍនភាព និងការផ្តល់ការណែនាំជាយុទ្ធសាស្ត្រសម្រាប់ការដោះស្រាយហានិភ័យ និងបញ្ហាដែលមិនអាចដោះស្រាយបានដោយ អង្គភាពគ្រប់គ្រងគម្រោង (PMU) តែម្នាក់ឯង។ ពួកគេនឹងអនុម័តសៀវភៅណែនាំការអនុវត្តគម្រោង (PIM) និងគោលការណ៍ណែនាំស្តីពីការរាយការណ៍គម្រោង (PRG) ដែលរៀបចំដោយ អង្គភាពគ្រប់គ្រងគម្រោង (PMU) ក្នុងដំណាក់កាលចាប់ផ្តើម។ កិច្ចប្រជុំ គណៈកម្មាធិការដឹកនាំគម្រោង (PSC) នឹងធ្វើឡើងពីរដងក្នុងមួយឆ្នាំ៖ មុនពេលផែនការថវិកាប្រចាំឆ្នាំ និងបន្ទាប់ពីការបិទឆ្នាំសារពើពន្ធ។

## អង្គភាពគ្រប់គ្រងគម្រោង (PMU)

៨៤. អង្គភាពគ្រប់គ្រងគម្រោង (PMU) នឹងត្រូវបានបង្កើតឡើងនៅក្រោមអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងសាទ (GDA/MAFF)។ អង្គភាពនេះ នឹងត្រូវបានគ្រប់គ្រងដោយអ្នកសម្របសម្រួលគម្រោងដែលនឹងទទួលខុសត្រូវក្នុងការអនុវត្តគម្រោង និងការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធទាំងអស់។ អង្គភាពគ្រប់គ្រងគម្រោង (PMU) នឹងទទួលខុសត្រូវក្នុងការធានាការអនុវត្ត និងការត្រួតពិនិត្យសកម្មភាពប្រចាំថ្ងៃ

តាមរយៈការសម្របសម្រួលជាមួយ អង្គភាពប្រតិបត្តិគម្រោង (EEs) គុណភាពបច្ចេកទេសនៃលទ្ធផលគម្រោង ការចូលរួមពីភាគីពាក់ព័ន្ធប្រកបដោយ ប្រសិទ្ធភាព និងការការពារគម្រោង និងអ្នកទទួលផលរបស់គម្រោង។ អ្នកសម្របសម្រួលគម្រោងដែលជ្រើសរើស ចេញពីសមភាគីរដ្ឋាភិបាល និងតែងតាំងដោយ GDA/MAFF នឹងក្លាយជានាយកគម្រោង ។

៨៥. ដោយមានដ៏ច្រើនលើការងារលទ្ធកម្មត្រូវបានរំពឹងទុកនៅក្នុងគម្រោង PEARL ជាពិសេសទាក់ទងនឹងយន្តការកសាងភាពធន់ក្នុងវិស័យកសិកម្មដែលដឹកនាំដោយកសិករ (FARM) ដែលបានស្នើឡើងក្រោមលទ្ធផល ២.២ អង្គភាពគ្រប់គ្រងគម្រោង (PMU) នឹងត្រូវបានជួយដោយបុគ្គលិកបន្ថែម បន្ថែមលើសមាជិកបុគ្គលិកស្នូលរបស់អង្គភាពគ្រប់គ្រងគម្រោង (PMU) ដើម្បីគាំទ្រការទទួលខុសត្រូវរបស់ខ្លួនសម្រាប់ការផ្តួចផ្តើម និងបញ្ចប់ករណីលទ្ធកម្មទាំងអស់ឱ្យបានទាន់ពេលវេលា និងផ្តល់ជំនួយដល់ក្រុមអ្នកទទួលផលក្នុងការធ្វើការទូទាត់ឡើងវិញឲ្យបានទាន់ពេលវេលា។ លើសពីនេះ គម្រោងក៏នឹងជ្រើសរើសអ្នកជំនាញថ្នាក់ជាតិលើការងារការពារបរិស្ថាននិងសង្គម ដើម្បីដឹកនាំកិច្ចខិតខំប្រឹងប្រែងរបស់គម្រោងក្នុងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដល់សង្គម និងបរិស្ថាន ខណៈពេលដែលបង្កើនភាពវិជ្ជមាន រួមទាំងបញ្ហាទាក់ទងនឹងយេនឌ័រ (សូមមើលឧបសម្ព័ន្ធទី ៦ និង ៨ នៃកញ្ចប់សំណើគម្រោង)។

៨៦. អង្គភាពគ្រប់គ្រងគម្រោង (PMU) នឹងរៀបចំផែនការការងារប្រចាំឆ្នាំ និងថវិកា រួមទាំងផែនការលទ្ធកម្ម ដែលនឹងត្រូវដាក់ឲ្យពិនិត្យ និងអនុម័តដោយគណៈកម្មាធិការដឹកនាំគម្រោង (PSC) ។ អង្គភាពគ្រប់គ្រងគម្រោង (PMU) ក៏នឹងមានទំនួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ចាប់ផ្តើម របាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស របាយការណ៍ការអនុវត្តប្រចាំឆ្នាំ និងរបាយការណ៍ចំណាយ ដូចដែលបានបង្ហាញនៅក្នុងផ្នែក E.៧។

៨៧. បុគ្គលិកសមាភាគីពីស្ថាប័នរដ្ឋាភិបាល និងបុគ្គលិកគម្រោងដែលនឹងត្រូវបានជ្រើសរើសដោយគម្រោង នឹងធ្វើការរួមគ្នាដើម្បីធានាបាននូវការអនុវត្តគម្រោងប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធភាព។ តួនាទីដាក់លាក់របស់សមាជិកសំខាន់ៗនៃបុគ្គលិ គម្រោងទាំងនេះមានពិពណ៌នានៅក្នុងតារាងទី ៨។

## អង្គភាពសម្របសម្រួលពហុភាគីពាក់ព័ន្ធ

៨៨. ការសម្របសម្រួលពហុភាគីពាក់ព័ន្ធ នឹងត្រូវបានបង្កើតឡើងក្រោមលទ្ធផល ៣.១។ ការគាំទ្រពីស្ថាប័ន និងកិច្ចខិតខំប្រឹងប្រែងសម្របសម្រួល និងយន្តការសម្រាប់គាំទ្រការផ្លាស់ប្តូរផ្អែកលើទីផ្សាររបស់កសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀតទៅកាន់កសិកម្មដែលធន់នឹងអាកាសធាតុ និងមានតម្លៃខ្ពស់នាពេលបច្ចុប្បន្ននៅមានកម្រិត។ លក្ខខណ្ឌនិយតកម្ម និងស្ថាប័ន ត្រូវតែបង្កើតនិងធានាបទដ្ឋានវិញ្ញាបនប័ត្រស្តីពីភាពធន់នឹងការបម្រែបម្រួលអាកាសធាតុដែលកំណត់គោលដៅក្នុងគម្រោង ដើម្បីសម្រេចបាននូវគោលដៅរបស់វា។ វិធីសាស្ត្រជាប្រព័ន្ធក្នុងការលើកកម្ពស់លទ្ធភាពទទួលបានហិរញ្ញវត្ថុដែលគិតគូរពីយេនឌ័រ និងប្រកបដោយបរិយាប័នសម្រាប់កសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀតដោយមិនមានលន្ធខ័ណ្ឌវត្ថុបញ្ចាំ ឬអ្នកធានា គឺចាំបាច់ដើម្បីបំពេញបន្ថែមយន្តការកសាងភាពធន់ក្នុងវិស័យកសិកម្មដែលដឹកនាំដោយកសិករ (FARM) នៅក្រោមលទ្ធផល ២.២ ដើម្បីពន្លឿនការផ្លាស់ប្តូររបស់ពួកគេ។ គម្រោង PEARL ក៏នឹងធ្វើឱ្យប្រសើរឡើងនូវភាពជាដៃគូសាធារណៈ និងឯកជន ដែលបច្ចុប្បន្នមានកំណត់នៅឡើយ និងយន្តការសម្របសម្រួលអន្តរ វិស័យ ដើម្បីគាំទ្រដល់ការផ្លាស់ប្តូរទៅកសិកម្មដែលធន់នឹងការបម្រែបម្រួលអាកាសធាតុ។ នៅក្រោមលទ្ធផលនេះ គម្រោង PEARL នឹងជួយដោយផ្ទាល់ជាមួយនឹងការទទួលស្គាល់របស់ GCF នៃ ធនាគារអភិវឌ្ឍន៍កសិកម្ម និងជនបទ (ARDB) ព្រោះថាធានាគារនេះនឹងដើរតួនាទីសម្របសម្រួលដ៏សំខាន់សម្រាប់សកម្មភាព ៣.១.២ ដើម្បីរៀបចំ និង

ដំណើរការប្រព័ន្ធពិន្ទុសម្រាប់វិស័យហិរញ្ញវត្ថុកសិកម្ម។ នៅពេលត្រូវបានទទួលស្គាល់ដោយ GCF នោះ ធនាគារអភិវឌ្ឍន៍កសិកម្ម និងជនបទ (ARDB) ត្រូវបានគេរំពឹងថានឹងបង្កើតនៅលើប្រព័ន្ធពិន្ទុ ដើម្បីបង្កើតគម្រោង GCF បំពេញបន្ថែមសម្រាប់ពង្រីកហិរញ្ញប្បទានកសិកម្មដែលមានតម្លៃទាប ដើម្បីគាំទ្រដល់ការផ្លាស់ប្តូរលឿនរបស់កម្ពុជាទៅកាន់វិស័យកសិកម្មដែលធន់នឹងអាកាសធាតុ។

៨៩. ការសម្របសម្រួល និងការចូលរួមរបស់ភាគីពាក់ព័ន្ធ ក៏ត្រូវបានដោះស្រាយនៅក្នុងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យរបស់គម្រោងផងដែរ។ ខណៈពេលដែលមាន គណៈកម្មាធិការដឹកនាំគម្រោង (PSC) ជាមួយសមាជិកខ្លួនមកពីក្រសួងតាមវិស័យសំខាន់ៗ អង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជននៅកម្រិតត្រួតពិនិត្យគម្រោងធានានូវការសម្របសម្រួល និង កិច្ចសហការប្រកបដោយប្រសិទ្ធភាពរវាងតួអង្គពាក់ព័ន្ធទាំងនេះ គម្រោងនេះនឹងរួមបញ្ចូលសកម្មភាពជាក់លាក់ដើម្បីកាត់បន្ថយហានិភ័យនេះ រួមមាន៖

- ការកសាងសមត្ថភាពអន្តរវិស័យ (ឧ. ការបណ្តុះបណ្តាល និងការលើកកម្ពស់ការយល់ដឹង) សកម្មភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីកាត់បន្ថយការគិត និងការអនុវត្តន៍តាមវិស័យ។
- កិច្ចព្រមព្រៀងចែករំលែកទិន្នន័យ (ឧ. សកម្មភាព ១.១.២ និង ៣.២.១) និង អនុស្សារណៈនៃការយោគយល់ (ឧ. សកម្មភាព ៣.១.២) ដើម្បីបង្កើតយន្តការសម្របសម្រួល និងកិច្ចសហការជាផ្លូវការ និង
- សកម្មភាព ៣.១.៣ ដើម្បីលើកកម្ពស់ការសម្របសម្រួលអន្តរវិស័យដែលប្រសើរឡើងតាមរយៈ ក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍដោយចិរភាព (NCSD) គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD) និងវេទិកាតាមខេត្ត។

៩០. ក្នុងការសម្របសម្រួលជាមួយ NDA និងចរន្តការងារដែលមានស្រាប់របស់ អង្គភាពប្រតិបត្តិគម្រោង (EEs) និងអ្នកសហការក្នុង វិស័យឯកជន អង្គការ FAO នឹងធ្វើការចែករំលែក និងបច្ចុប្បន្នភាពដល់ក្រុមជនទទួលផលដែលមានសក្តានុពលទាំងអស់ ស្តីពីសំណើរគម្រោង និងការចាប់ផ្តើម និងតាមដានការផ្លាស់ប្តូរនៅក្នុងនិន្នាការទីផ្សារ ឱកាស និង សមត្ថភាព និងលក្ខខណ្ឌមូលដ្ឋាន។ ក្នុងអំឡុងពេលមុន និងបន្ទាប់ពីការចាប់ផ្តើម គម្រោងនឹងបន្តធានាឱ្យ មានទំនាក់ទំនងទ្វេភាគីប្រកបដោយប្រសិទ្ធភាពជាមួយក្រុមជនទទួលផល ដើម្បីធានាថាផលប្រយោជន៍ និងតម្រូវការរបស់ពួកគេត្រូវបានឆ្លុះបញ្ចាំងយ៉ាងល្អនៅក្នុងសកម្មភាពគម្រោងសម្រាប់ការចូលរួមរបស់ពួកគាត់ និងភាគីពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព។

## ៣. លក្ខខណ្ឌមូលដ្ឋាននៃបរិស្ថាន និងសេដ្ឋកិច្ចសង្គម

### ៣.១ លក្ខខណ្ឌបរិស្ថាន

៩១. តំបន់គម្រោងក្នុងតំបន់ តំបន់ភាគខាងជើងនៃបឹងទន្លេសាបនៅផ្នែកខាងក្រោមអាងទន្លេមេគង្គ។

#### ៣.១.១ អាកាសធាតុ

៩២. នៅកម្ពុជា រដូវវស្សាដែលអូសបន្លាយពីខែឧសភា ដល់ដើមខែតុលា (រូបភាពទី ៤) មានចំនួន ៩០% នៃទឹកភ្លៀងប្រចាំឆ្នាំនៅក្នុងអាង។ រដូវប្រាំងចាប់ពីខែវិច្ឆិកាដល់ខែមេសា នាំមកនូវខ្យល់ស្ងួត និងត្រជាក់ជាងពីខែវិច្ឆិកាដល់ខែមីនា ហើយបន្ទាប់មកខ្យល់ក្តៅនៅខែមេសា និងដើមខែឧសភា។ សីតុណ្ហភាពមធ្យមអតិបរមានៅកម្ពុជាគឺប្រហែល ២៨°C និងសីតុណ្ហភាពមធ្យមអប្បបរមាគឺប្រហែល ២២°C។ និន្នាការនៃសីតុណ្ហភាពក្តៅជាងមុន និងអាកាសធាតុស្ងួតគឺបណ្តាលមកពីកត្តា El Niño Southern Os-cillation ចំណែកសីតុណ្ហភាពត្រជាក់ជាងត្រូវបានជះឥទ្ធិពលដោយព្រឹត្តិការណ៍ La Niña (GFDRR, 2011)។ ការវិភាគរបស់អង្គការ FAO លើទិន្នន័យ CORDEX ក្នុងអំឡុងពេល ១៩៨៧-២០១៦ បង្ហាញពីសីតុណ្ហភាពជាមធ្យមអតិបរមា និងសីតុណ្ហភាពអប្បបរមា (រូបភាពទី ៨) នៅទូទាំងប្រទេសកម្ពុជា។




*រូបភាពទី 4. បរិមាណទឹកភ្លៀងជាមធ្យមសរុប (មម) ក្នុងរដូវវស្សាខែឧសភា ដល់ខែតុលា (ឆ្វេង) និងចាប់ពីខែមករា ដល់ខែមេសា (ស្តាំ) ជាមធ្យមក្នុងរយៈពេល ១៩៨៩-២០១៦ (ពីសំណុំទិន្នន័យវិភាគឡើងវិញ W5E5 (FAO))*

*ប្រភព៖ ការវិភាគរបស់អង្គការ FAO*

#### សីតុណ្ហភាព

៩៣. សីតុណ្ហភាពប្រចាំឆ្នាំជាមធ្យមក្នុងប្រវត្តិសាស្ត្រនៅកម្ពុជាក្នុងអំឡុងឆ្នាំ ១៩០១-២០១៦ គឺ ២៧°C។ ជាមធ្យម វាបានកើនឡើង 0.៨°C ពីឆ្នាំ ១៩៦០ ដល់ឆ្នាំ ២០០៣ ជាពិសេសនៅក្នុងរដូវប្រាំង។ ទោះជាយ៉ាងណាក៏ដោយ អត្រានៃការកើនឡើងគឺយឺតជាងក្នុងរដូវវស្សា (World Bank Group, 2020)។ ចំនួនថ្ងៃក្តៅក្នុងមួយឆ្នាំ (សីតុណ្ហភាពអតិបរមា>៣៥°C y-១) បានកើនឡើងតាំងពីឆ្នាំ ១៩៦០ ដែលឈានដល់ជាមធ្យម ៤៦ ថ្ងៃក្តៅនៅឆ្នាំ ២០១៦។ ទឹកភ្លៀងប្រចាំឆ្នាំជាមធ្យមប្រែប្រួលតាមតំបន់ ដោយមានកម្រិត១៤00 មីលីម៉ែត្រនៅតំបន់កណ្តាល និងខ្ពស់ជាងនេះ ដល់ ៤000 mm នៅតំបន់ឆ្នេរសមុទ្រភាគនិរតី និងនៅតំបន់ខ្ពង់រាប (ធឿន, 2015)។ នៅកម្រិតថ្នាក់ជាតិ ការផ្លាស់ប្តូរសំខាន់ៗនៃអត្រាទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំមិនត្រូវបានរកឃើញពីឆ្នាំ ១៩០១ ដល់ឆ្នាំ ២០១៦ ដែលជាលទ្ធផលនៃសមត្ថភាពប្រែប្រួលនៃប្រេកង់ និងអាំងតង់ស៊ីតេខ្ពស់ ដែលរារាំងនិន្នាការទាំងមូល (World

Bank Group, 2020)។ ទោះជាយ៉ាងណាក៏ដោយ អ្នកវិភាគបានណែនាំថា រយៈពេលនៃរដូវវស្សាបានថយចុះជាង មួយសតវត្សចុងក្រោយនេះ (FAO, 2022)។




*រូបភាពទី 5. សីតុណ្ហភាពជាមធ្យមអតិបរមា (ឆ្វេង) និងសីតុណ្ហភាពអប្បបរមា (ស្តាំ) ក្នុងរដូវវស្សា ខែឧសភា ដល់ខែតុលា ក្នុងរយៈពេល ១៩៨៧-២០១៦ ពីសំណុំទិន្នន័យ W5E5*
*ប្រភព៖ ការវិភាគរបស់អង្គការ FAO*

៩៤. ឧប្បត្តិហេតុនៃព្រឹត្តិការណ៍អាកាសធាតុខ្លាំងដូចជាគ្រោះរាំងស្ងួត និងទឹកជំនន់មានភាពខុសប្លែកគ្នា តាមភូមិសាស្ត្រទូទាំងប្រទេស។ តំបន់ទំនាបកណ្តាលជួបប្រទះនឹងទឹកជំនន់តាមរដូវ ដែលនាំមកនូវជីមាន ដីជាតិ និងទឹកភាគច្រើននៅក្នុងតំបន់នេះ។ ភាពញឹកញាប់នៃទឹកជំនន់ធ្ងន់ធ្ងរបានកើនឡើងក្នុងរយៈពេលប្រវត្តិសាស្ត្រចាប់តាំងពីឆ្នាំ ១៩៩០។ ទឹកជំនន់ធ្ងន់ធ្ងរត្រូវបានកត់ត្រាក្នុងឆ្នាំ ១៩៩១, ១៩៩៦, ២០០០, ២០០១, ២០០២ និង ២០១១ (NCDM, 2011)។ ទោះជាយ៉ាងណាក៏ដោយ ទឹកជំនន់នៅក្នុងប្រទេសកម្ពុជាមិនមាន ទំនាក់ទំនងយ៉ាងតឹងរ៉ឹងទៅនឹងភ្លៀងធ្លាក់ខ្លាំងនោះទេ ហើយជារឿយៗត្រូវបានជំរុញដោយកម្ពស់ទឹកក្នុង ទន្លេមេគង្គ និងបឹងទន្លេសាបនៅចន្លោះដើមខែកក្កដា និងដើមខែតុលា។

៩៥. ផ្អែកលើទិន្នន័យពី ២០ ឆ្នាំមុន ការខាតបង់ក្នុងផលិតកម្មស្រូវភាគច្រើនបណ្តាលមកពីទឹកជំនន់ (ប្រហែល ៦២%) និងគ្រោះរាំងស្ងួត (ប្រហែល ៣៦%)។ ក្នុងរដូវប្រាំង ការដាំដុះស្រូវត្រូវបានប្រមូលផ្តុំនៅតំបន់ដែលមានទឹកល្អ នៅតំបន់អាងទន្លេមេគង្គក្រោម និងជុំវិញបឹងទន្លេសាប។

៩៦. គ្រោះរាំងស្ងួតនៅកម្ពុជាមានទំនាក់ទំនងយ៉ាងខ្លាំងជាមួយ El Nino ជាឧទាហរណ៍ ក្នុងអំឡុងព្រឹត្តិការណ៍ El Nino ឆ្នាំ ២០១៥/២០១៦ ដែលជាគ្រោះរាំងស្ងួតដ៏អាក្រក់បំផុតមួយសម្រាប់អាស៊ីអាគ្នេយ៍ក្នុង រយៈពេលជាច្រើនទសវត្សរ៍ ដែលមនុស្ស ២.៤ លាននាក់នៅទូទាំង ១៨ ខេត្តក្នុងប្រទេសកម្ពុជាត្រូវទទួលរងផលប៉ះពាល់។ យោងតាមការវាយតម្លៃរួមគ្នាជាមួយ ២៤០០ គ្រួសារដោយ WFP, FAO និង UNICEF ក្នុងខែឧសភា ឆ្នាំ ២០១៦, ៣៧% នៃគ្រួសារបានរាយការណ៍ពីការខ្វះខាតទឹក ១៨% នៃគ្រួសារកសិកម្មជួបប្រទះការបរាជ័យដំណាំ ផលិតកម្មស្រូវ និងដំឡូងមីបានធ្លាក់ចុះ ២២% អត្រាជំងឺ និងអត្រាមរណៈរបស់សត្វមានកម្រិតខ្ពស់ ជាពិសេសសម្រាប់បសុបក្សី។ ៦២% នៃគ្រួសារបានរាយការណ៍ពីការបាត់បង់ប្រាក់ចំណូល។ កំណើនកសិកម្មមានការធ្លាក់ចុះយ៉ាងខ្លាំងក្នុងអំឡុងពេលនោះ (រូបភាពទី ១០)។

## ដី និងភូគព្ភសាស្ត្រ

៩៧. ទឹកភ្លៀងប្រចាំឆ្នាំជាមធ្យមក្នុងតំបន់ប្រែប្រួលពី ១០០០ ទៅ ១៥០០ មីលីម៉ែត្រ។ មានប្រភេទដីសំខាន់ៗចំនួន ១០ និងតំបន់ទីជម្រាលសំខាន់ៗចំនួន ៥ រួមទាំងស្ទឹងសែន និងស្ទឹងស្ទោង ដែលជាប្រភពទឹកដ៏សំខាន់

សម្រាប់ផលិតកម្មស្រូវ និងការចិញ្ចឹមជីវិតក្នុងតំបន់ (Oeurng et al., 2019)។ ជាង ២០% នៃផលិតកម្មស្រូវក្រអូប របស់ប្រទេស ក្នុងចំណោមផលិតផលផ្សេងទៀតដូចជាដំឡូងមី (៣៥%) និងអំពៅ (២៧%) បាន មកពីតំបន់នេះ (NIS, 2019)។

## ៣.១.២ ការប្រើប្រាស់ដី

៩៨. ជាង ២០% នៃផលិតកម្មស្រូវក្រអូបរបស់កម្ពុជា ក្នុងចំណោមផលិតផលផ្សេងទៀតដូចជាដំឡូងមី (៣៥%) និងអំពៅ (២៧%) បានមកពីតំបន់គម្រោង (NIS, 2019)។

៩៨ . ទឹកភ្លៀងប្រចាំឆ្នាំជាមធ្យមក្នុងតំបន់ប្រែប្រួលពី ១000 ទៅ ១៥00 មីលីម៉ែត្រ។ មានប្រភេទដីសំខាន់ៗចំនួន ១០ និងតំបន់ទីជម្រាលសំខាន់ៗចំនួន ៥ រួមទាំងស្ទឹងសែន និងស្ទឹងស្ទោង ដែលជាប្រភពទឹកដ៏សំខាន់សម្រាប់ ផលិតកម្មស្រូវ និងការចិញ្ចឹមជីវិតក្នុងតំបន់ (Oeurng et al., 2019)។ ជាង ២០% នៃផលិតកម្មអង្ករក្រអូបរបស់ ប្រទេស ក្នុងចំណោមផលិតផលផ្សេងទៀតដូចជាដំឡូងមី (៣៥%) និងអំពៅ (២៧%) បានមកពីតំបន់នេះ (NIS, 2019)។

១00. ក្នុងចំណោមដំណាំសំខាន់ៗដែលផលិតក្នុងប្រទេសកម្ពុជា អង្ករគឺជាដំណាំចម្បង និងសំខាន់តែមួយគត់ នៅក្នុងប្រទេស ដែលផ្តល់នូវតម្រូវការអាហារូបត្ថម្ភជិត ៧0% និង ចូលរួមស្មើរតែ ៨0% នៃផលិតកម្មដំណាំសរុប របស់ប្រទេសកម្ពុជា (MoE, 2015a; MAFF, 2017 ) ផលិតកម្មស្រូវបានចូលរួមប្រហែល ១៥% នៃផលិតផល ក្នុងស្រុកសរុប (GDP) របស់ប្រទេស ហើយគ្របដណ្តប់ប្រហែល ៧៥% នៃផ្ទៃដីដាំដុះសរុប (IFC, 2015)។ ការ ពង្រីកវិស័យកសិកម្ម ដែលគាំទ្រដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេសក្នុងអំឡុង ទសវត្សរ៍កន្លងទៅនេះ ក៏បានកើត ឡើងផងដែរ ដោយការចំណាយលើការរេចរឹលបរិស្ថាន ភាគច្រើនតាមរយៈ ការកាប់បំផ្លាញព្រៃឈើ ដើម្បីជា មធ្យោបាយសម្រាប់ផលិតដំណាំ ជាពិសេសដំណាំសាច់ប្រាក់ ដូចជាដំឡូងមីជាដើម។

១០១. កសិកម្មក៏ជាកត្តាជំរុញដ៏សំខាន់មួយនៃការកាប់បំផ្លាញព្រៃឈើ និងការរេចរឹលព្រៃឈើតាមរយៈការទន្ទ្រាន និងការបំប្លែងព្រៃឈើទៅជាដីដំណាំ ដូចដែលបានពិពណ៌នានៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិ (ឆ្នាំ ២០១៧)។ បញ្ហា នៃការកាប់បំផ្លាញព្រៃឈើ និងការរេចរឹលព្រៃឈើបានកើតឡើងខ្លាំងនៅតំបន់ភាគខាងជើងនៃបឹងទន្លេសាបដោយ សារតែការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃការប្រើប្រាស់ដីសម្រាប់ការពង្រីកវិស័យកសិកម្មតាមរយៈ សម្បទានដីសេដ្ឋ កិច្ច (ELCs) (Forest Trends, 2015)។

## ៣.១.៣ ជីវៈចម្រុះ បរិស្ថាន និងព្រៃឈើ

### ការអភិរក្សកសិកម្ម និងបរិស្ថាន

១០២. ផែនការយុទ្ធសាស្ត្រ និងសកម្មភាពជាតិស្តីពីជីវៈចម្រុះ (NBSAP) (២០១៦) គូសបញ្ជាក់អំពីតួនាទី សំខាន់ វិស័យកសិកម្មក្នុងការថែរក្សា និងការស្តារឡើងវិញនូវសេវាប្រព័ន្ធអេកូឡូស៊ី និងភាពចម្រុះជីវសាស្ត្រ។ កសិកម្មត្រូវ បានពិពណ៌នាថាជាមធ្យោបាយដ៏សំខាន់មួយសម្រាប់ការលើកកម្ពស់ការអភិរក្សជីវៈចម្រុះ និងការស្តារប្រព័ន្ធអេកូឡូ ស៊ី និងការដោះស្រាយកត្តាដែលនាំទៅដល់ការបាត់បង់ទីជម្រក និងការរេចរឹល (ibid.)។ កសិកម្មក៏ជាកត្តាជំរុញដ៏ សំខាន់មួយនៃការកាប់បំផ្លាញព្រៃឈើ និងការរេចរឹលព្រៃឈើតាមរយៈការទន្ទ្រាន និងការបំប្លែងព្រៃឈើទៅជាដី ដំណាំ ដូចដែលបានពិពណ៌នានៅក្នុងយុទ្ធសាស្ត្ររេដបូកជាតិ (២០១៧)។ បញ្ហានៃការកាប់បំផ្លាញព្រៃឈើ និង ការរេចរឹលព្រៃឈើបានកើតឡើងខ្លាំងតំបន់ភាគខាងជើងនៃបឹងទន្លេសាប ដោយសារតែការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស នៃការប្រើប្រាស់ដីសម្រាប់ការពង្រីកកសិកម្មតាមរយៈសម្បទានដី សេដ្ឋកិច្ច (ELCs) (Forest Trends, 2015)។

១០៣. ដោយមើលឃើញពីតួនាទីសំខាន់របស់វិស័យនៅក្នុងសេដ្ឋកិច្ចរបស់ប្រទេស សកម្មភាពក្នុងវិស័យនេះទាមទារឱ្យមានការពិចារណាយ៉ាងប្រុងប្រយ័ត្ន ព្រោះវាមានផលប៉ះពាល់យ៉ាងសំខាន់លើនិរន្តរភាពអេកូឡូស៊ី របស់វិស័យ និងសុខុមាលភាពសេដ្ឋកិច្ចសង្គមរបស់ប្រជាជននៅជនបទ ដែលកត្តាទាំងពីរនេះគឺជាលក្ខខណ្ឌ ចាំបាច់សម្រាប់ភាពជោគជ័យនៃការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (NCSD, 2016; RGC, 2018c)។ ក្នុងទិដ្ឋិភាពនេះ ទាំងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (ASDP) (2015) និង CCPAP-AFF ជំរុញឱ្យមានសកម្មភាពលើកកម្ពស់វិស័យកសិកម្មដែលមានការបំភាយឧស្ម័នផ្ទះកញ្ចក់ទាប តាមរយៈ ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព ទាំងកម្រិតកសិកម្ម និងទេសភាព និងអនុវត្តកសិកម្មឆ្លាតវៃ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះនៃប្រព័ន្ធស្បៀងអាហាររបស់ប្រទេស និងសហគមន៍កសិកម្មជនបទ។

១០៤. ទោះជាយ៉ាងណាក៏ដោយ ទិសដៅយុទ្ធសាស្ត្របែបនេះប្រឈមមុខនឹងបញ្ហាប្រឈមមួយចំនួន។ ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម (២០១២) គឺសំដៅលើការគ្រប់គ្រងសារធាតុគីមីកសិកម្មដើម្បីធានាថាកសិករទាំងអស់មានលទ្ធភាពទទួលបានថ្នាំកសិកម្ម និងជីកសិកម្មដែលមានគុណភាពជាមួយនឹងស្លាកសញ្ញា និងការណែនាំជាភាសាខ្មែរ។ ទោះជាយ៉ាងណាក៏ដោយ ផលិតផលកសិកម្មក្លែងក្លាយ និងគុណភាពអន់ដែលមានស្លាកសញ្ញា និងការណែនាំដែលផ្តល់ជាភាសាបរទេសបានជន់លិចទីផ្សារ ហើយទាំងកសិករ ឬអ្នកលក់មិនត្រូវបានបណ្តុះបណ្តាលឱ្យប្រើប្រាស់ផលិតផលទាំងនេះទេ (Duong and Khin, 2016)។ នេះគូសបញ្ជាក់មិនត្រឹមតែបញ្ហានៃការអនុវត្តប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបញ្ហាដែលប្រទេសកម្ពុជាប្រឈមមុខក្នុងការធានានូវការសម្របសម្រួលអន្តរវិស័យ ឧទាហរណ៍ ដើម្បីរឹតបន្តឹងការអនុញ្ញាតនាំចូល និងនីតិវិធីទម្លាប់ដើម្បីបង្កើនការគ្រប់គ្រង (ibid.)។ លើសពីនេះ កិច្ចខិតខំប្រឹងប្រែងខ្ពស់ក្នុងការរៀបចំកម្មវិធីជាតិ IPM និង CamGAP នៅទូទាំងប្រព័ន្ធស្បៀងគឺត្រូវការជាចាំបាច់ដើម្បីបង្កើនការយល់ដឹង និងចំណេះដឹងរបស់អ្នកផ្គត់ផ្គង់ក្នុងស្រុក របស់កសិករ និងអ្នកផ្គត់ផ្គង់ក្នុងមូលដ្ឋានចំពោះ ការប្រើប្រាស់សារធាតុគីមីកសិកម្មឱ្យបានសមស្រប (ឧ. ៤Rs -ប្រភពត្រឹមត្រូវ អត្រាពេលវេលា និងទីកន្លែង) ក៏ដូចជាការយល់ដឹងអំពីអត្ថប្រយោជន៍ និងទីផ្សារនៃការអនុវត្តកសិកម្មតាមបែបកសិអេកូឡូស៊ី ដូចជាកសិកម្មសរីរាង្គ។

១០៥. ដើម្បីកសាងគំរូជោគជ័យសម្រាប់កសិកម្មដែលធន់នឹងអាកាសធាតុ និងនិរន្តរភាព ការបង្កើនកិច្ចខិតខំ ប្រឹងប្រែង និងការប្តេជ្ញាចិត្តនៅគ្រប់កម្រិតគឺត្រូវការជាចាំបាច់ដើម្បីកែលម្អការយល់ដឹងសាធារណៈ បង្កើនការវិនិយោគសាធារណៈ និងឯកជន និងការផ្ទេរបច្ចេកវិទ្យា និងការពង្រឹងការអនុវត្តច្បាប់ និងការសម្របសម្រួលស្ថាប័ន។

### ៣.១.៤ ធនធានទឹក

១០៦. គ្រោះរាំងស្ងួតនៅកម្ពុជាកើតឡើងជាទៀងទាត់ ហើយត្រូវបានជំរុញដោយរយៈពេលរាំងស្ងួតយូរ និងកម្រិតនៃធនធានទឹកនៅក្នុងអាងទឹកលើដី។ ភាពញឹកញាប់នៃគ្រោះរាំងស្ងួតប្រែប្រួលពីខេត្តមួយទៅខេត្តមួយ ជាមួយនឹងផ្នែកជាច្រើននៃតំបន់ភាគខាងជើងនៃបឹងទន្លេសាបរងផលប៉ះពាល់យ៉ាងខ្លាំង យោងទៅតាមសន្ទស្សន៍ភាពងាយរងគ្រោះនៃគ្រោះរាំងស្ងួត (Rai et al., 2015)។

១០៧. ជាឧទាហរណ៍ ក្នុងខេត្តកំពង់ធំ សន្ទស្សន៍ SPEI រយៈពេល ៣ ខែ (សន្ទស្សន៍ស្តង់ដារទឹកភ្លៀង) បង្ហាញពីនិន្នាការកើនឡើងក្នុងរយៈពេល ១៥ ឆ្នាំចុងក្រោយនេះ ប៉ុន្តែគ្រោះរាំងស្ងួតធ្ងន់ធ្ងរនៅតែបន្តកើតមានជាបន្តបន្ទាប់ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ SPEI គិតគូរទាំងទឹកភ្លៀង និងការរំហួតដែលមានសក្តានុពល ដូច្នេះ ការចាប់យកឥទ្ធិពលនៃការកើនឡើងសីតុណ្ហភាពលើតម្រូវការទឹកជាងសន្ទស្សន៍ទឹកភ្លៀងធម្មតាក្នុងការប៉ាន់ប្រមាណនៃភាពរាំងស្ងួតរបស់វា។ ក្នុងអំឡុងពេលគ្រោះរាំងស្ងួតឆ្នាំ២០១៩ កង្វះខាតទឹកត្រូវបានរាយការណ៍ក្នុងខេត្តភាគច្រើនដែលដាំដុះស្រូវរដូវប្រាំង។

១០៨. តំបន់ដាំដុះស្រូវសំខាន់ៗនៃបឹងទន្លេមេគង្គ-ទន្លេសាប ប្រឈមនឹងទឹកជំនន់ជារៀងរាល់ឆ្នាំ ប៉ុន្តែក្នុង ប៉ុន្មានឆ្នាំចុងក្រោយនេះ តែងតែប្រឈមនឹងទឹកជំនន់ខ្លាំង។ ជាទូទៅ ទឹកជំនន់នៅក្នុងប្រទេសកម្ពុជា មិនមែន ជាបញ្ហាអាកាសធាតុក្នុងស្រុកទាំងស្រុងនោះទេ ដោយសារកម្ពស់ទឹកត្រូវបានប៉ះពាល់យ៉ាងខ្លាំងដោយជលសាស្ត្រ នៅក្នុងអាងទន្លេមេគង្គទាំងមូល។ រយៈពេលយូរនៃទឹកជំនន់ទន្លេមេគង្គ និងបឹងទន្លេសាប បាន បំផ្លាញដំណាំស្រូវក្នុងទឹកជ្រៅជាច្រើន។ ក្នុងឆ្នាំមាន La-Nina ផ្ទៃដីដាំដុះរហូតដល់មួយភាគប្រាំ (០,៥លានហិកតា) នៃស្រូវរដូវវស្សាបានរងគ្រោះដោយទឹកជំនន់។ នៅតំបន់កសិកម្មដែលទឹកជំនន់កើតឡើងជាបណ្តោះអាសន្ន ទឹកជំនន់បណ្តាលឱ្យមានបញ្ហាធ្ងន់ធ្ងរដល់ដំណុះស្រូវពង្រោះ និងដំណាំនៅតំបន់ខ្ពង់រាបរួមទាំងពពួកសណ្តែកផងដែរ។

១០៩. ចាប់ពីឆ្នាំ ២០០០ ដល់ឆ្នាំ ២០១៩ ជាមធ្យម ៤.១% និង ៥.២% នៃផ្ទៃដីដាំដុះស្រូវសរុបត្រូវបានរងផលប៉ះពាល់ ដោយគ្រោះរាំងស្ងួត និងទឹកជំនន់នៅក្នុងខេត្តទាំងបួនក្នុងតំបន់ភាគខាងជើងនៃបឹងទន្លេសាប ដែលស្មើនឹងប្រហែល ៦.០០០ ហិកតា។ ខណៈ ដែលខេត្តកំពង់ធំជាខេត្តដែលរងគ្រោះដោយទឹកជំនន់ខ្លាំងជាងគេនោះ កសិករក្នុងខេត្តឧត្តរមានជ័យប្រឈមនឹងការបាត់បង់ទិន្នផលដោយសារគ្រោះរាំងស្ងួត។ ការវាយតម្លៃរបស់អង្គការ FAO លើតំបន់រងផលប៉ះពាល់ និងរងការខូចខាតដោយសារគ្រោះរាំងស្ងួត និងទឹកជំនន់ក្នុងខេត្តគោលដៅបង្ហាញថា ភាគរយនៃតំបន់រងការខូចខាតមានកម្រិតខ្ពស់សម្រាប់ទឹកជំនន់ធៀបនឹងគ្រោះរាំងស្ងួត ចំនុចនេះបង្ហាញថា ទឹកជំនន់បង្កហានិភ័យធំនៅពេលដែលកសិករខ្វះសមត្ថភាពបន្សាំ នៅពេលប្រឈមមុខនឹងបញ្ហាធំៗនិងព្រឹត្តិការណ៍ទឹកជំនន់។ បញ្ហាប្រឈមនេះគឺពាក់ព័ន្ធជាពិសេសសម្រាប់ផលិតកម្មស្រូវ និងស្វាយចន្ទីក្នុងខេត្តកំពង់ធំ និងសម្រាប់ផលិតកម្មបន្លែក្នុងខេត្តសៀមរាបផងដែរ។

## ៣.២ លក្ខខណ្ឌសេដ្ឋកិច្ច-សង្គម

### ភាពក្រីក្រ

១១០. ប្រជាជនកម្ពុជានៅជនបទដែលពឹងអាស្រ័យលើវិស័យកសិកម្ម ដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចរបស់ប្រទេស។ ភាពក្រីក្រ ធ្វើឱ្យសហគមន៍កសិកម្ម និងគ្រួសារជាច្រើនងាយរងគ្រោះដោយសារព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ និងគ្រោះមហន្តរាយធម្មជាតិដូចជាគ្រោះរាំងស្ងួត និងការបាក់ដី។ ការរេចរឹលបរិស្ថាន ដែលកើតចេញពីការពង្រីកវិស័យកសិកម្មក៏បានធ្វើឱ្យផលប៉ះពាល់បណ្តាលមកពីព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរទាំងនេះ កាន់តែធ្ងន់ធ្ងរថែមទៀត។

### ដីកសិកម្ម

១១១. ផលិតកម្មស្រូវចូលរួមចំណែកប្រហែល ១៥% នៃផលិតផលក្នុងស្រុកសរុប (GDP) របស់ប្រទេស និងគ្របដណ្តប់លើផ្ទៃដីប្រហែល ៧៥% នៃផ្ទៃដីដាំដុះសរុប (IFC, 2015)។ ការពង្រីកវិស័យកសិកម្ម ដែលគាំទ្រដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេស ក្នុងអំឡុងទសវត្សន៍កន្លងទៅនេះ ក៏បានកើតឡើងដោយសារការចំណាយលើការរេចរឹលបរិស្ថាន ភាគច្រើន តាមរយៈការកាប់បំផ្លាញព្រៃឈើ ដើម្បីជាមធ្យោបាយសម្រាប់ផលិតដំណាំ ជាពិសេសដំណាំសាច់ប្រាក់ ដូចជា ដំឡូងមីជាដើម។

១១២. ប្រហែល ៨០% នៃផលិតកម្មស្រូវមានប្រភពមកពីពូជក្នុងស្រុកដែលដាំដុះនៅរដូវវស្សា។ ពូជដែលផ្តល់ទិន្នផលខ្ពស់ត្រូវបានដាំជាចម្បងនៅរដូវប្រាំង ហើយចូលរួមចំណែកប្រហែល ២០% នៃផលិតកម្មសរុប។ ប្រហែល ៥០% ស្រូវដែលផលិតក្នុងប្រទេសកម្ពុជាត្រូវបាននាំចេញទៅកាន់ប្រទេសជិតខាង (ជាពិសេសវៀតណាម និងថៃ) ដើម្បីកិន និងចែកចាយបន្ត ដែលជាការបាត់បង់ឱកាសដ៏ធំសម្រាប់រោងម៉ាស៊ីនកិនស្រូវកម្ពុជា។

១១៣. ទោះបីជាមានការរីកចម្រើន និងការពង្រីកជារួមនៃវិស័យកសិកម្មក៏ដោយ ក៏កសិករខ្នាតតូចនៅតំបន់ជនបទមានការយឺតយ៉ាវគួរឱ្យកត់សម្គាល់ពីការរីកចម្រើននេះ ដោយសារសមត្ថភាពរបស់ពួកគេមានកម្រិត និងលទ្ធភាពទទួលបានហិរញ្ញវត្ថុ បច្ចេកវិទ្យា និងព័ត៌មាន។ ប្រហែល ៤៥% នៃកម្លាំងពលកម្មរបស់ប្រទេសគឺ ធ្វើការដោយផ្ទាល់នៅក្នុងវិស័យកសិកម្ម ហើយជាង ៦០% ត្រូវបានរកឃើញនៅតំបន់ជនបទដែលមានអត្រា ភាពក្រីក្រជាញឹកញាប់ខ្ពស់ជាង ២០% ធៀបនឹង ១០% នៅក្នុងរាជធានីរបស់ប្រទេសគឺរាជធានីភ្នំពេញ (RGC, 2014, 2018b). ប្រជាជនកម្ពុជានៅជនបទដែលពឹងអាស្រ័យលើវិស័យកសិកម្ម ដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចរបស់ប្រទេស។ ភាពក្រីក្រ ធ្វើឱ្យសហគមន៍កសិកម្ម និងគ្រួសារជាច្រើនងាយរងគ្រោះដោយសារព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ និងគ្រោះមហន្តរាយធម្មជាតិដូចជាគ្រោះរាំងស្ងួត និងការបាក់ដី។ ការរេចរឹលបរិស្ថាន ដែលកើតចេញពីការពង្រីកវិស័យកសិកម្មក៏បានធ្វើឱ្យផលប៉ះពាល់បណ្តាលមកពីព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរទាំងនេះ កាន់តែធ្ងន់ធ្ងរថែមទៀត។

១១៤. ដោយសារ ៨០% នៃផ្ទៃដីដាំដុះនៅក្នុងប្រទេស (ប្រហែល ៥,៣ លានហិកតា) ត្រូវបានប្រើប្រាស់ជា ចម្បងសម្រាប់កសិកម្មដែលពឹងអាស្រ័យលើទឹកភ្លៀង ហើយមានតែប្រហែល ២០% ប៉ុណ្ណោះដែលត្រូវគ្របដណ្តប់ដោយប្រព័ន្ធស្រោចស្រព កសិករក្នុងប្រទេសកម្ពុជាគឺងាយរងគ្រោះនឹងគ្រោះរាំងស្ងួតយ៉ាងខ្លាំង (ADB, 2018)។ ការជន់លិចតាមរដូវ នៅចន្លោះខែកក្កដា ដល់ខែតុលា ដោយសារកម្រិតទឹកឡើងខ្ពស់ក្នុងទន្លេមេគង្គ និងបឹងទន្លេសាប គឺជាផ្នែកសំខាន់នៃប្រព័ន្ធកសិកម្មក្នុងស្រុក ដែលផ្តល់ជីមានជីជាតិ និងទឹកដល់តំបន់ទំនាបកណ្តាល។ ទោះជាយ៉ាងណាក៏ដោយ ការកើនឡើងនូវភាពមិនអាចទាយទុកជាមុនបានក្នុងវិសាលភាព ពេលវេលា និងរយៈពេលនៃ ទឹកជំនន់តាមរដូវដែលបានសង្កេតឃើញក្នុងប៉ុន្មានទសវត្សរ៍ថ្មីៗនេះ បានធ្វើឱ្យវិស័យកសិកម្ម ជាពិសេសការ ផលិតស្រូវមានការលំបាកសម្រាប់កសិករជាច្រើន។ លើសពីនេះ ទិន្នផលទាប គួបផ្សំនឹងគ្រោះមហន្តរាយធម្មជាតិញឹកញាប់ រួមចំណែកធ្វើឱ្យខ្វះខាតស្បៀងអាហារបណ្តោះអាសន្ន។ ខេត្តចំនួនប្រាំពីរក្នុងចំណោមខេត្តទាំង ២៥ របស់ប្រទេសកម្ពុជា (រួមទាំងរាជធានីភ្នំពេញ) ត្រូវបានចាត់ថ្នាក់ថាជាខេត្តដែលមានអសន្តិសុខស្បៀងធ្ងន់ធ្ងរជាងគេ និងខេត្តប្រាំពីរមានអសន្តិសុខស្បៀងកម្រិតមធ្យម (NIS, 2015)។

### ព្រៃឈើ និងតំបន់ការពារធម្មជាតិ

១១៥. ព្រៃឈើនៅតែជាធាតុសំខាន់នៃការចិញ្ចឹមជីវិតសម្រាប់មនុស្សជាច្រើននៅតំបន់ជនបទ។ សកម្មភាព អភិរក្សតំបន់ព្រៃឈើតាមរយៈការការពារស្របច្បាប់ក្រោមច្បាប់តំបន់ការពារឆ្នាំ ២០០៨ ទទួលស្គាល់ពីតម្រូវការជាប្រចាំសម្រាប់សហគមន៍ចូលទៅកាន់តំបន់ព្រៃឈើ ក៏ដូចជាលក្ខខណ្ឌអំណោយផលឱ្យមានការថែរក្សាតំបន់កសិកម្ម។ ការសិក្សាមួយចំនួនបានកត់សម្គាល់ថា ខណៈពេលដែលតំបន់ការពារ មានការរឹតបន្តឹងមួយចំនួន សុវត្ថិភាពនៃការចូលប្រើប្រាស់ព្រៃឈើ និងការកាន់កាប់ដីមានភាពប្រសើរឡើង ក្នុងករណីជាច្រើនមានភាពប្រសើរឡើង ឬយ៉ាងហោចណាស់មិនមានផលប៉ះពាល់អវិជ្ជមានដល់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន។ ការបង្កើត ក្រុមសហគមន៍ដោយស្មើភាពគ្នា ដើម្បីបង្កើតព្រៃសហគមន៍ ឬតំបន់ការពារសហគមន៍ ក៏បានផ្តល់អត្ថប្រយោជន៍សង្គមទាក់ទងនឹងអភិបាលកិច្ចមូលដ្ឋាន ក៏ដូចជាការទទួលបានព័ត៌មាន និងការកែលម្អការសម្រេចចិត្តលើការប្រើប្រាស់ដីធ្លី។ ទោះជាយ៉ាងណាក៏ដោយ ភស្តុតាងច្បាស់លាស់បង្ហាញថាភាពជោគជ័យក្នុងការអភិវឌ្ឍសហគ្រាសក្នុងវិស័យព្រៃឈើពាក់ព័ន្ធនឹងអនុផលព្រៃឈើ គឺនៅមានកម្រិត ដោយសារបញ្ហាប្រឈមទីផ្សារ។

## ៣.៣ ការផ្លាស់ប្តូររំពឹងទុកជាសក្តានុពលនាពេលអនាគតទទួលបានជាលទ្ធផលពីសកម្មភាពដែលបានគ្រោងទុក

១១៦. បន្ថែមលើសក្តានុពលផ្លាស់ប្តូរគំរូនៃគម្រោង សេវាកម្មប្រឹក្សាកសិឧតុនិយមដែលប្រសើរឡើង និងការបង្កើតបាននូវទីផ្សារមាននិរន្តរភាពសម្រាប់ការអនុវត្តកសិកម្មធន់នឹងអាកាសធាតុ និងផ្តល់តម្លៃខ្ពស់ និងមាននិរន្តរភាពត្រូវបានគេរំពឹងថានឹងជំរុញឱ្យមានការរីកសាយភាយទូទាំងតំបន់ភាគខាងជើងនៃបឹងទន្លេសាប តាមរយៈកិច្ចខិតខំប្រឹងប្រែងសហហិរញ្ញប្បទានរបស់អង្គភាពអនុវត្តគម្រោង និងដៃគូអនុវត្តនានា និង សកម្មភាពនៃគម្រោងផ្សេងៗទៀតដែលកំពុងដំណើរការស្របគ្នា។ ផលប៉ះពាល់វិជ្ជមានបែបនេះនឹងត្រូវបានពង្រីក និងអនុវត្តនៅកន្លែងផ្សេងទៀតនៃប្រទេស ហើយអ្នកប្រើប្រាស់នឹងមានលទ្ធភាពទទួលបានសន្តិសុខស្បៀង និងអាហារដែលមានគុណភាព។ សក្តានុពលភាពដែលអាចពង្រីកបាន ការយកគំរូម៉ូដែលមកអនុវត្តតាម និងនិរន្តរភាពរបស់គម្រោងត្រូវបាន ពិភាក្សាដូចខាងក្រោម។

១១៧. គម្រោងនឹង៖

- បង្កើនភាពរកបាន និងលទ្ធភាពទទួលបានព័ត៌មានអំពីអាកាសធាតុជាក់លាក់សម្រាប់ដំណាំ និង យុទ្ធសាស្ត្រកាត់បន្ថយហានិភ័យនឹងជំរុញឱ្យមានការអនុវត្តកសិកម្មដែលពឹងផ្អែកលើព័ត៌មានអំពីអាកាសធាតុ និងការយល់ដឹងអំពីហានិភ័យ និងជម្រើសបន្សាំ។ កសិករ និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃផ្សេងទៀតនៅតំបន់ភាគខាងជើងនៃបឹងទន្លេសាបនិងកម្ពុជាមានសិទ្ធិចូលប្រើប្រាស់ និងអនុវត្តជាប្រចាំនូវព័ត៌មានអំពីទីប្រឹក្សាផ្នែកកសិ-ឧតុនិយមជាក់លាក់ ដែលអាចចូលដំណើរការបានតាមរយៈមជ្ឈដ្ឋានផ្សេងៗ ដើម្បីចាត់វិធានការទាន់ពេល ដើម្បីកាត់បន្ថយការបាត់បង់ និងការខូចខាត និងបង្កើនផលិតភាពរបស់ពួកគេដោយធ្វើសកម្មភាពបន្សាំ។ ក៏មានកិច្ចខិតខំប្រឹងប្រែងជាប្រព័ន្ធផងដែរ ដើម្បីលើកកម្ពស់ ការអនុវត្តការសម្របខ្លួន និងបច្ចេកវិទ្យាដែលបានបង្ហាញឱ្យឃើញតាមរយៈឧបករណ៍ផ្ទុកផ្សេងៗនៅកម្រិតកសិដ្ឋាន និងទេសភាព ដើម្បីដឹកនាំការបង្កើនការយល់ដឹងរបស់ពួកគេអំពីហានិភ័យអាកាសធាតុទៅជាសកម្មភាព។
- ការប្រើប្រាស់ភាពជោគជ័យនៃទីផ្សារជាគំរូក្នុងការផ្លាស់ប្តូរទៅរកកសិកម្មធន់នឹងអាកាសធាតុ និងមានតម្លៃខ្ពស់ នឹងបង្ហាញឱ្យឃើញករណីអាជីវកម្មដ៏រឹងមាំបំផុតសម្រាប់ជាគំរូ ដល់កសិករ និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃផ្សេងទៀត ព្រោះជាធម្មតាពួកគេនឹងអនុវត្តតាមទៅតាមនិន្នាការបែបនេះ។ កសិករ និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃផ្សេងទៀតនៅក្នុងតំបន់ភាគខាងជើងនៃបឹងទន្លេសាប និងនៅប្រទេសកម្ពុជាទាំងមូល ដែលប្រឈមមុខនឹងបញ្ហាកសិកម្ម និងសេដ្ឋកិច្ចសង្គមស្រដៀងគ្នា នឹងមានគំរូបង្ហាញពីទីផ្សារ ដែលបង្កើនសមត្ថភាពបន្សាំ និងជម្រើសជីវភាពនៅកម្រិតគ្រួសារ និងសហគមន៍។ ផ្នែកសាធារណៈ និងឯកជនក៏បានវិនិយោគជាយុទ្ធសាស្ត្រក្នុងឱកាសទាំងនេះ ដោយផ្តល់នូវបទប្បញ្ញត្តិ និងការត្រួតពិនិត្យគុណភាព ការបណ្តុះបណ្តាលជំនាញ និងការគាំទ្រផ្នែកអាជីវកម្ម និងទីផ្សារ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះត្រូវបានភ្ជាប់ជាមួយនឹងការបង្កើនលទ្ធភាពទទួលបានហិរញ្ញវត្ថុដែលមានតម្លៃទាបសម្រាប់កសិករ និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃផ្សេងទៀតដែលមានមធ្យោបាយមានកម្រិតក្នុងការចម្លងគំរូជោគជ័យនេះ។
- ការសម្របសម្រួលអន្តរវិស័យប្រកបដោយប្រសិទ្ធភាព ភាពជាដៃគូរវាងរដ្ឋ ឯកជន និងសហគមន៍និងការវិនិយោគគ្រប់គ្រាន់ដែលអាចប្រមើមើលបានវានឹងជួយធានាបាននូវនិរន្តរភាព។ ការចំណាយសាធារណៈ និងការបែងចែកធនធានជាប្រព័ន្ធធានាឱ្យមានការបើកលក្ខខណ្ឌជាប្រព័ន្ធដល់ បុគ្គល

និងស្ថាប័ន ដើម្បីបង្កើនលទ្ធភាពទទួលបានហិរញ្ញបទានសម្រាប់ការវិនិយោគរបស់តួអង្គឯកជននៅក្នុងវិស័យកសិកម្ម ដែលធន់នឹងអាកាសធាតុ មានតម្លៃខ្ពស់ និងបរិយាប័ន។ ដូចគ្នានេះផងដែរ មានប្រព័ន្ធមួយសម្រាប់ត្រួតពិនិត្យ និងរាយការណ៍ អំពីវឌ្ឍនភាពនៃការវិនិយោគ និងចន្លោះប្រហោងដើម្បីធានាបាននូវលទ្ធផលកើនឡើងនៅទូទាំង វិស័យ និងបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលនៃហិរញ្ញបទានអាកាសធាតុពីប្រភពសាធារណៈ និងឯកជន។

### ៣.៣.១ ផលប៉ះពាល់នៃការផ្លាស់ប្តូរក្នុងការរំពឹងទុករបស់គម្រោង PEARL

១១៨. កសិករខ្នាតតូចសរុបចំនួន ៤៥០.០០០ នាក់ តួអង្គក្នុងខ្សែច្រវាក់តម្លៃក្នុងស្រុកផ្សេងទៀត និងសមាជិកគ្រួសាររបស់ពួកគេ ជាពិសេសកសិករ និងតួអង្គក្នុងខ្សែច្រវាក់តម្លៃជាស្ត្រី (ស្ត្រី ៤០-៦០%) បានទទួលអត្ថប្រយោជន៍ពីគម្រោងដោយផ្ទាល់ពីការទទួលយកការអនុវត្តកសិកម្មធន់នឹងអាកាសធាតុ និងមានតម្លៃខ្ពស់ និងពិពិតកម្មរបរចិញ្ចឹមជីវិតក្នុងវិស័យកសិកម្មតាមរយៈការអភិវឌ្ឍខ្សែច្រវាក់តម្លៃ។

១១៩. គ្រួសារសរុបចំនួន ៩០.០០០ គ្រួសារ ដែលងាយរងគ្រោះដោយសារអាកាសធាតុ ជាពិសេសស្ត្រីជាមេគ្រួសារ (៤០%) ទទួលបានអត្ថប្រយោជន៍ដោយផ្ទាល់ដោយបង្កើនទិន្នផលដំណាំ និងសន្តិសុខស្បៀងក្នុងរយៈពេលអនុវត្តរបស់គម្រោង។

១២០. កសិករ ៥០.០០០ នាក់ដែលរស់នៅផ្នែកខាងក្រោមនៃបឹងទន្លេសាប (ស្ត្រី៤០-៦០%) ទទួលបានអត្ថប្រយោជន៍ពីសេវាកម្មប្រព័ន្ធអេកូឡូស៊ី និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។ សហគមន៍តំបន់ការពារធម្មជាតិ/សហគមន៍ព្រៃឈើ ចំនួន ២០ នឹងទទួលបានអត្ថប្រយោជន៍ដោយផ្ទាល់ពីការការស្តារឡើងវិញ និងការការពារតំបន់ផ្ទៃរងទឹកភ្លៀងដែលវានឹងធ្វើឱ្យប្រសើរឡើងនូវភាពធន់នឹងប្រព័ន្ធអេកូឡូស៊ីទៅនឹងការប្រែប្រួលអាកាសធាតុ (៧.៦០០ ហិកតានៃព្រៃឈើសំខាន់ៗ និង តំបន់អេកូឡូស៊ីសំខាន់ៗផ្សេងទៀតត្រូវបានស្តារ និង ការពារ តាមរយៈសកម្មភាពកសិរុក្ខកម្ម និងការធ្វើពិពិធកម្មជីវភាពរស់នៅផ្សេងទៀត សម្រាប់ការកែលម្អប្រព័ន្ធកសិអេកូឡូស៊ីសម្រាប់កសិករដែលរស់នៅផ្នែកខាងក្រោមនៃបឹងទន្លេសាប)។

១២១. អ្នកប្រើប្រាស់សកម្មជាង ៣.០០០ នាក់នៅក្នុងវិស័យសាធារណៈ និងឯកជនដែលទាញយកព័ត៌មានពីប្រព័ន្ធតាមដានកសិអេកូឡូស៊ីកម្រិតទេសភាព(LAMS)ដើម្បីជួយដល់ការសម្រេចចិត្តវិនិយោគរបស់ពួកគេក្នុងការអនុវត្តកសិកម្មធន់នឹងអាកាសធាតុ មានបរិយាប័ន ផ្តល់តម្លៃខ្ពស់ និងឆ្លើយតបនឹងយេនឌ័រ។

១២២. សមត្ថភាពបន្សុំរបស់កសិករខ្នាតតូចចំនួន ២៤.០០០នាក់ និងតួអង្គក្នុងខ្សែច្រវាក់តម្លៃក្នុងស្រុកផ្សេងទៀត (ស្ត្រី ៤០-៦០%) បានត្រូវបានពង្រឹង បង្កើនប្រាក់ចំណូល និងលើកកម្ពស់ជីវភាពរស់នៅ ដែលនេះជាលទ្ធផលផ្ទាល់ចេញពីសកម្មភាពគាំទ្រលើកម្មវិធីវិញ្ញាបនបត្របញ្ជាក់គុណភាពផលិតផលនៃខ្សែច្រវាក់តម្លៃ (ឧ. Cam-Gap, GI និងសរីរាង្គ, W+, ISO 2200 និង HACCP) និងការគាំទ្រសមត្ថភាពជាយុទ្ធសាស្ត្រតាមរយៈ ភាពជាដៃគូរវាងរដ្ឋ ឯកជន និងសហគមន៍(ឧ. ការគ្រប់គ្រងបទប្បញ្ញត្តិ ការត្រួតពិនិត្យគុណភាព ការបណ្តុះបណ្តាលជំនាញ កិច្ចសន្យាកសិកម្ម និង កិច្ចព្រមព្រៀងទិញ)។

១២៣. គណនីធនាគារក្រោមយន្តការ FARM ត្រូវបានបង្កើតឡើងសម្រាប់ក្រុមទទួលផលរហូតដល់ ១២៤ ក្រុមរួមមាន សហគមន៍កសិកម្ម សមាគមកសិករ ក្រុមអ្នកផលិត សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ សហជីពកសិកម្ម ដើម្បីផ្តល់លទ្ធភាពទទួលបានហិរញ្ញទានតម្លៃទាប(៧ លានដុល្លារ) ដែលស្មើនឹង១៣០-១៦៥% នៃតម្លៃវិនិយោគដំបូងរបស់ពួកគេ។ យ៉ាងហោចណាស់មានកម្មវិធីវិញ្ញាបនប័ត្រកសិកម្មចំនួនបួន (៤) ដែលត្រូវបាន

បំពេញបន្ថែមយ៉ាងពេញលេញជាមួយនឹងគោលនយោបាយ បទប្បញ្ញត្តិ សមត្ថភាពស្ថាប័ន និងឧបករណ៍ដែលចាំបាច់ ដើម្បីគាំទ្រដល់ផលិតកម្មដែលធន់នឹងអាកាសធាតុ និងមានតម្លៃខ្ពស់តាមរយៈខ្សែច្រវ៉ាក់តម្លៃគោលដៅ។

១២៤. យ៉ាងហោចណាស់មានការកើនឡើង ២00% ក្នុងការទទួលបានហិរញ្ញវត្ថុក្នុងចំណោមកសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀតនៅក្នុងតំបន់ភាគខាងជើងនៃបឹងទន្លេសាបសម្រាប់ការទទួលយកការអនុវត្តបច្ចេកទេស និងបច្ចេកវិទ្យាធន់នឹងអាកាសធាតុ និងផ្តល់តម្លៃខ្ពស់។

១២៥. កសិករខ្នាតតូចសរុបចំនួន ២៤.000 នាក់ និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀត (៤0- ៦0% ស្ត្រី) នឹងបានអនុវត្តដោយជោគជ័យលើការអនុវត្តបច្ចេកទេស និងបច្ចេកវិទ្យាដែលធន់នឹងអាកាសធាតុតាមរយៈសាលា រៀនស្រែកសិករ ការរៀនសូត្រពីមិត្តភ័ក្តិ និងការគាំទ្របន្ថែមពីវិស័យឯកជន និងប្រព័ន្ធផ្សព្វផ្សាយសង្គម និងកម្មវិធីទូរសព្ទដៃ។

### ៣.៣.២ ទ្រឹស្តីនៃការផ្លាស់ប្តូរ- របៀបដែលគម្រោងគាំទ្រការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ

១២៦. គម្រោងនេះប្រើប្រាស់វិធីសាស្ត្រខ្សែច្រវ៉ាក់តម្លៃដែលផ្តោតលើដំណាំ ស្វាយចន្ទី ស្វាយ ស្រូវសរីរាង្គ និងបន្លែ ដើម្បីជំរុញការសម្រេចបានឆ្ពោះទៅរកកសិកម្មដែលធន់នឹងអាកាសធាតុ ផ្តល់តម្លៃខ្ពស់ គ្រប់គ្រងដោយបរិយាប័ន និងមាននិរន្តរភាព។ ឈរលើទស្សនៈនេះ ទ្រឹស្តីនៃការផ្លាស់ប្តូរសម្រាប់គម្រោង PEARL ត្រូវបានផ្តល់ជូនខាងក្រោម នៅក្នុងរូបភាពទី ៦ និងនៅក្នុងការពិពណ៌នាអំពីជាតុផ្សំនៃគម្រោង។ ចំណាំ៖ សកម្មភាព គម្រោងមិនត្រូវបានពិភាក្សាលម្អិតនៅក្នុងផ្នែកនេះទេ សកម្មភាពទាំងនេះ មានពិពណ៌នាលម្អិតនៅក្នុងផ្នែក B.៣នៃឯកសារគម្រោងពេញលេញ។




*រូបភាពទី 6. ទ្រឹស្តីនៃការផ្លាស់ប្តូររបស់គម្រោង PEARL*

## ៤. ក្របខ័ណ្ឌច្បាប់ និងស្ថាប័ន

### ការបន្សុំនឹងគោលនយោបាយ

១២៧. រដ្ឋាភិបាលកម្ពុជាប្តេជ្ញាដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ ទាំងសកម្មភាពបន្សាំ និងសកម្មភាពការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ជាពិសេសស្របតាមអាទិភាពជាតិ និងក្របខណ្ឌផ្លូវច្បាប់។

១២៨. បច្ចុប្បន្នភាពផែនការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការចូលរួមចំណែកដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ (NDC) (MoE, 2020b) ចំពោះកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីអាកាសធាតុក្រោម UNFCCC គូសបញ្ជាក់អំពីតួនាទីសំខាន់របស់វិស័យកសិកម្មទាំងក្នុងសកម្មភាពកាត់បន្ថយ និងការបន្សាំ។ NDC នាំមកនូវការយកចិត្តទុកដាក់ ជាពិសេសចំពោះតម្រូវការក្នុងការបង្កើនភាពធន់នៃវិស័យកសិកម្ម ពីព្រោះកសិកម្មជាវិស័យមួយក្នុងចំនោមវិស័យដែលរងផលប៉ះពាល់ខ្លាំងបំផុតពីការប្រែប្រួលអាកាសធាតុ ហើយក៏ជាវិស័យមួយដើរតួនាទីសំខាន់សម្រាប់សេដ្ឋកិច្ចពីព្រោះប្រជាជនកម្ពុជាជាច្រើនអាស្រ័យដោយផ្ទាល់លើវិស័យកម្ម។ NDC គូសបញ្ជាក់អំពីផលប៉ះពាល់អវិជ្ជមានដែលរំពឹង ទុកនៃប្រព័ន្ធស្បៀង និងហានិភ័យនៃអសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភ ជាពិសេសក្នុងចំណោម ក្រុមងាយរងគ្រោះ រួមទាំងជនក្រីក្រ ស្ត្រី កុមារ និងក្រុមផ្សេងទៀតដែលមិនត្រូវបានទទួលការយកចិត្តទុកដាក់ក្នុងសង្គម។ ការព្រួយបារម្ភពីផលប៉ះពាល់បែបនេះ វាប៉ះពាល់ដល់ការបែងចែកកម្លាំងពលកម្ម និងបន្ទុកការងាររបស់កសិករស្ត្រី ដូច្នេះទាមទាឱ្យមានការផ្តោតលើសកម្មភាពឆ្លើយតបនឹងយេនឌ័រ និងតម្រូវការ ក្នុងការប្រមូលទិន្នន័យបែងចែកយេនឌ័រ ដើម្បីយល់កាន់តែច្បាស់ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ លើស្ត្រីក្នុងវិស័យកសិកម្ម។

១២៩. ក្នុងចំណោមសកម្មភាពបន្សាំអាទិភាពចំនួន ៥៨ ដែលត្រូវបានកំណត់នៅក្នុង NDC ដែលបានធ្វើបច្ចុប្បន្នភាព សកម្មភាពចំនួន១៧ ផ្តោតលើវិស័យកសិកម្ម (ibid.)។ ក្នុងចំណោមសកម្មភាពបន្សាំជាអាទិភាពទាំងនេះ សកម្មភាពចំនួន១០ គឺទាក់ទងដោយផ្ទាល់ទៅនឹងការបង្កើនសមត្ថភាពបន្សាំនៅតំបន់ភាគខាងជើងនៃបឹងទន្លេសាប តាមរយៈការលើកកម្ពស់ផលិតកម្មដែលធន់នឹងអាកាសធាតុ និងតម្លៃខ្ពស់នៃផលិតកម្មស្វាយចន្ទី ស្វាយ ស្រូវសរីរាង្គ និងបន្លែស្លឹកក្នុងចំណោមកសិករខ្នាតតូច។ សម្រាប់វិស័យកសិកម្ម NDC បានប៉ាន់ប្រមាណការចំណាយលើការបន្សាំនឹងការប្រែប្រួលអាកាសធាតុចំនួន ៣០៦ លានដុល្លារ ដែលភាគច្រើនត្រូវបានគេរំពឹងថានឹងបានមកតាមរយៈការគាំទ្រពីអន្តរជាតិ។

១៣០. សកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុទាំងនេះ គឺដើម្បីបង្កើនភាពធន់នៃប្រព័ន្ធដំណាំ និងជីវភាពពឹងអាស្រ័យលើកសិកម្ម ហើយសកម្មភាពទាំងនេះក៏ផ្តល់អត្ថប្រយោជន៍រួមគ្នាក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ផងដែរ ឧទាហរណ៍ តាមរយៈការផលិតជីសរីរាង្គ និងឡជីវឧស្ម័ន និងការកែលម្អការអនុវត្តការគ្រប់គ្រងដីដើម្បីបង្កើនមុខងារកសិអេកូឡូស៊ី។ NDC អំពាវនាវឱ្យមានការបង្កើនភាពជាដៃគូសាធារណៈ និងឯកជន (PPPs) ដើម្បីដោះស្រាយការវិនិយោគក្នុងវិស័យឯកជន និងលើកកម្ពស់ការផ្ទេរបច្ចេកវិទ្យា និងការផ្លាស់ប្តូរដែលជំរុញដោយទីផ្សារ ឆ្ពោះទៅរកការអភិវឌ្ឍន៍ដែលធន់នឹងអាកាសធាតុ និងនិរន្តរភាព។ NDC ក៏សង្កត់ធ្ងន់លើតម្រូវការសម្រាប់ការធ្វើឱ្យប្រសើរឡើងនូវការរៀបចំស្ថាប័ន និងសមត្ថភាពក្នុងចំណោមក្រសួងពាក់ព័ន្ធរួមមាន កសិកម្ម បរិស្ថាន និងធនធានទឹក តាមរយៈការប្រមូលទិន្នន័យ ការវិភាគ ការគ្រប់គ្រង ការតាមតាមដានត្រួតពិនិត្យ និងការរាយការណ៍ដើម្បីធានានូវបរិយាកាស បទប្បញ្ញត្តិអំណោយផលសម្រាប់ PPPs និងការជំរុញសកម្មភាពសម្របសម្រួលអាទិភាពខាងលើ (ibid)។

១៣១. NDC ចូលរួមចំណែកដោយផ្ទាល់ដល់ការធ្វើឱ្យសម្រេចផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP) (២០១៤) ដែលបានរៀបចំឡើង ដោយផ្អែកលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៤។

## ដំណើរការនៃផែនការជាតិបន្សាំ (NAP)

១៣២. ដំណើរការនៃការរៀបចំ NAP របស់កម្ពុជា ត្រូវបានធ្វើឡើង ដោយផ្អែកលើផែនការសកម្មភាពជាតិបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ(NAPA) (២០០៦) និងកំណត់ថា កង្វះលទ្ធភាពទទួលបានធនធានហិរញ្ញវត្ថុ បច្ចេកវិទ្យា និងមនុស្ស គឺជាបញ្ហាប្រឈមដ៏ចម្បង និងដាក់ចេញនូវគោលដៅបន្សាំរយៈពេលមធ្យម និងរយៈពេលវែងនៅតាមវិស័យដែងរងផលប៉ះពាល់ធ្ងន់ធ្ងរ ក្នុងនោះរួមទាំងធនធានកសិកម្ម និងទឹកឡើងវិញ និងសុខភាពមនុស្ស។ ដំណើរការនៃការរៀបចំ NAP បានចាប់ផ្តើមនៅឆ្នាំ២០១៤ ដើម្បីបង្កើនវឌ្ឍនភាពលើសមាសធាតុសំខាន់ៗចំនួន ៤៖ (១)ការរៀបចំមូលដ្ឋានគ្រឹះការងារ (២)ពិនិត្យនិងដំណើរការសមាសធាតុក្នុងការចំការងារ (៣)ការបង្កើតយុទ្ធសាស្ត្រអនុវត្តន៍ និង (៤)ការបង្កើតក្របខ័ណ្ឌក្នុងការរបាយការណ៍ និងត្រួតពិនិត្យ ដើម្បីដាក់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុជាផ្នែកស្នូលនៃរបៀបវារៈគោលនយោបាយ (GSSD, 2017)។ ដោយរួមគ្នាជាមួយនឹង NDC ផែនការបន្សាំថ្នាក់ជាតិនេះក៏រួមចំណែកដល់ការធ្វើឱ្យសម្រេច NSDP និង CCCSP ផងដែរ។

## កម្មវិធីប្រចាំប្រទេសរបស់ GCF ក្នុងប្រទេសកម្ពុជា

១៣៣. ដោយផ្អែកលើ NAPA, ដំណើរការនៃ NAP, CCCSP និងផែនការសកម្មភាពប្រែប្រួលអាកាសធាតុតាមវិស័យនោះ កម្មវិធីប្រចាំប្រទេស GCF (2020a) ក្នុងប្រទេសកម្ពុជាយកចិត្តទុកដាក់លើវិស័យកសិកម្ម ធនធានទឹក ហេដ្ឋារចនាសម្ព័ន្ធ ព្រៃឈើ សុខភាព និងការអភិវឌ្ឍឆ្នេរសមុទ្រជាផ្នែកវិនិយោគជាអាទិភាពរបស់ខ្លួនសម្រាប់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ កសិកម្ម និងព្រៃឈើក៏ត្រូវបានចាត់ទុកថាជាវិស័យគន្លឹះសម្រាប់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុផងដែរ។ កម្មវិធីប្រចាំប្រទេសនេះកំណត់ចំណាត់ថ្នាក់គម្រោង PEARL ជាថាគម្រោងបន្សាំនឹងអាកាសធាតុមានអាទិភាពខ្ពស់បំផុតរបស់ខ្លួន។ ការបង្កើត PPP ប្រកបដោយប្រសិទ្ធភាព ដើម្បីកៀរគរការវិនិយោគរបស់ផ្នែកឯកជន សម្រាប់គាំទ្រសកម្មភាពបន្សាំ គឺជាយុទ្ធសាស្ត្រសំខាន់មួយ ក្នុងកម្មវិធីប្រចាំប្រទេសនេះ។ នាបច្ចុប្បន្ន ប្រទេសកម្ពុជាមានស្ថាប័នទទួលបានសិទ្ធិទាក់ទងផ្ទាល់មួយ (DAE) គឺ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD)។ ការបង្កើនចំនួន DAE នៅកម្ពុជា គឺជាកិច្ចការអាទិភាពមួយទៀតរបស់ខ្លួន។ នៅក្នុងបរិបទនេះ ARDB បច្ចុប្បន្នត្រូវបានពិចារណាដោយ NDA ក្នុងការតែងតាំងជា DAE។

## ផែនការសកម្មភាពប្រែប្រួលអាកាសធាតុសម្រាប់វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១៣៤. ក្នុងការចូលរួមចំណែកដោយផ្ទាល់ដល់ CCCSP នេះ ផែនការសកម្មភាពប្រែប្រួលអាកាសធាតុសម្រាប់វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៦-២០២០ (CCPAP-AFF) (MAFF, 2016) មានគោលបំណងអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្សសមស្របក្នុងវិស័យនេះ ដើម្បីបង្កើតបច្ចេកវិទ្យា និងវិធានការថ្មីៗ និងអនានុវត្តន៍។ ផែនការនេះក៏មានគោលដៅបង្កើនការយល់ដឹងរបស់កសិករអំពីហានិភ័យទាក់ទងនឹងអាកាសធាតុ និងជម្រើសនានា ព្រមទាំងជានាថា កសិករមានមធ្យោបាយចាំបាច់ក្នុងការយកទៅអនុវត្តបច្ចេកវិទ្យា និងវិធានការណ៍ដែលធន់នឹងអាកាសធាតុ ដើម្បីកាត់បន្ថយជាអតិបរមានូវការខូចខាត និងការបាត់បង់ដំណាំ និងសត្វចិញ្ចឹមរបស់ពួកគេ។ CCPAP-AFF កំណត់គោលដៅយុទ្ធសាស្ត្រតាមអនុវិស័យរបស់ខ្លួនមានដូចជា (១)សន្តិសុខស្បៀង និងជីវភាពរស់នៅ (២)ចំការ (៣)សត្វចិញ្ចឹម (៤)ការគ្រប់គ្រងព្រៃឈើ និង (៥)ជលផល ដោយមានសកម្មភាពកាត់

បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងបង្កើនសមត្ថភាពបន្សាំខ្លួនរបស់ពួកគេ ដើម្បីទប់ទល់នឹងទឹកជំនន់ គ្រោះរាំងស្ងួត សីតុណ្ហភាព និងសត្វល្អិតនិងជំងឺដែលមានការកើនឡើង។ ទាក់ទងនឹងសន្តិសុខស្បៀង និងជីវភាពរស់នៅសកម្មភាពជាអាទិភាពរួមមានការលើកកម្ពស់ប្រព័ន្ធកសិកម្មប្រកបដោយនិរន្តរភាព និងបច្ចេកវិទ្យាក្រោយការប្រមូលផល ការអភិវឌ្ឍពូជដំណាំសមស្រប និងប្រព័ន្ធព័ត៌មានអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើវិស័យកសិកម្ម និងការចិញ្ចឹមជីវិត ការស្រាវជ្រាវ និងការអភិវឌ្ឍបច្ចេកវិទ្យាឆ្លាតវៃអំពីអាកាសធាតុ និងការកសាងសមត្ថភាពនៃសមាគមកសិករ និងសហគ្រាសខ្នាតតូចនិងមធ្យមលើកសិកម្មឆ្លាតវៃស្តីពីអាកាសធាតុ។

១៣៥. ទោះបីជា CCPAP-AFF កំណត់ផែនការសកម្មភាពដ៏ល្អិតល្អន់ដោយមានចំណុចដៅប្រកបដោយ មហិច្ឆិតានោះ ក៏ដោយ ក៏ទឹកប្រាក់តិចជាង ៥០% នៃចំនួន ២៤៦ លានដុល្លារអាមេរិកដែលត្រូវការសម្រាប់ការអនុវត្តពេញលេញនៃ CCPAP-AFF ត្រូវបានធានា នៅពេលចាប់ផ្តើមនៃការអនុវត្តសកម្មភាពរបស់ខ្លួន (ibid)។ ហិរញ្ញវត្ថុនេះមានប្រភពពីក្រុមការងារលេខាធិការដ្ឋាននៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (SCAFF) ការបែងចែកថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល កម្ចី និងជំនួយឥតសំណងពីធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម។ ទោះបីជាមូលនិធិការប្រែប្រួលអាកាសធាតុផ្សេងៗដែលត្រូវបានធ្វើឡើងតាមរយៈអង្គការសហប្រជាជាតិ និងទីភ្នាក់ងារទ្វេភាគីត្រូវបានផ្តល់ឱ្យបន្ថែមក៏ដោយ ក៏នៅតែមានតម្រូវការហិរញ្ញវត្ថុបន្ថែមច្រើនទៀតដើម្បីដោះស្រាយកង្វះខាតហិរញ្ញវត្ថុបច្ចុប្បន្ន។

## ក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDG) (២០១៦-២០៣០)

១៣៦. ដោយមានការចង្អុលបង្ហាញណែនាំពី NSDP និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៤ ក្របខ័ណ្ឌ CSDG (2018a) កំណត់ចំណុចគោលដៅ និងសូចនាករជាក់លាក់សម្រាប់ប្រទេសកម្ពុជា ដើម្បីតាមត្រួតពិនិត្យ និងតាមដានវឌ្ឍនភាពរបស់ខ្លួនក្នុងការធ្វើឱ្យសម្រេចគោលដៅទាំង ១៨ ដែលកែសម្រួលពីគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពសកល ដើម្បីឆ្លើយតបនឹងកាលៈទេសៈជាក់លាក់របស់ប្រទេស។ CSDG មានជាប់ពាក់ព័ន្ធជាពិសេសទៅនឹងគម្រោងដែលបានស្នើឡើងរួមមាន៖ គោលដៅទី ១ (គ្មានភាពក្រីក្រ) គោលដៅទី ២ (គ្មានភាពអត់ឃ្លាន) គោលដៅទី ៥ (សមភាពយេនឌ័រ) គោលដៅទី ១៣ (សកម្មភាពអាកាសធាតុ) និងគោលដៅទី ១៥ (ជីវិតនៅលើដី)។ ផ្អែកតាមក្របខ័ណ្ឌនេះ អត្រាជាមធ្យមនៃភាពក្រីក្រនៅតាមជនបទនឹងត្រូវកាត់បន្ថយពាក់កណ្តាល, តម្លៃនៃផលិតកម្មកសិកម្មសម្រាប់មនុស្សម្នាក់ៗនឹងកើនឡើងទ្វេដង ហើយការចំណាយសាធារណៈលើសកម្មភាពអាកាសធាតុក៏នឹងកើនឡើងមួយភាគរយត្រឹមឆ្នាំ២០៣០។

១៣៧. ដូច្នេះ សកម្មភាពរបស់ PEARL នឹងពង្រឹង និងជម្រុញឱ្យអនុវត្តក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់កម្ពុជា លើកកម្ពស់ការរៀបចំគោលនយោបាយបន្ថែមស្តីពីការបំភាយឧស្ម័នទាប និងធ្វើឱ្យប្រសើរឡើងនូវការរៀបចំផែនការ និងការអភិវឌ្ឍដែលឆ្លើយតបនឹងអាកាសធាតុនៅក្នុងតំបន់។ គម្រោង PEARL មានភាពស៊ីសង្វាក់គ្នាយ៉ាងល្អទៅនឹងគោលនយោបាយសាធារណៈជាតិមួយចំនួន ដែលគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងតំបន់ NTSB នៃប្រទេសកម្ពុជា។

## គោលនយោបាយសង្គម និងបរិស្ថាន

១៣៨. ដើម្បីគាំទ្រដល់ការអនុវត្តគម្រោង ការវាយតម្លៃហានិភ័យដើម្បីឆ្លើយតបទៅនឹងហានិភ័យសង្គម និងបរិស្ថានគឺចាំបាច់ ដើម្បីធានាថា ជីវភាពរស់នៅ និងបរិស្ថានត្រូវបានការពារពីផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន។ សេចក្តីសង្ខេបអំពីហានិភ័យទាំងនេះមានដូចខាងក្រោម។

១៣៩. ហានិភ័យសង្គម និងបរិស្ថានជាច្រើនត្រូវបានកំណត់នៅក្នុង ក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម(ESMF) (សូមមើលឯកសារគម្រោងនិងឧបសម្ព័ន្ធទី ៦ នៃឯកសារស្នើសុំគម្រោង)។ ហានិភ័យទាំងនេះអាចមានផលប៉ះពាល់អវិជ្ជមានលើជីវភាពរស់នៅរបស់អ្នកទទួលផលនៃគម្រោង និងបរិស្ថានជុំវិញដែលពួកគេពឹងផ្អែកពឹងអាស្រ័យពីមុខងារកសិកម្មបរិស្ថានផ្សេងៗ។ ជាពិសេស ដោយសារថា គម្រោងនេះប្រើប្រាស់វិធីសាស្ត្រខ្សែច្រវ៉ាក់តម្លៃ រួមនឹង FARM (ឧ. យន្តការហិរញ្ញវត្ថុ) ជាមធ្យោបាយចម្បងនៃការផ្លាស់ប្តូរនោះ គម្រោងត្រូវតែធានាថា កិច្ចខិតខំប្រឹងប្រែងរបស់គម្រោងក្នុងការដាក់បញ្ចូលទីផ្សារ និងហិរញ្ញវត្ថុមិនមិនបង្ករឱ្យមានឥទ្ធិពលផ្ទុយគ្នាលើក្រុមមនុស្ស និងបុគ្គលជាក់លាក់ ជាពិសេសស្ត្រី និងអ្នកផ្សេងៗទៀត ដែលងាយរងគ្រោះ និង/ឬត្រូវបានសង្គមមិនរាប់រក។

១៤០. ដូចដែលបានពិពណ៌នានៅក្នុងផ្នែកបន្ទាប់ ក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម(ESMF) របស់គម្រោង (ឧបសម្ព័ន្ធទី ៦ នៃការឯកសារស្នើសុំគម្រោង) កំណត់ពីយុទ្ធសាស្ត្ររួម ក្នុងការបន្ថយ/ទម្លាក់ចុះជាអតិបរមានូវហានិភ័យគ្រោះថ្នាក់ដល់សង្គម និង បរិស្ថាន។ ជាពិសេស ផែនការសកម្មភាពយេនឌ័រ (ឧបសម្ព័ន្ធទី ៨) ផែនការមានការចូលរួមពីភាគីពាក់ព័ន្ធ (ឧបសម្ព័ន្ធទី ៧ នៃឯកសារស្នើសុំគម្រោង) និងផែនការជនជាតិដើមភាគតិច (មើលផងដែរ ឧបសម្ព័ន្ធទី ៦ នៃឯកសារស្នើសុំគម្រោង) នឹងរៀបរាប់ពីវិធានការជាក់លាក់។ យុទ្ធសាស្ត្រ និងកិច្ចខិតខំប្រឹងប្រែងទាំងនេះនឹងត្រូវរៀបចំឡើងថែមទៀតតាមបរិបទ ដើម្បីដាក់បញ្ចូល ផែនការគ្រប់គ្រងបរិស្ថាននិងសង្គម (ESMP) ទៅក្នុងឯកសារចាប់ផ្តើមរបស់គម្រោង ដើម្បីអនុវត្តសកម្មភាពកាត់បន្ថយនៅទីតាំងគោលដៅ។

## ៥. គោលនយោបាយការពារសុវត្ថិភាពជាធរមាន

១៤១. ESMF នេះត្រូវបានរៀបចំឡើងដើម្បីគាំទ្រគម្រោងដែលបានស្នើឡើងមានឈ្មោះថា "ភាពជាដៃគូរវាងរដ្ឋ ឯកជន និងសហគមន៍ដើម្បីលើកកម្ពស់កសិកម្មភាតបរិស្ថាន និងជីវភាពដែលធន់នឹងអាកាសធាតុរបស់សហគមន៍ នៅភាគខាងជើងនៃបឹងទន្លេសាប (**គម្រោង PEARL**)" ដែលរៀបចំឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ហើយដាក់ជូន GCF។ គម្រោងនេះទទួលបានគាំទ្របន្ថែមពីអង្គការ FAO ក្នុងតួនាទីជាអង្គភាពទទួលស្គាល់ដោយ GCF។ អាស្រ័យហេតុនេះហើយទើបគម្រោងនេះត្រូវបានពិនិត្យវាយតម្លៃ ធៀបនឹងគោលនយោបាយការពារបរិស្ថាន និងសង្គមរបស់អង្គការ FAO[5] ក៏ដូចជាការការពារសុវត្ថិភាពបរិស្ថាន និងសង្គមរបស់ GCF និងគោលនយោបាយពាក់ព័ន្ធផ្សេងទៀត ដូចមានការកត់សម្គាល់ខាងក្រោម៖

១៤២. *គោលនយោបាយគណនេយ្យភាពរបស់ FAO (2014)៖* អង្គការ FAO ប្តេជ្ញាក្នុងការរៀបចំ និងអនុវត្តអភិក្រមរបស់ខ្លួនស្តីពីគណនេយ្យភាព ដោយផ្អែកលើតម្លៃស្នូលនៃការប្តេជ្ញាចិត្តរបស់អង្គការ FAO ការគោរពគ្នាទៅវិញទៅមក សុចរិតភាពនិងតម្លាភាព និងផ្អែកតាមគោលការណ៍ដូចខាងក្រោម៖ (i) ផ្តោតការយកចិត្តទុកដាក់លើគោលបំណង និងលទ្ធផលរបស់អង្គការ FAO សម្រាប់អ្នកទទួលផល និងដៃគូ (ii) កំណត់តួនាទី និងទំនួលខុសត្រូវច្បាស់លាស់ (iii) ធ្វើការសម្រេចដោយផ្អែកលើព័ត៌មាននិងមានតម្លាភាព ហើយប្រាស្រ័យទាក់ទងគ្នាយ៉ាងច្បាស់លាស់ដោយផ្តល់មូលដ្ឋានសម្រាប់ធ្វើសកម្មភាពផ្តោតលើលទ្ធផល និងតាមតួនាទីដែលបានកំណត់យ៉ាងច្បាស់ (iv) បញ្ចូលតម្លៃរបស់អង្គការ FAO ទៅក្នុងការអនុវត្ត តាមរយៈការអនុវត្តប្រកបដោយសង្គតភាពនៃជំនឿ និងវប្បធម៌រួមក្នុងការរៀបចំតាក់តែងគោលនយោបាយ និងអាកប្បកិរិយារបស់អ្នកបំពេញការងារ (v) បញ្ចូលភាគីពាក់ព័ន្ធក្នុងការអនុវត្តការងារ ដើម្បីធ្វើឱ្យគណនេយ្យភាពក្លាយជាការពិត និង(vi) បង្កើតវប្បធម៌ដោះស្រាយផលវិបាកក្នុងអត្ថន័យទូលំទូលាយ ព្រមទាំងត្រូវមានអារម្មណ៍ថាមានការទទួលខុសត្រូវ។

១៤៣. *គោលនយោបាយការពារតាមរយៈការផ្តល់ព័ត៌របស់អង្គការ FAO* (សារាចររដ្ឋបាលលេខ ២០១៩/០៦) ដែលអនុវត្តចំពោះបុគ្គលិករបស់អង្គការ FAO ណាម្នាក់ នៅពេលរៀបចំរបាយការណ៍ផ្ទៃក្នុង ឬខាងក្រៅ ដោយផ្អែកលើការពិចារណានៃសារាចរណ៍នេះ។

១៤៤. *គោលនយោបាយរបស់ GCF ស្តីពីការការពារអ្នកផ្តល់ព័ត៌មាន និងសាក្សី (២០១៨)* មានគោលបំណងផ្តល់សិទ្ធិអំណាចដល់បុគ្គលដែលមានទំនាក់ទំនងជាមួយនឹងគម្រោង GCF ក្នុងការរាយការណ៍ដោយចិត្តស្មោះត្រង់ និងមិនភ័យខ្លាចពីការតាមសងសឹកអំពីការសង្ស័យនៃការប្រព្រឹត្តខុស ដែលការធ្វើដូច្នេះធ្វើឱ្យ GCF អាចការពារផលប្រយោជន៍ ធនធាន និងបេសកកម្មរបស់ខ្លួនបានយ៉ាងមានប្រសិទ្ធភាព។

១៤៥. *គោលនយោបាយរបស់អង្គការ FAO ស្តីពីសមភាពយេនឌ័រ ឆ្នាំ២០២០-២០៣០* ព្យាយាមធ្វើឱ្យសម្រេចបានសមភាពរវាងស្ត្រី និងបុរស ក្នុងវិស័យកសិកម្ម និងការអភិវឌ្ឍជនបទដោយចីរភាព ដើម្បីលុបបំបាត់ភាពអត់ឃ្លាន និងភាពក្រីក្រ។

---

5

១៤៦. *គោលនយោបាយយេនឌ័រ GCF (២០១៩)* ពង្រឹងការឆ្លើយតបរបស់ GCF ទៅនឹងបរិបទវប្បធម៌ចម្រុះនៃសមភាពយេនឌ័រ ដើម្បីដោះស្រាយ និងផ្តល់មូលហេតុកាន់តែប្រសើរឡើងពីទំនាក់ទំនងរវាងសមភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុ។

១៤៧. *ការការពាររបស់អង្គការ FAO ពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ (PSAE) លេខ 2013/27៖* គោលការណ៍សុចរិតភាព វិជ្ជាជីវៈ ការគោរពសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូររបស់ប្រជាជនគ្រប់រូប ដែលបានកំណត់ក្នុងការប្តេជ្ញាចិត្តរបស់អង្គការ FAO ក្នុងការទប់ស្កាត់ និងដោះស្រាយទង្វើកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ (SEA)។

១៤៨. *គោលនយោបាយរបស់អង្គការ FAO ស្តីពីការទប់ស្កាត់ការយាយី ការបៀតបៀនផ្លូវភេទ និងការបំពារបំពានអំណាចរបស់អាជ្ញាធរ N° 2015/03 (2015)* និងគោលនយោបាយរបស់អង្គការ FAO ស្តីពីការបៀតបៀនផ្លូវភេទ (ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩) ដែលកំណត់ថា ការបៀតបៀនផ្លូវភេទក្នុងរាល់ទម្រង់គ្រប់ប្រភេទ គឺផ្ទុយនឹងធម្មនុញ្ញសហប្រជាជាតិ បទប្បញ្ញត្តិបុគ្គលិក និងវិធានបុគ្គលិករបស់អង្គការ និងបទដ្ឋានប្រតិបត្តិសម្រាប់សេវាកម្មស៊ីវិលអន្តរជាតិ។

១៤៩. *គោលនយោបាយដែលបានកែសម្រួលរបស់ GCF ស្តីពីការទប់ស្កាត់ និងការការពារពីការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពានផ្លូវភេទ និងការបៀតបៀនផ្លូវភេទ (២០២១)* ចែងពីកាតព្វកិច្ចច្បាស់លាស់សម្រាប់បុគ្គលដែលពាក់ព័ន្ធគម្រោង GCF ក្នុងការទប់ស្កាត់ និងឆ្លើយតបទៅនឹង ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH) និងដើម្បីទប់ស្កាត់ពីការទទួលយក ការលើកទឹកចិត្ត ការចូលរួម ឬការពាក់ព័ន្ធនឹង ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)។

១៥០. *គោលនយោបាយរបស់អង្គការ FAO ប្រឆាំងនឹងការក្លែងបន្លំ និងការប្រព្រឹត្តិអំពើពុករលួយផ្សេងទៀត លេខ ២០១៥/០៨ (២០១៥)៖* ការក្លែងបន្លំ និងការប្រព្រឹត្តអំពីពុករលួយផ្សេងទៀត បង្កការគំរាមកំហែងធ្ងន់ធ្ងរដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃគោលនយោបាយ និងគោលបំណងរបស់អង្គការ FAO។

១៥១. *គោលនយោបាយរបស់ GCF ស្តីពីសកម្មភាពហាមឃាត់ (២០១៩)៖* ហាមមិនឱ្យភាគីពាក់ព័ន្ធគម្រោងរបស់ GCF ចូលរួមក្នុងប្រព្រឹត្តអំពីពុករលួយ ការក្លែងបន្លំ ការបង្ខិតបង្ខំ ការឃុបឃិតគ្នា ឬសកម្មភាពរារាំង ឬការរំលោភបំពាន ជាដើម ដើម្បីរក្សាបាននូវកម្រិតខ្ពស់បំផុតនៃសុចរិតភាព គណនេយ្យភាព និងប្រសិទ្ធភាព។

១៥២. *គោលនយោបាយដែលបានកែសម្រួលរបស់ GCF ស្តីពីបរិស្ថាន និងសង្គម (២០២១)៖* គោលនយោបាយស្តីពីបរិស្ថាន និងសង្គមដែលបានកែសម្រួល ដើម្បីបញ្ជាក់ឡើងវិញពីការប្តេជ្ញាចិត្តរបស់មូលនិធិក្នុងការដោះស្រាយការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពានផ្លូវភេទ និងការបៀតបៀនផ្លូវភេទ បន្ថែមទៅនឹងការពិចារណាផ្សេងៗទៀតអំពីបរិស្ថាន និងសង្គមនៅក្នុងសកម្មភាពដែលទទួលបានមូលនិធិរបស់ខ្លួន។

១៥៣. ប្រការគួរតែឱ្យកត់សម្គាល់ផងដែរនោះគឺថា យោងតាមលក្ខខណ្ឌតម្រូវរបស់ GCF អង្គការ FAO ត្រូវបានស្នើសុំឱ្យបញ្ជាក់ថាតើ ការការពារពីការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពាន និងការបៀតបៀនផ្លូវភេទ (PSEAH)របស់ GCF កំពុងត្រូវបានអនុវត្តចំពោះគម្រោងដែលទទួលបានមូលនិធិពី GCF/FAO ដែរឬទេ? អង្គការ FAO កំពុងបង្កើតគោលនយោបាយថ្មីមួយ ដែលនឹងជំនួសគោលនយោបាយ ឆ្នាំ ២០១៥ ជាធរមាន - ក្របខ័ណ្ឌរបស់អង្គការ FAO ស្តីពីការគ្រប់គ្រងបរិស្ថាន និងសង្គម (FESM) - ដែលត្រូវបានរំពឹងថានឹងត្រូវអនុម័ត ដាក់ឱ្យប្រើប្រាស់នៅឆ្នាំ ២០២២។ ក្របខ័ណ្ឌរបស់អង្គការ FAO ស្តីពីការគ្រប់គ្រងបរិស្ថាន និងសង្គម (FESM) មានសេចក្តីយោងច្បាស់លាស់ពី ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH) ហើយនឹងមានការបន្ថែមសម្រាប់

ការអនុវត្តពីគោលការណ៍ណែនាំប្រតិបត្តិពាក់ព័ន្ធផ្សេងៗទៀត។ ក្នុងពេលជាមួយគ្នានេះ អង្គការ FAO បញ្ជាក់ថាមានប្រភព និងសមត្ថភាពបច្ចេកទេសគ្រប់គ្រាន់ ដើម្បីធានាបាននូវការគោរព និងអនុវត្តតាមលក្ខខណ្ឌរបស់ GCF ទាក់ទងនឹង ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)។ យើងក៏មានការយល់ដឹងពីផែនការសកម្មភាព ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)របស់ GCF ដែរថា GCF នឹងបង្កើតឧបករណ៍ពិនិត្យវាយតម្លៃហានិភ័យ ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)នៅក្នុងខែតុលា ដែលនឹងត្រូវយកមកពិចារណា នៅពេលបង្កើតគោលការណ៍ ណែនាំប្រតិបត្តិការនៃ ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)។

## ៥.១ បទដ្ឋានបរិស្ថាន និងសង្គមរបស់អង្គការ FAO

១៥៤. អង្គការ FAO មានបទដ្ឋានបរិស្ថាន និងសង្គម (ESS) ចំនួនប្រាំបួនដែលបានបង្កើតឡើងដើម្បីជួយគ្រប់គ្រង និងកែលម្អការអនុវត្តបរិស្ថាន និងសង្គមរបស់ FAO តាមរយៈវិធីសាស្ត្រផ្តោតការយកចិត្តលើហានិភ័យ និងលទ្ធផល (តារាងទី ៣)៖

**តារាងទី 3. ទិដ្ឋភាពទូទៅនៃបទដ្ឋានបរិស្ថាន និងសង្គមរបស់អង្គការ FAO**

| បទដ្ឋាន | ការពិពណ៌នា |
|---|---|
| ESS ១៖ ការគ្រប់គ្រងធនធានធម្មជាតិ | ផលប៉ះពាល់ពីគម្រោងដែលបានស្នើឡើងលើការរេចរឹលធនធានធម្មជាតិ និងការបាត់បង់សេវាកម្មប្រព័ន្ធអេកូឡូស៊ី ដែលបណ្តាលមកពីការប្រកួតប្រជែងកាន់តែខ្លាំងឡើងលើធនធានធម្មជាតិ (ក្នុងនោះរួមទាំងដី ទឹក ជីវៈចម្រុះ តំបន់ទេសភាព និងផ្លូវទឹកធម្មជាតិ)។ ESS១ ផ្តោតការយកចិត្តទុកដាក់លើបរិស្ថានគ្មានជីវិត (ឧ. ស្រទាប់ដី ដី ទឹក សុវត្ថិភាពនៃការកាន់កាប់ដី និងអាកាសធាតុ)។ |
| ESS ២៖ ជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងជម្រកធម្មជាតិ | ហានិភ័យដែលពាក់ព័ន្ធនឹងនានាភាព និងភាពប្រែប្រួលនៃសត្វ រុក្ខជាតិ និងអតិសុខុមប្រាណនៅកម្រិតហ្សែន/ពន្ធុ កម្រិតប្រភេទ និងប្រព័ន្ធអេកូឡូស៊ីដែលមានសារៈសំខាន់ក្នុងការគាំទ្ររចនាសម្ព័ន្ធ និងមុខងារនៃប្រព័ន្ធអេកូឡូស៊ីផលិតភាព។ |
| ESS ៣៖ ធនធានហ្សែន/ពន្ធុរុក្ខជាតិសម្រាប់ស្បៀង និងកសិកម្ម | ការទប់ស្កាត់ការបាត់បង់ភាពចម្រុះហ្សែន/ពន្ធុ និងផលវិបាកបរិស្ថាន និងសង្គមដោយអចេតនាតាមរយៈការលើកកម្ពស់ការកែលម្អដំណាំ និងផលិតកម្មដំណាំប្រកបដោយនិរន្តរភាព។ ESS ៣ នេះជម្រុញឱ្យមានការធានាថា ការផ្ទេរធនធានហ្សែន/ពន្ធុរុក្ខជាតិសម្រាប់ស្បៀង និងកសិកម្ម (PGRFA) មានការគោរពសិទ្ធិរបស់កសិករ និងលទ្ធភាពទទួលបានដោយស្មើគ្នាក្នុងការចែករំលែកផលប្រយោជន៍។ |
| ESS ៤៖ សត្វ-បសុសត្វ និងទឹក - ធនធានពន្ធុសម្រាប់អាហារ និងកសិកម្ម | ហានិភ័យពាក់ព័ន្ធនឹងការគ្រប់គ្រងប្រកបដោយនិរន្តរភាពនៃធនធានសត្វ និងជលផល ក្នុងនោះរួមទាំងការបាត់បង់ភាពចម្រុះហ្សែន/ពន្ធុ និងផលវិបាកបរិស្ថាននិងសង្គមដោយអចេតនា។ ធនធានពន្ធុសត្វសម្រាប់កសិកម្ម និងស្បៀង (AnGR) រួមមានប្រភេទសត្វណាមួយដែលត្រូវបានប្រើប្រាស់ ឬអាចប្រើប្រាស់សម្រាប់ផលិតអាហារ និងកសិកម្ម។ |

| | |
|---|---|
| ESS ៥៖ ការគ្រប់គ្រងសត្វល្អិត និងថ្នាំសម្លាប់សត្វល្អិត | ហានិភ័យទាក់ទងនឹងផលប៉ះពាល់អវិជ្ជមាននៃថ្នាំសម្លាប់សត្វល្អិតលើសុខភាព និងសុវត្ថិភាពរបស់សហគមន៍ អ្នកប្រើប្រាស់ និងបរិស្ថាន។ ESS ៥ នេះលើកទឹកចិត្តដល់ការគ្រប់គ្រងសត្វល្អិតរួមបញ្ចូលគ្នា (IPM) និងទទួលស្គាល់ការរួមចំណែកនៃថ្នាំសម្លាប់សត្វល្អិតក្នុងការផលិតដំណាំ និងស្បៀងប្រកបដោយប្រសិទ្ធភាព ប៉ុន្តែជម្រុញការកាត់បន្ថយការពឹងផ្អែកលើថ្នាំសម្លាប់សត្វល្អិត។ |
| ESS ៦៖ ការតាំងទីលំនៅថ្មី និងការផ្លាស់ទីលំនៅដោយស្ម័គ្រចិត្ត | ការការពារគ្រួសារពីការបណ្តេញចេញពីភូមិដោយបង្ខំ និងការកាត់បន្ថយជាអតិបរមានៃផលប៉ះពាល់សង្គម និងសេដ្ឋកិច្ចពីការរឹតបន្តឹងដីធ្លី ឬការរឹតបន្តឹងការប្រើប្រាស់ធនធានដែលអាចកើតឡើង។ ESS ៦ នេះលើកទឹកចិត្តឱ្យមានការដាក់បញ្ចូលវិធានការនានាដើម្បីកែលម្អ/ស្តារស្ថានភាពរស់នៅ ទ្រព្យផ្តល់ផល និងសុវត្ថិភាពនៃការកាន់កាប់ដីរបស់ជនណាម្នាក់ដែលបានផ្លាស់ទីលំនៅ ទោះបីជាលក្ខណៈរូបវន្ត ឬសេដ្ឋកិច្ចក៏ដោយ។ |
| ESS ៧៖ ការងារសមរម្យ | ការទទួលស្គាល់ពីតម្រូវការសម្រាប់ការងារពេញលេញ និងផលិតភាព ដើម្បីធានាសន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ។ ដើម្បីធានាដល់ការសម្រេច ESS ៧ នេះ គម្រោងត្រូវតែលើកកម្ពស់លទ្ធភាពទទួលបានការងារធ្វើនៅជនបទ ធានាបានឱកាសការងារដែលគ្មានការរើសអើង និងស្មើភាព គាំទ្រកម្មករ ក្នុងនោះរួមទាំងប្រភេទកម្មករជួបការលំបាក និងងាយរងគ្រោះ និងអនុវត្តបទដ្ឋានការងារអន្តរជាតិ រួមទាំងការទប់ស្កាត់ និងលុបបំបាត់ពលកម្មកុមារ។ គម្រោងនេះនឹងអនុវត្តគោលការណ៍គ្មានការអោនទាល់តែសោះ ចំពោះការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពាន និងការបៀតបៀនផ្លូវភេទ (SEAH)[6]។ |
| ESS ៨៖ សមភាពយេនឌ័រ | គម្រោងដែលបានស្នើឡើងនេះមានឥទ្ធិពលលើតួនាទី និងកាលានុវត្តភាពយេនឌ័រ និងការបញ្ជ្រាបយេនឌ័រ រួមនឹងការរួមចំណែករបស់គម្រោងដើម្បីសម្រេចបានសមភាពយេនឌ័រសម្រាប់អន្តរាគមន៍ប្រកបដោយនិរន្តរភាពក្នុងវិស័យកសិកម្ម និងជនបទ។ គម្រោងនេះក៏ប្តេជ្ញាបញ្ចៀស ហើយកន្លែងដែលមិនអាចបញ្ចៀសបាន កាត់បន្ថយហានិភ័យនៃ ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)។ យន្តការបណ្តឹងតវ៉ា(GRM) របស់គម្រោងគួរដាក់បញ្ចូលនីតិវិធីការការពារ ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)ដែលឆ្លើយតបនឹងយេនឌ័រ និងផ្តោតលើផ្តល់សិទ្ធិអំណាចដល់ស្ត្រី។ |
| ESS ៩៖ ជនជាតិដើមភាគតិច និងបេតិកភណ្ឌវប្បធម៌ | ហានិភ័យចំពោះចំណេះដឹង វប្បធម៌ និងទំនៀមទម្លាប់ប្រពៃណីរបស់ជនជាតិដើម សិទ្ធិក្នុងការសម្រេចខ្លួនឯង និងបេតិកភណ្ឌវប្បធម៌រូបី និងអរូបីសម្រាប់មនុស្សជំនាន់បច្ចុប្បន្ន និងជំនាន់ក្រោយ។ ESS ៩ នេះធានាថា គម្រោងគោរពអនុវត្ត ការព្រមព្រៀងជាមុន ដោយសេរី និងផ្អែកលើព័ត៌មានគ្រប់គ្រាន់ (FPIC)។ |

*ប្រភព៖ អង្គការ FAO, 2015*

[6] Note : FAO has recently developed a new policy that supersedes the existing 2015 policy – FAO’s Framework for Environmental and Social Management (FESM) – has just been endorsed in June 2022. FESM has explicit reference to SEAH, and will be accompanied by relevant operational guidance. In the meantime, FAO confirms that sufficient technical resources and capacities to ensure compliance with GCF requirements regarding SEAH are available (see also the FAO Annual Report on Corporate Policy, Processes and Measures on the Prevention of Harassment, Sexual Harassment and Sexual Exploitation and Abuse, https://www.fao.org/3/ng643en/ng643en.pdf ). It is also our understanding from GCF’s SEAH Action Plan is that GCF will develop a SEAH risk screening tool in October that would be taken into account when developing SEAH operational guidance.

## ៥.២ ការចាត់ចំណាត់ថ្នាក់ហានិភ័យរបស់គម្រោង

១៥៥. ការត្រួតពិនិត្យដំបូងលើគម្រោងរួមជាមួយនឹងការវិភាគបន្ថែម គម្រោងដែលបានស្នើសុំនេះបានកំណត់កម្រិតនៃហានិភ័យប្រភេទ ខ ដោយកម្រិតនេះបង្ហាញថា គម្រោងនេះមានសកម្មភាពដែលមានផលប៉ះពាល់ និងហានិភ័យអវិជ្ជមានតិចតួចជាសក្តានុពលលើបរិស្ថាន និង/ឬសង្គម មានជាលក្ខណៈដោយឡែកៗ ឬជាលក្ខណៈរួមបញ្ចូលគ្នា មានចំនួនតូច ជាទូទៅនៅតាមទីតាំងជាក់លាក់ ភាគច្រើនអាចកែប្រែឡើងវិញបាន និងងាយស្រួលដោះស្រាយ តាមរយៈវិធានការកាត់បន្ថយផ្សេងៗ។ សេចក្តីសង្ខេបពីការវាយតម្លៃនេះត្រូវបានផ្តល់ជូនខាងក្រោម៖

១៥៦. សេចក្តីសង្ខេបខាងក្រោមបង្ហាញពីហានិភ័យគួរឱ្យកត់សម្គាល់មួយចំនួនដែលអាចមានផលប៉ះពាល់អវិជ្ជមាន ជាសក្តានុពលលើបរិស្ថាន និងសង្គមដែលតម្រូវឱ្យមានផែនការកាត់បន្ថយជាក់លាក់។

**ផលប៉ះពាល់អវិជ្ជមានជាសក្តានុពលលើបរិស្ថាន និងសង្គមដែលអាចកំណត់អត្តសញ្ញាណ**មានដូចខាងក្រោម៖

- ហានិភ័យខ្ពស់ដោយផ្អែកលើការត្រួតពិនិត្យ ESS របស់អង្គការ FAO ដោយសារថា សកម្មភាពរបស់គម្រោងដែលត្រូវអនុវត្ត ស្ថិតនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិដែលកំណត់ដោយស្របច្បាប់ (តិចជាង ១០.000 ហិកតា) និងសហគមន៍ព្រៃឈើដែលមានទីតាំងនៅក្នុងឧទ្យានជាតិ និងដែនជម្រកសត្វព្រៃ ហើយដូច្នេះទប់ស្កាត់ហានិភ័យដែលប៉ះពាល់ដល់ជីវៈចម្រុះដែលត្រូវបានកំណត់ថាមានសារៈសំខាន់របស់ជាតិ។ ផ្អែកលើចំណុចនេះ ផែនការគ្រប់គ្រងជីវៈចម្រុះត្រូវបានបង្កើតឡើង ហើយការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមពេញលេញលើទីតាំងគោលដៅនឹងត្រូវធ្វើឡើង ហើយផែនការគ្រប់គ្រងពាក់ព័ន្ធត្រូវគ្នាត្រូវបានបង្កើតឡើង (ដែលផ្តោតលើផលប៉ះពាល់បរិស្ថាន និងសង្គម ក្នុងនោះរួមទាំងផលប៉ះពាល់លើក្រុមជនជាតិដើមភាគតិចក្នុងទីតាំងទទួលបានអន្តរាគមន៍ពីគម្រោង)។
- ហានិភ័យកម្រិតមធ្យមដែលមានជាប់ពាក់ព័ន្ធនឹងការដឹកជញ្ជូន និងការផ្តល់គ្រាប់ពូជ និងសម្ភារដាំដុះសម្រាប់ទាំងការដាំដុះលក្ខណៈកសិកម្ម និងការដាំដុះព្រៃឈើ ព្រមទាំងការបង្កើតព្រៃដាំ ដោយផ្អែកលើការគាំទ្រដល់ការផ្គត់ផ្គង់សន្និធិ/ស្តុកសម្រាប់ការដាំដែលមានការកែលម្អដល់សមាគមកសិកម្ម រួមទាំងការងារស្តារព្រៃឡើងវិញក្នុងសហគមន៍តំបន់ការពារធម្មជាតិ (តិចជាង ១០.000 ហិកតា) និងសហគមន៍ព្រៃឈើ។

១៥៧. ហានិភ័យផ្សេងទៀតទាំងអស់ត្រូវបានកំណត់ថាជាហានិភ័យទាប លើកលែងតែ ESS ៩៖ ជនជាតិដើមភាគតិច និងបេតិកភណ្ឌវប្បធម៌ ដែលហានិភ័យកម្រិតមធ្យមត្រូវបានកំណត់ ដោយផ្អែកលើវត្តមានរបស់ជនជាតិដើមភាគតិច។ ទោះជាយ៉ាងនេះក្តី លក្ខណៈស្នូលនៃគោលបំណង សកម្មភាពរបស់គម្រោង (ការព្យាយាមកែលម្អសកម្មភាពដែលមានជាប់ពាក់ព័ន្ធនឹងកសិកម្ម និងការគ្រប់គ្រងដីធ្លីនៅទូទាំងតំបន់ទេសភាពជាគោលដៅ តាមរយៈការអនុវត្តដែលការកែលម្អ និងការផ្តល់ការគាំទ្រមានភាពប្រសើរឡើង និងបរិយាកាសអំណោយផល) ត្រូវបានកំណត់ថាជាការកាត់បន្ថយចំណុចហានិភ័យបរិស្ថាន និងសង្គមឱ្យស្ថិតនៅក្រោមកម្រិតអនុវត្តសកម្មភាពជាធម្មតា នៅទីណាដែលមានការកំណត់ឃើញថាមានការពាក់ព័ន្ធនឹងកត្តាហានិភ័យ ហើយមានយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យដើម្បីធានាថាគ្មានហានិភ័យធ្ងន់ធ្ងរ នៅគ្រប់ទីតាំងដែលទទួលបានអន្តរាគមន៍ពីគម្រោង ក្នុងនោះរួមទាំងទំនាក់ទំនងជាមួយក្រុមជនជាតិដើមភាគតិចផង។

១៥៨. ផលប៉ះពាល់ដែលអាចកើតមាន មិនធ្លាប់កើតមានពីមុនមកក្នុងតំបន់អនុវត្តគម្រោងនោះទេ។

១៥៩. ផលប៉ះពាល់ជាសក្ដានុពលដែលបានកំណត់គឺមិនធ្លាប់កើតមានពីមុនមកនោះទេ ប៉ុន្តែមានជាប់ពាក់ព័ន្ធនឹងសកម្មភាពដែលកំពុងអនុវត្ត និងផលប៉ះពាល់ដែលកំពុងកើតមាននៅតាមតំបន់ទេសភាពរបស់គម្រោង ក្នុងនោះរួមមានការពង្រីកសកម្មភាពកសិកម្ម និងការខិតខំប្រឹងប្រែងដើម្បីស្ដារឡើងវិញនូវតំបន់ព្រៃរេចរឹល។ ជាក់ស្ដែងនៅគ្រប់ទីតាំងទាំងអស់ សកម្មភាពរបស់គម្រោងព្យាយាមកំណត់ចំណុចដៅក្នុងការកាត់បន្ថយកម្រិតនៃផលប៉ះពាល់ដែលអាចកើតមានក្នុងទម្រង់សេណារីយ៉ូសកម្មភាពធម្មតា ហើយទទួលបានការគាំទ្រ តាមរយៈការផ្ដល់ព័ត៌មាន ការបណ្ដុះបណ្ដាល និងឧបករណ៍និងប្រព័ន្ធប្រតិបត្តិការ និងស្ថាប័នដែលត្រូវបានរចនាឡើងដើម្បីជួយកាត់បន្ថយកម្រិតនៃផលប៉ះពាល់ដល់បរិស្ថាន និងសង្គម។

១៦០. ផលប៉ះពាល់ដែលអាចកើតមានត្រូវបានកំណត់ត្រឹមតំបន់រងផលប៉ះពាល់ពីគម្រោងប៉ុណ្ណោះ។

១៦១. ផលប៉ះពាល់ដែលបានកំណត់មានជាប់ពាក់ព័ន្ធផ្ទាល់ទៅនឹងសកម្មភាពដែលគម្រោងកំពុងត្រូវបានអនុវត្ត។ ដូច្នេះ ផលប៉ះពាល់ទាំងនេះត្រូវបានកំណត់ត្រឹមតំបន់រងផលប៉ះពាល់ពីគម្រោងប៉ុណ្ណោះ។ អាស្រ័យហេតុនេះ បើទោះបីជាគម្រោងនេះមានគោលបំណងគាំទ្រដល់ការផ្លាស់ប្ដូរជាប្រព័ន្ធដែលអាចពង្រីកការបរាជ័យណាមួយក្នុងការអនុវត្តសកម្មភាពដែលអាចបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានបន្ថែមទៀតនោះ ផលប៉ះពាល់ទាំងនេះមិនត្រូវបានកំណត់អត្តសញ្ញាណថា ហានិភ័យដែលអាចកើតមានមិនត្រូវបានសាយភាយហួសពីតំបន់ទទួលបានអន្តរាគមន៍ពីគម្រោង។

១៦២. ផលប៉ះពាល់ដែលអាចកើតមានគឺមិនអាចកែប្រែបាន ឬមានកំណើនរួមគ្នា

១៦៣. ផលប៉ះពាល់ដែលបានកំណត់ឃើញ មានសភាពធ្ងន់ធ្ងរខ្លាំងបំផុត ពោលគឺមានហានិភ័យនៃផលប៉ះពាល់នៅក្នុងតំបន់អភិរក្ស និងកន្លែងធ្វើការដាំព្រៃឈើក្នុងគោលបំណងការស្ដារព្រៃឈើ និងផលិតកម្មកសិកម្ម។ ក្នុងករណីទាំងនេះ ក៏ដូចជាករណីដែលបានវាយតម្លៃផ្សេងទៀតទាំងអស់ ផលប៉ះពាល់ដែលបានរកឃើញមិនត្រូវបានកំណត់ថាជាផលប៉ះពាល់ត្រួតគ្នាកើនឡើង ឬមានសក្ដានុពលក្នុងការជំរុញឱ្យមានការផ្លាស់ប្ដូររួមសរុប។ គ្មានផលប៉ះពាល់ណាត្រូវបានកំណត់រកឃើញទេមានលក្ខណៈមិនអាចកែប្រែបាន នៅពេលវិសាលភាពនៃផលប៉ះពាល់ត្រូវបានចាត់ទុកថាមានសក្ដានុពលលើតំបន់តូចៗដែលមានការបាត់បង់ព្រៃឈើ ហើយត្រូវកាត់បន្ថយតាមរយៈសកម្មភាពស្ដារឡើងវិញ។ លើសពីនេះទៀត ផលប៉ះពាល់ទាំងនេះត្រូវបានបញ្ចៀសជាអតិបរមាតាមរយៈការប្រើប្រាស់បច្ចេកទេសគ្រប់គ្រងដែលមានការទទួលស្គាល់ និងការអនុវត្តល្អ (សូមមើលខាងក្រោម)។

១៦៤. ផលប៉ះពាល់អវិជ្ជមានជាសក្ដានុពលអាចត្រូវបានដោះស្រាយដោយការប្រើប្រាស់បច្ចេកទេសអនុវត្ត និងគ្រប់គ្រងល្អដែលត្រូវបានទទួលស្គាល់។

១៦៥. ហានិភ័យដ៏ធ្ងន់ធ្ងរបំផុតដែលបានកំណត់រកឃើញមានជាប់ទាក់ទងនឹងការប្រើប្រាស់សន្និធិ/ស្ដុកសម្រាប់ការដាំដុះ អាចត្រូវបានគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាព តាមរយៈការអនុវត្តការគ្រប់គ្រងយ៉ាងល្អ ក្នុងនោះរួមទាំងការជ្រើសរើសប្រភេទសត្វ/រុក្ខជាតិ និងការរៀបចំផែនការប្រកបដោយប្រសិទ្ធភាពនៃសកម្មភាពកសិកម្ម និងការស្ដារព្រៃឈើ។ ហានិភ័យផ្សេងទៀតទាំងអស់ក៏អាចគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពផងដែរ តាមរយៈរចនាសម្ព័ន្ធគ្រប់គ្រងតាមបទដ្ឋានរបស់គម្រោង ដូចមានបង្ហាញក្នុងឯកសារបច្ចុប្បន្ន។

១៦៦. ព័ត៌មានបន្ថែមអំពីចំណុចហានិភ័យដែលបានកំណត់ និងវាយតម្លៃ ក៏ដូចជាការឆ្លើយតបចំពោះហានិភ័យទាំងនេះ ក៏មានផ្ដល់ជូនផងដែរនៅក្នុងតារាងខាងក្រោម ដោយអនុវត្តតាមបទដ្ឋានបរិស្ថាន និងសង្គមរបស់ (ESS) អង្គការ FAO ខណៈពេលដែលភ្ជាប់ហានិភ័យទាំងនេះទៅនឹងផ្សារភ្ជាប់ទៅនឹងបទដ្ឋានអនុវត្តរបស់ IFC ដែលបានអនុម័តឱ្យប្រើប្រាស់ជាបណ្ដោះអាសន្នដោយ GCF។ វិធីសាស្ត្រគ្រប់គ្រងហានិភ័យរបស់គម្រោងក៏នឹងអាស្រ័យជុំវិញ

លើវិធីសាស្ត្របីដំណាក់កាលរបស់អង្គការ FAO ក្នុងការកំណត់អត្តសញ្ញាណសកម្មភាព ការត្រួតពិនិត្យវាយតម្លៃ និងការរៀបចំផែនការគ្រប់គ្រង (មានជាអាទិ៍ ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP))។ បើទោះបីជា ក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម(ESMF) គូសបញ្ជាក់អំពីក្របខ័ណ្ឌកាត់បន្ថយហានិភ័យទាំងមូលក៏ដោយ ក៏ការវាយតម្លៃលម្អិតបន្ថែមទៀត និង ផែនការគ្រប់គ្រងបរិស្ថាននិងសង្គម(ESMP)នឹងត្រូវបានរៀបចំនៅកម្រិតសកម្មភាពនៅពេលកំណត់ជ្រើសរើសក្រុមអ្នកទទួលផល ទីតាំង និងបទដ្ឋានជាក់លាក់ នៅដំណាក់កាលចាប់ផ្តើមគម្រោង។

១៦៧. បញ្ជីការលើកលែងនៃសកម្មភាពដែលគម្រោងនឹងមិនផ្តល់ហិរញ្ញប្បទាន មាននៅក្នុងឧបសម្ព័ន្ធទី ២ នៃឯកសារបច្ចុប្បន្ន។

## ៥.៣ ការការពារសុវត្ថិភាពនៃមូលនិធិអាកាសធាតុបៃតង

១៦៨. GCF បានអនុម័តជាបណ្តោះអាសន្ននូវបទដ្ឋានអនុវត្ត និងការណែនាំនៃការអនុវត្តសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)[7]។ IFC មានបទដ្ឋានការអនុវត្តចំនួនប្រាំបីដែលមានការពិចារណាសំខាន់ៗលើផ្នែកបរិស្ថាន និងសង្គមដែលត្រូវយកចិត្តទុកដាក់ នៅពេលរៀបចំ និងអនុវត្តគម្រោងណាមួយ។ បទដ្ឋានរបស់ IFC នេះគឺស៊ីសង្វាក់គ្នានឹងបទដ្ឋានបរិស្ថាន និងសង្គមរបស់អង្គការ FAO (តារាងទី ៤)។

*តារាងទី 4. ការបន្សីបទដ្ឋានអនុវត្តរបស់ IFC និងបទដ្ឋានបរិស្ថាន និងសង្គមរបស់អង្គការ FAO*

| បទដ្ឋានប្រតិបត្តិការ IFC (PS) | បទដ្ឋានបរិស្ថាន និងសង្គមរបស់អង្គការ FAO (ESS) |
|---|---|
| PS ១. ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម | ESS ១. ការគ្រប់គ្រងធនធានធម្មជាតិ<br>ESS ៨. សមភាពយេនឌ័រ |
| PS ២. ពលកម្ម និងលក្ខខណ្ឌការងារ | ESS ៧. ការងារសមរម្យ |
| PS ៣. ប្រសិទ្ធភាពធនធាន និងការទប់ស្កាត់ការបំពុល | ESS ៥. សមាសភាពចង្រៃ និងការគ្រប់គ្រងថ្នាំសម្លាប់សត្វល្អិត |
| PS ៤. សុខភាព សុវត្ថិភាព និងសន្តិសុខសហគមន៍ | ESS ៧. ការងារសមរម្យ (ដោយផ្នែក) |
| PS ៥. ការទិញដី និងការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត | ESS ៦. ការតាំងទីលំនៅថ្មី និងការផ្លាស់ទីលំនៅដោយដោយមិនស្ម័គ្រចិត្ត |
| PS ៦. ការអភិរក្សជីវៈចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិរស់ដោយចីរភាព | ESS 2. ជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងទីជម្រកធម្មជាតិ<br>ESS ៣. ធនធានពន្ធុរុក្ខជាតិ សម្រាប់ស្បៀង និងកសិកម្ម<br>ESS ៤. សត្វ-ការចិញ្ចឹមសត្វ និងសត្វក្នុងទឹក-ធនធានបន្តុសម្រាប់ស្បៀង និងកសិកម្ម |
| PS ៧. ជនជាតិដើម | ESS ៩. ជនជាតិដើម បេតិកភណ្ឌវប្បធម៌ |
| ESS ៩. ជនជាតិដើម បេតិកភណ្ឌវប្បធម៌ | |

*ប្រភព៖ GCF/B.07/11; FAO 2015*

[7] GCF/B.07/11

## ៥.៤ ការការពារបរិស្ថាន និងសង្គមជាធរមានរបស់អង្គការ FAO

តារាងទី ៥ ផ្តល់នូវទិដ្ឋភាពទូទៅនៃការការពារសុវត្ថិភាពរបស់អង្គការ FAO ដែលត្រូវជំរុញ នៅក្នុងបញ្ជីត្រួតពិនិត្យសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃបរិស្ថាន និងសង្គមរបស់អង្គការ FAO។

*តារាងទី 5. ការការពារសុវត្ថិភាពរបស់អង្គការ FAO សម្រាប់គម្រោង PEARL*

| ការការពារសុវត្ថិភាពរបស់អង្គការ FAO | ការការពារសុវត្ថិភាពរបស់អង្គការ FAO ដែលត្រូវជំរុញ? | ការផ្តល់យុត្តិកម្ម |
|---|---|---|
| ESS១៖ ការគ្រប់គ្រងធមជានធម្មជាតិ | គ្មាន | គម្រោងនេះលើកកម្ពស់ការគ្រប់គ្រងដីដោយចីរភាព ដើម្បីទប់ស្កាត់ ឬកាត់បន្ថយការរេចរឹលដីតាមរយៈការគ្រប់គ្រងការហូរច្រោះដី ការគ្រប់គ្រងសារធាតុចិញ្ចឹមចម្រុះ ការគ្រប់គ្រង និងការស្តារឡើងវិញនូវធនធានដី ទឹក និងជីវៈចម្រុះ ព្រមទាំងការថែរក្សាសេវាកម្មប្រព័ន្ធអេកូឡូស៊ី ដោយធ្វើការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយអ្នកប្រើប្រាស់ដីនៅមូលដ្ឋាន។<br><br>គម្រោងនេះក៏នឹងគាំទ្រដល់ការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងព័ត៌មាន និងលទ្ធភាពទទួលបានហិរញ្ញវត្ថុ ដើម្បីគាំទ្របច្ចេកវិទ្យាដែលប្រសើរឡើង ដើម្បីបង្កើនប្រសិទ្ធភាព និងកាត់បន្ថយផលប៉ះពាល់នៃប្រព័ន្ធជាវាសាស្រ្ត(រួមទាំងប្រព័ន្ធជាវាសាស្រ្តពន្លឺព្រះអាទិត្យ និងប្រព័ន្ធជាវាសាស្រ្តឆ្លាតវៃ (ឧ. ប្រព័ន្ធជាវាសាស្រ្តស្រក់ និងស្រះ ព្រមទាំងប្រព័ន្ធស្រូវ-ត្រី) និងប្រព័ន្ធគ្រប់គ្រងទឹកនៅក្នុងតំបន់ដែលផលិតដោយថាមពល (ជាមួយនឹងប្រព័ន្ធទាំងអស់ដែលប្រើប្រាស់ទំនប់ក្រោម ៥ ម ៥ ម និងមិនមែនតំបន់គោលដៅលើសពី ២០ ហិកតា ២០ ហិកតា)។ អនុសកម្មភាពទាំងអស់ដែលបានស្នើឡើងដែលនឹងរួមបញ្ចូលសកម្មភាពប្រព័ន្ធជាវាសាស្រ្តជាក់លាក់ក៏នឹងត្រូវឆ្លងកាត់ការត្រួតពិនិត្យហានិភ័យមុនពេលអនុវត្តផងដែរ។ គម្រោងនេះក៏នឹងជួយគាំទ្រដល់ការគ្រប់គ្រងព័ត៌មាន និងលទ្ធភាពក្នុងការទទួលបានហិរញ្ញវត្ថុ ដើម្បីគាំទ្របច្ចេកវិទ្យាប្រសើរជាងមុនក្នុងការលើកកម្ពស់ប្រសិទ្ធភាព និងកាត់បន្ថយផលប៉ះពាល់នៃការបញ្ចេញបញ្ចូលទឹក (រួមមានប្រព័ន្ធជាវាសាស្រ្តដើរដោយថាមពលព្រះអាទិត្យ និងប្រព័ន្ធជាវាសាស្រ្តវៃឆ្លាត (ឧ. ប្រព័ន្ធស្រោចស្រពដំណក់ទឹក ស្រះ ក៏ដូចជាប្រព័ន្ធចិញ្ចឹមត្រីក្នុងស្រែ)និងប្រព័ន្ធគ្រប់គ្រងទឹកនៅក្នុងតំបន់ផលិតកម្ម (ដោយ |

| | | |
|---|---|---|
| | | ប្រព័ន្ធទាំងអស់ ប្រើប្រាស់ទំនប់ទឹកតិចជាង ៥ ម៉ែត្រ និងមិនកំណត់ទិសដៅស្រោចស្រពលើសពី ២០ ហិកតា)។ អនុសកម្មភាពទាំងអស់ដែលបានលើកឡើងនឹងរួមបញ្ចូលទៅក្នុងសកម្មភាពប្រព័ន្ធធារាសាស្ត្រជាក់លាក់ផង នឹងត្រូវឆ្លងកាត់ការត្រួតពិនិត្យហានិភ័យ មុននឹងអនុវត្តផងដែរ។<br><br>គម្រោងនេះនឹងលើកកម្ពស់ការបញ្ជាក់ឱ្យកាន់តែច្បាស់អំពីសិទ្ធិអាស្រ័យផល និងសិទ្ធិកាន់កាប់របស់កសិករ និងគ្រួសារ ដើម្បីកាត់បន្ថយហា និភ័យនៃការវិនិយោគក្នុងការជ្រើសរើសអនុវត្តបច្ចេកវិទ្យា និងការអនុវត្តធន់នឹងអាកាសធាតុ និងប្រកបដោយនិរន្តរភាព។ គម្រោងនេះនឹងមិនបណ្តាលឱ្យមានការផ្លាស់ប្តូរអវិជ្ជមានលើសិទ្ធិកាន់កាប់ស្របច្បាប់ដែលមានស្រាប់នោះទេ ដោយផ្តោតលើសហគមន៍កសិកម្មក្នុងស្រុក សហគមន៍តំបន់ការពារធម្មជាតិ និងក្រុមគ្រប់គ្រងព្រៃឈើដែលត្រូវបានកំណត់ជាសិទ្ធិអ្នកប្រើប្រាស់រួចហើយ ប៉ុន្តែអាចស្នើសុំការគាំទ្រឡើងវិញក្នុងការពង្រឹងក្នុងការចងក្រងឯកសារសម្រាប់សិទ្ធិទាំងនេះ។ សកម្មភាពណាមួយដើម្បីកែប្រែ ឬផ្លាស់ប្តូរសិទ្ធិនឹងត្រូវត្រួតពិនិត្យវាយតម្លៃពេញលេញ និងផែនការគ្រប់គ្រង។ គម្រោងនេះក៏នឹងធ្វើការសំដៅពង្រឹងសមត្ថភាពបន្សាំ និងភាពធន់នៃសហគមន៍គោលដៅ តាមរយៈព័ត៌មានដែលមានភាពល្អប្រសើរស្តីពីផលប៉ះពាល់អាកាសធាតុ និងព្រឹត្តិការណ៍អាកាសធាតុនានា ព្រមទាំងជំនាញ និងសកម្មភាពកសិកម្មដែលមានភាពប្រសើរឡើង ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាស។ តាមរយៈការគាំទ្រសកម្មភាពប្រើប្រាស់ដីដែលមានកែលម្អ ការដាំដុះ និងការដាំស្តារព្រៃឡើងវិញ គម្រោងនេះក៏នឹងផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើការលើកកម្ពស់ការស្តុកទុកកាបូន និងការកាត់បន្ថយការបំភាយឧស្ម័នផងដែរ។<br><br>បញ្ជីនៅក្នុងឧបសម្ព័ន្ធទី៦ ធានាបន្ថែមទៀតថា គម្រោងនេះនឹងមិនផ្តល់ហិរញ្ញវត្ថុដល់សកម្មភាពដែលបានចាត់ទុកថាមាន "ហានិភ័យខ្ពស់" ទេ។ |
| ESS២៖ ជីវៈចម្រុះ ប្រពន្ធអេកូឡូស៊ី និង ជម្រកធម្មជាតិ | មាន | គម្រោងនេះនឹងសហការមួយសហគមន៍តំបន់ការពារធម្មជាតិ ចំនួន ១៤ សហគមន៍ ដោយសហគមន៍ចំនួន ៣ ក្នុងចំណោមសហគមន៍ទាំង ១៤ ស្ថិតនៅក្នុងឧទ្យានជាតិ សហគមន៍ចំនួន៥ នៅក្នុងដែនជម្រកសត្វព្រៃ និងសហគមន៍ចំនួន២ទៀត ស្ថិតនៅច្រករបៀងអភិរក្សជីវៈចម្រុះភាគខាងជើង។ ខណៈពេល |

| | | |
|---|---|---|
| | | សកម្មភាពនានានៅក្នុងតំបន់ការពារធម្មជាតិ ត្រូវបានចាត់ទុកថាមានហានិភ័យខ្ពស់នោះ កត្តាកាត់បន្ថយមួយចំនួនដែលមានស្រាប់អាចជួយកាត់បន្ថយហានិភ័យនៃការអនុវត្តនៅក្នុងតំបន់ទាំងនេះ។ សកម្មភាពទាំងនោះមានដូចជា៖<br>• ប្រព័ន្ធផលិតកម្មកសិកម្មនៅក្នុងតំបន់ការពារធម្មជាតិនៅកម្ពុជា បានស្ថិតក្នុងតំបន់ការពារធម្មជាតិ មុនពេលបង្កើតតំបន់ការពារធម្មជាតិ និងគម្រោង ហើយត្រូវបានអនុញ្ញាតឱ្យបន្តរស់នៅ តែមិនត្រូវបានអនុញ្ញាតឱ្យពង្រីកដី ស្របតាមច្បាប់កម្ពុជា។<br>• សកម្មភាពដែលបានស្នើឡើងផ្តោតការយកចិត្តទុកដាក់លើការលើកកម្ពស់និរន្តរភាពនៃប្រព័ន្ធផលិតកម្មកសិកម្ម ហើយជាលទ្ធផលគាំទ្រដល់ការកសាងសមត្ថភាព និងការគាំទ្រដល់ការកាត់បន្ថយផលប៉ះពាល់ទៅលើកសិកម្មនៅក្នុងតំបន់ទាំងនេះ និងការស្តារឡើងវិញនូវតំបន់រេចរឹល (ដោយប្រើប្រាស់ប្រភេទរុក្ខជាតិមានស្រាប់នៅតំបន់នោះ និងប្រភេទក្នុងស្រុក) នៃតំបន់អភិរក្សដែលពីមុនបានរងផលប៉ះពាល់ដោយសារកសិកម្មពនេរចរ និង/ឬការកាប់ឈើ។<br>• ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP) ដែលគ្រប់ជ្រុងជ្រោយនឹងត្រូវបានរៀបចំសម្រាប់តំបន់គោលដៅ នៅពេលដែលទីតាំងជាក់លាក់ និងសកម្មភាពគាំទ្រត្រូវបានព្រមព្រៀងគ្នាក្នុងដំណាក់កាលអនុវត្ត ដោយវាត្រូវបានប្រើដើម្បីធ្វើបច្ចុប្បន្នភាព និងពង្រឹងការឆ្លើយតបទៅនឹងការគ្រប់គ្រងដែលបានស្នើឡើង |
| FAO ESS ៣៖ ធនធានពន្ធុរុក្ខជាតិសម្រាប់អាហារ និងកសិកម្ម និង<br>IFC PS ៦. ការអភិរក្សជីវៈចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិរស់ដោយចីរភាព | មាន | គម្រោងនេះនឹងមិនណែនាំដំណាំ និងពូជផ្សេងៗ ដែលពីមុនមិនបាន ដាំដុះក្នុងតំបន់គម្រោង ឬតំបន់ស្រដៀងគ្នាក្នុងប្រទេសកម្ពុជាឡើយ។<br>គម្រោងនេះនឹងគាំទ្រដល់ការស្តារឡើងវិញនូវសហគមន៍តំបន់ការពារ និងសហគមន៍ព្រៃឈើ ដោយផ្តោតលើការដាំដុះពូជដើម ក៏ដូចជា រុក្ខកម្មប្រកបដោយនិរន្តរភាពខ្នាតតូច (ឧ. ឈើហូបផ្លែ និងប្រព័ន្ធសួនច្បារតាមផ្ទះ) ដើម្បីបំពេញតម្រូវការគ្រួសារដែលកំពុងកើនឡើងសម្រាប់ប្រើប្រាស់ជា អុស និងផលិតផលធ្វើពីឈើ។ គម្រោងនេះនឹងអនុម័ត និងអនុវត្តតាមយ៉ាងជិតដល់នូវក្របខ័ណ្ឌជាតិ REDD+ និងច្បាប់ជាតិពាក់ព័ន្ធផ្សេងទៀត រួមទាំងគោលការណ៍ណែនាំ របស់សហគមន៍តំបន់ |

| | | |
|---|---|---|
| | | ការពារ និងសហគមន៍ព្រៃឈើ ដើម្បីកាត់បន្ថយហានិភ័យសង្គម និងបរិស្ថានតាមរយៈសកម្មភាពស្តារព្រៃឈើ។ |
| FAO ESS ៤៖ សត្វ-បសុសត្វ និងទឹក - ធនធានពន្ធុសម្រាប់អាហារ និងកសិកម្ម និង IFC PS ៦. ការអភិរក្សជីវៈចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិរស់ដោយចីរភាព | គ្មាន | គម្រោងនេះនឹងមិនណែនាំប្រភេទពូជដែលមិនមែនជាប្រភេទដើម ឬមិនមែនប្រភេទក្នុងស្រុកដែលអាចសម្របខ្លួនទៅតាមតំបន់ ប្រភេទពូជ ហៃ្សន ឬប្រភេទផ្សេងទៀតនោះទេ។ ការគាំទ្ររបស់គម្រោងក្នុងការធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ស្រះត្រីដែលភ្ជាប់ទៅនឹងប្រព័ន្ធធារាសាស្ត្រស្រូវក៏នឹងជួយលើកកម្ពស់ប្រព័ន្ធគ្រប់គ្រងទឹក និងកាត់បន្ថយផលប៉ះពាល់បរិស្ថាន ខណៈពេលដែលរួមចំណែកដល់សន្តិសុខស្បៀងក្នុងមូលដ្ឋាន។ |
| ESS ៥៖ ការគ្រប់គ្រងប្រភេទសត្វចង្រៃ និងថ្នាំសម្លាប់សត្វចង្រៃ និង PS ៣. ប្រសិទ្ធភាពធនធាន និងការការពារការបំពុល | គ្មាន | គម្រោងនេះនឹងលើកកម្ពស់ ការសម្គាល់អត្តសញ្ញាណភូមិសាស្ត្រ ទំនិញ (GI), ការអនុវត្តកសិកម្មល្អរបស់កម្ពុជា (CamGAP), ការវិភាគកម្រិតគ្រោះថ្នាក់ និងចំណុចត្រួតពិនិត្យសំខាន់ៗ (HACCP) និងការបង្កើត និងដំណើរការដែលអនុលោមតាមវិញ្ញាបនប័ត្រសរីរាង្គ និងវិធានការចម្រុះគ្រប់គ្រងដំណាំ (IPM)។ ដូចនេះ គម្រោងនេះនឹងបង្កើតគោលការណ៍ណែនាំ និងការគាំទ្រដល់កសិករដើម្បីកាត់បន្ថយ និងបញ្ជាក់ពីការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត ដោយផ្អែកលើការអនុវត្តជោគជ័យពីអន្តរជាតិ និងក្នុងស្រុក។ គម្រោងនេះនឹងមិនមានលទ្ធផលក្នុងការធ្វើលទ្ធកម្ម ឬការផ្គត់ផ្គង់ដោយផ្ទាល់នូវថ្នាំសម្លាប់សត្វល្អិត ឬថ្នាំកសិកម្ម ឡើយ។ |
| ESS ៦៖ ការតាំងទីលំនៅថ្មី និងការផ្លាស់ទីលំនៅដោយមិនស្ម័គ្រចិត្ត<br><br>IFC PS ៥. ការទិញដី និងការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត | គ្មាន | គម្រោងនេះនឹងមិនអនុញ្ញាតឱ្យមានការតាំងទីលំនៅថ្មី ឬការផ្លាស់ទីលំនៅដោយគ្មានការស្ម័គ្រចិត្តឡើយ។ ទោះបីជាមិនមានផលប៉ះពាល់អវិជ្ជមានត្រូវបានមើលឃើញជាមុននៅតាមសកម្មភាពដែលបានស្នើឡើងក៏ដោយ ក៏ ផែនការគ្រប់គ្រងបរិស្ថាននិងសង្គម(ESMP)នឹងត្រូវបានរៀបចំឡើងនៅពេលតំបន់អន្តរាគមន៍ជាក់លាក់ពីគម្រោងត្រូវបានកំណត់រួចរាល់។ ប្រការនេះនឹងធានាថា គ្មានក្រុមមនុស្សណាមួយនឹងត្រូវបានផ្លាស់ទីលំនៅចេញពីដីរបស់ពួកគេ ឬធ្វើឱ្យមានផលប៉ះពាល់ដល់សិទ្ធិកាន់កាប់ដីរបស់ពួកគេដែរ។ ហានិភ័យទាំងនេះមិនត្រូវបានគិតទុកជាមុននោះទេ ដោយសារថា ការរៀបចំគម្រោងផ្តោតលើការធ្វើការជាមួយសមាគម និងសហជីពកសិកម្មដែលបានបង្កើតឡើង ដែលមានតំបន់ផលិតកម្ម និងបានកំណត់ច្បាស់លាស់ ព្រមទាំងជាមួយសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើដែលមានតំបន់កំណត់ |

| | | |
|---|---|---|
| | | ព្រំប្រទល់ និងសិទ្ធិប្រើប្រាស់ដែលមានការទទួលស្គាល់តាមផ្លូវស្របច្បាប់។ |
| FAO ESS ៧៖ ការងារសមរម្យ និង<br>IFC PS ២. លក្ខខណ្ឌការងារ និងកម្លាំងពលកម្ម និង<br>IFC PS ៤. សុខភាព សុវត្ថិភាព និងសន្តិសុខសហគមន៍ | គ្មាន | គម្រោងនេះនឹងពុំមានការផ្តល់ការងារដោយផ្ទាល់ដល់បុគ្គលិកនោះទេ ប៉ុន្តែវាទំនងជានឹងផ្តល់ឱកាសការងារដោយប្រយោលមិនមែនដោយផ្ទាល់ទេ។<br>គម្រោងនេះនឹងអនុវត្តការងារនៅក្នុងខ្សែច្រវ៉ាក់តម្លៃ និងតំបន់ទេសភាពដែលរួមមានអ្នកផលិតដើម្បីគាំទ្រការចិញ្ចឹមជីវិត និងអ្នកធ្វើការក្នុងវិស័យកសិកម្មក្រៅផ្លូវការងាយរងគ្រោះផ្សេងទៀត ក៏ដូចជានៅក្នុងស្ថានភាពដែលយុវជនធ្វើការភាគច្រើនដោយគ្មានប្រាក់កម្រៃ ដើម្បីរួមចំណែកដល់គ្រួសារ។ សកម្មភាពរបស់គម្រោងគឺផ្តោតលើការកែលម្អលក្ខណៈការងារនៅក្នុងខ្សែច្រវ៉ាក់តម្លៃទាំងនេះ ក្នុងនោះរួមទាំងសកម្មភាពដើម្បីជួយកាត់បន្ថយឧប្បត្តិហេតុនៃ ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH) និង អំពើហិង្សាទាក់ទងនឹងយេនឌ័រ(GBV) និងការគាំទ្រដល់ការទទួលយកដែលមានការលើកកម្ពស់នៃវិធីសាស្ត្រ និងបទដ្ឋាននិរន្តរភាព និងមានគុណតម្លៃខ្ពស់ និងប្រកបដោយនិរន្តរភាព ដែលក្នុងករណីខ្លះមានការធ្វើឱ្យការងារកាន់តែប្រសើរឡើង។ តម្រូវការ និងជំនាញ ខណៈពេលអនុវត្តខ្សែច្រវ៉ាក់តម្លៃប្រសើរឡើង ក៏នឹងជួយកាត់បន្ថយការធ្វើចំណាកស្រុករបស់យុវជន តាមរយៈជម្រើសការងារដែលប្រសើរជាងមុន។ ក្រុមគោលដៅទាំងអស់គឺជាក្រុមដែលបានបង្កើតឡើងរួចហើយផងដែរដូចជា សមាគមន៍កសិកម្ម (ACs) សមាគមកសិករ (FAs) ក្រុមផលិតករ (PGs) និងសហជីពដែលបានដំណើរការជាក្រុម ហើយជាលទ្ធផលគម្រោងនឹងកម្ពស់កម្រិតសមធម៌នៅទូទាំងប្រព័ន្ធផលិតកម្មរបស់ពួកគេ។<br>ក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម(ESMF) ធ្វើការវាយតម្លៃលើបញ្ហាទាំងនេះ ក៏ដូចជាវិធានការកាត់បន្ថយហានិភ័យសំខាន់ៗ ដើម្បីដោះស្រាយនូវអ្វីដែលជាហានិភ័យដែលកំពុងមានវត្តមាន។<br>ទោះបីជាយ៉ាងណាក៏ដោយដោយសារតែហានិភ័យនៃសកម្មភាពនៅក្នុងខ្សែច្រវ៉ាក់តម្លៃ ផែនការគ្រប់គ្រងបរិស្ថាននិងសង្គម(ESMP)លម្អិតនឹងត្រូវបានរៀបចំនៅពេលដែលក្រុមអ្នកទទួលផលជាក់លាក់ ទីតាំង និងប្រព័ន្ធបញ្ជាក់គោលដៅត្រូវបានឯកភាព។ ផែនការគ្រប់គ្រងបរិស្ថាននិងសង្គម(ESMP) នេះក៏នឹងពិនិត្យមើលការចូលរួមពីតំបន់ការពារធម្មជាតិ |

| | | |
|---|---|---|
| | | ដូចដែលបានកត់សម្គាល់នៅក្រោម FAO ESS ២ ខាងលើផងដែរ។<br>សកម្មភាពសុខភាព និងសុវត្ថិភាពការងារ (OHS) នឹងត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំងសម្រាប់ការអនុវត្តសកម្មភាពគម្រោង។ ខណៈពេលដែលសកម្មភាពគម្រោងភាគច្រើនមានហានិភ័យទាប សកម្មភាពព្រៃឈើ និងកសិកម្មផ្សេងៗមានកម្រិតណា មួយនៃហា និភ័យ ឬមានហានិភ័យស្រាប់។ អន្តរាគមន៍របស់គម្រោងនឹងមិនបង្កើនហានិភ័យទាំងនេះ ដោយសារមានការបណ្តុះបណ្តាល និងការគាំទ្រប្រសើរជាងមុននៅលើ ការអនុវត្តកសិកម្មល្អរបស់កម្ពុជា (Cam-GAP) ក៏ដូចជាវឌ្ឍនភាពឆ្ពោះទៅរកវិញ្ញាបនបត្រស្តង់ដារពិភពលោក ដែលត្រូវបានមើលឃើញថាអាចជួយកាត់បន្ថយហានិភ័យទាំងនេះ – ដូចនេះចំណុចនេះត្រូវបានមើលឃើញថាមានហានិភ័យទាប។ |
| FAO ESS ៨៖ សមភាពយេនឌ័រ និង<br>IFC PS ១. ការវាយតម្លៃ និងការគ្រប់គ្រងបរិស្ថាន និងផលប៉ះពាល់ និងហានិភ័យសង្គម | គ្មាន | គម្រោងនេះនឹងគាំទ្រដល់ការពង្រឹងសមត្ថភាពនិងសមភាពយេនឌ័រ ហើយត្រូវបានរៀបចំឡើងដើម្បីគិតគូរពីតម្រូវការ និងអាទិភាពជាក់លាក់របស់ស្ត្រី និងកុមារី និងធ្វើការពិចារណាសំខាន់ៗពាក់ព័ន្ធនឹង ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH) និង អំពើហិង្សាទាក់ទងនឹងយេនឌ័រ(GBV)ថាតើសកម្មភាពអ្វីខ្លះដែលអាចអនុវត្តបានដើម្បីដោះស្រាយបញ្ហាទាំងនេះ។ ការវាយតម្លៃយេនឌ័រ និងផែនការសកម្មភាពយេនឌ័រត្រូវបានបង្កើតឡើងសម្រាប់គម្រោងដែលមានសកម្មភាពជាក់លាក់ត្រូវអនុវត្ត និងថវិកាតាមការបែងចែក។ |
| ESS ៩៖<br>ជនជាតិដើម<br>បេតិកភណ្ឌវប្បធម៌ និង<br>IFC PS ៧. ជនជាតិដើម (IP)<br>IFC PS ៨. បេតិកភណ្ឌវប្បធម៌ | មាន | មានមនុស្សជាង ៤០.000 នាក់នៅទូទាំង ១០ ក្រុមជនជាតិដើមភាគតិច ដែលបានកំណត់ថាកំពុងរស់នៅក្នុងខេត្តគោលដៅដោយផ្អែកលើព័ត៌មានស្ទង់មតិឆ្នាំ២០១៩[8]។ ខណៈពេលដែលទីតាំងគម្រោងជាក់លាក់មិនទាន់ត្រូវបានកំណត់អត្តសញ្ញាណនៅឡើយ ហើយដូច្នេះផលប៉ះពាល់របស់គម្រោងលើក្រុមជនជាតិដើមទាំងនេះមិនទាន់អាចត្រូវបានវាយតម្លៃបានពេញលេញនៅឡើយ។ ផែនការជនជាតិដើមភាគតិច (IPP) ត្រូវបានបង្កើតឡើងសម្រាប់គម្រោង ដោយផ្តល់នូវក្របខ័ណ្ឌណែនាំសកម្មភាព រួមនឹងការអភិវឌ្ឍបន្ថែមទៀតនៃ ផែនការជនជាតិដើមភាគតិច (IPP) ជាក់លាក់សម្រាប់តំបន់គោលដៅដែលត្រូវបានពិនិត្យឡើងវិញក្នុងអំឡុងពេលចាប់ផ្តើមគម្រោង |

[8] Government of Cambodia 2019 Census – available at http://nis.gov.kh/index.php/en/15-gpc/79-press-release-of-the-2019-cambodia-general-population-census

| | | |
|---|---|---|
| | | ប្រសិនបើពួកគេត្រូវបានដាក់បញ្ចូលទៅក្រុមជនជាតិដើមភាគតិច។<br><br>ផែនការនេះក៏យកចិត្តទុកដាក់ និងធានាថា កិច្ចខិតខំប្រឹងប្រែងនឹងត្រូវបានធ្វើឡើងក្នុងការគោរព ដាក់បញ្ចូល និងលើកកម្ពស់បញ្ហារបស់ជនជាតិដើម ក្នុងអំឡុងពេលអនុវត្តគម្រោង រួមទាំងសិទ្ធិរបស់ពួកគេក្នុងការផ្តល់ការឯកភាពដោយសេរី ជាមុន និងផ្អែកលើព័ត៌មានគ្រប់គ្រាន់ (FPIC) អំឡុងពេលកំណត់អត្តសញ្ញាណចុងក្រោយនៃកន្លែង<br>អន្តរាគមន៍។ |

## ៦. ការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម

១៧០. រូបភាពខាងក្រោមផ្តល់នូវទិដ្ឋភាពទូទៅនៃវិធីសាស្ត្រគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមរបស់អង្គការ FAO៖

**ការកំណត់និយមន័យនៅតាមអនុសកម្មភាព**

- ការកំណត់អត្តសញ្ញាណនៃអនុសកម្មភាព៖ សម្រាប់អនុសកម្មភាពនីមួយៗ ទីតាំងអនុវត្តនឹងត្រូវបានកំណត់ដោយស្របទៅនឹងសកម្មភាពដែលមានលក្ខណៈជាក់លាក់ទៅនឹងទីតាំងនីមួយៗ។

↓

**ការពិនិត្យហានិភ័យបរិស្ថាន និងសង្គមនៅតាមអនុសកម្មភាព**

- ការពិនិត្យហានិភ័យដែលអាចកើតមានឡើង សម្រាប់អនុវត្តនៅកម្រិតអនុសកម្មភាព គឺត្រូវប្រើប្រាស់បញ្ជីពិនិត្យបរិស្ថាន និងសង្គមរបស់អង្គការ FAO។
- ការពិពណ៌នាលម្អិតស្តីពីឯកសារការពារសុវត្ថិភាពមុនពេលអនុវត្ត (មួយអនុសកម្មភាពក្នុងមួយឆ្នាំ) ដោយអង្គភាពគ្រប់គ្រងគម្រោង។

↓

**ការគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម (ការត្រួតពិនិត្យ និងរាយការណ៍)**

- ការរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គម ដែលមានអនុសកម្មភាព ត្រូវបានកំណត់ថាមានហានិភ័យមធ្យម ដោយផ្អែកលើដំណើរការពិនិត្យហានិភ័យបរិស្ថាន និងសង្គម ដែលបានរៀបរាប់ខាងលើ ។ ការគ្រប់គ្រងបរិស្ថាន និងសង្គម នេះចាំបាច់ត្រូវធ្វើការកែសម្រួល ហើយទទួលបានការឯកភាពឱ្យអនុវត្តដោយអង្គភាពគ្រប់គ្រងបរិស្ថាន និងសង្គម នៅទីស្នាក់ការកណ្តាលរបស់អង្គការ FAO។
- បុគ្គលិករបស់អង្គភាពគ្រប់គ្រងគម្រោង និងបុគ្គលិកនៅមូលដ្ឋាន នឹងរៀបចំរបាយការណ៍ត្រួតពិនិត្យ ដែលក្នុងនោះរួមបញ្ចូលទាំងផ្នែកគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម ដោយធ្វើការសង្ខេបពីវឌ្ឍនភាពនៃការរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គម និងប្រធានបទផ្សេងៗទៀតទាក់ទងនឹងការការពារសុវត្ថិភាព។
- ការត្រួតពិនិត្យលើវឌ្ឍនភាពនៃការរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គម នឹងត្រូវធ្វើឡើងដោយក្រុមអ្នកជំនាញការផ្នែកការពារបរិស្ថាននិងសង្គម និង អ្នកជំនាញការផ្នែកយេនឌ័រ ដែលធ្វើការនៅក្នុងអង្គភាពគ្រប់គ្រងគម្រោង។ ពួកគេនឹងចងក្រងព័ត៌មានដែលទទួលបានពីរបាយការណ៍វឌ្ឍនភាព ព្រមទាំងព័ត៌មានអំពីយន្តការបណ្តឹង ហើយដាក់បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆមាសស្តីពីវឌ្ឍនភាពនៃការការពារបរិស្ថាន និងសង្គម ដែលនឹងត្រូវបានកែសំរួល និងទទួលបានការឯកភាពពីអង្គភាពគ្រប់គ្រងបរិស្ថាន និងសង្គម នៅទីស្នាក់ការកណ្តាលរបស់អង្គការ FAO។

*រូបភាពទី 7. ទិដ្ឋភាពទូទៅនៃវិធីសាស្ត្រគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គម (E&S) របស់អង្គការ FAO*

## ៦.១ ជំហានទី ១៖ ការកំណត់និយមន័យនៃអនុសកម្មភាព

១៧១. គម្រោង PEARL ត្រូវបានរំពឹងថានឹងផ្តល់ផលប្រយោជន៍ផ្នែកបរិស្ថាន និងសង្គមច្រើនជាងផលប៉ះពាល់អវិជ្ជមាន។ ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានពីគម្រោងគឺទំនងជាតូច និងនៅតំបន់ជាក់លាក់ដែលជាប់ទាក់ទងជាពិសេសទៅនឹងសកម្មភាពដែលធ្វើឡើងដោយសមាគម និងក្រុមកសិករជាក់លាក់ ដែលត្រូវបានផ្តល់អាទិភាពដោយ និងមានការចូលរួមជាមួយគម្រោង។ ដូចនេះ វាគឺជាផ្នែកគន្លឹះដែលថា នៅពេលកំណត់រកឃើញផលប៉ះពាល់ណាមួយនៅពេលដំបូង ក្នុងអំឡុងពេលនៃដំណើរការរៀបចំផែនការនោះ វិធានការកាត់បន្ថយត្រូវតែបានរៀបចំឡើង ហើយដាក់បញ្ចូលទៅក្នុងការរៀបចំផែនការ និងការអនុវត្តគម្រោង។ ជាអនុសាសន៍ ការត្រួតពិនិត្យវាយតម្លៃហានិភ័យត្រូវបានធ្វើឡើងនៅកម្រិតអនុសកម្មភាព នៅពេលសមាគម និងសហគមន៍តំបន់ការពារធម្មជាតិជាគោលដៅ និងអនុសកម្មភាពជាក់លាក់ដែលនឹងទទួលបានការគាំទ្រ (ក្រោមលទ្ធផល ២ ជាពិសេស) ត្រូវបានកំណត់។ ហានិភ័យទាំងនេះនឹងត្រូវបានកំណត់អត្តសញ្ញាណក្នុងអំឡុងពេលឆ្នាំទី១ និងទី២ នៃគម្រោង (តាមរយៈវិធានការដំបូងៗ ដើម្បីគាំទ្រដល់ការអនុវត្តនៃលទ្ធផល ២.១, ២.២. និង ២.៤)។ ចំពោះអនុសកម្មភាពនីមួយៗ ទីតាំងអនុវត្តនឹងត្រូវបានកំណត់ រួមទាំងសកម្មភាព ក្នុងនោះរួមមានការកសាងសមត្ថភាព ការបណ្តុះបណ្តាល និងព័ត៌មានអំពីការចូលរួមរបស់ភាគីពាក់ព័ន្ធដែលជាប់ទាក់ទងជាពិសេសទៅនឹងទីតាំងនីមួយៗ។

## ៦.២ ជំហានទី ២៖ ការត្រួតពិនិត្យហានិភ័យបរិស្ថាន និងសង្គមនៃអនុសកម្មភាព

១៧២. សកម្មភាពនីមួយៗនឹងត្រូវបានពិនិត្យវាយតម្លៃដោយប្រើបញ្ជីត្រួតពិនិត្យវាយតម្លៃបរិស្ថាន និងសង្គមរបស់អង្គការ FAO (ក្នុងឧបសម្ព័ន្ធទី ៣ នៃឯកសារនេះ)។ នៅពេល ទីតាំងអនុវត្ត អ្នកទទួលផល និងអនុសកម្មភាព ត្រូវបានកំណត់អត្តសញ្ញានរួចហើយ (ជំហានទី ១) បញ្ជីត្រួតពិនិត្យវាយតម្លៃនឹងត្រូវបានរៀបចំឱ្យរួចរាល់ សម្រាប់មួយសកម្មភាព ហើយចុះហត្ថលេខាទទួលស្គាល់ ដោយអ្នកជំនាញការពារសុវត្ថិភាព និងយេនឌ័រនៅក្នុងអង្គភាពគ្រប់គ្រងគម្រោង (PMU)។ បញ្ជីនេះនឹងមានចំណុចទាក់ទងនឹង ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)ដែលនឹងត្រូវបានកំណត់នៅក្រោម ESS៧ និង ESS៨ នៃការការពារសុវត្ថិភាពរបស់អង្គការ FAO ។ ដំណើរការពិនិត្យវាយតម្លៃ និងការអនុវត្តទូលំទូលាយក៏នឹងត្រូវស្របតាមគោលនយោបាយពាក់ព័ន្ធទាំងអស់របស់ GCF និងអង្គការ FAO ដូចបានធ្វើការកត់សម្គាល់ នៅពេលចាប់ផ្តើមនៃផ្នែកនេះ ដោយអ្នកឯកទេសការការពារសុវត្ថិភាព និងយេនឌ័រធ្វើការទទួលខុសត្រូវលើការវាយតម្លៃដំបូង និងធានាថា ការពិចារណានានាត្រូវមានជាប់ទាក់ទងទៅនឹង ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)ដូចមានកំណត់ក្នុងគោលនយោបាយរបស់អង្គការ FAO ស្តីពីការបង្ការការបំពារបំពាន ការបៀតបៀនផ្លូវភេទ និងការរំលោភបំពានរបស់អាជ្ញាធរ N° ២០១៥/០៣ (២០១៥) និងការបៀតបៀនផ្លូវភេទ F (១៣ កុម្ភៈ ២០១៩) ក៏ដូចជាគោលនយោបាយដែលបានកែលម្អរបស់ GCF ស្តីពីការទប់ស្កាត់ និងការពារពីការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពានផ្លូវភេទ និងការបៀតបៀនផ្លូវភេទ (២០២១)។ មន្ត្រីទាំងពីររូបនឹងទទួលបានការបណ្តុះបណ្តាលស្តីពីការដាក់បញ្ចូលខ្លឹមសារទាំងនេះ ក្នុងនោះរួមទាំងការប្រើប្រាស់ឯកសារស្តីពីគោលការណ៍ណែនាំរបស់អង្គការ FAO និង GCF (បានសម្គាល់ខាងលើថាកំពុងរៀបចំ) ពីទីស្នាក់ការកណ្តាលរបស់ FAO ហើយការរកឃើញពីការវាយតម្លៃនេះនឹងត្រូវបានត្រួតពិនិត្យដោយ អង្គភាពគ្រប់គ្រងគម្រោង (PMU)និងការិយាល័យប្រចាំប្រទេសរបស់ FAO ព្រមទាំងទីស្នាក់ការរបស់អង្គការ FAO ដែលទទួលខុសត្រូវចុងក្រោយក្នុងការអនុវត្តគោលនយោបាយទាំងនេះ។ ក្រុមការងារមកពីទីស្នាក់ការកណ្តាលរបស់អង្គការ FAO ក៏នឹងធ្វើទស្សនកិច្ចទៅកាន់គម្រោង តាមពេលវេលាកំណត់ទៅកាន់ក្នុងអំឡុងពេលចាប់ផ្តើម និងការអនុវត្ត ដើម្បីពិនិត្យមើលវឌ្ឍនភាព ធៀបនឹងសូចនាករជាច្រើន ក្នុងនោះរួមទាំងសូចនាករដែលជាប់ពាក់ព័ន្ធនឹងការអនុវត្តការការពារ សុវត្ថិភាព និងគោលនយោបាយដែលបានបង្ហាញខាងលើ។

១៧៣. ប្រការសំខាន់នោះគឺថា ការពិនិត្យវាយតម្លៃ ផែនការគ្រប់គ្រងបរិស្ថាននិងសង្គម(ESMP)នឹងចាប់ផ្តើមនៅឆ្នាំទី ១ ហើយវានឹងក្លាយជាដំណើរការបណ្តើរៗ និងបន្តនៅឆ្នាំទី ២ និងប្រហែលជាផ្នែកមួយចំនួននៃឆ្នាំទី ៣ នៅមានការពិគ្រោះយោបល់ជាជាមួយ និងមានការចូលរួមពីសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍កសិកម្មផ្សេងៗក្នុងដំណើរការរៀបចំផែនការ និងការអនុវត្ត។ លទ្ធផលនៃបញ្ជីត្រួតពិនិត្យវាយតម្លៃនេះ នឹងត្រូវបានប្រមូលផ្តុំដោយអ្នកឯកទេសការពារសុវត្ថិភាព។ បញ្ជីនេះនឹងត្រូវបញ្ជូនទៅអង្គភាព ESM របស់អង្គការ FAO ដើម្បីស្នើសុំការយល់ព្រម។ ការពិនិត្យវាយតម្លៃនេះនឹងធានាថា៖

- សកម្មភាពនេះទទួលបានការអនុញ្ញាត និងស្របតាមក្របខ័ណ្ឌច្បាប់ និងលក្ខខណ្ឌតម្រូវផ្នែកលិខិតបទដ្ឋានគតិយុត្តរបស់គម្រោង។
- កម្រិតសមស្របនៃការវាយតម្លៃបរិស្ថានត្រូវបានធ្វើឡើង ដោយផ្អែកលើកម្រិតនៃផលប៉ះពាល់ដែលបានរំពឹងទុក។

១៧៤. ខណៈដែលលក្ខណៈ វិសាលភាព ការកែប្រែ និងទីតាំងនៃផលប៉ះពាល់គឺជាសមាសធាតុស្នូលក្នុងការពិនិត្យវាយតម្លៃអនុសកម្មភាពនោះ ការវិនិច្ឆ័យរបស់អ្នកជំនាញនឹងជាកត្តាដ៏សំខាន់ក្នុងការសម្រេចថាតើអនុសកម្មភាពគួរតែបានដាក់បញ្ចូលក្នុងផែនការគ្រប់គ្រងបរិស្ថាន និងសង្គមដែរ ឬយ៉ាងណា (សូមមើល អនុផ្នែកខាងក្រោម)។

១៧៥. បញ្ជីត្រួតពិនិត្យសម្រាប់ត្រួតពិនិត្យវាយតម្លៃបរិស្ថាន និងសង្គមដែលបានពិនិត្យផ្ទៀងផ្ទាត់ដោយអ្នកឯកទេសការពារសុវត្ថិភាព និងអ្នកឯកទេសយេនឌ័រ (នៅពេលណាចាំបាច់) នឹងនាំដល់ការស្រេចលទ្ធផលពិនិត្យវាយតម្លៃដូចខាងក្រោម៖ (i) ការកំណត់ប្រភេទសម្រាប់ការវាយតម្លៃបន្ថែម។ និង (ii) ការកំណត់ថាតើឧបករណ៍វាយតម្លៃបរិស្ថានមួយណាគួរយកមកអនុវត្ត។

១៧៦. ឯកសារស្តីពីការការពារសុវត្ថិភាពនៃមុនពេលអនុវត្ត (ឯកសារមួយសម្រាប់អនុសកម្មភាពមួយ) នឹងត្រូវបានរៀបចំដោយអ្នកឯកទេសការការពារសុវត្ថិភាព និងទេសយេនឌ័រ ក្នុង PMU មុនពេលការអនុវត្តសកម្មភាពនានានៅក្នុងលទ្ធផលទី ២។ ឯកសារ និងព័ត៌មានខាងក្រោមនឹងត្រូវបានផ្តល់ជូនសម្រាប់អន្តរាគមន៍ជាក់លាក់ពីគម្រោង៖

- ការពិពណ៌នាអំពីសកម្មភាពដែលត្រូវអនុវត្តនៅគ្រប់ទីតាំងទាំងអស់។
- ការពិពណ៌នាអំពីទីតាំងអនុវត្តនីមួយៗ៖
  - ភូមិសាស្ត្រ និងភាពជាក់លាក់ទាក់ទងនឹងសកម្មភាព
  - អ្នកទទួលផល និងភាគីពាក់ព័ន្ធ
  - កូអរដោនេ GPS និងផែនទីបញ្ជាក់ទីតាំង
- ចំពោះអន្តរាគមន៍ទាំងអស់នៅក្នុងតំបន់ការពារ កូអរដោនេនៃទីតាំងអន្តរាគមន៍សម្រាប់អ្នកទទួលផលនឹងត្រូវបានវាយតម្លៃ មុននឹងអនុវត្តការវិនិយោគ ដើម្បីធានាថា ទីតាំងទាំងនោះស្ថិតនៅក្នុងតំបន់ដែលបានព្រមព្រៀងគ្នាជាមុនសម្រាប់សកម្មភាពកសិកម្ម ឬសកម្មភាពស្តារឡើងវិញ។ ការធ្វើដូច្នេះគឺធានាថាគ្មានសកម្មភាពណាដែលរួមចំណែកដល់ការរេចរឹលបន្ថែមទៀតនៃតំបន់ការពារធម្មជាតិ (សូមមើលជំពូកទី ៩ សម្រាប់ព័ត៌មានបន្ថែមអំពីក្របខ័ណ្ឌគ្រប់គ្រងជីវៈចម្រុះរបស់គម្រោង)។
- ការពិពណ៌នាអំពីដំណើរការចូលរួមរបស់ភាគីពាក់ព័ន្ធដែលត្រូវបានអនុវត្តនៅក្នុងដំណាក់កាលចាប់ផ្តើម និងផែនការការស្តីពីការចូលរួមរបស់ភាគីពាក់ព័ន្ធដែលត្រូវរៀបចំឡើង ក្នុងអំឡុងពេលអនុវត្ត
- ការរៀបចំព័ត៌មានដោយសម្រាប់ តាមទីតាំងនីមួយអំពីយន្តការដោះស្រាយបន្តឹងតវ៉ា និងការផ្សព្វផ្សាយព័ត៌មាន?

- លទ្ធផលសរុបនៃបញ្ជីត្រួតពិនិត្យសម្រាប់ត្រួតពិនិត្យវាយតម្លៃបរិស្ថាន និងសង្គមក្នុងមួយអនុសកម្មភាព ដែលទទួលបានការអនុម័ត និងចុះហត្ថលេខាដោយអង្គភាព ESM នៅក្នុងទីស្នាក់ការកណ្ដាលរបស់អង្គការ FAO។

## ៦.៣ ជំហានទី ៣៖ ផែនការគ្រប់គ្រងបរិស្ថាននិងសង្គម ការត្រួតពិនិត្យនិងការរាយការណ៍

១៧៧. អនុសមាសធាតុដែលហានិភ័យបរិស្ថាន និងសង្គមត្រូវបានកំណត់អត្តសញ្ញាណ នឹងត្រូវបង្កើតផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (ESMP) ដែលមានព័ត៌មានស្ដីពីវិធានការកាត់បន្ថយ សូចនាករ ការទទួលខុសត្រូវ និងរយៈពេលដែលរំពឹងថាត្រូវបញ្ចប់វិធានការបែបនេះ។ ផែនការគ្រប់គ្រងបរិស្ថាននិងសង្គម(ESMP)នឹងត្រូវបានបង្កើតឡើងសម្រាប់អនុសកម្មភាពដែលនឹងទទួលបានព័ត៌មានតាមរយៈដោយដំណើរការពិនិត្យវាយតម្លៃសកម្មភាពដែលបានពិពណ៌នា។

១៧៨. ខណៈពេលដែលលក្ខណៈ វិសាលភាព ការប្រែប្រួល និងទីតាំងនៃផលប៉ះពាល់គឺជាធាតុស្នូលក្នុងការពិនិត្យវាយតម្លៃមើលអនុសកម្មភាព ការវិនិច្ឆ័យរបស់អ្នកជំនាញដោយមន្ត្រីការពារសុវត្ថិភាពរបស់គម្រោង និងក្រុមប្រចាំតំបន់អង្គការ FAO នឹងក្លាយជាកត្តាចម្បងក្នុងការសម្រេចថាតើ ផែនការគ្រប់គ្រងបរិស្ថាននិងសង្គម(ESMP)ត្រូវជាតម្រូវការចាំបាច់សម្រាប់សកម្មភាព និង/ឬក៏ទីទាំងនោះដែរទេ។

១៧៩. ផែនការគ្រប់គ្រងបរិស្ថាននិងសង្គម(ESMP)គួរមានចំណុចដូចខាងក្រោម៖

- **វិធានការកាត់បន្ថយ៖** ផ្អែកលើផលប៉ះពាល់បរិស្ថាន និងសង្គមដែលបានកំណត់ពីបញ្ជីត្រួតពិនិត្យនោះ ផែនការគ្រប់គ្រងបរិស្ថាននិងសង្គម(ESMP)គួរពិពណ៌នាជាមួយព័ត៌មានលម្អិតផ្នែកបច្ចេកទេសវិធានការកាត់បន្ថយនីមួយៗ រួមនឹងការរចនា ការពិពណ៌នាឧបករណ៍ និងនីតិវិធីប្រតិបត្តិការ តាមភាពសមស្រប។
- **ការត្រួតពិនិត្យ៖** ការត្រួតពិនិត្យបរិស្ថាន និងសង្គមក្នុងអំឡុងពេលអនុវត្តសកម្មភាព ដើម្បីវាស់វែងភាពជោគជ័យនៃវិធានការកាត់បន្ថយ។ ជាពិសេស ផ្នែកត្រួតពិនិត្យនៃ ផែនការគ្រប់គ្រងបរិស្ថាននិងសង្គម(ESMP)ផ្ដល់ជូននូវ៖

  ការពិពណ៌នាជាក់លាក់ និងព័ត៌មានលម្អិតស្ដីពីបច្ចេកទេសនៃវិធានការត្រួតពិនិត្យដែលមានប៉ារ៉ាម៉ែត្រដើម្បីវាស់វែង វិធីសាស្ត្រដែលត្រូវប្រើ ទីតាំងសំណាកគំរូ ភាពញឹកញាប់នៃការវាស់វែង ដែនកំណត់នៃការរកឃើញ (ទីណាសមស្រប) និងការកំណត់នៃកម្រិតដែលនឹងបង្ហាញអំពីតម្រូវការសម្រាប់សកម្មភាពកែតម្រូវ។

  នីតិវិធីតាមដាន និងរាយការណ៍ ដើម្បីធានាដល់ការរកឃើញពីដំបូងនៃផលប៉ះពាល់ ដែលចាំបាច់ត្រូវមាន វិធានការបន្ថយជាក់លាក់ និងដើម្បីផ្ដល់ព័ត៌មានអំពីវឌ្ឍនភាព និងលទ្ធផលនៃការកាត់បន្ថយ (ឧ. តាមរយៈសវនកម្ម និងការស្ទង់មតិប្រចាំឆ្នាំ ដើម្បីតាមដានប្រសិទ្ធភាពជារួមនៃ ក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម (ESMF) នេះ។
- **ការរៀបចំស្ថាប័នសម្រាប់ M&E៖** ផែនការគ្រប់គ្រងបរិស្ថាននិងសង្គម (ESMP) ក៏ផ្ដល់ការពិពណ៌នាជាក់លាក់នៃការរៀបចំស្ថាប័ន ពោលគឺនរណាទទួលខុសត្រូវក្នុងការអនុវត្តវិធានការកាត់បន្ថយ និងត្រួតពិនិត្យសម្រាប់ប្រតិបត្តិការ ការត្រួតពិនិត្យ ការអនុវត្ត ការត្រួតពិនិត្យការអនុវត្ត សកម្មភាពដោះ

ស្រាយ ការផ្ដល់ហិរញ្ញប្បទាន របាយការណ៍ និងការបណ្ដុះបណ្ដាលបុគ្គលិក)។ លើសពីនេះទៀត ផែនការគ្រប់គ្រងបរិស្ថាននិងសង្គម(ESMP)គួរមានការប៉ាន់ប្រមាណនៃការចំណាយលើការអនុវត្ត វិធានការ និងសកម្មភាពដែលបានស្នើឡើង ដើម្បីបញ្ចូលមូលនិធិចាំបាច់ទៅក្នុងផ្នែកនេះនៃការរៀបចំ ផែនការការងារក្នុងអំឡុងឆ្នាំទី ១ និងទី ២ របស់គម្រោង។ វិធានការកាត់បន្ថយ និងការត្រួតពិនិត្យ ដែលបានស្នើដាក់បញ្ចូលទៅក្នុង ផែនការគ្រប់គ្រងបរិស្ថាននិងសង្គម(ESMP)គួរតែត្រូវបានបង្កើត ឡើង ដោយមានការពិគ្រោះយោបល់ជាមួយក្រុមដែលរងផលប៉ះពាល់ទាំងអស់ ដោយបញ្ចូលកង្វល់ និងទស្សនៈរបស់ពួកគេនៅក្នុងការរៀបចំ ផែនការគ្រប់គ្រងបរិស្ថាននិងសង្គម(ESMP)។

១៨០. នៅពេលឯកសារមុនពេលអនុវត្តនៅតាមទីតាំងជាក់លាក់មាន ផែនការគ្រប់គ្រងបរិស្ថាននិងសង្គម (ESMP)បានទទួលការអនុម័តពីអង្គភាពទទួលខុសត្រូវការគ្រប់គ្រងបរិស្ថាននិងសង្គម(ESM) របស់អង្គការ FAO ហើយនោះ អ្នកឯកទេសការពារសុវត្ថិភាពនឹងធានាថាមានការបញ្ចូល និងរាយការណ៍ពី ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម(ESMP)នោះ រួមទាំងការចូលរួមពីភាគីពាក់ព័ន្ធនៅក្នុងបរិបទនៃផែនការត្រួតពិនិត្យ។ ក្នុងបរិបទនេះ បុគ្គលិកទីវាល (បុគ្គលិកអង្គភាពគ្រប់គ្រងគម្រោង PMU សហការមួយអាជ្ញាធរខេត្ត និងមូលដ្ឋាន និងភ្នាក់ងារ ផ្សព្វផ្សាយ) នឹងទទួលខុសត្រូវក្នុងការត្រួតពិនិត្យ វឌ្ឍនភាពដែលជាប់ព័ន្ធក្នុងផែនការត្រួតពិនិត្យ ក៏ដូចជាកំណត់ហា និភ័យជាសក្ដានុពលណាមួយដែលអាចកើតមានដែល អាចកើតមានក្នុងដំណាក់កាលនៃការអនុវត្ត។ ព័ត៌មាននេះ នឹងត្រូវបានចងក្រងនៅក្នុងរបាយការណ៍ និងទម្រង់គំរូស្ដីពីវឌ្ឍនភាព ក្នុងនោះរួមទាំងផ្នែកមួយស្ដីពីការគ្រប់គ្រងហា និភ័យបរិស្ថាន និងសង្គម។

១៨១. ព័ត៌មានពីរបាយការណ៍វឌ្ឍនភាពនឹងត្រូវបញ្ជូនទៅអ្នកឯកទេសការពារសុវត្ថិភាព និងយេនឌ័រនៅក្នុង អង្គភាពគ្រប់គ្រងគម្រោង (PMU) ដែលនឹងចងក្រងព័ត៌មានទទួលបាននៅក្នុងរបាយការណ៍វឌ្ឍនភាព ក៏ដូចជា ព័ត៌មានទាក់ទងនឹងការបណ្ដឹងតវ៉ានៅក្នុងរបាយការណ៍ពាក់កណ្ដាលឆ្នាំស្ដីពីការអនុវត្តការការពារបរិស្ថាន និង សង្គមទៅដែលនឹងអនុម័តទទួលស្គាល់ពីអង្គភាព ESM នៅក្នុងអង្គការ FAO។

## ៦.៤ វិធានការកាត់បន្ថយហានិភ័យបរិស្ថាន និងសង្គមដែលមានសក្ដានុពល

១៨២. ផលប៉ះពាល់អវិជ្ជមានជាសក្ដានុពល និងវិធានការកាត់បន្ថយដែលបានស្នើឡើង ត្រូវបានកំណត់សម្រាប់ លទ្ធផលរបស់គម្រោងនីមួយៗនៃលទ្ធផលគម្រោងទាំងបី ហើយបម្រើជាមូលដ្ឋានក្នុងការរៀបចំ ផែនការគ្រប់គ្រងប រិស្ថាននិងសង្គម(ESMP) ដែលបង្កើតឡើង ដោយផ្អែកលើលទ្ធផល រួមនឹងវិធានការកាត់បន្ថយអន្តរវិស័យមួយ ចំនួន រួមទាំងការអនុវត្ត ការយល់ព្រមជាមុន ដោយសេរីដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់(FPIC) នៅគ្រប់ សកម្មភាពរបស់គម្រោង។

តារាងទី 6. ផលប៉ះពាល់អវិជ្ជមានជាសក្តានុពល និងវិធានការកាត់បន្ថយដែលបានស្នើឡើងសម្រាប់លទ្ធផលទី ១៖ សមត្ថភាពរបស់កសិករត្រូវបានពង្រឹងដើម្បីគ្រប់គ្រងផលប៉ះពាល់អាកាសធាតុ និងហានិភ័យពាក់ព័ន្ធ

| **ផលប៉ះពាល់ដែលអាចកើតមាន** | **វិធានការកាត់បន្ថយមួយ ឬច្រើន** |
|---|---|
| • ការលើកកម្ពស់ការបណ្តុះបណ្តាល និងការផ្តល់ព័ត៌ផ្តល់អត្ថប្រយោជន៍មិនបានសមស្របដល់កសិករមួយចំនួនដែលបង្កើនវិសមភាពរវាងក្រុម និង/ឬយេនឌ័រទាំងអស់។ | • សមាសធាតុទាំងអស់នៃការរៀបចំលទ្ធផលផ្តោតលើការបង្កើតសម្ភារ និងប្រព័ន្ធបរិយាប័ន្ន និងឆ្លើយតបយេនឌ័រ ដែលមានភាពសមស្របផងដែរសម្រាប់ការចូលរួមប្រសិនបើក្រុមជនជាតិដើមភាគតិច និងរួមបញ្ចូលនូវបុគ្គល/ភាគីទាំងឡាយណាដែលជួយកាត់បន្ថយហានិភ័យនៃការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)ដោយធ្វើការបញ្ជ្រាបគំនិត/ទស្សនទានទាំងនេះនៅក្នុងការរៀបចំគម្រោងដោយផ្តល់វិធានការកាត់បន្ថយយ៉ាងសំខាន់ ដែលនឹងត្រូវបានត្រួតពិនិត្យតាម រយៈ អង្គភាពគ្រប់គ្រងគម្រោង (PMU)។ សកម្មភាពជាក់លាក់ដើម្បីជួយសម្រួលវិធានការនេះក៏នឹងរួមមានដូចខាងក្រោម៖<br>– ការរៀបចំបង្កើតប្រព័ន្ធដែលមានភាពប្រសើរឡើងក្នុងការប្រមូល និងការព្យាករណ៍ទិន្នន័យនឹងពិចារណាវិធីសាស្ត្រនៃការធ្វើកសិកម្មផ្សេងៗគ្នា និងតម្រូវការខុសៗគ្នារបស់អ្នកផលិត និងអ្នកផលិតខ្នាតធំៗ និងខ្នាតតូច។<br>– ការអភិវឌ្ឍនៃ SOP(s) សម្រាប់ការផលិត និងការផ្សព្វផ្សាយសេវាកម្មប្រឹក្សាកសិឧតុនិយម និងតម្រូវការចែករំលែកទិន្នន័យ និងស្ថាបត្យកម្ម ការកំណត់គោលដៅស្វាយចន្ទី ស្វាយ អង្ករ និងបន្លែជាគោលដៅនឹងត្រូវធ្វើឡើង តាមរយៈដំណើរការដោយមានការចូលរួមពីភាគីពាក់ព័ន្ធច្រើនក្រុម ដើម្បីធានាថា វិធីសាស្ត្រដែលបានស្នើឡើងយកចិត្តទុកដាក់កលើតម្រូវការខុសៗគ្នានៃក្រុមកសិកម្មផ្សេងៗគ្នា និងមិនពង្រឹងអតុល្យភាពដែលមានស្រាប់ដែលជាប់ពពាក់ព័ន្ធនឹងសមត្ថភាពទទួលបានព័ត៌មាន។<br>– ការគាំទ្រដល់ការបង្កើនការយល់ដឹងអំពីសេវាកម្ម និងសម្ភារប្រឹក្សាកសិឧត្តុនិយមនឹងត្រូវបានកាត់តម្រូវ ដោយធ្វើការពិចារណាពីកម្រិតខុសៗគ្នានាពេលបច្ចុប្បន្ននៃការយល់ដឹង រួមទាំងសកម្មភាពគោលដៅ ដើម្បីកាត់បន្ថយភាពមិនស៊ីសង្វាក់ជាធរមាននៃព័ត៌មានក្នុងចំណោមក្រុមទាំងនោះ។<br>– ការដាក់បញ្ចូលចំណុចដៅដែលផ្តោតការយកចិត្តទុកដាក់លើសម្រាប់អ្នកសម្របសម្រួលការបណ្តុះបណ្តាល និងការចូលរួមក្នុងវគ្គបណ្តុះបណ្តាល ព្រមទាំងការចូលរួមជាគោលគោលដៅជាមួយក្រុមផលិតករ នឹងគាំទ្រដល់ការចូលរួមទូលំទូលាយ និងសម្របសម្រួលការផ្ទេរព័ត៌មាន និងជំនាញទៅកាន់ក្រុមមនុស្សដែលងាយរងគ្រោះនៅក្នុងសហគមន៍។ |

តារាងទី 7. ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន និងវិធានការដែលបានស្នើឡើងសម្រាប់លទ្ធផលទី២៖ សមត្ថភាពបន្សាំរបស់កសិករខ្នាតតូច និងតួអង្គខ្សែច្រវ៉ាក់តម្លៃផ្សេងៗទៀតនៅមូលដ្ឋាន ជាពិសេសកសិករ និងតួអង្គខ្សែច្រវ៉ាក់តម្លៃជាស្ត្រី ត្រូវបានលើកកម្ពស់ តាមរយៈកសិកម្មនិរន្តរភាព ធន់នឹងអាកាសធាតុ និងមានគុណតម្លៃខ្ពស់

| ផលប៉ះពាល់អវិជ្ជមានជាសក្តានុពល | វិធានការកាត់បន្ថយមួយ ឬច្រើន |
| --- | --- |
| • ការលើកកម្ពស់ការបណ្តុះបណ្តាល និងការគាំទ្រក្នុងនោះរួមទាំងលទ្ធភាពក្នុងការផ្តល់ហិរញ្ញវត្ថុកម្មវិធីវិញ្ញាបនប័ត្រធន់នឹងអាកាសធាតុ និងមានតម្លៃខ្ពស់ផ្តល់អត្ថប្រយោជន៍មិនសមាមាត្រដល់កសិករមួយចំនួនដែលបង្កើនវិសមភាពក្នុងចំណោមក្រុម និង/ឬយេនឌ័រតាមក្រុមទាំងអស់។ | • សមាសធាតុទាំងអស់នៃការរៀបចំលទ្ធផលផ្តោតលើការរៀបចំសម្ភារ និងប្រព័ន្ធបរិយាប័ន្ន និងឆ្លើយតបយេនឌ័រ ដែលមានភាពសមស្របសម្រាប់ការចូលរួម និងរួមបញ្ចូលទាំងបុគ្គល/ភាគីទាំងឡាយណាដែលជួយកាត់បន្ថយហានិភ័យនៃ ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)ដោយធ្វើការបញ្ជ្រាបគំនិត/ទស្សនទានទាំងនេះនៅក្នុងការរៀបចំគម្រោង ដោយផ្តល់វិធានការកាត់បន្ថយយ៉ាងសំខាន់ ដែលនឹងត្រូវបានត្រួតពិនិត្យតាមរយៈ អង្គភាពគ្រប់គ្រងគម្រោង (PMU)។ សកម្មភាពជាក់លាក់ដើម្បីជួយសម្រួលវិធានការនេះក៏នឹងរួមមានដូចខាងក្រោម៖<br>– ការជ្រើសរើសក្របខណ្ឌវិញ្ញាបនប័ត្រនឹងផ្អែកលើលក្ខណៈវិនិច្ឆ័យដែលមានលទ្ធភាពទទួលបានក្របខណ្ឌរបស់កសិករនៅកម្រិតខុសៗគ្នានៃសមត្ថភាព។<br>– ការបង្កើតផែនទីបង្ហាញផ្លូវខ្សែច្រវ៉ាក់តម្លៃនឹងធ្វើឡើង តាមរយៈដំណើរការមានការចូលរួម ហើយនឹងបញ្ចូលការផ្តោតការយកចិត្តទុកដាក់ពីវិធីគាំទ្រក្រុមមនុស្សងាយរងគ្រោះបំផុត និងមានលទ្ធភាពតិចតួចបំផុតដើម្បីបង្កើនបច្ចេកទេសផលិតកម្ម។<br>– រៀបចំបង្កើតលក្ខណៈវិនិច្ឆ័យ និងឯកសារគោលការណ៍ណែនាំ ក៏ដូចជាការបណ្តុះបណ្តាលមន្ត្រីរដ្ឋាភិបាល និងសមាជិកសមាគមកសិកម្ម និងវិស័យឯកជន ដើម្បីជួយពង្រឹងការរៀបចំបង្កើតកិច្ចព្រមព្រៀងកសិកម្មតាមកិច្ចសន្យា ដើម្បីធានាថា កិច្ចព្រមព្រៀងទាំងនោះគាំទ្រកសិករទាំងអស់ និងអាចពង្រឹងសមត្ថភាពរបស់ក្រុមមនុស្សទាំងឡាយណាដែលងាយរងគ្រោះបំផុត។<br>– ការរៀបចំបង្កើតសម្ភារបណ្តុះបណ្តាលសម្រាប់ភាគីពាក់ព័ន្ធច្រើនក្រុម និងប្រើប្រាស់មធ្យោបាយច្រើនប្រភេទ ដើម្បីធានាថា ក្រុម/ភាគីដែលមានកម្រិតអក្ខរកម្មទាប និង/ឬលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាទាប អាចទទួលបានការបណ្តុះបណ្តាលទាំងនោះ។<br>– ការរៀបចំដោយមានការចូលរួមនៃផលិតផលហិរញ្ញវត្ថុ ដើម្បីធានាដល់ការបំពេញតម្រូវការ និងការទទួលបានរបស់ភាគីពាក់ព័ន្ធច្រើនក្រុម។<br>– ការរៀបចំផែនទី និងការរៀបចំផែនការនៃទីតាំងបណ្តុះបណ្តាល និងសកម្មភាពបណ្តុះបណ្តាល ដើម្បីធានាឱ្យមានការគ្របដណ្តប់ល្អលើទីតាំងរបស់កសិករងាយរងគ្រោះ និងធានាថា ពួកគេទទួលបានការបណ្តុះបណ្តាលផង និងការគាំទ្រនាពេលអនាគតលើការផ្តល់វិញ្ញាបនបត្រ។ |

| | |
|---|---|
| | – ការដាក់បញ្ចូលគោលដៅផ្អែកលើយេនឌ័រក្នុងការចូលរួមវគ្គបណ្តុះបណ្តាល ក៏ដូចជាការចូលរួមជាគោលដៅជាមួយក្រុមអ្នកផលិត នឹងគាំទ្រដល់ការចូលរួមយ៉ាងទូលំទូលាយ ក៏ដូចជាការសម្របសម្រួលការផ្ទេរព័ត៌មាន និងជំនាញទៅឱ្យក្រុម/បុគ្គលងាយរងគ្រោះជាងនៅក្នុងសហគមន៍។ |
| • ផលប៉ះពាល់លើទីតាំងដាក់លាក់ដោយសារតែការអនុវត្តបច្ចេកវិទ្យាធន់នឹងអាកាសធាតុ រួមទាំងប្រព័ន្ធធារាសាស្ត្រខ្នាតតូច។ | • បញ្ជីដាក់លាក់នៃបច្ចេកវិទ្យាដែលបានស្នើឡើងនឹងត្រូវបង្កើតឡើងសម្រាប់បទអន្តរាគមន៍លើទីតាំងដាក់លាក់ ដោយផ្អែកលើការវាយតម្លៃក្នុងអំឡុងពេលនៃការអនុវត្តគម្រោងដំបូង។ ហើយតាមរយៈការវាយតម្លៃនេះ វិធីសាស្ត្រកាត់បន្ថយហានិភ័យមួយចំនួនអាចត្រូវបានបង្កើតឡើង ដោយក្នុងនោះរួមមាន៖<br>– ការបង្កើតវិធីសាស្ត្រត្រួតពិនិត្យវាយតម្លៃបរិស្ថាន និងសង្គមដោយផ្អែកលើទិន្នន័យមូលដ្ឋានសម្រាប់អន្តរាគមន៍ដែលបានស្នើឡើង ដើម្បីវាយតម្លៃហានិភ័យ។<br>– ការបង្កើតលក្ខណៈវិនិច្ឆ័យណែនាំ ដើម្បីវាយតម្លៃលទ្ធភាពសមស្របនៃទីតាំងនេះសម្រាប់ទទួលបានអន្តរាគមន៍ទាំងនេះ ក្នុងនោះរួមទាំងការកំណត់តំបន់ "មិនត្រូវអនុវត្ត"។<br>– ការរៀបចំបង្កើតគោលការណែនាំដោយប្រើទិន្នន័យជាមូលដ្ឋានសម្រាប់អនុវត្តបច្ចេកវិទ្យាដែលនឹងមានសមាសធាតុកាត់បន្ថយសំខាន់ៗ (ឧ. ការអនុវត្តការងារនៅទីវាល/មូលដ្ឋានដែលត្រូវធ្វើឡើងនៅរដូវប្រាំង ដើម្បីបញ្ចៀសកម្រិតខ្ពស់នៃការហូរដីល្បាប់)។<br>– ការកំណត់អត្តសញ្ញាណលិខិតបទដ្ឋានគតិយុត្តក្នុងប្រទេសសំខាន់ៗ ក៏ដូចជាការអនុវត្តល្អជាអន្តរជាតិ និងការបណ្តុះបណ្តាលដល់ក្រុមនានាអំពីកត្តាទាំងនេះ ដើម្បីជួយសម្រួលដល់ការអនុវត្តល្អបំផុតសម្រាប់ការអនុវត្តជាក់ស្តែង។ |
| • ផលប៉ះពាល់នៅតាមទីតាំងដាក់លាក់ ដោយសារតែការដាំប្រភេទឈើមិនបានសមស្រប ខុសលក្ខខណ្ឌទីតាំង។ | • ការណែនាំអំពីបន្ស៊ីគ្នារវាងប្រភេទឈើ និងទីតាំង នឹងត្រូវបានបង្កើតឡើងសម្រាប់ទីតាំងសហគមន៍តំបន់ការពារធម្មជាតិជាក់លាក់ ដែលនឹងផ្តល់ព័ត៌មានអំពីប្រភេទដើមឈើសំខាន់ៗដែលអាចសម្របខ្លួនទៅតាមទីតាំង និងលក្ខខណ្ឌទីតាំងដ៏ល្អសម្រាប់ប្រភេទឈើទាំងនោះ។ ការងារនេះនឹងកំណត់បន្ថែមពីទីតាំងណាដែលមិនត្រូវដាំប្រភេទដើមឈើមួយចំនួន ដោយផ្អែកលើលក្ខខណ្ឌទីតាំង។ បន្ថែមពីលើប្រភេទឈើមានដើមកំណត់ក្នុងទីតាំង គម្រោងនេះនឹងលើកកម្ពស់តែប្រភេទឈើមានដើមកំណើតនៅទីតាំង និងមានសមត្ថភាពក្នុងការបន្សុំខ្លួនទៅនឹងទីតាំងនោះប៉ុណ្ណោះ ព្រមទាំងមិនបង្កហានិភ័យដល់ជីវៈចម្រុះនៅក្នុងមូលដ្ឋាននោះ[9]។ |

[9] Based on available literature and national and international experience.

| | |
|---|---|
| • ប្រភេទដើមឈើនាំចូលពីបរទេសអាចនាំឱ្យបាត់បង់ជីវៈចម្រុះ ហើយប្រភេទឈើមិនមែនពូជក្នុងស្រុកអាចជាប្រភេទរាតត្បាត។ | • សកម្មភាពទាំងអស់នឹងអនុលោមតាមក្របខ័ណ្ឌច្បាប់របស់ប្រទេសកម្ពុជា ដូចបានរៀបរាប់នៅក្នុងផ្នែកទី ៤ (ឧ. គោលនយោបាយស្ដីពីព្រៃឈើ ច្បាប់ស្ដីពីការការពារបរិស្ថាន និងបទប្បញ្ញត្តិការពារបរិស្ថានផ្សេងៗទៀត ក្នុងចំណោមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ)។<br>• ជំនួយបច្ចេកទេសនឹងត្រូវផ្ដល់ជូនក្នុងការរៀបចំផែនការ ហើយនៅពេលទទួលបានការអនុម័ត ជំនួយបន្ថែមនឹងត្រូវបានផ្ដល់ជូនដើម្បីគាំទ្រដល់អង្គការសហគមន៍ក្នុងការអនុវត្តផែនការទាំងនេះ។ ធនធានមនុស្សនៅមូលដ្ឋាននឹងទទួលបានការបណ្ដុះបណ្ដាលស្ដីពីការអនុវត្តល្អ ហើយនឹងរក្សាទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន។<br>• គម្រោងនេះនឹងមិនអនុញ្ញាតឱ្យមានការកាប់ឆ្ការព្រៃ និងកំណត់តំបន់ដីសើម ឬប្រព័ន្ធអេកូឡូស៊ីសំខាន់ៗផ្សេងទៀតសម្រាប់សកម្មភាពស្ដារឡើងវិញឡើយ។ ការធ្វើទស្សនកិច្ចសិក្សានៅតាមទីតាំងនឹងធ្វើឡើងដោយអាជ្ញាធរមូលដ្ឋានក្នុងអំឡុងពេលនៃដំណើរការរៀបចំផែនការគ្រប់គ្រង ដើម្បីធានាថា តំបន់នោះមានលក្ខណៈសមស្រប និងដើម្បីប្រមូលព័ត៌មានសម្រាប់គាំទ្រសកម្មភាពត្រួតពិនិត្យ (កូអរដោនេ GPS ទិន្នន័យគោល/មូលដ្ឋាន ។ល។)។ សកម្មភាពដាំដើមឈើនឹងត្រូវបានអនុញ្ញាតដោយផ្អែកលើផែនការដែលបានអនុម័ត (ផែនការសហគមន៍តំបន់ការពារធម្មជាតិដែលទទួលបានការអនុម័តពីក្រសួងបរិស្ថាន និងអាជ្ញាធរពាក់ព័ន្ធផ្សេងទៀត)។ |
| • ហានិភ័យ (របួស) សុខភាពការងារ (របួស) ដោយសារការអនុវត្តកសិកម្មមិនសមរម្យ និង/ឬការអនុវត្តការគ្រប់គ្រងព្រៃឈើដោយគ្មានឧបករណ៍សុវត្ថិភាពសមស្រប។ | • ឯកសារ/សម្ភារបណ្ដុះបណ្ដាល និងសកម្មភាពគាំទ្រទាំងអស់មានបញ្ចូលព័ត៌មានស្ដីពី OH&S ក៏ដូចជាព័ត៌មានអំពីរបៀបទទួលបានព័ត៌មានបន្ថែមនៅក្នុងវិស័យទាំងនេះ។<br>• គ្រូបង្គោល/បុគ្គលិកផ្សព្វផ្សាយដែលគាំទ្រការអនុវត្តសកម្មភាពនឹងទទួលបានការបណ្ដុះបណ្ដាលលើការអនុវត្តល្អ ពិធីការ និងឧបករណ៍ស្ដីពី OHS ដែលនឹងបណ្ដុះបណ្ដាលបន្តដល់អ្នកទទួលផលគម្រោងដែលពាក់ព័ន្ធនឹងការស្ដារព្រៃឈើ ប្រព័ន្ធកសិរុក្ខកម្ម និងសកម្មភាពកសិកម្មប្រកបដោយនិរន្តរភាព។ |
| • ការរើសអើងប្រឆាំងនឹងស្ត្រីដែលបង្កការលំបាកក្នុងការអនុវត្តសកម្មភាពគម្រោង ឬមានការលំបាកក្នុងការទទួលបាន ការ | • យ៉ាងហោចណាស់ អ្នកទទួលផលគម្រោងចំនួន ៥០% នឹងជាស្ត្រី ក្នុងនោះរួមទាំងតំណាងសមស្របពីក្រុមជនជាតិដើមភាគតិច និងសហគមន៍ដែលទទួលបានការយកចិត្តទុកដាក់តិចតួចពីសង្គម ប្រសិនបើពួកគេមានវត្តមាននៅក្នុងទីតាំងអនុវត្តសកម្មភាពគម្រោង។<br>• ផែនការសកម្មភាពយេនឌ័រ មានវិធានការលើកកម្ពស់សិទ្ធិអំណាចរបស់ស្ត្រី និងសមភាពយេនឌ័រ ក៏ដូចជាកាត់បន្ថយហានិភ័យនៃ ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)និង អំពើហិង្សាទាក់ទងនឹងយេនឌ័រ(GBV) តាមរយៈការយល់ដឹង និងការបណ្ដុះ |

| | |
|---|---|
| កេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)ឬ អំពើហិង្សាទាក់ទងនឹងយេនឌ័រ(GBV)ដោយសារតែកិច្ចខិតខំប្រឹងប្រែងក្នុងការផ្លាស់ប្តូរតួនាទី ឬបង្កើនការផ្តល់សិទ្ធិអំណាចដល់ស្ត្រី។ | បណ្តាលជុំវិញតួនាទីយេនឌ័រដែលបានលើកកម្ពស់ ក៏ដូចជាការកែលម្អប្រព័ន្ធ GRM ដើម្បីលើកកម្ពស់លទ្ធភាពទទួលបានបណ្តឹងតវ៉ាពាក់ព័ន្ធនឹង SEAH និង អំពើហិង្សាទាក់ទងនឹងយេនឌ័រ(GBV) ក្នុងក្របខ័ណ្ឌនៃគម្រោង PEARL។ |
| • ហានិភ័យនៃ ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)មានការកើនឡើង ដោយសារកំណើននៃការចល័តរបស់ស្ត្រី និងអ្នកទទួលប្រយោជន៍ផលផ្សេងទៀត ក៏ដូចជាការបង្កើតកិច្ចព្រមព្រៀងកសិកម្មកិច្ចសន្យាដែលអាចនាំឱ្យ អតុល្យភាពអំណាច និងភាពងាយរងគ្រោះរបស់ | • ការធានាឱ្យមានការត្រួតពិនិត្យវាយតម្លៃពេញលេញលើសកម្មភាពដែលបានស្នើឡើង និងការផ្លាស់ប្តូរកម្រិតចល័តក្នុងការបំពេញការងារដើម្បីធានាថាមានវិធានការក្នុងការកាត់បន្ថយភាពងាយរងគ្រោះ (ការធ្វើដំណើរជាក្រុម ។ល។) ក៏ដូចជាការបណ្តុះបណ្តាលអ្នកចូលរួមដែលមានទំនាក់ទំនងនឹងហានិភ័យនៃ ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)។<br>• ការគាំទ្រពេញទំហឹងដល់ការរៀបចំបង្កើតកិច្ចព្រមព្រៀងកសិកម្មកិច្ចសន្យា ដើម្បីធានាឱ្យមានដំណើរការរៀបចំដែលមានភាពច្បាស់លាស់ និងតម្លាភាព។ |

| | |
|---|---|
| កសិករ ប្រសិនគ្មានការការពារ។ | |
| • ការរើសអើង ឬការចូលរួមមានកម្រិតរបស់ជនជាតិដើមភាគតិច។ | • ជនជាតិដើមភាគតិច និងក្របខណ្ឌរៀបចំការធ្វើផែនការដាក់បញ្ចូលក្នុងសង្គម រួមមានវិធានការដាក់បញ្ចូល និងការចូលរួមរបស់ជនជាតិដើមភាគតិចក្នុងក្របខ័ណ្ឌនៃគម្រោង PEARL។<br>• ផែនការជនជាតិដើមភាគតិចជាក់លាក់ នឹងជាផ្នែកមួយនៃការត្រួតពិនិត្យហានិភ័យបរិស្ថាន និងសង្គមលើទីតាំងជាក់លាក់ដែលនឹងត្រូវបានអនុវត្ត (ដូចដែលបានកត់សម្គាល់ខាងលើ) នៅពេលដែលព័ត៌មានលម្អិតនៃទីតាំងគោលដៅ និងក្រុមពាក់ព័ន្ធត្រូវបានបញ្ជាក់ច្បាស់លាស់។<br>• វិធានការជាគោលដៅសម្រាប់ការបញ្ចូលទៅក្នុងសង្គមគឺជាវិធានការចម្រុះវិស័យ និងត្រូវបញ្ចូលទៅក្នុងសកម្មភាពគម្រោង (ឧ. ការបណ្ដុះបណ្ដាលដល់អង្គការសង្គមស៊ីវិលដែលជាតំណាងឱ្យក្រុមទទួលបានការយកចិត្តទុកដាក់តិចតួចពីសង្គម ចំណុចដៅសម្រាប់គ្រូបណ្ដុះបណ្ដាលមកពីក្រុមទទួលបានការយកចិត្តទុកដាក់តិចតួចពីសង្គម ការបណ្ដុះបណ្ដាលអំពីចំណេះដឹងអាជីវកម្មសម្រាប់សមាជិកនៃក្រុមទទួលបានការយកចិត្តទុកដាក់តិចតួចពីសង្គម ឬក្រុមងាយរងគ្រោះខ្លាំង)។<br>• សកម្មភាពផ្តោតលើចំណេះដឹង និងការទំនាក់ទំនង (លទ្ធផលទី៣) នឹងមានព័ត៌មានពីបទពិសោធនៅថ្នាក់ជាតិ ការអនុវត្តល្អបំផុតពីកម្រិតអន្តរជាតិ ព្រមទាំងចំណេះដឹងរបស់ជនជាតិដើមភាគតិច (ក្នុងនោះសកម្មភាព ៣.១.១ និង ៣.២.២ ដោយផ្តោតលើការលើកកម្ពស់ការយល់ដឹងអំពីចំណេះដឹងរបស់ជនជាតិដើមភាគតិចលើការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ)។ ការធ្វើសមាហរណកម្មចំណេះដឹងពីតួអង្គចម្រុះទៅក្នុងវេទិកាផ្សព្វផ្សាយ និងចែករំលែកចំណេះដឹង នឹងលើកកម្ពស់ការដាក់បញ្ចូលទៅក្នុងសង្គម ព្រមទាំងអនុញ្ញាតឱ្យក្រុមចម្រុះបង្កើនបទពិសោធ និងចំណេះដឹងនៅមូលដ្ឋាន។<br>• ការបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់អនុវត្តសកម្មភាពគម្រោង គួរមានការចូលរួមពីបុរស និងស្ត្រីមកពីក្រុមជនជាតិដើមភាគតិច។<br>• បង្កើតទីបង្ហាញផ្លូវកសិកម្មនឹងមានបញ្ចូលការពិចារណាអំពីរបៀបនៃការដាក់បញ្ចូលក្រុមជនជាតិដើមភាគតិច ក៏ដូចជាការដាក់បញ្ចូលរបស់ក្រុមងាយរងគ្រោះផ្សេងទៀត។ |
| • ការវិនិយោគដែលអាចកើតមានពីវិស័យឯកជននឹងមិនកើតឡើងទាន់ពេលវេលា ក្នុងការគាំទ្រដល់ការអនុវត្តគម្រោង។ | • កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលជាមួយវិស័យឯកជននឹងចាប់ផ្តើមពីការចាប់ផ្តើមគម្រោង ហើយគម្រោងនឹងអនុវត្តកម្មវិធីលើកកម្ពស់ការយល់ដឹងដើម្បីជួយដល់ការចូលរួមពីតួអង្គក្នុងវិស័យឯកជន។<br>• ជំនួយបន្ថែមនឹងត្រូវបានផ្តល់ជូនដើម្បីជួយផលិតកររៀបចំ និងកសាងសមត្ថភាពរបស់ខ្លួន ដើម្បីសម្របសម្រួល និងចរចាជាមួយវិស័យឯកជន។ សិក្ខាសាលាបណ្តុះបណ្តាលស្តីពីធុរកិច្ច នឹងត្រូវរៀបចំឡើង សម្រាប់សមាជិកអង្គការគ្រប់គ្រងដោយសហគមន៍ ដែលនឹងជួយកសាង |

| | |
|---|---|
| | សមត្ថភាពរបស់ពួកគេដើម្បីទាក់ទង និងសម្របសម្រួលជាមួយវិស័យឯកជន ហើយកិច្ចខិតខំប្រឹងប្រែងនឹងគាំទ្រតួអង្គទាំងនេះដើម្បីរៀបចំផែនការអាជីវកម្មប្រកបដោយវិជ្ជាជីវៈសម្រាប់ការវិនិយោគដែលធន់នឹងអាកាសធាតុ។ |
| • សកម្មភាពគម្រោងអាចមានផលប៉ះពាល់អវិជ្ជមានលើតំបន់ការពារធម្មជាតិ ក្នុងតំបន់គោលដៅរបស់គម្រោង។ | • ក្របខ័ណ្ឌរៀបចំផែនការគ្រប់គ្រងជីវៈចម្រុះត្រូវបានរៀបរាប់លម្អិតនៅក្នុងផ្នែកទី ៨ ដើម្បីបញ្ចៀស កាត់បន្ថយ និងគ្រប់គ្រងហានិភ័យ។ សកម្មភាពគម្រោងត្រូវបានរំពឹងថានឹងមានឥទ្ធិពលវិជ្ជមានលើតំបន់ការពារធម្មជាតិ។<br>• ការវាយតម្លៃបរិស្ថាន និងសង្គមពេញលេញនឹងត្រូវបានធ្វើឡើង ស្តីពីការអនុវត្តគម្រោង ហើយផែនការគ្រប់គ្រងជាក់លាក់នឹងត្រូវបានបង្កើតឡើងសម្រាប់តំបន់គោលដៅ ក្នុងនោះរួមទាំងផលប៉ះពាល់លើជនជាតិដើមភាគតិច ដែលរស់នៅក្នុង និងជុំវិញតំបន់ដែលជាផ្នែកនៃផែនការជនជាតិដើមភាគតិច (IPP)ដោយធ្វើការបញ្ចូលការពិចារណាលើសម្ពាធលើដី និងការចេញចូលទៅកាន់ដីរបស់ពួកគេ។ |
| • ជម្លោះដែលអាចកើតមាននៅក្នុងក្រុមអ្នកប្រើប្រាស់សហគមន៍មូលដ្ឋានលើព្រំនៃការប្រើប្រាស់ដី | • ក្នុងពេលតំបន់គោលដៅស្ទើរតែទាំងអស់មានការបញ្ជាក់ពីបណ្ណកម្មសិទ្ធិដីធ្លីនោះ តំបន់កសិកម្មមួយចំនួនតូច ជាពិសេសតំបន់ផលិតស្វាយចន្ទីអាចមានការបញ្ជាក់ចំពោះដីដែលគ្មានបណ្ណកម្មសិទ្ធិ។ ការគាំទ្រដល់ការបញ្ជាក់ពីសិទ្ធិកាន់កាប់ដី និងសិទ្ធិចេញចូលតំបន់ទាំងនេះអាចបង្កទំនាស់។ បញ្ហាទាំងនេះអាចដោះស្រាយបានតាមរយៈ៖<br>- ការបញ្ចូលច្បាស់លាស់ជាមួយក្រុមដែលមានបញ្ហានៃបណ្ណកម្មសិទ្ធិស្របច្បាប់។<br>- គាំទ្រដល់ការបញ្ចូលនៃការបញ្ជាក់បណ្ណកម្មសិទ្ធិ តាមរយៈអាជ្ញាធរពាក់ព័ន្ធ។<br>- គាំទ្រដល់ដំណើរការចូលរួម ដើម្បីកែលម្អការបញ្ជាក់បណ្ណកម្មសិទ្ធិ។<br>• សកម្មភាពគាំទ្រកសិករឱ្យទទួលបានផលចំណេញច្រើនជាងមុនលើផ្ទៃដីរបស់ពួកគេ អាចបង្កឱ្យមានសម្ពាធបន្ថែមលើដី ហើយជាលទ្ធផលបង្កជម្លោះ។ ចំណុចនេះអាចដោះស្រាយបានតាមរយៈ<br>- ដំណើរការច្បាស់លាស់ក្នុងការបញ្ចូលសមាគមកសិករ និងផលិតការកសិកម្មផ្សេងៗទៀត ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ និងការប្តេជ្ញាចិត្តក្នុងការថែរក្សាតំបន់ផលិតកម្ម និងមិនព្យាយាមពង្រីកទៅតំបន់ផ្សេងៗទៀតដែលមិនមែនកំពុងផលិត ឬពាក់ព័ន្ធនឹងការផលិតកម្ម (ក្នុងនោះរួមទាំងសម្រាប់ហេតុផលបរិស្ថាន និងសង្គម)។<br>- គាំទ្រដល់ការដាក់បញ្ចូលអ្នកទិញ និងគោលការណ៍ផ្តល់វិញ្ញាបនបត្រ ដែលផ្តោតការយកចិត្តទុកដាក់លើប្រព័ន្ធផលិតកម្មប្រកបដោយនិរន្តរភាព និងមិនលើកទឹកចិត្តដល់សកម្មភាពពង្រីកផ្ទៃដី។ |
| • ជម្លោះដែលអាចកើតមានលើការជ្រើសរើសតំបន់ | • ការធ្វើការសម្រេចចិត្តត្រូវមានតម្លាភាព ហើយការសិក្សា និងព័ត៌មានដើម្បីគាំទ្រ (របាយការណ៍ កំណត់ហេតុនៃកិច្ចប្រជុំពិគ្រោះយោបល់ និងសិក្ខាសាលា) ត្រូវបានផ្សព្វផ្សាយជាសាធារណៈ។ |

| | |
|---|---|
| អាទិភាពដែលទទួលបានអន្តរាគមន៍។ | • ការគាំទ្រដែលបានកំណត់ តាមរយៈសមាគមកសិករដែលមានការទទួលស្គាល់ និងស្ថិតក្នុងសហគមន៍តំបន់ការពារធម្មជាតិ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យច្បាស់លាស់ ហើយដោយមានទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធរបស់គម្រោងជាច្រើនទៀត នឹងគាំទ្រការយល់ដឹង និងកិច្ចព្រមព្រៀងក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់។<br>• ក្នុងករណីដែលគ្រួសារ/ជនណាម្នាក់មានអារម្មណ៍ថា ខ្លួនទទួលរងគ្រោះពីការរើសអើង ឬមានបញ្ហាជាមួយគម្រោង ពួកគេក៏អាចប្រើប្រាស់យន្តការបណ្តឹងតវ៉ារបស់គម្រោងផងដែរ។ |

*តារាងទី ៨. ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន និងវិធានការកាត់បន្ថយដែលបានស្នើឡើងសម្រាប់លទ្ធផលទី ៣*

| **ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន** | **វិធានការកាត់បន្ថយមួយ ឬច្រើន** |
|---|---|
| • គោលនយោបាយលើកកម្ពស់ និងបរិយាកាសគាំទ្រ និងប្រព័ន្ធព័ត៌មានផ្តល់អត្ថប្រយោជន៍មិនសមស្របដល់កសិករមួយចំនួន ដែលប្រការនេះធ្វើឱ្យមានការកើនឡើងនូវវិសមភាពក្នុងចំណោមក្រុម និង/ឬយេនឌ័រផ្សេងៗគ្នា។ | • សមាសធាតុទាំងអស់សម្រាប់ការលទ្ធផលនេះ ផ្តោតការយកចិត្តទុកដាក់លើការរៀបចំបង្កើតសម្ភារ និងប្រព័ន្ធបរិយាប័ន្ន និងឆ្លើយតបយេនឌ័រដែលសមស្របផងដែរដល់ការដាក់បញ្ចូលការក្រុមជនជាតិដើមភាគតិច និងមានបញ្ចូលបុគ្គលទាំងឡាយណាដែលអាចជួយកាត់បន្ថយហានិភ័យនៃ ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)ដោយធ្វើការបញ្ជ្រាបគំនិតទាំងនេះទៅក្នុងការរៀបចំគម្រោង តាមរយៈការផ្តល់វិធានការកាត់បន្ថយសំខាន់ៗ ដែលនឹងត្រូវត្រួតពិនិត្យដោយ អង្គភាពគ្រប់គ្រងគម្រោង (PMU)។ សកម្មភាពជាក់លាក់ដើម្បីជួយសម្រួលនេះរួមមានដូចខាងក្រោម៖<br>- ធានាឱ្យមានការចូលរួមដោយសមធម៌នៃក្រុមនៅក្នុងស្ថាប័នធ្វើសេចក្តីសម្រេចសំខាន់ៗ គណៈកម្មាធិការ និងវេទិកាពហុភាគី ដើម្បីបង្កើនការពិចារណាលើតម្រូវការនានា។<br>- សកម្មភាពដើម្បីធានាឱ្យមានគោលការណ៍ណែនាំសម្រាប់អង្គភាពផ្តល់វិញ្ញាបនបត្រ ដោយមិនត្រូវធ្វើជាអង្គភាពបង្កឧបសគ្គក្នុងការដាក់បញ្ចូលក្រុមងាយរងគ្រោះ និង/ឬក្រុមកសិករដែលទទួលបានការយកចិត្តទុកដាក់តិចតួចក្នុងសង្គម។<br>- តុល្យភាពយេនឌ័រនៅក្នុងតំបន់គោលដៅសម្រាប់អ្នកដែលទទួលបានការបណ្តុះបណ្តាលលើការប្រើប្រាស់ប្រព័ន្ធថ្មី។<br>- SOPs ត្រូវបានបង្កើតឡើងដែលមានបញ្ចូលយេនឌ័រយ៉ាងពេញលេញ ក៏ដូចជាការពិចារណាលើក្រុមងាយរងគ្រោះ និងអ្នកដែលងាយរងគ្រោះជាង និង/ឬអ្នកដែលទទួលបានការយកចិត្តទុកដាក់តិចតួចក្នុងសង្គមក្នុងប្រព័ន្ធផលិតកម្ម។ |

១៨៣. លើសពីនេះ ហានិភ័យជាសក្តានុពលមួយចំនួនដែលពាក់ព័ន្ធនឹង ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)ក៏ត្រូវបានកំណត់អត្តសញ្ញាណ ដែលជាប់ពាក់ព័ន្ធនឹងលក្ខណៈទូទៅនៃការអនុវត្តគម្រោង ដែលនឹងបង្កើតបានសមាសធាតុនៃអតុល្យភាពអំណាចក្នុងចំណោមបុគ្គលពាក់ព័ន្ធនឹងគម្រោង ក៏ដូចជារវាងបុគ្គលិកគម្រោង និងអ្នកទទួលផលគោលដៅ។ បញ្ហាសំខាន់ៗត្រូវបានរំលេចនៅក្នុងតារាងខាងក្រោម។ ចំណុចទាំងនេះ (និងចំណុចផ្សេងៗទៀតដែលបានកំណត់នៅក្នុងតារាងខាងលើ) នឹងត្រូវបានធ្វើបច្ចុប្បន្នភាពបន្ថែមទៀតតាមរយៈគោលការណ៍ណែនាំដែលទទួលបានការអនុម័តនាពេលថ្មីៗ របស់អង្គការ FAO សម្រាប់ការគ្រប់គ្រងបរិស្ថាន និងសង្គម (FESM) ដែលមានសេចក្តីយោងច្បាស់លាស់ចំពោះ ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)ហើយនឹងមានការចូលរួមពីការណែនាំប្រតិបត្តិការពាក់ព័ន្ធក្នុងប៉ុន្មានខែខាងមុខ ក៏ដូចជានឹងឧបករណ៍ពិនិត្យហានិភ័យ ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)របស់ GCF ដែលត្រូវបានគេរំពឹងថានឹងដាក់ឱ្យដំណើរការ នៅមុនពេលចាប់ផ្តើមគម្រោង។

| វិធានការកាត់បន្ថយក្នុងការទប់ស្កាត់ការកេងប្រវ័ញ្ច ការរំលោភបំពាន និងការបៀតបៀនផ្លូវភេទ | |
|---|---|
| **ហានិភ័យទូទៅ** | **វិធានការកាត់បន្ថយ** |
| - កម្មវិធីនេះមិនមានវិធីសាស្ត្ររួមក្នុងការកំណត់អត្តសញ្ញាណ ការទប់ស្កាត់ និងការឆ្លើយតបចំពោះ ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ (SEAH)ទេ។<br>- មានការខ្វះខាតភាពច្បាស់លាស់អំពីរបៀបកំណត់អត្តសញ្ញាណ និងដោះស្រាយហានិភ័យរបស់កម្មវិធីរបស់ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)ក្នុងនោះរួមទាំងការជ្រើសរើសបុគ្គលិក ការផ្តល់ព័ត៌មាន ការគ្រប់គ្រងករណី និងការដោះស្រាយ។<br>- មានកង្វះសមត្ថភាពអំពីវិធីសាស្ត្រយេនឌ័រ និងការទប់ស្កាត់អំពើហិង្សាផ្អែកលើយេនឌ័រ។ | - ការការពារ ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(PSEAH)ត្រូវបានអនុម័ត ឬបង្កើតឡើងដោយផ្អែកលើគោលការណ៍ណែនាំប្រតិបត្តិថ្មីពី ក្របខ័ណ្ឌការគ្រប់គ្រងបរិស្ថាន និងសង្គម (FESM) របស់អង្គការ FAO និងគោលការណ៍ណែនាំប្រតិបត្តិស្តីពី ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)របស់ GCF ក្រោមវិធានការដែលនឹងជួយដល់ការធ្វើឱ្យសម្រេចនៃការប្តេជ្ញាចិត្តនោះ។<br>- ផែនការ ការពារការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(PSEAH)ឆ្លើយតបនឹងបទដ្ឋានពាក់ព័ន្ធ និងអនុលោមតាមច្បាប់ក្នុងស្រុក។ |
| - អង្គភាពគ្រប់គ្រងគម្រោង (PMU) ពុំមានភាពច្បាស់លាស់ពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនក្នុងការពារការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(PSEAH)។<br>- គណៈកម្មាធិការដឹកនាំកម្មវិធីមិនបែងចែកការទទួលខុសត្រូវ និងទទួលបានធនធានសម្រាប់ការពារសុវត្ថិភាពនៅក្នុង អង្គភាពគ្រប់គ្រងគម្រោង (PMU)។<br>- ផែនការអនុវត្តសម្រាប់ការពារ ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)មិនបានទទួលមូលនិធិសមរម្យ។ | - ការការពារសុវត្ថិភាព គឺជាចំណុចរបៀបវារៈទូទៅមួយនៅគណៈកម្មាធិការដឹកនាំកម្មវិធី។<br>- អ្នកឯកទេសយេនឌ័រគឺជាជនបង្គោលនៃការការពារសុវត្ថិភាព ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)។<br>- អង្គភាពគ្រប់គ្រងគម្រោង (PMU)មានជំនាញក្នុងការគ្រប់គ្រងភាពតានតឹងដែលកើតឡើងពីការអនុវត្តបទដ្ឋានការពារសុវត្ថិភាពនៅក្នុងបរិបទក្នុងស្រុក។<br>- ដំណើរការពិនិត្យ និងតាមដានកម្មវិធីដែលមានស្រាប់រួមមានវឌ្ឍនភាពពីការអនុវត្តវិធានការការពារសុវត្ថិភាព។ |

| | |
|---|---|
| - វិធានការការពារ ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)មិនត្រូវបានដាក់បញ្ចូលក្នុងការត្រួតពិនិត្យកម្មវិធី ឬដំណើរការត្រួតពិនិត្យ។ | |
| - អ្នកប្រឹក្សាជាច្រើននាក់នៃកម្មវិធីមិនទទួលស្គាល់ថា ផែនការការពារការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(PSEAH)គឺជាការទទួលខុសត្រូវរបស់ពួកគេទេ។<br>- បុគ្គលិកផ្នែក អង្គភាពប្រតិបត្តិ នៃកម្មវិធីមិនយល់ថា ការប្រព្រឹត្តរបស់ខ្លួនត្រូវតែឆ្លើយតបទៅនឹងការរំពឹងទុកទាំងក្នុងការងារអាជីព និងជីវិតផ្ទាល់ខ្លួនរបស់ពួកគេ។<br>- មានការខ្វះខាតចំណេះដឹងអំពីពិធីសារ និងបទប្បញ្ញត្តិសម្រាប់ការយោងទាក់ទងនឹងអំពើហិង្សាផ្អែកលើយេនឌ័រ។ | - ក្រមប្រតិបត្តិសម្រាប់បុគ្គលិកទាំងអស់នៃកម្មវិធីកំណត់អាកប្បកិរិយាសមរម្យ និងផលវិបាកពីការរំលោភបំពាន។<br>- ក្រមប្រតិបត្តិត្រូវបានបកប្រែជាភាសាក្នុងស្រុកសមស្រប។<br>- សៀវភៅណែនាំអំពីការយោងស្តីពីការបំពារបំពានយេនឌ័រត្រូវបានអនុវត្តសម្រាប់កម្មវិធី។ |
| - ដំណើរការជ្រើសរើសបុគ្គលិកសម្រាប់កម្មវិធីមានភាពទន់ខ្សោយ និងអនុញ្ញាតឱ្យបេក្ខជនដែលមានកំណត់ត្រាពីមុននៃការរំលោភបំពាន ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)ចូលរួមក្នុងកម្មវិធី ឬមិនពិចារណាលើការប្រព្រឹត្តិស្មើភាពគ្នា និងការការពារគ្រប់មធ្យោបាយនៃការបំភិតបំភ័យលើស្ត្រី និងបុរស។ | - គោលនយោបាយអង្គភាពប្រតិបត្តិ សម្រាប់ការជ្រើសរើសបុគ្គលិក រួមមានវគ្គសិក្សាស្តីពី ការការពារការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(PSEAH)និងក្រមសីលធម៌វិជ្ជាជីវៈ។ |
| - បុគ្គលិក ទីប្រឹក្សា អ្នកស្ម័គ្រចិត្ត និងជំនួយការមិនដឹងពីការទទួលខុសត្រូវក្នុងការការពារសុវត្ថិភាព។ | - ការបណ្តុះបណ្តាលស្តីពីការអនុវត្តការពារសុវត្ថិភាពត្រូវបានធ្វើឡើងសម្រាប់បុគ្គលិក អ្នកប្រឹក្សា អ្នកស្ម័គ្រចិត្ត និងជំនួយការថ្មី។<br>- កិច្ចប្រជុំទៀងទាត់ត្រូវបានប្រើប្រាស់ដើម្បីបន្តលើកកម្ពស់ការយល់ដឹងអំពីការការពារសុវត្ថិភាពដែលជាផ្នែកនៃផែនការ ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)។<br>- វគ្គបណ្តុះបណ្តាលវិក្រិត្យការត្រូវរៀបចំធ្វើជារៀងរាល់ឆ្នាំ។ |
| - សកម្មភាព ការពារការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(PSEAH)ត្រូវបានរៀបចំឡើងយ៉ាងកំសោយ និង/ឬពុំមានមូលនិធិអនុវត្ត ដែលជាហេតុធ្វើឱ្យហានិភ័យនៃ ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)កាន់តែធ្ងន់ធ្ងរ។<br>- មិនមានបទដ្ឋានច្បាស់លាស់នៃដំណើរការប្រតិបត្តិការសម្រាប់សកម្មភាពប្រថុយប្រថានជាពិសេសដូចជាការផ្សព្វផ្សាយកម្មវិធីសាច់ប្រាក់ សកម្មភាពចែកចាយ ឬអន្តរកម្មជាមួយមនុស្សវ័យជំទង់។ | - ការវិភាគបរិបទទៀងទាត់ ដើម្បីយកព័ត៌មានសម្រាប់រៀបចំសកម្មភាព ការពារការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(PSEAH)។<br>- ដំណើរការគ្រប់គ្រងសកម្មភាពការការពារការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(PSEAH)ដ៏រឹងមាំដែលលើកទឹកចិត្តឱ្យមានការសម្របសម្រួលកម្មវិធីដើម្បីវាយតម្លៃ និងកាត់បន្ថយហានិភ័យនៃ ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)។ |

| | |
|---|---|
| - ការចុះឈ្មោះហានិភ័យកម្មវិធីមិនមាន ឬមិនរួមបញ្ចូលការការពារ។ | - ហានិភ័យ ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)និងសកម្មភាពកាត់បន្ថយមានដាក់បញ្ចូលក្នុងបញ្ជីសកម្មភាពហានិភ័យ។ |
| - បុគ្គលិក ទីប្រឹក្សា អ្នកស្ម័គ្រចិត្ត និងជំនួយការមិនរាយការណ៍ពីកង្វល់/ការបារម្មណ៍នានា។<br>- ការត្រួតពិនិត្យតាមកាលកំណត់មិនត្រូវបានអនុវត្ត យន្តការបណ្តឹងតវ៉ា មិនត្រូវបានប្រើប្រាស់ឱ្យបានគ្រប់គ្រាន់ របាយការណ៍ និងការតាមដានមិនត្រូវបានធ្វើឡើង។ | - យន្តការប្តឹង និងបណ្តឹងតវ៉ាជាផ្លូវការ ដូចក្នុងឧបសម្ព័ន្ធ ជ ត្រូវបានរចនាឡើងសម្រាប់កម្មវិធី។<br>- យន្តការច្បាស់លាស់ និងសម្ងាត់បានរៀបចំរួចរាល់សម្រាប់ការអនុវត្ត។<br>- ទំនាក់ទំនងទៀងទាត់សម្រាប់បុគ្គលិក ទីប្រឹក្សា អ្នកស្ម័គ្រចិត្ត និងជំនួយការសម្រាប់ការរាយយការណ៍ មានការអនុវត្ត។ |
| - អ្នកទទួលផលពីកម្មវិធីមិនរាយការណ៍ពីកង្វល់។ | - យន្តការបណ្តឹងតវ៉ា (GRM) ត្រូវបានពង្រឹង ស្របតាមគោលការណ៍ណែនាំប្រតិបត្តិក្របខ័ណ្ឌការគ្រប់គ្រងបរិស្ថាន និងសង្គម (FESM) ថ្មីរបស់អង្គការ FAO និងគោលការណ៍ណែនាំប្រតិបត្តិស្តីពី ការពារការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ (PSEAH)របស់ GCF ដើម្បីដោះស្រាយ ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ (SEAH)យ៉ាងពេញលេញចំពោះបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលលើបញ្ហានេះ ព្រមទាំងជម្រើសសម្រាប់បណ្តឹងតវ៉ាដោយផ្ទាល់ទៅកាន់ការិយាល័យអធិការកិច្ច (OIG)។<br>- ទំនាក់ទំនងទៀងទាត់សម្រាប់បុគ្គលិក ទីប្រឹក្សា អ្នកស្ម័គ្រចិត្ត និងជំនួយការសម្រាប់ការរាយយការណ៍ មានការអនុវត្ត។ |
| - ការដោះស្រាយករណីមិនល្អ | - យន្តការប្តឹង និងបណ្តឹងតវ៉ាជាផ្លូវការ - ត្រូវបានរៀបចំឡើងក្នុងកម្មវិធី។ |

## ៧. ការប្រឹក្សាយោបល់ និងការចូលរួមរបស់ភាគីពាក់ព័ន្ធ

### ៧.១ ការកំណត់អត្តសញ្ញាណភាគីពាក់ព័ន្ធ

១៨៥. ការពិគ្រោះយោបល់ និងការដាក់បញ្ចូលភាគីពាក់ព័ន្ធ គឺជាស្នូលនៃគម្រោងនេះ។ កិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយដៃគូគម្រោង និងការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយភាគីពាក់ព័ន្ធក្នុងអំឡុងពេលការរៀបចំគម្រោង បានផ្តល់មតិកែលម្អដ៏មានតម្លៃ និងបានរៀបចំតម្រឹមគម្រោងទៅជាទម្រង់បច្ចុប្បន្ន។ ការបញ្ចូលភាគីពាក់ព័ន្ធជាបន្តក្នុងការអនុវត្តគម្រោងក៏ត្រូវបានគិតគូរជាមុនផងដែរ ដូចមានការបានពិពណ៌នានៅក្នុងចំណុច ៧.៣។

១៨៦. ភាគីពាក់ព័ន្ធត្រូវបានកំណត់ថាជាតួអង្គនៅក្នុងក្រុមតួអង្គ ដូចជា រដ្ឋាភិបាល សហគមន៍មូលដ្ឋាន អង្គការគ្រប់គ្រងដោយសហគមន៍ អង្គការសង្គមស៊ីវិល/អង្គការក្រៅរដ្ឋាភិបាល វិស័យឯកជន អង្គការសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិ និងអង្គការអន្តរជាតិ។

១៨៧. ភាគីពាក់ព័ន្ធគម្រោងសំខាន់ៗត្រូវបានកំណត់ពីដំបូង តាមរយៈការពិភាក្សាជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ក្នុងដំណាក់កាលរៀបចំគោលគំនិតដំបូង បន្ទាប់ពីបានអនុវត្តដំណាក់កាលមួយចំនួនទៀតដែលទាក់ទងនឹងការរៀបចំធ្វើការសិក្សាសមិទ្ធលទ្ធភាព និងការបង្កើតសកម្មភាពបង្កើតគម្រោងដែលចំណុចទាំងនេះមានបញ្ជាក់ក្នុងចំណុច ៧.២ ខាងក្រោម។

### ៧.២ ទិដ្ឋភាពទូទៅនៃការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ និងការបញ្ចូលភាគីពាក់ព័ន្ធក្នុងការរៀបចំគម្រោង[10]

១៨៨. តាមរយៈដំណើរការនៃការរៀបចំគម្រោងនេះ ភាគីពាក់ព័ន្ធជាបុគ្គលប្រមាណ ១.១០២ នាក់ ដែលតំណាងឱ្យស្ថាប័នសាធារណៈ អង្គការ និងផ្នែកឯកជនជាង ៦០០ ត្រូវបានជួបពិគ្រោះយោបល់ (ក្នុងនោះមានស្ត្រី ១៤៣ នាក់ និងបុរស ៩៦៦ នាក់)។ ក្រសួរ ស្ថាប័ន និងស្ថាប័នដែលបានពិគ្រោះមានជាអាទិ៍៖

- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- មន្ទីរពាក់ព័ន្ធ
- ស្ថាប័ន/គ្រឹះស្ថានហិរញ្ញវត្ថុ
- អង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍
- អង្គការគ្រប់គ្រងដោយសហគមន៍ (ជាពិសេសសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ)
- សហគមន៍កសិកម្ម សមាគមកសិករ ក្រុមអ្នកផលិត និងសហជីព។
- ផ្នែកឯកជន (អ្នកផ្គត់ផ្គង់ផលិតផលកសិកម្ម អ្នកផ្គត់ផ្គង់ជាតុចូល អាជីវករលក់ដុំ រោងម៉ាស៊ីនកិនស្រូវ អាជីវករលក់រាយ អ្នកកែច្នៃ។ល។)។

[10] Note: Meeting and workshop agendas, minutes and attendance sheets are available in Annex 7 of the project submission package.

១៨៩. កថាខណ្ឌខាងក្រោមផ្តល់សេចក្តីសង្ខេបនៃការពិគ្រោះយោបល់ដែលបានធ្វើឡើង ទោះជាយ៉ាងក្តី សេចក្តីសង្ខេបនៃកិច្ចប្រជុំលម្អិតបន្ថែមទៀត រូបថត និងបញ្ជីវត្តមានមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី ៧ នៃកញ្ចប់ឯកសារស្នើសុំរបស់គម្រោង។

១៩០. ការសិក្សាពីសមិទ្ធលទ្ធភាពលើគោលការណ៍ផ្តល់វិញ្ញាបនប័ត្រកសិកម្មនៅតំបន់អាងទន្លេសាបខាងជើង (ឆ្នាំ ២០១៨)។

១៩១. ការសិក្សាដែលទទួលបានការគាំទ្រពីអង្គការ FAO និងធ្វើឡើងដោយវិទ្យាស្ថាន Recherche et d'Application des Méthodes de Développement (IRRAM) បានពិនិត្យលើសក្តានុពលនៃការអភិវឌ្ឍទីផ្សារដែលធន់នឹងអាកាសធាតុ និងតម្លៃខ្ពស់សម្រាប់ទំនិញជាគោលដៅរបស់គម្រោង៖ អង្ករសេរីរាង្គក្នុងខេត្តព្រះវិហារ និងឧត្តរមានជ័យ ស្វាយចន្ទីនៅខេត្តកំពង់ធំ និងព្រះវិហារ និងស្វាយក្នុងខេត្តឧត្តរមានជ័យ។ ជម្រើសវិញ្ញាបនបត្រមួយចំនួនត្រូវបានស្រាវជ្រាវ សម្រាប់ខ្សែច្រវ៉ាក់តម្លៃទាំងនេះ (GI កសិកម្មសរីរាង្គ GAP។ល។)។ ការសិក្សានេះមានការចូលរួមពីបុគ្គលចំនួន ១២៩ នាក់ (ស្រី ៣១ នាក់) តាមរយៈការសម្ភាសន៍ និងកម្រងសំណួរ ដែលក្នុងនោះពីអង្គការមិនមែនរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ចំនួន ២០ នាក់ ក្រសួង ស្ថាប័នរបស់រដ្ឋាភិបាលចំនួន ២២ នាក់ វិស័យឯកជនចំនួន ២៨ នាក់ សមាគម/សហជីពកសិករចំនួន ១០ នាក់មកពី និងសមាគម និងក្រុមផលិតករចំនួន ៤៩ នាក់។

## បេសកកម្មបង្កើតគម្រោង (២០១៩)

១៩២. ក្នុងអំឡុងពេលបេសកកម្មបង្កើតគម្រោងដំបូងពីថ្ងៃទី២១ ខែតុលា ដល់ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ ២០១៩ ក្រុមការងារបង្កើតគម្រោងបានជួបប្រជុំជាមួយភាគីពាក់ព័ន្ធផ្សេងៗ ក្នុងនោះរួមទាំងតំណាងក្រសួង និងមន្ទីរពាក់ព័ន្ធរបស់ក្រសួងទាំងនេះ ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល សមាគមកសិកម្ម សមាគម/សហជីពកសិករ។ អ្នកផ្គត់ផ្គង់ធាតុបញ្ចូល ពាណិជ្ជករ និងអ្នកនាំចេញ ស្ថាប័ន/គ្រឹះស្ថានហិរញ្ញវត្ថុ និងក្រុមហ៊ុនធានារ៉ាប់រង។ បុគ្គលសរុបប្រមាណ ៧២ នាក់ (ស្រី ២០ នាក់) ដែលតំណាងឱ្យអង្គភាពចំនួន ២៧ ក្នុងខេត្តកំពង់ធំ ព្រះវិហារ សៀមរាប ឧត្តរមានជ័យ និងរាជធានីភ្នំពេញ ត្រូវបានពិគ្រោះយោបល់លើការផ្លាស់ប្តូរតម្លៃរបស់គម្រោង និងវិធីសាស្ត្រចម្រុះផ្អែកលើតំបន់ទេសភាព ក្នុងនោះរួមមានបញ្ហានានា ដូចជាជម្រើសផ្តល់វិញ្ញាបនប័ត្រកសិកម្ម លទ្ធភាពទទួលហិរញ្ញវត្ថុ និងបច្ចេកវិទ្យា សមត្ថភាពផ្សព្វផ្សាយកសិកម្ម និងផលប៉ះពាល់ពីអាកាសធាតុដែលបានសង្កេតឃើញនៅជុំវិញដំណាំគោលដៅទាំងបួន៖ ស្វាយចន្ទី ស្វាយ ស្រូវសរីរាង្គ និងបន្លែ។

## ការវាយតម្លៃផលប៉ះពាល់ពី COVID-១៩ លើវិស័យកសិកម្ម និងសន្តិសុខស្បៀង (ឆ្នាំ ២០២០)

១៩៣. អង្គការ FAO បានធ្វើការសិក្សាមួយ ដោយសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កសិកម្ម និងជនបទ (CARD) ក្នុងឆ្នាំ ២០២០។ ការសិក្សានេះមានគោលបំណង (ក)វិភាគបញ្ហាប្រឈម បញ្ហា និងកង្វល់ចំបងៗ លើវិស័យកសិកម្ម និងសន្តិសុខស្បៀងក្នុងអំឡុងពេល និងបន្ទាប់ពីវិបត្តិនៃជំងឺកូវីដ-១៩ (ខ)វាយតម្លៃផលប៉ះពាល់ពីជំងឺកូវីដ-១៩ លើវិស័យកសិកម្ម និងសន្តិសុខស្បៀង តាមប្រធានបទសំខាន់ៗ និង (គ)ផ្តល់នូវការឆ្លើយតបផ្នែកគោលនយោបាយភ្លាមៗ រយៈពេលមធ្យម និងពេលវែងលើវិស័យកសិកម្ម។ ក្នុងអំឡុងពេល និងក្រោយការរីករាលដាលនៃជំងឺកូវីដ-១៩។

១៩៤. ការសិក្សានេះមានការចូលរួមពីភាគីពាក់ព័ន្ធចំនួន ៣៧៨ នាក់នៅទូទាំង ១៤ ខេត្ត (តំណាងរដ្ឋាភិបាលចំនួន ២៩ នាក់ តំណាងដៃគូអភិវឌ្ឍន៍ចំនួន ២១ នាក់ តំណាងវិស័យឯកជនចំនួន ៦៦ នាក់ តំណាងក្រុមហ៊ុនក្នុងស្រុកចំនួន ១៩ នាក់ និងកសិករចំនួន ២៤៣ នាក់។

## ការសិក្សាសមិទ្ធលទ្ធភាពអំពីភាពធនក្នុងវិស័យកសិកម្មដោយផ្អែកលើគុណតម្លៃ (២០២០)

១៩៥. ការសិក្សាដែលត្រូវបានចាត់តាំងពីអង្គការ FAO និងបានធ្វើឡើងដោយមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការគ្រប់គ្រងបរិស្ថាន (ICEM) បានពិនិត្យគម្លាតចំណេះដឹងបច្ចុប្បន្ន និងឱកាសជំរុញទីផ្សារ រួមទាំងខ្សែច្រវ៉ាក់តម្លៃជាគោលដៅរបស់គម្រោង PEARL ដោយមានគោលបំណងកំណត់គម្លាតនៃការវិនិយោគសាធារណៈ និងឯកជន និងតម្រូវការសម្រាប់ការកែលម្អផលិតកម្មកសិកម្ម និងប្រព័ន្ធចែកចាយ ដើម្បីបង្កើតឱ្យមានការផ្គត់ផ្គង់ផលិតផលកសិកម្មដែលមានសុវត្ថិភាព និងធន់នឹងអាកាសធាតុនៅកម្ពុជា។

១៩៦. ការសិក្សានេះមានការចូលរួមពីបុគ្គលចំនួន ៦៥ នាក់ តាមរយៈកិច្ចសម្ភាសន៍ និងកម្រងសំណួរ ក្នុងនោះរួមទាំងតំណាងរដ្ឋាភិបាលចំនួន ១៦ នាក់ តំណាងផ្នែកឯកជនចំនួន ១ នាក់ អាជីវករលក់ដុំ/ឈ្មួញកណ្តាលចំនួន ៤ នាក់ កសិករចំនួន ៣៩ នាក់ តំណាងសមាគមកសិកម្មចំនួន ១ នាក់ និងតំណាងអ្នកផ្គត់ផ្គង់ធាតុចូលចំនួន ៤ នាក់។

១៩៧. ការសិក្សាសមិទ្ធលទ្ធភាពស្តីពីសនិទានភាពអាកាសធាតុ ការធ្វើគំរូដំណាំដាក់លាក់ ការវាយតម្លៃសមត្ថភាពសេវាកម្មកសិឧតុនិយម និងអនុសាសន៍សកម្មភាពបន្សាំ (២០២១)

១៩៨. ការសិក្សានេះមានគោលបំណង (១)ពិនិត្យ និងកំណត់អត្តសញ្ញាណផលប៉ះពាល់ដែលបានសង្កេត និងព្យាករណ៍ពីការប្រែប្រួលអាកាសធាតុលើខ្សែច្រវ៉ាក់តម្លៃគោលដៅទាំង ៤ របស់គម្រោង និង (២)វាយតម្លៃគម្លាតសមត្ថភាពជាធរមាន និងតម្រូវការសម្រាប់ការផ្តល់ព័ត៌មានកសិឧត្តុនិយមមានការកាត់តម្រឹមកម្រិតខ្ពស់ និងសម្រាប់ដំណាំជាក់លាក់ និងសេវាកម្មត្រូវផ្តល់ជូនចុងក្រោយ។ ការសិក្សានេះបានសម្របសម្រួលកិច្ចពិភាក្សាបច្ចេកទេសជាមួយក្រសួងធនធានទឹក និងឧតុនិយម និងអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (អ្នកជំនាញប្រមាណ៨នាក់) លើការធ្វើគំរូដំណាំ ដើម្បីបង្កើតប៉ារ៉ាម៉ែត្រជាក់លាក់សម្រាប់ស្រូវ និងបន្លែ។ ដូចគ្នានេះផងដែរ ការស្ទង់មតិចំនួនពីរដាច់ដោយឡែកក៏ត្រូវបានធ្វើឡើងផងដែរ។ ការស្ទង់មតិទីមួយបានផ្តោតការយកចិត្តទុកដាក់លើកង្វះខាត/គម្លាតសមត្ថភាព និងតម្រូវការរបស់ក្រសួងធនធានទឹក និងឧតុនិយម និងមន្ទីរក្រោមឱវាទរបស់ខ្លួន ហើយការស្ទង់មតិទីពីរផ្តោតលើផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ដោយធ្វើការប្រៀបធៀបនឹងខ្សែច្រវ៉ាក់តម្លៃទាំងបួន ព្រមទាំងឱកាសសម្រាប់ពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។ អ្នកចូលរួមត្រូវបានជ្រើសរើសដោយផ្អែកលើការចូលរួមរបស់ពួកគេនៅក្នុងសកម្មភាពជាក់លាក់នៃខ្សែច្រវ៉ាក់តម្លៃ។ បុគ្គលប្រមាណជា ១១៨ នាក់ (ស្រី ១៧ នាក់) តំណាងឱ្យអង្គភាពចំនួន ៦៣ អង្គភាព បានចូលរួមក្នុងការស្ទង់មតិនេះ។ ពួកគេជាតំណាងមកពីក្រសួង ស្ថាប័នរបស់រដ្ឋាភិបាល មន្ទីរ អង្គការក្រៅរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ សមាគមកសិកម្ម អ្នកផ្គត់ផ្គង់ធាតុចូល អាជីវករលក់ដុំ ស្ថាប័នហិរញ្ញវត្ថុ ។ល។

## ការសិក្សាសមិទ្ធលទ្ធភាពស្តីពីយន្តការហិរញ្ញប្បទានប្រកបដោយភាពច្នៃប្រឌិតៈ យន្តការកសាងភាពធន់ក្នុងវិស័យកសិកម្មដែលដឹកនាំដោយកសិករ (FARM) (២០២១)

១៩៩. ការសិក្សានេះបានពិនិត្យ និងកំណត់ជម្រើស និងលក្ខណៈបច្ចេកទេសសម្រាប់យន្តការធន់នឹងកសិកម្មដឹកនាំដោយកសិករ (FARM)។ FARM នេះមានគោលបំណងផ្តល់ឥណទានគ្មានការប្រាក់ដល់សហគមន៍កសិកម្ម សមាគម សហជីព និងក្រុមផលិតការដែលបានចុះបញ្ជីស្របច្បាប់ ក្នុងនោះរួមទាំងសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ នៅក្នុងតំបន់ភាគខាងជើងនៃបឹងទន្លេសាប សម្រាប់ការទិញយកបច្ចេកវិទ្យា និងធនធានហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់ដល់ការធ្វើកសិកម្មដែលធន់នឹងអាកាសធាតុ និងមានតម្លៃខ្ពស់។ FARM នេះក៏នឹងធានាថា បច្ចេកវិទ្យា និងធនធានទាំងនោះត្រូវបានជ្រើសរើស និងប្រើប្រាស់ ដោយមានលក្ខណៈឆ្លើយតបនឹងយេនឌ័រ បរិយាប័ន្ន និងសមធម៌។ ការសិក្សានេះបានពិគ្រោះយោបល់ជាមួយបុគ្គលប្រហែល ២០ នាក់ (ស្រី ៥ នាក់) ក្នុង

នោះរួមទាំងតំណាងមកពី ARDB និងស្ថាប័នហិរញ្ញវត្ថុឯកជនចំនួន ១០ នាក់ និងសហគមន៍កសិកម្ម និង SME ចំនួន ១០ នាក់។

### ការសិក្សាសមិទ្ធលទ្ធភាពស្តីពីការរៀបចំផែនការស្តារទីជម្រាល (២០២១)

២០០. ការសិក្សានេះបានកំណត់តំបន់សមស្របសម្រាប់ដាំស្តារព្រៃឈើ និងប្រភេទសកម្មភាពស្តារឡើងវិញជាក់លាក់តាមប្រភេទប្រើប្រាស់ដីខុសៗគ្នា ក្នុងនោះរួមទាំងសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើជាសក្តានុពល ដែលទទួលបានអន្តរាគមន៍ពីគម្រោង ដោយផ្អែកលើសក្តានុពលនៃការដាំស្តារទីជម្រាល និងសមត្ថភាពអភិបាលកិច្ច។

២០១. ក្រុមការងារសិក្សាបានធ្វើការពិគ្រោះយោបល់ជាបន្តបន្ទាប់ជាមួយភាគីពាក់ព័ន្ធសំខាន់ៗ រួមមានមន្ទីរបរិស្ថាន មន្ត្រីសង្កាត់រដ្ឋបាលព្រៃឈើ សមាជិកគណៈកម្មាធិការសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើ និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីជ្រើសរើសដោយសង្ខេបនូវហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើ នៅក្នុងខេត្តនៃតំបន់ភាគខាងជើងបឹងទន្លេសាប។ ក្រុមសិក្សាបានវិភាគសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើជាសក្តានុពល ដោយធ្វើការពិចារណាលើ (i)ព័ត៌មានប្រជាសាស្ត្រ (ចំនួនប្រជាជន ភាគរយនៃជនជាតិដើមភាគតិច អត្តសញ្ញាណប័ណ្ណក្រីក្រ កម្រិតប្រាក់ចំណូល មុខរបរ) (ii)ព័ត៌មានអំពីគម្របព្រៃឈើ (ប្រភេទ ប្រាំងមាត់ទឹក ច្រករបៀងអភិរក្សជីវៈចម្រុះ ទីជម្រាលផ្នែកខាងលើ) (iii)តំបន់ស្តារឡើងវិញដែលមានសក្តានុពល និង (iv)សមត្ថភាពអភិបាលកិច្ច (ឧ. ផែនការគ្រប់គ្រង)។ បុគ្គលសរុបចំនួន ៤៨ នាក់បានផ្តល់ការពិគ្រោះយោបល់ ហើយពួកគេតំណាងឱ្យសហគមន៍តំបន់ការពារធម្មជាតិរបស់ក្រសួងបរិស្ថាន និងសហគមន៍ព្រៃឈើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរក្រោមឱវាទរបស់ក្រសួងទាំងពីរ និងអង្គការក្រៅរដ្ឋាភិបាល ដូចជា សមាគមអភិរក្សសត្វព្រៃ (WCS)។

### ការសិក្សាសមិទ្ធលទ្ធភាពស្តីពីការវិភាគរួមលើផ្នែកហិរញ្ញវត្ថុ និងសេដ្ឋកិច្ច (IFEA)

២០២. ការសិក្សាបានពិនិត្យពីសមិទ្ធលទ្ធភាពរបស់គម្រោងពីទស្សនៈហិរញ្ញវត្ថុ និងសេដ្ឋកិច្ច ដោយធ្វើការវិភាគពីភាពមិនប្រាកដប្រជានៃសមាសធាតុសំខាន់ៗ។ ការសិក្សានេះមានការចូលរួមពីកសិករចំនួន ៣៧ នាក់ (ស្រី ១៨ នាក់) មកពីខេត្តត្បូងឃ្មុំ បន្ទាយមានជ័យ បាត់ដំបង កំពង់ធំ ព្រះវិហារ ព្រៃវែង ត្បូងឃ្មុំ កំពង់ចាម សៀមរាប ព្រៃវែង និងខេត្តកណ្តាល តាមរយៈការសម្ភាសន៍ និងការស្ទាបស្ទង់មតិ។

### ក្រុមការងារគម្រោង PEARL (PWG) (២០២១)

២០៣. ក្រុមការងារគម្រោងត្រូវបានបង្កើតឡើង ដើម្បីផ្តល់ការណែនាំ និងទិសដៅជាយុទ្ធសាស្ត្រដល់ក្រុមបង្កើតគម្រោង ក្រោមការដឹកនាំរបស់ NDA។ ក្រុមការងារនេះស្ថិតក្រោមការគ្រប់គ្រងរួមគ្នាដែលជាតំណាងពី NDA និងអង្គការ FAO កម្ពុជា។ ក្រុមការងារមានសមាសភាពជាជនបង្គោលបច្ចេកទេសពីក្រសួង ស្ថាប័ននៃរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលសំខាន់ៗ មួយចំនួន រួមមានដូចខាងក្រោម៖

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF)
- ក្រសួងបរិស្ថាន (MoE)
- ក្រសួងធនធានទឹក និងឧតុនិយម (MWRM)
- ក្រសួងពាណិជ្ជកម្ម (MoC)

- ធនាគារកសិកម្ម និងអភិវឌ្ឍន៍ជនបទ (ARDB)
- ក្រសួងកិច្ចការនារី (MoWA)
- អង្គការផ្សេងៗទៀត - ដៃគូប្រតិបត្តិក្រៅរដ្ឋាភិបាល (ឧ. WCS និង GRET)។

២០៤. ក្រុមការងារគម្រោងបានប្រជុំនៅថ្ងៃទី២៥ ខែសីហា ថ្ងៃទី២ ខែកញ្ញា និងថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១។ ការពិភាក្សាបច្ចេកទេសជាច្រើនទាក់ទងនឹងការរៀបចំការអនុវត្តគម្រោង និងសហហិរញ្ញប្បទានត្រូវបានធ្វើឡើងជាមួយសមាជិកជាឯកត្តបុគ្គលជាលក្ខណៈទ្វេភាគី ដើម្បីពិនិត្យ និងវាយតម្លៃការសម្រេចនៃកិច្ចប្រជុំរបស់ក្រុមការងារលើទី២។

២០៥. កិច្ចប្រជុំផ្សេងទៀតរួមមានៈ

២០៦. កិច្ចប្រជុំទ្វេភាគីស្តីពីការរៀបចំការអនុវត្តគម្រោង និងសហហិរញ្ញប្បទានជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅខែវិច្ឆិកា ឆ្នាំ២០២១ (អ្នកចូលរួមចំនួន ១០ នាក់មកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមបង្កើតគម្រោង និងអង្គការ FAO ប្រចាំប្រទេស)។

២០៧. កិច្ចប្រជុំទ្វេភាគីស្តីពីសហហិរញ្ញប្បទានជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងខែវិច្ឆិកា ឆ្នាំ២០២១ (អ្នកចូលរួមចំនួន ៩ នាក់ (ស្ត្រី ១ នាក់) ក្រសួងបរិស្ថាន ក្រុមបង្កើតគម្រោង និងការិយាល័យអង្គការ FAO ប្រចាំប្រទេស) និង

២០៨. កិច្ចប្រជុំទ្វេភាគីស្តីពីសហហិរញ្ញប្បទានជាមួយក្រសួងធនធានទឹក និងឧតុនិយម នៅខែធ្នូ ឆ្នាំ២០២១ (អ្នកចូលរួម ៩ នាក់ (ស្ត្រី ១ នាក់) ក្រុមបង្កើតគម្រោង និងការិយាល័យរបស់អង្គការ FAO ប្រចាំប្រទេស)។

**បេសកកម្មបង្កើតគម្រោងលើកទី២ ឆ្នាំ២០២១**

២០៩. បេសកកម្មបង្កើតគម្រោងលើកទី២ បានធ្វើឡើងនៅចន្លោះពីថ្ងៃទី៧ ដល់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១។

២១០. បេសកកម្មមានគោលបំណង ដើម្បី (១)បញ្ចប់សមាសធាតុសំខាន់ក្នុងការរៀបចំបង្កើតគម្រោង តាមរយៈការប្រជុំផ្តល់សុពលភាពពីភាគីពាក់ព័ន្ធលើសំណើសុំមូលនិធិ ក្នុងនោះរួមទាំងសនិទានភាពអាកាសធាតុ ក្របខ័ណ្ឌការងារជាក់ស្តែង ថវិកា សហហិរញ្ញវត្ថុ ការរៀបចំការអនុវត្តគម្រោង និងយន្តការហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត និង (២)ពិគ្រោះជាមួយអ្នកទទួលផលដែលបានកំណត់នៅក្នុងប្រទេស ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងពាណិជ្ជកម្ម ធនាគារ ARDB, ដៃគូអង្គការមិនមែនរដ្ឋាភិបាល និងភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីស្នើសុំធាតុចុងក្រោយសម្រាប់ការរៀបចំគម្រោង។

២១១. ក្រុមការងារបង្កើតគម្រោងបានជួប និងពិភាក្សាជាមួយបុគ្គលពាក់ព័ន្ធសរុបចំនួន ១០៥ នាក់ (ស្រី ២០ នាក់) មកពី ៥១ ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដែលក្នុងនោះស្ថាប័នហិរញ្ញវត្ថុចំនួន ១៥នាក់ មន្ទីរចំនួន ២១នាក់ ក្រសួងចំនួន ៩នាក់ អង្គការក្រៅរដ្ឋាភិបាលចំនួន ៩ នាក់ ដៃគូអភិវឌ្ឍន៍ចំនួន ៧ នាក់ សមាគម/សហគមន៍កសិករ/សហជីពចំនួន ៣១ នាក់ និងវិស័យឯកជនចំនួន ១៣នាក់។ តារាងទី ៣ គឺជាបញ្ជីនៃក្រុមភាគីពាក់ព័ន្ធដែលបានពិគ្រោះយោបល់ និងសេចក្តីសង្ខេបពីកិច្ចពិភាក្សាសំខាន់ៗ។

**ក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម (ESMF) និងសកម្មភាពវាយតម្លៃយេនឌ័រ (២០២២)**

២១២. ក្នុងអំឡុងពេលនៃដើមឆ្នាំ២០២២ កិច្ចសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយកិច្ចពិភាក្សាជាមួយក្រុមគោលដៅនៅថ្នាក់ខេត្តចំនួន ៤ ក្រុមត្រូវបានធ្វើឡើង ដើម្បីប្រមូលព័ត៌មាន

សម្រាប់ធ្វើការវាយតម្លៃនេះ។ កិច្ចប្រជុំទាំងនេះមានការចូលរួមពីតំណាងពីក្រសួង ស្ថាប័នរបស់រដ្ឋាភិបាល វិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងសហគមន៍កសិកម្ម អង្គការមិនមែនរដ្ឋាភិបាល និងក្រុមសហគមន៍។

## ៧.៣ ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធសម្រាប់ការអនុវត្តគម្រោង

២១៣. ដូចដែលបានរៀបរាប់ខាងលើ គម្រោង PEARL ត្រូវបានរៀបចំឡើង ដោយផ្អែកលើការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយភាគីពាក់ព័ន្ធចម្រុះវិស័យ នៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋានចាប់តាំងពីឆ្នាំ២០១៨។ ទោះយ៉ាងនេះក៏ដោយ កិច្ចប្រជុំពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធជាទៀងទាត់នឹងបន្តធ្វើឡើង ក្នុងអំឡុងពេលនៃការអនុវត្តគម្រោង ដើម្បីផ្តល់ព័ត៌មានពីវឌ្ឍនភាពរបស់គម្រោងជូនដល់ភាគីពាក់ព័ន្ធ គាំទ្រដល់ការកសាងសមត្ថភាព និងការលើកកម្ពស់ការយល់ដឹង ផ្តល់សុពលភាពលើលទ្ធផលរកឃើញ និងបង្ហាញលទ្ធផលផ្សេងៗទៀត ក្នុងចំណោមប្រធានបទជាច្រើនទៀត។

២១៤. អង្គការ FAO និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងធ្វើបច្ចុប្បន្នភាពជាប្រចាំ ក្នុងនោះរួមទាំងនៅលើគេហទំព័ររបស់ខ្លួន និងតាមរយៈការប្រើប្រាស់ទម្រង់នៃប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀត ដូចជាឯកសារបោះពុម្ព វិទ្យុ របាយការណ៍ និងការធ្វើបទបង្ហាញ។ ព័ត៌មាននេះនឹងបង្ហាញជាភាសាខ្មែរ និងអង់គ្លេស។

២១៥. លេខទូរសព្ទសម្រាប់ការទំនាក់ទំនងក៏នឹងត្រូវបានផ្តល់ជូនអ្នកទទួលផលពីគម្រោង និងភាគីពាក់ព័ន្ធដែលអាចពិភាក្សាបញ្ហាទាក់ទងនឹងគម្រោង លើកឡើងពីកង្វល់ ឬដាក់ពាក្យបណ្តឹង។

២១៦. នៅថ្នាក់ជាតិ ភាគីពាក់ព័ន្ធនឹងត្រូវបានអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំ PSC នៅរៀងរាល់កន្លះឆ្នាំម្តង ដើម្បីពិភាក្សាអំពីប្រធានបទសំខាន់ៗ។ ការចូលរួមកិច្ចប្រជុំនឹងត្រូវធ្វើឡើង ដោយផ្អែកលើការអញ្ជើញ ហើយដោយយកចិត្តទុកដាក់លើប្រធានបទសំខាន់សម្រាប់កិច្ចពិភាក្សាក្នុងកិច្ចប្រជុំ។

២១៧. ភាគីពាក់ព័ន្ធក៏នឹងត្រូវបានអញ្ជើញឱ្យចូលរួម តាមរយៈ អង្គភាពសម្របសម្រួលគម្រោង(PCU) ដែលនឹងប្រតិបត្តិការនៅថ្នាក់ជាតិ។

២១៨. របាយការណ៍គម្រោងប្រចាំឆ្នាំនឹងផ្តល់ជូនបន្ថែមនូវទិដ្ឋភាពរួមនៃការពិគ្រោះយោបល់ និងសិក្ខាសាលាដែលបានធ្វើឡើង និងផ្តល់ការយល់ឃើញលើព្រឹត្តិការណ៍សកម្មភាពដែលត្រូវអនុវត្តនៅក្នុងឆ្នាំបន្ទាប់។ ផែនការទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាននឹងត្រូវបានបង្កើត និងដាក់ឱ្យអនុវត្តនៅឆ្នាំទី៣ នៃការអនុវត្តគម្រោង។

២១៩. ការចូលរួមនៅក្នុងគម្រោង PEARL គឺជាការស្ម័គ្រចិត្ត ហើយ ការយល់ព្រមជាមុន ដោយសេរីដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់(FPIC)នឹងក្លាយជាផ្នែកស្នូលដែលបញ្ជាក់ពីគោលការណ៍ដែលបានប្រើប្រាស់ជាមួយអង្គការគ្រប់គ្រងដោយសហគមន៍ទាំងអស់ ខណៈដែលដំណើរការ ការយល់ព្រមជាមុន ដោយសេរីដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់(FPIC)ពេញលេញ និងផ្លូវការនឹងត្រូវបានអនុវត្ត នៅពេលមានការចូលរួមពីក្រុមជនជាតិដើមភាគតិច។ ដើម្បីចូលរួមក្នុងគម្រោងបាន គោលការណ៍ ការយល់ព្រមជាមុន ដោយសេរីដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់(FPIC) នឹងត្រូវគោរពតាម តាមរយៈការពិគ្រោះយោបល់ជាមួយក្រុមសមាគមកសិករ និងសហគមន៍តំបន់ការពារធម្មជាតិទាំងអស់។ គោលការណ៍នេះធ្វើឡើងដោយផ្អែកលើសៀវភៅរបស់អង្គការ FAO ស្តីពី ការយល់ព្រមជាមុន ដោយសេរីដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់(FPIC)សម្រាប់អ្នកអនុវត្តគម្រោង (សូមមើលចំណុចទី ៨.៥.៣ សម្រាប់ព័ត៌មានលម្អិតបន្ថែមទៀត)។ បន្ទាប់ពីបានរៀបចំបានរួចរាល់នូវបញ្ជីសមាគមកសិករ និងសហគមន៍តំបន់ការពារធម្មជាតិនៅក្នុងលទ្ធផល ២ នោះ កិច្ចពិគ្រោះយោបល់នឹងត្រូវធ្វើឡើង ដើម្បីពិនិត្យមើលឡើងវិញ និងរៀបចំសកម្មភាព ដោយមានការចូលរួម និងដើម្បីធានាថា ភាគីពាក់ព័ន្ធ និងម្ចាស់សិទ្ធិទាំងអស់បានទទួលព័ត៌មានពេញ

លេចញអំពីសកម្មភាពរបស់គម្រោង។ ដំណើរការនេះនឹងធានាដល់ការផ្តល់ព័ត៌មានពេញលេញទាន់ពេលវេលា មុនពេលអនុវត្តគម្រោង ដោយសង្កត់ធ្ងន់ថា ការចូលរួមនៅក្នុងគម្រោង គឺស្ម័គ្រចិត្តទាំងស្រុង ហើយថា ក្នុងករណីដែលមិនអនុលោមតាមការរៀបចំដែលបានព្រមព្រៀងគ្នា ជនជាតិដើមភាគតិចមានសិទ្ធិដកការឯកភាពរបស់ខ្លួនចេញដោយប្រើប្រាស់នីតិវិធីដែលបានបង្កើតឡើង និងបានឯកភាពគ្នាទៅវិញទៅមកតាមគោលការណ៍ ការយល់ព្រមជាមុន ដោយសេរីដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់(FPIC)។ ព័ត៌មានស្តីពីយន្តការដោះស្រាយបណ្តឹងតវ៉ារបស់គម្រោងក៏នឹងត្រូវបានផ្សព្វផ្សាយនៅពេលនោះផងដែរ (សូមមើលចំណុចទី ៧.៥ និង ៨.៩)។

២២០. សកម្មភាពនីមួយៗដែលបានគ្រោងទុកសម្រាប់គម្រោង PEARL មានព្រឹត្តិការណ៍បញ្ចូលភាគីពាក់ព័ន្ធ និងសកម្មភាពដើម្បីលើកលើកកម្ពស់ការយល់ដឹង។ ឧទាហរណ៍នៃការបញ្ចូលភាគីពាក់ព័ន្ធមានដូចខាងក្រោម៖

- កិច្ចប្រជុំពិគ្រោះយោបល់ និងសិក្ខាសាលាស្តីពីការរៀបចំដំណើរការ និងនីតិវិធីប្រកបដោយសុខដុមកម្មសម្រាប់ផ្តល់សេវាកម្មប្រឹក្សាកសិឧតុនិយម តាមរយៈអ្នកផ្តល់សេវាកម្មផ្សព្វផ្សាយសាធារណៈ និងឯកជន
- កិច្ចប្រជុំពិគ្រោះយោបល់ និងសិក្ខាសាលាស្តីពីការរៀបចំបង្កើតផែនទីបង្ហាញផ្លូវសម្រាប់ទំនាក់ទំនងរវាងខ្សែច្រវ៉ាក់តម្លៃ និងតួអង្គនានា ដោយធ្វើការកំណត់អត្តសញ្ញាណកម្មវិធី និងយុទ្ធសាស្ត្រផ្តល់វិញ្ញាបនបត្រជាគោលដៅ ដែលបានរៀបចំនៅថ្នាក់ខេត្ត សម្រាប់រៀបចំច្រវ៉ាក់តម្លៃនៃផលិតផលមានតម្លៃខ្ពស់ ឆ្លើយតបនឹងយេនឌ័រ និងបរិយាប័ន្នតាមរយៈកម្មវិធីផ្តល់វិញ្ញាបនបត្រ។ តួអង្គពាក់ព័ន្ធនឹងខ្សែច្រវ៉ាក់តម្លៃ រួមមានអ្នកផ្តល់ជាតុចូល កសិករ រោងម៉ាស៊ីនកិនស្រូវ អាជីវករប្រមូលផលិតផល អាជីវកទិញលក់/អ្នកនាំចេញ អាជីវករលក់រាយនៅមូលដ្ឋាន ម្ចាស់សណ្ឋាគារ និងភោជនីយដ្ឋាន។ កិច្ចប្រជុំពិគ្រោះយោបល់ និងសិក្ខាសាលាស្តីពីចំណេះដឹងជាប្រពៃណីនៅមូលដ្ឋានសម្រាប់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុក៏បានរៀបចំឡើងផងដែរ។
- កិច្ចប្រជុំពិគ្រោះយោបល់លើការរៀបចំឧបករណ៍ហិរញ្ញប្បទានដោយចីរភាព សម្រាប់កសិករខ្នាតតូច និងតួអង្គខ្សែច្រវ៉ាក់តម្លៃៗផ្សេងទៀតនៅមូលដ្ឋានត្រូវបានធ្វើឡើង។
- កិច្ចប្រជុំពិគ្រោះយោបល់ជាមួយសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើ ដែលចូលរួមក្នុងការការពារ និងការស្តារឡើងវិញនៃទីជម្រាល តាមរយៈការងារកសិរុក្ខកម្ម និងការងារក្រោមកិច្ចសន្យា។
- ឧបសម្ព័ន្ធទី ១ នៃឯកសារបច្ចុប្បន្ន ផ្តល់ទិដ្ឋភាពលម្អិតបន្ថែមទៀតនៃព្រឹត្តិការណ៍ប្រជុំពិគ្រោះយោបល់ និងសិក្ខាសាលាជាមួយភាគីពាក់ព័ន្ធផ្អែកតាមផែនការ ក្នុងអំឡុងពេលនៃការរៀបចំផែនការការងារ ក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម(ESMF)។

## ៧.៤ ការផ្សព្វផ្សាយព័ត៌មាន

២២១. ការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធអំពីគម្រោងជួយភាគីពាក់ព័ន្ធចូលរួមយ៉ាងមានប្រសិទ្ធភាព។ អង្គការ FAO នឹងផ្សព្វផ្សាយព័ត៌មានឱ្យបានទាន់ពេលវេលា ដែលអាចរកមើលបាន និងសមស្របតាមវប្បធម៌ប្រពៃណី ដោយផ្តោតការចិត្តទុកដាក់ជាពិសេសលើតម្រូវការជាក់លាក់របស់ក្រុមសហគមន៍ ដែលអាចរងផលប៉ះពាល់ដោយការអនុវត្តគម្រោង (ដូចជាយេនឌ័រ អក្ខរកម្ម ភាពខុសគ្នានៃភាសា ឬលទ្ធភាពទទួលបានព័ត៌មានបច្ចេកទេស ឬបណ្តាញ)។

២២២. ដើម្បីកាត់បន្ថយហានិភ័យឱ្យនៅកម្រិតមធ្យមពីគម្រោងនោះ អង្គការ FAO នឹងផ្សព្វផ្សាយព័ត៌មានជាធរមានឱ្យបានលឿនបំផុតតាមអាចធ្វើបាន ពោលមិនឱ្យលើសពី ៣០ ថ្ងៃមុនពេលការអនុម័តគម្រោង។ រយៈពេល ៣០ ថ្ងៃនេះចាប់ផ្ដើម តែបន្ទាប់ពីបានផ្ដល់ព័ត៌មានពាក់ព័ន្ធទាំងអស់ដែលបានស្នើសុំពីគម្រោង និងផ្សព្វផ្សាយដល់សាធារណជន។

២២៣. អង្គការ FAO នឹងផ្សព្វផ្សាយព័ត៌មានសម្រាប់គម្រោងកំណត់ហានិភ័យនៅកម្រិតមធ្យម។ ក្នុងករណីនេះ គេហទំព័រផ្សាយព័ត៌មានត្រូវបានបង្កើតឡើង ដើម្បីផ្សព្វផ្សាយជាសាធារណៈនូវឯកសារគម្រោងទាក់ទងនឹងការការពារបរិស្ថាន និងសង្គម (ការវិភាគបរិស្ថាននិងសង្គម ការវាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គម ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម ជនជាតិដើមភាគតិច និងផែនការដាក់បញ្ចូលសង្គម និងឯកសារពាក់ព័ន្ធផ្សេងទៀត)។ គេហទំព័រ៖ http://www.fao.org/environmental-social-standards/en/។

២២៤. ដើម្បីធានាដល់ការផ្សព្វផ្សាយ និងការបញ្ចេញផ្សព្វផ្សាយព័ត៌មានគម្រោងឱ្យបានទូលំទូលាយបំផុតនោះ ក្នុងនោះរួមទាំងព័ត៌មានលម្អិតទាក់ទងនឹងការការពារសុវត្ថិភាពបរិស្ថាន និងសង្គមជាធរមាននោះ ឧបករណ៍ផ្សព្វផ្សាយព័ត៌មានក្នុងប្រទេស និងអាចចូលប្រើបាន មានជាអាទិ៍ ខិត្តប័ណ្ណ ប័ណ្ណព័ត៌មាន វីដេអូ និងការផ្សព្វផ្សាយតាមវិទ្យុសហគមន៍ នឹងត្រូវបានប្រើប្រាស់ បន្ថែមទៅនឹងឧបករណ៍ផ្សេងទៀត។ ជាងនេះទៀត ការយកចិត្តទុកដាក់ជាពិសេសនឹងត្រូវបានធ្វើឡើងសម្រាប់ស្ត្រី ជនជាតិដើមភាគតិច ក្រុមជនជាតិភាគតិចដែលទទួលបានការយកចិត្តទុកដាក់តិចតួចក្នុងសង្គម ជនអនក្ខរកម្ម ឬជនអនក្ខរកម្មផ្នែកបច្ចេកវិទ្យា និងបុគ្គលដែលមានការលំបាកក្នុងការស្ដាប់ ឬការមើលឃើញ ប្រជាជនដែលគ្មាន ឬមានប្រព័ន្ធអ៊ីនធឺណិតតិចតួច និងក្រុមផ្សេងទៀតដែលមានតម្រូវការពិសេស។ ការផ្សព្វផ្សាយព័ត៌មានឱ្យដល់ក្រុមទាំងនេះនឹងត្រូវធ្វើឡើងជាមួយសមភាគីរបស់គម្រោង និងតួអង្គនៅមូលដ្ឋាន ដូចជានៅទីប្រជុំជន សមាគមផលិតករ សមាគមជនជាតិដើមភាគតិច អង្គការតំណាងឱ្យក្រុមជនជាតិភាគតិចដែលទទួលបានការយកចិត្តទុកដាក់តិចតួចក្នុងសង្គម អង្គការស្ត្រី តួអង្គរបស់រដ្ឋាភិបាល និងតួអង្គផ្សេងៗក្នុងតំបន់។

## ៧.៥ យន្តការដោះស្រាយបណ្ដឹងតវ៉ា

### ៧.៥.១ យន្តការបណ្ដឹងតវ៉ារបស់អង្គការ FAO

២២៥. យន្តការដោះស្រាយបណ្ដឹងតវ៉ានេះត្រូវបានរៀបចំឡើង ដើម្បីធានាថាគ្មានបុគ្គល ឬក្រុមណាមួយរងផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ តាមរយៈការប្ដឹង ឬការតវ៉ា។ ការចំណាយណាមួយដែលអាចមានជាប់ពាក់ព័ន្ធនឹងការរៀបចំ ឬការចេញពាក្យបណ្ដឹង ឬការប្ដឹងស្របច្បាប់ (ឧ. ការបញ្ចូលបុគ្គលមានគុណវុឌ្ឍិដើម្បីជួយដល់អ្នកប្ដឹងតវ៉ា) នឹងត្រូវទូទាត់ដោយយន្តការបណ្ដឹងតវ៉ា។ កិច្ចខិតខំប្រឹងប្រែងពិសេសនឹងត្រូវបានធ្វើឡើង ដើម្បីធានាឱ្យមាននៅនឹងកន្លែងនូវយន្តការដោះស្រាយបណ្ដឹងតវ៉ាសម្រាប់មនុស្សទាំងអស់ ហើយក្រុមស្ត្រី ជនជាតិដើមភាគតិច បុគ្គលទទួលបានការយកចិត្តទុកដាក់តិចតួចក្នុងសង្គម និង/ឬក្រុមងាយរងគ្រោះ និងក្រុមរងការប្រទេចទោលពីសង្គម មានសិទ្ធិទទួលបានស្មើៗគ្នានូវ និងពុំមានផលប៉ះពាល់អវិជ្ជមានពីការដាក់ពាក្យប្ដឹង ឬបណ្ដឹងតវ៉ាណាឡើយ។

២២៦. អង្គការ FAO ប្ដេជ្ញាធានាថា កម្មវិធីរបស់ខ្លួនត្រូវបានអនុវត្ត ស្របតាមបទដ្ឋានបរិស្ថាន និងសង្គមរបស់អង្គការ។ ដើម្បីសម្រេចបាននូវគោលដៅទាំងនេះឱ្យកាន់តែប្រសើរឡើង និងដើម្បីធានាថា អ្នកទទួលផលពីកម្មវិធីរបស់អង្គការ FAO មានលទ្ធភាពប្រើប្រាស់យន្តការនេះឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា ដើម្បីដោះស្រាយកង្វល់របស់ពួកគេអំពីការមិនអនុលោមតាមកាតព្វកិច្ច និងការរៀបចំទាំងនេះដើម្បីបំពេញបន្ថែមវិធានការសម្រាប់ទទួល ពិនិត្យឡើងវិញ និងមានចំណាត់ការ តាមភាពសមស្របលើលើកង្វល់ទាំងនេះនៅកម្រិតគ្រប់គ្រងកម្មវិធី មានទំនុកចិត្តលើ

ការិយាល័យអធិការកិច្ច (OIG) ដែលមានអាណត្តិពិនិត្យដោយឯករាជ្យលើពាក្យបណ្តឹងដែលមិនអាចដោះស្រាយបាននៅកម្រិតនោះ។

២២៧. អង្គការ FAO នឹងជួយសម្រួលដល់ការដោះស្រាយកង្វល់របស់អ្នកទទួលផលពីកម្មវិធីរបស់អង្គការ FAO ទាក់ទងនឹងការរំលោភបំពានដែលបានចោទប្រកាន់ ឬមានសក្តានុពលលើការប្តេជ្ញាចិត្តផ្នែកសង្គម និងបរិស្ថានរបស់អង្គការ FAO។ ដើម្បីសម្រេចបានគោលបំណងនេះ ការព្រួយបារម្ភនានាអាចត្រូវបានបញ្ជូនទៅដោះស្រាយដោយអនុលោមតាមលក្ខណៈវិនិច្ឆ័យទទួលយកបាននៃគោលការណ៍ណែនាំសម្រាប់ការត្រួតពិនិត្យការអនុលោមបន្ទាប់បានទទួលបណ្តឹងតវ៉ាទាក់ទងនឹងបទដ្ឋានបរិស្ថាន និងសង្គមរបស់អង្គការ ដែលអនុវត្តចំពោះកម្មវិធី និងគម្រោងទាំងអស់របស់អង្គការ FAO (គោលការណ៍ណែនាំសម្រាប់ត្រួតពិនិត្យការអនុលោម បន្ទាប់ពីបានទទួលបណ្តឹងទាក់ទងនឹងបទដ្ឋានបរិស្ថាន និងសង្គមរបស់អង្គការ)។

២២៨. ការព្រួយបារម្ភទាំងអស់ត្រូវតែដោះស្រាយនៅកម្រិតកៀកបំផុតកន្លែងមានបណ្តឹង ឧ. នៅកម្រិតគ្រប់គ្រងគម្រោង/បច្ចេកទេស ហើយប្រសិនបើចាំបាច់នៅកម្រិតការិយាល័យតំបន់។ ប្រសិនបើការព្រួយបារម្ភ ឬបណ្តឹងតវ៉ាណាមួយមិនអាចដោះស្រាយបាន តាមរយៈការពិគ្រោះយោបល់ និងវិធានការនៅកម្រិតគ្រប់គ្រងគម្រោងទេនោះ បណ្តឹងតវ៉ាស្នើសុំឱ្យមានការពិនិត្យលើការអនុលោម អាចត្រូវបានដាក់ទៅ ការិយាល័យអធិការកិច្ច (OIG) ដោយអនុលោមតាមគោលការណ៍ណែនាំ។ អ្នកគ្រប់គ្រងគម្រោងនឹងទទួលខុសត្រូវដោះស្រាយកង្វល់ដែលបានបញ្ជូនទៅកាន់ជនបង្គោល។

២២៩. គោលការណ៍ដែលត្រូវអនុវត្តតាម ក្នុងអំឡុងពេលនៃដំណើរការដោះស្រាយបណ្តឹងរួមមាន ភាពមិនលំអៀង ការគោរពសិទ្ធិមនុស្ស ក្នុងនោះរួមទាំងសិទ្ធិទាក់ទងនឹងជនជាតិដើមភាគតិច ការអនុលោមតាមបទដ្ឋានជាតិ ការប្រកាន់ខ្ជាប់ទៅនឹងបទដ្ឋាន សមភាព តម្លាភាព ភាពស្មោះត្រង់ និងការគោរពគ្នាទៅវិញទៅមក។

២៣០. វិធីសាស្ត្រនេះត្រូវបានរៀបរាប់លម្អិតបន្ថែមទៀតសម្រាប់ប្រទេសកម្ពុជានៅក្នុងសេចក្តីព្រាងយន្តការពិនិត្យបណ្តឹងតវ៉ារបស់អង្គការ FAO នៅកម្ពុជា ដែលបច្ចុប្បន្នកំពុងត្រូវបានរៀបចំបញ្ចប់ ហើយនឹងដាក់ឱ្យអនុវត្ត នៅពាក់កណ្តាលឆ្នាំ២០២២ (សេចក្តីព្រាងកំណែមានភ្ជាប់មកជាមួយក្នុងឧបសម្ព័ន្ធទី ៤)។

### ៧.៥.២ យន្តការបណ្តឹងតវ៉ានៅកម្រិតគម្រោង

២៣១. យន្តការបណ្តឹងតវ៉ានៅកម្រិតនេះ ត្រូវបានបង្កើតឡើងដើម្បីទទួលស្គាល់ និងដោះស្រាយរាល់ផលប៉ះពាល់អវិជ្ជមានទាំងអស់ពីបណ្តឹងតវ៉ាដែលកើតឡើងពីលទ្ធផលនៃការអនុវត្តគម្រោង។ បណ្តឹងតវ៉ាណាមួយគួរឆ្លងកាត់ការវិភាគ និងកាត់បន្ថយឱ្យបានលឿន តាមដែលអាចធ្វើទៅបាន ដើម្បីបញ្ចៀសភាពតានតឹង ឬជម្លោះណាមួយ។

២៣២. គោលបំណងនៃយន្តការដោះស្រាយបណ្តឹងតវ៉ា គឺដើម្បី៖

- ផ្តល់ជូនប្រជាពលរដ្ឋដែលរងផលប៉ះពាល់នូវច្រកទំនាក់ទំនងមួយសម្រាប់ឱ្យពួកគេអាចបញ្ចេញកង្វល់ និងការមិនពេញចិត្តរបស់ខ្លួន។
- បង្កើតវេទិកាដែលភាគីពាក់ព័ន្ធ និងសមាជិកសហគមន៍អាចលើកឡើងដោយសេរីពីកង្វល់ និងបណ្តឹងនានាដែលត្រូវដោះស្រាយប្រកបដោយប្រសិទ្ធភាព។
- បង្ហាញដល់ភាគីពាក់ព័ន្ធរបស់គម្រោង និងសហគមន៍ថា ពួកគេមានតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំ និងការអនុវត្តគម្រោង។
- តាមដាន និងរាយការណ៍អំពីកិច្ចខិតខំប្រឹងប្រែងដើម្បីចាត់វិធានការកែតម្រូវ។

២៣៣. យន្តការបណ្តឹងតវ៉ាដែលបានស្នើឡើងនេះនឹងអនុវត្តតាមវិធីសាស្ត្រ GRM របស់ FAO ដូចដែលបានរៀបរាប់ខាងលើ និងនៅក្នុងយន្តការត្រួតពិនិត្យបណ្តឹងតវ៉ារបស់អង្គការ FAO នៅកម្ពុជា ដែលបច្ចុប្បន្នកំពុងត្រូវរៀបចំបញ្ចប់ ហើយនឹងដាក់ឱ្យអនុវត្ត នៅពាក់កណ្តាលឆ្នាំ២០២២ (សូមមើលសេចក្តីព្រាងកំណែនៅក្នុងឧបសម្ព័ន្ធទី ៤)។ ផ្អែកលើគោលការណ៍នៃសិទ្ធិអំណាចថ្នាក់កណ្តាល គម្រោងនេះនឹងព្យាយាមរកដំណោះស្រាយរាល់បណ្តឹងតវ៉ាជាដំបូងនៅកម្រិត អង្គភាពគ្រប់គ្រងគម្រោង (PMU)ជាមួយនឹងមន្ត្រីការពារសុវត្ថិភាពរបស់គម្រោងដែលកំពុងប្រតិបត្តិការជាជនបង្គោល ក្នុងការទទួល ចងក្រង ត្រួតពិនិត្យវាយតម្លៃ កត់ត្រា និងធ្វើការជាមួយសមាជិក អង្គភាពគ្រប់គ្រងគម្រោង (PMU)និងដៃគូផ្សេងៗទៀត ដើម្បីកំណត់ការឆ្លើយតបពាក់ព័ន្ធ។ វិធីសាស្ត្រនេះនឹងពឹងផ្អែកលើ និងភ្ជាប់ជាមួយនឹងវិធីសាស្ត្រប្រចាំការិយាល័យក្នុងប្រទេស ហើយអនុវត្តតាម និងអនុវត្តតាមពិធីការចម្រុះរួមមួយចំនួន មានជាអាទិ៍៖

ក. មធ្យោបាយនៃការទទួលបណ្តឹងតវ៉ា - យន្តការជាច្រើនរួមមាន អ៊ីមែល ទូរស័ព្ទ (រួមទាំងកម្មវិធីផ្ញើសារ) ជា លាយលក្ខណ៍អក្សរ ក៏ដូចជាដោយផ្ទាល់ នឹងត្រូវបានផ្តល់ព័ត៌មានច្បាស់លាស់ដល់ភាគីពាក់ព័ន្ធគម្រោងតាមរយៈមធ្យោបាយទាំងនេះ ក៏ដូចជាមធ្យោបាយទាក់ទងជាមួយមន្ត្រីទទួលបន្ទុកបណ្តឹងតវ៉ារបស់អង្គការ FAO ក្នុងប្រទេស និង/ឬ ការិយាល័យអធិការកិច្ច (OIG)ក៏ដូចជាការណែនាំអំពីពេលដែលចាំបាច់។

ខ. ការចងក្រងឯកសារនៃបណ្តឹងតវ៉ា - វិធីសាស្ត្រនេះនឹងអនុវត្តតាមទម្រង់ដូចគ្នានឹងទម្រង់របស់អង្គការ FAO ប្រចាំប្រទេស ដើម្បីធានាបានពីភាពច្បាស់លាស់ និងការបញ្ចូលក្នុងប្រព័ន្ធ។

គ. ការកំណត់ពេលវេលាសម្រាប់ពិនិត្យ និងឆ្លើយតបចំពោះបណ្តឹងតវ៉ា – រាល់បណ្តឹងតវ៉ាទាំងអស់នឹងត្រូវបានត្រួតពិនិត្យ និងទទួលស្គាល់ក្នុងរយៈពេលមួយសប្តាហ៍បន្ទាប់ពីទទួលបាន ដោយត្រូវធ្វើចំណាត់ការបន្ថែមទៀតដោយផ្អែកលើលក្ខណៈនៃបណ្តឹងតវ៉ា។

ឃ. ការត្រួតពិនិត្យវាយតម្លៃ – រាល់បណ្តឹងតវ៉ាទាំងអស់នឹងត្រូវបានពិនិត្យវាយតម្លៃ ដោយផ្អែកលើចំណាត់ថ្នាក់នៃវិធីសាស្ត្រ FAO GRM ទៅជាប្រភេទ ក (ទាប) ខ (មធ្យម) និង គ (ខ្ពស់) ដោយបណ្តឹងតវ៉ាមានហានិភ័យខ្ពស់ទាំងអស់ត្រូវបានរាយការណ៍ភ្លាមៗទៅអង្គការ FAO ប្រចាំប្រទេស ហើយនឹងត្រូវបានលើកបន្តទៀតទៅការិយាល័យអធិការកិច្ច (OIG)។ គួរកត់សម្គាល់ផងដែរថា ប្រព័ន្ធបច្ចុប្បន្នផ្តោតជាចម្បងលើបណ្តឹងតវ៉ាដែលទាក់ទងនឹង ESS។ ការចោទប្រកាន់ពីការក្លែងបន្លំផ្នែកហិរញ្ញវត្ថុ ការបំពានអំណាច អំពើពុករលួយ និងប្រភេទផ្សេងទៀតនៃការប្រព្រឹត្តខុសដោយបុគ្គលិករបស់អង្គការ FAO ឬដោយភាគីទីបីពាក់ព័ន្ធ នឹងត្រូវបានបញ្ជូនបន្តដោយផ្ទាល់ទៅ ការិយាល័យអធិការកិច្ច (OIG)ដើម្បីពិនិត្យ។

ង. ដំណើរការ - ផ្អែកលើចំណាត់ថ្នាក់ គម្រោងនឹងចាត់វិធានការដើម្បីដោះស្រាយបណ្តឹងតវ៉ា។

ច. មតិកែលម្អ – សកម្មភាពដែលបានអនុវត្ត/ស្នើឡើង នឹងត្រូវបញ្ជូនទៅអ្នកប្តឹង ដែលទទួលបានឱកាសសម្រាប់ចូលរួម និងការដោះស្រាយបន្ថែមទៀត ប្រសិនបើការដោះស្រាយទាំងនេះពុំមានលក្ខណៈគ្រប់គ្រាន់។ ប្រសិនបើអ្នកប្តឹងតវ៉ាយល់ឃើញថា ដំណោះស្រាយមានលក្ខណៈមិនគ្រប់គ្រាន់ទេនោះ ពួកគេអាចបញ្ជូនពាក្យបណ្តឹងដោយផ្ទាល់ទៅអង្គការ FAO ប្រចាំប្រទេស (តាមរយៈដំណើរការដែលមានចែងក្នុងឧបសម្ព័ន្ធទី ៤) ឬការបញ្ជូនបន្តទៅ ការិយាល័យអធិការកិច្ច (OIG)។

ធ. សេចក្តីសន្និដ្ឋាន - បន្ទាប់ពីបញ្ចប់ចំណាត់ការ កំណត់គ្រានានានឹងត្រូវបានធ្វើឡើង នៅគ្រប់ជំហានទាំងអស់ដែលបានធ្វើឡើង ហើយលទ្ធផលស្របតាមវិធីសាស្ត្រ GRM របស់អង្គការ FAO ប្រចាំប្រទេសកម្ពុជា។

២៣៤. មន្ត្រីការពារសុវត្ថិភាព និង អង្គភាពគ្រប់គ្រងគម្រោង(PMU)ក៏នឹងផ្តល់ព័ត៌មានបច្ចុប្បន្នភាពជាប្រចាំ (ប្រចាំត្រីមាស) ដល់មន្ត្រីត្រួតពិនិត្យបណ្តឹងតវ៉ាទាំងអស់ដែលបានលើកឡើង និងចំណាត់ការដើម្បីដោះស្រាយ។

២៣៥. ប្រការគួរឱ្យកត់សម្គាល់នោះគឺថា សេចក្តីព្រាងប្រព័ន្ធយន្តការបណ្តឹងតវ៉ា (GRM) បច្ចុប្បន្នដែលមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធមិនរួមបញ្ចូល ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)ជាក់លាក់ ការគ្រប់គ្រងបណ្តឹងតវ៉ាពាក់ព័ន្ធ និងមធ្យោបាយបញ្ជូន ករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ(GBV)ទេ។ ដូចនេះ ក្នុងដំណាក់កាលចាប់ផ្តើម គម្រោងនឹងសហការជាមួយអង្គការ FAO ប្រចាំប្រទេសកម្ពុជា ដើម្បីបញ្ចូលសមាសធាតុទាំងនេះទៅក្នុងប្រព័ន្ធ តាមរយៈការចាត់តាំងជនបង្គោល (រួមទាំងអ្នកជំនាញយេនឌ័រជាតិនៅក្នុងគម្រោងបច្ចុប្បន្ន) និងការ បណ្តុះបណ្តាលរបស់ពួកគេក្នុងបញ្ហា SEAH និង អំពើហិង្សាទាក់ទងនឹងយេនឌ័រ(GBV)ព្រមទាំងការរៀបចំបង្កើតវិធីសាស្ត្រក្នុងការរាយការណ៍ភ្លាមៗនូវបញ្ហាបែបនេះ ដើម្បីធានាថា បណ្តឹងតវ៉ាដែលបានលើកឡើង ត្រូវបានឆ្លងកាត់ខ្សែច្រវ៉ាក់ការរាយការណ៍ ហើយ ចំណាត់ការត្រូវបានធ្វើឡើងជាបន្ទាន់ ហើយថា បណ្តឹងតវ៉ាត្រូវបានគ្រប់គ្រងដោយវិធីសាស្ត្រចម្រុះ យកចិត្តទុកដាក់ដល់ជនរងគ្រោះ និងផ្តោតលើយេនឌ័រ និងការចូលរួមជាកាតព្វកិច្ចរបស់ FAO E&S និងអ្នកឯកទេសយេនឌ័រក្នុងការត្រួតពិនិត្យដំណើរការ។

២៣៦. នៅពេលចាប់ផ្តើមគម្រោង ការត្រួតពិនិត្យនឹងត្រូវបានធ្វើឡើងដើម្បីវាយតម្លៃថាតើវិធីសាស្ត្រខាងលើអាចត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធជាតិរបស់កម្ពុជាផ្ទាល់ (ដូចមានព័ត៌មានលម្អិតខាងក្រោម) ដើម្បីជួយគាំទ្រដល់ការពង្រឹងប្រព័ន្ធទាំងនេះ និងធ្វើឱ្យប្រព័ន្ធ យន្តការបណ្តឹងតវ៉ា (GRM)ងាយស្រួលបន្ថែមទៀតសម្រាប់អ្នកប្រើប្រាស់។ បើទោះការត្រួតពិនិត្យមានលទ្ធផលយ៉ាងណាក៏ដោយ ក៏គម្រោងនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយប្រព័ន្ធទាំងនេះ ដើម្បីធានាថា បណ្តឹងតវ៉ាពាក់ព័ន្ធណាមួយដែលបានលើកឡើង ត្រូវបានចុះបញ្ជីដោយគម្រោង និងចំណាត់ការត្រូវបានអនុវត្ត។

## ប្រព័ន្ធតវ៉ាថ្នាក់ជាតិ

២៣៧. ប្រព័ន្ធច្បាប់ផ្លូវការនៅក្នុងប្រទេសកម្ពុជាផ្តល់ឱ្យភ្នាក់ងាររដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន ស្ថាប័នតុលាការ និងសហគមន៍មូលដ្ឋាននូវទំនួលខុសត្រូវក្នុងការទទួលយកមតិកែលម្អ និងបណ្តឹងតវ៉ា។ ប្រព័ន្ធទាំងនេះត្រូវបានវាយតម្លៃថាជាផ្នែកមួយនៃដំណើរការអភិវឌ្ឍន៍ REDD+ (ដូចបង្ហាញក្នុងតារាងទី ៩) តាមរយៈគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ (NCCD) ប្រព័ន្ធ "ប្រអប់គណនេយ្យភាព" ដែលត្រូវបានចាត់ទុកថាមានការពាក់ព័ន្ធបំផុត។

២៣៨. យន្តការ GRM ឈានមុខនេះ រួមមានប្រអប់ទទួលមតិកែលម្អដែលមានទីតាំងនៅតាមឃុំ សង្កាត់នីមួយៗនៅទូទាំងប្រទេស។ ប្រជាពលរដ្ឋអាចដាក់ពាក្យបណ្តឹងអនាមិកអំពីប្រធានបទណាមួយទៅក្នុងប្រអប់នេះ។

២៣៩. តាមការការត្រួតពិនិត្យរបស់ NCCD ក្រុមការងារគណនេយ្យភាពខេត្តពិសេសមួយ (PAWG) បំពេញការងារតាមខេត្ត ដើម្បីទទួលពាក្យបណ្តឹងទាំងអស់ដែលប្រមូលបានតាមប្រអប់ និងចាត់វិធានការសមស្រប។ PAWG ដំណើរការជាអង្គភាពបញ្ជូនបណ្តឹងតវ៉ាពីរជំហានក្នុងខេត្តនីមួយៗ។ ជាដំបូង ខេត្តពិនិត្យមើលពាក្យបណ្តឹងនីមួយៗដែលខ្លួនទទួលបានដោយផ្ទាល់។ បន្ទាប់មក ខេត្តបញ្ជូនពាក្យបណ្តឹងទៅអង្គភាពថ្នាក់ខេត្ត/មូលដ្ឋានដែលមានយុត្តាធិការ និងផ្តល់ដំណោះស្រាយលើបញ្ហានេះ។

២៤០. ខណៈពេលដែលពាក្យបណ្ដឹងជាធម្មតាចាត់ទុកបញ្ហាដូចជាបញ្ហាទាក់ទងនឹងគម្រោង បណ្ដឹងប្រឆាំងនឹងមន្ត្រីរដ្ឋាភិបាល ឬក្រុមប្រឹក្សាឃុំ និងបញ្ហាក្នុងការផ្ដល់សេវាផ្សេងទៀត អាណត្តិរបស់ប្រអប់គណនេយ្យភាពមានលក្ខណៈទូលំទូលាយ ហើយអាចរួមបញ្ចូលសកម្មភាពរបស់គម្រោង។

២៤១. ស្ថិតិទាក់ទងនឹងបរិមាណនៃពាក្យបណ្ដឹងដែលបានទទួល និងព័ត៌មានជាក់លាក់បន្ថែមទៀតអំពីលក្ខណៈនៃបណ្ដឹងតវ៉ាដែលទទួលបាន គឺអាចរកបានតាមរយៈ NCDD។

២៤២. ប្រព័ន្ធបច្ចុប្បន្នក៏កំពុងត្រូវបានធ្វើបច្ចុប្បន្នភាព ដោយបានដាក់ចេញនូវ "សេវាកម្មច្រកចេញចូលតែមួយ" ថ្មីសម្រាប់សេវាកម្មថ្នាក់ខេត្ត និងស្រុក ដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរួមក្នុងការសម្រួលសេវាកម្មនៅកម្រិតមូលដ្ឋាន។

តារាងទី ៩. យន្តការបណ្ដឹងតវ៉ា ដំណោះស្រាយបណ្ដឹង និងការតវ៉ារបស់កម្ពុជា

| GRM ដែលមានស្រាប់នៅក្នុង PLR | ស្ថានភាពបច្ចុប្បន្ន | ស្ថានភាព និងសក្ដានុពលក្នុងការអនុវត្ត |
|---|---|---|
| គណៈកម្មាធិការជាតិដោះស្រាយទំនាស់ដីធ្លីក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ | ត្រូវបានបង្កើតឡើង ដោយផ្អែកតាមច្បាប់ស្ដីពីតំបន់ការពារធម្មជាតិឆ្នាំ ២០០៨ បច្ចុប្បន្នមិនទាន់ដំណើរការទេ។ | តំណាងយុត្តាធិការដ៏មានសក្ដានុពល និងការយកចិត្តទុកដាក់លើបច្ចេកទេស។ ទោះយ៉ាងណានេះក៏ដោយ បច្ចុប្បន្នមិនទាន់ដំណើរការនៅឡើយ។ |
| អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | បង្កើតឡើង ផ្អែកតាមអនុក្រឹត្យស្ដីពីសមាសភាពអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី លេខ១៦៨ (២០០៦) ប្រើប្រាស់ជាបណ្ដើរៗសម្រាប់ពេលច្រើនឆ្នាំ ប៉ុន្តែបច្ចុប្បន្នមិនដំណើរការទេ។ | យុត្តាធិការផ្ដោតលើទំនាស់ដីធ្លី - សក្ដានុពលសម្រាប់ប្រើប្រាស់ក្នុងគម្រោង ប៉ុន្តែមិនត្រូវបានកំណត់ជាអាទិភាព |
| សេវាកម្មជំនួយផ្នែកច្បាប់ដែលគ្រប់គ្រងដោយរដ្ឋាភិបាល | គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BAKC) ផ្ដល់សេវាកម្មជំនួយផ្នែកច្បាប់ ដោយផ្ដល់ថ្លៃសេវាដល់មេធាវីដែលបានជ្រើសរើសសម្រាប់សំណុំរឿងតំណាងឱ្យអតិថិជនក្រីក្រ។ ថវិកាប្រចាំឆ្នាំសរុបមានកម្រិតខ្វះខាត ហើយសំណុំរឿងមានទំនោរទៅរកបញ្ហាគ្រួសារ ទំនាស់តូចតាច និងរឿងព្រហ្មទណ្ឌ | កម្រិត និងវិសាលភាពនៃសេវាកម្មមានកម្រិតធ្វើឱ្យកម្មវិធីជំនួយផ្នែកច្បាប់ មិនអាចឆ្លើយតបនឹងតម្រូវការ REDD+។ |
| កម្មវិធីជំនួយផ្នែកច្បាប់ដែលដឹកនាំដោយអង្គការក្រៅរដ្ឋាភិបាល | អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងកិច្ចខិតខំប្រឹងប្រែងដែលទទួលជំនួយពីម្ចាស់ជំនួយ គាំទ្រសេវាកម្មផ្លូវច្បាប់លើបញ្ហាជាច្រើនចាប់ពីការការពារសិទ្ធិមនុស្សរហូតដល់តំណាងចុងចោទលើរឿងក្ដីព្រហ្មទណ្ឌ រហូតដល់សិទ្ធិកាន់កាប់ដីធ្លី | កម្រិតមូលនិធិមិនទៀតទាត់ និងការផ្លាស់ប្ដូរអាទិភាពពីសំណាក់ម្ចាស់ជំនួយធ្វើឱ្យលទ្ធភាពជោគជ័យមានភាពមិនប្រាកដប្រជា។ មេរៀនជាបទ |

| | | |
|---|---|---|
| | តាមការជ្រើសរើសមួយចំនួន និងសិទ្ធិជនជាតិដើមភាគតិច។ ការពឹងផ្អែកលើមូលនិធិពីខាងក្រៅធ្វើឱ្យបេសកកម្មយូរអង្វែងរបស់អង្គការទាំងនេះមានភាពមិនច្បាស់លាស់។ | ពិសោធ និងលទ្ធភាពក្នុងកិច្ចសហការគួរត្រូវបានសិក្សា និងអនុវត្ត។ |
| នីតិវិធីដោះស្រាយវិវាទរបស់រដ្ឋបាលព្រៃឈើ | បទល្មើសព្រៃឈើ ជាពិសេសអាចត្រូវបានបញ្ជូនទៅរដ្ឋបាលព្រៃឈើ។ មន្ត្រីនគរបាលយុត្តិធម៌នៅរដ្ឋបាលព្រៃឈើមានយុត្តាធិការស៊ើបអង្កេតលើបទល្មើសទាំងនោះ ហើយរៀបចំឯកសារ និងសំណុំរឿងទៅតុលាការ ដែលបន្ទាប់មកសម្រេចលើសំណុំរឿងទី។<br><br>ច្បាប់ស្តីពីព្រៃឈើ (២០០២) ក៏កំណត់ដំណើរការបណ្តឹងឧទ្ធរណ៍ ដែលបុគ្គលអាចប្តឹងឧទ្ធរណ៍ទៅប្រធានរដ្ឋបាលព្រៃឈើ ហើយប្រសិនបើសេចក្តីសម្រេចនៅតែមិនយល់ព្រម នោះអាចប្តឹងឧទ្ធរណ៍ទៅប្រព័ន្ធតុលាការសំណុំរឿង។ | ពាក់ព័ន្ធសម្រាប់សកម្មភាពនានានៅក្នុងសហគមន៍ព្រៃឈើ |
| ប្រព័ន្ធគណៈកម្មការសុរិយោដី | ២៤៣. **ច្បាប់ភូមិបាល (២០០១)** ដោះស្រាយវិវាទលើអចលនវត្ថុ។ វិវាទពាក់ព័ន្ធនឹងដីដែលមិនមានប័ណ្ណកម្មសិទ្ធិផ្លូវការ ត្រូវបានដោះស្រាយដោយគណៈកម្មការសុរិយោដី ដែលបង្កើតឡើងដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខណៈដែលតុលាការបើកសវនាការលើសំណុំរឿងវិវាទដីធ្លីដែលមានការចុះបញ្ជីជាផ្លូវការ។ | ការប្រើប្រាស់សក្តានុពលសម្រាប់គម្រោងក្នុងអនុសកម្មភាពជាក់លាក់ |
| គណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិច | គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច (២០០៩) បង្កើតគណៈកម្មាធិការសហគមន៍ដែលជាយន្តការសម្រាប់ដោះស្រាយវិវាទនៃវិវាទដីធ្លី ដែលបានកើតឡើងក្នុងសហគមន៍ដោយមានអាណត្តិថា រាល់វិវាទដីធ្លីក្នុងសហគមន៍ជនជាតិដើមភាគតិចត្រូវដោះស្រាយដោយគណៈកម្មាធិការសហគមន៍ និងយន្តការការសម្រេចចិត្តសហគមន៍។ ប្រសិនបើសហគមន៍ផ្សេងទៀតមានការពាក់ព័ន្ធនឹងវិវាទនោះ នីតិវិធីច្បាប់ត្រូវបានចែងក្នុងអនុក្រឹត្យស្តីពីគណៈកម្មាធិការចុះបញ្ជីដីធ្លី។ | យន្តការដោះស្រាយវិវាទសហគមន៍ជនជាតិដើមភាគតិចជាធម្មតាមានប្រសិទ្ធភាពខ្ពស់ក្នុងការដោះស្រាយបញ្ហាដែលកើតឡើងនៅក្នុងបរិបទសហគមន៍ជនជាតិដើមភាគតិច។ ទោះជាយ៉ាងណាក៏ដោយ យន្តការទាំងនេះមិនត្រូវបានប្រើប្រាស់ច្រើនឡើងសម្រាប់ដោះស្រាយវិវាទដែលបានកើតឡើងពីភាគីមកពីខាងក្រៅសហគមន៍ ដោយគម្រោងមានតួនាទីជាសក្តានុ |

| | | |
|---|---|---|
| | ប្រសិនបើវិវាទមិនអាចផ្សះផ្សាដោយគណៈកម្មាធិការសហគមន៍នោះ គណៈកម្មាធិការតម្រូវឱ្យបញ្ជូនវិវាទនោះទៅយន្តការដោះស្រាយវិវាទមួយផ្សេងទៀត ឬទៅតុលាការ។ គោលនយោបាយនេះក៏មានចែងពីស្ថាប័នពាក់ព័ន្ធត្រូវផ្តល់សេវាកម្មបកប្រែ ប្រសិនបើវិវាទដីធ្លីដែលបានទទួលពីគណៈកម្មការសហគមន៍ ហើយភាគីវិវាទមិនអាចនិយាយភាសាខ្មែរបាន។ ទោះជាយ៉ាងណាក៏ដោយ ជារួម ចំពោះវិវាទណាមួយដែលកើតឡើងនៅក្នុងសហគមន៍ជនជាតិដើមភាគតិចភាគីវិវាទអាចស្វែងរកដំណោះស្រាយពេញលេញនៅក្នុងថ្នាក់ដឹកនាំភូមិជាធម្មតា និងយន្តការដោះស្រាយវិវាទ។ | ពលក្នុងការបំពេញភារកិច្ចបែបនេះ។ |

*តារាងនេះដកស្រង់ចេញពីសេចក្តីថ្លែងការណ៍របស់ប្រទេសកម្ពុជាស្តីពីកម្មវិធីសន្តិសុខរ៉េដបូកដែលបានដាក់ជូន UNFCCC។*

## ការផ្សព្វផ្សាយស្តីពីការត្រួតពិនិត្យឡើងវិញលើបណ្តឹងតវ៉ា

២៤៤. ដោយសារថា យន្តការបណ្តឹងតវ៉ាត្រូវបានបង្កើតឡើង ដើម្បីផ្តល់វេទិកាសម្រាប់កង្វល់របស់ភាគីណាមួយនោះ វាជាប្រការសំខាន់ដែលថា វិធីសាស្ត្រដែលប្រើសម្រាប់បណ្តឹងតវ៉ា ត្រូវផ្សព្វផ្សាយយ៉ាងមានប្រសិទ្ធភាពដល់ភាគីពាក់ព័ន្ធ និងសមាជិកសហគមន៍ទាំងអស់នៅក្នុងតំបន់របស់គម្រោង។ ព័ត៌មានអំពីយន្តការដោះស្រាយបណ្តឹងតវ៉ា នឹងត្រូវផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធ និងសហគមន៍ទាំងអស់តាមរយៈ៖

- សិក្ខាសាលាចាប់ផ្តើមគម្រោង PEARL នៅថ្នាក់ជាតិ និងនៅតាមខេត្តទាំង៣ដែលជាកន្លែងអនុវត្តគម្រោង
- ព្រឹត្តិការណ៍ផ្សព្វផ្សាយព័ត៌មាន និងកិច្ចប្រជុំសហគមន៍ ក្នុងនោះរួមមានការផ្តល់ព័ត៌មានទាំងផ្ទាល់មាត់ និងតាមរយៈឯកសារព័ត៌មាន
- ខិត្តប័ណ្ណ/ប័ណ្ណផ្សព្វផ្សាយទាក់ទងនឹងយន្តការដោះស្រាយបណ្តឹងតវ៉ារបស់គម្រោង PEARL (រៀបចំឡើងជាភាសាខ្មែរ) ត្រូវចែកជូនភាគីពាក់ព័ន្ធទាំងអស់ ក្នុងនោះរួមទាំងអង្គការសង្គមស៊ីវិលនៅមូលដ្ឋាន និងថ្នាក់ខេត្ត
- គេហទំព័ររបស់អង្គការ FAO ប្រចាំប្រទេសកម្ពុជា
- ដាក់បញ្ចូលជាផ្នែកមួយនៃសម្ភារៈទំនាក់ទំនងដែលត្រូវបានរៀបចំ និងផ្សព្វផ្សាយក្នុងអំឡុងពេលអនុវត្តគម្រោង។

*តារាងទី 10. ទិដ្ឋភាពរួមនៃនីតិវិធីពិនិត្យបណ្តឹងតវ៉ា*

| ជំហាន | និតិវិធី |
|---|---|
| ១. ទទួល និងចុះបញ្ជី | ▪ អង្គការសហគមន៍ គ្រួសារ បុគ្គល ឬភាគីពាក់ព័ន្ធផ្សេងទៀត ក្នុងនោះរួមទាំងតាមរយៈប្រព័ន្ធគណនេយ្យភាព បញ្ជូនបណ្តឹងតវ៉ាទៅមន្រ្តីការពារសុវត្ថិភា អង្គភាពគ្រប់គ្រងគម្រោង(PMU)និងមន្រ្តីគាំទ្រនៅក្នុង អង្គភាពគ្រប់គ្រងគម្រោង(PMU)។<br>▪ មន្រ្តីការពារសុវត្ថិភាពនឹងទទួលបណ្តឹងតវ៉ា ឬមតិកែលម្អតាម រយៈទូរស័ព្ទ/សារអេឡិចត្រូនិក មតិកែលម្អ/ប្រអប់ដាក់បណ្តឹងតវ៉ា ឬទម្រង់សរសេរ ឬផ្ទាល់មាត់ផ្សេងទៀត។ |
| ២. ទទួលស្គាល់ ពិនិត្យ វាយតម្លៃ និងចាត់តាំង | ▪ អ្នកជំនាញ M&R របស់ អង្គភាពគ្រប់គ្រងគម្រោង(PMU)នឹងពិនិត្យបណ្តឹងតវ៉ានីមួយៗ ដើម្បីធានាពីភាពអាចទទួលយកបាន ហើយនឹងចាត់បុគ្គលិកឱ្យវាយតម្លៃ និងស៊ើបអង្កេតបណ្តឹងតវ៉ា ឬបញ្ជូនបណ្តឹងតវ៉ាទៅស្ថាប័នកម្រិតខ្ពស់ ប្រសិនបើមានភាពស្មុគស្មាញពេកក្នុងការដោះស្រាយនៅកម្រិតរៀងៗខ្លួន។<br>▪ មន្រ្តីដែលទទួលខុសត្រូវលើការស៊ើបអង្កេត និងដោះស្រាយបណ្តឹងតវ៉ា រៀបចំ និងបង្ហាញរបាយការណ៍អំពីបណ្តឹងតវ៉ា ដោយលើកឡើងពីជម្រើសដំណោះស្រាយដែលអាចទទួលយកបាន។ |
| ៣. ឆ្លើយតប និងដំណោះស្រាយ | ▪ អ្នកជំនាញ M&R របស់ PMU ស្នើសុំជម្រើសដើម្បីដោះស្រាយបណ្តឹងតវ៉ាសម្រាប់អ្នកប្តឹងតវ៉ា និងភាគីពាក់ព័ន្ធផ្សេងទៀតដើម្បីទទួលបានកិច្ចព្រមព្រៀង។ |
| ៤. អនុវត្ត និងត្រួតពិនិត្យ | ▪ អ្នកជំនាញ M&R របស់ PMU ស្នើសុំឱ្យអនុវត្តជម្រើសដែលបានព្រមព្រៀងលើដំណោះស្រាយ ហើយរួមទាំងជាតុចូលពីមន្រ្តី PMU ផ្សេងទៀត ចាត់តាំងមន្រ្តីពាក់ព័ន្ធដើម្បីតាមដានវឌ្ឍនភាព និងប្រសិទ្ធភាពនៃការអនុវត្ត។ |
| ៥. រាយការណ៍ | ▪ អ្នកឯកទេសពី M&R របស់ PMU រៀបចំរបាយការណ៍មួយដោយផ្អែកលើទម្រង់គំរូមានបទដ្ឋាន និងលើស្ថានភាពនៃ បណ្តឹងតវ៉ាទាំងអស់។ បន្ទាប់មករបាយការណ៍នេះត្រូវបញ្ជូនទៅនាយកគម្រោងថ្នាក់ជាតិ (NPD) និងមន្រ្តីការពារសុវត្ថិភាពរបស់ អង្គភាពគ្រប់គ្រងគម្រោង(PMU)។<br>▪ របាយការណ៍នេះនឹងផ្សព្វផ្សាយលើគេហទំព័រផ្លូវការដើម្បីឱ្យសាធារណជនចូលមើល និងអានបាន។ |

## ការពិនិត្យបណ្តឹងតវ៉ាក្រៅផ្លូវការ និងផ្អែកតាមទំនៀមទម្លាប់

២៤៥. ទម្លាប់អនុវត្តផ្អែកតាមទំនៀមទម្លាប់របស់ក្រុមសហគមន៍ ជនជាតិដើមភាគតិច និងក្រុមសាសនាផ្សេងៗគ្នា ដើម្បីគ្រប់គ្រងជម្លោះក៏នឹងត្រូវដាក់បញ្ចូលទៅក្នុងយន្តការដោះស្រាយបណ្តឹងតវ៉ាជាផ្លូវការផងដែរ។ ក្នុងករណីជាច្រើន ករណីបណ្តឹងតវ៉ាត្រូវបានដោះស្រាយក្រៅផ្លូវការដោយសហគមន៍មូលដ្ឋាន ក្រោមការដឹកនាំរបស់សហគមន៍ ឬអ្នកដឹកនាំប្រពៃណី។ អ្នកជំនាញ M&R នឹងពិចារណាលើយោបល់ ឬអនុសាសន៍របស់អ្នកដឹកនាំអំពីយន្តការដោះស្រាយក្រៅផ្លូវការណាមួយ មុនពេល ធ្វើការសម្រេចណាមួយ។

## ដំណោះស្រាយ

២៤៦. នៅពេលបណ្តឹងតវ៉ាត្រូវបានដោះស្រាយ ហើយភាគីដែលដាក់បណ្តឹងតវ៉ាព្រមទទួលយកដំណោះស្រាយនោះ កិច្ចព្រមព្រៀងមួយត្រូវបានរៀបចំឡើងដោយការចុះហត្ថលេខាពីភាគីពាក់ព័ន្ធទាំងអស់។ កំណត់ហេតុនៃបណ្តឹងតវ៉ាទាំងអស់ដែលបានធ្វើ និងបានដោះស្រាយ គួរតែរក្សាទុក ដើម្បីធានាដល់ការអនុវត្តតាមជាបន្ត និងធានាឱ្យមានយន្តការពិនិត្យបណ្តឹងតវ៉ាប្រកបដោយតម្លាភាព។

# ៨. ជនជាតិដើមភាគតិច និងក្របខ័ណ្ឌរៀបចំផែនការបរិយាប័ន្នសង្គម

## ៨.១ ជនជាតិដើមភាគតិច និងក្របខ័ណ្ឌរៀបចំផែនការបរិយាប័ន្នសង្គម

២៤៧. ក្របខ័ណ្ឌផែនការបរិយាប័ន្នសង្គមរបស់ជនជាតិដើមភាគតិច និងសង្គម (IPSIPF) នឹងត្រូវអនុវត្ត នៅគ្រប់ទីតាំងទាំងអស់នៅក្នុងតំបន់អនុវត្តគម្រោង។

២៤៨. នៅក្នុងតំបន់អនុវត្តគម្រោង ក្រុមគោលដៅ ក្នុងនោះរួមទាំងក្រុមសមាគមកសិករ ក្រុមសហគមន៍តំបន់ការពារធម្មជាតិ និងក្រុមសហគមន៍ព្រៃឈើ រួមមានសមាជិកជាបុរស និងស្ត្រីមានសាវតារវប្បធម៌ សង្គម ជាតិពន្ធចម្រុះ និងរួមទាំងសមាជិកមកនៃក្រុមជនជាតិដើមភាគតិច[11]។ ដូច្នេះ ការធ្វើបរិយាប័ន្នសង្គម និងការការពារសិទ្ធិជនជាតិដើមភាគតិច និងសហគមន៍ទទួលបានការយកចិត្តទុកដាក់តិចតួច/មិនយកចិត្តទុកដាក់សោះផ្សេងៗទៀតត្រូវតែបានយកចិត្តទុកដាក់នៅគ្រប់សកម្មភាពទាំងអស់របស់គម្រោង ហើយត្រូវបានត្រួតពិនិត្យ ជាទម្រង់ការឆ្លើយតប និងបុរេសកម្ម។

២៤៩. ដោយអនុវត្តតាមក្របខ័ណ្ឌច្បាប់អន្តរជាតិពាក់ព័ន្ធ គោលនយោបាយរបស់អង្គការ FAO ស្តីពីជនជាតិដើមភាគតិច និងកុលសម្ព័ន្ធ និងគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងបរិស្ថាន និងសង្គមរបស់អង្គការ FAO ក៏ដូចជាគោលនយោបាយរបស់ GCF ស្តីពីជនជាតិដើមនោះ ក្របខ័ណ្ឌរៀបចំផែនការខាងក្រោមស្តីពីជនជាតិដើមភាគតិច និងបរិយាប័ន្នសង្គមត្រូវបានបង្កើតឡើង ដើម្បីធានាឱ្យមានការខិតខំប្រឹងប្រែងសមស្របដើម្បីគោរព ដាក់បញ្ចូល និងយកចិត្តទុកដាក់លើបញ្ហាសំខាន់ៗដែលមានភាពចាំបាច់សម្រាប់ជនជាតិដើមភាគតិច ក្រុមងាយរងគ្រោះ និង/ឬក្រុមដែលមិនទទួលបានការយកចិត្តទុកដាក់ក្នុងសង្គម ក្នុងអំឡុងពេលអនុវត្តគម្រោង ក្នុងនោះរួមទាំងសិទ្ធិរបស់ពួកគេក្នុងការយល់ព្រមដោយសេរី ជាមុន និងផ្អែកលើព័ត៌មានគ្រប់គ្រាន់ (FPIC)។ ក្របខ័ណ្ឌនេះនឹងក្លាយជាមូលដ្ឋានគ្រឹះសម្រាប់បញ្ចូលជនជាតិដើមភាគតិច និងក្រុមងាយរងគ្រោះ និង/ឬមិនទទួលបានការយកចិត្តទុកដាក់ក្នុងសង្គម ជាភាគីពាក់ព័ន្ធរបស់គម្រោង ជំរុញកិច្ចពិគ្រោះយោបល់ និងការប្រាស្រ័យទាក់ទងជាប្រចាំ ក្នុងពេញមួយជីវិតរបស់គម្រោង បង្កើតយន្តការទទួលមតិកែលម្អនិងបណ្តឹងតវ៉ា បញ្ជាក់ឱ្យកាន់តែច្បាស់ពីពីការរៀបចំការត្រួតពិនិត្យ និងការវាយតម្លៃ លើកកម្ពស់វិធានការដើម្បីបន្ថយជាអតិបរិមា និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន និងធានាថា សកម្មភាពទាំងអស់របស់គម្រោងត្រូវបានអនុវត្តឱ្យបានសមស្របតាមទំនៀមទម្លាប់ប្រពៃណីនៃក្រុមនីមួយៗ។

### ៨.១.១ ព័ត៌មានជាមូលដ្ឋាន

#### ៨.១.១.១ ជនជាតិដើមភាគតិចនៅកម្ពុជា

២៥០. ចំនួនប្រជាជនកម្ពុជាភាគច្រើន (ជាង ៩០%) គឺជាជនជាតិខ្មែរ ហើយប្រជាជននៅសល់គឺជាជាជនជាតិភាគតិចវៀតណាម (៥%) ជនជាតិចិន ចាម (ភាគច្រើនជាជនជាតិឥស្លាម) និងជនជាតិដើមភាគតិច ដោយពេលខ្លះហៅថាខ្មែរលើ។

២៥១. ក្រុមជនជាតិដើមភាគតិចសរុបចំនួន ២៤ ក្រុម ត្រូវបានទទួលស្គាល់ជាទូទៅថាមានវត្តមាននៅក្នុងប្រទេសកម្ពុជា ទោះបីជាពុំមានការកំណត់ច្បាស់លាស់ពីភាពខុសគ្នាជាច្រើននៃក្រុមទាំងនេះក៏ដោយ។ ក្រុមជនជាតិដើមភាគតិចទាំងនេះត្រូវបានប៉ាន់ប្រមាណថាមានប្រហែល ១៨៤.000 នាក់ និងមានចំនួនប្រមាណជា ១,២៥ ភាគរយ

[11] The project will utilise the guidance within the GCF policy on IP along with national protocols to clarify the identification of IP groups within the target areas during early project implementation.

នៃប្រជាជនទាំងអស់។ ក្រុមជនជាតិដើមភាគតិចមានសមាជិកពី ១០០ ទៅ ១៩.០០០ នាក់ រួមមាន ព្នង កួយ មិល ក្រោល ថ្មូន ខោញ ទំពួន ចារាយ គ្រឹង ការ៉ែត សួយ លុន កាចក់ ព្រៅ និងស្ទៀង។

២៥២. កុលសម្ព័ន្ធព្រៃភ្នំរស់នៅសំខាន់តាមតំបន់ភ្នំជាប់ស្រយាលភាគឦសាននៃខេត្តរតនគិរី និងមណ្ឌលគិរី និងតំបន់ភ្នំនៃខេត្តកោះកុងស្ថិតនៅភាគនិរតីនៃប្រទេស។ ភាសារបស់ជនជាតិដើមភាគតិចនេះមានភាសាសំខាន់ៗចំនួនពីរ គឺខ្មែរ-មន និងភាសាម៉ាឡេយ៉ូ-ប៉ូលីនេស៊ី។ សហគមន៍ជនជាតិដើមភាគតិចធំជាងគេបំផុតក្នុងប្រទេសគឺ កួយ ព្នង ស្ទៀង ប្រាវ ទំពួន ព័រ ចារាយ និងរដែ។ ក្រុមទាំងនេះភាគច្រើនអនុវត្តកសិកម្មពនេចរ ហើយពួកគេភាគច្រើនបានរក្សាទំនៀមទម្លាប់ប្រពៃណីសាសនាតាមតំបន់របស់គេរៀងៗខ្លួន។

២៥៣. ជីវភាពរស់នៅរបស់ជនជាតិដើមភាគតិចដាច់ស្រយាល និងជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា មានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងដីធ្លី និងការប្រើប្រាស់ធនធានធម្មជាតិ ទោះជាយ៉ាងនេះក្តី ការអនុវត្តជាក់ស្តែងមានលក្ខណៈខុសគ្នាពីក្រុមមួយទៅក្រុមមួយទៀត។ សកម្មភាពទាំងនេះអាចមានការកាប់ឈើ ការកាប់ឆ្ការ ដុតព្រៃ និងតំបន់ដីសើមដើម្បីដាំបន្លែផ្លែឈើ ដើម្បីទ្រទ្រង់ជីវភាពរស់នៅ ការធ្វើនេសាទ (ទាំងសម្រាប់ចិញ្ចឹមជីវិត និងពាណិជ្ជកម្ម) ការបរបាញ់សត្វព្រៃ ការចិញ្ចឹមសត្វ ការផលិតធ្យូង ការប្រមូលផលិតផល/អនុផលព្រៃឈើ និងការប្រមូលឈើរសាត់តាមទឹក។ សហគមន៍ជនជាតិដើមភាគតិចមានចំណេះដឹង និងការអនុវត្តសំខាន់ៗយ៉ាងច្រើនច្រើននៅតាមមូលដ្ឋាន ដែលមនុស្សពីខាងក្រៅមិនអាចមើលឃើញ។

២៥៤. ក្រុមជនជាតិដើមភាគតិច និងក្រុមជនជាតិភាគតិចដទៃទៀត នៅតាមទីតាំងយ៉ាងច្រើនបានរងផលប៉ះពាល់ខ្លាំងបំផុត ពីការប្រែប្រួលបរិស្ថាន និងការផ្លាស់ប្តូរទម្រង់នៃការប្រើប្រាស់ដីធ្លី។ ជនជាតិដើមភាគតិចជាច្រើនក្រុមពុំមានសិទ្ធិកាន់កាប់ដីធ្លីដោយសុវត្ថិភាពទេ ហើយបានប្រឈមមុខនឹងបញ្ហាដែលទាក់ទងនឹងសកម្មភាពអភិវឌ្ឍន៍ ដូចជាសម្បទានដីសេដ្ឋកិច្ច (ELC) ជាដើម។

២៥៥. បើទោះបីក្រុមជនជាតិដើមភាគតិចភាគច្រើនចេះនិយាយភាសាខ្មែរក៏ដោយ ក៏ភាសានេះអាចជាភាសាទីពីរ ឬទីបីរបស់ពួកគេដែរ ហើយមានជាប់ពាក់ព័ន្ធនឹងបញ្ហាប្រឈមក្នុងទទួលបានការសិក្សារៀនសូត្រក្នុងសាលានៅតំបន់ជនបទ។ ក្រុមជនជាតិដើមភាគតិច និងក្រុមជនជាតិភាគតិចផ្សេងទៀតក៏បានទទួលការយកចិត្តទុកដាក់តិចតួចបំផុតក្នុងសង្គម ដោយសារតែគម្លាតនៃការទទួលបានព័ត៌មាន និង/ឬមានសមត្ថភាព ក្នុងការតទល់នឹងវិសមភាព ឬសកម្មភាពខុសច្បាប់ក្នុងទឹកដីរបស់ខ្លួន។

### ៨.១.១.២ លិខិតបទដ្ឋានគតិយុត្តស្តីពីជនជាតិដើមភាគតិចនៅកម្ពុជា

២៥៦. លិខិតបទដ្ឋានគតិយុត្តសំខាន់ៗចំនួនដែលបានដាក់ឱ្យអនុវត្តទទួលស្គាល់សិទ្ធិរបស់របស់ជនជាតិដើមភាគតិច និងក្រុមងាយរងគ្រោះផ្សេងទៀតផងដែរ។ លិខិតបទដ្ឋានគតិយុត្តទាំងនេះរួមមាន[12]៖

២៥៧. **គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច៖** អនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រី នៅថ្ងៃទី ២៤ ខែមេសា ឆ្នាំ ២០០៩ និងកំណត់ពីគោលនយោបាយរបស់រដ្ឋាភិបាលទាក់ទងនឹងជនជាតិដើមភាគតិចលើវិស័យវប្បធម៌ ការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ សុខាភិបាល បរិស្ថាន ដីធ្លី កសិកម្ម ធនធានទឹក ហេដ្ឋារចនា

---

[12] Text adapted from – Cambodia Sustainable Landscape and Eco-tourism project (CSLEP), Indigenous Peoples Planning Framework (2019)– available at https://documents1.worldbank.org/curated/fr/100851548911249934/Indigenous-Peoples-Planning-Framework.pdf

សម្ព័ន្ធ យុត្តិធម៌ ទេសចរណ៍ និងឧស្សាហកម្ម រ៉ែ និងថាមពល។ រួមជាមួយនឹងច្បាប់ភូមិបាល (២០០១) គោលនយោបាយនេះទទួលស្គាល់សិទ្ធិជនជាតិដើមភាគតិចពាក់ព័ន្ធនឹងដីធ្លីជាប្រពៃណី វប្បធម៌ និងទំនៀមទម្លាប់។

២៥៨. **គោលនយោបាយស្តីពីការចុះបញ្ជី និងសិទ្ធិប្រើប្រាស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា**ត្រូវបានអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រីនៅថ្ងៃទី ២៤ ខែមេសា ឆ្នាំ ២០០៩ ហើយអនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចត្រូវបានចុះហត្ថលេខានៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៩ ដោយនាយករដ្ឋមន្ត្រី។ គោលនយោបាយនេះត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការទទួលស្គាល់នៅក្នុងច្បាប់ភូមិបាលឆ្នាំ ២០០១ អំពីសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងការកាន់កាប់ និងប្រើប្រាស់ដីជាកម្មសិទ្ធិសមូហភាពរបស់ពួកគេ។

២៥៩. **រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣)** គាំទ្រសិទ្ធិទទួលបានការអប់រំ ការអប់រំសម្រាប់ទាំងអស់គ្នា និងការអប់រំជាមូលដ្ឋានរយៈពេល ៩ ឆ្នាំ (មាត្រា ៦៥, ៦៦, ៦៧ និង ៦៨)។ មាត្រា ៤៨ ចែងថា "រដ្ឋការពារសិទ្ធិកុមារ ដូចមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិរស់រានមានជីវិត ទទួលបានការអប់រំ ការការពារក្នុងសម័យសង្គ្រាម និងពីការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច ឬផ្លូវភេទ។ មាត្រា ៤៦ ចែងថា "រដ្ឋ និងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនារី ជាពិសេសនារីនៅជនបទដែលគ្មានគ្មានទីពឹង បានទទួលការឧបត្ថម្ភ ដើម្បីមុខរបរ មានលទ្ធភាពព្យាបាលជំងឺ ឱ្យកូនទៅរៀន និងមានជីវភាពសមរម្យ"។ មាត្រា ៣១.២ ចែងថា "ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ"។ មាត្រា ៤៤ ធានាសិទ្ធិស្របច្បាប់ក្នុងការកាន់កាប់ដីធ្លីស្មើភាពគ្នាសម្រាប់ប្រជាពលរដ្ឋខ្មែរគ្រប់រូប "ជនណាក៏ដោយ ទោះជាបុគ្គលក្តី ឬជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិម្ចាស់កម្មសិទ្ធិលើដីធ្លី"។

២៦០. ច្បាប់ស្តីពីការអប់រំត្រូវបានអនុម័តដោយរដ្ឋសភានៅថ្ងៃទី១៩ ខែតុលា ឆ្នាំ ២០០៧ ដោយមានគោលបំណងអភិវឌ្ឍធនធានមនុស្សដោយផ្តល់ការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ដើម្បីឱ្យអ្នកសិក្សាឱ្យទទួលបាននូវចំណេះដឹង ជំនាញ សមត្ថភាព សេចក្តីថ្លៃថ្នូរ អាកប្បកិរិយាប្រកបដោយសីលធម៌ សំដៅជំរុញឱ្យអ្នកសិក្សាស្គាល់ស្រឡាញ់ រួមចំណែកការពារអត្តសញ្ញាណជាតិ វប្បធម៌ជាតិ និងភាសាជាតិ។

២៦១. **ច្បាប់ភូមិបាលឆ្នាំ ២០០១** ទទួលស្គាល់សិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជាក្នុងការកាន់កាប់អចលនវត្ថុ ដីរបស់ពួកគេ ដោយមានប័ណ្ណសម្គាល់កម្មសិទ្ធិសមូហភាព។ មាត្រា ២៣ ក្នុងច្បាប់កំណត់សហគមន៍ជនជាតិដើមភាគតិចដូចជា៖

- សមាជិកទាំងអស់បង្ហាញនូវការឯកភាពជាតិពន្ធុ សង្គមវប្បធម៌ និងសេដ្ឋកិច្ច
- ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និង
- ដាំដុះលើដីដែលខ្លួនកាន់កាប់ ទៅតាមក្បួនខ្នាតទំនៀមទម្លាប់នៃការប្រើប្រាស់ជាសមូហភាព។

២៦២. **មាត្រា ២៥ នៃច្បាប់នេះកំណត់ពីដីសហគមន៍ជនជាតិដើមភាគតិច៖** "ដីសហគមន៍ជនជាតិដើមភាគតិចគឺជាដីទាំងអស់ដែលសហគមន៍បានរៀបចំនិវេសនដ្ឋាន និងប្រកបរបរកសិកម្មប្រពៃណី" ហើយដីទាំងនេះ "រួមបញ្ចូលមិនត្រឹមតែដីដែលបានដាំដុះដាក់ស្តែងនោះទេ ប៉ុន្តែមានដីបំរុងចាំបាច់ក្នុងការដូរវេនដំណាំថែមទៀតដែលតម្រូវទៅតាមរបៀបទាញយកផលដែលធ្លាប់ធ្វើកន្លងមក ហើយត្រូវបានទទួលស្គាល់ដោយអាជ្ញាធររដ្ឋបាល"។ មាត្រា ២៥ ក៏ចែងថា "ការវាស់វែង និងការកំណត់ព្រំប្រទល់នៃអចលនវត្ថុរបស់សហគមន៍ទាំងនេះ ត្រូវកំណត់ទៅតាមស្ថានភាព

ដាក់ស្តែង ដូចដែលបានអះអាងដោយសហគមន៍ ដោយមានការព្រមព្រៀងពីអ្នកជិតខាង៉។ មាត្រា ២៦ ចែងថា ៉កម្មសិទ្ធិនៃអចលនវត្ថុដែលមានចែងក្នុងមាត្រា ២៥ ត្រូវបានផ្តល់ដោយរដ្ឋជូនសហគមន៍ជនជាតិដើមភាគតិចជាកម្មសិទ្ធិសមូហភាព។ កម្មសិទ្ធិសមូហភាពរួមមានរាល់សិទ្ធិ និងការការពារកម្មសិទ្ធិ ដូចកម្មសិទ្ធិឯកជនដែរ៉។

២៦៣. ទោះបីជាច្បាប់នេះផ្តល់មូលដ្ឋានរឹងមាំសម្រាប់ប័ណ្ណកម្មសិទ្ធិសហគមន៍ជនជាតិដើមភាគតិចក៏ដោយ ក៏ប្រការគួរឱ្យកត់សម្គាល់ថា តាមរបាយការណ៍ ក្នុងងចំណោមសហគមន៍ជនជាតិដើមភាគតិចជាង ៤៥៥ សហគមន៍នៅកម្ពុជា សហគមន៍តែ ៣៣ ប៉ុណ្ណោះទទួលបានប័ណ្ណកម្មសិទ្ធិបែបនេះក្នុងរយៈពេល ២០ ឆ្នាំចាប់តាំងពីច្បាប់ភូមិបាលបានអនុម័ត[13]។

២៦៤. **ច្បាប់ស្តីពីព្រៃឈើឆ្នាំ ២០០២** (មាត្រា ១១, ១៥, ១៦, ៤០) ធានា និងទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការបន្តការប្រើប្រាស់ និងក្នុងការចេញ-ចូលតំបន់ព្រៃមួយចំនួនដែលក្រុមទាំងនេះប្រើប្រាស់ជាប្រពៃណី និងអនុវត្តរបៀបរស់នៅរបស់ខ្លួន តាមរយៈការទទួលបានផលប្រយោជន៍ពីព្រៃឈើ។ ខណៈពេលដែលច្បាប់ស្តីពីព្រៃឈើចែងពីមូលដ្ឋានច្បាប់សម្រាប់សហគមន៍ព្រៃឈើ ក៏អនុក្រឹត្យឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើកំណត់វិធានក្នុងការបង្កើត គ្រប់គ្រង និងការប្រើប្រាស់ព្រៃឈើទាំងនេះនៅក្នុងប្រទេសកម្ពុជា។

២៦៥. **ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (២០០៨)** កំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ការពារធម្មជាតិ។ គោលបំណងនៃច្បាប់គឺធានានូវការគ្រប់គ្រង ការអភិរក្សជីវៈចម្រុះ និងការធានាការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ ច្បាប់នេះទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមភាគតិចដែលពឹងអាស្រ័យព្រៃឈើ និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងរស់នៅក្នុងតំបន់ការពារធម្មជាតិ។ ច្បាប់នេះធ្វើការបែងចែកតំបន់ការពារធម្មជាតិជាបួនតំបន់ដែលកំណត់ពីការប្រើប្រាស់ និងការគ្រប់គ្រងដីតាមតំបន់ជាក់លាក់នោះ។ តំបន់ទាំងបួនរួមមានតំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍។ ច្បាប់នេះស្ថិតនៅក្រោមយុត្តាធិការរបស់ក្រសួងបរិស្ថាន។ វិសោធនកម្មឆ្នាំ ២០១៧ ក៏មានចែងពីការបង្កើតសហគមន៍តំបន់ការពារធម្មជាតិដែលជាយន្តការមួយផ្សេងទៀតដែលតាមរយៈយន្តការនេះ សហគមន៍អាចមានសិទ្ធិក្នុងប្រើប្រាស់ដី និងធនធានរបស់ខ្លួន និងរក្សាតួនាទីអភិបាលកិច្ចរបស់ខ្លួន។

២៦៦. នៅតាមផ្នែកផ្សេងៗទៀតនៃច្បាប់ជាធរមាននោះ និយមន័យជាច្រើនក៏ត្រូវបានបង្កើតឡើងផងដែរសម្រាប់ក្រុម ជនជាតិដើមភាគតិច។ ច្បាប់ភូមិបាល (២០០១) កំណត់សហគមន៍ជនជាតិដើមភាគតិចថាជា ៉ក្រុមមនុស្សដែលមករស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធ សង្គមវប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណីនិងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទំលាប់នៃការប្រើប្រាស់ជាសមូហភាព៉។ ច្បាប់ស្តីពីព្រៃឈើ (២០០២) ក៏កំណត់និយមន័យនៃសហគមន៍មូលដ្ឋានថាជាសហគមន៍ជនជាតិដើមភាគតិច ឬក្រុមអ្នកស្រុកដែលមានលំនៅដើមកំណើតក្នុងភូមិមួយ ឬច្រើនស្ថិតនៅក្នុង ឬក្បែរតំបន់ព្រៃឈើរដ្ឋដែលមានប្រពៃទំនៀមទំលាប់ ជំនឿសាសនា វប្បធម៌ និងរស់នៅចិញ្ចឹមជីវិតដោយពឹងអាស្រ័យទៅលើការរុករកផល-អនុផលព្រៃឈើ និងប្រើប្រាស់ធនធានព្រៃឈើទាំងនេះជាមូលដ្ឋាន។ ច្បាប់នេះក៏កំណត់ "សហគមន៍" ថាជាក្រុមអ្នកស្រុករស់នៅក្នុងភូមិមួយ ឬច្រើនក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានការចាប់អារម្មណ៍រួមលើបញ្ហាសង្គម វប្បធម៌ ប្រពៃណី និងសេដ្ឋកិច្ចក្នុងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាពនៃតំបន់មួយដែលពួកគាត់រស់នៅក្នុង ឬក្បែរតំបន់នោះ ក្នុងគោលបំណងចិញ្ចឹមជីវិត និងកែលំអជីវភាពរស់

[13] Data from Open Development Mekong - https://data.opendevelopmentmekong.net/library_record/access-to-collective-land-titles-for-indigenous-communities-in-cambodia - accessed March 2022

នៅ។ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (២០០៨) កំណត់ "ជនជាតិដើមភាគតិច" ជាអ្នកស្រុកដើមដែលរស់នៅតំបន់ភ្នំ ភាគច្រើនចិញ្ចឹមជីវិតដោយប្រព័ន្ធកសិកម្មពនេចរ និងប្រកបរបរបន្ថែមផ្សេងទៀត ដូចជាការបរបាញ់ ការនេសាទ និងការប្រមូលផល អនុផលធនធានធម្មជាតិជាដើម។ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច (២០០៩) ក៏ចែងថា ជនជាតិដើមភាគតិច គឺជាតិពន្ធុដែលរស់នៅក្នុងប្រទេសកម្ពុជាតាំងពីដើមរៀងមក ហើយមានភាសា វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណីរបស់ខ្លួនខុសពីជនជាតិខ្មែរដែលជាប្រជាជាតិស្នូល។

២៦៧. នៅកម្រិតអន្តរជាតិ កម្ពុជាជាភាគីនៃសន្ធិសញ្ញាសិទ្ធិមនុស្សស្នូលចំនួន៨ ក្នុងចំណោមសន្ធិសញ្ញាសិទ្ធិមនុស្សស្នូលទាំង ៩[14]៖

- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ICESCR)
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)
- អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (ICERD)
- អនុសញ្ញាស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW)
- អនុសញ្ញាប្រឆាំងនឹងការដាក់ទោស និងការធ្វើទារុណកម្មឃោរឃៅ អមនុស្សធម៌ ឬថោកទាបផ្សេងទៀត ឬការផ្តន្ទាទោស (CAT)
- អនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC)
- អនុសញ្ញាស្តីពីសិទ្ធិជនពិការ (CRDP)
- អនុសញ្ញាសម្រាប់ការការពារមនុស្សទាំងអស់ពីការបាត់ខ្លួនដោយបង្ខំ (CED)។

២៦៨. ប្រទេសកម្ពុជាក៏បានផ្តល់សច្ចាប័នលើពិធីសារជម្រើសចំនួននៃសន្ធិសញ្ញាទាំងនេះដែលកំណត់ឱ្យមានកាតព្វកិច្ចបន្ថែមលើរដ្ឋាភិបាល៖ ពិធីសារជម្រើសនៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម (OPCAT) ពិធីសារជម្រើសនៃអនុសញ្ញា CEDAW (OP-CEDAW) និងពិធីសារជម្រើសចំនួនពីរទៀតនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ក្នុងការដោះស្រាយជាមួយទាហានកុមារ និងការកេងប្រវ័ញ្ចកុមារ (CRC-OPAC និង CRC-OPSC)។

២៦៩. ការអនុវត្តសន្ធិសញ្ញាទាំងនេះនៅកម្ពុជាត្រូវបានធានាក្នុងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញប្រទេសកម្ពុជា។ នៅឆ្នាំ ២០០៧ បន្ទាប់ពីបានទទួលញត្តិពីអង្គការសិទ្ធិកុមារដែលគាំទ្រដោយ OHCHR ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាបានចេញសេចក្តីសម្រេចមួយដោយបញ្ជាក់យ៉ាងច្បាស់ថា សន្ធិសញ្ញាសិទ្ធិមនុស្សដែលកម្ពុជាបានផ្តល់សច្ចាប័នគឺជាផ្នែកមួយនៃច្បាប់ក្នុងស្រុក ហើយគួរតែត្រូវបានអនុវត្តដោយចៅក្រមនៅក្នុងតុលាការ។

២៧០. ប្រទេសកម្ពុជាក៏បានបោះឆ្នោតនៅឆ្នាំ ២០០៧ ដើម្បីអនុម័តសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនជាតិដើមភាគតិចទទួលយកខ្លឹមសារទាំងស្រុង ហើយបានផ្តល់សច្ចាប័នលើ CERD, CEDAW, និង CRC។ ទោះជាយ៉ាងនេះក្តី កម្ពុជាមិនទាន់បានអនុម័តប្រើប្រាស់អនុសញ្ញាលេខ ១៦៩ របស់អង្គការ ILO នៅឡើយទេ។

### ៨.១.១.៣ ជនជាតិដើមភាគតិចនៅក្នុងតំបន់គោលដៅនៃគម្រោង

២៧១. កិច្ចប្រជុំពិគ្រោះយោបល់ជាមួយ និងមានការចូលរួមពីជនជាតិដើមភាគតិច និងជនងាយរងគ្រោះ និង/ឬក្រុមមនុស្សមិនទទួលបានការយកចិត្តទុកដាក់ក្នុងសង្គមគឺជាមូលដ្ឋានគ្រឹះដ៏សំខាន់នៃគម្រោង PEARL និងក្នុងការធានាឱ្យមានការសម្រេចគោលបំណងរបស់គម្រោង។ ក្នុងចំណោមខេត្តគោលដៅចំនួន ៤ នៅក្នុងតំបន់គម្រោង

[14] Cambodia has also signed but not ratified the International Convention on the Protection of the Rights of All Migrant Workers and Members of Their Families.

PEARL មានក្រុមជនជាតិដើមភាគតិចជាង ១១ ក្រុម សរុបចំនួនសមាជិកជិត ៤0.000 នាក់ ដែលមានចំនួន និងភាគរយខ្ពស់បំផុតនៃចំនួនប្រជាជនសរុបគឺស្ថិតនៅក្នុងខេត្តព្រះវិហារ (សូមមើលតារាងទី ១១)។

*តារាងទី 11. ចំនួនជនជាតិដើមភាគតិចក្នុងខេត្តចំនួនបួន*[15]

| ក្រុម IP | សៀមរាប | | ឧត្តរមានជ័យ | | កំពង់ធំ | | ព្រះវិហារ | |
|---|---|---|---|---|---|---|---|---|
| | ចំនួនខ្នងផ្ទះ | ចំនួនប្រជាជន | ចំនួនខ្នងផ្ទះ | ចំនួនប្រជាជន | ចំនួនខ្នងផ្ទះ | ចំនួនប្រជាជន | ចំនួនខ្នងផ្ទះ | ចំនួនប្រជាជន |
| ព្នង | 0 | 0 | ៤៥ | ២៣៥ | 0 | 0 | ១៨៣ | ៦៥៩ |
| កួយ | ៩៨ | ៣៨៧ | ១៦៧ | ៨0៣ | ៣.000 | ១៣.៤0៣ | ៤.៩៩១ | ២0.៦៥៤ |
| ស្ទៀង | 0 | 0 | ២ | ១៤ | 0 | 0 | ៤ | ២0 |
| ក្រោល | 0 | 0 | ១ | ១៤ | 0 | 0 | 0 | 0 |
| ថ្មូន | 0 | 0 | ១ | ៥ | 0 | 0 | 0 | 0 |
| ទំពួន | 0 | 0 | ៣ | ១៩ | 0 | 0 | ១ | ៥ |
| ចារាយ | 0 | 0 | ៣ | ១៧ | 0 | 0 | | |
| កាចក់ | 0 | 0 | 0 | 0 | 0 | 0 | | |
| ជង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| ព័រ | 0 | 0 | 0 | 0 | 0 | 0 | ៤២0 | ១.៥២0 |
| ស្អូច | 0 | 0 | ៤ | ១៥ | 0 | 0 | 0 | 0 |
| ផ្សេងៗ | ២៨ | ១0៦ | ១៩ | ២៧ | 0 | 0 | ១៩ | ៦៣ |
| **សរុប** | **១២៦** | **៤៩៣** | **២៤៥** | **១.១៤៩** | **៣.000** | **១៣.៤0៣** | **៥.៦១៨** | **២២.៩២១** |
| **ចំនួនប្រជាជនជនជាតិដើមភាគតិចសរុប** | | | | | | | | **៣៧.៩៦៦** |
| **ចំនួនប្រជាជនក្នុងខេត្តសរុប** | | ១.0៩៤.000 | | ២៧៦.0៣៩ | | ៦៨១.៥៤៩ | | ២៥៤.៨២៧ |
| **ចំនួនប្រជាជនគិតជាភាគរយ** | | 0,0៤% | | 0,៤% | | ២% | | ៩% |

## ៨.១.២ លទ្ធផលរកឃើញសំខាន់ៗ និងការវិភាគផលប៉ះពាល់ ហានិភ័យ និងឱកាស

២៧២. ការប្រែប្រួលអាកាសធាតុនឹងមានផលប៉ះពាល់អវិជ្ជមានក្នុងកម្រិតខុសៗគ្នាលើជនជាតិដើមភាគតិច។ ក្រុមទាំងនេះជាញឹកញាប់ងាយរងគ្រោះជាងក្រុមដទៃទៀតទៅនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិដែលបង្កឡើងដោយអាកាសធាតុ ដោយសារតែការរើសអើងពីជំនាន់មួយទៀតជំនាន់មួយទៀត (ការផាត់

[15] Data from Royal Government of Cambodia 2009 Census – available at http://mail.nis.gov.kh/nis/CSES/Final%20Report%20CSES%202009.pdf

ចេញពីសង្គម និងសេដ្ឋកិច្ច)។ ជាធម្មតា ក្រុមទាំងនេះពឹងផ្អែកយ៉ាងខ្លាំងលើធនធានធម្មជាតិសម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគេ ហើយពួកគេជារឿយៗរស់នៅក្នុងតំបន់ដែលមានហានិភ័យខ្ពស់ ដែលជារឿយៗស្ថិតនៅតាមដងទន្លេ ឬនៅតំបន់ដែលងាយរងគ្រោះនឹងការបាក់ដី ឬការហូរច្រោះដី។ ដូច្នេះ គម្រោងនេះផ្តល់ផលប្រយោជន៍ដោយផ្ទាល់ដល់ពួកគេ ពីព្រោះថា គម្រោងនេះនឹងពង្រឹងភាពធន់របស់ជនជាតិដើមភាគតិចទៅនឹងការប្រែប្រួលអាកាសធាតុដែលរស់នៅក្នុងតំបន់ងាយរងគ្រោះ។

### ៨.១.២.១ ផលប៉ះពាល់ដែលអាចកើតមានពីគម្រោង PEARL លើជនជាតិដើមភាគតិច និងជនងាយរងគ្រោះផ្សេងទៀត និង/ឬជនមិនត្រូវបានយកចិត្តទុកដាក់ខ្ពស់ក្នុងសង្គម

២៧៣. ក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម(ESMF)បានកត់សម្គាល់ពីផលប៉ះពាល់សក្តានុពលមួយចំនួនដែលអាចកើតមាន រួមទាំងយន្តការគ្រប់គ្រងជាសក្តានុពលដើម្បីដោះស្រាយនេះ។ ហានិភ័យទាំងនេះផ្តោតជាចម្បងលើ៖

- គម្រោងដែលលើកកម្ពស់វិសមភាពសង្គម និងសេដ្ឋកិច្ចដែលកំពុងកើតមាន តាមរយៈការផ្តល់អត្ថប្រយោជន៍ដល់ក្រុមមនុស្សមានជីវភាពធូរធា និងខកខានមិនបានផ្តល់ផលប្រយោជន៍ដល់ក្រុមមនុស្សងាយរងគ្រោះ និង/ឬមិនទទួលបានការយកចិត្តទុកដាក់ក្នុងសង្គម ក្នុងនោះរួមទាំងជនជាតិដើមភាគតិចផងដែរ។
- សកម្មភាពគម្រោងដែលបណ្តាលឱ្យមានសម្ពាធច្រើនឡើងលើជនជាតិដើមភាគតិច ឬតំបន់ដីរបស់ក្រុមមនុស្សងាយរងគ្រោះ និង/ឬក្រុមមនុស្សដែលមិនទទួលបានការយកចិត្តទុកដាក់ក្នុងសង្គម និងការផ្លាស់ប្តូរជាសក្តានុពលនៃសកម្មភាពប្រើប្រាស់ដី តាមរយៈសកម្មភាពកសិកម្ម ឬសកម្មភាពស្តារព្រៃឈើ។
- ការមិនយកចិត្តទុកដាក់ ឬឥទ្ធិពលមានកម្រិតនៃជនជាតិដើមភាគតិច ឬក្រុមមនុស្សងាយរងគ្រោះ និង/ឬក្រុមមនុស្សដែលមិនត្រូវបានយកចិត្តទុកដាក់នៅក្នុងអង្គការគ្រប់គ្រងដោយសហគមន៍។

២៧៤. គម្រោងនេះព្យាយាមដោះស្រាយបញ្ហាទាំងនេះ តាមរយៈវិធីសាស្ត្រគ្រប់គ្រងដែលបានរកឃើញ ព្រមទាំងកំណត់ពីតម្រូវការក្នុងការត្រួតពិនិត្យវាយតម្លៃហានិភ័យជាក់លាក់បន្ថែមទៀតដែលចាំបាច់ត្រូវធ្វើ និងផែនការគ្រប់គ្រងដែលត្រូវបានបង្កើតឡើង ដោយផ្អែកលើការវាយតម្លៃលម្អិតបន្ថែមទៀតនៃទីតាំងគម្រោងជាក់លាក់ និងអ្នកទទួលផលជាគោលដៅ ក្នុងអំឡុងពេលអនុវត្តគម្រោងដំបូងៗ (សូមមើលចំណុច ៦.៤ នៃ ក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម(ESMF)។

២៧៥. គម្រោងក៏ធ្វើការកត់សម្គាល់ផងដែរនូវសមាសធាតុសំខាន់ៗមួយចំនួននៅក្នុងការរៀបចំគម្រោងដែលធានាដល់ការបញ្ជ្រាបដាក់បញ្ចូលវិធានកាត់បន្ថយជាគន្លឹះនូវហានិភ័យ ហើយតាមពិតធានាថា សកម្មភាពដែលបានស្នើឡើង គឺផ្តោតលើការគាំទ្រក្រុមងាយរងគ្រោះ និង/ឬមិនទទួលបានការយកចិត្តទុកដាក់ក្នុងសង្គម និងជួយបង្កើនភាពធន់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ជនបទ។ សមាសធាតុសំខាន់ៗមួយចំនួននៃប្រការនេះគឺ៖

ក. ការចូលរួមនៅក្នុងគម្រោងនេះគឺជាការស្ម័គ្រចិត្ត ហើយ ការយល់ព្រមជាមុន ដោយសេរីដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់(FPIC)នឹងក្លាយជាគោលការណ៍អន្តរវិស័យដែលត្រូវអនុវត្តដើម្បីធានាថាមានការផ្តល់ការយល់ព្រមជាមុន ដោយសេរី និងផ្អែកលើព័ត៌មានគ្រប់គ្រាន់មុនពេលនឹងអនុវត្តសកម្មភាពណាមួយ ផ្អែកលើដំណើរការ ការយល់ព្រមជាមុន ដោយសេរីដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់(FPIC)ផ្លូវ

ការ និងពេញលេញតាមកំណត់ត្រាឯកភាពដោយត្រូវអនុវត្តនៅគ្រប់បរិបទទាំងអស់ដែលមានវត្តមានជនជាតិដើមភាគតិច[16]។

ខ. គម្រោងផ្តោតការយកចិត្តទុកដាក់លើការបង្កើនការយល់ដឹងរបស់សហគមន៍ជនបទអំពីផលប៉ះពាល់នាពេលអនាគតស្តីពីការប្រែប្រួលអាកាសធាតុ និងផ្តល់ឱ្យពួកគេនូវឧបករណ៍ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ពោលគឺជួយគាំទ្រសហគមន៍ជនបទឱ្យធន់ទៅនឹងបញ្ហាអាកាសធាតុ។

គ. គម្រោងគាំទ្រដល់ការអនុវត្តកសិកម្មល្អ (GAP) និងការអនុវត្តកសិកម្មផ្សេងៗទៀតដែលមានភាពប្រសើរឡើងដែលនឹងបង្កើនគុណភាព និងតម្លៃផលិតកម្ម ដោយក្នុងពេលជាមួយគ្នានេះបង្កើនភាពធន់នឹងភាពមិនប្រាកដប្រជាជានៃការប្រែប្រួលបរិស្ថាន តាមរយៈការដាក់បញ្ចូលគ្នានៃការធ្វើកសិកម្មទំនើប ប្រាក់ចំណូលកើនឡើង និងសមត្ថភាពមានភាពប្រសើរឡើង និងប្រព័ន្ធអភិបាលកិច្ចដើម្បីឆ្លើយតបទៅនឹងការភាពមិនប្រាកដប្រជានៃការប្រែប្រួលអាកាសធាតុ។

ឃ. គម្រោងនេះនឹងជួយស្តារតំបន់ព្រៃឈើដែលមានភាពរេចរឹល ដោយជួយកែលម្អភាពសម្បូរបែបនៃធនធានព្រៃឈើ ក៏ដូចជាសេវាកម្មបរិស្ថាន និងទីជម្រាលសំខាន់ៗ។

ង. គម្រោងនេះគឺពឹងផ្អែកលើវិធីសាស្ត្រដោយមានការចូលរួមមួយស្របតាមគោលការណ៍របស់ ការយល់ព្រមជាមុន ដោយសេរីដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់(FPIC)ដើម្បីឱ្យជនជាតិដើមភាគតិចអាចទទួលអនុវត្តវិធានការដែលសមស្របនឹងបរិបទក្នុងតំបន់ និងភាពងាយរងគ្រោះខុសគ្នារបស់ពួកគេ។

ច. ការជ្រើសរើសទីតាំងគោលដៅរបស់គម្រោង សហគមន៍កសិកម្មដែលបានស្នើឡើង និងអន្តរាគមន៍នានា គឺផ្អែកលើការពិគ្រោះយោបល់ និងការចូលរួមយ៉ាងទូលំទូលាយ ហើយផ្តោតយកចិត្តទុកដាក់លើសហគមន៍កសិកម្មដែលស្ថិតនៅក្នុងសហគមន៍ជនបទ ព្រមទាំងក្រុមសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើដែលកំពុងរស់នៅក្នុងតំបន់ជនបទ។ អាស្រ័យហេតុនេះ គម្រោងកំពុងផ្តោតការយកចិត្តទុកដាក់លើក្រុមនានាដែលមានប្រវត្តិធ្លាប់ទទួលរងភាពងាយរងគ្រោះ និង/ឬក្រុមមនុស្សដែលមិនទទួលបានការយកចិត្តទុកដាក់ក្នុងសង្គម ហើយកំពុងធ្វើការដើម្បីកសាងសមត្ថភាពរបស់ក្រុមមនុស្សទាំងនេះ និងលើកកម្ពស់សុខុមាលភាពរបស់ពួកគេ។

ឆ. គម្រោងបានកំណត់អត្តសញ្ញាណបទដ្ឋានកសិកម្មដោយចីរភាព ដែលនឹងត្រូវយកមកអនុវត្តសម្រាប់ឱ្យមានការចូលរួមរបស់សហគមន៍កសិកម្មទាំងអស់ ក្នុងនោះរួមទាំងលក្ខខណ្ឌតម្រូវសម្រាប់ផលិតកម្ម ដែលមិនបណ្តាលឱ្យមានការរេចរឹលបរិស្ថាន និងការកាប់ឆ្ការព្រៃឈើ ឬការផ្លាស់ទីលំនៅរបស់សហគមន៍ជនបទ។

ជ. គម្រោងបានប្តេជ្ញាចិត្តលើការដាំដើមឈើឡើងវិញ និងការស្តារព្រៃឈើឡើងវិញដែលត្រូវបានធ្វើឡើងស្របតាមការអនុវត្តល្អបំផុតជាអន្តរជាតិ ក្នុងរួមទាំងការមិនផ្លាស់ទីលំនៅរបស់សហគមន៍។

---

[16] The procedure for implementing FPIC will be based on guidance provided through both FAO and GCF as well as other international and national best practice with this knowledge being utilised to design the most appropriate system for the local context and community practices.

២៧៦. បន្ថែមទៅនឹងសកម្មភាពទាំងអស់នេះ គម្រោងនឹងប្រើប្រាស់វិធីសាស្ត្រដោយការចូលរួមដែលនឹងផ្តោតការយកចិត្តទុកដាក់លើការចូលរួមពេញលេញ និងមានប្រសិទ្ធភាពពីជនជាតិដើមភាគតិច និងក្រុមមនុស្សងាយរងគ្រោះ និង/ឬមិនបានទទួលការយកចិត្តទុកដាក់ក្នុងសង្គមដែលសកម្មភាពទាំងនោះមានដូចជា៖

ក. ការផលិតព័ត៌មានតាមវិធីច្រើនយ៉ាងដើម្បីសម្រួលដល់ដំណើរការចូលរួមពីភាគីពាក់ព័ន្ធច្រើនក្រុម ក្នុងនោះរួមទាំងក្រុមជនជាតិដើមភាគតិចផង។

ខ. នៅពេលមានការពាក់ព័ន្ធ ការផលិតព័ត៌មានពាក់ព័ន្ធ និងសម្ភារកសាងសមត្ថភាពត្រូវរៀបចំឡើងជាភាសាជនជាតិដើមភាគតិច ដើម្បីបង្កើនដំណើរការចូលរួមពីក្នុងក្រុមទាំងនេះ និងជួយសម្រួលដល់ការសិក្សាពីមិត្តភ័ក្តិម្នាក់ទៅម្នាក់ទៀត។

គ. ការរៀបចំបង្កើតផែនការជនជាតិដើមភាគតិចដាក់លាក់ នឹងក្លាយជាផ្នែកមួយនៃការត្រួតពិនិត្យវាយតម្លៃហានិភ័យបរិស្ថាន និងសង្គមលើទីតាំងជាក់លាក់ ហើយជាផ្នែកមួយនៃ ESMP ដែលនឹងត្រូវបានអនុវត្ត (ដូចបានកត់សម្គាល់ខាងលើ) នៅពេលមានការបញ្ជាក់ច្បាស់លាស់ពីព័ត៌មានលម្អិតនៃទីតាំងគោលដៅ និងក្រុមមនុស្សចូលរួមអនុវត្តសកម្មភាពគម្រោង។

ឃ. វិធានការគោលដៅសម្រាប់ការដាក់បញ្ចូលក្នុងសង្គមគឺត្រូវធ្វើឡើងនៅគ្រប់វិស័យ និងបញ្ចូលទៅក្នុងសកម្មភាពគម្រោង (ឧ. ការបណ្តុះបណ្តាលអង្គការសង្គមស៊ីវិលដែលតំណាងឱ្យក្រុមងាយរងគ្រោះ និង/ឬមិនទទួលបានការយកចិត្តទុកដាក់ក្នុងសង្គម តម្រង់ទិសដៅលើគ្រូបណ្តុះបណ្តាលមកពីក្រុមងាយរងគ្រោះ និង/ឬមិនទទួលបានការយកចិត្តទុកដាក់ក្នុងសង្គម ការបណ្តុះបណ្តាលចំណេះដឹងអាជីវកម្មដល់សមាជិកក្រុមងាយរងគ្រោះ និង/ឬមិនទទួលបានការយកចិត្តទុកដាក់ក្នុងសង្គម)។

ង. សកម្មភាពផ្តោតលើចំណេះដឹង និងការប្រាស្រ័យទាក់ទង (លទ្ធផលទី ៣) នឹងមានបញ្ចូលព័ត៌មានពីបទពិសោធថ្នាក់ជាតិ ការអនុវត្តល្អបំផុតនៅកម្រិតអន្តរជាតិ ព្រមទាំងចំណេះដឹងក្នុងស្រុក និងជនជាតិដើមភាគតិច (រួមទាំងសកម្មភាព ៣.១.១ និង ៣.២.២ ដោយផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើការលើកកម្ពស់ការយល់ដឹងអំពីចំណេះដឹងនៅក្នុងប្រទេស និងជនជាតិដើមភាគតិចស្តីពីការបន្សាំខ្លួនទៅនឹងអាកាសធាតុ)។ ការធ្វើសមាហរណកម្មចំណេះដឹងពីតួអង្គចម្រុះទៅក្នុងវេទិកាផ្សព្វផ្សាយ និងចែករំលែកចំណេះដឹងនឹងលើកកម្ពស់ការធ្វើបរិយាប័ន្នសង្គម និងក៏អនុញ្ញាតឱ្យក្រុមចម្រុះបង្កើនបទពិសោធ និងចំណេះដឹងមូលដ្ឋានផងដែរ។

ច. ការបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់ការអនុវត្តសកម្មភាពគម្រោង គួរតែរួមបញ្ចូលបុរស និងស្ត្រីមកពីក្រុមជនជាតិដើមភាគតិច។

ឆ. ការរៀបចំបង្កើតផែនទីបង្ហាញផ្លូវកសិកម្មនឹងមានការបញ្ចូលការពិចារណាអំពីវិធីក្នុងការដាក់បញ្ចូលក្រុមជនជាតិដើមភាគតិច ក៏ដូចជាការដាក់បញ្ចូលក្រុមមនុស្សងាយរងគ្រោះផ្សេងទៀត។

២៧៧. គម្រោងនេះមានគោលបំណងមិនបង្កគ្រោះថ្នាក់ដល់ជនជាតិដើមភាគតិច ក្នុងនោះរួមទាំងការបាត់បង់ជីវភាពរស់នៅ ឬផលប៉ះពាល់លើអត្តសញ្ញាណវប្បធម៌របស់ជនជាតិដើមភាគតិច ហើយសកម្មភាពមិនរាប់បញ្ចូលមួយចំនួនមានកំណត់នៅក្នុងឧបសម្ព័ន្ធទី ២ នៃឯកសារនេះ ក្នុងនោះរួមទាំងការតាំងលំនៅថ្មី ឬការផ្លាស់ទីលំនៅដោយបង្ខំពីដីធ្លី ឬឱកាសសេដ្ឋកិច្ច សសង្គម ឬវប្បធម៌។ ជនជាតិដើមភាគតិចដែលបានពិគ្រោះយោបល់បានកត់សម្គាល់ថា គម្រោងនេះដោះស្រាយបញ្ហាជាច្រើនដែលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគេ រួមមានការប្រែប្រួល

អាកាសធាតុ គ្រោះថ្នាក់ធម្មជាតិដែលបណ្ដាលមកពីអាកាសធាតុ និងនិន្នាការរេចរឹលដីនៅក្នុងទីតាំងគម្រោង។ ពួកគេបានកត់សម្គាល់ថា កង្វះខាតទឹក និងកំដៅខ្លាំងដែលពួកគេកំពុងជួបប្រទះប៉ះពាល់ដល់ផលិតកម្មកសិកម្មរបស់ពួកគេ ហើយយល់ឃើញថា ទឹកជំនន់ និងការហូរបាក់ដីបង្កផលប៉ះពាល់អវិជ្ជមានបន្ថែមទៀតដល់ជនជាតិដើមភាគតិចនៅក្នុងតំបន់អន្តរាគមន៍ពីគម្រោង។ ការរេចរឹលព្រៃឈើ និងដីក៏ជះឥទ្ធិពលអវិជ្ជមានបន្ថែមទៀតដល់ជីវភាពរស់នៅរបស់ពួកគេ ដោយសារតែការកាត់បន្ថយភាពសម្បូរបែប និងគុណភាពនៃផលិតផលព្រៃឈើ ក្នុងនោះរួមទាំងរុក្ខជាតិឱសថ និងអនុផលព្រៃឈើ។ អាស្រ័យដូច្នេះហើយទើប ការអន្តរាគមន៍ពីគម្រោងត្រូវបានរំពឹងថានឹងមានឥទ្ធិពលវិជ្ជមានយ៉ាងខ្លាំងទៅលើក្រុមជនជាតិដើមភាគតិច និងក្រុមមនុស្សដែលងាយរងគ្រោះ និង/ឬមិនទទួលបានការយកចិត្តទុកដាក់ក្នុងសង្គមនៅក្នុងទីតាំងទទួលបានបទអន្តរាគមន៍ពីគម្រោង។

២៧៨. គម្រោងនេះក៏មានបញ្ចូលផងដែរនូវ GRM ដែលនឹងត្រូវបានពិនិត្យឡើងវិញ ក្នុងដំណាក់កាលចាប់ផ្តើមអនុវត្តគម្រោងដើម្បីធានាថា គម្រោងនេះបំពេញបានយ៉ាងពេញលេញនូវតម្រូវការរបស់ក្រុមជនជាតិដើមភាគតិចនៅក្នុងទីតាំងទទួលបានអន្តរាគមន៍ពីគម្រោង ដោយផ្អែកលើកម្រិតសក្តានុពលនៃការចូលរួម និងតម្រូវការជាក់លាក់របស់ពួកគេ។

### ៨.១.២.២ ការពិគ្រោះយោបល់ជាមួយជនជាតិដើមភាគតិច

២៧៩. តាមរយៈដំណើរការនៃការរៀបចំអនុវត្តគម្រោង ភាគីពាក់ព័ន្ធជាឯកត្តជនប្រមាណជា ១.១០២ នាក់តំណាងស្ថាប័នសាធារណៈ និងវិស័យឯកជន ជាង ៦០០ ត្រូវបានពិគ្រោះ (ក្នុងនោះមានស្ត្រី ១៤៣ នាក់ និងបុរស ៩៦៦ នាក់) ក៏ដូចជាតំណាងរបស់ជនជាតិដើមភាគតិច និងក្រុមមនុស្សដែលងាយរងគ្រោះ និង/ឬមិនទទួលបានការយកចិត្តទុកដាក់ក្នុងសង្គម។ ស្ថាប័នសាធារណៈ វិស័យឯកជន និងភាគីពាក់ព័ន្ធសំខាន់ៗដែលបានពិគ្រោះយោបល់ មានដូចខាងក្រោម៖

- ក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល
- មន្ទីរពាក់ពន្ធតាមខេត្ត
- ស្ថាប័នហិរញ្ញវត្ថុ
- អង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍
- អង្គការដឹកនាំដោយសហគមន៍ (ជាពិសេសសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ)
- សហគមន៍កសិកម្ម សមាគមកសិករ ក្រុមផលិតករ និងសហជីព។
- ផ្នែកឯកជន (អ្នកផ្គត់ផ្គង់ផលិតផលកសិកម្ម អ្នកផ្គត់ផ្គង់ធាតុចូល អាជីវករលក់ដុំ រោងម៉ាស៊ីនកិនស្រូវ អាជីវករលក់រាយ អ្នកកែច្នៃ ។ល។)

២៨០. ប្រការគួរឱ្យកត់សម្គាល់នោះគឺថា នៅក្នុងខេត្តទាំងនេះមិនមានបណ្ដាញជនជាតិដើមភាគតិចដែលត្រូវបានបង្កើតឡើងយ៉ាងរឹងមាំ និងពេញលេញទេ ក្រៅតែពីបុគ្គល គ្រួសារ ឬសហគមន៍ជនជាតិដើមភាគតិចចូលរួម ហើយត្រូវបានរួមបញ្ចូលនៅក្នុងបណ្តាញផ្សេងទៀតដែលមានទំនាក់ទំនងទៅនឹងផលិតកម្មកសិកម្ម ឬការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ។ ដូច្នេះ ទស្សនៈរបស់ក្រុមក្រុមជនជាតិដើមភាគតិច ត្រូវបានកត់ត្រានៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រុមទាំងនេះផ្សេងៗទៀត។

២៨១. បញ្ហាសំខាន់ៗជាប់ទាក់ទងនឹងក្រុមជនជាតិដើមភាគតិចដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ទាំងនេះត្រូវបានសង្ខេបដាក់ក្នុងផែនការជនជាតិដើមភាគតិចដោយផ្តោតការយកចិត្តទុកដាក់លើការបន្តលទ្ធភាពក្នុងការចេញ-ចូលដី និងទម្រង់នៃការប្រើប្រាស់ដីជាប្រពៃណី ក៏ដូចជាលទ្ធភាពអនុវត្តអភិបាលកិច្ចជាបន្ត

លើការប្រើប្រាស់ដីធ្លីរបស់សហគមន៍។ លើសពីនេះ បំណងប្រាថ្នាក្នុងការភ្ជាប់ប្រកបដោយប្រសិទ្ធភាពជាមួយទីផ្សារកសិកម្ម និងខ្សែច្រវ៉ាក់ផ្គត់ផ្គង់តម្លៃខ្ពស់ ត្រូវបានមើលឃើញថាមានសារៈសំខាន់ផងដែរ។

២៨២. តាមរយៈដំណើរការរៀបចំគម្រោងរយៈពេលជាង ៤ ឆ្នាំនេះ ក្រុមការងាររៀបចំគម្រោងបានធានាថា ជនជាតិដើមភាគតិច និងក្រុមដែលងាយរងគ្រោះ និង/ឬមិនទទួលបានការយកចិត្តទុកដាក់ក្នុងសង្គមត្រូវបានទទួលការដំណឹងយ៉ាងត្រឹមត្រូវ ប្រកបដោយតម្លាភាព និងមិនលំអៀងអំពីសកម្មភាពគម្រោងដែលកំពុងស្នើឡើង។ ការពិភាក្សាម្តងហើយម្តងទៀត ដោយផ្តែកលើការសិក្សាសមិទ្ធលទ្ធភាពលើទីតាំងគោលដៅ និងការចូលរួមក្នុងសកម្មភាពគម្រោងដែលបានស្នើសុំ ត្រូវបានធ្វើឡើងពីឆ្នាំ២០១៨ ដល់ខែមីនា ឆ្នាំ២០២២ និងបានចងក្រងជាឯកសារនូវលទ្ធផលពាក់ព័ន្ធ និងធ្វើការផ្សព្វផ្សាយដល់គ្រប់ភាគីទាំងអស់ (សេចក្តីសង្ខេបនៃកិច្ចប្រជុំ និងបញ្ជីវត្តមានមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី ៧ នៃសំណើសុំគម្រោងនេះ។

### ៨.១.២.៣ សេចក្តីសង្ខេបនៃសមាសធាតុសម្រាប់ដាក់បញ្ចូលក្នុង ផែនការជនជាតិដើមភាគតិច (IPP)

២៨៣. នៅពេលបញ្ចប់ការវាយតម្លៃបន្ថែមនៃតំបន់គោលដៅរួចហើយ ហើយសកម្មភាពបន្ថែមទៀតត្រូវបានធ្វើឡើងដើម្បីកំណត់អត្តសញ្ញាណទីតាំង និងក្រុមមនុស្សពាក់ព័ន្ធសម្រាប់អនុវត្តសកម្មភាពគម្រោង និងស្របតាមនីតិវិធីពិនិត្យវាយតម្លៃដែលបានកំណត់ក្នុង ក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម(ESMF)និង ផែនការជនជាតិដើមភាគតិច (IPP)បច្ចុប្បន្ននេះ – ឯកសារ ផែនការជនជាតិដើមភាគតិច (IPP)លម្អិតបន្ថែមទៀតសម្រាប់តំបន់គោលដៅនឹងត្រូវបានរៀបចំឡើងដោយសហការជាមួយក្រុមជនជាតិដើមភាគតិចនៅក្នុងតំបន់ទាំងនេះ។ សកម្មភាពទាំងនេះគួរតែត្រូវបានបង្កើតឡើង ស្របតាមការណែនាំដែលមាននៅក្នុងគោលការណ៍ជនជាតិដើមភាគតិចរបស់GCF និងមានព័ត៌មានអំពីៈ

ក) ព័ត៌មានមូលដ្ឋាន (ពីដំណើរការវាយតម្លៃហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គមដែលបានធ្វើឡើងដោយឯករាជ្យ និងមានការចូលរួម)។

ខ) លទ្ធផលរកឃើញសំខាន់ៗ និងការវិភាគពីផលប៉ះពាល់ ហានិភ័យ និងឱកាស។

គ) វិធានការដើម្បីបញ្ចៀស កាត់បន្ថយ និងសម្រាលផលប៉ះពាល់អវិជ្ជមាន និងលើកកំពស់ឥទ្ធិពលវិជ្ជមាន និងឱកាសនានា។

ឃ) ការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍។

ង) លទ្ធផលនៃកិច្ចប្រជុំពិគ្រោះយោបល់ (ក្នុងអំឡុងពេលដំណើរការវាយតម្លៃហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម) ក្នុងនោះរួមទាំងបញ្ជីមនុស្ស និងអង្គការដែលបានចូលរួម កាលវិភាគពេលវេលាដែលទទួលខុសត្រូវលើសកម្មភាពនីមួយៗ ការយល់ព្រមជាមុន ដោយសេរី និងផ្អែកលើព័ត៌មានគ្រប់គ្រាន់ និងផែនការចូលរួមនាពេលអនាគត។

ច) ការវាយតម្លៃយេនឌ័រ និងផែនការសកម្មភាព។

ឆ) ផែនការបែងចែកផលប្រយោជន៍។

ជ) ការរៀបចំការកាន់កាប់ដីធ្លី។

ឈ) យន្តការដោះស្រាយបណ្តឹងតវ៉ា។

ញ) ការចំណាយ ថវិកា កាលវិភាគពេលវេលា ទំនួលខុសត្រូវរបស់អង្គការ និង

ង)  ការត្រួតពិនិត្យ ការវាយតម្លៃ និងការរាយការណ៍។

២៨៤. បើទោះបីសកម្មភាពមួយចំនួននៅក្នុងផែនការនេះអាចត្រូវបានអនុវត្តដោយដៃគូអនុវត្តគម្រោងក៏ដោយ ក៏អង្គការ FAO ដែលអង្គការមាននីតិសម្បទានឹងតម្រូវឱ្យ ព្រមទាំងធានាថា អង្គភាពប្រតិបត្តិ និងអន្តរការីផ្សេងទៀតត្រូវអនុវត្ត និងបំពេញលក្ខខណ្ឌនៃផែនការ ស្របតាមគោលនយោបាយជនជាតិដើមភាគតិចរបស់ GCF។ ការអនុវត្ត និងការត្រួតពិនិត្យ សកម្មភាពទាំងនេះដំបូងនឹងជាការទទួលខុសត្រូវរបស់បុគ្គលិកគម្រោង ក្នុងនោះរួមទាំងអ្នកឯកទេសផ្នែកការពារសុវត្ថិភាព និង អង្គភាពគ្រប់គ្រងគម្រោង(PMU) ប៉ុន្តែនឹងត្រូវបានត្រួតពិនិត្យដោយអង្គការ FAO ក្នុងប្រទេស និងមជ្ឈមណ្ឌលថ្នាក់តំបន់ តាមរយៈដំណើរការរាយការណ៍ប្រចាំត្រីមាស និងដំណើរទស្សនកិច្ចត្រួតពិនិត្យតាមពេលវេលាកំណត់។

## ៨.២ ការវាយតម្លៃ និងសកម្មភាពយេនឌ័រ

២៨៥. ជាផ្នែកនៃការរៀបចំ ក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម(ESMF) នោះ ការវាយតម្លៃយេនឌ័រជាសំខាន់ត្រូវបានធ្វើឡើង ហើយផែនការសកម្មភាពត្រូវបានរៀបចំឡើង។ ការវាយតម្លៃនេះត្រូវបានធ្វើឡើង ដោយមានការចូលរួមពីភាគីពាក់ព័ន្ធផ្សេងៗគ្នា រួមទាំង តួអង្គពាក់ព័ន្ធនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ សហគមន៍ និងវិស័យឯកជននៅក្នុងខេត្តដែលបានកំណត់ជ្រើសរើស និងផ្អែកលើវិធីសាស្ត្រសំខាន់ៗមួយចំនួនដូចជា៖

ក. **ការពិនិត្យវិភាគលើឯកសារ៖** សំណើរបស់គម្រោង និងការសិក្សាសមិទ្ធលទ្ធភាព គោលនយោបាយ និងយុទ្ធសាស្ត្រថ្នាក់ជាតិ និងតាមវិស័យត្រូវបានប្រមូល និងពិនិត្យវិភាគ។ ផ្អែកពាក់ព័ន្ធពីការសិក្សាយុទ្ធសាស្ត្រ និងគោលនយោបាយដែលមានស្រាប់ កំពុងពិនិត្យនិងដាក់បញ្ចូលទៅក្នុងរបាយការណ៍ស្តីពីការវាយតម្លៃយេនឌ័រនេះ។

ខ. **ការសំភាសន៍ជាមួយអ្នកព័ត៌មានសំខាន់ៗ៖** ការសម្ភាសន៍ស៊ីជម្រៅត្រូវបានធ្វើឡើងជាមួយស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ តួអង្គវិស័យឯកជន និងអ្នកតំណាងសហគមន៍ ដើម្បីវាយតម្លៃទស្សនៈរបស់ពួកគេទាក់ទងនឹងគម្លាតយេនឌ័រក្នុងវិស័យកសិកម្ម និងក្នុងវិសាលភាពជាក់លាក់នៃគម្រោងដែលបានស្នើឡើង។ ការសម្ភាសន៍ស៊ីជម្រៅសរុបចំនួន ១៤ លើកដែលមានអ្នកចូលរួមសរុបចំនួន ៣០ នាក់ (ក្នុងនោះមានអ្នកចូលរួម ៨ នាក់ជាស្ត្រី) ត្រូវបានធ្វើឡើងជាមួយតំណាងនៃ (១) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) (២) ក្រសួងបរិស្ថាន (MoE) (៣) ក្រសួងធនធានទឹក និងឧតុនិយម (MoWRAM) (៤) ក្រសួងកិច្ចការនារី (MoWA) (៥) ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) (៦) អង្គការស្បៀងអាហារ និងកសិកម្ម (FAO) (៧ និង ៨) មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត (PDAFF) នៅខេត្តសៀមរាប និងកំពង់ធំ (៩ និង ១០) មន្ទីរបរិស្ថានខេត្ត (PDE) នៅខេត្តសៀមរាប និងកំពង់ធំ (១១ និង ១២) មន្ទីរកិច្ចការនារីខេត្ត (PDoWA) នៅខេត្តសៀមរាប និងកំពង់ធំ (១៣) កសិដ្ឋានអេកូក្នុងសៀមរាប និង (១៤) សមាគមកសិកម្មខេត្តព្រះវិហារ (PMUAC)។ ដើម្បីកាត់បន្ថយហានិភ័យនៃជំងឺកូវីដ-១៩ និងពេលវេលាធ្វើដំណើរ កិច្ចសម្ភាសន៍ត្រូវបានធ្វើឡើងតាមប្រព័ន្ធអ៊ិនធើណិត និងជួបទល់មុខគ្នា។ បញ្ជីអ្នកដែលបានជួបមានភ្ជាប់ជាមកជាមួយក្នុងឧបសម្ព័ន្ធទី ៣ នៃឯកសារស្នើសុំ។

គ. **ការពិភាក្សាជាមួយក្រុមគោលដៅ៖** ការពិភាក្សាជាមួយក្រុមគោលដៅ (FDG) សរុបចំនួន ៤ ក្រុម ត្រូវបានរៀបចំឡើងនៅក្នុងសហគមន៍ផ្សេងៗគ្នាក្នុងខេត្តសៀមរាប និងខេត្តកំពង់ធំ។ FGD ត្រូវបានរៀបចំឡើង ដោយមានការរៀបចំដូចគ្នានៅខេត្តសៀមរាប និងខេត្តកំពង់ធំ។ ក្នុងខេត្តសៀមរាប

សមាជិកគណៈកម្មាធិការសហគមន៍តំបន់ធម្មជាតិ ចំនួន ១០ (ស្រី ៥ នាក់) រស់នៅលើកំពូលភ្នំគូលែន (ឧទ្យានជាតិ) នៅស្រុកស្វាយលើ ខេត្តសៀមរាប ត្រូវបានអញ្ជើញឱ្យចូលរួមក្នុង FGD។ អ្នកចូលរួមសរុបចំនួន ១៨នាក់ (ស្រី ១១នាក់) ដែលជាសមាជិកគណៈកម្មាធិការ និងសមាជិកនៃសហគមន៍កសិកម្មត្រូវបានអញ្ជើញឱ្យចូលរួមក្នុង FGD ដែលរៀបចំនៅស្រុកសូទ្រនិគម ខេត្តសៀមរាប។ នៅខេត្តកំពង់ធំ សមាជិកគណៈកម្មាធិការ និងសមាជិកសហគមន៍តំបន់ការពារធម្មជាតិចំនួន ១២ (ស្ត្រី ៤ នាក់) រស់នៅក្នុងស្រុកប្រាសាទសំបូរ បានចូលរួមនៅក្នុង FGD ហើយសមាជិកគណៈកម្មាធិការ និងសមាជិកសហគមន៍កសិកម្មចំនួន ១៩ នាក់ (ស្ត្រី ១២ នាក់) ក៏បានចូលរួមជាមួយ FGD នៅស្រុក សន្ទុកផងដែរ។ អ្នកចូលរួមទាំងនេះត្រូវបានរួមបញ្ចូលគ្នារវាងអ្នកដឹកនាំសហគមន៍ កសិករខ្នាតតូច តួអង្គខ្សែច្រវ៉ាក់តម្លៃ និងផលិតករកសិកម្ម។ FGD ចំណាយពេលចន្លោះពី ៦០ ទៅ ៩០ នាទី រៀបចំនៅកន្លែងបើកចំហ ដើម្បីជៀសវាងហានិភ័យនៃការឆ្លងជំងឺ COVID-១៩។ FGD នេះត្រូវបានសម្របសម្រួលដោយអ្នកជំនាញ/ទីប្រឹក្សាយេនឌ័រថ្នាក់ជាតិ និងទទួលបានជំនួយពីជំនួយការម្នាក់។ អ្នកចូលរួមទាំងអស់ត្រូវបានស្នើសុំការយល់ព្រម ដើម្បីពិភាក្សាលើប្រធានបទនៃការវាយតម្លៃ ក៏ដូចជាការកត់ត្រា។

២៨៦. ការវាយតម្លៃនេះបានកត់ត្រាពីការពិចារណាសំខាន់ៗមួយចំនួន និងអនុសាសន៍ជាសក្តានុពល ដោយផ្អែកលើការពិនិត្យឡើងវិញលើឯកសារដែលមានស្រាប់ និងសកម្មភាពអភិវឌ្ឍន៍កន្លងមកនៃគម្រោងផ្សេងៗ ក៏ដូចជាការពិគ្រោះយោបល់ដែលធ្វើឡើងជាផ្នែកមួយនៃការវាយតម្លៃនេះ។ ផ្នែកខាងក្រោមនេះសង្ខេបសកម្មភាពទាំងនេះ និងភ្ជាប់សកម្មភាពទាំងនេះទៅនឹងចំណុចដែលបានដាក់បញ្ចូលក្នុងផែនការសកម្មភាពយេនឌ័រ និងសំណើសុំមូលនិធិសំខាន់ៗ។ ការវាយតម្លៃនេះក៏បានកត់សម្គាល់ផងដែរថា នាពេលបច្ចុប្បន្ននេះ អន្តរាគមន៍ភាគច្រើនក្នុងចំណោមអន្តរាគមន៍ទាំងនេះមានលក្ខណៈទូលំទូលាយនៅឡើយ ពីព្រោះថា អន្តរាគមន៍ជាក់លាក់ និងចំគោលដៅជាងមុននឹងបង្កើតឡើងជាផ្នែកមួយនៃការអនុវត្តគម្រោង នៅពេលដែលសហគមន៍កសិកម្ម និងសហគមន៍តំបន់ការពារធម្មជាតិគោលដៅជាក់លាក់ ត្រូវបានកំណត់ ក៏ដូចជាតាមរយៈការអភិវឌ្ឍផលិតផលសំខាន់ៗ របស់គម្រោង (ឧ. ការអភិវឌ្ឍផែនយុទ្ធសាស្ត្រទំនិញ)។ សមាសធាតុយ៉ាងច្រើនក្នុងចំណោមសមាសភាពទាំងនេះនឹងត្រូវបានសម្របសម្រួល ដោយអ្នកឯកទេសយេនឌ័រជាតិ ដោយមានការគាំទ្រពីទីស្នាក់ការកណ្តាលរបស់អង្គការ FAO និងទីប្រឹក្សាផ្សេងៗទៀត ដូចបានរៀបរាប់នៅក្នុងសំណើសុំមូលនិធិនេះ។ ទោះជាយ៉ាងនេះក្តី សមាសធាតុសំខាន់នៃវិធីសាស្ត្រដ៏សំខាន់នេះមាន៖

**ប្រព័ន្ធកសិកម្មជាក់លាក់៖**

២៨៧. *លទ្ធភាពទទួលបានសេវាកម្មកសិ-ឧតុនិយម៖* មានឧបសគ្គ/កត្តាកំណត់យ៉ាងខ្លាំងលើសមត្ថភាពរបស់ស្ត្រីក្នុងការទទួលបានព័ត៌មានកសិ-ឧតុនិយមប្រកបដោយប្រសិទ្ធភាព ដោយសារកត្តាមួយចំនួនដូចខាងក្រោម៖

- *សមត្ថភាព៖* វិសមភាពយេនឌ័រជាធរមាន (ជាប់ទាក់ទងទៅនឹងលទ្ធភាពទាបក្នុងការទទួលបានការអប់រំ និងការបណ្តុះបណ្តាល) ព្រមទាំងលទ្ធភាពទទួលបានបច្ចេកវិទ្យា ដូចជាទូរស័ព្ទចល័តបានរឹតត្បិតសមត្ថភាពរបស់ស្ត្រីក្នុងការទទួលបានពេញលេញ និងយល់ដឹងពីព័ត៌មានកសិ-ឧតុនិយម ក៏ដូចជាព័ត៌មានទីផ្សារផ្សេងទៀត។
- *គុណភាពនៃប្រព័ន្ធ៖* ប្រព័ន្ធព័ត៌មានកសិ-ឧតុនិយមមានស្រាប់ពុំមានលក្ខណៈទូលំទូលាយខាងវិសាលភាព និងកម្រិតនៃព័ត៌មានលម្អិត ព្រមទាំងភាពត្រឹមត្រូវ ហើយជាលទ្ធផល ពុំសូវមានប្រយោជន៍ដល់កសិករ ក្នុងនោះរួមទាំងស្ត្រីផងដែរ ពីព្រោះព័ត៌មានទាំងនេះមានភាពចាំបាច់។

- *អត្រាគ្របដណ្តប់នៃប្រព័ន្ធ៖* ប្រព័ន្ធនេះនាពេលបច្ចុប្បន្នមិនគ្របដណ្តប់លើទីតាំង មានលក្ខណៈលម្អិតគ្រប់គ្រាន់ ឬមិនបានផ្តល់ព័ត៌មានដែលបានកាត់តម្រឹមសម្រាប់ប្រព័ន្ធផលិតកម្មផ្សេងៗគ្នា សម្រាប់ប្រព័ន្ធកសិកម្មខ្នាតតូច ដែលជារឿយៗដឹកនាំដោយស្ត្រី ដូចជាការដាំបន្លែដែលមានតម្រូវការខ្ពស់សម្រាប់ប្រព័ន្ធបែបនេះដែលជារឿយៗផ្គត់ផ្គង់មិនល្អ។

២៨៨. *អនុសាសន៍៖* ក្នុងការរៀបចំប្រព័ន្ធកសិ-ឧតុនិយម ប្រការសំខាន់ចាំបាច់នោះគឺត្រូវពិចារណាលើតម្រូវការច្រើនផ្សេងៗគ្នា ក្នុងនោះរួមទាំងការផលិតព័ត៌មាន និងវិធីក្នុងការផ្សព្វផ្សាយព័ត៌មានទាំងនេះ។

២៨៩។ អនុសាសន៍ទាំងនេះត្រូវបានពិនិត្យ និងដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពយេនឌ័រ ហើយបញ្ជ្រាបទៅក្នុងឯកសារគម្រោង។

២៩០. *លទ្ធភាពទទួលបានព័ត៌មាន និងឱកាសទីផ្សារ៖* ដូចដែលបានកត់សម្គាល់នៅក្នុងចំណុចស្តីពីប្រព័ន្ធកសិ-ឧតុនិយមខាងលើ និងខ្លឹមសារនៃរបាយការណ៍នេះ ស្ត្រីប្រឈមមុខនឹងបញ្ហាប្រឈមមួយចំនួនដែលទាក់ទងនឹងបទដ្ឋានយេនឌ័រ និងបញ្ហាយេនឌ័រជាប្រព័ន្ធ។ បញ្ហាសំខាន់ៗមួយចំនួនត្រូវបានកត់សម្គាល់ដូចខាងក្រោម រួមទាំងអនុសាសន៍តាមដំណាក់កាល ដើម្បីដោះស្រាយបញ្ហាទាំងនេះ និងតំណភ្ជាប់ជាមួយនឹងវិធីដែលបញ្ហាទាំងនេះត្រូវបានពិចារណា និងដាក់បញ្ចូលក្នុងផែនការសកម្មភាពយេនឌ័រ និងឯកសារគម្រោង។

- លទ្ធភាពទទួលបានព័ត៌៖ ស្ត្រីជាញឹកញាប់មានលទ្ធភាពតិចតួចក្នុងការទទួលបានព័ត៌មានដោយសារហេតុផលមួយចំនួនដែលបណ្តាលមកពីវិសមភាពរចនាសម្ព័ន្ធ (ឧ. ការទទួលបានការអប់រំទាប) ក៏ដូចជាបទដ្ឋានយេនឌ័រ (ឧ. តួនាទីមានកម្រិតនៅក្នុងអង្គភាពធ្វើការសម្រេចចិត្ត ក៏ដូចជាការទទួលបានតិចតួចនៃបច្ចេកវិទ្យា)។
- ការចល័ត/ការធ្វើដំណើរ៖ តាមរយៈបទសម្ភាសន៍ទាំងអស់ ស្ត្រីមានការធ្វើដំណើរ/ការចល័តក្នុងកម្រិតទាប (ក្នុងនោះមានការយកផលិតផលទៅទីផ្សារ ការចូលទៅកាន់តំបន់កសិដ្ឋានដាច់ស្រយាល ឬការចូលរួមក្នុងការល្បាតសហគមន៍តំបន់ការពារធម្មជាតិ) ត្រូវបានកត់សម្គាល់ថាជាឧបសគ្គក្នុងការដោះស្រាយបញ្ហាគម្លាតយេនឌ័រមួយចំនួន។
- បទដ្ឋានយេនឌ័រនៅក្នុងគ្រួសារ៖ ក្រុមការងារមានការកត់សម្គាល់យ៉ាងច្រើនដែលថា ស្ត្រីបន្តបំពេញតួនាទីជាច្រើននៅក្នុងគ្រួសារ ហើយដូច្នេះមានឱកាសតិចដើម្បីធ្វើសកម្មភាពផ្សេងទៀតដែលជាប់ទាក់ទងទៅនឹងតួនាទីដឹកនាំក្នុងការអភិវឌ្ឍកសិកម្ម។
- លទ្ធភាពទទួលបានហិរញ្ញវត្ថុ៖ លទ្ធភាពទទួលបានហិរញ្ញវត្ថុក៏ត្រូវបានកត់សម្គាល់ផងដែរថាជាបញ្ហាប្រឈមនៅក្នុងបញ្ហាពាក់ព័ន្ធនឹងយេនឌ័រជាក់ ដែលជាប់ទាក់ទងនឹងស្ត្រី ដោយជាញឹកញាប់ពួកគាត់ដំណើរការសហគ្រាសដែល "ថ្មី" នៅលើទីផ្សារ ឬជាអ្នកផ្តល់សេវាកម្មហិរញ្ញវត្ថុដែលមិនសូវមានបទពិសោធ និងមិនសូវសម្របខ្លួនបានល្អចំពោះសេវាកម្មនោះ។

២៩១. *អនុសាសន៍៖* ការដោះស្រាយបញ្ហាប្រឈមទាំងនេះតម្រូវឱ្យមានសមាសធាតុចម្រុះ ដោយប្រើប្រាស់វិធីសាស្ត្ររួម មានប្រសិទ្ធភាពក្នុងក្នុងការដោះស្រាយភាពមិនស្មើគ្នាផ្នែកយេនឌ័រ។ សមាសធាតុសំខាន់ៗនៃប្រការនេះមានដូចខាងក្រោម៖

- លទ្ធភាពទទួលបានវគ្គបណ្តុះបណ្តាលមានភាពប្រសើរឡើង៖ ប្រការសំខាន់ចាំបាច់នោះគឺថា ស្ត្រីមេគ្រួសារ និងស្ត្រីដែលពាក់ព័ន្ធផ្សេងទៀតទទួលបានការបណ្តុះបណ្តាលតាមរយៈអន្តរាគមន៍ពីគម្រោង ដោយមានខ្លឹមសារយកចិត្តទុកដាក់លើស្ត្រី និងឆ្លើយតបទៅនឹងតម្រូវការជាក់លាក់របស់ពួកគេ។

- ការលើកកម្ពស់ការយល់ដឹង និងការបណ្ដុះបណ្ដាលស្ដីពីបញ្ហាយេនឌ័រ៖ ប្រការសំខាន់ចាំបាច់នោះគឺថា គម្រោងត្រូវរៀបចំសកម្មភាពទូលំទូលាយ ដើម្បីគាំទ្រដល់ការលើកកម្ពស់ការយល់ដឹងអំពីយេនឌ័រ ក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗរបស់គម្រោង ដើម្បីបង្កើនការយល់ដឹងអំពីបញ្ហាប្រឈម និងតម្រូវការផ្សេងៗដែលយេនឌ័រប្រឈម និងពីវិធីដែលយេនឌ័រត្រូវឆ្លើយតប។
- ការបញ្ជ្រាបវិធីសាស្រ្តផ្អែកលើយេនឌ័រទៅក្នុងផែនការតាមវិស័យ និងផែនការអាជីវកម្មសំខាន់ៗ ព្រមទាំងសមាសធាតុទាំងអស់នៃការអនុវត្តគម្រោង៖ ដោយផ្អែកលើសមាសធាតុខាងលើ សមាសធាតុយេនឌ័រត្រូវបញ្ចូលទៅក្នុងលទ្ធផលគម្រោងសំខាន់ៗ ពាក់ព័ន្ធនឹងផែនការយុទ្ធសាស្រ្ត និងផលិតផលសេវាកម្មកសិ-ឧតុនិយម និងហិរញ្ញវត្ថុ ដើម្បីធានាថា ផលិតផលទាំងនេះអាចបំពេញទាំងតម្រូវការ ព្រមទាំងជួយដោះស្រាយវិសមភាពយេនឌ័រ។
- ការផលិតផលផលិតផលលើកកម្ពស់ការយល់ដឹងអំពីយេនឌ័រនៅទូទាំងដំណាក់កាលនៃការអនុវត្តគម្រោង៖ ផលិតផលរបស់គម្រោងទាំងអស់រាប់តាំងពីសម្ភារព័ត៌មាន និងសម្ភារលើកកកម្ពស់ការយល់ដឹង ត្រូវមានបញ្ជ្រាបបញ្ហាយេនឌ័រដើម្បីដើម្បីគាំទ្រដល់លទ្ធភាពទទួលបានសម្ភារទាំងនេះកាន់តែប្រសើរជាងមុន ហើយពួកគេអាចគាំទ្រផ្នែកមុខងារដើម្បីកាត់បន្ថយវិសភាពយេនឌ័រ។

**បញ្ហាអន្តរវិស័យ**

២៩២. *ការកំណត់បរិមាណប្រកបដោយប្រសិទ្ធភាពនៃឥទ្ធិពលរបស់គម្រោង និងការផ្លាស់ប្ដូរក្នុងប្រព័ន្ធកសិកម្មសម្រាប់ស្ត្រី៖* គម្រោងនេះកំពុងព្យាយាមធ្វើឱ្យប្រសើរជាក់ស្ដែងលើជីវិតរស់នៅរបស់ស្ត្រី ដែលស្ត្រីភាគច្រើនក្នុងសហគមន៍កសិកម្មកំពុងប្រឈមមុខនឹងបញ្ហាប្រឈមបន្ថែម ដែលទាក់ទងនឹងបទដ្ឋានយេនឌ័រ ក្នុងនោះរួមទាំងតម្រូវការដែលទាក់ទងនឹងការងារនៅមូលដ្ឋាន តាមផ្ទះ ព្រមទាំងឧបសគ្គក្នុងការធ្វើដំណើរ/ការចល័ត និងលទ្ធភាពទទួលបានព័ត៌មានស្ដីពីបច្ចេកទេសកសិកម្មដែលមានប្រសើរ។

- *អនុសាសន៍ - ការអនុវត្តវិធីសាស្រ្ត W+៖* បទដ្ឋាន W+ គឺជាបទដ្ឋានផ្ដោតការយកចិត្តទុកដាក់លើស្ត្រីដំបូងបង្អស់ ដែលវាស់វែងការផ្ដល់សិទ្ធិអំណាចដល់ស្ត្រី ប្រកបដោយតម្លាភាព និងគ្រប់គ្រាន់ ផ្ដល់តម្លៃជាប្រាក់កាសដើម្បីឈានទៅសម្រេចលទ្ធផល និងបង្កើតមធ្យោបាយថ្មីដើម្បីដឹកស្ត្រីដល់ការទទួលបានធនធានហិរញ្ញវត្ថុ។ ដូច្នេះ បទដ្ឋាននេះនឹងផ្ដល់ផលប្រយោជន៍ទ្វេ ពោលគឺផ្ដល់យន្តការគម្រោងដើម្បីត្រួតពិនិត្យឥទ្ធិពលរបស់គម្រោង និងមធ្យោបាយដែលអ្នកទទួលផលអាចចូលកាន់ទីផ្សារកាន់តែប្រសើរឡើង ព្រមទាំងទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុដោយផ្ទាល់។
- សក្ដានុពលនៃវិធីសាស្រ្តនេះត្រូវបានកត់សម្គាល់នៅក្នុងអនុសកម្មភាព ២.១.២.៤៖ ស្វែងយល់ពីលទ្ធភាពនៃការជ្រើសរើស និងដំណើរការបទដ្ឋាន W+ ដើម្បីផ្ដល់សិទ្ធិអំណាចដល់កសិករជាស្ត្រី ជាពិសេសនៅក្នុងវិស័យបន្លែ។

២៩៣. *អំពើហិង្សាលើស្ត្រី (VAW) និងការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពាន និងការបៀតបៀន (SEAH)៖* សមាសធាតុទាំងនេះមិនត្រូវបានគោរពការណ៍យ៉ាងទូលំទូលាយ ក្នុងពេលប្រជុំពិគ្រោះយោបល់ទេ ប៉ុន្តែបញ្ហាទាំងនេះនៅតែជាហានិភ័យនៅឡើយ ដោយសារតែអត្រាប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រីនៅតាមតំបន់ជនបទ (ក្នុងនោះស្ត្រីចំនួន ៣៣% រាយការណ៍ថាធ្លាប់ឆ្លងកាត់អំពើហិង្សា[17]) ក៏ដូចជាការផ្លាស់ប្ដូរអំណាច និងទម្រង់ប្រតិបត្តិការ

[17] National Institute of Statistics, Directorate General for Health, and ICF International, 2015. Cambodia Demographic and Health Survey 2014. Phnom Penh, Cambodia, and Rockville, Maryland, USA: National Institute of Statistics, Directorate General for Health, and ICF International. Available at https://dhsprogram.com/pubs/pdf/FR312/FR312.pdf

ក្រោមបទអន្តរាគមន៍ពីគម្រោង (ដូចដែលបានកត់សម្គាល់នៅក្នុងចំណុចទី ៣.៩ នៃការវាយតម្លៃយេនឌ័រ) ហើយហានិភ័យទាំងនេះត្រូវតែដោះស្រាយក្នុងពេលការអនុវត្តគម្រោង។

- *អនុសាសន៍៖* គម្រោងត្រូវតែធានាថាមានវិធានការសមស្របរួចរាល់ ដើម្បីលើកកម្ពស់ចំណេះដឹង និងការយល់ដឹងអំពី អំពើហិង្សាលើស្ត្រី (VAW) និង ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)និងគាំទ្រការអប់រំដើម្បីកាត់បន្ថយហានិភ័យរបស់គម្រោង។ កិច្ចការនេះក៏ត្រូវធ្វើដោយសហការជាមួយយន្តការដោះស្រាយបណ្តឹងតវ៉ា និងយន្តការដោះស្រាយបញ្ហា ប្រកបដោយប្រសិទ្ធភាព។

២៩៤. *យន្តការដោះស្រាយបណ្តឹងតវ៉ា (GRM)៖* ព័ត៌មានលម្អិតស្តីពីមុខងារនៃយន្តការបណ្តឹងតវ៉ាជាធរមានពុំមានឡើង សម្រាប់ប្រើជាផ្នែកមួយនៃការវាយតម្លៃនេះ។

- *អនុសាសន៍៖* ដូចដែលបានកត់សម្គាល់នៅក្នុង ក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម(ESMF) គម្រោងនឹងប្រើប្រាស់យន្តការបណ្តឹងតវ៉ារបស់របស់អង្គការ FAOក្នុងប្រទេស ដែលនឹងត្រូវអនុវត្ត នៅពេលគម្រោងចាប់ផ្តើម។ យន្តការនេះនឹងត្រូវបានពង្រឹងបន្ថែមទៀត ដើម្បីធានាថាមានយន្តការធ្វើមូលដ្ឋានីយកម្មដើម្បីអាចដោះស្រាយបញ្ហា ការកេងប្រវ័ញ្ច ការបំពារបំពាន និងការបៀតបៀនផ្លូវភេទ(SEAH)និង អំពើហិង្សាលើស្ត្រី (VAW) រួមទាំងការបណ្តុះបណ្តាលផ្តល់ដល់បុគ្គលិក និងការណែនាំរបស់អ្នកជំនាញអំពីរបៀបធានាដល់ប្រព័ន្ធដែលផ្តល់វិធីសាស្ត្រឆ្លើយតបយេនឌ័រ និងវិធីសាស្ត្រយកចិត្តទុកដាក់លើអ្នករស់រានមាន ជីវិត។ ដំណើរការនេះនឹងទទួលបានការគាំទ្រតាមរយៈគម្រោង និងតាមរយៈជំនាញរបស់អ្នកជំនាញយេនឌ័រជាតិ ក៏ដូចជាក្រុមការងារសកលរបស់អង្គការ FAO។

២៩៥. *និរន្តរភាព៖* និរន្តរភាពនៃអន្តរាគមន៍ផ្អែកលើយេនឌ័រគឺមានភាពចាំបាច់ដែលត្រូវឱ្យមានឥទ្ធិពលដែលចាំបាច់ដើម្បីបន្តអនុវត្ត បន្ទាប់ពីបញ្ចប់គម្រោង។

- *អនុសាសន៍៖* គម្រោងនេះមានយន្តការនិរន្តរភាពដែលបានដាក់បញ្ចូលក្នុងការរៀបចំគម្រោងដោយប្រើគំរូនៃភាពជាដៃគូរវាងរដ្ឋ ឯកជន និងសហគមន៍ជាមធ្យោបាយជំរុញការផ្លាស់ប្តូរ ដោយមានសកម្មភាពក្នុងការរៀបចំផែនការ និងយុទ្ធសាស្ត្រអាជីវកម្មដែលបន្ទាប់មកទទួលបានការគាំទ្រពីលទ្ធភាពទទួលបានហិរញ្ញវត្ថុកាន់តែប្រសើរឡើង ព័ត៌មានកសិ-ឧតុនិយម និងទីផ្សារមានតម្លៃខ្ពស់។ គោលបំណងទាំងនេះគឺស្របគ្នានឹងយុទ្ធសាស្ត្រ និងផែនការកសិកម្មសំខាន់ៗនៅក្នុងប្រទេសកម្ពុជា ក្នុងនោះរួមទាំងផែនការសកម្មភាពឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុសម្រាប់វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៦-២០២០ (CCPAP-AFF) និង NDC។ តាមទស្សនៈយេនឌ័រ គម្រោងនេះក៏នឹងបន្សីនឹងផែនការនារីរតនៈ (NR) ជំណាក់កាលទី V ក៏ដូចជាផែនការយុទ្ធសាស្ត្រយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (GCCSP) ២០១៤-២០២៣ និងផែនការសកម្មភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (GCCAP) ឆ្នាំ ២០១៩-២០២៣ ជំណាក់កាលទីពីរ ក៏ដូចជាផែនការមេសម្រាប់យេនឌ័រ និងការប្រែប្រួលអាកាសធាតុ (២០១៨-២០៣០) ដែលត្រូវបានរៀបចំ និងប្រើប្រាស់ជាផែនទីបង្ហាញផ្លូវសម្រាប់បង្កើតគម្រោង និងកម្មវិធីដោយក្រសួងកិច្ចការនារី។

ដោយផ្អែកលើអនុសាសន៍ទាំងនេះ ចំណុចនៃសកម្មភាពខាងក្រោមត្រូវបានបង្កើតឡើងជាផ្នែកនៃផែនការសកម្មភាពយេនឌ័រ ដោយមានបន្ថែមព័ត៌មានបន្ថែដូចមានបញ្ជាក់ក្នុងតារាងខាងក្រោម។

*តារាងទី 12. សកម្មភាពផ្តោតការយកចិត្តទុកដាក់លើយេនឌ័រ*

| **សកម្មភាពផ្តោតការយកចិត្តទុកដាក់លើយេនឌ័រ** |
|---|
| សេចក្តីថ្លែងការណ៍អំពីផលប៉ះពាល់៖ កសិករខ្នាតតូចជាស្ត្រី និងតួអង្គខ្សែច្រវាក់តម្លៃក្នុងស្រុកផ្សេងទៀតត្រូវបានផ្តល់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចតាមរយៈការធ្វើឱ្យប្រសើរឡើងនៃលទ្ធភាពប្រើប្រាស់ដែលរំពឹងថានឹងប៉ះពាល់ដល់ផ្នែកទីផ្សារបុព្វលាភដែលកំពុងកើនឡើង ខណៈពេលដែលប្រើប្រាស់លទ្ធភាពទទួលបានទីផ្សារដែលប្រសើរឡើងដើម្បីលើកទឹកចិត្តការផ្លាស់ប្តូររបស់ពួកគេទៅកាន់ការអនុវត្តដែលធន់នឹងអាកាសធាតុ, ជាពិសេស ភាពជាដៃគូរវាងរដ្ឋ ឯកជន និងសហគមន៍យ៉ាងមានប្រសិទ្ធភាព។ |
| លទ្ធផលទី ១៖ សមត្ថភាពរបស់កសិករត្រូវបានពង្រឹង ដើម្បីគ្រប់គ្រងផលប៉ះពាល់អាកាសធាតុ និងហានិភ័យពាក់ព័ន្ធ |
| **លទ្ធផលទី ១.១៖** ភាពអាចរកបាន និងលទ្ធភាពទទួលបានសេវាប្រឹក្សាខាងឧតុនិយម ដែលតម្រូវតាមខ្សែច្រវាក់តម្លៃគោលដៅ មានភាពប្រសើរឡើងក្នុងចំណោមកសិករខ្នាតតូច និងតួអង្គខ្សែច្រវាក់តម្លៃជាស្ត្រី |
| • គាំទ្រការរួមបញ្ចូលការពិចារណាអំពីយេនឌ័រនៅក្នុងលក្ខខណ្ឌមូលដ្ឋាន និងសមត្ថភាព និងគម្លាតទិន្នន័យនៃស្ថានីយ៍ដែលមានស្រាប់ និងតំបន់ដែលត្រូវការ។<br>• គាំទ្រដល់ការអភិវឌ្ឍលក្ខណៈវិនិច្ឆ័យដែលរួមបញ្ចូលការពិចារណាអំពីយេនឌ័រសម្រាប់ការវាយតម្លៃ<br>• ស្ថានីយ៍អាទិភាពសម្រាប់ការធ្វើឱ្យប្រសើរឧបករណ៍ចាប់សញ្ញាបន្ថែម ទីតាំងយុទ្ធសាស្ត្រសម្រាប់ការបន្ថែមស្ថានីយអាកាសធាតុថ្មី និងតម្រូវការបណ្តុះបណ្តាលសម្រាប់អ្នកគ្រប់គ្រងស្ថានីយ៍ អ្នកវិភាគទិន្នន័យ និងអ្នកគ្រប់គ្រងប្រព័ន្ធ<br>• ផ្តល់ការកសាងសមត្ថភាពដល់ TWG-AW ដែលដឹកនាំដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម ជាមួយនឹងអ្នកជំនាញបន្ថែមពីអង្គភាពពាក់ព័ន្ធផ្សេងទៀត លើការពិចារណាអំពីយេនឌ័រដែលភ្ជាប់ទៅនឹងដំណើរការអភិវឌ្ឍ និងប្រមូលផ្តុំពួកគេឱ្យប្រសើរឡើងនូវការរួមបញ្ចូលការពិចារណាអំពីយេនឌ័រនៅក្នុងការរចនាស្ថានីយ៍ និងការផ្តល់ព័ត៌មាន។<br>• ការត្រួតពិនិត្យជាបន្ត និងបញ្ចូលទៅក្នុងការអភិវឌ្ឍសម្ភារៈ TOT និងឧបករណ៍ផ្សេងទៀត ក៏ដូចជាព័ត៌មានស្ដីពីការលើកកម្ពស់ការយល់ដឹងអំពីពួកវា ដើម្បីធានាថាពួកគេអាចចូលប្រើបានសម្រាប់ស្ត្រី និងកសិករជនជាតិភាគតិចដទៃទៀត និងច្រវាក់តម្លៃក្នុងស្រុក។ |
| លទ្ធផលទី ២៖ សមត្ថភាពសម្របខ្លួនរបស់កសិករខ្នាតតូច និងតួអង្គខ្សែច្រវាក់តម្លៃក្នុងស្រុកផ្សេងទៀត ជាពិសេសកសិករស្ត្រីដែលងាយរងគ្រោះ ត្រូវបានបង្កើនតាមរយៈការលើកទឹកចិត្តទីផ្សារដែលលើកកម្ពស់ភាពធន់នឹងអាកាសធាតុ តម្លៃខ្ពស់ ការធ្វើពិពិធកម្ម និងផលិតកម្ម និងដំណើរការប្រកបដោយនិរន្តរភាព។ |
| **លទ្ធផលទី ២.១៖** ឱកាសទទួលបានទីផ្សារពិសេសសម្រាប់អ្នកផលិតគ្រាប់ស្វាយចន្ទី ស្វាយ អង្ករសរីរាង្គ និងអ្នកផលិត និងកែច្នៃបន្លែបានកើនឡើងតាមរយៈកម្មវិធីវិញ្ញាបនប័ត្រដែលធន់នឹងអាកាសធាតុ និងមានតម្លៃខ្ពស់ (ភ្ជាប់ទៅផ្នែករង ២.២. និង ២.៣ សម្រាប់ការផ្តល់ហិរញ្ញប្បទាន និងការកសាងសមត្ថភាពបច្ចេកទេស)។ |
| • ការផ្តល់ការបណ្តុះបណ្តាលដល់ភាគីពាក់ព័ន្ធសំខាន់ៗលើការពិចារណាលើយេនឌ័រជាផ្នែកនៃការអភិវឌ្ឍផែនទីបង្ហាញផ្លូវ។ |

- គាំទ្រការរួមបញ្ចូលយេនឌ័រទៅក្នុងផែនទីបង្ហាញផ្លូវតាមរយៈការពិនិត្យឡើងវិញ និងធាតុចូលសម្រាប់ដំណើរការ និងឯកសារ។
- បង្កើតការវាយតម្លៃយេនឌ័រមូលដ្ឋានដែលមានការចូលរួមនៃសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើជាមួយសមាជិក
- ជួយសមាគមក្រុមអ្នកផលិតក្នុងសហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ និងសហជីពកសិករក្នុងការរៀបចំផែនការសកម្មភាព/ ផែនការអាជីវកម្មជាក់លាក់សម្រាប់ដំណាំសម្រាប់ប្រតិបត្តិការផែនទីបង្ហាញផ្លូវរៀងៗខ្លួនក្នុងទម្រង់បុរសដែលឆ្លើយតបដោយរួមបញ្ចូល និងយេនឌ័រ
- គាំទ្រដល់ការពិនិត្យឡើងវិញ និងបង្កើតគោលការណ៍ណែនាំបន្ថែម ឧបករណ៍ និងសម្ភារៈបណ្តុះបណ្តាលដោយយកចិត្តទុកដាក់លើយេនឌ័រក្នុងបរិបទនៃហានិភ័យអាកាសធាតុ និងយុទ្ធសាស្ត្រសម្រាប់កម្មវិធីវិញ្ញាបនប័ត្រដែលបានកំណត់នៅក្រោមសកម្មភាព ២.១.១។

**លទ្ធផលទី ២.២៖** លទ្ធភាពទទួលបានបច្ចេកវិទ្យាសម្រាប់កសិកម្មដែលធន់នឹងអាកាសធាតុ និងការអភិវឌ្ឍច្រវ៉ាក់តម្លៃត្រូវបានធ្វើឱ្យប្រសើរឡើងក្នុងចំណោមកសិករខ្នាតតូច និងតួអង្គខ្សែច្រវ៉ាក់តម្លៃផ្សេងទៀត ជាពិសេសស្ត្រី (ភ្ជាប់ទៅសមាសភាគរង ២.១ ដើម្បីគាំទ្រផែនការអាជីវកម្មរបស់សមាគមក្រុមអ្នកផលិតរបស់សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ និងសហគមន៍កសិកម្ម)

- គាំទ្រដល់ការពិនិត្យឡើងវិញ និងបង្កើតជម្រើសហិរញ្ញវត្ថុហានិភ័យដោយផ្អែកលើការពិចារណាអំពី យេនឌ័រ
- គាំទ្រដល់ការអភិវឌ្ឍសម្ភារៈ និងយុទ្ធសាស្ត្រលើកកម្ពស់ការយល់ដឹង ដើម្បីធានាថាពួកគេឆ្លើយតបយ៉ាងពេញលេញអំពីយេនឌ័រ។

**លទ្ធផលទី ២.៣៖** ការយល់ដឹង និងចំណេះដឹងអំពីកសិកម្មដែលធន់នឹងអាកាសធាតុ និងនិរន្តរភាព កសិកម្មដែលមានតម្លៃខ្ពស់បានកើនឡើងក្នុងចំណោមកសិករ និងតួអង្គខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀត ជាពិសេសកសិករស្ត្រី និងតួអង្គខ្សែច្រវ៉ាក់តម្លៃ (ភ្ជាប់ទៅផ្នែករង ២.១ ដើម្បីគាំទ្រដល់ប្រតិបត្តិការនៃផែនការអាជីវកម្មដោយសមាគមក្រុមអ្នកផលិតរបស់សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ និងសហគមន៍កសិកម្ម)។

- បញ្ចូលទៅក្នុងការអភិវឌ្ឍយន្តការបោសសម្អាតផ្ទះដើម្បីធានាថាវាចាប់យកព័ត៌មានផ្អែកលើយេនឌ័រប្រកបដោយប្រសិទ្ធភាព និងផ្តល់ព័ត៌មានឆ្លើយតបយេនឌ័រយ៉ាងពេញលេញ។
- គាំទ្រដល់ការអភិវឌ្ឍការបណ្តុះបណ្តាលសម្រាប់មន្ត្រីផ្នែកបន្ថែម អ្នកលក់រាយ អ្នកសណ្ឋាគារ ភោជនីយដ្ឋាន និងពាណិជ្ជករ/អ្នកនាំចេញ ដែលបង្កើនការយល់ដឹងអំពីការពិចារណាលើយេនឌ័រនៅក្នុងក្រុមកសិកម្ម និងលើកកម្ពស់គុណភាពនៃការផ្តល់សេវា។

**លទ្ធផលទី ២.៤៖** ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌកសិ-អេកូឡូស៊ី និងការតភ្ជាប់។

សូមមើលការគាំទ្រនៅក្រោមសកម្មភាព ២.១។

លទ្ធផលទី ៣៖ ក្របខ័ណ្ឌបទប្បញ្ញត្តិ និងស្ថាប័ន និងសមត្ថភាពសម្រាប់វិញ្ញាបនប័ត្រកសិកម្មដែលធន់នឹងអាកាសធាតុ ការសម្របសម្រួលឆ្លងវិស័យសម្រាប់ការបង្កើន PSPPs និងការផ្តល់ហិរញ្ញប្បទានដល់ម្ចាស់អាជីវកម្មខ្នាតតូច និងការគាំទ្រការវិនិយោគដែលមានព័ត៌មានអំពីអាកាសធាតុត្រូវបានពង្រឹង។

| |
|---|
| **លទ្ធផលទី ៣.១៖** ការរៀបចំបទប្បញ្ញត្តិ និងស្ថាប័ន និងសមត្ថភាពពាក់ព័ន្ធក្នុងការអភិវឌ្ឍប្រវ៉ាក់តម្លៃផ្អែកលើវិញ្ញាបនបត្រត្រូវបានពង្រឹង ដើម្បីផ្តល់លក្ខខណ្ឌអំណោយផលសម្រាប់ការទទួលយកកសិកម្មដែលធន់នឹងអាកាសធាតុ តម្លៃខ្ពស់ និងនិរន្តរភាព និងសន្តិសុខស្បៀង។ |
| • ការពិនិត្យឡើងវិញជាមូលដ្ឋាននៃការពិចារណាអំពីយេនឌ័រនៅក្នុងគោលនយោបាយដែលមានស្រាប់និងបរិយាកាសអំណោយផល<br>• បញ្ចូលទៅក្នុងការអភិវឌ្ឍនៃបរិស្ថានបទប្បញ្ញត្តិដែលបានកែប្រែ |
| **លទ្ធផលទី ៣.២៖** ប្រព័ន្ធត្រួតពិនិត្យបរិស្ថានវិទ្យាកម្រិតទេសភាពដែលឆ្លើយតបនឹងយេនឌ័រ (LAMS) ត្រូវបានបង្កើតឡើងសម្រាប់ហ្វូងមនុស្សនៅក្នុងការវិនិយោគសាធារណៈ និងឯកជនក្នុងវិស័យកសិកម្មដែលធន់នឹងអាកាសធាតុ តម្លៃខ្ពស់ និងនិរន្តរភាព។ |
| • ការពិនិត្យឡើងវិញជាមូលដ្ឋាននៃតម្រូវការយេនឌ័រក្នុងការអភិវឌ្ឍ LAMS<br>• បញ្ចូលទៅក្នុងការអភិវឌ្ឍ LAMS និង SOP<br>• ការដាក់បញ្ចូលការពិចារណាអំពីយេនឌ័រក្នុងការលើកកម្ពស់ការយល់ដឹង និងសម្ភារៈបណ្តុះបណ្តាល។ |

## ៩. ក្របខ័ណ្ឌការគ្រប់គ្រងជីវៈចម្រុះ

### ៩.១ សេចក្តីផ្តើម

២៩៦. ហានិភ័យលើជីវៈចម្រុះពីសម្រាប់គម្រោង PEARL ត្រូវបានកំណត់ថាខ្ពស់ នៅក្នុងការវាយតម្លៃបឋមរបស់អង្គការ FAO លើកត្តាហានិភ័យ ដោយសារការអនុវត្តសកម្មភាពរបស់គម្រោងនៅក្នុងតំបន់ការពារធម្មជាតិ។

២៩៧. ទោះបីជាយ៉ាងណាក៏ដោយ ការរៀបចំគម្រោង និងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ (ដែលបានបញ្ចូលក្នុងឯកសារនេះ) ត្រូវបានមើលឃើញថាមានលក្ខណៈគ្រប់គ្រាន់ ដើម្បីធានាថា ការអនុវត្តគម្រោងនឹងមិនមានកត្តាហានិភ័យដែលអាចកើតមានលើជីវៈចម្រុះនោះទេ។ កត្តានេះអាចសម្រេចបានតាមរយៈ៖

- ក. ការរៀបចំគម្រោងជារួមដែលផ្តោតការយកចិត្តទុកដាក់លើការកសាងសមត្ថភាពរបស់សហគមន៍ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដូច្នេះបង្កើនភាពស៊ាំ និងកាត់បន្ថយលទ្ធភាពនៃផលប៉ះពាល់ដែលមានការកើនឡើងលើតំបន់ព្រៃឈើ។
- ខ. ការជ្រើសរើសទីតាំងក្នុងសហគមន៍តំបន់ការពារធម្មជាតិ និងសហគន៍ព្រៃឈើដែលធ្វើឡើងដោយផ្អែកលើទីតាំងដែលមានគណៈកម្មការគ្រប់គ្រងសហគមន៍ខ្លាំងជាស្រេចដែលអាចអនុវត្តផែនការស្របតាមគោលដៅរបស់គម្រោង និង/ឬគឺជាតំបន់ដែលមានតម្រូវការចាំបាច់សម្រាប់ស្តារឡើងវិញ និងគាំទ្រ ហើយដូចនេះ កិច្ចអន្តរាគមន៍របស់គម្រោងនឹងកំណត់ពីការកែលម្អយ៉ាងច្រើនលើសពីស្ថានភាពមូលដ្ឋាន។
- គ. សកម្មភាពនៃការស្តារព្រៃឈើដែលត្រូវអនុវត្ត ស្របតាមផែនការគ្រប់គ្រងសម្រាប់តំបន់គោលដៅនីមួយៗដោយប្រើប្រាស់អភិក្រមផ្អែកលើវិធីសាស្ត្រវាយតម្លៃឱកាសស្តារព្រៃឈើឡើងវិញ (ROAM) (Bernacki et al., 2018) របស់អង្គការ FAO និងអង្គការ IUCN រួមទាំងអភិក្រមអនុវត្តល្អបំផុតនានានៅថ្នាក់ជាតិក្នុងការស្តារព្រៃឈើឡើងវិញ។
- ឃ. គាំទ្រលើកសិកម្ម ដោយផ្តោតការយកចិត្តទុកដាក់លើការការចូលរួម ដោយប្រើប្រាស់បទដ្ឋាននិរន្តរភាព ដែលអាចលើកម្ពស់/មិនមានការកាប់បំផ្លាញព្រៃឈើ។
- ង. ការប្រើប្រាស់គោលការណ៍ណែនាំច្បាស់លាក់ និងសកម្មភាពគ្រប់គ្រងហានិភ័យ រួមទាំងការវាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គមតាមទីតាំងជាក់លាក់ ការរៀបចំផែនទីតំបន់កសិកម្មនិងតំបន់ស្តារឡើងវិញ និងការចូលរួមជាបន្តជាមួយក្រុមសហគមន៍ (មើលតារាងទី ១៣ អំពីផលប៉ះពាល់ជាយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រគ្រប់គ្រង)។

២៩៨. កាន់តែទូលំទូលាយជាងនេះទៀត គម្រោងក៏ត្រូវបានកំណត់ផងដែរថានឹងអាចផ្តល់ផលប្រយោជន៍យ៉ាងច្រើន ដោយមានយន្តការសុវត្ថិភាពសមស្រប។ គម្រោងនេះនឹងផ្តល់ផលប្រយោជន៍ រួមមានកាបូនស្តុកមានប្រភពមកពីការដាំដុះដើមស្វាយ និងដើមស្វាយចន្ទី នៅលើទីតាំងដីដែលពីមុនត្រូវបានប្រើប្រាស់សម្រាប់ដាំដុះដំណាំប្រចាំឆ្នាំ ដូចជាដំឡូងមីជាដើម។ គម្រោង PEARL នឹងបង្ការមិនឱ្យមានការពង្រីកផ្ទៃដីចម្ការបន្ថែមទៅក្នុងតំបន់ព្រៃឈើដែលមានស្រាប់នោះទេ។ ក្រៅពីនេះ គម្រោងនឹងស្តារឡើងវិញ និងការពារផ្ទៃដីព្រៃអាងរងទឹកភ្លៀងសំខាន់ៗទំហំ ៧៦០០ ហិកតា និងតំបន់ការពារប្រភពទឹកសំខាន់ៗផ្សេងៗទៀតនៅផ្នែកខាងលើនៃតំបន់ទីជម្រាល តាមរយៈការគ្រប់គ្រងទីជម្រាលចម្រុះ (IWM) និងអន្តរាគមន៍កសិ-រុក្ខកម្ម។

២៩៩. គម្រោងក៏ត្រូវបានរំពឹងទុកបន្ថែមទៀតផងដែរក្នុងពង្រឹងការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ និងការការគ្រប់គ្រងធនធានធម្មជាតិដោយចីរភាព និងសុាំនឹងអាកាសធាតុ ដោយរំពឹងថា គម្រោងនេះលើកកម្ពស់ការយល់ដឹងពីសារៈសំខាន់នៃការបញ្ច្រាបវិធានការកាត់បន្ថយ និងវិធានការបបន្សាំនឹងការប្រែប្រួលអាកាសធាតុទៅក្នុងការគ្រប់គ្រងព្រៃឈើ និងការគ្រប់គ្រងកសិដ្ឋានរបស់ពួកគេ។

## ៩.២ គោលបំណង និងវិធីសាស្ត្រអភិរក្សជីវៈចម្រុះ

៣០០. ក្របខ័ណ្ឌគ្រប់គ្រងជីវៈចម្រុះនេះមានគោលបំណងពិពណ៌នាពីផែនការដែលបានគ្រោងទុក និងត្រូវបានអនុវត្តដោយគម្រោង PEARL ដើម្បីធានាសុវត្ថិភាពធនធានជីវៈចម្រុះ គ្រប់គ្រងនិងកាត់បន្ថយផលប៉ះពាល់ដែលអាចនឹងកើតមានឡើងក្នុងអំឡុងពេលអនុវត្តគម្រោង។

៣០១. ជីវៈចម្រុះត្រូវបានមើលឃើញថាមានផ្តល់ប្រយោជន៍បន្ថែមយ៉ាងច្រើន តាមរយៈសកម្មភាពរបស់គម្រោង ហើយគម្រោងនេះត្រូវបានបន្សីុគ្នាទៅនឹងយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះ ឆ្នាំ២០១៦-២០២០ ដែលក្នុងនោះរួមមានសកម្មភាពជាអាទិភាពដល់សកម្មភាពគ្រប់គ្រងដោយសហគមន៍ និងសកម្មភាពពីការប្រែប្រួលអាកាសធាតុ។ គម្រោងនេះក៏មានលក្ខណៈស្របគ្នានឹងយុទ្ធសាស្ត្រជាតិស្តីពីតំបន់ការពារធម្មជាតិឆ្នាំ ២០១៧ របស់ប្រទេស ដែលផ្តោតសំខាន់លើការពង្រឹងការអភិរក្ស និងការស្តារតំបន់ឡើងវិញនូវតំបន់ការពារធម្មជាតិ (ក្នុងគោលដៅយុទ្ធសាស្ត្រទី ១) ការលើកកម្ពស់ការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងពង្រឹងជីវភាពរស់នៅរបស់សហគមន៍ (គោលដៅយុទ្ធសាស្ត្រទី ៤៖ បង្កើនការចូលរួមរបស់សហគមន៍ និងអត្ថប្រយោជន៍)។

៣០២. ដូចនេះ គម្រោងនឹងប្រើប្រាស់វិធីសាស្ត្រជាក់លាក់មួយ ដោយផ្អែកមិនត្រឹមតែលើការវិនិយោគផ្ទាល់ដើម្បីពង្រឹងភាពសុាំរបស់សហគមន៍មូលដ្ឋាន និងប្រព័ន្ធអេកូឡូស៊ីប៉ុណ្ណោះទេ តែថែមទាំងលើការពង្រឹងសមត្ថភាពស្ថាប័ននៅថ្នាក់ខេត្ត ថ្នាក់មូលដ្ឋាន(ទីប្រជុំជននៅជនបទ) និងអង្គការគ្រប់គ្រងដោយសហគមន៍ និងលើកកម្ពស់ការយល់ដឹង ការផ្តល់ចំណេះដឹង និងការប្រាស្រ័យទាក់ទង។ ជាមួយគ្នានេះ វិធានការទាំងនេះនឹងជួយគាំទ្រដល់ការផ្លាស់ប្តូរទៅរកការអនុវត្តកសិកម្មដែលសុាំនឹងអាកាសធាតុ នៅក្នុងវិស័យប្រើប្រាស់ដីធ្លី។

៣០៣. នៅក្នុងបរិបទនៃ ESMF នៅពេលអ្នកទទួលផលពីគម្រោង (សហគមន៍កសិកម្ម ក្រុមសហគមន៍ព្រៃឈើ និងក្រុមសហគមន៍តំបន់ការពារធម្មជាតិ) និងអន្តរាគមន៍ជាក់លាក់នៅក្នុងទីតាំងជាក់លាក់ណាមួយ (ពោលគឺផែនការស្តារ និងសកម្មភាពគាំទ្រការងារកសិកម្ម ព្រមទាំងបទដ្ឋានវិញ្ញាបនប័ត្រកសិកម្ម) ត្រូវបានកំណត់រួចហើយនោះ សកម្មភាពត្រួតពិនិត្យវាយតម្លៃបរិស្ថាន និងសង្គមនឹងធ្វើឡើងដោយប្រើប្រាស់តារាងផ្ទៀតផ្ទាត់វាយតម្លៃបរិស្ថាន និងសង្គមរបស់អង្គការ FAO។ ឧបករណ៍នេះនឹងជួយក្នុងការកំណត់អនុសកម្មភាពដែលទាមទារឱ្យមានវិធានការកាត់បន្ថយ ក្នុងនោះរួមទាំងវិធាននានាដែលបានពិភាក្សាក្នុងផ្នែកទី ៦ នៃឯកសារនេះ។ ចំពោះអនុសកម្មភាពដែលត្រូវការវិធានការកាត់បន្ថយ ក្រុមការងារនឹងរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គមដើម្បីត្រួតពិនិត្យក្នុងដំណាក់កាលអនុវត្តគម្រោង។

### ហានិភ័យដែលបានរកឃើញ និងវិធានការកាត់បន្ថយ

៣០៤. ជាផ្នែកមួយនៃដំណាក់កាលនៃការរៀបចំគម្រោង ហានិភ័យមួយចំនួនត្រូវបានកំណត់អត្តសញ្ញាណ រួមទាំងកំណត់កម្រិតហានិភ័យជាសក្តានុពល និងវិធានការកាត់បន្ថយ។ ហានិភ័យ និងវិធានការកាត់បន្ថយមានបញ្ជាក់ក្នុងតារាងខាងក្រោម៖

*តារាងទី 13. ទិដ្ឋភាពរួមនៃផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានលើជីវៈចម្រុះបណ្តាលមកពីសកម្មភាពគម្រោង*

| ផលប៉ះពាល់អវិជ្ជមាន | លទ្ធភាពកើតមាន | ផលប៉ះពាល់ | កម្រិតហានិភ័យ | វិធានការកាត់បន្ថយ |
|---|---|---|---|---|
| ការឈូសឆាយព្រៃឈើក្នុងគោលបំណងពង្រីកដីធ្វើកសិកម្ម | អាច[18] | ទាប | ទាប | វិធានការកាត់បន្ថយមួយចំនួនមានជាធរមាន ហើយត្រូវបានអនុវត្តដើម្បីកាត់បន្ថយផលប៉ះពាល់នេះ ក្នុងនោះរួមមាន៖<br>- ការជ្រើសរើសទីតាំង និងការគាំទ្រជាបន្ត៖ ទីតាំងក្នុងសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើត្រូវបានជ្រើសរើស ដោយផ្អែកលើសមត្ថភាព ក្នុងការគ្រប់គ្រងទីតាំងរបស់ពួកគេ។ ដូច្នេះ សហគមន៍ទាំងនេះត្រូវបានជ្រើសរើសឱ្យអនុវត្តផែនការគ្រប់គ្រង និងគ្រប់គ្រងវិវាទនានានៅមូលដ្ឋាន ដែលជាប់ទាក់ទងនឹងហានិភ័យនៃការពង្រីកដី។<br>- ការត្រួតពិនិត្យទីតាំង៖ តំបន់កសិកម្មនឹងត្រូវរៀបចំដាក់បញ្ចូលក្នុងផែនទី និងត្រួតពិនិត្យដើម្បីធានាកុំឱ្យពង្រីកបន្ថែមនៅក្នុងតំបន់ការពារធម្មជាតិ។<br>- ការពិនិត្យវាយតម្លៃលើសកម្មភាពទាំងអស់ដែលបានស្នើឡើងដើម្បីអនុវត្តក្នុងតំបន់ការពារធម្មជាតិ។<br>- គោលការណ៍វិញ្ញាបនប័ត្រកសិកម្មដោយមិនមានការបាត់បង់ព្រៃឈើ៖ ការផ្តោតការយកចិត្តទុកដាក់លើការគាំទ្រឱ្យមានការចូលរួមអនុវត្តបទដ្ឋានវិញ្ញាបនប័ត្រកសិកម្មដែលតម្រូវឱ្យប្រើប្រាស់វិធីសាស្ត្រមិនកាប់បំផ្លាញព្រៃឈើ និងការអភិរក្សជីវៈចម្រុះ។ |
| ផលប៉ះពាល់នៅតាមទីតាំងជាក់លាក់ ដែលមានជាប់ទំនាក់ទំនងនឹងសកម្មភាពកសិកម្ម (ពោលគឺការហូរច្រោះដីកើនឡើងពីសកម្មភាពកសិកម្ម) | អាច | ទាប | ទាប | - វិធានការកាត់បន្ថយមួយចំនួនមានជាធរមាន និងត្រូវបានអនុវត្តដើម្បីដោះស្រាយផលប៉ះពាល់នេះ ក្នុងនោះរួមមាន៖<br>- ការជ្រើសរើសទីតាំង និងការគាំទ្រជាបន្ត៖ តំបន់ក្នុងសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើត្រូវបានជ្រើសរើស ដោយផ្អែកលើសមត្ថភាពក្នុងការគ្រប់គ្រងតំបន់របស់ពួកគេ។ ជាលទ្ធផល សហគមន៍ទាំងនេះត្រូវជ្រើសរើសដើម្បីអនុវត្តផែនការគ្រប់គ្រង និងអនុវត្តតាមគោលការណ៍អនុវត្តល្អ។<br>- ការផ្តល់ការបណ្តុះបណ្តាល និងការរៀបចំគោលការណ៍ណែនាំ៖ គោលការណ៍ណែនាំ និងការបណ្តុះបណ្តាលមួយចំនួននឹងត្រូវរៀបចំឡើង ដោយផ្តោតលើការជ្រើសរើសនិងអនុវត្តការអនុវត្តកសិកម្មល្អ ដែលនឹងជួយទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានណាមួយពីទីតាំងផលិតកម្ម។ |

[18]Through actions to increase the value of agriculture and level of productivity per ha there is a risk that this will contribute to increasing pressure to expand land area under production. Conversely such increases may also help to mitigate this threat as communities require less land for subsistence production and to meet their income needs.

| | | | | |
|---|---|---|---|---|
| | | | | - ការត្រួតពិនិត្យវាយតម្លៃសកម្មភាពទាំងអស់ដែលបានស្នើឡើង ដើម្បីត្រូវអនុវត្តក្នុងតំបន់ការពារធម្មជាតិ។<br>- ការលើកកម្ពស់ការអនុវត្តកសិកម្មល្អដោយផ្អែកលើគោលការណ៍វិញ្ញាបនប័ត្រកសិកម្មៈ ការលើកកម្ពស់គោលការណ៍ទាំងនេះ នឹងជួយដល់អ្នកផលិតជាគោលដៅដល់ការអនុវត្តការអនុវត្តកសិកម្មល្អ ដើម្បីធានាទីផ្សារផលិតផល។ |
| ប្រភេទរាតត្បាតដែលត្រូវបានបញ្ចូលទៅក្នុងតំបន់គោលដៅ | អាច | មធ្យម | ទាប | វិធានការកាត់បន្ថយមួយចំនួនមានជាធរមាន និងត្រូវបានអនុវត្តដើម្បីដោះស្រាយផលប៉ះពាល់នេះ ក្នុងនោះរួមមានៈ<br>- សកម្មភាពដាំឈើ និងស្តារព្រៃឈើឡើងវិញទាំងអស់នឹងត្រូវធ្វើឡើង ស្របតាមការអនុវត្តល្អក្នុងការដាំស្តារព្រៃឈើ ដូចមានបញ្ជាក់ក្នុងវិធីសាស្ត្រវាយតម្លៃឱកាសស្តារព្រៃឈើឡើងវិញ (ROAM_ Bernacki et al., 2018) របស់អង្គការ FAO និងអង្គការ IUCN រួមទាំងអភិក្រមនៃការអនុវត្តល្អបំផុតនានានៅថ្នាក់ជាតិ លើការស្តារព្រៃឈើឡើងវិញ។ ករណីនេះនឹងដាក់បញ្ចូលទាំងការជ្រើសរើសប្រភេទដោយយកតែប្រភេទក្នុងស្រុក ឬប្រភេទដែលមានភាពស៊ាំខ្លាំង។<br>- កូនឈើបង្កាត់ពីដាលិកា (planting stock) ទាំងអស់ ត្រូវយកពីអ្នកផ្គត់ផ្គង់ដែលមានការទទួលស្គាល់ច្បាស់លាស់នៅក្នុងស្រុក ដើម្បីបង្កាដល់ការដាំប្រភេទរាតត្បាតចម្រៃ និងដើម្បីធានាថាគ្មានការបញ្ជូនប្រភេទរុក្ខជាតិរាតត្បាតដោយចៃដន្យឡើយ។ |

៣០៥. ការវិភាគពិស្តារពីផលប៉ះពាលអវិជ្ជមានជាសក្តានុពល នឹងត្រូវបានអនុវត្ត ដោយមានលម្អិតនៅក្នុងផែនការគ្រប់គ្រងជីវៈចម្រុះ ដំណាក់កាលបើកដំណើរការគម្រោង និងអនុវត្តគម្រោងនៅដំណាក់កាលដំបូងៗ។

៣០៦. ព័ត៌មានបន្ថែមពីស្ថានភាពជីវៈចម្រុះ តំបន់ការពារធម្មជាតិនៅកម្ពុជា និងដំណើរនៃការជ្រើសរើសទីតាំង និងលក្ខណៈនៃសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើជាគោលដៅ ក៏ត្រូវបានបញ្ជាក់ដូចខាងក្រោម ដើម្បីផ្តល់ព័ត៌មានបន្ថែមទៀតអំពីអភិក្រមកាត់បន្ថយផលប៉ះពាល់បឋម និងបង្ហាញពីបរិបទនៃហានិភ័យផងដែរ។

## ៩.៣ ស្ថានភាពជីវៈចម្រុះ

៣០៧. កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសនៅអាស៊ីអគ្នេយ៍ដែលមានធនធានជីវៈចម្រុះច្រើនជាងគេបំផុត ក្នុងនោះរួមមានរុក្ខជាតិចំនួន ៨២៦០ប្រភេទ ផលជលិកសត្វនិងល្មូនចំនួន ២៥០ប្រភេទ ត្រីចំនួន ៨៧៤ប្រភេទ និងបក្សីជាង ៥០០ប្រភេទ[19]។ ប្រទេសកម្ពុជាមានតំបន់ប្រព័ន្ធអេកូឡូស៊ីចំនួន ៨ តំបន់ ក្នុងរួមមានព្រៃបៃតងតំបន់ភ្នំភាគខាងត្បូងអាណាម ព្រៃបៃតងជួរភ្នំក្រវាញ ព្រៃតំបន់ដីសើមទឹកសាបតំបន់បឹងទន្លេសាប ព្រៃតំបន់ដីមមោកទន្លេមេគង្គ ព្រៃរបោះតំបន់ត្រូពិកនិងអនុត្រូពិក ព្រៃតំបន់ស្ងួតនៅភាគកណ្តាលឥណ្ឌូចិន ព្រៃស្រោងស្ងួតនៅភាគខាងត្បូង

[19] https://www.fauna-flora.org/countries/cambodia/

ឥណ្ឌូចិន ព្រៃកោងកាងឥណ្ឌូចិន និងតំបន់ទឹកសាបមេគង្គ[20]។ ប្រទេសកម្ពុជាជាទីជម្រកនៃប្រភេទសត្វធំៗជាច្រើន ដូចជា ដំរី ខ្លាឃ្មុំ និងខ្ទីង ជាដើម (ត្រូវបានគេស្គាល់ដែរថាគោព្រៃឥណ្ឌា ដែលជាអំបូរគោសាទិសធំជាងគេបំផុតនៅលើពិភពលោក)។

៣០៨. ការអភិរក្សជីវៈចម្រុះ និងការលើកកម្ពស់ការអភិវឌ្ឍដោយចីរភាពជាការងារអាទិភាពរបស់ប្រទេស។ ប្រទេសកម្ពុជាក៏មានប្រព័ន្ធតំបន់ការពារធម្មជាតិដ៏ធំធេង ដែលក្នុងនោះរួមមាន សហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើ។ ប្រព័ន្ធតំបន់ការពារធម្មជាតិនេះមានតួនាទីយ៉ាងសំខាន់ក្នុងការអភិរក្សជីវៈចម្រុះ ហើយគ្របដណ្តប់លើផ្ទៃដីប្រមាណ ៣៩% នៃផ្ទៃដីសរុបរបស់ប្រទេស ដែលនេះជាអត្រាតំបន់ការពារធម្មជាតិដ៏ខ្ពស់ជាងគេមួយនៅក្នុងពិភពលោក។ ដោយសារតែភាពសម្បូរបែបនៃធនធានជីវៈចម្រុះនេះ តំបន់បឹងទន្លេសាបដែលជាតំបន់គោលដៅរបស់គម្រោង ត្រូវបានកំណត់ជាបរិមណ្ឌលជីវៈមណ្ឌលរបស់អង្គការ UNESCO ហើយតំបន់ការពារធម្មជាតិមួយចំនួនមានទីតាំងស្ថិតនៅភាគខាងជើងនៃតំបន់គោលដៅរបស់គម្រោងដែលគ្របដណ្តប់ផ្នែកខាងលើនៃផ្ទៃអាងរងទឹកភ្លៀងនៃបឹងទន្លេសាប ហើយអាស្រ័យហេតុនេះមានសារៈសំខាន់សម្រាប់ការបំពេញមុខងារនៃប្រព័ន្ធធម្មជាតិទាំងមូល។

៣០៩. ទោះបីជាប្រទេសកម្ពុជាមានការយកចិត្តខ្ពស់លើស្ថានភាពតំបន់ការពារធម្មជាតិក៏ដោយ ក៏តំបន់ទាំងនេះនៅតែរងការគម្រាមកំហែងពីការអនុវត្តគ្មាននិរន្តរភាព ដូចជាការប្រែក្លាយដីព្រៃជាដីកសិកម្មជាដើម។ ប្រទេសកម្ពុជាប្រឈមនឹងបញ្ហាសំខាន់ៗក្នុងអភិវឌ្ឍន៍សេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ដោយមិនដកហូតធនធានធម្មជាតិដ៏វិសេសវិសាល ដែលប្រការនេះធ្វើឱ្យកាន់តែពិបាកដោយសារតែសមត្ថភាពមានកំណត់ផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសក្នុងគ្រប់គ្រងបរិស្ថានដោយចីរភាព។ គម្របព្រៃឈើក្នុងប្រទេសកម្ពុជាបានធ្លាក់ចុះមកត្រឹម ២០% តាំងពីឆ្នាំ១៩៩០ ហើយការនេសាទសមុទ្រហួសកម្រិតបានធ្វើឱ្យធនធានបរិស្ថានមានការថយចុះយ៉ាងខ្លាំង។ បុព្វហេតុនៃការអនុវត្តគ្មាននិរន្តរភាពមានទំនាក់ទំនងជាសំខាន់ជាមួយនឹងតម្រូវបំពេញប្រាក់ចំណូល និងសុវត្ថិភាពស្បៀង ដែលជាធម្មតាតាមរយៈការពង្រីកកសិកម្ម។

៣១០. មូលដ្ឋានគ្រឹះនៃច្បាប់ស្តីពីកិច្ចការពារធនធានជីវិផ្លីរបស់ប្រទេសកម្ពុជា ត្រូវបានតាក់តែងឡើងជាយូរណាស់មកហើយ។ ក្នុងឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលកម្ពុជាចេញព្រះរាជក្រឹត្យមួយ ដើម្បីកំណត់ទីតាំង ២៣ តំបន់គ្របដណ្តប់លើមានផ្ទៃដីប្រមាណជា ៣,៣ លានហិកតា (១៨,៣% នៃផ្ទៃដីសរុប) ជាតំបន់ការពារធម្មជាតិ (បច្ចុប្បន្នកើនឡើងរហូតដល់ ៣៩%)។ និយមន័យនៃ "តំបន់ការពារធម្មជាតិ" ត្រូវបានបង្កើតឡើង ជា "កន្លែងផ្តល់កិច្ចការពារបន្ថែមដើម្បីគាំទ្រដល់ការអភិរក្សរយៈពេលវែងនូវសត្វព្រៃ ធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី និងវប្បធម៌"។

៣១១. នៅក្នុងឆ្នាំថ្មីៗនេះ ប្រទេសកម្ពុជាមានវឌ្ឍនភាពយ៉ាងច្រើនក្នុងការតាក់តែងច្បាប់ លិខិតបទដ្ឋានគតិយុត្តសម្រាប់ការអភិរក្ស និងការគ្រប់គ្រងតំបន់ការពារធម្មជាតិដោយចីរភាព។ នៅឆ្នាំ២០១៥ ក្រសួងបរិស្ថាននៃប្រទេសកម្ពុជាបានចាប់ផ្តើមរៀបចំសេចក្តីព្រាងសំណុំច្បាប់ថ្មីស្តីពីបរិស្ថានក្នុងគោលបំណងកែលម្អអភិបាលកិច្ចបរិស្ថាន ដែលនៅពេលនេះស្ថិតក្នុងដំណាក់កាលចុងក្រោយនៃការរៀបចំតាក់តែង។ ក្រមបរិស្ថាន និងធនធានធម្មជាតិ (ENR Code) ដែលត្រូវបានតាក់តែងឡើងក្នុងការកែលម្អនេះ គឺជាសំណុំច្បាប់ដែលវែងជាងគេបង្អស់របស់កម្ពុជា គ្របដណ្តប់លើវិស័យជាច្រើន និងផ្តល់ការការពារបរិស្ថានមានកម្រិតខ្ពស់បំផុត លក្ខណៈបើកចំហរ និងមានការគណនេយ្យភាពជាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមុនៗក្នុងវិស័យបរិស្ថាននៃប្រទេសកម្ពុជា។ ក្រមនេះមាន

---

[20] World Wildlife Fund (WWF) Ecoregions by country.

បញ្ចូលបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងធនធានធម្មជាតិដោយចីរភាព ជាពិសេសកិច្ចការពារធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ដោយការអនុវត្តជាក់ស្តែង នៅក្នុងរបៀងសត្វព្រៃ និងការពារប្រភេទសំខាន់ៗ។

៣១២. ដើម្បីកែលម្អការគ្រប់គ្រងព្រៃឈើក្នុងតំបន់ការពារធម្មជាតិ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការផ្ទេរប្តូរដែនសមត្ថកិច្ចគ្រប់គ្រងព្រៃឈើរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាននៅឆ្នាំ២០១៦ ក្នុងគោលបំណងធានាឱ្យមានបែងចែកច្បាស់លាស់ពីមុខងារព្រៃឈើ ការបែងចែកតំបន់ព្រៃឈើ និងការទទួលខុសត្រូវលើការគ្រប់គ្រង។ ក្នុងឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើនតំបន់ការពារធម្មជាតិរហូតដល់ចំនួន ៥៥ តំបន់ (ពីចំនួន ២៣ តំបន់ក្នុងឆ្នាំ១៩៩៣) និងរបៀងអភិរក្សជីវៈចម្រុះចំនួន ០៣ តំបន់ ដែលមានផ្ទៃដីប្រមាណ ៧,២ លានហិកតា ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។ តំបន់ទាំងនេះគ្រប់គ្រងដោយក្របខ័ណ្ឌច្បាប់ ក្នុងនោះរួមទាំងរាជក្រឹត្យនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ និងច្បាប់ស្តីពីការការពារបរិស្ថាន និងការអភិវឌ្ឍធនធានធម្មជាតិ ឆ្នាំ១៩៩៦។ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ ចែងពីមូលដ្ឋានគតិយុត្តក្នុងការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ ហើយជាលទ្ធផលអនុញ្ញាតឱ្យមានការគ្រប់គ្រងសហគមន៍មូលដ្ឋាន និងសិទ្ធិប្រើប្រាស់ធនធានធម្មជាតិជាប្រពៃណី។ រហូតដល់ត្រឹមឆ្នាំ២០១៨ សហគមន៍តំបន់ការពារធម្មជាតិចំនួន ១៥៣ សហគមន៍ត្រូវបានបង្កើតឡើងនៅក្នុងតំបន់ការពារធម្មជាតិ ដោយគ្របដណ្តប់លើផ្ទៃដីសរុបប្រមាណ ២៤៦.៦៣០ ហិកតា។

## ៩.៤ សហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើគោលដៅ

### ៩.៤.១ ទិដ្ឋភាពរួម

៣១៣. គម្រោងភាពជាដៃគូរវាងរដ្ឋ ឯកជន និងសហគមន៍ដើម្បីលើកកម្ពស់កសិកម្មភាតរបរិស្ថាន និងជីវភាពដែលធន់នឹងអាកាសធាតុរបស់សហគមន៍នៅភាគខាងជើងនៃបឹងទន្លេសាប (PEARL) នៅក្រោមលទ្ធផលរំពឹងទុក ២.៤ គាំទ្រលើការស្តារព្រៃឈើទំហំ ៧.៦០០ ហិកតា (ហត) នៃព្រៃក្នុងតំបន់ផ្ទៃអាងរងទឹកភ្លៀងសំខាន់ៗ និងតំបន់អេកូឡូស៊ីផុយស្រួយផ្សេងៗទៀត នៅតំបន់ទីជម្រាលផ្នែកខាងលើ តាមរយៈការគ្រប់គ្រងតំបន់ទីជម្រាលចម្រុះ (IWM) និងអន្តរាគមន៍លើកសិ-រុក្ខកម្ម ដោយសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើ។ ការជ្រើសរើសទីតាំងទាំងនេះត្រូវធ្វើឡើងដោយក្រុមអ្នកជំនាញថ្នាក់ជាតិ ដោយផ្អែកលើគោលការណ៍ណែនាំស្តីពីវិធីសាស្ត្រក្នុងវាយតម្លៃឱកាសក្នុងការស្តារព្រៃឈើឡើងវិញ (ROAM) (Bernacki et al., 2018) រួមទាំងព័ត៌មានក្នុងការរៀបចំគម្រោងដើម្បីរៀបចំលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសទីតាំង។ បន្ទាប់មក ចំណុចនេះត្រូវបូកបន្ថែមទៅនឹងការចូលរួមយ៉ាងទូលំទូលាយពីមន្ត្រីរដ្ឋាភិបាល និងបុគ្គលិកអង្គការ រួមទាំងការពិភាក្សាជាមួយតំណាងសហគមន៍មូលដ្ឋានបន្ថែមទៀត។

៣១៤. លទ្ធផលនៃការវាយតម្លៃបានកំណត់អត្តសញ្ញាណ និងណែនាំសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើសរុបទាំងអស់ចំនួន ២០ សហគមន៍ដើម្បីឱ្យទទួលបានការគាំទ្រពីគម្រោង PEARL ដោយក្នុងនោះមានសហគមន៍តំបន់ការពារធម្មជាតិចំនួន ១៤សហគមន៍ និងសហគមន៍ព្រៃឈើចំនួន ៦សហគមន៍។ ក្រុមសហគមន៍ដ៏ធំនេះស្ថិតនៅក្នុងតំបន់ផ្ទៃអាងរងទឹកភ្លៀងស្ទឹងសែន (មើលរូបភាពទី៥) ដែលសកម្មភាពស្តារ និងការពារផ្ទៃអាងរងទឹកភ្លៀងមានឥទ្ធិពលយ៉ាងខ្លាំងលើតំបន់ធ្វើស្រែនៅផ្នែកខាងក្រោមក្នុងខេត្តកំពង់ធំ និងខេត្តព្រះវិហារ។ សហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើផ្សេងទៀតស្ថិតជិតឧទ្យានជាតិភ្នំគូលែន ខេត្តសៀមរាប និងដែនជម្រកសត្វព្រៃសង្ឃរុក្ខវ័ន្ត ខេត្តឧត្តរមានជ័យ។

៣១៥. ទាំងសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើដែលបានជ្រើសមានចំណុចខ្លាំងច្រើន។ ចំណុចខ្លាំងទាំងនោះមានជាអាទិ៍៖ សហគមន៍ទាំងនេះមានព្រំប្រទល់ច្បាស់លាស់ លក្ខន្តិកៈសហគមន៍ដោយមានសមាជិកគណៈកម្មការសកម្ម និងសមាជិកចូលរួមយ៉ាងសកម្ម មានកិច្ចព្រមព្រៀងចុះហត្ថលេខាទទួលស្គាល់ពីក្រសួងពាក់ព័ន្ធ មានផែនការគ្រប់គ្រង ព្រមទាំងមានការគាំទ្រពីថ្នាក់ជាតិ និងដៃគូអភិវឌ្ឍន៍អន្តរជាតិ។ ចំណុចខ្លាំងទាំងនេះគឺមាននៅក្នុងសហគមន៍តំបន់ការពារធម្មជាតិចំនួន ១៤ និងសហគមន៍ព្រៃឈើចំនួន៦ ដែលបានជ្រើសរើសដោយការសិក្សានេះ ទោះបីជាសហគមន៍ទាំងនេះមានភាពខ្លាំងក្នុងកម្រិតគ្នាក៏ដោយ ហើយចំណុចខ្លាំងទាំងនេះជាកត្តាដ៏រឹងមាំក្នុងការចូលរួមចំណែកដល់អនុវត្តគម្រោង PEARL ដោយជោគជ័យ។

### ៩.៤.២ សហគន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើសមស្របសម្រាប់គំនិតផ្តួចផ្តើម/កម្មវិធីក្នុងការស្តារការស្តារដីព្រៃឈើឡើងវិញ

៣១៦. ការសិក្សាបានធ្វើឡើងនេះបង្កើតបានបញ្ជីដ៏វែងមួយនៃសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើសរុបចំនួន ៤៣ សហគមន៍តាមរយៈកិច្ចប្រជុំពិគ្រោះយោបល់ជាមួយមន្ត្រីរដ្ឋាភិបាលទទួលបន្ទុក បុគ្គលិកអង្គការ អាជ្ញាធរមូលដ្ឋាន និងតំណាងសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើនៅក្នុងតំបន់ភាគខាងជើងនៃបឹងទន្លេសាប។ ពីបញ្ជីសហគមន៍ដ៏វែងនេះ សហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើដែលសមស្របចំនួន ២០សហគមន៍ត្រូវកំណត់អត្តសញ្ញាណ។ នៅក្នុងបញ្ជីសម្រង់ចុងក្រោយ សហគមន៍តំបន់ការពារធម្មជាតិមានចំនួន ១៤ និងសហគន៍ព្រៃឈើចំនួន៦។ ព័ត៌មានលម្អិតពីសហគមន៍តំបន់ការពារធម្មជាតិ/សហគន៍ព្រៃឈើមានបញ្ជាក់ក្នុងឧបសម្ព័ន្ធ៧ ក្នុងរបាយការពេញលេញនៃការសិក្សា។ បញ្ជីសម្រង់សហគមន៍តំបន់ការពារធម្មជាតិ និងសហគន៍ព្រៃឈើត្រូវបានពិពណ៌នាជាសង្ខេបដូចខាងក្រោម៖

**<u>ខេត្តកំពង់ធំ</u>**

៣១៧. សហគមន៍តំបន់ការពារធម្មជាតិចំនួន ០៤ ដែលបានជ្រើសរើសដោយផ្អែកភាគច្រើនបំផុតលើអនុសាសន៍ពីមន្ត្រីរដ្ឋាភិបាល។ ការផលិតស្រូវសរីរាង្គត្រូវបានអនុវត្ត នៅទូទាំងខេត្ត។ សហគមន៍តំបន់ការពារធម្មជាតិទាំងនេះស្ថិតនៅជិតៗគ្នា ហើយសហគមន៍តំបន់ការពារធម្មជាតិទាំង៤នៅជាប់ព្រំប្រទល់គ្នាដែលជាមានផលវិជ្ជមានដ៏ធំសម្រាប់ការអភិរក្ស និងការពារជីវៈចម្រុះ ការលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋានក្នុងនាមជាសមាជិកនៃសហគមន៍តំបន់ការពារធម្មជាតិ និងជាអ្នកអនុវត្តគម្រោង។ សហគមន៍តំបន់ការពារធម្មជាតិទាំងនេះរួមមាន៖

១. សហគមន៍តំបន់ការពារធម្មជាតិគគីប្រហោង ស្ថិតនៅក្នុងភូមិស្រែវាលខាងលិច និងសំពណ៌តូច ឃុំដងកាំបិត ស្រុកសណ្តាន់។

២. សហគមន៍តំបន់ការពារធម្មជាតិស្គរក្រូច ស្ថិតនៅក្នុងភូមិដង្ហិត ភូមិប្រាសាទអណ្តែត ភូមិក្រសាំង ភូមិព្រគគីរ និងភូមិខ្មែរ ឃុំសណ្តាន់ ស្រុកសណ្តាន់

៣. សហគមន៍តំបន់ការពារធម្មជាតិជាំធ្លក ស្ថិតក្នុងភូមិរវៀង ភូមិដងទទឹង ភូមិក្រាំងដើម ភូមិស្វាយ ភូមិងន ភូមិវាលព្រិញលើ និងភូមិស្រឡៅ ឃុំងន ស្រុកសណ្តាន់។ សហគមន៍តំបន់ការពារធម្មជាតិទាំងបីដំបូងគេនេះស្ថិតក្នុងដែនជម្រកសត្វព្រៃបឹងពែរ និង

៤. សហគមន៍តំបន់ការពារធម្មជាតិក្បាលដូនក្រី ស្ថិតក្នុងភូមិបឹង ឃុំមានរិទ្ធ ស្រុកសណ្តាន់ ដែលស្ថិតនៅក្នុងរបៀងអភិរក្សជីវៈចម្រុះព្រៃឡង់

៣១៨. សហគមន៍ព្រៃឈើចំនួន៣ ត្រូវបានស្នើឡើងសម្រាប់ដាក់បញ្ចូលក្នុងការអនុវត្តគម្រោង PEARL ព្រោះសហគមន៍ទាំងនេះបំពេញលក្ខណៈវិនិច្ឆ័យរបស់គម្រោង ទីតាំងនៅជិតជិត និងអនុសាសន៍ដែលធ្វើឡើងដោយមន្ត្រីរដ្ឋាភិបាល និងបុគ្គលិកអង្គការ។ បន្ថែមលើនេះទៀត សហគមន៍តំបន់ការពារធម្មជាតិ និងសហគន៍ព្រៃឈើដូចបញ្ជាក់ខាងលើនឹងមានតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់សេវាកម្មប្រព័ន្ធអេកូឡូស៊ីដល់អ្នកផលិតស្រូវសរីរាង្គ និងបន្លែនៅផ្នែកខាងក្រោម។ សហគមន៍ព្រៃឈើទាំងនេះរួមមាន៖

១. សហគមន៍ព្រៃឈើព្រៃតាតី ស្ថិតនៅក្នុងភូមិកាន់ធី ឃុំមានរិទ្ធ ស្រុកសណ្តាន់

២. សហគមន៍ព្រៃឈើអូរក្រហូង ស្ថិតនៅក្នុងភូមិដាំស្វាយ ឃុំមានរិទ្ធ ស្រុកសណ្តាន់។ សហគមន៍ព្រៃឈើចំនួន ២ ដំបូងនេះមានព្រំប្រទល់ជាប់គ្នា និងស្ថិតនៅក្នុងឃុំតែមួយ ដែលសាកសមនឹងជ្រើសរើសសម្រាប់អនុវត្តគម្រោង និង

៣. សហគមន៍ព្រៃឈើអូរសោម ស្ថិតក្នុងភូមិអូរសោម ឃុំសាលាវិស័យ ស្រុកប្រាសាទបាល័ង្គ មានទីតាំងនៅជិតដែនជម្រកសត្វព្រៃបឹងពែរ។

**<u>ខេត្តសៀមរាប</u>**

៣១៩. សហគមន៍តំបន់ការពារធម្មជាតិចំនួន៣ ស្ថិតក្នុងឧទ្យានជាតិភ្នំគូលែនត្រូវបានជ្រើសរើស ក្នុងឃុំខ្នងភ្នំស្រុកស្វាយលើ។ សហគមន៍ទាំងនេះជាភូមិករស្ថិតក្នុងឧទ្យាជាតិភ្នំគូលែន និងមានព្រំជាប់គ្នា ខ័ណ្ឌដាច់ពីគ្នាដោយព្រំប្រទល់តំបន់ព្រៃ។ តំបន់ផ្ទៃអាងរងទឹកភ្លៀងរបស់សហគមន៍ទាំងនេះមានភាពចាំបាច់យ៉ាងខ្លាំងក្នុងការធានាឱ្យមានសេវាកម្មប្រព័ន្ធអេកូឡូស៊ី ពិសេសសេវាកម្មផ្គត់ផ្គង់ទឹក និងមានលក្ខខណ្ឌកសិ-អេកូឡូស៊ី ដែលមិនត្រឹមតែសម្រាប់សហគមន៍ខ្លួនឯងនោះទេ ប៉ុន្តែថែមទាំងសម្រាប់តំបន់នៅផ្នែកខាងក្រោម ដែលជាតំបន់គោលដៅរបស់គម្រោងផ្តោតគោលដៅលើអ្នកផលិតបន្លែផងដែរ។ សហគមន៍តំបន់ការពារធម្មជាតិទាំងនេះក៏ត្រូវបានណែនាំយ៉ាងទទូចពីក្រសួងបរិស្ថាន និងទទួលបានការគាំពីគម្រោងដៃគូអភិវឌ្ឍន៍ជាច្រើន តាមរយៈក្រសួងបរិស្ថាន ដូចនេះសហគមន៍ទាំងនេះមានសមត្ថភាពពាក់ព័ន្ធក្នុងអនុវត្តសកម្មភាពស្តារ និងការពារ។ សហគមន៍តំបន់ការពារធម្មជាតិទាំងនេះរួមមាន៖

១. សហគមន៍តំបន់ការពារធម្មជាតិជប់តាសុខ ស្ថិតក្នុងភូមិខ្លាឃ្មុំ ឃុំខ្នងភ្នំ ស្រុកស្វាយលើ

២. សហគមន៍តំបន់ការពារធម្មជាតិព្រៃធំ អន្លង់ធំ ស្ថិតក្នុងភូមិអន្លង់ធំ ឃុំខ្នងភ្នំ ស្រុកស្វាយលើ

៣. សហគមន៍តំបន់ការពារធម្មជាតិព្រៃធំពពេល ស្ថិតក្នុងភូមិខ្លាឃ្មុំ ឃុំខ្នងភ្នំ ស្រុកស្វាយលើ

**<u>ខេត្តឧត្តរមានជ័យ</u>**

៣២០. សហគមន៍តំបន់ការពារធម្មជាតិចំនួន៤ត្រូវបានជ្រើសរើសនៅក្នុងខេត្តនេះ។ សហគមន៍នេះដំបូងឡើយជាសហគមន៍ព្រៃឈើ ក្នុងអំឡុងពេលដែលដែនព្រៃនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ ហើយបន្ទាប់មក សហគមន៍ទាំងនេះត្រូវបានផ្លាស់ប្តូរទៅជាសហគមន៍តំបន់ការពារធម្មជាតិ នៅពេលដែលតំបន់នោះត្រូវបានដាក់ជាតំបន់ការពារធម្មជាតិ ក្រោមដែនសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន នៅឆ្នាំ២០១៦។ សហគមន៍តំបន់ការពារធម្មជាតិចំនួន ២ ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃសង្ឃរុក្ខវ័ន្ត និង២ផ្សេងទៀតស្ថិតនៅក្នុងរបៀងអភិរក្សជីវៈចម្រុះឧត្តរ។ សហគមន៍ទាំងនេះបានទទួលការណែនាំឱ្យដាក់ចូលក្នុងគម្រោង PEARL ព្រោះថា សហគមន៍តំបន់ការពារធម្មជាតិទាំងនោះមានសារៈសំខាន់ក្នុងការធានា និងស្តារឡើងវិញនូវសេវាកម្មប្រព័ន្ធអេកូឡូស៊ី ជាប្រយោជន៍

ដល់សកម្មភាពកសិកម្មក្នុងតំបន់ និងភាពកម្រធនធាន ព្រមទាំងជាឱកាសសម្រាប់អភិវឌ្ឍន៍ជីវភាពរស់នៅ ដោយសារតែតំបន់នេះស្ថិតនៅដាច់ស្រយាល។ សហគមន៍តំបន់ការពារធម្មជាតិ ទាំងនេះរួមមានៈ

១. សហគមន៍តំបន់ការពារធម្មជាតិសង្ឃរុក្ខវ័ន្ត មាន៥ភូមិ គឺភូមិស្រះកែវ ភូមិសំបួរ ភូមិទំនប់ថ្មី ភូមិថ្នារចាស់ និងភូមិថ្នារថ្មី ឃុំត្រពាំងត្រាវ ស្រុកអន្លង់វែង

២. សហគមន៍តំបន់ការពារធម្មជាតិរតនៈរការ មាន៧ភូមិៈ ភូមិកូនដំរី ភូមិបាក់នឹម ភូមិចារអៀប ភូមិគោគព្រេស ភូមិអូរកងសែង ភូមិដូនកែវ ភូមិឈូក ភូមិពូល ភូមិត្រពាំងវែង ភូមិម្សុត ភូមិតាំម៉ាន ភូមិចម្ប៉ាសុក ភូមិឈើក្រោម ភូមិគគីរន្ទែ ភូមិបូស និងភូមិបន្ទាយ ឃុំសំរោង និងឃុំកូនដំរី ក្រុងសំរោង (ស្រុក)

៣. សហគមន៍តំបន់ការពារធម្មជាតិសាមគ្គី មាន១ភូម គឺភូមិអូរសំរោង ឃុំត្រាវ ស្រុកអន្លង់វែង និង

៤. សហគមន៍តំបន់ការពារធម្មជាតិថ្មដាអូរគ្រេស ស្ថិតនៅក្នុងភូមិក្បាលកៀង ភូមិអូរបេង ភូមិច្រូក ភូមិអូរជិត និងភូមិព្រះចំបក់ ឃុំផាវ ស្រុកត្រពាំងប្រាសាទ

## ខេត្តព្រះវិហារ

៣២១. សហគមន៍តំបន់ការពារធម្មជាតិចំនួន៣ត្រូវបានជ្រើសរើសសម្រាប់គម្រោង PEARL នៅក្នុងខេត្តនេះ។ សហគមន៍ទាំងនោះស្ថិតក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ដែលជាតំបន់មានតម្លៃអភិរក្សខ្ពស់ និងជាប្រភពដ៏សំខាន់សម្រាប់ជីវភាពរស់នៅរបស់ប្រជាជនមូលដ្ឋាន។ ដោយសារទីតាំងសហគមន៍ទាំងនេះស្ថិតនៅជិតគ្នានោះទំនាក់ទំនង និងនៅជិតតំបន់ដាំដុះស្រូវសរីរាង្គនៅផ្នែកខាងក្រោម មានឥទ្ធិពលមានសក្តានុពលយ៉ាងខ្លាំង ក្រោមកិច្ចអន្តរាគមន៍ពីគម្រោង។ សហគមន៍តំបន់ការពារធម្មជាតិទាំងនេះរួមមានៈ

១. សហគមន៍តំបន់ការពារធម្មជាតិអភិវឌ្ឍព្រៃវែង ស្ថិតក្នុងភូមិព្រៃវែង ឃុំត្រយ៉ង់ ស្រុកគូលែន

២. សហគមន៍តំបន់ការពារធម្មជាតិសំបូរអភិវឌ្ឍន៍ ស្ថិតក្នុងភូមសំបូ ឃុំត្រយ៉ង ស្រុកគូលែន

៣. សហគមន៍តំបន់ការពារធម្មជាតិពោធិ៍រៀង ស្ថិតនៅក្នុងភូមិពោធិ៍រៀង ឃុំគូលែនជើង ស្រុកគូលែន

៣២១. បន្ថែមលើនេះទៀត សហគមន៍ព្រៃឈើចំនួន៣ត្រូវបានជ្រើសរើសក្នុងស្រុកគូលែន។ សហគមន៍ព្រៃឈើទាំង៣នេះមានការចង្អុលបង្ហាញច្បាស់លាស់ដោយខណ្ឌរដ្ឋបាលព្រៃខេត្តព្រះវិហារ ដោយសារមានភាពសកម្មក្នុងការគ្រប់គ្រង និងខិតខំការពារព្រៃឈើពីការកាប់រានដីព្រៃ និងការបំផ្លិតបំផ្លាញនានា។ ជាមួយគ្នានឹងសហគមន៍តំបន់ការពារធម្មជាតិ ដូចបានពិពណ៌នាខាងលើ ការគាំទ្ររបស់គម្រោង PEARL លើសហគមន៍ព្រៃឈើទាំងនេះនឹងជួយពង្រឹងសកក្តានុពលនៃឥទ្ធិពល តាមរយៈភាពជោគជ័យក្នុងការតភ្ជាប់តំបន់ផ្ទៃអាងរងទឹកភ្លៀង និងកិច្ចខិតខំប្រឹងប្រែងរួមជាកម្រិតតំបន់ទេសភាព។ សហគមន៍ព្រៃឈើទាំងនេះរួមមានៈ

១. សហគមន៍ព្រៃឈើព្រៃម្លូង ស្ថិតក្នុងភូមិត្រយ៉ងត្បូង ឃុំត្រយ៉ង ស្រុកគូលែន

២. សហគមន៍ព្រៃឈើកោះកេរ្តិ៍កចំរើន ស្ថិតក្នុងភូមិកោះកេរ្តិ៍ ឃុំត្រយ៉ង ស្រុកគូលែន

៣. សហគមន៍ព្រៃឈើព្រៃពូមេបុណ្យ ស្ថតិក្នុងភូមព្យូរជ្រូក ឃុំគូលែនជើង ស្រុកគូលែន។

៣២២. តារាងទី ១៣ ខាងក្រោមជាសេចក្តីសង្ខេបនៃសហគមន៍តំបន់ការពារធម្មជាតិទាំង១៤ និងសហគមន៍ព្រៃឈើទាំង៦ ដែលត្រូវបានជ្រើសរើសតាមរយៈការសិក្សានេះ ដោយផ្អែកលើបញ្ជីសម្រង់លក្ខណៈវិនិច្ឆ័យ រួមទាំងមានផែនការគ្រប់គ្រង សហគមន៍តំបន់ការពារធម្មជាតិ/សហគន៍ព្រៃឈើ រចនាសម្ព័ន្ធរឹងមាំ ជិតតំបន់គោលដៅគម្រោង (ផលប៉ះពាល់) ប្រភេទ ដំណាំ និងប្រព័ន្ធដាំដុះដំណាំ និងសកក្តានុពលបង្កើនជីវភាពរស់នៅ តាមរយៈការអភិវឌ្ឍ

តំបន់ទេសចរណ៍ធម្មជាតិជាដើម។ ជាងនេះទៀត គម្រោងក៏មានសារៈសំខាន់ដែរក្នុងការកំណត់នៅទីនេះដែលថា នៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ និងសហគន៍ព្រៃឈើ ផ្ទៃដីជាកម្មវត្ថុផលិតកម្មដំណាំមិនត្រូវបានអនុញ្ញាត្តឱ្យធ្វើការពង្រីកផ្ទៃដីបន្ថែមពីផ្ទៃមានស្រាប់មុនពេលតំបន់នោះដាក់ជាសហគមន៍តំបន់ការពារធម្មជាតិ និងសហគន៍ព្រៃឈើនោះទេ។

*តារាងទី 14. សេចក្តីសង្ខេបពីសហគមន៍តំបន់ការពារធម្មជាតិ និងសហគន៍ព្រៃឈើដែលត្រូវបានជ្រើសរើសសម្រាប់គម្រោង PEARL*

| ល.រ | ឈ្មោះ CPA/ CF | ទីតាំង (ខេត្ត/ PA) | ផែនការគ្រប់គ្រង | អភិបាលកិច្ច | ផលប៉ះពាល់ (នៅជិត) | ដំណាំ (ដំណាំគោដៅ៖ ស្វាយ ស្វាយចន្ទី ស្រូវ |
|---|---|---|---|---|---|---|
| ១ | សហគមន៍តំបន់ការពារធម្មជាតិគគីប្រហោង (ដែនជម្រកសត្វព្រៃបឹងពែរ) | ឃុំដងកាំបិត ស្រុកសណ្តាន់ ខេត្តកំពង់ធំ | ផែនការគ្រប់ស្ថិតក្នុងដំណាក់កាលរៀបចំ។ សហគមន៍មានផ្ទៃក្រឡា ១ ៥២៤ហត និងបានប្រកាសក្នុងឆ្នាំ២០១០ ពីក្រសួងបរិស្ថានក្រោមការគាំទ្រពីមូលនិធិបន្សាំរបស់ក្រសួងបរិស្ថាន | លក្ខន្តិកៈបានរៀបចំរួចនៅឆ្នាំ ២០១០ និងធ្វើបច្ចុប្បន្នភាពនៅឆ្នាំ២០១៩ ក្រោមការគាំទ្រពីគម្រោងព្រៃឡង់/USAID។ សមាជិកគណកម្មសហគមន៍សកម្ម និងមានការល្បាតសហគមន៍ | សហគមន៍តំបន់ការពារធម្មជាតិ នេះមានព្រំជាប់នឹងសហគមន៍ស្តុះក្រូច និងក្បាលដូនគ្រី | ចម្ការដំណាំចម្រុះ ចម្ការស្វាយស្វាយចន្ទី និងដំឡូងមី គ្របដណ្តប់ធំជាង ២៨% (៤២៦ហត)។ ដំណាំស្រូវ និងដំណាំសាកវប្បកម្មគឺត្រូវបានដាំដុះនៅក្រៅតំបន់សហគមន៍តំបន់ការពារធម្មជាតិ |
| ២ | សហគមន៍តំបន់ការពារធម្មជាតិស្តុះក្រូច (ដែនជម្រកសត្វព្រៃបឹងពែរ) | ឃុំសណ្តាន់ ស្រុកសណ្តាន់ ខេត្តកំពង់ធំ | មានផែនការគ្រប់គ្រងរយៈពេល៥ឆ្នាំ (២០១៦-២០២០) លើផ្ទៃដីជា៣៤៤៩ហត ត្រូវបានរៀបចំឡើងក្នុងឆ្នាំ២០១៥ ក្រោមការគាំទ្រពីមូលនិធិបន្សាំរបស់ក្រសួងបរិស្ថាន។ វាត្រូវបានអនុម័តនៅឆ្នាំ២០១៦ | លក្ខន្តិកៈមានរចនាសម្ព័ន្ធគណៈកម្មច្បាស់លាស់ឯកភាពក្នុងឆ្នាំ ២០១០ ហើយបន្ទាប់មកធ្វើបច្ចុប្បន្នភាពនៅឆ្នាំ២០២០ ក្រោមការគាំទ្រពីគម្រោងព្រៃឡង់/USAID។ គណកម្មការមានភាពសកម្ម | សហគមន៍តំបន់ការពារធម្មជាតិ នេះមានព្រំជាប់គគីប្រហោង CPAនិងសហគមន៍តំបន់ការពារធម្មជាតិជាំធ្លក | ចម្ការដំណាំចម្រុះមានស្វាយ ស្វាយចន្ទី ដំឡូងមី ស្រូវ និងសាកវប្បកម្ម មានផ្ទៃលើពី ៣០០០ហត។ ដំណាំស្រូវ និងសកវប្បកម្មផ្សេងទៀតត្រូវបានដាំដុះនៅក្រៅតំបន់សហគមន៍តំបន់ការពារធម្មជាតិ |

| | | | | | | |
|---|---|---|---|---|---|---|
| ៣ | សហគមន៍តំបន់ការពារធម្មជាតិដាំធ្លក-(ដែនជម្រកសត្វព្រៃបឹងពែរ) | ឃុំងន ស្រុកសណ្ដាន់ ខេត្តកំពង់ធំ | មានផែនការគ្រប់គ្រងរយៈពេល៥ឆ្នាំ (២០១៦-២០២០) លើផ្ទៃដីជា៥២០៤ ហត (ឯកភាពពីក្រសួង បរិស្ថាន ឆ្នាំ ២០១០ ត្រូវបានរៀបចំឡើងក្នុងឆ្នាំ២០១៥ ជាមួយនឹងលក្ខន្តិកៈ) ក្រោមការគាំទ្រពីមូលនិធិបន្សាំរបស់ក្រសួងបរិស្ថាន។ វាត្រូវបានអនុម័តនៅឆ្នាំ ២០១៦ | លក្ខន្តិកៈរៀបចំនៅឆ្នាំ២០១០ និងទទួលបានប្រកាសក្រសួងនៅឆ្នាំ២០១០ ក្រោមការគទ្រពីគម្រោងបន្សាំនៃ MOE។ លក្ខន្តិកៈត្រូវបានធ្វើបច្ចុប្បន្នភាពនៅឆ្នាំ២០២០ គាំទ្រពីគម្រោងព្រៃឡង់/USAID។ គណកម្មការមានភាពសកម្ម | សហគមន៍នេះមានព្រំជាប់នឹងសហគមន៍តំបន់ការពារធម្មជាតិស្ពក្រូច។ | ចម្ការដំណាំចម្រុះ រួមទាំងដំណាំសំខាន់ៗដូចជា ស្វាយចន្ទី និងដំឡូងមី លើផ្ទៃដី ៤០៧៦ហត។ ដំណាំស្រូវតំបន់ខ្ពង់រាប និងឈើហូបផ្លែក៏ត្រូវបានដាំដុះក្នុងតំបន់សហគមន៍តំបន់ការពារធម្មជាតិ |
| ៤ | សហគមន៍តំបន់ការពារធម្មជាតិក្បាលដូនក្រី (របៀងអភិរក្សជីវៈចម្រុះព្រៃឡង់ | ឃុំមានរិទ្ធិ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ | ផែនការគ្រប់គ្រងទទួលបានការឯកភាពនៅឆ្នាំ ២០២១ លើផ្ទៃដីទំហំ ១៨០៣ ហត។ ផែនការនេះត្រូវបានរៀបចំតាំងពីឆ្នាំ ២០១៩ ក្រោមការគាំទ្រពីគម្រោងបន្សាំនៃក្រសួងបរិស្ថាន ហើយវាបាទទួលការឯកភាពនៅឆ្នាំ ២០១៩ | លក្ខន្តិកៈដោយ MOE ក្នុងឆ្នាំ ២០២១ ក្រោមការគាំទ្រពីគម្រោងព្រៃឡង់/USAID នៅឆ្នាំ២០២០ និងខណ្ឌរដ្ឋបាលព្រៃឈើនៅឆ្នាំ២០១៩ | សហគមន៍នេះមានព្រំជាប់នឹងសហគមន៍ព្រៃតាទៃ និងសហគមន៍ព្រៃឈើអូរគ្រញូង | ចម្ការដំណាំចម្រុះ រួមទាំងដំណាំសំខាន់ៗដូចជា កៅស៊ូ ស្វាយចន្ទី មានផ្ទៃក្រឡា ៥៤០ហត (២០%)។ ដំណាំផ្សេងទៀតមានដូចជា ស្រូវ និងដំណាំសាកវប្បកម្មត្រូវបានដាំនៅតំបន់មួយចំនួនក្នុងសហគមន៍តំបន់ការពារធម្មជាតិ |

| | | | | | | |
|---|---|---|---|---|---|---|
| ៥ | សហគន៍ព្រៃឈើព្រៃតាទៃ | ឃុំមានរិទ្ធិ ស្រុកសណ្តាន់ ខេត្តកំពង់ធំ | ផែនការយៈពេល១៥ឆ្នាំ (២០១៥-២០២៩) ត្រូវបានឯកភាពក្នុងឆ្នាំ ២០១៥។ សហគមន៍នេះមានផ្ទៃដី ១ ៣៩៥.៤៤ហត ដែលទទួលបានប្រកាសពី ក.ស.ក នៅឆ្នាំ ២០០៨។ ការចុះកិច្ចព្រមព្រៀងធ្វើឡើងនៅឆ្នាំ២០០៩ | លក្ខន្តិកៈបានរៀបចំតាំងពីឆ្នាំ ២០០២ និងឯកភាពពី ក.ស.ក នៅឆ្នាំ ២០០៨ ដោយមានការគាំទ្រពីអង្គការ RECOFTC តាមរយៈអង្គការម្លប់បៃតង។ សមាជិកគណកម្មការមានភាពសកម្ម | សហគមន៍នេះមានព្រំជិតសហគមន៍ព្រៃឈើអូរគ្រញូង និងសហគមន៍តំបន់ការពារធម្មជាតិជាំឆ្លក | ចម្ការដំណាំចម្រុះមានស្វាយចន្ទី និងដំឡូងមី លើផ្ទៃដីជាង ១១៩ហត។ មិនមានដាំដុះស្រូសរិវាង្គ ឬ ស្រូវនៅក្នុងសហគមន៍ព្រៃឈើនេះនោះទេ |
| ៦ | សហគមន៍ព្រៃឈើព្រៃអូរគ្រញូង | ឃុំមានរិទ្ធិ ស្រុកសណ្តាន់ ខេត្តកំពង់ធំ | ផែនការយៈពេល១៥ឆ្នាំ (២០១៥-២០២៩) ត្រូវបានរៀបចំនៅឆ្នាំ២០១៥ និងឯកភាពឆ្នាំ ២០១៦ ក្រោមការគាំទ្រពីនាយកដ្ឋាន និងអង្គការដៃគូរ។ សហគមន៍នេះមានក្រឡាផ្ទៃ ១១៣១ ហត និងទទួលបានប្រកាសពី ក.ស.ក ក្នុងឆ្នាំ ២០១០ | លក្ខន្តិកៈរៀបចំក្នុងឆ្នាំ២០០២ ក្រោមការគាំទ្រពីអង្គការក្នុងស្រុក RPFD និងនាយកដ្ឋានរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ប្រកាសទទួលបានក្នុងឆ្នាំ ២០១០។ លក្ខន្តិកៈ និងសមាជិកគណកម្មត្រូវពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពក្នុងឆ្នាំ២០១៤ ក្រោមការគាំទ្រពីអង្គការម្លប់បៃតង និង | សហគមន៍នេះមានព្រំជិតនឹងសហគមន៍ព្រៃឈើដូនតាទៃ និងសហគមន៍តំបន់ការពារធម្មជាតិក្បាលដូនក្រី | ចម្ការដំណាំចម្រុះរួមមាន ស្វាយចន្ទី និងដំឡូងមី លើផ្ទៃដី ១៥០ហត នៅក្នុងសហគន៍ព្រៃឈើ។ ប្រភេទដំណាំផ្សេងទៀតមានដូចជា ស្រូវ (៥ហត) និងមិនមានដាំដុះស្រូវសរិវាង្គនោះទេ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | នាយកដ្ឋាន។ សហគមន៍នៅបន្តមានការគាំទ្រពីគម្រោងព្រៃឡង់/ USAID | | |
| ៧ | សហគមន៍ព្រៃឈើអូរសោម | ឃុំសាលាវិស័យ ស្រុកប្រាសាទបាល័ង្គ ខេត្តកំពង់ធំ | ផែនការគ្រប់គ្រងរយៈពេល១៥ឆ្នាំ (២០១៦-២០៣០) ត្រូវបានរៀបចំឡើង និងទទួលបានការឯកភាពក្នុងឆ្នាំ២០១៦ លើផ្ទៃដីដីទំហំ ៣០៧,៦៩ហតទទួលបានប្រកាសពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុង ២០១៥ | លក្ខន្តិកៈបានរៀបចំរួចក្នុងឆ្នាំ ២០០៤ ក្រោមការគាំទ្រពីនាយកដ្ឋានជំនាញរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការ BFDK និងទទួលបានប្រកាសក្នុងឆ្នាំ ២០១៤។ លក្ខន្តិកៈ និងសមាជិកគណកម្មការត្រូវបានធ្វើបច្ចុប្បន្នភាពក្នុងឆ្នាំ ២០១៣។ បច្ចុប្បន្ននៅមានការគាំទ្រដោយអង្គការ COW តាំងពីឆ្នាំ ២០២១ លើការល្បាតព្រៃឈើ និងក្រុមសន្សំ | សហគមន៍ព្រៃឈើនៅជិតដែនជម្រកសត្វព្រៃបឹងពែ | ចម្ការដំណាំចម្រុះមានដូចជា ស្វាយចន្ទី លើផ្ទៃដីប្រមាណជាង ១៨ហតនៅក្នុងសហគន៍ព្រៃឈើ។ មិនមានការដាំដុះប្រភេទដំណាំផ្សេងៗដូចជា ស្រូវ និងស្រូវសេរីវង្គ នៅក្នុងតំបន់ព្រៃសហគមន៍នោះទេ។ |
| ៨ | សហគមន៍តំបន់ការពារធម្មជាតិជប់តាសុខ (ឧទ្យានជាតិភ្នំគូលែន) | ឃុំខ្នងភ្នំ ស្រុកស្វាយលើ ខេត្តសៀមរាប | ផែនការគ្រប់គ្រងត្រូវបានរៀបចំឡើងក្នុងឆ្នាំ២០១៨ សហគមន៍មានផ្ទៃក្រឡាង | លក្ខន្តិកៈទទួបានការឯកភាពពីក្រសួងបរិស្ថានក្នុងឆ្នាំ ២០០៨ ក្រោមការគាំទ្រពី LLP | សហគមន៍នេះមានព្រំប្រទល់ជាប់សហគមន៍ព្រៃធំអន្លង់ធំ | មានដំណាំប្រចាំឆ្នាំចំនួនប្រភេទរួមមានស្វាយចន្ទី ស្វាយ ដាំដុះលើផ្ទៃដីប្រមាណ ២៥ហត និងមានតំបន់ទេសចរណធម្ម |

| | | | | | | |
|---|---|---|---|---|---|---|
| | | | ២៥០ហត ដែលត្រូវបាន បង្កើតក្នុងឆ្នាំ ២០០៣ ក្រោម ការគាំទ្រពី គម្រោង UNDP's BESD អនុវត្ត ដោយក្រសួងប រិស្ថាន គាំទ្រលើ ការស្តារព្រៃឈើ ឡើងវិញទំហំ ប្រមាណ ១៣ ហត | ពីឆ្នាំ ២០១៧-២០២០ លើ ការល្បាត និង កិច្ចប្រជុំប្រចាំ ខែរបស់គណ កម្មការ។ សមាជិកគណ កម្មការសកម្ម នឹងការងារ។ | និងព្រៃធំ ពពេល | ជាតិទំហំ ២៤ហត។ មិនមានដាំដុះស្រូវ និងស្រូវស្រូវសេរីរាង្គ នៅក្នុងសហគមន៍ នេះនោះទេ |
| ៩ | សហគមន៍ តំបន់ការពារ ធម្មជាតិព្រៃធំ អន្លង់ធំ (ឧទ្យានជាតិភ្នំ គូលែន) | ឃុំខ្នងភ្នំ ស្រុក ស្វាយលើ ខេត្ត សៀមរាប | ផែនការ គ្រប់គ្រងរយៈ ពេល៥ឆ្នាំត្រូវ បានរៀបចំឡើង (២០២១-២០២៥)ក្នុង ឆ្នាំ២០២០ លើ ផ្ទៃដីទំហំ ៣៦៥ហត និង បានទទួល ប្រកាសពី ក្រសួងនៅឆ្នាំ ២០០១ ក្រោម ការគាំទ្រពី គម្រោងរបស់ អង្គការ UNDP's BESD (ភាត របរិស្ថានដើម្បី ការអភិវឌ្ឍ ដោយនិរន្តរភាព នៅប្រទេសកម្ពុ ជា) អនុវត្តោយ ក្រសួរងបរិស្ថាន | លក្ខន្តិកៈបាន រៀបចំរួចក្នុងឆ្នាំ ២០០១ ក្រោម ការគាំទ្រ បច្ចេកទេសពី អង្គការ FAO និងក្រសួងប រិស្ថាន។ ប្រកាសទទួល បានក្នុងឆ្នាំ ២០០៣ លក្ខន្តិកៈត្រូវធ្វើ បច្ចុប្បន្នភាព ក្នុងឆ្នាំ២០០៨ និង២០២០ ក្រោមការគាំទ្រ ពីអង្គការ FAO និងអង្គការក្នុង ស្រុកជាច្រើន ទៀតតាំងពីឆ្នាំ ២០១៦មក ដោយផ្តោតលើ ការល្បាតព្រៃ និងការគាំទ្រ ជីវភាពរបស់ | សហគមន៍ តំបន់ការពារ នេះ មានព្រំ ប្រទល់នឹង សហគមន៍ ព្រៃធំពពេល និងសហគម ន៍តំបន់ ការពារធម្ម ជាតិជប់តា សុខ | មិនមានចម្ការ ឬស្រែ នៅក្នុងសហគមន៍ នេះទេ ប៉ុន្តែសហគម ន៍នេះត្រូវដាក់ក្នុង តំបន់ផលិតកម្ម ប្រើ ប្រាសធនធានព្រៃ ឈើក្រោមច្បាប់អនុ ញ្ញាត្ត (២៧ហត) តំបន់ទេសចរណ៍ធម្ម ជាតិ ២៤ហត និងផ្ទៃ ដី៧៧ហតជាតំបន់ ដាំស្តារ ដែលកន្លង មកជាចម្ការដំណាំ ចម្រុះ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | សហគមន៍មូលដ្ឋាន | | |
| ១០ | សហគមន៍តំបន់ការពារធម្មជាតិព្រៃធំពពេល (ឧទ្យានជាតិគូលែន) | ឃុំខ្នងភ្នំ ស្រុកស្វាយលើ ខេត្តសៀមរាប | ផែនការគ្រប់គ្រងរយៈពេល៥ឆ្នា (២០២១-២០២៥) ត្រូវបានរៀបចំឡើងតាំងពីឆ្នាំ ២០២០ លើផ្ទៃដីទំហំ៧៩៨ ហត ទទួលបានប្រកាសក្នុងឆ្នាំ ២០០៣ ក្រោមការគាំទ្រពីគម្រោង UNDP's BESD (ភាតបរិស្ថានដើម្បីការអភិវឌ្ឍដោយនិរន្តរភាពនៅប្រទេសកម្ពុជា) អនុវត្តដោយក្រសួងបរិស្ថាន | លក្ខន្តិកៈត្រូវបានរៀបចំឡើក្នុងឆ្នាំ២០០៣ ក្រោមការគាំទ្រពីអង្គការ FAO និងនាយកដ្ឋានជំនាញពីក្រសួងបរិស្ថានហើយទទួលបានប្រកាសក្នុងឆ្នាំដដែល លក្ខន្តិកៈត្រូវបានធ្វើបច្ចុប្បន្នភាពក្នុងឆ្នាំ ២០០៨ និង ២០២០ ដោយកំណត់រចនាសម្ព័ន្ធគណកម្មការគ្រប់គ្រងច្បាស់លាស់ ក្រោមការគាំទ្រពីអង្គការUNDP និងអង្គការក្នុងស្រុកជាច្រើនទៀត តាំងពីឆ្នាំ ២០១៦មកលើការល្បាតព្រៃ និងការអភិវឌ្ឍជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន | សហគមន៍នេះមានព្រំប្រទល់ជាប់នឹងសហគមន៍ជប់តាសុខ និងសហគមន៍តំបន់ការពារធម្មជាតិព្រៃធំអន្លងធំ | មានចម្ការស្វាយចន្ទីចំនួន៥០ចម្ការ លើផ្ទៃដីប្រមាណ ១០០ ហតស្ថិតនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ។ តំបន់ទេសចរណ៍ធម្មជាតិ ១២៨ហត តំបន់អភិវឌ្ឍន៍ទំហំ ៥៨ហត និងតំបន់ស្តារព្រៃឈើឡើងវិញ ៤៦ហត |
| ១១ | សហគមន៍តំបន់ការពារធម្មជាតិ/សហគមន៍ព្រៃឈើ-សង្ឃរុក្ខវ័ន្ត | ឃុំត្រពាំងត្រាវ និងឃុំកូនគ្រៀល ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ | ផែនការគ្រប់គ្រងរយៈពេល៥ឆ្នាំ (២០១៨-២០២២) ត្រូវ | លក្ខន្តិកៈឯកភាពក្នុងឆ្នាំ ២០១៨ និងចុះកិច្ចព្រមព្រៀងក្នុងឆ្នាំ២០១៩ | សហគមន៍ព្រៃឈើ/តំបន់ការពារធម្មជាតិជាប់នឹង | ចម្ការដំណាំចម្រុះមានស្វាយ ស្វាយចន្ទី និងដំឡូងមី លើផ្ទៃដីទំហំជាង៩១៣ហត (៥%) |

| | | | | | | |
|---|---|---|---|---|---|---|
| | (ដែនជម្រកសត្វព្រៃសង្ឃរុក្ខវ័ន្ន) | | បានរៀបចំឡើងក្នុងឆ្នាំ២០១៨ ស្ថិតនៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានផ្ទៃដី ១៨ ២៦១ ហត ក្រោយមកដាក់បញ្ចូលនៅក្រោមដែនសមត្ថកិច្ចក្រសួងបរិស្ថានក្នុងឆ្នាំ២០២០ ក្រោមការគាំទ្រពីគម្រោងមូលនិធិបន្សាំនៃក្រសួងបរិស្ថាន ផែនការគ្រប់គ្រងត្រូវបានទទួលការឯកភាពក្នុងឆ្នាំ ២០២០ | ជាមួយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រោមការគាំទ្រពីអង្គការ Dan Mission (អង្គការអន្តរជាតិ) តាំងពីឆ្នាំ២០២០ ដោយផ្តោតលើកិច្ចប្រជុំគណកម្មការសហគមន៍ ផ្សព្វផ្សាយលក្ខន្តិកៈ ធ្វើផ្លូវភ្លើងតំបន់ទេសចរណ៍ធម្មជាតិនិងការល្បាតសហគមន៍។ សហគមន៍នេះសកម្មណាស់។ | សហគមន៍រតនៈរកា | ផ្ទៃដីទំហំ ១៨០០ ហត (១០%) សម្រាប់ការអភិវឌ្ឍតំបន់ទេសចរណ៍ធម្មជាតិ(១០%)។ មិនមានការដាំដុះដំណាំដូចជាស្រូវនៅក្នុងតំបន់សហគមន៍នោះទេ |
| ១២ | សហគមន៍តំបន់ការពារធម្មជាតិ/ព្រៃឈើរតនៈរការ (ដែនជម្រកសត្វព្រៃសង្ឃរុក្ខវ័ន្ន) | ឃុំសំរោង និងឃុំកូនគ្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ | ផែនការគ្រប់គ្រងមិនទាន់បានរៀបចំនៅឡើយ ហើយកំពុងស្ថិតក្នុងដំណើការដាក់ជាសហគមន៍តំបន់ការពារធម្មជាតិ។សហគមន៍នេះដំបូងឡើយជាសហគមន៍ព្រៃឈើស្ថិតនៅក្រោម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឆ្នាំ | លក្ខន្តិកៈ និងកិច្ចព្រមព្រៀងសហគមន៍បានអនុវត្តរួចរាល់ក្នុងឆ្នាំ២០០៩ ក្រោមការគាំទ្រពី CDA (សមាគមន៍អភិវឌ្ឍន៍កុមារអង្គការក្នុងស្រុក) សមាជិកមានចូលរួមយ៉ាងសកម្ម | សហគមន៍នេះមានព្រំប្រទល់ជាប់សហគមន៍តំបន់ការពារធម្មជាត/ព្រៃឈើសង្ឃរុក្ខវ័ន្ន | ផ្ទៃដីទំហំ ១៥០០ ហត ត្រូវបានកំណត់សម្រាប់សកម្មភាពទេសចរណ៍ធម្មជាតិ រួមមាន៖ កសិ-រុក្ខកម្ម ចម្ការដំណាំចម្រុះ និងចម្ការដំណាំចម្រុះ និងស្រូវសរីរាង្គ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | ២០០៥ ក្រោមការគាំទ្រពីគម្រោង REDD+ តាមរយៈមូលនិធិបន្សាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើផ្ទៃដីទំហំ ១២៨៧២ហត | | | |
| ១៣ | សហគមន៍តំបន់ការពារធម្មជាតិ/ព្រៃឈើ-សាមគ្គី (របៀងអភិរក្សជីវៈចម្រុះឧត្តរ) | ឃុំត្រពាំងត្រាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ | ផែនការគ្រប់គ្រងស្ថិតក្នុងដំណាក់កាលរៀបចំក្រោមការគាំទ្រពីគម្រោង REDD+ តាមរយៈមូលនិធិបន្សាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ សហគមន៍នេះមានផ្ទៃដីទំហំ ១០៧៩ហត ហើយក្នុងឆ្នាំ ២០០៥ ត្រូវបានបង្កើតឡើយនៅក្រោមក្រសួងកសិកម្ម | លក្ខន្តិកៈស្ថិតនៅសេចក្តីព្រាងនៅឡើយ ក្រោមការគ្រប់គ្រងពីអង្គការសុវណ្ណភូមិ (អង្គការក្នុងស្រុក) និងអង្គការ UNDP ហើយទទួលបានប្រកាសតាំងពីឆ្នាំ ២០១៧ | សហគមន៍តំបន់ការពារធម្មជាតិ/ព្រៃឈើនេះ មានព្រំជាប់នឹងសហគមន៍រតនៈរការ | មិនមានដីចម្ការចម្រុះ ឬស្រែនៅក្នុងតំបន់សហគមន៍ ហើយវាព្រៃតំបន់ភ្នំ ផ្ទៃដីទំហំ ១១ហត ត្រូវបានកំណត់សម្រាប់អភិវឌ្ឍន៍ជាតំបន់ទេសចរណ៍ធម្មជាតិ (ទឹកធ្លាក់ដំស្រស់ស្អាត) |
| ១៤ | សហគមន៍តំបន់ការពារធម្មជាតិ/ព្រៃឈើ-ថ្មដាអរូទឹកខៀវ (របៀងអភិរក្សជីវៈចម្រុះឧត្តរ) | ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ | ផែនការគ្រប់គ្រងបានរៀបចំឡើងនៅឆ្នាំ ២០១៤ ក្រោមការគាំត្រពីម្រោង REDD+ ម្រោងREDD+ តាមរយៈមូលនិ | លក្ខន្តិកៈត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៤ ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងត្រូវបានធ្វើបច្ចុប្បន្ន | សហគមន៍នេះមានព្រំជាប់នឹងសហគមន៍តំបន់ការពារធម្មជាតិ/ព្រៃឈើសាមគ្គ | មិនមានចម្ការដំណាំចម្រុះ ឬស្រែនៅក្នុងតំបន់ព្រៃសហគមន៍នោះទេ ហើយវាព្រៃតំបន់ភ្នំ។ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | ធិបន្យាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ សហគមន៍នេះមានផ្ទៃក្រឡា ២០២៥ហាត បង្កើតឡើងនៅឆ្នាំ២០១៤ ក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ភាពតាមរយៈអង្គការWCS និងUSAID-ព្រៃឡង់បៃតង លើសកម្មភាពល្បាតរបស់សហគមន៍ និងការគ្រប់គ្រងទេសចរណ៍ធម្មជាតិ | | |
| ១៥ | សហគមន៍តំបន់ការពារធម្មជាតិ/ព្រៃឈើ-អភិវឌ្ឍន៍ព្រៃវែង (ដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព) | ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ | ផែនការគ្រប់គ្រងស្ថិតក្នុងដំណាក់កាលរៀបចំក្រោមការគាំទ្រពីអង្គការWCS និង MOE។ សហគមន៍នេះមានផ្ទៃក្រឡា ១០៤៨ហាត | លក្ខន្តិកៈត្រូវបានរៀបចំរួចក្នុងឆ្នាំ ២០១៤។ សមាជិកគណកម្មការសហគមន៍ចូលរួមយ៉ាងសកម្ម សហគមន៍បច្ចុប្បន្នមានការគាំទ្រពីអង្គការWCS និង USAID-ព្រៃឡង់បៃតង លើសកម្មភាពល្បាតរបស់សហគមន៍ និងក្រុមសន្សំក្នុងឆ្នាំ២០២១ | ព្រំប្រទល់ជាប់សហគមន៍តំបន់ការពារធម្មជាសំបូរ និងភូរៀង | មិនមានចម្ការដំណាំចម្រុះនោះទេ ប៉ុន្តែមានតំបន់ផលិតស្រូវសរីរាង្គលើផ្ទៃដីជាង៥០ហាត នៅក្នុងតំបន់សហគមន៍ រួមទាំងតំបន់ទេសចរណ៍ធម្មជាតិ។ ដំណាំទាំងនេះត្រូវបានអនុញ្ញាតតែនៅក្រៅតំបន់សហគមន៍ប៉ុណ្ណោះ |
| ១៦ | សហគមន៍តំបន់ការពារធម្មជាតិ/ព្រៃឈើ-សំបូរអភិវឌ្ឍន៍ (ដែនជម្រកសត្វព្រៃ | ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ | ផែនការគ្រប់គ្រងស្ថិតក្នុងដំណាក់កាលរៀបចំក្រោមការគាំទ្រពីអង្គការWCS និងនាយកដ្ឋាន | លក្ខន្តិកៈត្រូវបានរៀបចំឡើងក្នុងឆ្នាំ ២០១៣ ដោយមានការគាំទ្រពីអង្គការWCS និងនាយកដ្ឋាន | ព្រំប្រទល់ជាប់នឹងសហគមន៍តំបន់ការពារធម្មជាតិអភិវឌ្ឍន៍ព្រៃវែង | មានតែចម្ការស្វាយចន្ទីប៉ុណ្ណោះដែលគ្របដណ្តប់លើផ្ទៃដីប្រហែង ៤ហាត នៅក្នុងតំបន់ព្រៃសហគមន៍។ ខណៈដែលដីស្រែ ឬស្រែធ្វើស្រូវ |

| | | | | | | |
|---|---|---|---|---|---|---|
| | គូលែនព្រហ្ម ទេព) | | ជំនាញនៃ ក្រសួងបរិស្ថាន សហគមន៍នេះ មានផ្ទៃក្រឡា ១០៧១ហត | ជំនាញនៃ ក្រសួងបរិស្ថាន សមាជិកគណ កម្មគ្រប់ចូលរួម យ៉ាងសកម្ម ហើយក៏មាន ការគាំទ្រផង ដែរលើការ ល្បាត ជួសជុល ទំនប់ទឹក និង ផលិតកម្មស្រូវ សរីរាង្គ តាំងពី ឆ្នាំ២០២១ ដោយអង្គការ WCS និង USAID-ព្រៃ ឡង់បៃតង | | សរីរាង្គនៅក្រៅតំបន់ សហគមន៍ ផ្ទៃដីប្រមាណ១៥% ស្មើឡើងសម្រាប់ធ្វើ ចម្ការឡើងវិញ ក្នុង នោះរួមមានកសិរុក្ខ កម្ម និងស្រែផលិត ស្រូវសរីរាង្គ ផ្ទៃដី ៥% ត្រូវប្រើប្រាស់ ដើម្បីកម្ពស់ ទេសចរណ៍ធម្មជាតិ |
| ១៧ | សហគមន៍ តំបន់ការពារ ធម្មជាតិ/ព្រៃ ឈើ-ភូរៀង (ដែនជម្រក សត្វព្រៃគូលែន ព្រហ្មទេព) | ឃុំគូលែនជើង ស្រុកគូលែន ខេត្តព្រះវិហារ | ផែនការ គ្រប់គ្រងស្ថិត នៅដំណាក់ កាលរៀបចំ ដែលមានគាំទ្រ ដោយគម្រោង មូលនិធិបន្សាំ របស់គម្រោងប រិស្ថាន សហគមន៍នេះ មានផ្ទៃក្រឡា ៥៦៧,២២ហត | លក្ខន្តិកៈត្រូវ រៀបចំរួចរាល់ ក្នុងឆ្នាំ២០១៩ ក្រោមការគាំទ្រ ជីវិត និងធម្ម ជាតិ នាយក ដ្ឋានជំនាញ របស់ក្រសួងប រិស្ថានពីអង្គការ FAO | ព្រំប្រទល ជាប់នឹងសហ គមន៍អភិវឌ្ឍ ន៍ព្រៃវែង និង នៅជិតសហ គមន៍តំបន់ ការពារធម្ម ជាតិសំបូរ អភិវឌ្ឍន៍ | មិនមានចម្ការដំណាំ ចម្រុះនោះទេ ស្រូវសរីរាង្គ (ស្រូវត្រ យ៉ង) ត្រូវបានបង្ករ បង្កើនផលនៅក្រៅ តំបន់សហគមន៍ ផ្ទៃដី១៥% ប្រើប្រាស់ សម្រាប់រៀបចំចម្ការ ឡើងវិញ ក្រោម អន្តរាគមន៍ពីមនុស្ស (រួមទាំងកសិរុក្ខកម្ម កសិកដ្ឋានស្រូវសរិរា ង្គ) និង ៥% សម្រាប់ទេសចរណ៍ ធម្មជាតិ |
| ១៨ | សហគមន៍ព្រៃ ឈើព្រៃម្លូង | ឃុំស្រយ៉ង ស្រុកគូលែន ខេត្តព្រះវិហារ | ផែនការ គ្រប់គ្រងស្ថិត នៅដំណាក់ កាលរៀបចំ និង បានចុះកិច្ចព្រម ព្រៀងសហគម | លក្ខន្តិកៈត្រូវ បានរៀបចំ រួចរាល់ក្នុងឆ្នាំ ២០០៨ ក្រោម ការគាំទ្រពី នាយកដ្ឋាន | ព្រំប្រទល់ សហគមន៍ នេះមិននៅ ជាប់នឹងសហ គមន៍ដទៃ ផ្សេងទៀត | មានដីចម្ការទំហំ ៣៥ ហត ដាំដើម ស្វាយចន្ទី និងស្លាយ ហើយមិនមានស្រែ ផលិតស្រូវសរីរាង្គ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | ន៍នៅឆ្នា ២០១៨។ សហគមន៍នេះ មានផ្ទៃក្រឡា ១៧៤០ហត | ជំនាញរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ទទួលបាន ប្រកាសនៅឆ្នាំ ២០២០ សមាជិកគណ កម្មការសហ គមន៍ចូលរួម យ៉ាងសកម្ម | នោះទេ ប៉ុន្តែ នៅជិតព្រៃពូ មេបុណ្យ និង សហគមន៍ ព្រៃឈើកោះ កេរ្តិ៍កចំរើន ហើយស្ថិតនៅ ក្នុងភូមិ សាស្ត្រឃុំតែ មួយ | ស្ថិតនៅក្នុងតំបន់ សហគមន៍នោះទេ |
| ១៩ | សហគមន៍ព្រៃ ឈើកោះកេរ្តិ៍ក ចំរើន | ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ | ផែនការ គ្រប់គ្រងរយៈ ពេល ១៥ឆ្នាំ (២០១៧-២០២៣) ត្រូវ បានរៀបចំឡើង ក្នុងឆ្នាំ២០១៦ និងទទួលបាន ការឯកភាពក្នុង ឆ្នាំ២០១៧ កិច្ច ព្រមព្រៀមសហ គមន៍ត្រូវបាន រៀបចំនៅឆ្នាំ ២០១៧ជាមួយ ខណ្ឌរដ្ឋបាល ព្រៃខេត្តព្រះ វិហារ សហគមន៍នេះ មានផ្ទៃក្រឡា ១៨៦៤ហត | លក្ខន្តិកៈត្រូវ បានរៀបចំ ឡើងក្នុងឆ្នាំ ២០១៧ និង ទទួលបាន ប្រកាសនៅក្នុង ឆ្នាំដដែល សមាជិកគណ កម្មការសហ គមន៍មានការ ចូលរួមយ៉ាង សកម្ម | ព្រំប្រទល់ ជាប់សហគម ន៍ព្រៃឈើព្រៃ ពូមេបុណ្យ | មានដីចម្ការលើផ្ទៃដី ៨ហត ដាំស្វាយចន្ទី និងដំឡូងមី មិនមានការផលិតស្រូ វសេរីរាង្គ (ស្រូវត្រ យ៉ង)នៅក្នុងតំបន់ ព្រៃសហគមន៍នោះ ទេ |
| ២០ | សហគមន៍ព្រៃ ឈើព្រៃពូមេ បុណ្យ | ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ | ផែនការ គ្រប់គ្រង (២០១៧-២០៣១) បាន រៀបចំរួចរាល ក្នុងឆ្នាំ២០១៦ និងបានទទួល | លក្ខន្តិកៈត្រូវ បានរៀបចំរួច រាលក្នុងឆ្នាំ ២០១៧ និង ទទួលបាន ប្រកាសនៅក្នុង ឆ្នាំដដែល | ប្រទល់ជាប់ នឹងសហគម ន៍ព្រៃឈើ កោះកេរ្តិ៍កចំ រើន | មានដីចម្ការទំហំ ១០ ហត ដាំដុះស្វាយចន្ទី ដូង ស្វាយ និងដំឡូង មី ហើយក៏មាន ផលិតកម្មស្រូវសេរីរាង្គ នៅក្នុងតំបន់សហគម ន៍នេះផងដែរ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | ការឯកភាពនៅឆ្នាំ២០១៧ កិច្ចព្រមព្រៀងសហគមន៍ត្រូវបាចុះរួចរាលក្នុងឆ្នាំ២០១៧ ជាមួយខណ្ឌរដ្ឋបាលព្រៃខេត្តព្រះវិហារ។ សហគមន៍នេះមានផ្ទៃក្រឡា ៥៨២ហត | សមាជិកគណកម្មការសហគមន៍មានការចូលរួមយ៉ាងសកម្ម | | |




*រូបភាពទី ៨. ផែនទីសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើត្រូវបានជ្រើសរើសជាតំបន់គោលដៅគម្រោង PEARL*

*ប្រភព៖ សៀក សុផាត់, ២០២១ របាយការណ៍ចុងក្រោយស្តីពីអត្តសញ្ញាណនៃតំបន់សំខាន់ៗសម្រាប់ស្តារឡើងវិញនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើ*[21]

២១ ការប្រើឈ្មោះទាំងឡាយ និងព័ត៌មានផ្សេងៗដែលមានបង្ហាញក្នុងឯកសារនេះមិនមែនជាការសម្តែងមតិណាមួយរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) ពាក់ព័ន្ធនឹងស្ថានភាពផ្លូវច្បាប់ ឬស្ថានភាពអភិវឌ្ឍន៍របស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ណាមួយ ឬ អាជ្ញាធរនៃប្រទេស ដែនដី ទីក្រុង ឬតំបន់ ឬពាក់ព័ន្ធនឹងការកំណត់ព្រំដែន របស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ទាំងនេះឡើយ។

**បញ្ហាប្រឈមក្នុងដំណើការជ្រើសរើសសហគមន៍តមបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើ**

៣២៤. បញ្ហាប្រឈមចំនួន ២ ប្រភេទ ត្រូវបានអង្កេត ក្នុងអំឡុងពេលនៃការអនុវត្តការសិក្សានេះពោលគឺ៖ ផ្នែកបច្ចេកទេស និងរូបវន្តៈ

៣២៥. បញ្ហាប្រឈមផ្នែកបច្ចេកទេសមានទំនាក់ទំនាក់ទំនងយ៉ាងសំខាន់នឹង៖

- លទ្ធភាពរកបាន និងអំណោយផលទិន្នន័យមានតិចតួចអំពីសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើ ជាពិសេសបញ្ជី និងប្រភេទទិន្នន័យផ្លូវការ៖ ព័ត៌មានទាក់ទងនឹងលក្ខន្តិកៈ ស្ថានភាព និងកាលបរិច្ឆេទចុះបញ្ជី កិច្ចព្រមព្រៀងរបស់សហគមន៍តំបន់ការពារធម្មជាតិ/ព្រៃឈើជាមួយក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផែនការគ្រប់គ្រងសហគមន៍នៅមិនទាន់មានការប្រមូលផ្តុំ ងាយស្វែងរក។
- ភាពខុសគ្នានៃទិន្នន័យ និងគម្លាតលទ្ធផល៖ ប្រភពផ្សេងៗគ្នានៃទិន្នន័យ និងព័ត៌មាន ដោយមានទិន្នន័យខុសៗគ្នា ធ្វើការវិភាគ និងការជ្រើសរើសសហគមន៍តំបន់ការពារធម្មជាតិ/ព្រៃឈើមានបញ្ហាប្រឈម។
- លក្ខណៈវិនិច្ឆ័យស្នើឡើងដែលបង្កើតឡើងដោយអង្គការ FAO ក្នុងការជ្រើសរើស៖ មន្រ្តីពីមន្ទីរបរិស្ថាន និងខណ្ឌរដ្ឋបាលព្រៃឈើ និងតំណាងអង្គការ និងសហគមន៍មិនបានផ្តល់ការគាំទ្រលើលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើស ពីព្រោះលក្ខខណៈវិនិច្ឆ័យទាំងនេះមិនសមស្របទៅនឹងជម្រើសរបស់ពួកគេ។ ឧ. មន្រ្តីរដ្ឋាភិបាលចង់ឱ្យគម្រោង PEARL ដាក់បញ្ចូលសហគមន៍ដែលពួកគេបានធ្វើការងារជាមួយកន្លងមក ហើយសហគមន៍នោះមានការលំបាក់ទំនាក់ទំនង។ ភាគីអង្គការពេញចិត្តសហកមន៍ដែលគាំទ្រដោយគម្រោងរបស់អង្គការនោះ ព្រោះថាអង្គការនោះបានវិនិយោគលើការងារអេភិវឌ្ឍ។ ប្រជាជនមូលដ្ឋានទាមទារថា សហគមន៍របស់ពួកគេមានការគាំទ្រតិចតួចពីរដ្ឋាភិបាល និងអង្គការ។ ដូចនេះឱកាសនេះសហគមន៍របស់ពួកគេគួរទទួលបានការគាំទ្រ។

៣២៦. បញ្ហាប្រឈបផ្នែករូបវន្តកើតមានដោយសារថា៖

- ការរីរាលដាលនៃការឆ្លងជំងឺកូវីដ-១៩៖ ការធ្វើដំណើរ និងការរឹតត្បិតក្នុងការជួបជុំសង្គមធ្វើឱ្យមានការលំបាកដល់អ្នកជំនាញថ្នាក់ជាតិក្នុងការជួបប្រជុំផ្ទាល់ជាមួយមន្រ្តីរដ្ឋាភិបាល អង្គការ និងភាគីពាក់ព័ន្ធផ្សេងៗ។ ដើម្បីបញ្ចប់ការងារនេះ ចាំបាច់ត្រូវជួបគ្នាផ្ទាល់ ប៉ុន្តែដោយសារមានការហាមឃាត់ការប្រមូលផ្តុំផ្ទាល់នាំឱ្យការពន្យាពេលការងារ។
- ការធ្វើដំណើរតាមផ្លូវមានការលំបាក បូករួមនឹងរដូវភ្លៀងធ្លាក់៖ លក្ខណ្ឌទាំងនេះបានរារាំងសកម្មភាពចុះទីវាលដើម្បីពិនិត្យសហគមន៍តំបន់ការពារធម្មជាតិ/ព្រៃឈើ ដែលទទួលបានអនុសាសន៍ពីមន្រ្តីរដ្ឋាភិបាល និងបុគ្គលឹកអង្គការ។ អ្នកជំនាញជាតិបានធ្វើការសម្ភាសន៍ជាមួយគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ/ព្រៃឈើតាមទូរស័ព្ទ និងតាមប្រព័ន្ធអនឡាញផ្សេងៗទៀតតាមអាចធ្វើទៅបាន។

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ១៖ ផែនការការងារក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម (ESMF)

ឧបសម្ព័ន្ធ២៖ បញ្ជីសកម្មភាពមិនគាំទ្រដោយគម្រោង

ឧបសម្ព័ន្ធ៣៖ បញ្ជីផ្ទៀងផ្ទាត់ការត្រួតពិនិត្យវាយតម្លៃសុវត្ថិភាពបរិស្ថាន និងសង្គមរបស់អង្គការ FAO

ឧបសម្ព័ន្ធទី៤៖ យន្តការពិនិត្យឡើងវិញលើបណ្តឹងតវ៉ារបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិប្រចាំនៅកម្ពុជា

## ឧបសម្ព័ន្ធទី១៖ ផែនការការងារ និងថវិការក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម( ESMF )

តារាងខាងក្រោមបង្ហាញពីផែនការការងារ និងថវិកាសម្រាប់គម្រោង PEARL ក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម(ESMF) ក្នុងនោះរួមមានផែនការសកម្មជីវៈចម្រុះ ជនជាតិដើមភាគតិច ផែនការបរិយាប័ន្នសង្គម និងផែនការសកម្មភាពយេនឌ័រ។ ក្របខ័ណ្ឌការងារត្រួតពិនិត្យ និងការរៀបចំគម្រោងមានការបញ្ចូល និងបញ្ជ្រាបការពិចារណាពីយេនឌ័រ ជីវៈចម្រុះ និងជនជាតិដើមភាគតិចយ៉ាងពេញលេញ និងបរិយាប័ន្នសង្គមទៅក្នុងគោលដៅរបស់គម្រោង ដោយសមាសភាពទាំងនេះផ្តល់ការណែនាំដ៏សំខាន់សម្រាប់អនុវត្តគម្រោង។ ដូច្នេះឯកសារបច្ចុប្បន្ននេះមានគោលដៅទាំងនេះ (ពីរជួរឈរចុងក្រោយ) ដើម្បីបង្ហាញថាតើចំណុចត្រូវបានដាក់បញ្ចូលនៅក្នុងផ្នែកណា។ សកម្មភាពគម្រោងទាំងអស់ក៏ត្រូវបានបញ្ចូល (ជួរឈរទីមួយ) ដើម្បីបង្ហាញពីកម្រិតនៃការបញ្ជ្រាប ក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម(ESMF) ដែលអនុញ្ញាតឱ្យមានសំណុំសកម្មភាពដែលបានបញ្ជ្រាបទៅក្នុងផែនការដែលមានស្រាប់។

ស្របតាមវិធីសាស្ត្រនេះ ផែនការការងារ និងថវិកាបានយកចិត្តទុកដាក់នៅជុំវិញការងាររបស់អ្នកជំនាញការពារសុវត្ថិភាពជាតិ និងអ្នកជំនាញយេនឌ័រជាតិដែលនឹងធ្វើការរួមគ្នាលើការបញ្ជ្រាបការការពារលើគ្រប់ផ្នែកនៃការងារស្របតាម ក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម(ESMF) និង ផែនការគ្រប់គ្រងបរិស្ថាននិងសង្គម(ESMPs) ជាក់លាក់ដែលមានបញ្ចូលការវាយតម្លៃទិន្នន័យមូលដ្ឋាន ការដាក់បញ្ចូលការពិចារណាអំពីការការពារសុវត្ថិភាពទៅក្នុងការបណ្តុះបណ្តាល និងការលើកកម្ពស់ការយល់ដឹងដល់បុគ្គលិកគម្រោង និងភាគីពាក់ព័ន្ធកាន់តែទូលំទូលាយ តាមរយៈដំណើរការអនុវត្ត ក៏ដូចជាការត្រួតពិនិត្យឡើងវិញ និងធានាថា ផលិតផល និងវិធីសាស្ត្ររបស់គម្រោងមានបញ្ជ្រាបយ៉ាងពេញលេញនូវការពិចារណាអំពីយេនឌ័រ។ ចំណុចនេះមានបញ្ចូលការងាររបស់អ្នកឯកទេសការពារសុវត្ថិភាពអន្តរជាតិ និងក្រុមទីប្រឹក្សាយេនឌ័រជាតិ ដែលនឹងផ្តល់ការគាំទ្របន្ថែមដល់ការវាយតម្លៃទិន្នន័យមូលដ្ឋាន ដោយផ្តោតជាសំខាន់លើផ្នែកសំខាន់ៗ ការបង្កើត ផែនការគ្រប់គ្រងបរិស្ថាននិងសង្គម(ESMP) ជាក់លាក់ និងការអនុវត្តការសិក្សាលើទិន្នន័យជាមូលដ្ឋាន និងការណែនាំជាក់លាក់សម្រាប់ការអនុវត្តការការពារសុវត្ថិភាពបរិស្ថាន និងសង្គម។

ការអនុវត្តការការពារនឹងធ្វើឡើង តាមរយៈកិច្ចសម្របសម្រួលយ៉ាងជិតស្និទ្ធរវាងអង្គភាពគ្រប់គ្រងគម្រោង (PMU) និង ដៃគូអនុវត្តថ្នាក់ជាតិ ក្នុងនោះរួមទាំងក្រសួងបរិស្ថានដែលនឹងដឹកនាំលើកិច្ចក្នុងតំបន់សហគមន៍តំបន់ការពារធម្មជាតិ និងសហគន៍ព្រៃឈើដែលបង្កហានិភ័យមួយក្នុងចំណោមហានិភ័យសំខាន់ៗក្នុងការការពារសុវត្ថិភាព ដោយសារទីតាំងនៃតំបន់ទាំងនេះស្ថិតក្នុងតំបន់ការពារធម្មជាតិ និងលទ្ធភាពខ្ពស់នៃវត្តមានរបស់ជនជាតិដើមភាគតិច និងក្រុមងាយរងគ្រោះដទៃទៀត។

| សកម្មភាពគម្រោងសំខាន់ៗ | សកម្មភាពផ្តោតសំខាន់លើការការពារ | សូចនាករនិងគោលដៅ | កាលកំណត់ | ថវិកា | ទំនួលខុសត្រូវ | ភ្ជាប់ទៅគោលដៅគម្រោងសំខាន់ៗ | |
|---|---|---|---|---|---|---|---|
| | | | | | | ពាក់កណ្តាលអាណត្តិ | អាណត្តិចុងក្រោយ |
| សេចក្តីថ្លែងការណ៍អំពីផលប៉ះពាល់៖ កសិករខ្នាតតូចជាស្ត្រីនិងជាតួអង្គខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀតទទួលបានសិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចតាម រយៈការធ្វើឱ្យប្រសើរឡើងនៃលទ្ធភាពប្រើប្រាស់ដែលរឹងថានឹងប៉ះពាល់ដល់ផ្នែកទីផ្សារផលិតផលតម្លៃខ្ពស់ដែលកំពុងកើនឡើង ហើយក្នុងពេលជាមួយគ្នាប្រើប្រាស់លទ្ធភាពចូលទីផ្សារដែលមានភាពប្រសើរឡើងដើម្បីលើកទឹកចិត្តទៅលើការផ្លាស់ប្តូរទៅការអនុវត្តដែលធន់នឹងអាកាសធាតុ ជាពិសេសតាមរយៈភាពជាដៃគូយ៉ាងមានប្រសិទ្ធភាពរវាងសាធារណៈ ឯកជន និងសហគមន៍។ | | | | | | | |
| លទ្ធផលទី ១៖ សមត្ថភាពរបស់កសិករត្រូវបានពង្រឹង ដើម្បីគ្រប់គ្រងផលប៉ះពាល់ពីអាកាសធាតុ និងហានិភ័យពាក់ព័ន្ធ | | | | | | | |
| លទ្ធផលទី ១.១ ភាពមានព័ត៌មាន និងលទ្ធភាពទទួលបានសេវាប្រឹក្សាខាងកសិឧតុនិយម ឆ្លើយតបតម្រូវការតាមខ្សែច្រវ៉ាក់តម្លៃគោលដៅ ត្រូវបានកែលម្អក្នុងចំណោមកសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុក ជាពិសេសកសិករ និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃជាស្ត្រី។ | | | | | | | |
| សកម្មភាព ១.១.១៖ បង្កើនវិសាលភាពការប្រមូលទិន្នន័យកសិឧតុនិយម និងសមត្ថភាពវិភាគបកស្រាយទិន្នន័យ ដើម្បីផលិតការព្យាករណ៍កសិឧតុនិយម និងសេវាកម្មប្រឹក្សាកសិឧតុនិយមដែលឆ្លើយតបតាមតម្រូវការប្រើប្រាស់ក្នុងខ្សែច្រវ៉ាក់តម្លៃគោលដៅ។ | គាំទ្រការរួមបញ្ចូលការ ពិចារណាលើការការពារនៅក្នុងលក្ខខណ្ឌមូលដ្ឋាន សមត្ថភាព និងគម្លាតទិន្នន័យនៃស្ថានីយ៍និងតំបន់ដែលមានស្រាប់ដែលត្រូវការ ហើយបញ្ចូលទៅក្នុងការបង្កើតលក្ខណៈវិនិច្ឆ័យដែលរួមបញ្ចូលការពិចារណាលើការការពារសម្រាប់ការវាយតម្លៃរបស់ស្ថានីយ៍អាទិភាព និងតម្រូវការបណ្តុះបណ្តាលសម្រាប់អ្នកគ្រប់គ្រងស្ថានីយ៍ អ្នកវិភាគទិន្នន័យ និងអ្នកគ្រប់គ្រងបែបបទផ្តល់ការក | លក្ខណៈវិនិច្ឆ័យសម្រាប់ការពិនិត្យឡើងវិញនៃស្ថានីយ៍ដែលបានស្នើឡើង និងទីតាំងបណ្តុះបណ្តាលរួមមានការពិចារណាលើការការពារនិងរបាយការណ៍សង្ខេបស្តីពីដំណើរការជ្រើសរើសដែលមាន។ ចំនួនភាគីពាក់ព័ន្ធសំខាន់ៗបានយល់ដឹងអំពីបញ្ហាការពារ។ | ឆ្នាំទី១-៥ | សូមមើល ២.៤ អ្នកជំនាញការពារជាតិ | អ្នកជំនាញការពារជាតិ | SOPs សម្រាប់ដំណាំគោលដៅទាំងបួន (៤) ត្រូវបានអភិវឌ្ឍ និងឯកភាពគ្នាយ៉ាងពេញលេញក្នុងចំណោមដៃគូរដ្ឋ និងឯកជន និងការអនុវត្តជាក់ស្តែង។<br><br>១៥% នៃគោលដៅកសិករខ្នាតតូច និងតួអង្គខ្សែច្រវ៉ាក់តម្លៃ | ព័ត៌មានកសិឧតុវិទ្យា ជាក់លាក់អំពីដំណាំសម្រាប់ដំណាំគោលដៅទាំងបួន (៤) គឺអាចរកបានយ៉ាងពេញលេញ និងអាចចូលដំណើរការបានតាមរយៈប្រតិបត្តិការនៃ SOPs។ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| សកម្មភាព ១.១.២៖ បង្កើតនិតិវិធីប្រតិបត្តិការស្តង់ដារ (SOP) សម្រាប់ការផលិត និងការផ្សព្វផ្សាយសេវាកម្មប្រឹក្សាផ្នែកកសិឧតុនិយម និងតម្រូវការចែករំលែកទិន្នន័យ និងរចនាសម្ព័ន្ធ ដោយផ្តោតលើដំណាំស្វាយចន្ទី ស្វាយ ស្រូវ និងបន្លែតាមរយៈមធ្យោបាយផ្សេងៗ។<br><br>សកម្មភាព១.១.៣៖ បង្កើនការយល់ដឹងអំពីសេវាប្រឹក្សាកសិឧតុនិយម និងអត្ថប្រយោជន៍នៃការអនុវត្តក្នុងការគ្រប់គ្រងដំណាំ និងសកម្មភាព | សាងសមត្ថភាពដល់ TWG-AW ដែលដឹកនាំដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម ជាមួយនឹង អ្នកជំនាញបន្ថែមពីអង្គភាពពាក់ព័ន្ធផ្សេងទៀត លើការពិចារណាលើការការពារដែលភ្ជាប់ទៅនឹងដំណើរការអភិវឌ្ឍបំផុសពួកគេឱ្យប្រសើរឡើងនូវការរួមបញ្ចូល លើការការពារនៅក្នុងការរចនាស្ថានីយ៍ និងការផ្តល់ព័ត៌មាន។<br><br>ការត្រួតពិនិត្យជាបន្ត និងបញ្ចូលទៅក្នុងការអភិវឌ្ឍសម្ភារៈ TOT និងឧបករណ៍ផ្សេងទៀត ដូចជាព័ត៌មានស្តីពីការលើកកម្ពស់ការយល់ដឹងអំពីពួកវា ដើម្បីធានាថាពួកគេអាចទទួលបានសម្រាប់កសិករជនជាតិភាគតិចគ្រប់ក្រុម និងតួអង្គខ្សែច្រវ៉ាក់តម្លៃក្នុងស្រុក។ គាំទ្រការរួមបញ្ចូលការ | ការពិនិត្យវាយតម្លៃជាផ្នែកនៃដំណើរការអភិវឌ្ឍបានបញ្ចប់។ ការពិចារណាការការពារដែលរួមបញ្ចូលយ៉ាងពេញលេញទៅក្នុងសម្ភារៈ ToT ក៏ដូចជាឧបករណ៍ផ្សេងទៀតនិងព័ត៌មានដែលយល់ដឹង។<br>លក្ខណៈវិនិច្ឆ័យសម្រាប់ការពិនិត្យឡើងវិញនៃស្ថានីយ៍ដែលបានស្នើឡើង និងទីតាំងបណ្តុះបណ្តាលរួមមានយេនឌ័រ និងរបាយការណ៍សង្ខេបស្តីពីដំណើរការជ្រើសរើសដែលមាន។<br><br>ចំនួនភាគីពាក់ព័ន្ធសំខាន់ៗបានយល់ដឹងអំពីវិសមភាពយេនឌ័រនៅក្នុងបរិបទនៃការចូលប្រើទិន្នន័យអាកាសធាតុ និងកសិកម្មអេកូឡូស៊ី និងការប្រើប្រាស់ទិន្នន័យដែលបែងចែកភេទ ដើម្បីជួយដល់ការ | ១ ដល់៥ ឆ្នាំ<br><br>២ - ៥ឆ្នាំ | ៤0.៥00<br><br>៩៩.000 | អង្គភាពគ្រប់គ្រងគម្រោង (PMU) អ្នកជំនាញយេនឌ័រជាតិ ក្រុមទីប្រឹក្សាយេនឌ័រជាតិ។ | ក្នុងស្រុកផ្សេងទៀត (ស្ត្រី ៥0%)។ | ជាង ៤0% នៃគោលដៅកសិករខ្នាតតូច និងតួអង្គច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀត (ស្ត្រី ៥0%)។ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| បង្កើនតម្លៃបន្ថែម ដើម្បីគាំទ្រដល់ការសម្រេចចិត្ត និងកាត់បន្ថយភាពងាយរងគ្រោះរបស់កសិករខ្នាតតូច និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀត ចំពោះការប្រែប្រួលអាកាសធាតុជាពិសេសកសិករ និងតួអង្គក្នុងខ្សែច្រវ៉ាក់តម្លៃជាស្ត្រី។ | ពិចារណាអំពីយេនឌ័រនៅក្នុងលក្ខខណ្ឌមូលដ្ឋាន និងសមត្ថភាព និងគម្លាតទិន្នន័យនៃស្ថានីយ៍ដែលមានស្រាប់ និងតំបន់ដែលត្រូវការ។ គាំទ្រដល់ការអភិវឌ្ឍលក្ខណៈវិនិច្ឆ័យដែលរួមបញ្ចូលការពិចារណាអំពីយេនឌ័រសម្រាប់ការវាយតម្លៃស្ថានីយ៍អាទិភាពសម្រាប់ការធ្វើឱ្យប្រសើរឧបករណ៍ចាប់សញ្ញាបន្ថែម ទីតាំងយុទ្ធសាស្ត្រសម្រាប់ការបន្ថែមស្ថានីយ៍កសិឧតុវិទ្យាថ្មី និងតម្រូវការបណ្តុះបណ្តាលសម្រាប់អ្នកគ្រប់គ្រងស្ថានីយ៍អ្នកវិភាគទិន្នន័យ និងអ្នកគ្រប់គ្រងប្រព័ន្ធផ្តល់ការកសាងសមត្ថភាពដល់TWG-AW ដែលដឹកនាំដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងធនធានទឹក និងឧតុនិយម ជាមួយនឹងអ្នកជំនាញបន្ថែមពី | សម្រេចចិត្ត។ ការត្រួតពិនិត្យការវាយ តម្លៃជាផ្នែកនៃដំណើរការអភិវឌ្ឍន៍បានបញ្ចប់។ ការពិចារណាអំពីយេនឌ័របានរួមបញ្ចូលយ៉ាងពេញលេញទៅក្នុងសម្ភារៈ ToT ក៏ដូចជាឧបករណ៍ផ្សេងទៀត និងព័ត៌មាននៃការយល់ដឹង។ | | | ក្រុមទីប្រឹក្សាយេនឌ័រជាតិ | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | អង្គភាពពាក់ព័ន្ធផ្សេងទៀត លើការពិចារណាអំពីយេនឌ័រ ដែលភ្ជាប់ទៅនឹងដំណើរការអភិវឌ្ឍ និងប្រមូលផ្តុំពួកគេឱ្យប្រសើរឡើងនូវសមាហរណកម្មការពិចារណាអំពីយេនឌ័រនៅក្នុងការរចនាស្ថានីយ៍ និងការផ្តល់ព័ត៌មាន។<br>ការត្រួតពិនិត្យជាបន្ត និងបញ្ចូលទៅក្នុងការអភិវឌ្ឍសម្ភារៈTOT និងឧបករណ៍ផ្សេងទៀត ក៏ដូចជាព័ត៌មានស្តីពីការលើកកម្ពស់ការយល់ដឹងអំពីពួកវា ដើម្បីធានាថា ពួកគេអាចប្រើប្រាស់បានសម្រាប់ស្ត្រី និងកសិករជនជាតិភាគតិចផ្សេងទៀត និងតួអង្គខ្សែច្រវ៉ាក់តម្លៃនៅមូលដ្ឋាន។ | | | | | | |
| លទ្ធផលទី ២៖ សមត្ថភាពបន្សាំខ្លួនរបស់កសិករខ្នាតតូច និងតួអង្គខ្សែច្រវ៉ាក់តម្លៃក្នុងស្រុកផ្សេងទៀត ជាពិសេសកសិករស្ត្រីដែលងាយរងគ្រោះត្រូវបានបង្កើន តាមរយៈការលើកទឹកចិត្តផ្នែកទីផ្សារដែលលើកកម្ពស់ការផលិត និងការកែច្នៃដែលភាពធន់នឹងអាកាសធាតុ មានតម្លៃខ្ពស់ ពិពិធកម្ម និងប្រកបដោយនិរន្តរភាព។ | | | | | | | |
| លទ្ធផលទី ២.១៖ ឱកាសទទួលបានទីផ្សារពិសេសសម្រាប់កសិករ និងអ្នកកែច្នៃស្វាយចន្ទី ស្វាយ ស្រូវសរីរាង្គ និង បន្លែបានកើនឡើងតាមរយៈកម្មវិធីវិញ្ញាបនប័ត្របញ្ជាក់គុណភាពផលិតផលដែលធន់នឹងអាកាសធាតុ និងមានតម្លៃខ្ពស់ (ភ្ជាប់ទៅផ្នែករង ២.២. និង ២.៣ សម្រាប់ការផ្តល់ហិរញ្ញប្បទាន និងការកសាងសមត្ថភាពផ្នែកបច្ចេកទេស)។ | | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
|---|---|---|---|---|
| | | | • អនុវត្តតាមគោលនយោបាយព្រៃឈើជាតិ កម្មវិធីព្រៃឈើ ឬយុទ្ធសាស្ត្រប្រហាក់ប្រហែលដែលមានស្រាប់។<br>• ការប្រតិបត្តិតាមគោលការណ៍ ៩,១០,១១ និង១២ នៃគោលការណ៍ស្ម័គ្រចិត្តស្តីពីព្រៃដាំ មានលក្ខណៈគ្រប់គ្រាន់សម្រាប់ព្រៃធម្មជាតិដែលដុះដោយខ្លួនវា ប៉ុន្តែត្រូវតែឆ្លើយតបទាំងស្រុងជាមួយបទដ្ឋាន បរិស្ថាន និងសង្គម (ESS៩) ជនជាតិដើមភាគតិច និងបេតិកភណ្ឌវប្បធម៌។<br>• អ្នករៀបចំផែនការ និងអ្នកគ្រប់គ្រងត្រូវបញ្ចូលការអភិរក្សជីវៈចម្រុះជាមូលដ្ឋាននៅក្នុងការធ្វើផែនការ ការគ្រប់គ្រង ការប្រើប្រាស់ និងការតាមដានធនធានព្រៃដាំ។<br>• នៅក្នុងការកាត់បន្ថយហានិភ័យ ឧប្បត្តិហេតុ និងផលប៉ះពាល់បរិស្ថាននៃភ្នាក់ងារបំផ្លាញជីវិត និងអជីវិត និងដើម្បីធ្វើឱ្យប្រសើរឡើងនូវសុខភាព និងផលិតភាពព្រៃដាំ អង្គការស្បៀង និងកសិកម្មពិភពលោកនឹងធ្វើការជាមួយភាគីពាក់ព័ន្ធនានាដើម្បីបង្កើត និងស្វែងរកដម្រើសឆ្លើយតបដែលមានប្រសិទ្ធិភាពនៅក្នុងការគ្រប់គ្រងព្រៃដាំ។ | សមត្ថភាពរបស់សហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើ ដោយផ្តោតទៅលើប្រភេទឈើដាំដែលមានប្រភពក្នុងស្រុក ក៏ដូចជាកសិរុក្ខកម្មខ្នាតតូចដែលមាននិរន្តរភាព (ឧទាហរណ៍ ឡូត៍ព្រៃឈើ និងប្រព័ន្ធសួនដំណាំតាមផ្ទះ) ដើម្បីបំពេញតម្រូវការអុស និងឈើប្រើប្រាស់។ គម្រោងនេះនឹងទទួលយក និងអនុវត្តយ៉ាងម៉ឺងម៉ាត់នូវក្របខ័ណ្ឌសុវត្ថិភាព REDD+ និងបទដ្ឋានគតិយុត្តិថ្នាក់ជាតិដែលពាក់ព័ន្ធ រួមមានគោលការណ៍ណែនាំស្តីពីសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើ ដើម្បីកាត់បន្ថយហានិភ័យសង្គម និងបរិស្ថាន តាមរយៈសកម្មភាពស្តារព្រៃឈើឡើងវិញ។ |

## ផ្នែកសុវត្ថិភាព ៤ ធនធានសេណេទិចសត្វ (ការចិញ្ចឹមសត្វ និងវារីវប្បកម្ម) សម្រាប់ស្បៀង និងកសិកម្ម

| | នាំយកមកនូវប្រភេទ/ពូជថ្មី និងកែប្រែនៅក្នុងប្រព័ន្ធផលិតកម្មនៃពូជក្នុងស្រុក | គ្មាន | មាន | មតិយោបល់ |
|---|---|---|---|---|
| ៤.១ | តើគម្រោងនេះនាំយកមកនូវប្រភេទ ពូជ សេណូទីប ឬ សម្ភារៈសេណេទិកផ្សេងទៀតទៅកាន់តំបន់ ឬ ប្រព័ន្ធផលិតកម្មមួយ? | **ហានិភ័យទាប** | បន្តទៅសំណួរបន្ទាប់ | គម្រោងនេះនឹងមិនពាក់ព័ន្ធនឹងការនាំយកមកនូវការចិញ្ចឹមសត្វឡើយ។ |
| ៤.១.១ | តើគម្រោងនេះប្រមើលឃើញពីការកើនឡើងផលិតកម្មលើសពី៣០ % (ដោយផ្អែកលើការនាំយកមក) ពាក់ព័ន្ធនឹងពូជសត្វដែលមានស្រាប់ក្នុងស្រុកក្នុងពេលបច្ចុប្បន្ន និងតាមដានលទ្ធផលផលិតកម្ម? | មិនអាចបន្តទៅមុខ | ហានិភ័យទាប | |
| ៤.១.២ | តើគម្រោងនេះនាំយកមកនូវសារពាង្គកាយដែលត្រូវបានកែប្រែសេណេទិច ឧទាហរណ៍តាមរយៈការបង្កាត់ពូជដោយជម្រើស ការកែប្រែបណ្តុំក្រូម៉ូសូម ការបង្កាត់ពូជហាយប្រីត ការកែប្រែហ្សែន ឬផ្ទេរហ្សែន និង/ឬ នាំយកមក ឬបង្កើតផលិតផលនៃបច្ចេកវិទ្យាទាំងនោះ? | **ហានិភ័យទាប** | **ហានិភ័យខ្ពស់**<br><br>ទាមទារឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ។<br>សូមទាក់ទងអង្គភាពគ្រប់គ្រងសង្គម និងបរិស្ថាន សម្រាប់គោលការណ៍ណែនាំបន្តទៀត។ | |

| | | | | |
|---|---|---|---|---|
| ៤.២ | តើគម្រោងនេះនាំយកមកនូវប្រភេទ ឬពូជដែលមិនមាន ឬគ្មានប្រភពដើមនៅក្នុងស្រុក ដែលជាការនាំយកមកជាលើកទី១ ចូលទៅក្នុងប្រទេស ឬប្រព័ន្ធផលិតកម្មមួយ? | **ហានិភ័យទាប** | ហានិភ័យមធ្យម<br>ការវាយតម្លៃផលប៉ះពាល់សេដ្ឋកិច្ច គួរត្រូវបានធ្វើឡើង មុនពេលផ្តល់ការអនុញ្ញាតឱ្យនាំចូល (គ្របដណ្តប់ទៅការធ្វើអត្តសញ្ញាណកម្មសត្វ កំណត់ត្រាលទ្ធផល និងការបង្កើតសមត្ថភាពដែលផ្តល់ជាការតាមដានទៅលើផលិតភាព សុខភាព និងនិរន្តរភាពសេដ្ឋកិច្ច នៅក្នុងវដ្តផលិតកម្មច្រើនរបស់ប្រភេទ/ពូជសត្វដែលត្រូវនាំយកមកនោះ)<br>http://www.fao.org/docrep/012/i0970e/i0970e00.htm<br>•ftp://ftp.fao.org/docrep/fao/012/i0970e/i0970e03.pdf | |
| ៤.៣ | តើគម្រោងនេះនាំយកមកនូវប្រភេទ ឬពូជដែលមិនមាន ឬគ្មានប្រភពដើមនៅក្នុងស្រុក ដោយមិនខ្វល់ថាប្រភេទ/ពូជទាំងនោះមាននៅស្រុកស្រាប់ទៅហើយ? | **ហានិភ័យទាប** | **ហានិភ័យមធ្យម**<br>• ប្រសិនបើគម្រោងនាំចូល ឬជំរុញការប្រើប្រាស់ប្រភេទ/ពូជដែលមានលទ្ធផលខ្ពស់ជាងពូជដែលមានស្រាប់ក្នុងប្រទេស ត្រូវធានានូវធនធានចំណី ការគ្រប់គ្រងសុខភាព សមត្ថភាពគ្រប់គ្រងកសិដ្ឋាន ការផ្គត់ផ្គង់ធាតុចូល និងការរៀបចំកសិករដែលអាចឱ្យប្រភេទ/ពូជថ្មីទាំងនោះបង្ហាញពីសក្តានុពលសេដ្ឋកិច្ចរបស់វា<br>• អនុវត្តតាមក្រមសត្វរស់នៅលើគោក និងទឹករបស់អង្គការពិភពលោកសម្រាប់សុខភាពសត្វ ដើម្បីធានាថា ប្រភេទ/ពូជសត្វដែលនាំយកមក មិនមានផ្ទុកជំងឺផ្សេងពីពូជក្នុងស្រុក<br>• រួមបញ្ចូលនូវការវាយតម្លៃហានិភ័យសុខភាព និងការអភិវឌ្ឍ | |

| | | | | |
|---|---|---|---|---|
| | | | សមត្ថភាពពេទ្យសត្វ/កសិករនៅក្នុងគម្រោង ដើម្បីធានាថាប្រភេទ/ពូជសត្វដែលនាំយកមកនេះមិនងាយឆ្លងជំងឺដែលមានស្រាប់ក្នុងស្រុក រួមទាំងពពួកប៉ារ៉ាស៊ីតដែលរស់លើ និងក្នុងសារពាង្គកាយ បើប្រៀបធៀបនឹងប្រភេទ/ពូជសត្វដែលមានស្រាប់/មានប្រភពដើមក្នុងស្រុក។ | |
| ៤.៤ | តើគម្រោងនេះធានាថាគ្មានការសាយភាយសម្ភារៈសេណេទិចដែលនាំយកមកនេះ ទៅក្នុងប្រព័ន្ធផលិតកម្មដទៃទៀត (ពោល គឺបង្កាត់លាយឡំជាមួយប្រភេទ/ពូជក្នុងស្រុក)? | **ហានិភ័យមធ្យម** យកមកនូវ a) ការធ្វើអត្តសញ្ញាណកម្មសត្វ និងយន្តការកត់ត្រា នៅក្នុងគម្រោង និង b) ការបង្កើតថ្មី ឬកែប្រែទៅលើគោលនយោបាយចិញ្ចឹមសត្វ និងផែនការសកម្មភាពនិងយុទ្ធសាស្ត្រជាតិសម្រាប់ធនធានសេណេទិចសត្វ (AnGR) | **ហានិភ័យទាប** | |
| | **ប្រមូលធនធានសេណេទិចព្រៃសម្រាប់ប្រព័ន្ធកសិដ្ឋានចិញ្ចឹមសត្វ** | **គ្មាន** | **មាន** | **មតិយោបល់** |
| ៤.៥ | តើគម្រោងនេះប្រមូលធនធានមានជីវិតពីក្នុងព្រៃ ឧទាហរណ៍ សម្រាប់ការបង្កាត់ពូជ ឬ កូនសត្វ និងពងសត្វ សម្រាប់បន្តចិញ្ចឹមឱ្យធំ? | ហានិភ័យទាប | **ហានិភ័យមធ្យម** នឹងផ្តល់គោលការណ៍ណែនាំ | **គម្រោងនេះនឹងមិនជាប់ពាក់ព័ន្ធនឹងការប្រមូលធនធានមានជីវិតចេញពីព្រៃឡើយ។** |
| | ការកែប្រែទីជម្រក | គ្មាន | មាន | មតិយោបល់ |
| ៤.៦ | គម្រោងនេះនឹងកែប្រែទីជម្រកជុំវិញ ឬប្រព័ន្ធ | ហានិភ័យទាប | **ហានិភ័យមធ្យម** នឹងផ្តល់គោលការណ៍ណែនាំ | **គ្មានសកម្មភាពពាក់ព័ន្ធ** |

| | | | | |
|---|---|---|---|---|
| | ផលិតកម្មដែលត្រូវបានប្រើប្រាស់ដោយធនធានសេណេទិចដែលមានស្រាប់? | | | |
| ៤.៧ | តើគម្រោងនេះស្ថិតនៅក្នុង ឬក្បែរតំបន់អភិរក្សដែលត្រូវបានទទួលស្គាល់ពីអន្តរជាតិ ឧទាហរណ៍ តំបន់រ៉ាមសារ ឬ តំបន់បេតិកភណ្ឌថ្នាក់ជាតិ ឬទីជម្រកដែលមានសារៈសំខាន់ថ្នាក់ជាតិផ្សេងទៀត ដូចជាឧទ្យានជាតិ ឬដីកសិកម្មដែលមានតម្លៃធម្មជាតិខ្ពស់? | **ហានិភ័យទាប** | **ហានិភ័យមធ្យម** នឹងផ្តល់គោលការណ៍ណែនាំ | គម្រោងនេះនឹងធ្វើការជាមួយក្រុមសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើដែលស្ថិតនៅក្នុងទីជម្រកសំខាន់ៗថ្នាក់ជាតិដែលមាននៅក្នុងតំបន់ការពារធម្មជាតិ។ សកម្មភាពនៅក្នុងតំបន់ទាំងនេះនឹងផ្តោតទៅលើការស្តារទីជម្រកធម្មជាតិឡើងវិញ និងគាំទ្រដល់កសិកម្មដែលមានស្រាប់តាំងពីមុន និងអនុញ្ញាតដោយច្បាប់នៅក្នុងតំបន់ទាំងនោះ ដើម្បីពង្រឹងនិរន្តរភាព និងកាត់បន្ថយផលប៉ះពាល់។ |
| ៤.៨ | AQGR ធនធានសេណេទិចសារពាង្គកាយក្នុងទឹ តើគម្រោង | ហានិភ័យទាប | **ហានិភ័យមធ្យម** នឹងផ្តល់គោលការណ៍ណែនាំ | **គ្មានសកម្មភាពពាក់ព័ន្ធ** |

| | | | | |
|---|---|---|---|---|
| | នេះរាំង ឬបង្កើតផ្លូវហូរចូលសម្រាប់ប្រភេទសារពាង្គកាយរស់នៅក្នុងទឹក? | | | |
| ៤.៩ | តើគម្រោងនេះផ្លាស់ប្តូរបរិមាណ និងគុណភាពទឹកនៅក្នុងតំបន់គម្រោង ឬតំបន់ជាប់នឹងគម្រោង ? | ហានិភ័យទាប | **ហានិភ័យមធ្យម** នឹងផ្តល់គោលការណ៍ណែនាំ | **គ្មានសកម្មភាពពាក់ព័ន្ធ** |
| ៤.១០ | តើគម្រោងនេះបង្កឱ្យមានការប្រែប្រួលប្រព័ន្ធផលិតកម្ម/ទីជម្រកសំខាន់ៗ ដែលជំរុញឱ្យមានឱកាសសម្រាប់លំហូរសេណេទិច ឧទាហរណ៍ ការតភ្ជាប់ផ្ទៃទឹក ឬប្រព័ន្ធអេកូឡូស៊ីដែលមានភាពខុសប្លែកគ្នាទៅតាមភូមិសាស្ត្រ? ឬគម្រោងនេះរំខានដល់ទីជម្រក ឬច្រកចេញចូល និងរចនាសម្ព័ន្ធសេណេទិចនៃប្រភេទ/បណ្តុំធនធាន/ពូជសត្វដែលមានក្នុងស្រុក ឬដ៏មានតម្លៃ? | ហានិភ័យទាប | **ហានិភ័យខ្ពស់** ទាមទារឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ។ សូមទាក់ទងអង្គភាពគ្រប់គ្រងសង្គម និងបរិស្ថាន សម្រាប់គោលការណ៍ណែនាំបន្តទៀត។ | **គ្មានសកម្មភាពពាក់ព័ន្ធ** |
| ៤.១១ | តើគម្រោងនេះជាប់ពាក់ព័ន្ធនឹងពិពិធកម្មប្រព័ន្ធផលិតកម្មដែលបណ្តាលឱ្យមានការផ្លាស់ប្តូរការប្រើប្រាស់ដី (ឧទាហរណ៍ ការកាប់បំផ្លាញព្រៃឈើ) ការកើនឡើងបន្ថែមនូវ | ហានិភ័យទាប | **ហានិភ័យមធ្យម** នឹងផ្តល់គោលការណ៍ណែនាំ | គម្រោងនេះនឹងគាំទ្រដល់ការពង្រឹងផលិតភាពកសិកម្ម ប៉ុន្តែធ្វើឡើងដោយផ្អែកលើទម្រង់កសិកម្មដែលមានស្រាប់ |

| | | | | |
|---|---|---|---|---|
| | ជាតុចូលសារជាតុ ចិញ្ចឹមខ្ពស់ឈានទៅរកការបំពុលទឹក ឬការបំពុលដី ឬការប្រែប្រួលរបបទឹក (ការបង្ហូរចេញ ការស្រោចស្រព)? | | | និងផ្តោតទៅលើការទទួលយកការអនុវត្តកសិកម្មល្អ (GAP) ក៏ដូចជាពង្រឹងគុណភាពផលិតកម្មឱ្យស្របទៅតាមបទដ្ឋាននិរន្តរកម្មដែលត្រូវបានទទួលស្គាល់ដោយថ្នាក់ជាតិ និងសកលលោក។ |
| | | | | |

## ផ្នែកសុវត្ថិភាព ទី៥ ការគ្រប់គ្រងសត្វល្អិត និងថ្នាំសម្លាប់សត្វល្អិត

| | **ការផ្គត់ផ្គង់ថ្នាំសម្លាប់សត្វល្អិតដោយអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO)** | **គ្មាន** | **មាន** | **មតិយោបល់** |
|---|---|---|---|---|
| ៥.១ | តើគម្រោងនេះនឹងទទួលបាន ផ្គត់ផ្គង់ ឬបណ្តាលឱ្យមានការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតទៅលើដំណាំ បសុសត្វ វារីវប្បកម្ម ឬព្រៃឈើដែរឬទេ? | ហានិភ័យទាប | **ហានិភ័យមធ្យម**<br>• ត្រូវតែផ្តល់អាទិភាពដល់វិធីសាស្ត្រនានាដែលអាចគ្រប់គ្រងសត្វល្អិតប្រកបដោយនិរន្តរភាពដូចជា វិធានការចម្រុះគ្រប់គ្រងដំណាំ (IPM) ការប្រើប្រាស់វិធីសាស្ត្រគ្រប់គ្រងសត្វល្អិតបែបអេកូឡូស៊ី និងការប្រើប្រាស់ឧបករណ៍គ្រប់គ្រងសត្វល្អិតបែបមេកានិក វប្បធម៌ រូបសាស្ត្រ ឬជីវសាស្ត្រ ដែលទ្រទ្រង់ដល់សារជាតុគីមីសំយោគ និងវិធានការបង្ការ និងតាមដាន | គម្រោងនេះនឹងលើកកម្ពស់ការទទួលយក GI, CamGAP, HACCP ព្រមទាំងផលិតកម្ម និងដំណើរការដែលអនុលោមតាមវិញ្ញាបនបត្រសេរីរាង្គ និង IPM។ ដូច្នេះ |

| | | | | |
|---|---|---|---|---|
| | | | • នៅពេលដែលមិនមានជម្រើសផ្សេងក្រៅពីការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតដែលមានផ្ទុកសារធាតុគីមី ការជ្រើសរើស និងការទទួលយកថ្នាំសម្លាប់សត្វល្អិតគឺស្ថិតនៅក្រោមនីតិវិធីនៃការសម្អាតផ្ទៃក្នុង (Internal Clearance Procedure) http://www.fao.org/fileadmin/templates/agphome/documents/Pests_Pesticides/Code/E_SS5_pesticide_checklist.pdf<br>• លក្ខណៈវិនិច្ឆ័យដែលបានបញ្ជាក់នៅក្នុងគោលការណ៍ណែនាំពី ESM របស់អង្គការ FAO ដែលស្ថិតនៅក្រោម ESS៥ ត្រូវតែមានបញ្ចូល ឬមានឯកសារយោងនៅក្នុងឯកសារគម្រោង។<br>• លក្ខណៈវិនិច្ឆ័យដែលបានបញ្ជាក់នៅក្នុងគោលការណ៍ណែនាំពី ESM របស់អង្គការ FAO ដែលស្ថិតនៅក្រោម ESS៥ ត្រូវតែមានបញ្ចូល ឬមានឯកសារយោងនៅក្នុងឯកសារគម្រោង។<br>• ប្រសិនបើថ្នាំសម្លាប់សត្វល្អិតដែលមានបរិមាណច្រើន (ច្រើនជាង ១០០០ លីត្រ ឬគីឡូក្រាម) នឹងត្រូវបានផ្គត់ផ្គង់ ឬប្រើប្រាស់ក្នុងអំឡុងពេលអនុវត្តគម្រោងនោះគឺត្រូវតែមានការរៀបចំផែនការគ្រប់គ្រងសត្វល្អិត ក្នុងគោលបំណងបង្ហាញពីរបៀបដែល IPM ត្រូវបានផ្សព្វផ្សាយដើម្បីកាត់បន្ថយការពឹងផ្អែកលើថ្នាំសម្លាប់សត្វល្អិត ហើយវិធានការនានាដែលត្រូវបានយកមកអនុវត្តដើម្បីកាត់បន្ថយហានិភ័យនៃការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត។<br>• វាត្រូវតែមានការបញ្ជាក់ឱ្យច្បាស់ថាបុគ្គលណាខ្លះ នៅក្នុង(កម្រិតប្រតិបត្តិ) ស្ថាប័នពាក់ព័ន្ធ ដែលនឹងទទួលខុសត្រូវចំពោះការរក្សាទុកដាក់ឱ្យបានត្រឹមត្រូវ | គម្រោងនេះនឹងបង្កើតគោលការណ៍ណែនាំ និងការគាំទ្រដល់កសិករក្នុងការកាត់បន្ថយ និងធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ថ្នាំកសិកម្មដែលធ្លាប់បានប្រើពីមុនមក ដោយផ្អែកទៅតាមបទពិសោធន៍នៃការអនុវត្តល្អៗទាំងនៅថ្នាក់អន្តរជាតិ និងក្នុងស្រុក។ គម្រោងនេះនឹងមិនពាក់ព័ន្ធនឹងកិច្ចការលទ្ធកម្ម ឬការផ្គត់ផ្គង់ដោយផ្ទាល់នូវថ្នាំកសិកម្ម ឬថ្នាំគីមីកសិកម្មនោះទេ។ |

| | | | | |
|---|---|---|---|---|
| | | | ការដឹកជញ្ជូន ការចែកចាយ និងការប្រើប្រាស់ផលិតផលខាងលើ ដោយអនុលោមទៅតាមតម្រូវការ។ | |
| ៥.២ | តើគម្រោងនេះនឹងផ្តល់គ្រាប់ពូជ ឬសម្ភារផ្សេងទៀត ដែលបានប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតសម្រាប់ព្យាបាលដែរឬទេ (នៅទីវាល និង/ឬនៅកន្លែងរក្សាទុក)? | ហានិភ័យទាប | **ហានិភ័យមធ្យម**<br>• ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតដែលមានសារធាតុគីមីសម្រាប់ការព្យាបាលគ្រាប់ពូជ ឬការរក្សាទុកនូវផលិតផលដែលបានពីការប្រមូលផលគឺស្ថិតនៅក្រោមនីតិវិធីនៃការបោសសម្អាតផ្ទៃក្នុង(Internal Clearance Procedure) [http://www.fao.org/fileadmin/templates/agphome/documents/Pests_Pesticides/Code/E_SS5_pesticide_checklist.pdf]. លក្ខណៈវិនិច្ឆ័យដែលបានបញ្ជាក់នៅក្នុងគោលការណ៍ណែនាំពី ESM របស់អង្គការ FAO ដែលស្ថិតនៅក្រោម ESS៥ ទាក់ទងនឹងការផ្គត់ផ្គង់ថ្នាំសម្លាប់សត្វល្អិត និងការព្យាបាលគ្រាប់ពូជ គឺត្រូវតែមានបញ្ចូល ឬមានឯកសារយោង នៅក្នុងឯកសារគម្រោង។ | មិនមានសកម្មភាពពាក់ព័ន្ធ |
| ៥.៣ | តើគម្រោងនេះនឹងផ្តល់ធាតុចូលដល់កសិករដោយផ្ទាល់ ឬតាមរយៈគ្រោងការណ៍ប័ណ្ណទូទាត់ (voucher schemes)? | ហានិភ័យទាប | **ហានិភ័យមធ្យម**<br>• គម្រោង FAO នឹងមិនទទួលខុសត្រូវចំពោះការប្រឈមនឹងហានិភ័យនៃថ្នាំសម្លាប់សត្វល្អិតទៅដល់មនុស្ស ឬបរិស្ថានឡើយ។ ប្រភេទ និងបរិមាណថ្នាំសម្លាប់សត្វល្អិត ព្រមទាំងកម្មវិធី និងឧបករណ៍ការពារពាក់ព័ន្ធ ដែលបានផ្តល់ជូនអ្នកប្រើប្រាស់ប័ណ្ណទូទាត់ គឺត្រូវតែអនុលោមទៅតាមលក្ខខណ្ឌដែលមានចែងក្នុង ESS៥ ជានិច្ច ហើយក៏ត្រូវអនុវត្តទៅតាមនីតិវិធីបោសសម្អាតផ្ទៃក្នុងផងដែរ [តំណភ្ជាប់]។ សកម្មភាពទាំងនេះគឺត្រូវតែមានបញ្ចូល ឬមានឯកសារយោង នៅក្នុងឯកសារគម្រោង។<br>• ត្រូវតែផ្តល់អាទិភាពដល់វិធីសាស្ត្រនានាដែលអាចគ្រប់គ្រងសត្វល្អិតប្រកបដោយនិរន្តរភាពដូចជា វិធានការចម្រុះគ្រប់គ្រងដំណាំ (IPM) ការប្រើប្រាស់វិធីសាស្ត្រ | **មិនមានសកម្មភាពពាក់ព័ន្ធ** |

| | | | | |
|---|---|---|---|---|
| | | | គ្រប់គ្រងសត្វល្អិតបែបអេកូឡូស៊ី និងការប្រើប្រាស់ឧបករណ៍គ្រប់គ្រងសត្វល្អិតបែបមេកានិក ឬជីវសាស្ត្រ ដែលទ្រទ្រង់ដល់សារធាតុគីមីសំយោគ។ | |
| ៥.៤ | តើគម្រោងនេះនឹងនាំឱ្យមានការកើនឡើងនូវការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតតាមរយៈការពង្រឹង ឬពង្រីកផលិតកម្មដែរឬទេ? | ហានិភ័យទាប | **ហានិភ័យមធ្យម** លើកទឹកចិត្តដល់ភាគីពាក់ព័ន្ធឱ្យបង្កើតផែនការគ្រប់គ្រងសត្វល្អិត ដើម្បីបង្ហាញពីរបៀបដែល IPM ត្រូវបានផ្សព្វផ្សាយដើម្បីកាត់បន្ថយការពឹងផ្អែកលើថ្នាំសម្លាប់សត្វល្អិតក៏ដូចជាវិធីសាស្ត្រនានាដែលត្រូវបានប្រើដើម្បីកាត់បន្ថយហានិភ័យនៃការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត។ សកម្មភាពនេះគួរតែជាផ្នែកមួយនៃផែនការអនុវត្តគម្រោងប្រកបដោយនិរន្តរភាព សម្រាប់ការពារ ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថាន និងសង្គមផ្សេងទៀតដែលបណ្តាលមកពីការជំរុញផលិតកម្ម។ | គម្រោងនេះនឹងលើកកម្ពស់ការទទួលយក GI, CamGAP, HACCP ព្រមទាំងផលិតកម្ម និងដំណើរការដែលអនុលោមតាម វិញ្ញាបនបត្រសេរីរាង្គ និង IPM។ ដូច្នេះ គម្រោងនេះនឹងបង្កើតគោលការណ៍ណែនាំ និងការគាំទ្រដល់កសិករក្នុងការកាត់បន្ថយ និងធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ថ្នាំកសិកម្មដែលធ្លាប់បានប្រើពីមុនមក ដោយផ្អែកទៅតាមបទពិសោធន៍នៃការអនុវត្តល្អៗទាំងនៅថ្នាក់អន្តរជាតិ និងក្នុងស្រុក។ គម្រោងនេះនឹងមិនពាក់ព័ន្ធនឹងកិច្ចការលទ្ធ |

| | | | | |
|---|---|---|---|---|
| | | | | កម្ម ឬការផ្គត់ផ្គង់ដោយផ្ទាល់នូវថ្នាំកសិកម្ម ឬថ្នាំគីមីកសិកម្មនោះទេ។ |
| ៥.៥ | តើគម្រោងនេះនឹងមានការគ្រប់គ្រង ឬបោះចោលកាកសំណល់ពីថ្នាំសម្លាប់សត្វល្អិត ថ្នាំសម្លាប់សត្វល្អិតដែលឈប់ប្រើប្រាស់ហើយ ឬថ្នាំសម្លាប់សត្វល្អិតដែលមានផ្ទុកនូវសារធាតុសំណល់ដែលធ្វើឱ្យមានភាពកខ្វក់ដែរឬទេ ? | ហានិភ័យទាប | **ហានិភ័យខ្ពស់**<br>ទាមទារឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ។<br>សូមទំនាក់ទំនងអង្គភាព ESM សម្រាប់ការណែនាំបន្ថែម។ | **មិនមានសកម្មភាពពាក់ព័ន្ធ** |

## ផ្នែកសុវត្ថិភាពទី ៦ ការតាំងទីលំនៅថ្មី និងការផ្លាស់ទីលំនៅដោយអចេតនា

| | | គ្មាន | មាន | គ្មាន |
|---|---|---|---|---|
| ៦.១ | តើ ការដេកយកចេញ* ធ្វើឡើងដោយស្ម័គ្រចិត្តដែរឬទេ ?<br><br>*ការដេកយកចេញជាបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ចំពោះមនុស្សចេញពីផ្ទះរបស់គាត់ ឬ | មិនអាចបន្តបានទេ | **ហានិភ័យខ្ពស់**<br>ទាមទារឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ។<br>សូមទំនាក់ទំនងអង្គភាព ESM សម្រាប់ការណែនាំបន្ថែម។ | គម្រោងនេះនឹងមិនអនុញ្ញាតឱ្យមានការតាំងទីលំនៅថ្មី ឬការផ្លាស់ទីលំនៅដោយអចេតនានោះទេ |

| | | | | |
|---|---|---|---|---|
| | មធ្យោបាយក្នុងការចិញ្ចឹមជីវិត ឬរឹតបន្តឹងលទ្ធភាពនៃមធ្យោបាយចិញ្ចឹមជីវិតរបស់គាត់ | | | |

## ផ្នែកសុវត្ថិភាពទី ៧ ការងារសមរម្យ

| | | គ្មាន | មាន | មតិយោបល់ |
|---|---|---|---|---|
| ៧.១ | តើគម្រោងនេះនឹងមានការបញ្ឈប់ការងារដែរឬទេ? (ឧ. បណ្តាលមកពីការរៀបចំហេដ្ឋារចនាសម្ព័ន្ធឡើងវិញតាមវិស័យ ឬការផ្លាស់ប្តូរមុខរបរ) | ហានិភ័យទាប | **ហានិភ័យខ្ពស់**<br>ទាមទារឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ។<br>សូមទំនាក់ទំនងអង្គភាព ESM សម្រាប់ការណែនាំបន្ថែម។ | បើទោះបីជាមិនមានផលប៉ះពាល់អវិជ្ជមានណាមួយត្រូវបានព្យាករណ៍ទុកក៏ដោយ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ នៅតែត្រូវបានអនុវត្តដើម្បីធានាថាមិនមានផលប៉ះពាល់អវិជ្ជមានប្រាកដមែន។ |
| ៧.២ | គម្រោងនេះនឹងប្រតិបត្តិការនៅក្នុងវិស័យ ឬច្រវ៉ាក់តម្លៃដែលគ្របដណ្តប់ដោយអ្នកផលិតសម្រាប់តែតម្រូវការប្រចាំថ្ងៃ ឬអ្នកធ្វើកសិកម្ម | ហានិភ័យទាប | **ហានិភ័យមធ្យម**<br>ចាត់វិធានការដើម្បីប្រមើលមើលហានិភ័យដែលអាចបណ្តាលឱ្យភាពក្រីក្រនៅតែបន្តកើតមាន និងវិសមភាពនៅក្នុងសង្គមពាក់ព័ន្ធនឹងវិស័យកសិកម្ម និងប្រព័ន្ធស្បៀងអាហារដែលមិនមាននិរន្តរភាព។ ការងារសមរម្យ និងការងារដែលមានផលិតភាពខ្ពស់ គួរតែត្រូវបានចាត់ទុកជាអាទិភាព ឬជម្រើសផ្សេងទៀត គម្រោងគួរតែបង្កើត | បើទោះបីជាមិនមានការគ្រោងទុកក៏ដោយ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ នៅតែត្រូវបានអនុវត្តដើម្បីធានាថា |

| | | | | |
|---|---|---|---|---|
| | ក្រៅផ្លូវការដែលងាយនឹងរងគ្រោះផ្សេងទៀត ហើយជាទូទៅត្រូវបានកំណត់ថាជាលក្ខណៈ «ភាពក្រីក្រក្នុងការងារ» កម្រិតខ្ពស់ដែរឬទេ? | | ឡើងនូវការរួមបញ្ចូលគ្នារវាងការងារជាក់លាក់ណាមួយ ជាមួយនឹងកម្មវិធីការពារសង្គម ឧ. ការអនុគ្រោះឱ្យមានការប្រើប្រាស់គម្រោងគាំពារសង្គម ឬក្នុងទម្រង់ជាការធានារ៉ាប់រងសង្គម ជាដើម។ វិធានការ និងយន្តការជាក់លាក់មួយចំនួន គួរតែត្រូវបានណែនាំ ដើម្បីផ្តល់សិទ្ធិអំណាចទៅកាន់ក្រុមមនុស្ស ជាពិសេសគឺកម្មករនៅតាមទីជនបទដែលស្ថិតនៅក្នុងប្រភេទងាយរងគ្រោះ ឬមិនសូវទទួលបានផលប្រយោជន៍ ដូចជាអ្នកផលិតខ្នាតតូច ការប្រកបមុខរបរជាលក្ខណៈគ្រួសារ ការធ្វើកសិកម្មសម្រាប់ផ្គត់ផ្គង់គ្រួសារ កម្មករទទួលបានប្រាក់ឈ្នួលក្រៅប្រព័ន្ធពីវិស័យកសិកម្ម ដោយយកចិត្តទុកដាក់ជាពិសេសចំពោះស្ត្រី និងយុវជនដែលភាគច្រើនត្រូវបានរកឃើញថាកំពុងស្ថិតនៅក្នុងស្ថានភាពការងារដូចបានរៀបរាប់ខាងលើនេះ។ ការវិភាគច្រវ៉ាក់តម្លៃសង្គមតាមអាយុ និងយេនឌ័រ ឬការវាយតម្លៃពីជីវភាព/ការងារ គឺជាតម្រូវការចាំបាច់សម្រាប់គម្រោងធំៗ។ | មិនមានហានិភ័យណាមួយនោះទេ ហើយប្រសិនបើមាននោះយុទ្ធសាស្ត្រសមស្របនឹងត្រូវបានស្នើឡើង។ |
| ៧.៣ | តើគម្រោងនេះនឹងដំណើរការនៅក្នុងស្ថានភាពដែលយុវជនភាគច្រើនធ្វើការនៅក្នុងមុខរបររបស់គ្រួសារដោយមិនទទួលបានប្រាក់ខែ ខ្វះលទ្ធភាពក្នុងការទទួលបានការងារសមរម្យ ហើយមានកំណើននៃការបោះបង់ចោលវិ | ហានិភ័យទាប | **ហានិភ័យមធ្យម**<br>ចាត់វិធានការដើម្បីប្រមើលមើលហានិភ័យដែលអាចកើតមានលើវិស័យកសិកម្ម និងប្រព័ន្ធស្បៀងអាហារដែលមិនមាននិរន្តរភាព ដោយរួមបញ្ចូលនូវវិធានការជាក់លាក់ ដើម្បីគាំទ្រដល់ការពង្រឹងសមត្ថភាពយុវជន និងការងារក្នុងវិស័យកសិកម្ម។ ការវាយតម្លៃការងារ/ជីវភាពរស់នៅរបស់យុវជន គឺជាតម្រូវការចាំបាច់។<br>វិធានការបំពេញបន្ថែមគួរតែត្រូវបានរួមបញ្ចូលក្នុងគោលបំណងបណ្តុះបណ្តាលយុវជន ភ្ជាប់ទំនាក់ទំនងពួកគាត់ និងបណ្តាញរបស់គាត់ឱ្យចូលរួមនៅក្នុងច្រវ៉ាក់តម្លៃ សម្របសម្រួលឱ្យគាត់ទទួលបាននូវធនធានសំខាន់ៗ ឥណទាន ទីផ្សារ និងជំរុញការ | សកម្មភាពគម្រោង នឹងផ្តោតលើការភ្ជាប់ទំនាក់ទំនងជាមួយសហគមន៍កសិកម្មដែលមានស្រាប់ ហើយនឹងគាំទ្រដល់ការអនុម័តបទដ្ឋាននិរន្តរភាពទីផ្សារដែលលើកកម្ពស់ការងារដោយយុត្តិធម៌ |

| | | | | |
|---|---|---|---|---|
| | ស័យកសិកម្ម និងការចាកចេញពីតំបន់ជនបទដែរឬទេ? | | ផ្តល់សេវាអភិវឌ្ឍន៍អាជីវកម្មដែលមានភាពងាយស្រួលសម្រាប់យុវជន។ | |
| ៧.៤ | តើគម្រោងនេះនឹងដំណើរការនៅក្នុងស្ថានភាពដែលមានវិសមភាពយេនឌ័រខ្លាំងនៅក្នុងទីផ្សារការងារដែរឬទេ? (ឧ. ជាកន្លែងដែលស្ត្រីភាគច្រើនមានទំនោរធ្វើការនៅក្នុងគ្រួសារដោយមិនទទួលបានប្រាក់ខែ ធ្វើកសិកម្មសម្រាប់ផ្គត់ផ្គង់តែក្នុងគ្រួសារ មានជំនាញ និងគុណវុឌ្ឍិទាប ផលិតភាព និងប្រាក់ឈ្នួលទាបមិនសូវបានបញ្ចេញមតិនៅក្នុងនាមជាអ្នកផលិត និងកម្មករនៅក្នុងស្ថាប័នកិច្ចសន្យាមិនផ្លូវការ និងមានអត្រាមិនផ្លូវការខ្ពស់។ | ហានិភ័យទាប | **ហានិភ័យមធ្យម**<br>ចាត់វិធានការដើម្បីប្រមើលមើលហានិភ័យដែលអាចកើតមានចំពោះវិស័យកសិកម្ម និងប្រព័ន្ធស្បៀងអាហារដែលមិនមាននិរន្តរភាពក្នុងសង្គម ដោយរួមបញ្ចូលវិធានការជាក់លាក់ដើម្បីកាត់បន្ថយវិសមភាពយេនឌ័រ និងលើកកម្ពស់ការពង្រឹងសិទ្ធិអំណាចសង្គម និងសេដ្ឋកិច្ចរបស់ស្ត្រីនៅតាមជនបទ។ ការវិភាគច្រាំក់តម្លៃសង្គមជាក់លាក់ ឬការវាយតម្លៃជីវភាពរស់នៅ/ការងារ គឺត្រូវការជាចាំបាច់សម្រាប់គម្រោងខ្នាតធំ។ ការសម្របសម្រួលគួរតែត្រូវបានផ្តល់ជូនសម្រាប់ស្ត្រីគ្រប់វ័យក្នុងការទទួលបានធនធានសំខាន់! (រួមទាំងដីធ្លី) ឥណទាន ទីផ្សារ និងបណ្តាញទីផ្សារ ការអប់រំ និងវគ្គបណ្តុះបណ្តាលជំនាញ បច្ចេកវិទ្យា សកម្មភាពសមូហភាព ឬការផ្តល់ប្រឹក្សាជាដើម។<br>បទប្បញ្ញត្តិសម្រាប់ការការពារមាតុភាព រួមទាំងកន្លែងថែទាំកុមារគួរតែត្រូវបានចាត់ទុកជាអាទិភាព ដើម្បីលើកទឹកចិត្តដល់ការចូលរួមរបស់ស្ត្រី និងប្រមើលមើលពីផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានលើកម្លាំងពលកម្មកុមារ កើនឡើងនៃបន្ទុកការងារសម្រាប់ស្ត្រី និងហានិភ័យទាក់ទងនឹងសុខភាពលើស្ត្រីមានផ្ទៃពោះ និងស្ត្រីបំបៅដោះកូន។ | វាមានហានិភ័យទាប ប៉ុន្តែ ជាផ្នែកមួយនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ការវិភាគយេនឌ័រនៃគម្រោងនឹងត្រូវបានធ្វើឡើង ហើយផែនការសកម្មភាពយេនឌ័រនឹងត្រូវបានរៀបចំ ក្នុងដំណាក់កាលអភិវឌ្ឍគម្រោង។ |

| | | | | |
|---|---|---|---|---|
| ៧.៥ | តើគម្រោងនេះនឹងដំណើរការនៅក្នុងតំបន់ ឬប្រវ៉ាក់តម្លៃដែលមានវត្តមានកម្មករចំណាកស្រុក ឬអាចនឹងមានសក្តានុពលក្នុងការទាក់ទាញកម្មការចំណាកស្រុកដែរឬទេ? | ហានិភ័យទាប | **ហានិភ័យមធ្យម**<br>ចាត់វិធានការដើម្បីប្រមើលមើលការរើសអើងដែលអាចកើតមានប្រឆាំងនឹងកម្មករចំណាកស្រុក និងដើម្បីប្រាកដថាសិទ្ធិរបស់គាត់គឺទទួលបាននូវការការពារត្រឹមត្រូវដោយមានការយកចិត្តទុកដាក់ជាពិសេសលើក្រុមមនុស្សផ្សេងៗគ្នា ដូចជាយុវជន ស្ត្រី និងបុរស។ | មិនមានសកម្មភាពពាក់ព័ន្ធ |

| | | គ្មាន | មាន | មតិយោបល់ |
|---|---|---|---|---|
| ៧.៦ | តើគម្រោងនេះនឹងផ្តល់ការងារដល់បុគ្គលិកដោយផ្ទាល់ដែរឬទេ? | ហានិភ័យទាប | **ហានិភ័យមធ្យម**<br>គម្រោង FAO នឹងធានាដល់សិទ្ធិរបស់និយោជិតតាមបទដ្ឋាន UN/FAO ដោយផ្អែកទៅតាមព័ត៌មានស្តីពីសិទ្ធិកម្មករ ការទូទាត់ប្រាក់ទៀងទាត់។ល។ ការសម្រេចចិត្តពាក់ព័ន្ធនឹងការជ្រើសរើសបុគ្គលិកគម្រោង គឺត្រូវអនុវត្តទៅតាមបទដ្ឋានរបស់អង្គការសហប្រជាជាតិ (UN) ដូច្នេះហើយវានឹងមិនមានការជ្រើសរើសដោយផ្អែកតែទៅលើចរិតលក្ខណៈរបស់បុគ្គលដែលមិនទាក់ទងនឹងតម្រូវការការងារនោះទេ។ ការជ្រើសរើសបុគ្គលិកគម្រោងនឹងផ្អែកលើគោលការណ៍ការទទួលបានឱកាសស្មើគ្នា និងយុត្តិធម៌ ហើយវានឹងមិនមានការរើសអើងចំពោះទិដ្ឋភាពណាមួយនៃទំនាក់ទំនងការងារនោះទេ ដូចជាការជ្រើសរើសបុគ្គលិក ការផ្តល់សំណង (រួមទាំងប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ) ស្ថានភាពការងារ និងលក្ខខណ្ឌការងារ ការទទួលបានវគ្គបណ្តុះបណ្តាល ការចាត់តាំងការងារ ការឡើងដំណែង ការបញ្ចប់ការងារ ឬការចូលនិវត្តន៍។ល។ | គម្រោងនេះនឹងមិនមានការផ្តល់ឱកាសការងារដល់បុគ្គលិកណាម្នាក់ដោយផ្ទាល់ឡើយ។ ឱកាសការងារទំនងជានឹងទទួលបានក្នុងលក្ខណៈជាអនុផលរបស់គម្រោង ប៉ុន្តែមិនមែនទទួលបានដោយផ្ទាល់ពីគម្រោងនោះទេ។ |

| | | | | |
|---|---|---|---|---|
| ៧.៧ | តើគម្រោងនេះពាក់ព័ន្ធនឹងការចុះកិច្ចសន្យាបន្តដែរឬទេ? | ហានិភ័យទាប | **ហានិភ័យមធ្យម**<br>ចាត់វិធានការដើម្បីប្រមើលមើលហានិភ័យ ដែលអាចកើតមាននៃវិសមភាព និងការរំលោភបំពានសិទ្ធិការងារដោយដាក់ចេញនូវវិធានការបំពេញបន្ថែម។ គម្រោងរបស់របស់អង្គការ FAO ដែលពាក់ព័ន្ធនឹងការចុះកិច្ចសន្យាបន្ត គួរតែផ្សព្វផ្សាយតាមលទ្ធភាពដែលអាចធ្វើទៅបាន ផ្តល់កិច្ចសន្យាបន្តដល់សហគ្រិនក្នុងស្រុក ជាពិសេសទៅដល់ស្ត្រី និងយុវជននៅតាមទីជនបទ ដើម្បីបង្កើនឱកាសការងារដែលមានស្ថានភាពសមរម្យ។ ក្នុងនោះដែរ អង្គការ FAO គួរតែត្រួតពិនិត្យ និងបន្តផ្តល់ការគាំទ្រដល់អ្នកម៉ៅការ ដើម្បីបំពេញតាមបទដ្ឋាននៃទម្រង់ និងគុណភាពដោយគិតគូរដល់បទដ្ឋានសង្គម និងការងារទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ។ | មិនមានសកម្មភាពពាក់ព័ន្ធ |

Food and Agriculture Organization of the United Nations

# ឧបសម្ព័ន្ធទី ៤៖ យន្តការពិនិត្យលើបណ្តឹងតវ៉ារបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិប្រចាំនៅកម្ពុជា

## យន្តការការពិនិត្យលើបណ្តឹងតវ៉ា (GRM) របស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ កម្ពុជា – គោលការណ៍ណែនាំ

កំណត់សម្គាល់នេះត្រូវបានបង្កើតឡើងដោយផ្អែកលើគោលការណ៍ណែនាំរបស់អង្គការស្បៀង និងកសិកម្ម នៃសហប្រជាជាតិ នៅកម្រិតសាជីវកម្ម រួមមាន គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងបរិស្ថាន និងសង្គម ការត្រួតពិនិត្យដោយអនុលោមទៅតាមបណ្តឹងតវ៉ាដែលទាក់ទងនឹងគោលការណ៍ណែនាំស្តីពីបទដ្ឋានបរិស្ថាន និងសង្គម ក៏ដូចជាការណែនាំរបស់ ស្តីពីគណនេយ្យភាពចំពោះប្រជាជនដែលរងផលប៉ះពាល់ (ជាពិសេស គឺការប្តេជ្ញាចិត្តនៅចំណុចទី៣ ស្តីពី «មតិយោបល់ និងពាក្យបណ្តឹងតវ៉ា»)

### I. និយមន័យ

**១. បណ្តឹងតវ៉ា៖** គឺជាកង្វល់ទាំងឡាយណាដែលត្រូវបានលើកឡើងដោយអ្នកទទួលផលប្រយោជន៍ទៅកាន់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ តាមរយៈបណ្តាញដែលបានកំណត់ ទាក់ទងនឹងកម្មវិធី ឬគម្រោងរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ ដូចមានចែងក្នុងការប្តេជ្ញាចិត្តចំណុចទី៣ ពាក់ព័ន្ធ នឹងគណនេយ្យភាពរបស់អង្គការអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ ចំពោះប្រជាជនដែលរងផលប៉ះពាល់ (AAP) ក៏ដូចជាការចោទប្រកាន់ និង/ឬការបំពានដែលអាចមានទាក់ទងនឹងបទដ្ឋានសង្គម និងបរិស្ថាន (ESS) និងក្រមសីលធម៌ និងបទដ្ឋានអន្តរជាតិសម្រាប់ការអនុវត្តវិជ្ជាជីវៈនៃសវនកម្មផ្ទៃក្នុង ដែលត្រូវបានបោះពុម្ពដោយវិទ្យាស្ថានសវនករផ្ទៃក្នុង (IIA)។

**២. ដើមបណ្តឹងតវ៉ា៖** ភាគី បុគ្គល ឬអង្គភាពដែលបានលើកឡើងពីកង្វល់/បញ្ជូនបណ្តឹងតវ៉ាទៅកាន់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ។

**៣. កម្មវិធីរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ៖** សកម្មភាពគម្រោងដែលមានលក្ខណៈជាជំនួយបច្ចេកទេស ឬជំនួយសង្គ្រោះបន្ទាន់ណាមួយដែលត្រូវបានអនុវត្តដោយផ្ទាល់នៅក្នុងប្រទេសកម្ពុជាដោយអង្គការ ឬដៃគូអនុវត្តក្នុងនាមអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ ឬជាផ្នែកមួយនៃគម្រោងដែលសហការគ្នាជាមួយអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ។

៤. អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិប្តេជ្ញាថារាល់កម្មវិធីរបស់ខ្លួននឹងត្រូវបានអនុវត្តដោយស្របតាមគោលនយោបាយរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ ស្តីពីការក្លែងបន្លំ និងសកម្មភាពពុករលួយផ្សេងៗ គោលនយោបាយដាក់ទណ្ឌកម្មឈ្មួញតូចតាច (សារាចរណែនាំ ២០១៤/២៧) គោលនយោបាយការពារអ្នករាយការណ៍ពីសកម្មភាពមិនត្រឹមត្រូវរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (សារាចរណែនាំ ២០១១/០៥) និងការការពារពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ ព្រមទាំងសកម្មភាពផ្សេងទៀតដូចមានរៀបរាប់នៅទីនេះ៖ http://intranet.fao.org/ departments/oig/investigations/ រួមទាំងការិយាល័យអធិការកិច្ច

(OIG), គោលនយោបាយបទដ្ឋានបរិស្ថាន និងសង្គម របស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ ព្រមទាំងការប្តេជ្ញាចិត្តពាក់ព័ន្ធនឹងគណនេយ្យភាពចំពោះប្រជាជនដែលរងផលប៉ះពាល់ ។

ការិយាល័យតំណាងអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ នៅកម្ពុជា បានបង្កើតយន្តការ ពិនិត្យលើបណ្តឹងតវ៉ា (GRM) នេះ ដើម្បីផ្តល់ឱ្យអ្នកទទួលផលពីកម្មវិធីរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ នូវយន្តការប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងទាន់ពេលវេលា សម្រាប់ការផ្តល់មតិកែលម្អ និងបង្ហាញពីកង្វល់របស់គាត់។ វាក៏នឹងផ្តល់ជូនគាត់នូវមធ្យោបាយមួយដើម្បីដោះស្រាយ កង្វល់ទាំងនេះ និងអាចជូនដំណឹងដល់ពួកគាត់ពីសកម្មភាពដែលកំពុងតែធ្វើឡើងដើម្បីដោះស្រាយបណ្តឹងតវ៉ារបស់គាត់ក្នុងអំឡុងពេលនៃការពិនិត្យបណ្តឹងតវ៉ានេះ។ យន្តការពិនិត្យឡើងវិញនូវបណ្តឹងតវ៉ាបានកំណត់ពីនីតិវិធីសម្រាប់ការទទួល និងដំណើរការបណ្តឹងតវ៉ា និងកង្វល់ទាំងនេះ ក្នុងគោលបំណង បង្កើតនូវអនុសាសន៍ និងចាត់វិធានការដែលសមស្របសម្រាប់ដោះស្រាយ។

## II វិសាលភាព

គោលការណ៍ណែនាំរបស់យន្តការពិនិត្យឡើងវិញនូវបណ្តឹងតវ៉ា នឹងត្រូវអនុវត្តចំពោះការិយាល័យប្រចាំប្រទេសដើម្បីពិនិត្យឡើងវិញនូវបណ្តឹងតវ៉ា និងកង្វល់នានាដែលពាក់ព័ន្ធនឹងការប្តេជ្ញាចិត្តរបស់បទដ្ឋានបរិស្ថាន និងសង្គម និងគណនេយ្យភាពចំពោះប្រជាជនដែលរងផលប៉ះពាល់ របស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ ហើយវាមានគោលបំណងកំណត់នូវសកម្មភាពសម្រាប់ការដោះស្រាយបញ្ហានៅកម្រិតកម្មវិធី ឬគម្រោងដែលពាក់ព័ន្ធ។ ពាក្យបណ្តឹងតវ៉ាពីការប្រព្រឹត្តខុស ឬអំពើខុសឆ្គង និងអាកប្បកិរិយាគ្មានសីលធម៌ផ្សេងទៀតដែលត្រូវបានលើកឡើងដោយអ្នកទទួលផល និងភាគីពាក់ព័ន្ធនឹងកម្មវិធីរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិប្រចាំនៅកម្ពុជា គួរតែត្រូវបានបញ្ជូនទៅអង្គភាពដែលសមស្របសម្រាប់ការដោះស្រាយ ដូចមានចែងក្នុងគោលនយោបាយពាក់ព័ន្ធ។

យន្តការពិនិត្យឡើងវិញនូវបណ្តឹងតវ៉ាដែលបានស្នើឡើងនឹងត្រូវអនុវត្តចំពោះគ្រប់គម្រោង និងកម្មវិធីទាំងអស់ដែលត្រូវបានអនុវត្តដោយផ្ទាល់ដោយអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ។ យន្តការការពិនិត្យឡើងវិញលើបណ្តឹងតវ៉ា (GRM) មានគោលបំណងដោះស្រាយការបំពានលើបទដ្ឋានបរិស្ថាន និងសង្គម (ESS)។ យន្តការពិនិត្យឡើងវិញនូវបណ្តឹងតវ៉ាមិនមានគោលដៅក្នុងការដោះស្រាយបណ្តឹងតវ៉ាទាក់ទងនឹងការរំលោភបំពានផ្លូវភេទ ទំនាស់ផលប្រយោជន៍ការក្លែងបន្លំ អំពើពុករលួយ។ល។ ការពិភាក្សានាពេលថ្មីៗនេះរវាងការិយាល័យអធិការកិច្ច (OIG) ការិយាល័យក្រមសីលធម៌ ផ្នែកសង្គ្រោះបន្ទាន់ និងភាពធន់ (PSE) អង្គភាពគ្រប់គ្រងបរិស្ថាន និងសង្គម (ESMU) និងកម្មវិធីគាំទ្រ និងនាយកដ្ឋានកិច្ចសហប្រតិបត្តិការបច្ចេកទេស (PS) លើកឡើងថា ជំនួសឱ្យយន្តការដាច់ដោយឡែកសម្រាប់ប្រភេទផ្សេងគ្នានៃបណ្តឹងតវ៉ា វាគួរតែមានចំណុចទំនាក់ទំនងរួមមួយ ដែលអាចបែងចែក និងដឹកនាំរាល់បណ្តឹងតវ៉ាដែលត្រូវបានធ្វើឡើងចំពោះកម្មវិធីរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ។ ពាក្យបណ្តឹងតវ៉ាទាក់ទងនឹងការិយាល័យផ្សេងទៀតនឹងត្រូវបានបញ្ជូនទៅការិយាល័យដែលសមស្រប (ឧ. ការិយាល័យអធិការកិច្ច ឬការិយាល័យក្រមសីលធម៌) ដើម្បីដោះស្រាយ។ ការចោទប្រកាន់ពីការក្លែងបន្លំ អំពើពុករលួយ ឬការប្រព្រឹត្តខុសផ្សេងៗដោយបុគ្គលិករបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ ឬដោយភាគីទីបីគួរតែត្រូវបានបញ្ជូនដោយផ្ទាល់ទៅកាន់ការិយាល័យអធិការកិច្ច របស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ សម្រាប់ការស៊ើបអង្កេតប្រសិនបើចាំ បាច់។ ប្រសិនបើបណ្តឹងតវ៉ាបង្កើតឱ្យមានការសង្ស័យដ៏សមហេតុផល ឬបង្ហាញពីការក្លែងបន្លំ អំពើពុករលួយ ការបង្ខិតបង្ខំ ឬផ្សំគំនិត ឬការប្រើប្រាស់ធនធានរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិដោយមិនសមស្រប នោះត្រូវតែមានការរាយការណ៍ភ្លាមៗទៅការិយាល័យអធិការកិច្ចដោយយោងតាមច្បាប់ និងបទប្បញ្ញត្តិរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ ។

## III. ការពិនិត្យបណ្តឹងតវ៉ា និងរចនាសម្ព័ន្ធយន្តការ

៥. ផែនទីពេញលេញនៃយន្តការពិនិត្យឡើងវិញនូវបណ្តឹងតវ៉ា ដែលបញ្ជាក់ពីទំនួលខុសត្រូវ និងលំហូរនីតិវិធីត្រូវបានរៀបរាប់លម្អិតនៅក្នុងឧបសម្ព័ន្ធ ១។

សមាសភាពសំខាន់នៃរចនាសម្ព័ន្ធរបស់យន្តការពិនិត្យឡើងវិញនូវបណ្តឹងតវ៉ា គឺមានដូចខាងក្រោម៖

i. **មន្ត្រីត្រួតពិនិត្យបណ្តឹងតវ៉ា** (GRO)៖ បុគ្គលិកដែលស្ទាត់ជំនាញភាសាខ្មែរ ហើយមិនមានទំនាក់ទំនងក្នុងការងារគ្រប់គ្រងគម្រោង ត្រូវបានតែងតាំងជាជនបង្គោលនៅការិយាល័យអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ ដើម្បីទទួល និងដំណើរការបណ្តឹងតវ៉ា និងកង្វល់របស់ភាគីពាក់ព័ន្ធ។ អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិប្រចាំនៅកម្ពុជា គួរតែតែងតាំងអ្នកជំនួស មន្ត្រីត្រួតពិនិត្យបណ្តឹងតវ៉ា (RGO) ដែលអាចដោះស្រាយនូវបណ្តឹងតវ៉ា និងកង្វល់ក្នុងករណីដែល RGO អវត្តមាន។ បុគ្គលិកទាំងនេះ ត្រូវទទួល ចុះឈ្មោះ និងដាក់ពាក្យបណ្តឹងតវ៉ា ហើយជូនដំណឹងទៅដល់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិប្រចាំនៅកម្ពុជា ដើម្បីពិភាក្សាអំពីសិទ្ធិទទួលបាន ណែនាំនូវសកម្មភាពសម្រាប់តាមដានបន្ត និងផ្តល់អនុសាសន៍ទាក់ទងនឹងការបង្កើតសមាសភាពគណៈកម្មាធិការពិនិត្យបណ្តឹងតវ៉ាក្នុងករណីចាំបាច់។ មន្ត្រីត្រួតពិនិត្យបណ្តឹងតវ៉ា មានទំនួលខុសត្រូវក្នុងការពិនិត្យ និងកត់ត្រាដំណើរការដោះស្រាយពាក្យបណ្តឹងតវ៉ាពីដើមដល់ចប់ ដោយធានាថាបានអនុលោមតាមគោលការណ៍ណែនាំទាំងនេះ។

ii. **មន្ត្រីផ្ទៀងផ្ទាត់បណ្តឹងតវ៉ា** (GVO)៖ បុគ្គលិករបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិដែលត្រូវបានចាត់តាំងឱ្យកត់ត្រា និងធ្វើការផ្ទៀតផ្ទាត់ ត្រូវអនុវត្តតាមវិធីសាស្ត្រដែលអនុម័តដោយគណកម្មការពិនិត្យបណ្តឹងតវ៉ា (GRC)។

## IV. ការធានានូវការយល់ដឹងអំពីយន្តការ

៦. កម្មវិធី និងគម្រោងរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ ត្រូវបានទាមទារឱ្យមានការផ្សព្វផ្សាយពីយន្តការពិនិត្យឡើងវិញនូវបណ្តឹងតវ៉ា នៅកម្រិតមូលដ្ឋាន។ ដើម្បីធានាថាភាគីពាក់ព័ន្ធបានដឹងអំពីយន្តការពិនិត្យឡើងវិញនូវបណ្តឹងតវ៉ា វិធានការខាងក្រោមនេះនឹងត្រូវបានដាក់ឱ្យដំណើរការក្នុងអំឡុងពេលអនុវត្ត គម្រោង៖

i. អ្នកទទួលផលនឹងត្រូវបានជូនដំណឹងអំពីយន្តការទាំងនេះដោយបុគ្គលិកគម្រោង ក៏ដូចជាដៃគូអនុវត្ត និងអ្នកផ្តល់សេវា ដោយមានការចូលរួមពីអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ ក្នុងអំឡុងពេលជ្រើសរើសអ្នកទទួលផល ដំណើរការចែកចាយ និងការត្រួតពិនិត្យក្រោយការចែកចាយ។

ii. ដៃគូអនុវត្ត និងអ្នកផ្តល់សេវាដែលពាក់ព័ន្ធនឹងការអនុវត្តគម្រោងរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ នឹងត្រូវតម្រូវឱ្យមានការយល់ដឹងអំពីយន្តការនានា និងទាមទារឱ្យលើកកម្ពស់ការយល់ដឹងអំពីយន្តការពិនិត្យឡើងវិញនូវបណ្តឹងតវ៉ា ក្នុងចំណោមអ្នកទទួលផល ដែលជាផ្នែកមួយនៃកិច្ចសន្យារបស់គេជាមួយនឹងអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ។

iii. បុគ្គលិកអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិណាក៏ដោយ ដែលត្រូវបានទាក់ទងសម្រាប់ការដាក់បណ្តឹងតវ៉ា ឬកង្វល់នានា គួរតែបញ្ជូនដើមបណ្តឹងតវ៉ាទៅកាន់បណ្តាញដែលបានកំណត់ សម្រាប់ការបញ្ជូនបណ្តឹងតវ៉ា (សូមមើលផ្នែកទី៥ ខាងក្រោម)។

## V. ដំណើរការត្រួតពិនិត្យបណ្តឹងតវ៉ា

### ការទំនាក់ទំនងបណ្តឹងតវ៉ា

៧. បុគ្គល ក្រុម ឬអ្នកតំណាងរបស់បុគ្គល ឬក្រុមណាមួយ ដែលចូលរួមដោយផ្ទាល់ ឬរងផលប៉ះពាល់ដោយសកម្មភាពរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិប្រចាំនៅកម្ពុជា អាចដាក់ពាក្យប្តឹងតវ៉ាបាន។ បណ្តឹងតវ៉ា អាចត្រូវបានទទួលដោយការិយាល័យរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិជាលាយលក្ខណ៍អក្សរ ដោយប្រើប្រាស់ទម្រង់ដែលបានផ្តល់ជូនក្នុងឧបសម្ព័ន្ធ ២ តាមរយៈបណ្តាញផ្លូវការមួយចំនួនដូចខាងក្រោម៖

- តាមរយៈអ៊ីម៉េលទៅកាន់៖ FAO-KH@fao.org, ដោយដាក់ចំណងជើងថា "បណ្តឹងតវ៉ា លេខ៖ XXXX"។
- តាមរយៈការទាក់ទងតាមទូរស័ព្ទ(ឬផ្ញើសារ) ទៅកាន់លេខទូរស័ព្ទ (ទូរស័ព្ទនេះគឺត្រូវបានគ្រប់គ្រង និងត្រួតពិនិត្យដោយមន្ត្រីត្រួតពិនិត្យបណ្តឹងតវ៉ា)
- តាមរយៈកម្មវិធីផ្ញើសារ៖

  ក. តេឡេក្រាម

  ខ. WhatsApp

  គ. វេទិកាផ្ញើសារស្រដៀងគ្នាផ្សេងទៀតដែលពាក្យបណ្តឹងតវ៉ាអាចទទួលជាលាយលក្ខណ៍អក្សរបាន។

ប្រសិនបើអ្នកទទួលផលពីកម្មវិធី ឬភាគីពាក់ព័ន្ធមិនអាចប្រើប្រាស់បច្ចេកវិទ្យាដូចរៀបរាប់ខាងលើបាន ដោយសារតែមិនមានសមត្ថភាពក្នុងការសរសេរ ឬប្រើប្រាស់បច្ចេកវិទ្យា ពួកគេអាចស្វែងរកជំនួយពីមន្ត្រីត្រួតពិនិត្យបណ្តឹងតវ៉ា ក្នុងការបំពេញទម្រង់បែបបទបណ្តឹងតវ៉ា ហើយបន្ទាប់មកបញ្ជូនបណ្តឹងតវ៉ានោះទៅបណ្តាញមួយក្នុងចំណោមបណ្តាញដែលបានរៀបរាប់ខាងលើ។

៨. ក្នុងករណីដែលសមភាគីរាជរដ្ឋាភិបាល ឬដៃគូ បានពាំនាំនូវក្តីកង្វល់របស់អ្នកទទួលផលទៅកាន់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ នោះមន្ត្រីត្រួតពិនិត្យបណ្តឹងតវ៉ានឹងតាមដានជាមួយអ្នកទទួលផលពាក់ព័ន្ធ ហើយនៅពេលសមស្របណាមួយ គាត់នឹងលើកទឹកចិត្តឱ្យមានការដាក់បញ្ជូនបណ្តឹងតវ៉ាទៅកាន់បណ្តាញនានាដែលបានកំណត់។

### ការចុះឈ្មោះបណ្តឹងតវ៉ា

៩. នៅពេលដែលទទួលបានបណ្តឹងតវ៉ា មន្ត្រីត្រួតពិនិត្យបណ្តឹងតវ៉ា នឹងបង្កើតលេខចូលមួយនៅក្នុងសៀវភៅចុះលេខចូលបណ្តឹងតវ៉ា។ រាល់បណ្តឹងតវ៉ាដែលស្ថិតក្នុងវិសាលភាពនៃយន្តការ ហើយមិនត្រូវបានបញ្ជូនទៅការិយាល័យផ្សេង មន្ត្រីត្រួតពិនិត្យបណ្តឹងតវ៉ា នឹងជូនដំណឹងដល់ការិយាល័យអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិប្រចាំនៅកម្ពុជា ព្រមទាំងធ្វើការពិនិត្យដំបូងសិនដើម្បីធានាថាមានព័ត៌មានគ្រប់គ្រាន់ មុននឹងពិនិត្យពីលក្ខខណ្ឌរបស់បណ្តឹងតវ៉ា និងតាមដានបន្ត។ ប្រសិនបើមិនមានការបញ្ចូលនូវព័ត៌មានសំខាន់ៗសម្រាប់ការដាក់បញ្ជូនបណ្តឹងតវ៉ាទេ នោះមន្ត្រីត្រួតពិនិត្យ នឹងទាក់ទងទៅដើមបណ្តឹងតវ៉ាដើម្បីស្នើសុំឱ្យបំពេញព័ត៌មានចាំបាច់។

ព័ត៌មានខាងក្រោមនេះ ត្រូវតែកត់ត្រានៅក្នុងបញ្ជីនៃបណ្តឹងតវ៉ា៖

១. កាលបរិច្ឆេទនៃបណ្តឹងតវ៉ា

២. លេខយោង (លេខរៀងនៃបណ្ដឹងតវ៉ា និងឆ្នាំដែលបានដាក់បញ្ជូនបណ្ដឹងតវ៉ា)

៣. លេខកូដគម្រោង ឬកម្មវិធីដែលបណ្ដឹងតវ៉ាសំដៅលើ

៤. ទីតាំងភូមិសាស្ត្រនៃសកម្មភាពកម្មវិធី ឬគម្រោងពាក់ព័ន្ធ

៥. ឈ្មោះដើមបណ្ដឹងតវ៉ា

៦. ភេទរបស់ដើមបណ្ដឹងតវ៉ា

៧. ការពិពណ៌នាពីបុគ្គល/ក្រុម ដែលរងផលប៉ះពាល់ដោយសារកម្មវិធីរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ

៨. ការពិពណ៌នាសង្ខេបពីបណ្ដឹងតវ៉ា

៩. បណ្ដឹងតវ៉ាគួរតែមានភាពជាក់លាក់តាមដែលអាចធ្វើទៅបាន ដោយពិពណ៌នាអំពីផលប៉ះពាល់ជាក់ស្ដែង ឬសក្ដានុពលនៃផលប៉ះពាល់ដែលមានទំនាក់ទំនងជាមួយកម្មវិធីរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ

១០. បណ្ដឹងតវ៉ាអនាមិកគឺមិនត្រូវបានលើកទឹកចិត្តដោយមន្ត្រីត្រួតពិនិត្យបណ្ដឹងតវ៉ានោះទេ ដោយគេនឹងចុះបញ្ជីទុក ប៉ុន្តែមិនធ្វើការពិនិត្យឡើយ។ ឈ្មោះដើមបណ្ដឹងតវ៉ានឹងត្រូវបានរក្សាទុកជាការសម្ងាត់តាមការស្នើសុំ។

១១. ដើមបណ្ដឹងតវ៉ាអាចកែប្រែ ឬបំពេញបណ្ដឹងតវ៉ាដែលបានដាក់ជូនដោយផ្ដល់នូវព័ត៌មានបន្ថែម ឬកង្វល់ថ្មី នៅពេលវេលាណាមួយ មុនពេលការពិនិត្យពីលក្ខខណ្ឌរបស់បណ្ដឹងតវ៉ាត្រូវបានកំណត់ និងទំនាក់ទំនង។

១២. មន្ត្រីត្រួតពិនិត្យបណ្ដឹងតវ៉ានឹងទទួលស្គាល់ពីការទទួលបាននូវបណ្ដឹងតវ៉ាទៅកាន់ដើមបណ្ដឹងតវ៉ាក្នុងរយៈពេលមួយសប្ដាហ៍ ដោយផ្អែកលើការបែងចែកចំណាត់ថ្នាក់ទៅលើបណ្ដឹងតវ៉ា/ពាក្យបណ្ដឹងតវ៉ាទៅជាកម្រិតទាប មធ្យម និងខ្ពស់ ដើម្បីធានាថាមានអាទិភាពនៅក្នុងការដោះស្រាយបណ្ដឹងតវ៉ាទៅតាមប្រភេទជាក់លាក់ណាមួយ។

| | |
|---|---|
| ប្រភេទ ក<br>ទាប | ទាប<br>– ការសាកសួរ<br>– សំណើសុំជំនួយ<br>– ការទំនាក់ទំនងតាមទូរស័ព្ទមិនជោគជ័យ |
| ប្រភេទ ខ<br>មធ្យម | មធ្យម<br>– ប្រតិបត្តិការ (ការផ្តល់ជាតុចូល និងសេវាកម្មយឺត។ល។<br>– មិនស្ថិតនៅក្នុងបញ្ជីអ្នកទទួលផល<br>– ការចែកចាយបរិមាណតិចជាងការរំពឹងទុក<br>– លក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសគឺមិនច្បាស់លាស់ ឬមិនត្រូវបានអនុត្ត<br>– គុណភាពនៃទំនិញ និងសេវាកម្មដែលបានផ្តល់ |

– ការមិនពេញចិត្តចំពោះសកម្មភាពរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ

**ការពិនិត្យពីលក្ខខណ្ឌនៃបណ្តឹងតវ៉ា**

១៤. មន្ត្រីត្រួតពិនិត្យបណ្តឹងតវ៉ា ជូនដំណឹង ពិភាក្សា និងពិនិត្យជាមួយការិយាល័យអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិប្រចាំនៅកម្ពុជា នូវបណ្តឹងតវ៉ា និងឯកសារដែលមានដើម្បីកំណត់នូវលក្ខខណ្ឌ ដែលត្រូវទទួលបានការពិនិត្យ និងកំណត់នូវបណ្តាញសមស្របសម្រាប់ការពិនិត្យដោយអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ។ ក្នុងករណីដែលពាក្យបណ្តឹងតវ៉ាគឺកំពុងតែលើកឡើងពីបញ្ហាទាក់ទងនឹងតំណាងអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ នោះមន្ត្រីត្រួតពិនិត្យបណ្តឹង នឹងពិគ្រោះយោបល់ជាមួយប្រធានផ្នែកប្រតិបត្តិការ។ លក្ខខណ្ឌសម្រាប់ការពិនិត្យ ត្រូវបានវាយតម្លៃដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖

**ក. ការមិនតវ៉ា៖** រាល់សំណើសុំព័ត៌មាន និងសំណួរទាក់ទងនឹងគម្រោងផ្សេងទៀតដោយអ្នកទទួលផល ដៃគូ និងអ្នកផ្គត់ផ្គង់ មន្ត្រីត្រួតពិនិត្យបណ្តឹង នឹងបញ្ជូនសំណើទាំងអស់នេះទៅកាន់បុគ្គលិកអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ ដោយផ្ទាល់ សម្រាប់ការតាមដាន។

**ខ. បណ្តឹងដែលមិនគ្រប់លក្ខខណ្ឌ៖** គឺជាបណ្តឹងដែលមិនបំពេញតាមលក្ខណៈវិនិច្ឆ័យ នៃលក្ខខណ្ឌដែលត្រូវទទួលបានការពិនិត្យឡើងវិញ (សូមមើលកថាខណ្ឌ ១៧.៨) រួមទាំងបណ្តឹងដែលទាក់ទងនឹងគម្រោង ឬកម្មវិធីដែលមិនត្រូវបានគាំទ្រដោយអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ ឬក៏បានបញ្ចប់ការគាំទ្រហើយ ហើយរាល់សកម្មភាពរបស់អង្គការ នឹងមិនអាចចាត់ទុកថាជាដើមហេតុដែលបណ្តាលឱ្យមានការព្រួយបារម្ភដូចដែលបានលើកឡើងនោះទេ។ មន្ត្រីត្រួតពិនិត្យបណ្តឹងតវ៉ា ធានាថាការបង្ហាញពីភស្តុតាងត្រឹមត្រូវដែលបញ្ជាក់ថាបណ្តឹងនេះមិនមាន គ្រប់លក្ខខណ្ឌនឹងត្រូវបានទាក់ទងទៅដើមបណ្តឹងតវ៉ា។

**គ. បញ្ហាដែលត្រូវបញ្ជូនទៅការិយាល័យអធិការកិច្ច (OIG)៖** មានតែបណ្តឹងទាក់ទងនឹងគោលនយោបាយបទដ្ឋានបរិស្ថាន និងសង្គម ប៉ុណ្ណោះដែលនឹងត្រូវបានដោះស្រាយជាចម្បងដោយការិយាល័យអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ នៅក្នុងប្រទេសកម្ពុជា។ ការចោទប្រកាន់ពីការកេងបន្លំផ្នែកហិរញ្ញវត្ថុ ការរំលោភបំពានសិទ្ធិអំណាច អំពើពុករលួយ និងសកម្មភាពផ្សេងទៀតដែលបានប្រព្រឹត្តខុសដោយបុគ្គលិករបស់អង្គការស្បៀង និង

កសិកម្មនៃសហប្រជាជាតិ ឬដោយភាគីទីបីដែលជាប់ពាក់ព័ន្ធ នឹងត្រូវបានបញ្ជូនបន្តទៅការិយាល័យអធិការកិច្ចដើម្បីពិនិត្យដោយផ្ទាល់ ។

ឃ. ចងចាំទុកពីបរិបទក្នុងស្រុក។ មានការផ្តល់អនុសាសន៍ឱ្យរាយការណ៍ពីកង្វល់នានាទាក់ទងនឹងការកេងប្រវ័ញ្ចផ្លូវភេទ ឬការរំលោភបំពានដែលអាចកើតមាន ដោយទំនាក់ទំនងទៅការិយាល័យអធិការកិច្ចដោយផ្ទាល់តាមរយៈ៖

ង. អ៊ីម៉ែល៖ investigations-hotline@fao.org

ខ្សែទូរស័ព្ទបន្ទាន់ និងសម្ងាត់៖ (+ 39) 06 570 52333

ច. បណ្តឹងតវ៉ាដែលគ្រប់លក្ខខណ្ឌ12៖

ឆ. ការចោទប្រកាន់ ឬសក្តានុពលទំនាស់នៃគោលការណ៍របស់អង្គការ FAO ស្តីពីការគ្រប់គ្រងបរិស្ថាន និងសង្គម និងបទដ្ឋាននានាស្ថិតនៅក្រោមកម្មវិធីរបស់អង្គការ FAO ប្រចាំនៅកម្ពុជា។ នេះសំដៅជាពិសេសទៅលើសុវត្ថិភាពបរិស្ថាននិងសង្គម (ESS) ទាំង៩របស់ស្ថាប័នដូចមានបញ្ជាក់ក្នុងគោលការណ៍គ្រប់គ្រងបរិស្ថាន និងសង្គម ។ គោលការណ៍នេះរៀបចំឡើងដើម្បីធានាថា បំផ្លិតបំផ្លាញដល់បរិស្ថាន និងជីវសាស្ត្រ ទាំងដោយផ្ទាល់និងប្រយោលក្នុងរាល់គម្រោងរបស់អង្គការ FAO ដោយធ្វើយ៉ាងណាគម្រោងនឹងបង្កផលប៉ះពាល់អវិជ្ជមានដល់សុខមាលភាពរបស់មនុស្ស ជីវភាពរស់នៅ ទ្រព្យសម្បត្តិ និងជំនាញ។ គោលការណ៍ក៏ធានាថា គម្រោងមិនបង្កបញ្ហាធ្ងន់ធ្ងរក្នុងសង្គម ដោយ ដាក់អ្នកទទួលផលពីគម្រោង ឬភាគីពាក់ព័ន្ធក្នុងស្ថានភាពគ្រោះថ្នាក់ ហើយរាល់ភាគីពាក់ព័ន្ធត្រូវដោះស្រាយស្មើភាពគ្នា។

ក. ESS១៖ ការគ្រប់គ្រប់គ្រងធនធាន (រួមទាំងការគ្រប់គ្រងដី និងធនធានដី ការគ្រប់គ្រងធនធានទឹក និងដំនប់ទឹកតូចៗ កម្មសិទ្ធិដីធ្លី និងអាកាសធាតុ

ខ. ESS២៖ ជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងទីជម្រកសំខាន់ៗ (រួមទាំងតំបន់ការពារធម្មជាតិ តំបន់ទ្រនាប់ ជម្រកធម្មជាតិ ការអភិរក្សជីវៈចម្រុះ ប្រើប្រាស់ប្រភេទនាំចូល ឬប្រភេទក្រៅស្រុក ទទួលបាននិងចែករំលែកធនធានពន្ធុ និងធនធានធម្មជាតិមានជីវិត)

គ. ESS៣៖ ធនធានពន្ធុរុក្ខជាតិសម្រាប់ចំណីអាហារ និងកសិកម្ម (រួមទាំងការណែនាំពីប្រភេទដំណាំ និងពូជដំណាំ ការផ្តល់គ្រាប់ពូជនិងកូនដំណាំ ជីវៈតិចណូឡូជីទំនើប និងប្រើប្រាស់ផលិតផលក្នុងផលិតកម្មដំណាំ និងដាំដុះព្រៃឈើ)

ឃ. ESS៤៖ សត្វ សត្វចិញ្ចឹម វារីជាតិ ធនធានពន្ធុសម្រាប់អាហារ និងកសិកម្ម (រួមទាំងពីការបង្កាត់ប្រភេទផលិតផលបរិស្ថានថ្មីផ្លាស់ប្តូរប្រព័ន្ធផលិតកម្មតាមរយៈការទទួលការបង្កាត់ក្នុងតំបន់ណែនាំ ប្រភេទថ្មីប្រមូលធនធានពន្ធុសម្រាប់ប្រព័ន្ធកសិកម្ម និងការផ្លាស់ប្តូរទីជម្រក)

ង. ESS៥៖ សត្វល្អិត និងការគ្រប់គ្រងសត្វល្អិត (រួមទាំងការគ្រប់គ្រងសត្វល្អិត ការជ្រើសរើសថ្នាំសម្លាប់សត្វល្អិត ការផ្គត់ផ្គង់ប្រភេទថ្នាំសម្លាប់សត្វល្អិតដោយអង្គការ FAO សំណល់ និងការទទួលខុសត្រូវ)

ច. ESS៦៖ ការតាំងលំនៅដ្ឋាន និងការជំលាស់ចេញ (រួមទាំងការហាមឃាត់ចំពោះការបណ្តេញចេញដោយបង្ខំ បង្ការ និងកាត់បន្ថយការការបណ្តេញចេញទាំងលក្ខណៈរូប និងសេដ្ឋកិច្ច និងផែនការអភិវឌ្ឍសម្រាប់លក្ខណៈរូប និងសេដ្ឋកិច្ច)

ឆ. ESS៧៖ ការងារសមរម្យ (រួមទាំងការបង្កើតឱ្យបានច្រើន និងប្រសើជាងមុននូវឱកាសការងារពិសេសសម្រាប់យុវជន និងស្ត្រី ដោយមិនរើសអើង និងផ្តល់ឱកាសការងារស្មើៗគ្នា សុវត្ថិភាពការងារនិងសុខភាព ទប់ស្កាត់ និងកាត់បន្ថយពលកម្មកុមារ ការបង្ខំកំលាំងពលកម្ម និងការងារ ព្រមទាំងស្ថានប័នអ្នកផ្គត់ផ្គង់)

ជ. ESS៨៖ សមភាពយេនឌ័រ (លុបបំបាត់ភាពរើសអើង ផ្តល់ឱកាសស្មើគ្នារវាងស្ត្រី និងបុរសក្នុងការចូលរួម)

ឈ. ESS៩៖ ជនជាតដើមភាគតិច និងកេតំណែលវប្បធម៌ (កំណត់ជនជាតិដើមភាគតិច សិទ្ធិលើដីធ្លី ទឹកដី និងធនធានធម្មជាតិ មុនធ្វើការវាយតម្លៃផលប៉ះពាល់លើជនជាតដើមភាគតិច ការយល់ព្រមដោយសេរី ផ្អែកលើព័ត៌មានគ្រប់គ្រង (FPIC) ផែនការសម្រាប់ជនជាតិដើមភាគតិច និងបេតិកភណ្ឌវប្បធម៌)។

៣. ការព្រួយបារម្ភពាក់ព័ន្ធកម្មវិធីរបស់អង្គការនៅតាមដំណាក់កាលនីមួយៗនៃវដ្តគម្រោង ដូចមានកំណត់ ក្នុងការប្តេជ្ញាចិត្តចំពោះគណនេយ្យភាពចំពោះផលប៉ះពាល់ដល់មនុស្ស (AAP) ៣ រួមទាំង (ក្នុងចំណោមបញ្ហា) ថាតើត្រឹមត្រូវតាមគោលបំណងរបស់គម្រោង និងគោលដៅរបស់អ្នកទទួលផល គម្រោងឬអត់ថាតើកម្មវិធីត្រូវបានអនុវត្តត្រឹមត្រូវកម្រិតណា ថាតើមានបានដឹងជាមុនពីសកត្តានុពល នៃផលប៉ះពាល់អវិជ្ជមានមកលើអ្នកចូលរួម ឬយ៉ាងណា។

ដ. ប្រសិនបើមានទោះស្ថិតនៅក្នុងដំណាក់កាលណាក៏ដោយក្នុងការពិនិត្យលើបណ្តឹង នោះបណ្តឹងដែល ទទួលបានលេញចេញនូវការសង្ស័យ ឬចង្អុលបង្ហាញពីក្លែងបន្លំ ការពុករលួយ ការបង្ខិតបង្ខំ ឬការជៀត្នេស ឬផ្សេងៗទៀត

បុគ្គលិកអង្គការ FAO ដែលមិនមានក្រមសីលធម៌ ឬភាគីទី៣ដែលចូលរួមជាមួយអង្គការ បើមានករណីត្រូវវាយការណ៍ជាបន្ទាន់ទៅ ការិយាល័យអធិការកិច្ច (OIG)។

រាល់បណ្តឹងតវ៉ាត្រូវបញ្ជាក់ឱ្យច្បាប់ពីជំហាននីមួយដែលដើមបណ្តឹងបានអនុវត្ត ក្នុងការព្យាយាមដោះបណ្តឹងរបស់ពួកគេជាមួយថ្នាក់គប់គ្រងកម្មវិធី និងលទ្ធផលនៃចេត្តនាទាំងនោះ។ ការប្តឹងផ្តល់ដែលជនទាំងឡាយណា ដែលមិនមានចេតនាល្អក្នុងការដោះស្រាយបញ្ហារបស់ពួកគេជាមួយថ្នាក់គ្រប់គ្រងគម្រោង ឬមិនមានហេតុសមស្របចំពោះថ្នាក់គ្រប់គ្រងគម្រោង (ពោលគឺ ភ័យខ្លាចចំពោះសុវត្ថភាព) នឹងមិនត្រូវបានទទួលយកនោះទេ។

## ដំណើការនៃការទទួលយកបណ្តឹង

១៥. នៅពេលបណ្តឹងមួយត្រូវបានរកឃើញថាអាចទទួលយកបានក្នុងអំឡុងពេលត្រួតពិនិត្យ មន្ត្រីត្រួតពិនិត្យបណ្តឹងតវ៉ា (GRO) ដោយពិគ្រោះយោបល់ជាមួយតំណាងអង្គការ FAO ត្រូវស្នើឡើងនូវដំណើការពិនិត្យលើបណ្តឹងឱ្យត្រឹមត្រូវ ផ្អែកលើករណីជាក់ស្តែង។

## ការឆ្លើយតប

១៦. លទ្ធផលនៃការត្រួតពិនិត្យបណ្តឹង និងសកម្មភាពតាមដាន នឹងត្រូវវាយការណ៍ឱ្យដើមបណ្តឹង ដោយមន្ត្រីត្រួតពិនិត្យបណ្តឹងតវ៉ា (GRO)

១៧. ករណីដើមបណ្តឹងមិនពេញចិត្តទៅនឹងការឆ្លើយតប គាត់អាចប្តឹងស្នើសុំពិនិត្យលើអនុលោមភាពទៅការិយាល័យអធិការកិច្ច (OIG) ស្របតាមគោលការណ៍ណែនាំស្តីពីការពិនិត្យលើបណ្តឹង១៥។

## ការសនិដ្ឋានលើការពិនិត្យបណ្តឹងតវ៉ា

១៨. ដោយផ្អែកលើការសនិដ្ឋាននៃការពិនិត្យករណីបណ្តឹង មន្ត្រីត្រួតពិនិត្យបណ្តឹងតវ៉ា (GRO)នឹងធានាថារាល់ព័ត៌តទៅនឹងត្រូវកត់ត្រាក្នុងបញ្ជីបណ្តឹង (បន្ថែមលើការកត់ត្រាទាំងនោះ ដូចមានបញ្ជាក់ក្នុងកថាខណ្ឌ៩ខាងលើ)

ក) លទ្ធផលនៃការពិនិត្យលើលក្ខណៈដែលទទួលយកបាននៃបណ្តឹង

ខ) សមាសភាពក្នុងយន្តការដោះស្រាយបណ្តឹងតវ៉ា (GRM)

គ) ឈ្មោះ មន្ត្រីផ្ទៀងផ្ទាត់បណ្តឹងតវ៉ា (GVO)

ឃ) ផ្ទៀងផ្ទាត់វិធីសាស្ត្របន្តបន្ទាប់

ង) ការពិនិត្យលើបណ្តឹងចុងក្រោយ

ច) សេចក្តីសង្ខេបពីសកម្មភាពតាមដាន ឬសកម្មភាពត្រូវអនុវត្ត

ជ) រក្សាទុកជាឯកសារស្តីពីការទំនាក់ទំនងទៅភាគីដើមបណ្តឹងត្រង់ចំណុចនៃការសនិដ្ឋានលើដំណើរត្រួតពិនិត្យបណ្តឹង និងសកម្មតាមដាន

ឈ) ការសាទរនឹងលទ្ធផលដោះស្រាយ មិនពេញចិត្ត ឬប្រតិកម្មផ្សេងទៀតពីដើមបណ្តឹង

ញ) ឯកសារផ្សេងៗពាក់ព័ន្ធ។

## VI. ការរាយការណ៍ និងបទពិសោធន៍ទទួលបាន

១៩. ព័ត៌មានស្តីពីលទ្ធផលនៃការពិនិត្យបណ្តឹងនីមួយៗ (ទាំងការពិនិត្យដំណាក់កាលបើក ឬដំណាក់កាលបិទការត្រួតពនិត្យបណ្តឹង) នឹងត្រូវបង្ហាញទៅតំណាងអង្គការ FAO និង បុគ្គលឹកជាន់ខ្ពស់របស់អង្គការ FAOដោយផ្តោតមេរៀនសម្រាប់សកម្មភាពអនាគត

២០. បណ្តឹងដែលពាក់ព័ន្ធនឹង ក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម(ESMF) ការបន្ថែបន្លំ និងក្រមសីលធម៌នឹងត្រូវរាយការឱ្យបានត្រឹមត្រូវទៅអង្គភាពពាក់ព័ន្ធនៅការិយាល័យថ្នាក់តំបន់ និងថ្នាក់កណ្តាលរបស់អង្គការFAOនៅរាល់កន្លះឆ្នាំម្តង។ វាអាចមានការចាំបាច់រាយការណ៍ពីប្រភេទបណ្តឹងផ្សេងៗទៀត ទៅផ្នែកផ្សេងទៀតប្រសិនមានការស្នើសុំ

២១. របាយការណ៍សង្ខេបនឹងត្រូវរាយការណ៍គណកម្មការតម្រង់ទិសរបស់គម្រោង (PSC) ឬផ្នែកសម្របសម្រួលគម្រោងពាក់ព័ន្ធផ្សេងទៀត ឬ ស្ថាប័នគ្រប់គ្រងដើម្បីជម្រាបជូនពួកគេពីចំនួនបណ្តឹង ដែលទទួលបាន និងលទ្ធផលនៃត្រួតពិនិត្យ និងផ្ទៀងផ្ទាត់បណ្តឹង

២២. នៅពេលអនាគត កំណត់ត្រាបណ្តឹងមាននៅក្នុងប្រព័ន្ធអនឡាញក្នុងគេហទំព័រអង្គការ FAO នៅប្រចាំនៅកម្ពុជា និងត្រូវបានចែករំលែកផងដែរនៅអង្គភាពទទួលបន្ទុកលើក្របខណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គមដើម្បីដាក់ផ្សាយក្នុងគេហទំព័ររបស់អង្គការ FAOនៅថ្នាក់កណ្តាល។

២៣. យន្តការដោះស្រាយបណ្តឹងតវ៉ានឹងត្រូវធ្វើបច្ចុប្បន្នភាព ក្នុងករណីចាំបាច់ផ្អែលតាមមេរៀនបទពិសោធ។

## ឧបសម្ព័ន្ធ១៖ យន្តការទទួលបណ្តឹង និងដំណើការបណ្តឹងតវ៉ា



## ឧបសម្ព័ន្ធ-២៖ ទម្រង់ដាក់ពាក្យបណ្ដឹងតវ៉ា

ការិយាល័យអង្គការ FAO នៅកម្ពុជា បានបង្កើតយន្តការពិនិត្យបណ្ដឹងតវ៉ា (GRM) ដើម្បីផ្ដល់នូវយន្តការតម្លាភាពជូនអ្នកទទួលផលពីគម្រោងរបស់អង្គការ FAO តាមរយៈការផ្ដល់នូវមតិកែលម្អ លើកឡើងពីកង្វល់ បង្កើតសកម្មភាពកែតម្រូវដែលមានលក្ខណៈសមស្រប និងទទួលមតិកែលម្អលើសកម្មភាពដែលបានធ្វើឡើង។

បុគ្គលណាមួយ ក្រុម ឬតំណាងរបស់បុគ្គល ឬក្រុមណាមួយ ដែលចូលរួមដោយផ្ទាល់ ឬរងផលប៉ះពាល់ដោយសកម្មភាពនៅក្នុងប្រទេសណាមួយរបស់អង្គការ FAO អាចដាក់ពាក្យបណ្ដឹងជាលាយលក្ខណ៍អក្សរដោយប្រើទម្រង់នេះ ហើយបញ្ជូនវាតាមរយៈអ៊ីម៉េល (FAO-KH@FAO.org) កម្មវិធី WhatsApp, តេឡេក្រាម (+855 78 792 555) គេហទំព័រ ឬដាក់មកដោយផ្ទាល់ទៅកាន់ការិយាល័យរបស់អង្គការ FAO ដែលមានអាស័យដ្ឋាននៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគារលេខ ២០០ មហាវិថីនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា និងមានប្រអប់សំបុត្រលេខ ៥៣។

### ព័ត៌មានទាក់ទងនឹងដើមបណ្ដឹងតវ៉ា

| | |
|---|---|
| ១. ឈ្មោះ | ……………………………………………………………… |
| ២. ថ្ងៃខែឆ្នាំកំណើត | ……… /……… /…………… |
| ៣. ទីកន្លែងកំណើត | ……………………………………………………………… |
| ៤. សញ្ជាតិ | ……………………………………………………………… |
| ៥. លេខអត្តសញ្ញាណបណ្ណ | ……………………………………………………………… |
| ៦. ភេទ | ☐ ប្រុស ☐ស្រី |
| ៧. មុខរបរ | ……………………………………………………………… |
| ៨. អាស័យដ្ឋានបច្ចុប្បន្ន | ……………………………………………………………… |
| ៩. លេខទូរស័ព្ទ | ……………………………………………………………… |
| ១១. ស្ថានភាពនៃដើមបណ្ដឹងតវ៉ា | ៖ អ្នកដែលរងផលប៉ះពាល់៖ ជំនួសមុខឱ្យអ្នករងផលប៉ះពាល់ តើអ្នកបានទទួលការអនុញ្ញាតពីបុគ្គលដែលអ្នកកំពុងដាក់ពាក្យបណ្ដឹងតវ៉ាជំនួសនេះដែរឬទេ? ☐ មាន ☐ទេ |

### ១. ព័ត៌មានទាក់ទងនឹងបុគ្គល/ក្រុមដែលរងផលប៉ះពាល់ ប្រសិនបើអ្នកផ្សេងជាដើមបណ្ដឹងតវ៉ា

| | |
|---|---|
| ១. ឈ្មោះ | ……………………………………………………………… |
| ២. ថ្ងៃខែឆ្នាំកំណើត | ……… /……… /…………… |
| ៣. ទីកន្លែងកំណើត | ……………………………………………………………… |
| ៤. សញ្ជាតិ | ……………………………………………………………… |
| ៥. លេខអត្តសញ្ញាណប័ណ្ណ | ……………………………………………………………… |

| | | |
|---|---|---|
| ៦. | ភេទ | ☐ ប្រុស ☐ស្រី |
| ៧. | មុខរបរ | ………………………………………………………………… |
| ៨. | អាស័យដ្ឋានបច្ចុប្បន្ន | ………………………………………………………………… |
| ៩. | លេខទូរស័ព្ទ | ………………………………………………………………… |

16 បណ្តឹងជាលក្ខណៈអនាមិកគឺមិនត្រូវបានលើកទឹកចិត្តនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ឈ្មោះដើមបណ្តឹងតវ៉ានឹងត្រូវបានរក្សាទុកជាសម្ងាត់ទៅតាមការស្នើសុំ

ការពិពណ៌នាពីបណ្តឹង៖ សូមផ្តល់ព័ត៌មានលម្អិតទៅតាមលំដាប់លំដោយ ក៏ដូចជាហេតុការណ៍ កាលៈទេសៈពាក់ព័ន្ធនឹងបណ្តឹង ដោយរួមបញ្ចូលនូវការពិពណ៌នា ឈ្មោះ កាលបរិច្ឆេទ និងទីកន្លែង៖

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

**ការអនុញ្ញាតសម្រាប់ការបង្ហាញឈ្មោះ**

តើអ្នកយល់ព្រមក្នុងការបញ្ចេញឈ្មោះរបស់អ្នកទៅភាគីពាក់ព័ន្ធដែរឬទេ ក្នុងករណីដែលពាក្យបណ្តឹងតវ៉ារបស់អ្នកតម្រូវឱ្យមានការបង្ហាញបែបនេះ?

☐ បាទ/ចាស ☐ទេ

២. កាលបរិច្ឆេទ និងហត្ថលេខា

កាលបរិច្ឆេទ/ទីកន្លែង៖

……………………………………………………………………………………………..

ហត្ថលេខាដើមបណ្ដឹងតវ៉ា/តំណាងភាគីដើមបណ្ដឹងតវ៉ា

…………………………………………………………………………………………….

៣. បញ្ជីឯកសារដែលបានភ្ជាប់ (មិនមែនជាឯកសារច្បាប់ដើមទេ គឺជាឯកសារថតចម្លង ប្រសិនបើពាក់ព័ន្ធ)

១.…………………………………………………………………………..

២. …………………………………………………………………………..

៣. …………………………………………………………………………..

៤. ………………………………………………………………………….